ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំសម្រាប់ផលិតកម្មកសិកម្ម តាមកិច្ចសន្យានៅកម្ពុជា

នាយកដ្ឋានកសិ-ឧស្សាហកម្ម

សហការជាមួយ

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

និងទទួលបានហិរញ្ញប្បទានពី

ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ

AFD

( ខែកុម្ភៈ ឆ្នាំ២០១៨ )

# សៀវភៅណែនាំ
# សម្រាប់ផលិតកម្មកសិកម្ម
# តាមកិច្ចសន្យានៅកម្ពុជា

( ខែកុម្ភៈ ឆ្នាំ២០១៨ )

# មាតិកា

**មាតិកា** ..... ii

បញ្ជីតារាង រូបភាព និងការពន្យល់បន្ថែម ..... ix

អក្សរកាត់ ..... xi

**សារម្នាក់ថា និង ការថ្លែងអំណរគុណ** ..... 1

សេចក្តីផ្តើម៖ គោលបំណង វិសាលភាព និងការប្រើប្រាស់សៀវភៅណែនាំនេះ ..... 2

តើសៀវភៅណែនាំនេះធ្វើឡើងសម្រាប់នរណា? ..... 2

គោលការណ៍ណែនាំ និងព័ត៌មានសម្រាប់ជួយធ្វើការសម្រេចចិត្ត ..... 2

តើអ្នកអាននឹងទទួលបានអ្វីខ្លះពីសៀវភៅនេះ? ..... 3

ផ្នែកទី ១៖ ទិដ្ឋភាពទូទៅនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា ..... 5

១.១. និយមន័យ និងម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យា ..... 5

១.១.១. និយមន័យនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា ..... 5

១.១.២. ម៉ូឌែលផ្សេងៗនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា ..... 8

១.២. ឱកាស និងហានិភ័យនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ការអភិវឌ្ឍ និងជីវភាពគ្រួសារកសិករខ្នាតតូច ..... 12

១.២.១. អត្ថប្រយោជន៍នៃផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់កសិករខ្នាតតូច ..... 12

១.២.២. ហានិភ័យដែលត្រូវពិចារណាសម្រាប់កសិករខ្នាតតូច ..... 13

១.២.៣. លក្ខខណ្ឌទូទៅមួយចំនួនដែលត្រូវពិចារណាសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីផ្តល់ផលប្រយោជន៍ជូនគ្រួសារកសិករ ..... 14

១.៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ម៉ូឌែលអាជីវកម្មមួយណា? ..... 14

ផ្នែកទី ២៖ បរិបទនៃផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា ..... 17

២.១. ប្រវត្តិនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា ..... 17

២.១.១. លក្ខណៈពិសេសនៃការអភិវឌ្ឍបច្ចុប្បន្ននៅក្នុងវិស័យកសិកម្មកម្ពុជា ..... 17

២.១.២. បទពិសោធន៍បច្ចុប្បន្ននៃផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា ..... 19

## មាតិកា


២.២. សាវតារផ្នែកច្បាប់សម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា ...................................... 26

២.២.១. ច្បាប់ស្នូល ...................................................................................................... 26

២.២.២. ច្បាប់ពិសេសដែលពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា ........................................ 29

២.៣. គោលនយោបាយ និងវិធានការគាំទ្រសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា .......... 34

២.៣.១. ផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងយុទ្ធសាស្រ្ត និងគោលនយោបាយ រាជ រដ្ឋាភិបាល ........ 34

២.៣.២.វិធានការគាំទ្រសាធារណៈចំពោះការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា........................ 35

២.៣.៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្លងប្រទេស៖ អាចមានការគាំទ្រពីរដ្ឋាភិបាលកម្ពុជាលើកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់ផលិតកម្មកសិកម្មតាមកិច្ចសន្យាស្ថិតក្រោម ACMECS .............. 37

**ផ្នែកទី ៣៖ នីតិវិធីសម្រាប់ការសម្របសម្រួលដល់ការចរចាផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការចុះបញ្ជីកិច្ចសន្យា** ...................................................................................................38

៣.១. តើនរណាអាចផ្តល់ការគាំទ្រសម្រាប់ការបង្កើតកិច្ចសន្យាផលិតកម្មកសិកម្ម............................ 38

៣.១.១. សេវាគាំទ្ររបស់ក្រសួងកសិកម្មដែលបានស្នើដល់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចដែលមានបំណងបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា.................................................................. 38

៣.១.២. ស្ថាប័នផ្សេងទៀតដែលអាចផ្តល់ការគាំទ្រ និងយោបល់................................................ 40

៣.២. ការជ្រើសរើសដៃគូ (ភាគីអ្នកទិញ/ភាគីអ្នកផលិត) ........................................................ 41

៣.២.១. ការប៉ាន់ប្រមាណលើការជឿទុកចិត្តលើក្រុមហ៊ុន (ភាគីអ្នកទិញ)......................................... 41

៣.២.២. ការកំណត់អត្តសញ្ញាណតំបន់និងអ្នកផលិតដែលមានសក្តានុពល........................................ 43

៣.៣. ការចុះបញ្ជីកិច្ចសន្យា៖ គុណសម្បត្តិ គុណវិបត្តិ និងដំណើរការនៃការចុះបញ្ជីកិច្ចសន្យា ............ 45

៣.៣.១. ហេតុអ្វីគួរចុះបញ្ជីកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/នាយកដ្ឋានកសិ-ឧស្សាហកម្ម? ............................................................................................... 45

៣.៣.២. នីតិវិធីដើម្បីចុះបញ្ជីកិច្ចសន្យាផលិតកម្មកសិកម្ម........................................................ 47

**ផ្នែកទី ៤ ៖ ខ្លឹមសារកិច្ចសន្យា និងយោបល់សម្រាប់ការចរចា និងការសរសេរកិច្ចសន្យា៖** ..................... 48

៤.១. ទម្រង់នៃកិច្ចសន្យា (គំរូ) .................................................................................... 48

## មាតិកា


៤.១.១. ទិដ្ឋភាពទូទៅនៃរចនាសម្ព័ន្ធកិច្ចសន្យាដែលបានផ្តល់ជាយោបល់ ............ 49

៤.១.២. មតិយោបល់លើខ្លឹមសារនៃផ្នែកនីមួយៗដែលបានរំពឹងទុក ............ 49

៤.២. ការគាំទ្ររបស់ភាគីអ្នកទិញ៖ ធាតុចូល /បុរេហិរញ្ញប្បទាន /យោបល់បច្ចេកទេស ....... 56

៤.២.១. ធាតុចូលឬការផ្គត់ផ្គង់សម្ភារ ............ 56

៤.២.២. ការផ្តល់សេវាកម្ម ............ 57

៤.២.៣. បុរេហិរញ្ញប្បទាន ឬសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត ............ 57

៤.២.៤. ការបណ្តុះបណ្តាល ឬការគាំទ្រផ្នែកបច្ចេកទេស ............ 57

៤.៣. ប្រភេទផលិតផល និងបរិមាណដែលត្រូវផ្គត់ផ្គង់ ............ 58

៤.៣.១. ប្រភេទផលិតផល ............ 58

៤.៣.២. ការបញ្ជាក់បរិមាណ ............ 58

៤.៣.៣. ឯកតា និងវិធីសាស្រ្តវាស់វែង ............ 62

៤.៤. គុណភាព៖ លក្ខណៈបច្ចេកទេសនៃផលិតផល និងវិធីសាស្រ្តផ្ទៀងផ្ទាត់ ............ 63

៤.៤.១. លក្ខណៈបច្ចេកទេសនៃផលិតផល ............ 63

៤.៤.២. វិធីសាស្រ្តផ្ទៀងផ្ទាត់ ............ 65

៤.៥. កាតព្វកិច្ចពាក់ព័ន្ធនឹងវិធីសាស្រ្ត និងការផ្ទៀងផ្ទាត់ផលិតកម្ម ............ 66

៤.៦. កាតព្វកិច្ចផ្សេងទៀតរបស់ភាគីអ្នកផលិត (ឧ. ព័ត៌មានពាក់ព័ន្ធដែលត្រូវផ្តល់ស្តីពីផលិតផលគំរូនៃផលិតកម្ម មុខងារសេវាកម្ម ។ល។) ............ 67

៤.៦.១. កាតព្វកិច្ចព័ត៌មាន ............ 67

៤.៦.២. កាតព្វកិច្ចចូលរួមប្រជុំ និងការបណ្តុះបណ្តាល ............ 67

៤.៦.៣. សេវាកម្មពាក់ព័ន្ធដែលត្រូវអនុវត្តដោយភាគីអ្នកផលិត ............ 68

៤.៧. តម្លៃ និងការយោងតម្លៃ............ 68

៤.៧.១. តម្លៃថេរ ............ 69

៤.៧.២. តម្លៃតាមទីផ្សារ ............ 71

## មាតិកា


៤.៧.៣. តម្លៃតាមទីផ្សារ + ថ្លៃបុព្វលាភ ..... 72

៤.៧.៤. តម្លៃអប្បបរមាដែលបានធានា ឬតម្លៃទីផ្សារ ប្រសិនបើលើសនេះ ..... 74

៤.៧.៥. តម្លៃអប្បបរមាដែលបានធានា ឬតម្លៃទីផ្សារ ប្រសិនបើលើសនេះ + បុព្វលាភ ..... 75

៤.៧.៦. ឯកសារយោង និងរូបមន្តដែលត្រូវប្រើ ពេលមានតម្លៃផ្សេងគ្នា (/តម្លៃទីផ្សារ) ..... 77

៤.៧.៧. ការប្រែប្រួលនៃតម្លៃទៅតាមគុណភាព ..... 86

៤.៨. ការគ្រប់គ្រងកិច្ចប្រតិបត្តិការ៖ ការដឹកជញ្ជូន ការប្រគល់ ការទទួល ។ល។ ..... 86

៤.៨.១. ចំនួនគំរូស្តង់ដារនៃការប្រគល់ និង/ឬបរិមាណនៃការប្រគល់ ..... 88

៤.៨.២. ចំណុចប្រគល់ទំនិញ ..... 88

៤.៨.៣. ការរៀបចំការដឹកជញ្ជូន ..... 89

៤.៨.៤. ការត្រួតពិនិត្យគុណភាព ..... 89

៤.៨.៥. ការសម្របសម្រួល និងបែបបទទំនាក់ទំនង ..... 90

៤.៩. របៀបនិងពេលទូទាត់ប្រាក់ ..... 90

៤.៩.១. ចំនួនដំណាក់កាល និងពេលទូទាត់ប្រាក់ ..... 90

៤.៩.២. មធ្យោបាយទូទាត់ប្រាក់ ..... 91

៤.៩.៣. ការចេញវិក័យបត្រ និងទម្រង់ភស្តុតាងការទូទាត់ប្រាក់ ..... 93

៤.៩.៤. ជម្រើសផ្សេងទៀតដែលអាចពិចារណា ..... 94

៤.១០. ករណីពិសេសដែលមិនអាចអនុវត្តកាតព្វកិច្ច៖ ហានិភ័យធម្មជាតិ/ប្រធានស័ក្តិ ..... 95

៤.១០.១. ព្រឹត្តិការណ៍ដែលហួសពីសមត្ថភាពគ្រប់គ្រង ..... 95

៤.១០.២. ការផ្លាស់ប្តូរស្ថានភាពដែលលែងអាចអនុវត្តកាតព្វកិច្ចបាន ..... 98

៤.១០.៣. ការបង្ការស្ថានភាពអាក្រក់តាមរយៈការបែងចែកហានិភ័យ ..... 99

៤.១១. រយៈពេល ការបន្ត និងការបញ្ចប់កិច្ចសន្យា ..... 101

៤.១១.១. រយៈពេលនៃកិច្ចសន្យា ..... 101

៤.១១.២ ការបន្តកិច្ចសន្យា ..... 102

## មាតិកា


៤.១១.៣ ការបញ្ចប់កិច្ចសន្យា ..... 103

៤.១២.ដំណោះស្រាយសម្រាប់ការរំលោភកិច្ចសន្យា ..... 104

៤.១២.១. ដំណោះស្រាយតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជា ..... 105

៤.១២.២. ប្រភេទសំខាន់ៗនៃដំណោះស្រាយ ..... 106

៤.១៣. ការដោះស្រាយវិវាទ ..... 110

៤.១៤. លក្ខខណ្ឌផ្នែកច្បាប់ផ្សេងទៀត (ចំនួនសេចក្ដីចម្លង ភាសា) ..... 111

៤.១៤.១ ច្បាប់ជាធរមាន ..... 111

៤.១៤.២. ចំនួនសេចក្ដីចម្លង ..... 111

៤.១៤.៣. ភាសាក្នុងកិច្ចសន្យា ..... 112

៤.១៤.៤. ការចុះហត្ថលេខាលើកិច្ចសន្យា ..... 112

**ផ្នែកទី ៥ ៖ ក្នុងពេល និងក្រោយពេលអនុវត្តកិច្ចសន្យា៖ ការត្រួតពិនិត្យ និងការវាយតម្លៃ** ..... 114

៥.១. ក្នុងអំឡុងពេលនៃការផលិត៖ តាមដាន និងប្រាស្រ័យទាក់ទង ដើម្បី ប្រមើលមើលអំពីភាពលំបាកនានា ដែលអាចនឹងកើតមានឡើង ..... 114

៥.១.១. តាមដាន និងកត់ត្រាអំពីការអនុវត្តនៃការប្ដេជ្ញាចិត្តរបស់ភាគីអ្នកទិញ ..... 115

៥.១.២. ការត្រួតពិនិត្យ និងកត់ត្រាអំពីការអនុវត្តតាមការប្ដេជ្ញាចិត្តរបស់អ្នកផលិតក្នុងពេលផលិត . 117

៥.១.៣. ការប្រាស្រ័យទាក់ទង ការរាយការណ៍ក្នុងករណីមានបញ្ហា ឬស្ថានភាពមិនរំពឹងទុក ..... 119

៥.១.៤. ការកែតម្រូវផ្សេងទៀតដើម្បីដោះស្រាយស្ថានការណ៍ដែលមើលមិនឃើញ ..... 122

៥.២ ពេលប្រមូលផល/ពេលប្រគល់ទំនិញ៖ ការធានាភាពរលូន ..... 123

៥.២.១. ការកំណត់ពេលប្រមូលផល និងការប្រគល់ទំនិញ ..... 123

៥.២.២. ភស្តុភារសម្រាប់ការប្រមូលផល និងការប្រគល់ទំនិញ ..... 124

៥.២.៣ ការវាយតម្លៃគុណភាពនៅពេលប្រគល់ទំនិញ ..... 127

៥.២.៤. កំណត់ហេតុផ្ទេរប្រគល់ទំនិញ ..... 128

# មាតិកា


៥.២.៥. តម្លៃ និងការទូទាត់ប្រាក់ ........................................ 128

៥.៣. ក្រោយការអនុវត្តៈ ការប៉ាន់ប្រមាណលទ្ធផល កំណត់រកបញ្ហាដើម្បីកែលម្អកិច្ចសន្យាថ្មី .......... 131

៥.៣.១. ប៉ាន់ប្រមាណលើការគោរពលក្ខខណ្ឌនៃកិច្ចសន្យា ........................................ 131

៥.៣.២. កំណត់រកចំណុចដែលមិនបានដាក់បញ្ចូលក្នុងកិច្ចសន្យាចាស់ ដែលត្រូវដាក់បញ្ចូលថ្មី ........ 134

៥.៣.៣. ប៉ាន់ប្រមាណកម្រិតនៃការពេញចិត្ត ........................................ 134

៥.៣.៤. ការដកពិសោធន៍ដើម្បីកែលម្អដំណាក់កាលក្រោយ (ឬបញ្ចប់ភាពជាដៃគូ!) ........................ 136

**ផ្នែកទី ៦៖ ការដោះស្រាយជម្លោះក្នុងពេលអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា** ..............................137

៦.១.ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ជម្រើសផ្សេងៗសម្រាប់ការដោះស្រាយវិវាទ ............. 137

៦.១.១.ការដោះស្រាយវិវាទអនុឡោមតាមអនុក្រឹត្យលេខ៣៦ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ........................................ 137

៦.១.២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមជម្រើសផ្សេងទៀត ........................................ 138

៦.១.៣.ជម្រើសផ្សេងទៀតដើម្បីគ្រប់គ្រងការដោះស្រាយវិវាទ ........................................ 143

៦.២. ការដោះស្រាយវិវាទតាមផ្លូវតុលាការ៖ ប្រព័ន្ធតុលាការ ........................................ 148

៦.៣. តារាងសង្ខេប ........................................ 150

**ផ្នែកទី ៧៖ ការផ្គត់ផ្គង់អង្គការកសិករ/សហករដែលពាក់ព័ន្ធក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យា** ..........151

៧.១. ករណីមួយនៃ "គំរូអន្តរការី"៖ អង្គការកសិករមិនមែនជាអ្នកផលិតទេ ប៉ុន្តែដើរតួជាអន្តរការីឲ្យកសិករ និងអ្នកទិញ ........................................ 151

៧.២. ធានាដល់ការប្តេជ្ញាចិត្ត និងការផ្គត់ផ្គង់ដោយសមាជិកអង្គការកសិករ ........................................ 151

៧.៣. បញ្ហានៃការគ្រប់គ្រងគុណភាពនៅក្នុងអង្គការកសិករ ........................................ 153

៧.៣.១. ការរកឃើញ និងការលើកកម្ពស់ការអនុវត្តល្អដើម្បីលើកកម្ពស់គុណភាព ........................ 154

៧.៣.២. ការតាមដានការអនុវត្តរបស់កសិករ ........................................ 155

៧.៣.៣. ការគ្រប់គ្រងក្នុងពេលផលិត / ពេលប្រមូលផល ........................................ 156

៧.៤. បញ្ហាលំហូរសាច់ប្រាក់/ការពន្យាពេលទូទាត់ប្រាក់នៅក្នុងអង្គការកសិករ.............................. 157

# មាតិកា


៧.៥ ការធានារ៉ាប់រងលើការចំណាយផ្ទាល់របស់អង្គការកសិករ ........ 160

៧.៥.១. ការចំណាយដែលត្រូវរ៉ាប់រងនៅក្នុងអង្គការកសិករ/កម្រិតសហករ........ 161

៧.៥.២. ធនធានដើម្បីទូទាត់លើការចំណាយ........ 163

**ជីវប្រវត្តិ /** ........165

**ឯកសារយោងសំខាន់** ........165

**សន្ទស្សន៍** ........169

**ឧបសម្ព័ន្ធ** ........170

# បញ្ជីតារាង រូបភាព និងការពន្យល់បន្ថែម

## បញ្ជីតារាង


តារាង ៣.២.ក.៖ បញ្ជីត្រួតពិនិត្យជាមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យសម្រាប់ពិចារណា ក្នុងពេលប៉ាន់ប្រមាណលើភាពអាចជឿទុកចិត្តរបស់ភាគីអ្នកទិញ (ក្រុមហ៊ុនកសិ-ឧស្សាហកម្ម) ..... 43

តារាង ៣.២.ខ.៖ បញ្ជីត្រួតពិនិត្យជាមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យសម្រាប់ពិចារណា ក្នុងពេលប៉ាន់ប្រមាណភាពសមរម្យរបស់ភាគីអ្នកផលិត ..... 46

តារាង ៤.៩.ក.៖ ការពិនិត្យមើលជម្រើសផ្សេងៗនៃមធ្យោបាយទូទាត់ប្រាក់ ..... 102

តារាង ៥.១.ខ ៖ ឧទាហរណ៍នៃបញ្ជីត្រួតពិនិត្យដើម្បីតាមដានការអនុវត្តការប្តេជ្ញាចិត្តរបស់ផលិតករដែលពាក់ព័ន្ធនឹងវិធីសាស្ត្រផលិតកម្ម ..... 129

តារាង ៥.២.ក. ៖ លិខិតផ្ទេរប្រគល់ និងបង្កាន់ដៃទូទាត់ប្រាក់ ឬតម្រូវការសម្រាប់ការចេញវិក្កយប័ត្រដែលផ្អែកលើស្ថានភាពជាក់ស្តែង ..... 142

តារាង ៥.៣.ក. ៖ បញ្ជីត្រួតពិនិត្យសម្រាប់ការពិនិត្យមើលការអនុវត្តជាក់ស្តែងចំពោះលក្ខខណ្ឌនៃកិច្ចសន្យា (ឧ. ការចិញ្ចឹមមាន់) ..... 145


## បញ្ជីរូបភាព


រូបភាព ៦.១.ក.៖ ស្ថិតិនៃករណីដែលបានទទួលដោយ « មណ្ឌលសេវាកម្មយុត្តិធម៌ » ..... 157


## បញ្ជីនៃការពន្យល់បន្ថែម


មតិយោបល់លើពាក្យដែលប្រើប្រាស់ក្នុងនិយមន័យខាងលើនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

ការពន្យល់បន្ថែម ២.៣.ក ៖ ការគាំទ្រដែលអាចមានពីគម្រោងរបស់រាជរដ្ឋាភិបាលស្តីពីបណ្តាញកសិករខ្នាតតូចទៅកាន់ទីផ្សារតាមរយៈប្រតិបត្តិការផលិតកម្មកសិកម្មតាមកិច្ចសន្យា ..... 36

ជម្រើសដែលប្រើបាន សម្រាប់កាត់ប្រាក់បុរេប្រទានទៅសងអ្នកចុះកិច្ចសន្យាវិញ ..... 104

ការពន្យល់បន្ថែម ៤.១១.ក ..... 112

ផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមរដូវកាល ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រុមហ៊ុន AMRU Rice (Cambodia) និងសហគមន៍កសិកម្មនៅខេត្តព្រះវិហារ ..... 112

ការពន្យល់បន្ថែម ៥.១.ក ..... 127

## បញ្ជីតារាង រូបភាព និងការពន្យល់បន្ថែម


ការកែតម្រូវភ្លាមៗរបស់ភាគីអ្នកផលិត និងបរិមាណដែលពាក់ព័ន្ធ ក្នុងដំណាក់កាលផលិតកម្ម ផ្អែកលើការគ្រប់គ្រងការអនុលោមតាមស្តង់ដារ ..... 127

៥.១.ខ. ឧទាហរណ៍នៃទម្រង់របាយការណ៍សម្រាប់ការវាយតម្លៃការខូចខាត និងការអនុគ្រោះពីការអនុវត្តកាតព្វកិច្ចសម្រាប់ភាគីអ្នកផលិតក្នុងករណី «ប្រធានសក្តិ» ដូចជា គ្រោះធម្មជាតិជាដើម ..... 132

ការបង្ហាញពីករណី ៥.១.គ ..... 133

ការសម្រុះសម្រួលក្នុងពេលអនុវត្តដើម្បីដោះស្រាយបញ្ហាដែលភាគីទាំងពីរកំពុងប្រឈមមុខ ..... 133

ការបង្ហាញពីករណី ៥.២.ក ..... 138

ការបរាជ័យនៃកិច្ចសន្យាដោយសារមិនមាននីតិវិធីគ្រប់គ្រាន់សម្រាប់គ្រប់គ្រងគុណភាព ..... 138

ការពន្យល់បន្ថែម ៥.២.ខ. ..... 141

កិច្ចព្រមព្រៀងស្តីពីការយោងតម្លៃ៖ ការពន្យល់ជាក់ស្តែងនៅក្នុងកិច្ចសន្យាសម្រាប់ការផ្គត់ផ្គង់ស្រូវនៅខេត្តព្រះវិហារ ..... 141

សង្ខេប៖ ការប្រៀបធៀបរវាងវិធីផ្សេងគ្នាសម្រាប់ដោះស្រាយវិវាទ ..... 163

ការពន្យល់បន្ថែម ៧.២.ក ..... 165

ទម្រង់មួយនៃកិច្ចសន្យារវាងគណៈកម្មាធិការគ្រប់គ្រងសហករកសិកម្មនិងសមាជិក សហករកសិកម្ម ស្តីពីផលិតកម្មស្រូវសរីរាង្គ ..... 165

ការពន្យល់បន្ថែម ៧.៤.ក. ការគណនាដើមទុនចាំបាច់សម្រាប់ទូទាត់ប្រាក់ទៅឱ្យកសិករនៅពេលប្រគល់ទំនិញ និងការទូទាត់របស់អ្នកទិញទៅឱ្យអង្គការកសិករ បន្ទាប់ពីការពន្យាពេលប៉ុន្មានថ្ងៃ ..... 172

ការពន្យល់បន្ថែម ៧.៥.ក. ឧទាហរណ៍នៃការធ្វើគម្រោងថវិកា (ចំណាយ និងចំណូល) របស់សហគមន៍សម្រាប់ការប្រមូល និងការលក់ស្រូវ ..... 175

# អក្សរកាត់

| | |
|---|---|
| AC | សហគមន៍កសិកម្ម |
| ACMECS | Ayeyawady Chao Phraya Mekong Economic Cooperation Strategy |
| ADR | ការដោះស្រាយវិវាទក្រៅផ្លូវតុលាការ |
| AFD | Agence Française de Développement / ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ |
| AMIS | ប្រព័ន្ធព័ត៌មានទីផ្សារកសិកម្ម |
| AMO | ការិយាល័យស្វែងរកទីផ្សារកសិកម្ម |
| CC | ក្រុមប្រឹក្សាឃុំសង្កាត់ |
| CCC | សភាពាណិជ្ជកម្មកម្ពុជា |
| CDRC | គណៈកម្មាធិការដោះស្រាយវិវាទឃុំសង្កាត់ |
| CF | ផលិតកម្មកសិកម្មតាមកិច្ចសន្យា |
| CFCC | គណៈកម្មាធិការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា |
| CSR | ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន |
| DACP | នាយកដ្ឋានលើកកម្ពស់សហគមន៍កសិកម្ម |
| DAE | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| DAI | នាយកដ្ឋានកសិ-ឧស្សាហកម្ម |
| DAL | នាយកដ្ឋាននីតិកម្មកសិកម្ម |
| DDM | ម៉ូឌែលជំរុញតម្រូវការ |
| Dis. | ស្រុក |
| DP | ដៃគូអភិវឌ្ឍន៍ |
| DPS | នាយកដ្ឋានផែនការ និងស្ថិតិ (នៃ MAFF) |
| FAO | អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ |
| FI | ស្ថាប័នហិរញ្ញវត្ថុ |
| FO | អង្គការកសិករ |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |

# អក្សរកាត់

| | |
|---|---|
| GI | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ |
| ICS | ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង |
| IPM | វិធានការចម្រុះការពារដំណាំ |
| JBWC | គណៈកម្មាធិការចម្រុះទ្វេភាគី(រវាងកម្ពុជានិងថៃឡង់ដ៍) |
| JBWCLMO | សារពាង្គកាយកែច្នៃរស់ |
| LMO<MAFF | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| MAFFMEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOJ | ក្រសួងយុត្តិធម៌ |
| MoWRaM | ក្រសួងធនធានទឹកនិងឧតុនិយម |
| M&E | ការតាមដាននិងវាយតម្លៃ |
| NCAC | មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្ទៃកពាណិជ្ជកម្ម |
| NPACD | គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្ម |
| PDAFF | មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទរាជធានី-ខេត្ត |
| RDB | ធនាគារអភិវឌ្ឍន៍ជនបទ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SCCRP | គម្រោងគាំទ្រការធ្វើពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| SME | សហគ្រាសខ្នាតតូចនិងមធ្យម |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SPS | អនាម័យ និងភូត្គគាមអនាម័យ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNIDROIT | វិទ្យាស្ថានអន្តរជាតិសម្រាប់ការបង្រួបបង្រួមច្បាប់ឯកជន |
| WIPO | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

# អារម្ភកថា និងការថ្លែងអំណរគុណ

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងភាពជាដៃគូជាមួយគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា ដែលសម្របសម្រួលដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងផ្តល់ហិរញ្ញប្បទានដោយ *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* (ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង, AFD)។

អ្នកជំនាញមួយចំនួនដែលបានចូលរួមចំណែកក្នុងការធ្វើសេចក្តីព្រាងសៀវភៅណែនាំនេះ មកពី **នាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** និងពីអង្គការជាដៃគូ រួមមាន៖

IRAM (វិទ្យាស្ថានស្រាវជ្រាវ និងអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍)៖ www.iram-fr.org
អង្គការ AVSF (អង្គការអ្នកក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន)៖ www.avsf.org
CIRD (វិទ្យាស្ថានកម្ពុជាដើម្បីការស្រាវជ្រាវ និងអភិវឌ្ឍជនបទ)៖ www.cird.org.kh
សមាគមហង់រី កាពីតង់នៅកម្ពុជា៖ www.henricapitant-cambodia.org
Aide au Développement Gembloux៖ www.ong-adg.be

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍ជាលក្ខណៈអន្តរជាតិ ឯកសារ និងការអនុវត្តល្អបំផុត (សូមមើលបញ្ជីសៀវភៅនៅចុងបញ្ចប់នៃសៀវភៅនេះ) បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកជំនាញ បទពិសោធន៍សាកល្បងនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា ជាពិសេសអ្នកដែលបានគាំទ្រវិស័យស្រូវអង្ករដោយគម្រោង SCCRP ព្រមទាំងអ្នកប្រកបរបរផ្សេងទៀត និងបទពិសោធន៍វិស័យឯកជននៅក្នុងសង្វាក់តម្លៃផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។
ជាចុងក្រោយ សៀវភៅនេះក៏ត្រូវបានវាយតម្លៃ និងផ្តល់ជាយោបល់ដោយអ្នកជំនាញអន្តរជាតិមកពីអង្គការ FAO និង Unidroit ផងដែរ។

ខ្លឹមសារនៃសៀវភៅណែនាំនេះត្រូវបានពិនិត្យឡើងវិញ និងបានកែសម្រួល ហើយត្រូវបានអនុម័តចុងក្រោយដោយក្រុមការងារផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលដឹកនាំដោយ ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# សេចក្តីផ្តើមៈ គោលបំណង វិសាលភាព និងការប្រើប្រាស់សៀវភៅណែនាំនេះ

## តើសៀវភៅណែនាំនេះធ្វើឡើងសម្រាប់នរណា?

សៀវភៅណែនាំនេះបង្កើតឡើងជាពិសេស សម្រាប់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចក្នុងវិស័យកសិកម្មដែលកំពុងពិចារណាលើការបង្កើតភាពជាដៃគូដោយផ្អែកលើទំនាក់ទំនងនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ភាគីពាក់ព័ន្ធទាំងនេះអាចស្ថិតនៅផ្នែកខាងផលិត (កសិករ ឬ អង្គការកសិករ) ឬ ក៏កសិ-ឧស្សាហកម្ម ឬ ឧស្សាហកម្មស្បៀងអាហារដែលត្រូវការផលិតផលកសិកម្ម។
គោលដៅបន្ទាប់របស់សៀវភៅនេះគឺសម្រាប់បង្ហាញពីស្ថាប័នគាំទ្រ ដែលមានតួនាទីកសាងសមត្ថភាពដល់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ឬ មានតួនាទីសម្របសម្រួលក្នុងការគាំទ្រដល់ការបង្កើតកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌។

ដោយយោងតាមអនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមាននាយកដ្ឋានកសិ-ឧស្សាហកម្មជាស្ថាប័នបង្គោលក្នុងការដឹកនាំសម្របសម្រួលរៀបចំកិច្ចសន្យា គាំទ្របច្ចេកទេស និងដោះស្រាយពេលមានវិវាទកើតឡើង។

អង្គការ ឬ ស្ថាប័នផ្សេងៗអាចផ្តល់ការគាំទ្រសេវាកម្មផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ក្នុងករណី បើភាគីនៅក្នុងកិច្ចសន្យាមានបំណងចង់ទទួលបានសេវាកម្មពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ/នាយកដ្ឋាន កសិ-ឧស្សាហកម្ម (ជាអាទិ៍ ប្រព័ន្ធសម្របសម្រួលរៀបចំកិច្ចសន្យា ប្រព័ន្ធដំណោះស្រាយវិវាទ...) ក្នុងន័យនេះ អ្នកសម្របសម្រួល ត្រូវតែមានការទទួលស្គាល់ដោយនាយកដ្ឋានកសិ-ឧស្សាហកម្ម និង ត្រូវតែដើរតាមនីតិវិធីរបស់នាយកដ្ឋាន កសិ-ឧស្សាហកម្ម។

## គោលការណ៍ណែនាំ និងព័ត៌មានសម្រាប់ជួយធ្វើការសម្រេចចិត្ត

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ទទួលស្គាល់ថាកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាចាំបាច់ត្រូវមានការប្រែប្រួលនូវលក្ខខណ្ឌនានា ដែលត្រូវចែងដោយអ្នកពាក់ព័ន្ធនានាដើម្បីឱ្យសមស្របទៅនឹងគោលបំណង ឧបសគ្គក៏ដូចជាស្ថានភាពរបស់ពួកគេ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញជាសារាចរណែនាំលេខ ១៩៦ សរណន.កសក. ស្តីអំពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ចុះថ្ងៃ ទី១៧ ខែ មីនា ឆ្នាំ ២០១៧ ដែលបានចង្អុលបង្ហាញនូវដំណើរការស្នើសុំអនុវត្ត និងស្ថាប័នបង្គោលក្នុងការជួយផ្ទូរផ្គងស្វែងរកដៃគូ សម្របសម្រួលរៀបចំកិច្ចសន្យា ដល់ភាគីដែលមានបំណងចង់អនុវត្តផលិតកម្មកសិកម្មតាម កិច្ចសន្យា។ នាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដែលជា ស្ថាប័នបង្គោលក្នុងការផ្តល់ព័ត៌មានដល់ភាគីមុនធ្វើការសម្រេចចិត្ត និងដឹកនាំជួយសម្របសម្រួលអនុវត្តផលិត កម្មកសិកម្មតាមកិច្ចសន្យា។ ភាគីដែលមានបំណងចង់អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាទៅតាមអនុក្រឹត្យ លេខ ៣៦ អនក្រ.បក នឹងត្រូវបានឲ្យបំពេញពាក្យស្នើសុំ និងត្រូវបានផ្តល់ឲ្យនូវគំរូកិច្ចសន្យាដោយនាយកដ្ឋាន កសិ-ឧស្សាហកម្ម ឬ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត សម្រាប់ជាជំនួយក្នុងការធ្វើ សេចក្តីសម្រេចចិត្ត (សូមមើល **ផ្នែកទី ៤** និង**ឧបសម្ព័ន្ធ ៤**)។

# សេចក្តីផ្តើម៖ គោលបំណង វិសាលភាព និងការប្រើប្រាស់សៀវភៅណែនាំនេះ

ក្រៅពីគោលការណ៍ណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចបានជម្រាបជូនខាងលើ ដើម្បីផ្តល់ជាព័ត៌មាន និងគំនិតដែលជាជំនួយដល់ភាគីពាក់ព័ន្ធក្នុងការសម្រេចចិត្តដោយផ្ទាល់ខ្លួន សៀវភៅណែនាំនេះនឹងរៀបរាប់អំពីដំណោះស្រាយដែលអាចប្រើបានឬជម្រើសដើម្បីឆ្លើយនឹងសំណួរ
សំខាន់ៗនៃកិច្ចសន្យា និងធ្វើការវិភាគអំពីគុណសម្បត្តិ ក៏ដូចជាគុណវិបត្តិនៃជម្រើសផ្សេងៗគ្នា ដែលទាក់ទងនឹងប្រព័ន្ធតម្លៃដែលអាចអនុវត្តបាន សូចនាករនៃបរិមាណដើម្បីប្រគល់ផលិតផល មធ្យោបាយទូទាត់ប្រាក់ យន្តការដែលអាចធ្វើបានដើម្បីដោះស្រាយជម្លោះជាដើម ។ល។ ក្នុងពេលកន្លងមក យើងបានព្យាយាមធ្វើការសង្ខេបចូលទៅក្នុងតារាងប្រៀបធៀបគុណសម្បត្តិ ឬគុណវិបត្តិនៃជម្រើសដែលអាចប្រើបានផ្សេងៗដើម្បីដោះស្រាយបញ្ហាទាំងនេះ។

## តើអ្នកអាននឹងទទួលបានអ្វីខ្លះពីសៀវភៅនេះ ?

គោលបំណងនៃការរៀបចំសៀវភៅនេះឡើងគឺដើម្បីបង្ហាញពីជម្រើសផ្សេងៗនៃដំណើរការយន្តការ ដែលអាចអនុវត្តបានជាក់ស្តែង និងដើម្បីបង្ហាញពីជម្រើសផ្សេងៗនៃវិធីសាស្រ្ត និងចំណុចគន្លឹះសំខាន់ៗដែលត្រូវចែងក្នុងកិច្ចសន្យា សម្រាប់ជាចំណេះដឹងដល់គ្រប់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច និងស្ថាប័នគាំទ្រ ក៏ដូចជាភាគីអ្នកផលិត និងភាគីអ្នកទិញ ដែលមានបំណងចង់អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។ មិត្តអ្នកអាននឹងបានជ្រួតជ្រាបអំពីដំណើរការ និងយន្តការ ក្នុងការជួយសម្របសម្រួលរៀបចំកិច្ចសន្យា ការជួយដោះស្រាយវិវាទដែលកើតមានឡើងក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាតាមរយៈក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងបានយល់ដឹងអំពីជម្រើសផ្សេងៗនៃវិធីសាស្រ្តរៀបចំកិច្ចសន្យាផលិតកម្មកសិកម្មសម្រាប់ករណីក្នុងប្រទេសកម្ពុជា។ រចនាសម្ព័ន្ធរបស់សៀវភៅនេះត្រូវបានរៀបចំឡើងតាមលំដាប់លំដោយដែលបានមកពីគំនិតនៃបណ្តាប្រទេសដែលមានបទពិសោធន៍ ដូចជាការធ្វើសុពលភាពនៃគោលការណ៍និងជម្រើសរបស់ដៃគូ ការចរចាកិច្ចសន្យា និងតាមរយៈការអនុវត្ត និងការវាយតម្លៃរបស់ក្រុមការងារផ្ទាល់។ ការពន្យល់ ឬ ករណីសិក្សាត្រូវបានគូសបញ្ជាក់ក្នុងការពន្យល់បន្ថែមហើយព័ត៌មានគន្លឹះនានាត្រូវបានបញ្ចូលបន្ថែមជាមួយនឹងសញ្ញា ។

សម្រាប់អ្នកដែលថ្មីអាចមើលនិយមន័យនៅក្នុង **ផ្នែកទី ១** និយាយអំពីនិយមន័យនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការរៀបរាប់អំពីម៉ូឌែលផ្សេងៗគ្នា ព្រមទាំងសមាសភាពនានាដែលទាក់ទងនឹងអត្ថប្រយោជន៍នាពេលអនាគត (និងហានិភ័យ) នៃផលិតកម្មកសិកម្មតាមកិច្ចសន្យា និងរបៀបដែលវាអាចផ្តល់ផលប្រយោជន៍ដល់អាជីវកម្មមួយបាន។

**ផ្នែកទី ២** ផ្តល់នូវព័ត៌មានសាវតារជាក់លាក់បន្ថែមទៀតសម្រាប់ករណីក្នុងប្រទេសកម្ពុជា ជាពិសេសទាក់ទងទៅនឹងប្រវត្តិនៃផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា សាវតារផ្នែកច្បាប់ និង (ឬការព្យាករណ៍) គោលនយោបាយដែលមានស្រាប់ ព្រមទាំងវិធានការការគាំទ្រ។

**ផ្នែកទី ៣** អ្នកអានអាចសម្គាល់ថានរណាអាចគាំទ្រដល់ពួកគេក្នុងការបង្កើតភាពជាដៃគូធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា នីតិវិធីដែលត្រូវអនុវត្តតាម ព្រមទាំងគន្លឹះក្នុងការជ្រើសរើសដៃគូចុះកិច្ចសន្យាដែលសមស្របផងដែរ។

**ផ្នែកទី ៤** ផ្តោតលើកិច្ចសន្យាផ្ទាល់ ឧទាហរណ៍ ទម្រង់នៃកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលត្រូវបានណែនាំឱ្យប្រើដោយនាយកដ្ឋានកសិ-ឧស្សាហកម្មនៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ វាមិនមាននៅក្នុងគំរូស្តង់ដារទេ ដោយសារតែគ្មានគំរូនៃកិច្ចសន្យាណាដែល "អាចប្រើប្រាស់បានទាំងអស់" នោះទេ។ ប៉ុន្តែ **ផ្នែកទី** ៤ ភ្ជាប់ "ជំពូក" ដែលបានផ្តល់ជាយោបល់ ឬប្រការនៃកិច្ចសន្យា និងសំណួរនានា ដែលកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវតែធ្វើការដោះស្រាយ។ សម្រាប់សំណួរនីមួយៗ (ដូចជា គុណភាព តម្លៃ និងបែបបទនៃការបង់ប្រាក់ជាដើម) មិនត្រូវបានផ្តល់នូវការឆ្លើយតបជាស្តង់ដារទេ ប៉ុន្តែវាផ្តល់ជាជម្រើសដែលអាចប្រើបាននានាដែលភាគីពាក់ព័ន្ធត្រូវយកមកពិភាក្សា និងសម្រេចចិត្ត តាមករណីមួយៗ និងដោយផ្អែកលើការចរចា។

មិនមែនអ្វីៗគ្រប់យ៉ាងសុទ្ធតែត្រូវបានកំណត់ឡើងដោយពេញលេញ នៅពេលកិច្ចសន្យាត្រូវបានចុះហត្ថលេខានោះឡើយ។ ផលិតផលនៅក្នុងវិស័យកសិកម្ម អាចប្រឈមមុខនឹងគ្រោះថ្នាក់ច្រើនជាងផលិតផលក្នុងវិស័យផ្សេងៗទៀត ហើយរឿងរ៉ាវទាំងអស់ក៏មិនមែនតែងតែកើតឡើងទៅតាមការគ្រោងទុករហូតនោះដែរ។ ភាគីទាំងពីរត្រូវរក្សាការប្រាស្រ័យទាក់ទងល្អក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាដើម្បីប្រឈមមុខនឹងយថាភាពនានា និងបង្ការជម្លោះកុំឲ្យកើតមានជាដើម។

**ផ្នែកទី៥** ផ្តល់ជាអនុសាសន៍ក្នុងការតាមដានការអនុវត្ត ដើម្បីរៀបចំការប្រមូលផលិតផល និងរៀបចំនៅក្រោយពេលបញ្ចប់កិច្ចសន្យាដើម្បីធ្វើការវាយតម្លៃលទ្ធផល ក៏ដូចជាការលំបាកនានា ក្នុងគោលបំណងដើម្បីកែលម្អភាពជាដៃគូ ប្រសិនបើកិច្ចសន្យានឹងត្រូវបន្ត។

**ផ្នែកទី ៦** បញ្ជាក់អំពីដំណោះស្រាយវិវាទនៅពេលអនុវត្តកិច្ចសន្យាកសិកម្ម ហើយធ្វើការបង្ហាញ និងប្រៀបធៀបយន្តការផ្សេងៗគ្នា ដែលភាគីពាក់ព័ន្ធក្នុងកិច្ចសន្យានេះអាចប្រើប្រាស់ដើម្បីដោះស្រាយវិវាទ។ ផ្នែកនេះក៏មានជម្រើសជាច្រើន និងយន្តការដែលអាចធ្វើបានផងដែរ ហើយសមាសធាតុដែលបានផ្តល់នៅក្នុងផ្នែកនេះគឺដើម្បីជួយភាគីពាក់ព័ន្ធធ្វើការជ្រើសនូវជម្រើសដែលបានផ្តល់ជូនរួចហើយ។

ចុងក្រោយ **ផ្នែកទី ៧** ត្រូវដាក់ជូនជាពិសេសសម្រាប់អង្គការកសិករដែលពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា។ នៅក្នុងករណីភាគច្រើន យ៉ាងហោចណាស់ក្នុងប្រទេសកម្ពុជាសហករណ៍កសិកម្ម ឬអង្គការកសិករផ្សេងទៀតមិនបានផលិតដោយខ្លួនឯងទេ ប៉ុន្តែអាចប្រមូល និងលក់ផលិតផលរបស់សមាជិករបស់ពួកគេ។ នៅពេលពួកគេបានចូលរួមនៅក្នុងកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា អង្គការកសិករត្រូវធានាថា ពួកគេពិតជាមានសមត្ថភាពផ្គត់ផ្គង់ផលិតផល ដូចបានព្រមព្រៀងគ្នា ទាំងបរិមាណ និងគុណភាពដែលវាអាចជាបញ្ហាប្រឈម។ គន្លឹះជំនួយ និងឧបករណ៍នានាត្រូវបានស្នើឡើងដោយ អង្គការកសិករ ក្នុងគោលបំណងដើម្បីជួយពួកគេក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ។

# ផ្នែកទី ១៖ ទិដ្ឋភាពទូទៅនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

## ១.១. និយមន័យ និងម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យា

### ១.១.១. និយមន័យនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

ខ្លឹមសារនៅលើផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ ផ្តល់ជានិយមន័យជាច្រើនសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលយើងមិនរាប់បញ្ចូល និងធ្វើការពិភាក្សានៅក្នុងសៀវភៅណែនាំនេះទេ។ យើងស្នើនៅទីនេះនូវនិយមន័យបណ្តោះអាសន្នសម្រាប់គោលបំណងនៃសៀវភៅណែនាំនេះ ដែលគ្របដណ្តប់លើចំណេះដឹងយ៉ាងទូលំទូលាយអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ការបកស្រាយអំពីពាក្យមួយចំនួនត្រូវបានបង្ហាញនៅក្នុងការពន្យល់បន្ថែមខាងក្រោម។

មាត្រា ៤ នៃអនុក្រឹត្យលេខ ៣៦ អនក្រ.បក (មើលឧបសម្ព័ន្ធទី ១) ចែងពីនិយមន័យវាក្យសព្ទសំខាន់ៗនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដូចខាងក្រោម ៖

ផលិតកម្មកសិកម្មតាមកិច្ចសន្យា សំដៅដល់ផលិតកម្មកសិកម្ម ដោយមានការធានាអំពីតម្លៃ បរិមាណ និងគុណភាពផលិតផល ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀតដែលមានការព្រមព្រៀងគ្នាមុនការផលិត។ ខាងក្រោមនេះបង្ហាញពីនិយមន័យពិស្តារ ដែលមិនផ្ទុយពីនិយមន័យក្នុងអនុក្រឹត្យលេខ ៣៦ អនក្រ.បក ប៉ុន្តែជួយផ្តល់ន័យបន្ថែមកាន់តែជាក់លាក់ និងក្បោះក្បាយ ៖

> នៅក្នុងសៀវភៅនេះ **ផលិតកម្មកសិកម្មតាមកិច្ចសន្យា** មានន័យថាជា៖
>
> **ការរៀបចំជាប់កាតព្វកិច្ច** រវាងអ្នកចុះកិច្ចសន្យា (**អ្នកទិញ**ផលិតផលកសិកម្មជាទូទៅជាក្រុមហ៊ុន) និង**ផលិតករ** ឬ**អង្គការផលិតករ**ក្នុងទម្រង់ជា**កិច្ចសន្យា** ដោយផ្ទាល់មាត់ឬដោយលាយលក្ខណ៍អក្សរ **ដែលបានចរចាមុនពេលផលិតកម្ម ចាប់ផ្តើម** (ឬនៅដំណាក់កាលដំបូងនៃដំណើរការផលិតកម្ម) ដែលផលិតករប្តេជ្ញា**ផលិតផលកសិកម្មជាក់លាក់** (អាចស្ថិតនៅក្នុងលក្ខណៈជាក់លាក់ណាមួយ) និង**លក់ផលិតផលនោះទៅឲ្យអ្នកចុះកិច្ចសន្យា**ផ្តាច់មុខ ឬ ជាអាទិភាព ឬ តាមបរិមាណអប្បបរមាដែលបានព្រមព្រៀងគ្នា ចំណែកឯអ្នកចុះកិច្ចសន្យាត្រូវប្តេជ្ញាទិញផលិតផលនោះ (ផលិតកម្មទាំងអស់ឬបរិមាណអប្បបរមាដែលបានព្រមព្រៀងគ្នា) **នៅក្នុងតម្លៃដែលបានព្រមព្រៀងគ្នា ឬ តម្លៃដែលបានកំណត់អាស្រ័យលើបែបបទដែលបានព្រមព្រៀងគ្នា** ហើយត្រូវផ្តល់នូវជំនួយផ្នែកបច្ចេកទេស និង/ឬសម្ភារ និង/ឬជំនួយផ្នែកហិរញ្ញវត្ថុទៅដល់ផលិតករ។

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

### មតិយោបល់លើពាក្យប្រើប្រាស់ក្នុងនិយមន័យខាងលើនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

"ការរៀបចំជាប់កាតព្វកិច្ច[១] រវាងអ្នកចុះកិច្ចសន្យា (អ្នកទិញផលិតផលកសិកម្ម ជាទូទៅគឺជាក្រុមហ៊ុន[២]) និងផលិតករ ឬអង្គការផលិតករជាទូទៅហៅថា ភាគីអ្នកផលិត[៣] ក្នុងទម្រង់ជាកិច្ចសន្យា[៤] ដោយផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សរ[៥] ដែលបានចរចាមុនពេលផលិតកម្មចាប់ផ្តើម[៦] ដែលផលិតករបានប្តេជ្ញាផលិត[៧]ផលិតផលកសិកម្ម[៨] (អាចនៅក្នុងលក្ខណៈជាក់លាក់ណាមួយ[៩]) និងលក់ផលិតផលនោះទៅឲ្យអ្នកចុះកិច្ចសន្យាផ្តាច់មុខ ឬជាអាទិភាព ឬតាមបរិមាណអប្បរមាដែលបានព្រមព្រៀងគ្នា[១០] ចំណែកឯអ្នកចុះកិច្ចសន្យាត្រូវប្តេជ្ញាទិញផលិតផលនោះ(ផលិតកម្មទាំងអស់ ឬបរិមាណអប្បបរមាដែលបានព្រមព្រៀងគ្នា[១១]) ហើយអាចផ្តល់ជាជំនួយផ្នែកបច្ចេកទេស និង/ឬសម្ភារ និង/ឬជំនួយផ្នែកហិរញ្ញវត្ថុទៅដល់ភាគីអ្នកផលិត[១២]។"

<u>មតិយោបល់អំពីការ ប្រើប្រាស់ពាក្យក្នុងសៀវភៅណែនាំនេះ៖</u>

[១] **ការជាប់កាតព្វកិច្ច៖** ជាកិច្ចសន្យាដែលចូលរួមដោយភាគីទាំងពីរជាផ្លូវការ។ វាជាប់កាតព្វកិច្ចដោយស្របច្បាប់ ហើយអាចនឹងអនុវត្តបានតាមរយៈការសម្រេចចិត្តរបស់តុលាការក្នុងករណីដែលភាគីណាមួយមិនបានគោរពតាម។

[២] **ក្រុមហ៊ុន៖** ជាទូទៅសំដៅភាគីអ្នកទិញ គឺជាក្រុមហ៊ុនដែលបានបង្កើតឡើងដោយស្របច្បាប់។ ប៉ុន្តែ វាក៏ទៅរួចផងដែរ ដែលថាអ្នកចុះកិច្ចសន្យានេះគឺជារូបវន្តបុគ្គល ដែលមានគោលការណ៍ដូចដែលបានរៀបរាប់នៅក្នុងសៀវភៅនេះ។

[៣] **ផលិតករ ឬអង្គការផលិតកដែលជាទូទៅហៅថា ភាគីអ្នកផលិត ៖** យើងរួមបញ្ចូលទាំងកិច្ចសន្យាជាមួយអង្គការផលិតករ ទោះបីជាអង្គការផលិតករមិនបានផលិតផលិតផលកសិកម្មដោយផ្ទាល់ក៏ដោយ។ អង្គការផលិតករអាចជាភាគីហត្ថលេខីមួយនៃកិច្ចសន្យា និងចូលរួមជាមួយសមាជិកកសិកររបស់ពួកគេស្ថិតក្រោមឈ្មោះរបស់អង្គការ។ ប៉ុន្តែត្រូវតែមានការគូសបញ្ជាក់ឲ្យបានច្បាស់លាស់ថា នៅពេលដែលយើងនិយាយអំពីកិច្ចសន្យាដែលអាចអនុវត្តបានដោយស្របច្បាប់ គឺភាគីហត្ថលេខីត្រូវតែបង្កើតឡើងដោយស្របច្បាប់៖ ទាំងរូបវន្តបុគ្គល ឬអង្គការកសិករដែលបានចុះបញ្ជីដោយស្របច្បាប់។ ក្រុមកសិករមិនផ្លូវការអាចនឹងមានជម្លោះក្នុងនាមជាហត្ថលេខីនៃកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា។

[៤] **កិច្ចសន្យា៖** ការប្រើពាក្យ "កិច្ចសន្យា" នេះបានបង្កើតជាការចងកាតព្វកិច្ចស្របច្បាប់រវាងភាគីទាំងពីរ។

[៥] **ផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ៖** និយមន័យនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលមានឃើញនៅក្នុងខ្លឹមសារជាញឹកញាប់ រួមមានកិច្ចព្រមព្រៀងផ្ទាល់មាត់នៅក្នុងវិសាលភាពនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាកាលពីអតីតកាល។ ប៉ុន្តែ គេទទួលស្គាល់ថាការអនុវត្តកិច្ចព្រមព្រៀងផ្ទាល់មាត់អាចកើតមានឡើង ហើយការពិចារណាលើផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវជាប់កាតព្វកិច្ចដោយស្របច្បាប់ ដែលបណ្តាលឲ្យមានការលំបាកក្នុងការអនុវត្ត។ យើងនឹងផ្តល់ការណែនាំនៅក្នុងសៀវភៅនេះអំពីការបង្កើតទម្រង់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរស្របតាម អនុក្រឹត្យលេខ ៣៦ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាបានចែងយ៉ាងច្បាស់ថា កិច្ចសន្យាត្រូវធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

[៦] **បានចរចា និងចុះហត្ថលេខាមុនចាប់ផ្តើមផលិតកម្ម៖** បើតាមគោលការណ៍ កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាគួរមានការចុះហត្ថលេខានៅមុនពេលការចាប់ផ្តើមដំណើរការផលិតកម្ម។ ប៉ុន្តែពេលខ្លះ កិច្ចព្រមព្រៀងនៅតែចាត់ទុកថាស្ថិតនៅក្នុងវិសាលភាពនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា នៅពេលកិច្ចសន្យានេះត្រូវបានចុះហត្ថលេខានៅដំណាក់កាលដំបូងនៃដំណើរការផលិតកម្ម ប៉ុន្តែបន្ទាប់មកគេពិតជាបានចាប់ផ្តើមអនុវត្តវាជាក់ស្តែងប្រាកដមែន។

[៧] **ជាក់លាក់៖** ផលិតផលកសិកម្មជាក់លាក់មានន័យថា មិនត្រឹមតែលក្ខណៈនៃផលិតផលដែលអាចត្រូវបានកំណត់នៅក្នុងកិច្ចសន្យានោះទេ ប៉ុន្តែផលិតផលទាំងនោះត្រូវបានអនុវត្តស្របទៅតាមលក្ខណៈបច្ចេកទេសដែលមានគុណភាពដូចដែលបានកំណត់ផងដែរ។

[៨] **ផលិតផលកសិកម្ម៖** គួរតែយល់ឲ្យបានទូលំទូលាយ។ វាអាចរួមមាន ផលិតផលពីដំណាំគ្រប់ប្រភេទ ផលិតផលបសុសត្វ ផលិតផលជលផល ឬផលិតផលព្រៃឈើ ។

[៩] **លក្ខណៈជាក់លាក់៖** កិច្ចសន្យាមិនកំណត់ត្រឹមតែលើលក្ខណៈគុណភាពរបស់ផលិតផលដែលត្រូវចែកចាយប៉ុណ្ណោះទេ ប៉ុន្តែក៏កំណត់ (ឬហាមឃាត់) អំពីវិធីសាស្ត្រផលិត ឬការប្រើប្រាស់ធាតុចូលជាក់លាក់នានាផងដែរ។

[១០] **ផ្តាច់មុខ ឬជាអាទិភាព ឬតាមបរិមាណអប្បបរមាដែលបានព្រមព្រៀងគ្នា៖** នៅក្នុងនិយមន័យតូចចង្អៀតនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា អ្នកចុះកិច្ចសន្យាត្រូវមានសិទ្ធិផ្តាច់មុខលើការផលិតក្រោមកិច្ចសន្យា ទោះក្នុងបរិមាណទិន្នផលកម្រិតណាក៏ដោយ។ ទោះជាយ៉ាងណា នៅក្នុងករណីមួយចំនួន អ្នកផលិតពិតជាបានប្តេជ្ញាផ្គត់ផ្គង់ក្នុងបរិមាណអប្បបរមាមែន ប៉ុន្តែការផលិតមានចំនួនលើសពីបរិមាណអប្បបរមានេះ ដូច្នេះភាគីអ្នកផលិតមានសិទ្ធិលក់នូវបរិមាណដែលលើសនេះទៅឲ្យភាគីអ្នកទិញផ្សេងទៀតបាន។ ភាគីអ្នកទិញធានាថានឹងទិញផលិតផលក្នុងតម្លៃទីផ្សារក្នុងស្រុកដែលខ្ពស់ជាងគេ ប៉ុន្តែគាត់ក៏ត្រូវផ្តល់សេរីភាពឲ្យអ្នកផលិតមានសិទ្ធិលក់ទៅឱ្យអ្នកផ្សេងផងដែរ បើសិនអ្នកផលិតអាចស្វែងរកអ្នកទិញដែលហ៊ានផ្តល់ជូននូវតម្លៃដែលភាគីអ្នកទិញមិនទាន់ហ៊ានអនុវត្ត។

[១១] **ផលិតកម្មទាំងអស់ ឬបរិមាណអប្បបរមាដែលបានព្រមព្រៀងគ្នា៖** ដូចបានរៀបរាប់ខាងលើ ភាគីអ្នកទិញអាចទទួលយកការទិញផលិតផលទាំងអស់ ឬយ៉ាងហោចណាស់ទិញក្នុងបរិមាណជាក់លាក់ណាមួយ (ជាធម្មតា អាស្រ័យលើទិន្នផល/បរិមាណផលិតផលជាក់ស្តែងដែលផ្អែកលើកត្តាផលិតកកម្មដែលពាក់ព័ន្ធ។

[១២] **ផ្តល់នូវជំនួយផ្នែកបច្ចេកទេស និង/ឬសម្ភារ និង/ឬជំនួយផ្នែកហិរញ្ញវត្ថុទៅឲ្យភាគីអ្នកផលិត៖** នៅក្នុងគោលការណ៍ កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាបញ្ជាក់ថា ភាគីអ្នកទិញគួរមានការគាំទ្រផ្តល់យោបល់ផ្នែកបច្ចេកទេស និង/ឬគាំទ្រ និង/ឬជំនួយផ្នែកសម្ភារ(ជាទូទៅ ការផ្គត់ផ្គង់ធាតុចូល ដូចជាគ្រាប់ពូជ/សំណាប ឬជី ឬសត្វចិញ្ចឹមដំបូង និងចំណីនៅក្នុងករណីផលិតកម្មសត្វ) និង/ឬ បុរេហិរញ្ញប្បទាន (ប្រាក់កម្ចី) ដើម្បីធានាលើការចំណាយនៃផលិតកម្ម។

## វាក្យសព្ទដែលប្រើក្នុងសៀវភៅណែនាំនេះ

អ្នកផលិតដែលចូលរួមក្នុងកិច្ចសន្យាក្នុងឯកសារនេះហៅថា "ភាគី**អ្នកផលិត**" ឬ "**កសិករ**"។ វាក្យសព្ទក្នុងសៀវភៅនេះអាចនឹងមានអង្គការអ្នកផលិត (ដូចជា សហគមន៍កសិកម្ម ឬអង្គការកសិករស្របច្បាប់) ដើម្បីកំណត់ភាគីក្នុងកិច្ចសន្យាសម្រាប់ទទួលខុសត្រូវលើការផលិត និងការផ្គត់ផ្គង់ផលិតផល។

ក្រុមហ៊ុនដែលទិញផលិតផលហៅថា "ភាគី**អ្នកទិញ**" ឬ "**ក្រុមហ៊ុន**"។ មួយវិញទៀតតាមរយៈការសរសេរបោះពុម្ពមុនៗគេហៅថា "អ្នកទទួលទិញ" ឬ "អ្នកឧបត្ថម្ភ"។ ប៉ុន្តែយើងមិន ប្រើពាក្យទាំងនេះនៅក្នុងសៀវភៅណែនាំនេះទេ។

កិច្ចព្រមព្រៀងរវាងពួកគេហៅថា "**កិច្ចសន្យាផលិតកម្មកសិកម្ម**"។

នៅក្នុង**កិច្ចសន្យា** កាតព្វកិច្ចគឺជាចំណុចស្នូលនៃគំនិត។ យោងតាមច្បាប់រដ្ឋប្បវេណី **កាតព្វកិច្ច**គឺជា *"ទំនាក់ទំនងផ្លូវច្បាប់ដែលបានចូលរួមជាមួយបុគ្គលពិសេសណាមួយជាមួយបុគ្គលម្នាក់ផ្សេងទៀតតាមរយៈការសន្មត់អំពីកាតព្វកិច្ចពិតប្រាកដមួយដោយគោរពទៅនឹងអ្វីដែលបុគ្គលនោះបញ្ជាក់ជាចុងក្រោយ"*។

**កូនបំណុល** គឺជាភាគីដែលមានកាតព្វកិច្ច (អាចហៅបានថាឥណទាយិក) ដែលជាអ្នកមានកាតព្វកិច្ចសងប្រាក់បំណុល បង់លុយ ធ្វើអ្វីមួយ ឬ ក៏មិនឲ្យធ្វើអ្វីមួយយោងតាមលក្ខខណ្ឌនៃកិច្ចព្រងព្រៀង។

**ម្ចាស់បំណុល** គឺជាភាគីដែលអាចហៅថា (ឥណទាយក) ដែលកូនបំណុលជំពាក់កាតព្វកិច្ចយោងតាមលក្ខខណ្ឌកិច្ចព្រមព្រៀង។

## ១.១.២. ម៉ូឌែលផ្សេងៗនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

### ធាតុផ្សំនៃកិច្ចព្រមព្រៀងរវាង ភាគីអ្នកផលិត និងភាគីអ្នកទិញដែលអាចធ្វើឲ្យមានភាពខុសប្លែកគ្នាក្នុងម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យា

គំរូនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចមានភាពខុសប្លែកគ្នាដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួនក្នុងលក្ខខណ្ឌកិច្ចព្រមព្រៀងរវាង ភាគីអ្នកទិញនិងភាគីអ្នកផលិត។ ឧទាហរណ៍ដូចជា៖

- ការផ្តល់ធាតុចូលដោយភាគីអ្នកទិញ (មិនមានធាតុចូល/ ផ្នែកខ្លះនៃធាតុចូល/ ធាតុចូលទាំងអស់)
- ការផ្តល់ឥណទានដោយភាគីអ្នកទិញ
- ការផ្តល់ការណែនាំផ្នែកបច្ចេកទេស ឬសេវាផ្សព្វផ្សាយ ឬមិនមាន
- ការផ្តល់សេវាផ្សេងទៀតដោយភាគីអ្នកទិញ (ការរៀបចំដីការត្រួតពិនិត្យសត្វល្អិតដឹកជញ្ជូនការត្រួតពិនិត្យគុណភាព ... )
- សំណុំបែបបទកិច្ចសន្យា (ផ្ទាល់មាត់ឬលាយលក្ខណ៍អក្សរ)
- ចុះកិច្ចសន្យាផលិតដោយរូបវន្តបុគ្គលឬនីតិបុគ្គល
- ការចូលរួមរបស់ភាគីផ្សេងទៀតនៅក្នុងកិច្ចសន្យា (ស្ថាប័នហិរញ្ញវត្ថុដូចជាធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ អ្នកផ្តល់សេវាបច្ចេកទេសដូចជាការផ្តល់សេវាការត្រួតពិនិត្យគុណភាព ឬ សេវាផ្នែកបន្ថែម...)
- ភាពរឹងមាំនៃតម្រូវការគុណភាព / ការបញ្ជាក់នៅលើផលិតផលនេះ
- ការកេងប្រវ័ញ្ច ឬមិនមានវិធីសាស្ត្រក្នុងការផលិត និងកំរិតនៃការចូលរួមរបស់ភាគីអ្នកទិញក្នុងការត្រួតពិនិត្យ ឬការគ្រប់គ្រងការផលិត
- មានការចែករំលែកហានិភ័យគ្នា ឬមិនមានសិទ្ធិផ្តាច់មុខរបស់ភាគីអ្នកទិញលើផលិតផល (ឬការប្តេជ្ញាចិត្តរបស់ភាគីអ្នកផលិតក្នុងការផ្គត់ផ្គង់បរិមាណជាក់លាក់មួយ ប៉ុន្តែមិនតម្រូវឲ្យច្រើនហួសពីបរិមាណដែលបានព្រមព្រៀងគ្នាទេ)
- វិធីសាស្ត្រក្នុងការដាក់តម្លៃ
- ការកែច្នៃដែលមានលក្ខណៈប្រមូលផ្តុំ ឬការកែច្នៃនៅហ្វឹងកន្លែង
- ។ល។

### ឯកសារខាងវិទ្យារបស់ I FAD ម៉ូឌែលនៃអ្នកជាំទ្រង់ទ្រាយធំ

មានការបញ្ចូលគ្នាច្រើននៅក្នុងចំណោមលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់ខាងលើ ហើយទាំងនេះក៏មិនមានម៉ូឌែលស្តង់ដារសម្រាប់ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាដែរ។ ចំណុចនេះផ្តល់ឱកាសឲ្យភាគីទាំងពីរ (ភាគីអ្នកផលិត និងភាគីអ្នកទិញ) ចរចាគ្នា និងកែសម្រួលម៉ូឌែលណាដែលសមស្របជាមួយគេបំផុត។ ប៉ុន្តែតាមផ្នែកអក្សរសាស្ត្របានបង្ហាញពីប្រភេទខុសប្លែកគ្នាយោងតាមម៉ូឌែលធម្មតា។ យើងធ្វើការបង្ហាញនៅក្នុងការពន្យល់បន្ថែមខាងក្រោម ពីការចាត់ថ្នាក់ប្រភេទទាំងប្រាំនៃម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលបានធ្វើដោយ TechnoServe និង IFAD (ដោយមានមតិយោបល់មួយចំនួនខាងក្រោម) ។

## ឋានលេខានៃម៉ូឌែលអ្នកជាំទ្រង់ទ្រាយធំ (ដោយ TechnoServe និង IFAD)




<u>ប្រភព៖</u> Technoserve និង IFAD (២០១១)៖ "គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ បង្កើនចំណេញ" សង្ខេបពីបច្ចេកទេស IFAD ទីក្រុងរ៉ូម (អ៊ីតាលី) ខែកញ្ញា ២០១១ (http៖//www.ifad.org/ruralfinance/pub/technoserve.pdf).

### ម៉ូឌែលក្រៅផ្លូវការ

ដូចដែលបានរៀបរាប់ខាងលើ ឋានលេខាវិទ្យា ដោយ TechnoServe និង IFAD "ម៉ូឌែលក្រៅផ្លូវការ" អាចពិបាកក្នុងការចាត់ទុកជាម៉ូឌែលនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា។ វាជាការប្រសើរសម្រាប់ក្រុមហ៊ុនមួយដែលម៉ូឌែលនៃផលិតផលដែលមានប្រភពមកពីអ្នកផលិត អាចមានលទ្ធភាពក្នុងការពិភាក្សាជាអាទិភាពចំពោះការទិញផលិតផលនៅកន្លែងប្រមូលផល ប៉ុន្តែមិនមានការប្តេជ្ញាចិត្តតាមបែបផ្លូវការទេ (សូម្បីផ្ទាល់មាត់ក៏មិនមាន) ដើម្បីទិញដោយពិតប្រាកដ ហើយក៏មិនមានការចូលរួមពីក្រុមហ៊ុនជាមួយភាគីអ្នកផលិត ហើយក៏មិនមានជាលក្ខខណ្ឌក្នុងការដាក់បញ្ចូលសម្ភារផ្គត់ផ្គង់ ឬឥណទាន ហើយថែមទាំងមិនមាននៅការផ្តល់នូវជំនាញបច្ចេកវិទ្យាដែរ។

### ម៉ូឌែលចំពោះមុខ

ក្នុងម៉ូឌែលចំពោះមុខ ភាគីអ្នកទិញ (ក្រុមហ៊ុន) ធ្វើកិច្ចសន្យាចំពោះមុខមួយដែលទទួលបន្ទុកក្នុងការប្រមូលផលិតផលពីកសិករម្នាក់ៗ។ កិច្ចសន្យាចំពោះមុខនឹងបង្កើតកិច្ចព្រមព្រៀងជាមួយអ្នកផលិតផងដែរ(អាចជាផ្លូវការច្រើន ឬមិនសូវផ្លូវការ) ដើម្បីធានាការផ្គត់ផ្គង់ផលិតផល។

កិច្ចសន្យាជាមួយអង្គការកសិករ ក៏អាចចាត់ទុកជាករណីជាក់លាក់មួយនៃម៉ូឌែលចំពោះមុខ ដែលអង្គការកសិករ (ឧទាហរណ៍ដូចជា សហគមន៍កសិកម្ម) ដែលដើរតួរជាអ្នកប្រមូលទិញ ហើយអាចបង្ហាញការណែនាំបច្ចេកទេស ឬសម្រួលការផ្គត់ផ្គង់ជាមួយនឹងធាតុចូល ឬពិនិត្យមើលគុណភាពផលិតផល។

### ម៉ូឌែលពហុភាគី

ម៉ូឌែលពហុភាគីដូចគ្នានឹងករណីនៃគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលមិនត្រឹមតែពាក់ព័ន្ធជាមួយអ្នកផលិតប៉ុណ្ណោះទេ គឺមានទាំងអ្នកទិញទៀតផងដែរ ប៉ុន្តែក៏អាចពាក់ព័ន្ធភាគីដទៃទៀតជាមួយមុខងារដែលបានផ្តល់ឲ្យនៅក្នុងគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា។

ឧទាហរណ៍ ប្រព័ន្ធនោះអាចពាក់ព័ន្ធជាមួយអ្នកផ្គត់ផ្គង់ ដែលផ្តល់ធាតុចូលឲ្យដែលនឹងត្រូវជាប់កិច្ចសន្យាដើម្បីផ្គត់ផ្គង់ធាតុចូលសម្រាប់អ្នកផលិត ឬសម្រាប់ស្ថាប័នហិរញ្ញវត្ថុ( ធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ក្នុងការផ្តល់សេវាឥណទានបង្កប់ ឬជាអ្នកផ្តល់សេវាកម្ម (ពេលខ្លះមាន អង្គការក្រៅរដ្ឋាភិបាល) ដើម្បីសម្របសម្រួលក្នុងការអនុវត្ត និងគ្រប់គ្រងផលិតកម្ម ឬផ្តល់ការណែនាំបច្ចេកទេស និងពង្រីកសេវាកម្ម។

គេសម្គាល់ឃើញថាម៉ូឌែលចំពោះមុខ និងពហុភាគីអាចដាក់បញ្ចូលគ្នាបាន។ ឧទាហរណ៍ក្នុងប្រព័ន្ធដែលអ្នកទិញបានធ្វើកិច្ចសន្យាជាមួយឈ្មួញកណ្តាល ( ឬសហការគ្នាដើម្បីធ្វើជាអ្នកដើរប្រមូលទិញ) និងចូលរួមពីដៃគូផ្សេងទៀតដើម្បីផ្តល់សេវាបន្ថែមដូចជា ការពង្រីកការងារកសិកម្ម ឬការចែកចាយធាតុចូល ឬឥណទាន។

### ម៉ូឌែលប្រមូលផ្តុំ

ម៉ូឌែលប្រមូលផ្តុំ គឺជាម៉ូឌែលផ្លូវការមួយនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយការបញ្ចូលគ្នាយ៉ាងល្អនៃដំណើរការផលិតដោយអ្នកទិញ។ កិច្ចសន្យាផ្លូវការត្រូវបានចុះហត្ថលេខាជាមួយអ្នកផលិត ហើយកម្រិតនៃការចូលរួមរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងការផលិតគឺមានសារៈសំខាន់។ ករណីភាគច្រើន ក្រុមហ៊ុននឹងផ្តល់យ៉ាងហោចណាស់ធាតុចូលដែលត្រូវបានប្រើមួយចំនួន និងផ្តល់ (ជាមួយបុគ្គលិកផ្ទាល់របស់ខ្លួន) សេវាកម្មប្រឹក្សាយោបល់ដែលនៅជិត និងការពិនិត្យការផលិត។ នេះជារឿងសំខាន់សម្រាប់អ្នកផលិតដើម្បីអនុវត្តតាមការផ្តល់យោបល់ផ្នែកបច្ចេកទេសឲ្យបានតឹងរឹង។ ម៉ូឌែលមួយនេះជួយធានាកម្រិតខ្ពស់នៃការគ្រប់គ្រងក្រុមហ៊ុនទៅលើគុណភាពផលិតផល ប៉ុន្តែនេះជាការបង្ហាញអំពីការវិនិយោគដ៏ខ្ពស់មួយសម្រាប់ភាគីអ្នកទិញ។

### ម៉ូឌែលនៃការផ្តល់ហិរញ្ញប្បទាន និងគ្រប់គ្រងការផលិតដោយអ្នកទិញ

ម៉ូឌែលនៃការផ្តល់ហិរញ្ញប្បទាន និងគ្រប់គ្រងការផលិតដោយភាគីអ្នកទិញ មានលក្ខណៈស្រដៀងគ្នានឹងម៉ូឌែលប្រមូលផ្តុំដែរ ប៉ុន្តែខុសគ្នាត្រង់ថា ក្រុមហ៊ុន (ភាគីអ្នកទិញ) ផ្តល់ប្រភពមួយផ្នែកធំនៃផលិតផលដែលនឹងត្រូវធ្វើការកែច្នៃ និងការធ្វើទីផ្សារតាមរយៈកសិកម្ម ឬកសិដ្ឋានខ្នាតធំរបស់ខ្លួន (អចលនទ្រព្យ/ដីសម្បទានសេដ្ឋកិច្ច...) ព្រមទាំងផ្តល់ប្រភពតែផ្នែកផលិតផលកសិកម្ម វត្ថុធាតុដើម ដែលបានមកពីការធ្វើកិច្ចសន្យាជាមួយកសិករខ្នាតតូច។ តាមពិតមានយុទ្ធសាស្ត្រខុសគ្នាច្រើនសម្រាប់ក្រុមហ៊ុន ប៉ុន្តែបើនិយាយជារួម ម៉ូឌែលនៃកសិករមានកិច្ចសន្យាមិនខុសគ្នាច្រើនពីម៉ូឌែលប្រមូលផ្តុំដែលបានរៀបរាប់ខាងលើប៉ុន្មានទេ។

អត្ថប្រយោជន៍មួយនៃម៉ូឌែលនៃការផ្តល់ហិរញ្ញប្បទាន និងគ្រប់គ្រងការផលិតដោយអ្នកទិញសម្រាប់ក្រុមហ៊ុនដែលវិនិយោគនៅក្នុងអង្គភាពកែច្នៃលមានតម្លៃខ្ពស់នេះគឺដើម្បីធានាឱ្យបាន (ពីអចលនទ្រព្យរបស់ខ្លួន) ទំហំអប្បបរមានៃផលិតផលដើម្បីផ្គត់ផ្គង់អង្គភាពកែច្នៃ (ហើយធានាបានថាការវិនិយោគនឹងត្រូវយកមកប្រើប្រាស់) ប៉ុន្តែអាចនឹងមានហានិភ័យកាន់តែច្រើនសម្រាប់អ្នកវិនិយោគក្នុងការវិនិយោគលើរោងចក្រកែច្នៃមួយដែលមានតម្លៃខ្ពស់ដោយពឹងផ្អែកតែទៅលើការផ្គត់ផ្គង់របស់កសិករខ្នាតតូច អាចដឹងហើយថាកសិករខ្នាតតូចទាំងនោះអាចធ្វើការសម្រេចចិត្តផ្លាស់ប្តូរពីកន្លែងផលិតមួយទៅកន្លែងមួយទៀត អាស្រ័យលើការវិវឌ្ឍន៍នៃតម្លៃផលិតផលកសិកម្ម។

### ឋានលេខាវិទ្យាសាមញ្ញដោយពឹងលើធនធានដែលផ្តល់ដោយភាគីនីមួយៗ

ប្រភេទសាមញ្ញនៃគំរូផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺត្រូវបានប្រើភាគច្រើន ដោយយោងទៅលើការចង្អុលបង្ហាញថាអ្នកណា (ពីអ្នកទិញ ឬអ្នកផលិត) ដែលកំពុងផ្តល់ធនធានសំខាន់ទាំង ៥ ដូចជា៖ ដី កម្មករ ទុន បច្ចេកវិទ្យា និងទីផ្សារ។

តារាង ១.១.ក.៖ ម៉ូឌែលលក្ខខណ្ឌនានាក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម

| ម៉ូឌែល | កសិករផ្តល់... | អ្នកទិញ (/ក្រុមហ៊ុន) ផ្តល់... |
|---|---|---|
| ២+៣ | ដី និងកម្មករ | ទីផ្សារ ទុន បច្ចេកទេស |
| ៣+២ | ដី កម្មករ និងទុន | ទីផ្សារ និងបច្ចេកទេស |
| ៤+១ | ដី កម្មករ ទុន និងបច្ចេកទេស | ទីផ្សារ |
| ១+៤ | ដី | កម្មករ ទុន បច្ចេកទេស និងទីផ្សារ |

ប្រភព៖ NAFES (២០១២)៖ “គោលការណ៍ណែនាំសម្រាប់សម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យាបានត្រឹមត្រូវ

ឋានលេខាវិទ្យានេះមានភាពសាមញ្ញ ហើយម៉ូឌែលចំពោះមុខក៏ដូចគ្នា (ជាពិសេសទំនងជាភាគីនីមួយៗនឹងផ្តល់ផ្នែកខ្លះនៃបច្ចេកវិទ្យា រួមជាមួយផ្នែកខ្លះនៃទុនដែលត្រូវការសម្រាប់ការផលិត)។ ប៉ុន្តែវាជាឧបករណ៍ល្អមួយសម្រាប់ការវិភាគបឋមទៅលើកិច្ចសន្យា និងដើម្បីកំណត់លក្ខណៈពិសេសសំខាន់ៗនៃកិច្ចព្រមព្រៀងនៅក្នុងដំណាក់កាលដំបូងនៃដំណើរការចរចា។

## ១.២. ឱកាស និងហានិភ័យនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ការអភិវឌ្ឍ និងជីវភាពគ្រួសារកសិករខ្នាតតូច

### ១.២.១. អត្ថប្រយោជន៍នៃផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់កសិករខ្នាតតូច

អត្ថប្រយោជន៍មានលក្ខណៈធំទូលាយមួយ ដែលមានសក្តានុពលដល់កសិករខ្នាតតូចក្នុងការចូលរួមជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា។ យោងទៅលើករណីនីមួយៗអត្ថប្រយោជន៍ដែលមានសក្តានុពល រួមមាន៖

- ប្រើបច្ចេកវិទ្យា និងមានធាតុចូលដែលមានគុណភាព ដែលអាចធ្វើឲ្យប្រសើរឡើងនៃផលិតភាព ឬគុណភាពផលិតផលរបស់ពួកគេ។
- ប្រើឥណទានដែលបានបង្កប់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយក្នុងការផលិត (ដោយផ្ទាល់ដោយភាគីអ្នកទិញ ឬដោយស្ថាប័នហិរញ្ញវត្ថុដែលពាក់ព័ន្ធ)។
- ធានាថាមានទីផ្សារ ហើយអាចជាទីផ្សារមួយដែលមានតម្លៃខ្ពស់។
- តម្លៃច្រកទ្វារកសិដ្ឋានដោយសារការផ្សារភ្ជាប់ជាមួយអ្នកទិញធំៗ អ្នកនាំចេញ ឬដោយសារគុណភាពមានភាពប្រសើរឡើង ឬដោយការវាយតម្លៃគុណភាពមានភាពប្រសើរឡើងដែរ។
- តម្លៃដែលមានស្ថេរភាព (អាស្រ័យលើប្រភេទនៃការរៀបចំកំណត់តម្លៃ ដែលបានបង្កើតឡើងនៅក្នុងកិច្ចសន្យានោះ - សូមមើល ផ្នែក ៤.៧ "តម្លៃនិងឯកសារយោងអំពីតម្លៃ") ។
- ឱកាសដែលអាចមានក្នុងការបង្កើតផលិតផលថ្មី និងបង្កើតឲ្យមានអ្វីផ្សេងៗនៅលើវិស័យកសិកម្ម និងប្រាក់ចំណូល។
- ករណីមួយចំនួន ប្រសិនបើជាសមាសភាពចែករំលែកហានិភ័យត្រូវបានរួមបញ្ចូលនៅក្នុងកិច្ចសន្យានេះគឺបានកាត់បន្ថយភាពងាយរងគ្រោះចំពោះគ្រោះថ្នាក់ដែលអាចមាន។

**ការពន្យល់បន្ថែម ១.២.ក.**

**ការទទួលបានប្រាក់ច្រើនមិនមែនសុទ្ធតែជាកត្តាលើកទឹកចិត្តសម្រាប់កសិករទេ៖ លទ្ធភាពប្រើប្រាស់បច្ចេកបច្ចេកវិទ្យា និងចំណេះដឹងអាចជាកត្តាលើកទឹកចិត្តផងដែរ៖ ករណីកិច្ចសន្យាសម្រាប់ផលិតពូជស្រូវ**

ក្នុងឆ្នាំ ២០១៣ សហគមន៍កសិករនៅខេត្តបាត់ដំបងបានចុះកិច្ចសន្យាជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវទៅលើការបង្កើនពូជស្រូវ។ សុពលភាពនៃកិច្ចសន្យាគឺមានសម្រាប់តែមូលហេតុមួយគត់ ហើយលក្ខខណ្ឌសំខាន់នៃកិច្ចសន្យាគឺម្ចាស់រោងម៉ាស៊ីនកិនស្រូវ ត្រូវជួយបង្កើនសមត្ថភាពសម្រាប់ទទួលបានបច្ចេកទេសក្នុងការផលិតពូជ នឹងអាចផ្តល់ពូជដែលសុទ្ធល្អក្នុងតម្លៃនៃស្រូវដែលប្រើប្រាស់ ហើយទិញនៅពេលប្រមូលផលបានពាក់កណ្តាលនៃពូជដែលបានផលិតក្នុងតម្លៃនៃស្រូវដែលបានប្រើប្រាស់ ហើយពាក់កណ្តាលដែលនៅសល់ជាកម្មសិទ្ធិរបស់សហគមន៍នេះដើម្បីផ្គត់ផ្គង់ដល់សមាជិករបស់ខ្លួននៅឆ្នាំបន្ទាប់ទៀត។

ករណីនេះ លក្ខខណ្ឌនៃកិច្ចសន្យាយោងទៅលើតម្លៃគឺមិនអំណោយផលដល់អ្នកផលិត ដោយសារតែពូជដែលផលិតបានមានគុណភាពត្រូវទិញក្នុងតម្លៃនៃស្រូវដែលប្រើប្រាស់។ ប៉ុន្តែសហគមន៍ទទួលកិច្ចព្រមព្រៀងនេះ ដោយសារតែផ្ទៃដីសម្រាប់ធ្វើនោះនៅមានកម្រិត (ប្រហែល ២ ហិចតា) ហើយអត្ថប្រយោជន៍សម្រាប់សហគមន៍ដែលរំពឹងទុកនោះមិនមែនជាប្រាក់កម្រៃសម្រាប់ដឹកជញ្ជូន និងពូជដែលបានផលិតគ្រប់ឡើយ ប៉ុន្តែការពង្រឹងសមត្ថភាពចំណេះដឹង និងបច្ចេកទេសក្នុងការផលិតគ្រាប់ពូជដែលមានគុណភាពជាជំនាញដែលពួកគេអាចផ្តល់តម្លៃបន្ថែមទៀតសម្រាប់រយៈពេលវែងនៅរដូវបន្តបន្ទាប់ទៀត។

## ១.២.២. ហានិភ័យដែលត្រូវពិចារណាសម្រាប់កសិករខ្នាតតូច

ម្យ៉ាងវិញទៀត ពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះក៏អាចបង្ហាញពីហានិភ័យខ្លះៗ សម្រាប់កសិករខ្នាតតូច៖

វិធីសាស្ត្រផលិតកម្មដែលបានប្រើប្រាស់ ពេលខ្លះបរាជ័យក្នុងការបង្ហាញផលិតភាពខ្ពស់ ពីព្រោះថាវាជាពូជដែលមកពីបរទេសហើយមិនអាចសម្របបានល្អទៅនឹងស្ថានភាពក្នុងស្រុក ឬដោយសារជាពូជថ្មីសម្រាប់អ្នកផលិតដែលមិនទាន់ស្ទាត់ជំនាញនឹងវា។

វិធីសាស្ត្រក្នុងការផលិតដែលអាចមានដែលបានប្រើ ឬបានណែនាំឲ្យប្រើ អាចចង្អុលបង្ហាញពីការវិនិយោគខ្ពស់ ឬការចំណាយក្នុងការផលិតខ្ពស់ ដែលមានន័យថាវាអាចជាហានិភ័យខ្ពស់ក្នុងការខាតបង់ ក្នុងករណីដែលកើតមានគ្រោះមហន្តរាយធម្មជាតិ ឬសត្វល្អិត/ជំងឺដែលប៉ះពាល់ដល់ការផលិត និងអាចជាហានិភ័យក្នុងការកើនឡើងនៃប្រាក់បំណុលរបស់កសិកផងដែរ។

វិធីសាស្ត្រក្នុងការផលិតដែលបានប្រើ ឬបានណែនាំឲ្យប្រើអាចមានផលប៉ះពាល់ផ្សេងគ្នាទៅលើទុនធម្មជាតិរបស់កសិដ្ឋាន ការកំណត់សម្គាល់ពីដីដែលមានជីជាតិល្អ។ ចំណុចទាំងនេះត្រូវយកមកគិតពិចារណាពីតុល្យភាពនៃគុណសម្បត្តិ និងគុណវិបត្តិ។ ការទទួលបានប្រាក់ចំណូលខ្ពស់ក្នុងពេលបច្ចុប្បន្នអាចនឹងមិនមានតុល្យភាពគ្នា ព្រោះដីដែលមានជីវជាតិអាចថយចុះសម្រាប់រយៈពេលយូរខាងមុខ។

ទស្សនៈកន្លងមកពាក់ព័ន្ធវិធីសាស្ត្រក្នុងការផលិតដោយមានបច្ចេកទេសដែលបានប្រើ ឬបានណែនាំឲ្យប្រើ៖ ម៉ូឌែលនេះអាចត្រូវបានស្នើរឡើងនៅក្នុងវិធីដែលជាស្តង់ដារមួយសម្រាប់អ្នកផលិតមួយចំនួនដែលមិនមានធនធានដូចគ្នា នៅក្នុងលក្ខខណ្ឌនៃកត្តាផលិតកម្ម (ដី កម្មករ ទុន)។ ការសម្របខ្លួនពីមួយករណីទៅមួយករណីសម្រាប់ស្ថានភាពកសិករម្នាក់ៗ មិនមែនចេះតែកើតមាន ឬធ្វើទៅបាននោះទេ រួមទាំងការប្រឹងប្រែងដើម្បីជ្រើសរើសកសិករ[2] ដែលមានលទ្ធភាពជាងគេក្នុងការសម្របខ្លួនមកធ្វើជាមួយម៉ូឌែលដែលបានស្នើរឲ្យប្រើ តែងតែមិនសូវមានអ្នកធ្វើបានឡើយ។

តម្លៃដែលទទួលបានមិនមែនតែងតែខ្ពស់នោះទេ អាស្រ័យទៅតាមលក្ខខណ្ឌក្នុងការកំណត់តម្លៃនិងឯកសារយោងនៃតម្លៃដែលបានប្រើប្រាស់។

ការចូលរួមផលិតកម្មកសិកម្មតាមកិច្ចសន្យា អាចមានអត្ថន័យពិសេសបន្ថែមទៀតសម្រាប់កសិករ ៖

ការបែងចែកកត្តាផលិតកម្មជាច្រើនទៀត ( ដី ជាចម្បង ) ចំពោះផលិតកម្មដូចគ្នា ( ដំណាំដូចគ្នា ពូជដូចគ្នា) ដើម្បីកាត់បន្ថយប្រភេទផ្សេងគ្នាច្រើន ដែលទាំងនេះមានភាពងាយរងគ្រោះខ្លាំងទៅនឹងហានិភ័យនានា (ឬមានភាពធន់តិចតួច)។

សមត្ថភាពនៅមានកម្រិតក្នុងការតវ៉ា ឬការការពារសិទ្ធិរបស់ពួកគេក្នុងករណីមិនធ្វើតាមលំនាំដើមកិច្ចសន្យា។

ការកាត់បន្ថយស្វ័យភាពក្នុងការសម្រេចចិត្តទៅលើការគ្រប់គ្រងកសិដ្ឋាន។

---

[2] សូមមើលការចេញផ្សាយជាពិសេសរបស់សាកលវិទ្យាល័យ Wageningen ៖ Ton G.; Mheen-Sluijer; J. van der (២០០៩)៖ “បញ្ជីត្រួតពិនិត្យផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងលើបញ្ហាសំខាន់ៗក្នុងការរៀបចំផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីអភិវឌ្ឍន៍ប្រទេស”។

### ១.២.៣. លក្ខខណ្ឌទូទៅមួយចំនួនដែលត្រូវពិចារណាសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីផ្តល់ផលប្រយោជន៍ជូនគ្រួសារកសិករ

ជារួមកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា អាចផ្តល់នូវឱកាសសម្រាប់កសិករដើម្បីបង្កើតប្រាក់ចំណូលបន្ថែមទៀតពីសកម្មភាពធ្វើកសិកម្មរបស់ពួកគេ ប៉ុន្តែផលិតកម្មកសិកម្មតាមកិច្ចសន្យាមិនបានបង្កើតផលប្រយោជន៍ដោយឯងៗសម្រាប់កសិករនោះទេ ហើយផលប៉ះពាល់ទៅលើជីវភាពរស់នៅ គឺពឹងផ្អែកតែលើលក្ខខណ្ឌនៃកិច្ចសន្យាដែលបានចរចា។

ការចូលរួមរបស់អង្គការកសិករប្រសើរជាងកសិករតែម្នាក់ៗគឺជាអ្វីដែលគេចង់បាន ពីព្រោះវាអាចជួយបង្កើនអំណាចរបស់កសិករក្នុងការតថ្លៃ និងសមត្ថភាពក្នុងការចរចាក្នុងកិច្ចសន្យា។ អង្គការផ្តល់ការគាំទ្រ (រដ្ឋបាលសាធារណៈ អង្គការមិនមែនរដ្ឋាភិបាល សហព័ន្ធអង្គការកសិករ គម្រោងនានា ។ល។) អាចផ្តល់ការគាំទ្រដើម្បីធ្វើការវិភាគទៅលើលក្ខខណ្ឌនៃកិច្ចសន្យា និងធ្វើការវាយតម្លៃពីផលប្រយោជន៍ និងហានិភ័យ ហើយត្រូវធានាថាលក្ខខណ្ឌនៃកិច្ចព្រមព្រៀងគឺបានយល់យ៉ាងច្បាស់លាស់។

តាមលទ្ធភាពដែលអាចធ្វើបាន វាអាចជាការអនុគ្រោះមួយប្រសិនបើ កិច្ចសន្យាអាចធានាពីតម្លៃអប្បបរមាមួយ ដើម្បីរ៉ាប់រងលើការចំណាយរបស់ផលិតកម្ម និងបន្សល់ទុកប្រាក់កម្រៃសមរម្យសម្រាប់ការងាររបស់កសិករ។ នេះជារឿងមួយដែលគេចង់បានផងដែរក្នុងការរក្សាកម្រិតច្បាស់លាស់មួយនៃប្រភេទផលិតផលខុសៗគ្នា សម្រាប់សកម្មភាពផលិតកម្មក្នុងកសិដ្ឋានដើម្បីកាត់បន្ថយការប៉ះពាល់នៃហានិភ័យ។

## ១.៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ម៉ូឌែលអាជីវកម្មមួយណា?

ផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចមើលឃើញថាជាឧបករណ៍ពាក់ព័ន្ធជាក់លាក់មួយទៅតាមស្ថានភាពដូចខាងក្រោម៖

១. ដើម្បីបង្ហាញពីផលិតកម្មថ្មីក្នុងតំបន់ដល់កសិករ ហើយអ្វីទាំងនោះមិនទាន់មានបណ្តាញណាបង្កើតទុកមុនសម្រាប់ការប្រមូលក្នុងស្រុកទេ។ ករណីនេះផលិតកម្មកសិកម្មតាមកិច្ចសន្យានឹងនាំមកនូវសន្តិសុខទីផ្សារ ដែលកសិករចាប់ផ្តើមផលិតកម្មថ្មី ដែលមិនអាចមានឱកាសសម្រាប់ទីផ្សារដទៃទៀតទេ។

២. បង្ហាញពីភាពផ្លាស់ប្តូរនៃវិធីសាស្ត្រផលិតកម្ម ដោយប្រៀបធៀបទៅនឹងការអនុវត្តនាពេលបច្ចុប្បន្នរបស់កសិករ (ឧ. ពូជ ប្រភេទជាក់លាក់នៃធាតុចូល ដំណាំ និងសត្វ ។ល។)ដែលធ្វើផលិតផលឲ្យមានគុណភាពខុសគ្នា ជាមួយនឹងតម្លៃបន្ថែម។ ផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងករណីនេះ វាមានការពាក់ព័ន្ធជាក់លាក់ប្រសិនបើការគាំទ្រពីអ្នកចុះកិច្ចសន្យា ជួយដល់កសិករក្នុងការប្រើប្រាស់ធាតុចូល និងបច្ចេកទេសដែលពួកគេអាចមានលទ្ធភាពយកមកប្រើ ប៉ុន្តែប្រសិនបើការផ្លាស់ប្តូរក្នុងការអនុវត្ត ហើយគុណភាពនៃធាតុចេញត្រូវបានលើកទឹកចិត្តជាតម្លៃខ្ពស់ (ឬដោយបង្កើនផលិតភាព)។

៣. ដើម្បីធានាពីកម្រិតនៃការតាមដាន ឬព័ត៌មានទៅលើវិធីសាស្ត្រនៃការផលិតដែលតម្រូវសម្រាប់អ្នកទិញដើម្បីអាចឈានទៅដល់កម្រិតស្តង់ដារជាក់លាក់មួយ ឬមានវិញ្ញាបនបត្របញ្ជាក់ ដែលនឹងអាចមានតម្លៃបន្ថែមទៀតសម្រាប់ទីផ្សារ។ ផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្នុងករណីបែបនេះក៏អាចទទួលជោគជ័យផងដែរ តាមការផ្តល់ផ្នែកដែលមានតម្លៃបន្ថែម ដែលមានវិញ្ញាបនបត្របញ្ជាក់ដែលទទួលបានរួចយកមកចែករំលែកជាមួយអ្នកផលិត។

ចំណាំថា ចំពោះស្ថានភាពទី ១ ខាងលើ កិច្ចសន្យាចំពោះតម្លៃថេរមួយអាចមានការពាក់ព័ន្ធ ខណៈដែលស្ថានភាពម៉ូឌែលទី ២ និង ទី ៣ "តម្លៃនៅទីផ្សារ + បុព្វលាភ" គឺ ភាគច្រើនបំផុតអាចទទួលយកបាន (មើលផ្នែក ៤.៧. នៅក្នុងសៀវភៅណែនាំនេះ)

## ការពន្យល់បន្ថែម ១.៣.ក

### ផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ផលិតកម្មរមៀតដោយក្រុមហ៊ុន AKAY នៅបាត់ដំបង

AKAY គឺជាក្រុមហ៊ុនឥណ្ឌាមួយដែលបានចាប់ផ្តើមធ្វើការអភិវឌ្ឍផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយកសិករនៅខេត្តបាត់ដំបង សម្រាប់ផលិតកម្មរមៀត។

សម្រាប់ AKAY ផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺជាវិធីសាស្ត្រមួយក្នុងការផ្គត់ផ្គង់បរិមាណច្រើននៃផលិតកម្មរមៀតដែលមានគុណភាពល្អពីកម្ពុជា (ដែលមានកម្រិតជាតិម្សៅរមៀតខ្ពស់) ដែលការវិនិយោគលើផ្ទៃដីមានកម្រិត ។ ផលិតផលរមៀតអាចបង្ហាញពីឱកាសសម្រាប់ការដាំដំណាំ (និងមានប្រាក់ចំណូល) ប្រភេទផ្សេងទៀតសម្រាប់កសិករដែលអាចធ្វើទៅបាន ក្នុងទំហំធំមួយ តាមរយៈភាពជាដៃគូជាមួយក្រុមហ៊ុននេះ ព្រោះថាទីផ្សារនៅមានកម្រិតនៅឡើយ (មិនមានសង្វាក់តម្លៃនាំចេញនៃផលិតផលរមៀតក្នុងប្រទេសកម្ពុជាមុនការវិនិយោគរបស់ក្រុមហ៊ុន AKAY ។

ហានិភ័យទីផ្សារនានាត្រូវបានការពារសម្រាប់កសិករដោយសារតែកិច្ចសន្យាបានបង្កើតឡើងក្នុងតម្លៃថេរមួយ។ ក្រៅពីនេះការផ្តល់ជំនួយបច្ចេកទេសពីក្រុមហ៊ុន ( ឧទាហរណ៍ ការគាំទ្រដល់ការវិនិយោគលើធារាសាស្ត្រ) ដែលផ្តល់សន្តិសុខល្អមួយដល់ការផលិត។ ម្យ៉ាងទៀតហានិភ័យក៏នៅមានកម្រិតដោយសាររមៀតជាទូទៅគ្រាន់តែជាដំណាំបន្ទាប់បន្សំសម្រាប់កសិករ និងរួមចំណែកដល់យុទ្ធសាស្ត្រក្នុងការបង្កើតឲ្យមានដំណាំផ្សេងៗគ្នាច្រើន។



◁ចំការរមៀត ក្រោមផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តបាត់ដំបង (រូបភាព. Akay)

នៅក្នុងបរិយាកាសមួយដែលអ្នកផលិតមានទំនាក់ទំនងជាមួយអ្នកទិញ ដែលមានសក្តានុពលច្រើនសម្រាប់ផលិតផលរបស់ពួកគេ ផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីផលិត ផលិតផលមួយចំនួនតាមធម្មតា ហើយទិញក្នុងតម្លៃតាមធម្មតានោះគឺវាគ្មានប្រយោជន៍ឡើយ។ ដំណើរការនៃការចរចាអំពីការព្រមព្រៀងលើផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការសម្របសម្រួលនៃការអនុវត្តរបស់ខ្លួនតែងតែឈានដល់តម្លៃមួយដែលខ្ពស់សម្រាប់ក្រុមហ៊ុន ដែលទទួលការផ្គត់ផ្គង់ផ្ទាល់តាមរយៈបណ្តាញប្រមូលទិញដែលមានស្រាប់។ ករណីដែលការផលិតក្នុងស្រុក និងទីផ្សារក្នុងស្រុកមានការរីកចម្រើនសម្រាប់ផលិតផលទាំងនេះ ហើយប្រសិនបើគោលបំណងនេះគឺដើម្បីទទួលបានគុណភាពផលិតផលដដែលដូចអ្វីដែលត្រូវបានផ្តល់ជូនរួចទៅហើយ នៅតម្លៃទីផ្សារ នៅពេលនោះផលិតកម្មកសិកម្មតាមកិច្ចសន្យាវាមិនមានការចាំបាច់ទេ ហើយទំនងជានឹងអាចចំណាយច្រើនជាងសង្វាក់ផ្គត់ផ្គង់តាមទំលាប់ពីមុនសម្រាប់អ្នកទិញ។

# ផ្នែកទី ២៖ បរិបទនៃផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា

## ២.១. ប្រវត្តិនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា

### ២.១.១. លក្ខណៈពិសេសនៃការអភិវឌ្ឍបច្ចុប្បន្ននៅក្នុងវិស័យកសិកម្មកម្ពុជា

កសិកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានចំនួនប្រហែល ២៦.៣% ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ ២០១៦ ក្នុងនោះសម្រាប់ផ្នែកដំណាំមានចំនួន ៦២,៣៩% ផ្នែកផលិតកម្មសត្វ ១១,៩៦% ផ្នែកជលផល ២៤,២៦% និងផ្នែកព្រៃឈើ ៧,១៩% (របាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦)។ ប្រជាជនក្រីក្រមានជាង ៩០ ភាគរយ រស់នៅតំបន់ជាច់ស្រយាល និងពឹងផ្អែកលើវិស័យកសិកម្ម សម្រាប់ប្រភពដ៏ចម្បងនៃជីវភាពរស់នៅរបស់ពួកគេ។ វិស័យនេះត្រូវបានកំណត់ដោយការធ្វើកសិកម្មខ្នាតតូចប្រហែល ៤០ ភាគរយនៃកសិករ ដែលមានដីកសិកម្មតិចជាងមួយហិកតា។ ចាប់ពីមួយទៅពីរទសវត្សមកហើយវិស័យកសិកម្មនៅកម្ពុជាកំពុងមានការប្រែប្រួល ដោយមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់អំពីផលិតកម្មនៅតំបន់ខ្ពង់រាប។ ដំណាំសម្រាប់កែច្នៃបែបឧស្សាហកម្មកំពុងមានការកើនឡើងនៅក្នុងតំបន់ទាំងនេះជាមួយនឹងការអភិវឌ្ឍគួរឱ្យកត់សម្គាល់នៃផលិតផលកៅស៊ូដំឡូងមី និងស្វាយចន្ទី។ ការអភិវឌ្ឍផលិតកម្មសត្វចិញ្ចឹមដែលមានការកើនឡើងច្រើនជាងមុនគឺជានិន្នាការដែលកំពុងដើបឡើងក្នុងរយៈពេលដូចគ្នានេះ។ ជាចុងក្រោយលក្ខណៈពិសេសនាពេលថ្មីៗនេះនៃការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា គឺជាការតម្រង់ទិសដែលកំពុងកើនឡើងឆ្ពោះទៅរកទីផ្សារនាំចេញក្នុងវិស័យតូចៗ (ដូចជាអង្ករដំឡូងមីគ្រឿងទេស កៅស៊ូ.....) ដែលនាំមកនូវការផ្លាស់ប្តូរដោយមានការយកចិត្តទុកដាក់ចំពោះគុណភាព និងស្តង់ដារ។ នេះគឺជាការផ្លាស់ប្តូរយ៉ាងសំខាន់មួយ ប៉ុន្តែនៅក្នុងទសវត្សមុន ផលិតកម្មស្ទើរតែទាំងអស់ផ្តោតជាចម្បងលើទីផ្សារក្នុងស្រុក។ ផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចជាមធ្យោបាយមួយក្នុងការតភ្ជាប់អ្នកផលិតទៅនឹងទីផ្សារនាំចេញ ប៉ុន្តែក៏សម្រាប់អ្នកនាំចេញដើម្បីដើរឱ្យទាន់ការវិវត្តនៃផលិតកម្ម ហើយនឹងការផ្លាស់ប្តូរដែលចាំបាច់ដើម្បីពង្រឹងគុណភាព ការអនុលោមតាមស្តង់ដារ និងភាពអាចតាមដានថយក្រោយបាន។

ដើម្បីកែលំអផលិតភាពកសិកម្ម និងទីផ្សារសម្រាប់ផលិតផលកសិកម្ម រដ្ឋាភិបាលបាននឹងកំពុងលើកកម្ពស់ផលិតកម្មកសិកម្មតាមកិច្ចសន្យា ជាមធ្យោបាយនៃការលុបបំបាត់ឧបសគ្គមួយចំនួនលើកំណើនផ្នែកកសិកម្ម រួមទាំងការតភ្ជាប់ផ្នែកកសិកម្មចំពោះទីផ្សារធាតុចូល និងធាតុចេញ។ បញ្ហាប្រឈមសំខាន់ៗ រួមមានធាតុចូលរបស់ផលិតកម្មដែលពិបាកទទួលបាននិងមានតម្លៃថ្លៃ ជាញឹកញាប់ដោយសារតែកង្វះខាតការផ្គត់ផ្គង់នឹងតម្លៃខ្ពស់ គុណភាពជីមិនអាចទុកចិត្តបាន និងគុណភាពមិនល្អដែលនាំឱ្យទិន្នផលធ្លាក់ចុះ អត្រាការប្រាក់ឥណទាន និងបំណុលខ្ពស់ ព្រមទាំងកង្វះខាតជំនួយបច្ចេកទេសផងដែរ។ ផលិតកម្មកសិកម្មតាមកិច្ចសន្យាបានផ្តល់ឱកាសដល់កសិករខ្នាតតូចក្នុងការចូលរួមវេទិកាពាណិជ្ជកម្មដែលគេបានបង្កើតឡើង មានឫសគល់ក្នុងក្របខណ្ឌស្ថាប័នល្អៗដែលផ្តល់ជូននូវតម្លៃសមរម្យជាងមុន និងតម្រូវការមានស្ថេរភាពជាងមុន។

ផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានគេមើលឃើញយ៉ាងច្បាស់ថាជាយន្តការដែលមានប្រសិទ្ធភាពដើម្បីបង្កើនការដាក់បញ្ចូល និងផលប្រយោជន៍សម្រាប់ កសិករខ្នាតតូច[3] ខណៈពេលដែលផលិតកម្មកសិកម្មតាមកិច្ចសន្យាផ្ដល់ការគ្រប់គ្រងមួយចំនួនលើផលិតកម្មដល់កសិវប្បកម្ម ដោយមិនទាមទារកម្មសិទ្ធិដីធ្លី។ នៅក្នុងប្រទេសកម្ពុជា ផលិតកម្មកសិកម្មតាមកិច្ចសន្យា មានច្រើនទម្រង់ ហើយពាក់ព័ន្ធនឹងដំណាំឧស្សាហកម្មនិងម្ហូបអាហារ។ រហូតមកដល់ពេលនេះមានការកំណត់វិធានគាំទ្រពីរដ្ឋាភិបាល៖ ភាគច្រើននៃគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាដំណើរការដោយភ្នាក់ងារគាំទ្រនឹង ភាគីអ្នកទិញជាមួយឯកសារកិច្ចសន្យា (រូបមន្តនិងទម្រង់) រៀបចំដោយភាគីអ្នកទិញ ដោយមិនមានការតវ៉ាចំពោះយន្តការកាសម្របសម្រួល។

ដោយគិតពីសក្ដានុពល និងនិន្នាការសម្រាប់ការអភិវឌ្ឍផលិតកម្មកសិកម្មតាមកិច្ចសន្យាថែមទាំងហានិភ័យនិងករណីបរាជ័យដែលកើតមានពីមុន រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៣៦អនក្រ.បកស្ដីពី"**ផលិតកម្មកសិកម្មតាមកិច្ចសន្យា**" ចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ (សូមមើលក្នុងឧបសម្ព័ន្ធ ១)។ នៅក្នុងអនុក្រឹត្យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នបង្គោលក្នុងការភ្ជាប់ទំនាក់ទំនងឲ្យមានភាពជាដៃគូចុះកិច្ចសន្យា និងជួយសម្របសម្រួលរៀបចំកិច្ចសន្យា និងដោះស្រាយពេលមានវិវាទឡើងនៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា ហើយក៏បានបង្កើតគណៈកម្មាធិការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា (CFCC) ដែលមានតួនាទីទទួលខុសត្រូវខ្ពស់ក្នុងការរៀបចំគោលនយោបាយធ្វើផែនការយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ផលិតកម្មកសិកម្មតាមកិច្ចសន្យា ពង្រឹងសុខដុមនីយកម្មរវាងភាគីដែលបានចុះកិច្ចសន្យា និងធ្វើអន្តរាគមន៍ឬដោះស្រាយជម្លោះដែលកើតចេញពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រំពឹងទុកថាជាមួយក្របខណ្ឌនេះការលើកកម្ពស់ផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីជួយពង្រឹងផលិតភាពកសិកម្ម និងប្រាក់ចំណូលតាមតំបន់ដាច់ស្រយាល នឹងមានប្រសិទ្ធភាពជាងពេលកន្លងមក។ យ៉ាងណា នៅមានបញ្ហាជាច្រើនទៀតដែលត្រូវដោះស្រាយ និងពង្រឹងបន្ថែមក្នុងគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា។ កន្លងមកនេះក្រោយពីការចេញអនុក្រឹត្យលេខ៣៦ អនក្រ.បក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនឯកជន និងដៃគូរអភិវឌ្ឍន៍នានាកំពុងធ្វើការសាកល្បងអំពីផលិតផលកសិកម្មតាមកិច្ចសន្យា និងមានគោលដៅស្វែងរកម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលអាចបង្កើនផលប្រយោជន៍ទាំងកសិករខ្នាតតូច និងក្រុមហ៊ុនប្រមូលទិញ។ ថ្មីៗនេះទៀត ក្រសួងកសិកម្ម បានចេញជាសារាចរណែនាំលេខ ១៩៦សរណន.កសក.ស្ដីអំពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០១៧ ដែលបានចង្អុលបង្ហាញនូវដំណើរការស្នើសុំអនុវត្ត និងស្ថាប័នបង្គោលក្នុងការជួយផ្គូរផ្គងស្វែងរកដៃគូ សម្របសម្រួលរៀបចំកិច្ចសន្យាដល់ភាគីដែលមានបំណងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបានស្នើម៉ូឌែលនៃទម្រង់ធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា (សូមមើលក្នុងឧបសម្ព័ន ៤ និងជំពូក ៤ ក្នុងសៀវភៅណែនាំ) ហើយមានបំណងធ្វើការអភិវឌ្ឍយន្តការនិងគោលនយោបាយគាំទ្របន្ថែមសម្រាប់ការអភិវឌ្ឍន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា។

[3] ឱកាស និងហានិភ័យនានាសម្រាប់កសិករខ្នាតតូចដែលមាននៅក្នុង ផ្នែកទី១.២.

## ២.១.២. បទពិសោធន៍បច្ចុប្បន្ននៃផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា

ការអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅមិនទាន់មានការរីករាលដាលទូលំទូលាយក្នុងប្រទេសកម្ពុជានៅឡើយទេ។ ប៉ុន្តែក្នុងកំឡុងពេលដប់ទៅដប់ប្រាំឆ្នាំចុងក្រោយនេះ មានករណី និមិត្តរូបមួយចំនួន (ពិតជាជោគជ័យ) នៃភាពជាដៃគូផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងក្រុមហ៊ុនដែលចូលរួមក្នុងការកែច្នៃនឹងផ្គួញផ្គង់ផលិតកម្មកសិកម្ម និងកសិករ។ ក្នុងចំណោមការអភិវឌ្ឍល្បីបំផុតគឺ ការអភិវឌ្ឍន៍ផលិតផលថ្នាំជក់ក្រោមគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលអនុវត្តដោយក្រុមហ៊ុនថ្នាំជក់អាមេរិក និងអង់គ្លេស *(BAT)- សូមមើលការពន្យល់លើសង្ខេប ២.១.ក ខាងក្រោមការអភិវឌ្ឍផលិតកម្មស្រូវក្រអូបក្រោមកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយក្រុមហ៊ុនអង្គរកសិកម្មរុងរឿង* (AKR) -សូមមើលក្នុងការពន្យល់លើសង្ខេប២.១.ខ ទំព័របន្ទាប់ - ឬការអភិវឌ្ឍផលិតកម្មសត្វចិញ្ចឹម និងម៉ូឌែលរួមបញ្ចូលគ្នាដែលផ្សព្វផ្សាយដោយក្រុមហ៊ុន CP Group ។

យើងក៏អាចលើកឡើងអំពីផលិតកម្មស្រូវ និងគម្រោងទិញដែលបង្កើតឡើងដោយអង្គការសេដាក់ (CEDAC) សម្រាប់អង្ករផ្ការំដួលសរីរាង្គ។ នេះជាករណីក្រៅផ្លូវការមួយស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ( មានតែការប្តេជ្ញាចិត្តផ្ទាល់មាត់តែប៉ុណ្ណោះ) ប៉ុន្តែត្រូវបានពង្រីកក្នុងកម្រិតទ្រង់ទ្រាយធំ (រហូតដល់ទៅ ២.៣៥០ គ្រួសារដែលបានចូលរួម)។

### ការពន្យល់បន្ថែម ២.១.ក

### គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយ British American Tobacco (BAT នៅកំពង់ចាម[4]

BAT បានអភិវឌ្ឍន៍ផលិតកម្ម និងប្រមូលប្រភពនៃស្លឹកថ្នាំជក់ស្ងួតៗ តាមរយៈគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយនឹងអ្នកផលិតបែបបុគ្គលៗ។ គម្រោងមួយនេះមានកសិករឡើងដល់ ១០០០ នាក់ ក្នុងឆ្នាំ ២០១០ ( ប៉ុន្តែសព្វថ្ងៃបានថយចុះ មានអ្នកដាំតែត្រឹម ៣៥០ នាក់ប៉ុណ្ណោះដោយសារតម្រូវការថយចុះ)។ ការផ្គត់ផ្គង់សម្រេចបានរហូតដល់ ២០០០ តោននៃស្លឹកស្ងួត។

គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះអាចត្រូវបានចាត់ទុកថាជាគំរូប្រមូលផ្តុំ (បើទោះ ភាគីមួយចំនួនផ្សេងទៀតបានចូលរួមក៏ដោយ ប៉ុន្តែជាចម្បងដូចជាអ្នកផ្តល់សេវាដែលចុះកិច្ចសន្យាដោយក្រុមហ៊ុនថ្នាំជក់ BAT ដូចជា មន្ទីរកសិកម្ម ដែលផ្តល់ការបណ្តុះបណ្តាល IPM ដល់កសិករ ឬអង្គការសេដាកដែលចុះកិច្ចសន្យាដើម្បីផ្តល់ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឲ្យមានសុវត្ថិភាព)។

ក្រៅពីការបណ្តុះបណ្តាលខាងក្រៅ បុគ្គលិកសហគមន៍របស់ BAT ផ្តល់ការបណ្តុះបណ្តាលស្តីពីផលិតកម្មបច្ចេកទេសដែលចាប់ផ្តើមនៅដំណាក់កាលដំបូងនៃការដាំរហូតដល់ប្រមូលផល និងក្រោយប្រមូលផល (ការសម្ងួត)។ ការគាំទ្រផ្នែកបច្ចេកទេសដល់កសិកគឺមានកម្រិតខ្ពស់ បុគ្គលិកសហគមន៍ម្នាក់ទទួលខុសត្រូវលើអ្នកដាំថ្នាំជក់ចំនួន ២០ នាក់។

កសិករត្រូវបានគេជ្រើសរើសនៅក្នុងតំបន់ដែលនៅជិតនឹងរោងចក្រក្រុមហ៊ុនថ្នាំជក់ BAT និងផ្អែកលើកត្តាផ្សេងៗគ្នាមានដូចជា៖ ការជំរុញទឹកចិត្តរបស់ពួកគេផងដែរ។ បន្ថែមពីការគាំទ្របច្ចេកទេស ក្រុមហ៊ុនផ្តល់នូវគ្រាប់ពូជ (កូនកាត់នាំចូល) ដល់កសិករ ដោយឲ្យជំពាក់ និងផ្តល់ឥណទានផងដែរ សម្រាប់ការចំណាយលើធាតុចូលផ្សេងទៀតក្នុងចំនួនទឹកប្រាក់ ១០% នៃតម្លៃប៉ាន់ប្រមាណរបស់ដំណាំ។ ការចំណាយលើផលិតកម្មត្រូវគេរាប់បញ្ចូលក្នុងការកំណត់តម្លៃ។

[4] ផ្អែកលើការសិក្សាដែលបានអនុវត្តដោយអ្នកប្រឹក្សាយោបល់គម្រោងថ្នាក់ជាតិរបស់ DAI និង SCCRP..

ថ្មីៗនេះ គំនិតផ្តួចផ្តើមថ្មីនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាបានចាប់ផ្តើមរីកស្គុះស្គាយ។ កិច្ចសន្យាជាផ្លូវការត្រូវបានគេជួបប្រទះនៅក្នុងវិស័យស្រូវអង្ករ (ជាពិសេស ជាមួយនឹងការគាំទ្រ *គំរោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា)* ជាមួយនឹងករណីដែលទទួលបានជោគជ័យជាច្រើន (ឧទាហរណ៍ នៅក្នុងកិច្ចសន្យាដែលបានបង្កើតឡើងដោយក្រុមហ៊ុន AMRU និងក្រុមហ៊ុន Golden Rice ជាមួយអង្គការកសិករ)។ នៅក្នុងប៉ុន្មានឆ្នាំថ្មីនេះផងដែរ ម៉ូឌែលច្នៃប្រឌិតថ្មីបានចាប់ផ្តើមធ្វើការសាកល្បងដោយក្រុមហ៊ុនក្នុងស្រុក ឬអន្តរជាតិដូចជាក្រុមហ៊ុនដំឡូងមីកម្ពុជា (សម្រាប់ដំឡូងមី) ឬក្រុមហ៊ុនឥណ្ឌា Akay សម្រាប់ផលិតកម្មម្រេះ (សូមមើលការពន្យល់បន្ថែម ១.៣.ក នៅក្នុងផ្នែកមុន)។ ទាំងនេះអាចត្រូវបានចាត់ថ្នាក់ថាជា "គំរូប្រមូលផ្តុំ" នៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយផ្អែកតាមប្រភេទដែលបានបង្កើតឡើងនៅក្នុង ផ្នែក ១.១.២. ម៉ូឌែលផ្សេងគ្នានៃផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ពាក់ព័ន្ធនឹងក្រុមហ៊ុន BAT ឬ AKR ម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺស្ថិតនៅចំកណ្តាលក្នុងគំរូអាជីវកម្មរបស់ក្រុមហ៊ុនទាំងនេះ ហើយវាហាក់ដូចជារីកលូតលាស់ខ្លាំងសម្រាប់វិស័យកសិ-ឧស្សាហកម្មកែច្នៃដោយផ្តោតលើទីផ្សារនាំចេញ។

ក្រៅពីករណីដែលលេចធ្លោទាំងនេះ ក៏មានកិច្ចព្រមព្រៀងក្រៅផ្លូវការមួយចំនួនផងដែរ រវាងក្រុមហ៊ុនតូចៗ ឬឈ្មួញកណ្តាលដែលគេជួបប្រទះនៅពេលមានការផ្តួចផ្តើមផ្ទាល់របស់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចទាំងនេះ។ កិច្ចព្រមព្រៀងទាំងនេះជាញឹកញាប់ធ្វើឡើងដោយផ្ទាល់មាត់ និងផ្អែកលើការវិនិយោគមានកម្រិតដោយភាគីអ្នកទិញ (ពីរបី - ប្រសិនបើមាន - ធាតុចូល/សេវាដែលបានផ្តល់ដល់កសិករដោយភាគីអ្នកទិញ និងពីតិចតួចដល់គ្មានព័ត៌មានលម្អិតអំពីផលិតផល) ។

## ការពន្យល់បន្ថែម ២.១.៥

### គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយអង្គរកសិកម្មរុងរឿង ជាមួយកសិករ[5]

ក្រុមហ៊ុន អង្គរកសិកម្មរុងរឿងបានអនុវត្តម៉ូឌែលផលិតកម្មកសិកម្មតាមកិច្ចសន្យា (ដែលអាចបង្កលក្ខណៈសម្បត្តិជា "គំរូប្រមូលផ្តុំ" តាមការចាត់ថ្នាក់ដែលបានបង្ហាញនៅក្នុង ផ្នែក ១.១.២. ម៉ូឌែលផ្សេងគ្នានៃផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ក្នុងឆ្នាំ ១៩៩៩ ក្រុមហ៊ុន AKR បានចាប់ផ្តើមធ្វើការជាមួយគ្រួសារ ប្រមាណ ២០០០ គ្រួសារនៃកសិករខ្នាតតូច (ជាមធ្យមប្រហែល ២ ហិកតា) សម្រាប់ផលិតកម្មស្រូវ និងបានឈានដល់ជាង ៣០.០០០ គ្រួសារ នៅក្នុងខេត្តចំនួនបួន (កំពង់ស្ពឺ កណ្តាល តាកែវ និងកំពត) នៅកម្រិតខ្ពស់នៃការអភិវឌ្ឍម៉ូឌែលនេះ។ នេះគឺដើម្បីកំណត់កាលបរិច្ឆេទមួយនៃគម្រោងធំបំផុតចំពោះផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលមិនធ្លាប់មាននៅក្នុងប្រទេសកម្ពុជា។ ក្នុងម៉ូឌែលរបស់ AKR ក្រុមហ៊ុននេះផ្តល់ជូននូវជំនួយបច្ចេកទេស និងធាតុចូល (គ្រាប់ពូជ) ដោយផ្ទាល់ដល់កសិករ និងបន្ទាប់មកទិញស្រូវមកវិញដោយមានព័ត៌មានផលិតផលម៉ត់ចត់។ កសិករផ្តល់ជូនដីធ្លី និងពលកម្ម ហើយគុណភាពផលិតផលគឺត្រូវពិនិត្យដោយបុគ្គលិកបច្ចេកទេសនៅក្នុងក្រុមហ៊ុន។




កិច្ចសន្យានេះបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការលើកកម្ពស់ និងពង្រីកដំណាំពូជស្រូវក្រអូប (បានធ្វើពាណិជ្ជូបនីយកម្មដោយក្រុមហ៊ុន AKR មានឈ្មោះថា "នាងម្លិះ") ដែលជំនួសឲ្យពូជប្រពៃណីដែលមានតម្លៃទាប ដាំដុះដោយកសិករ។ បើទោះបីជាទំហំនៃគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះត្រូវបានកាត់បន្ថយនៅប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ផ្នែកខ្លះនៃការផ្លាស់ប្តូរដែលផលិតកម្មកសិកម្មតាមកិច្ចសន្យាបានផលិតចេញជាផលិតកម្មស្រូវនៅតែត្រូវបានទ្រទ្រង់ ជាពិសេសនៅក្នុងរយៈពេលនៃការធ្វើឲ្យប្រសើរឡើងនៃគុណភាពស្រូវដែលបានផលិតដោយកសិករដែលចូលរួមនៅក្នុងគម្រោងនេះ។ ដូច្នេះ ផលិតកម្មកសិកម្មតាមកិច្ចសន្យានេះមានឥទ្ធិពលលើវិស័យស្រូវអង្ករទាំងមូល ហើយមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ក្រុមហ៊ុនដែលបានអនុវត្តប៉ុណ្ណោះទេ។

---

[5] ផ្អែកលើការសិក្សាខាងក្រោម៖ Dani, Selvie (២០១៤)៖ "Étude sur les Pratiques de l'Agriculture Contractuelle pour la Culture du Riz au Cambodge"។

### ការពន្យល់បន្ថែម ២.១.គ

### គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយក្រុមហ៊ុន AMRU Rice (Cambodia) Co. Ltd និងសហគមន៍កសិកម្មនៅព្រះវិហារសម្រាប់ផ្គត់ផ្គង់ស្រូវសរីរាង្គ

ក្រុមហ៊ុន AMRU Rice (Cambodia) Co. Ltd បានបង្កើតសង្វាក់ផ្គត់ផ្គង់ស្រូវសរីរាង្គសម្រាប់គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្មជាច្រើនកន្លែងនៅក្នុងខេត្តព្រះវិហារ។ គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះអាចត្រូវបានចាត់ទុកថាជា "ម៉ូដែលអន្តរការី" សហគមន៍នេះបានដើរតួនាទីជាចំណុចប្រទាក់ក្តាររវាងសមាជិករបស់ខ្លួន និងក្រុមហ៊ុន។

នៅឆ្នាំ ២០១៦ កសិករជាង ១៦០០ នាក់ (មកពី ១២ សហគមន៍) បានចូលរួមនៅក្នុងគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ និងស្រូវសរីរាង្គ ៨០០០ តោន (ផ្អែកលើស្តង់ដារសរីរាង្គសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក) ត្រូវបានផ្គត់ផ្គង់ទៅឲ្យក្រុមហ៊ុន AMRU Rice ។

នៅពេលដែលវាបានក្លាយជាស្រូវសរីរាង្គមានវិញ្ញាបនបត្របញ្ជាក់ ពេលនោះនឹងមានភាពចាំបាច់ដាច់ខាតសម្រាប់ភាគីទាំងពីរ ដើម្បីធានាសុវត្ថិភាពតំណពាណិជ្ជកម្មរបស់ពួកគេរយៈពេលវែង មុនពេលការប្រមូលផល៖ សម្រាប់សហគមន៍ដែលកំពុងវិនិយោគនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាបាននូវការបញ្ជាក់គុណភាព វាចាំបាច់ត្រូវប្រាកដថា ពួកគេនឹងលក់ទៅឲ្យឈ្មួញម្នាក់ក្នុងចំណោមឈ្មួញតិចតួចដែលមានសក្តានុពល ដែលត្រៀមខ្លួនជាស្រេចក្នុងការបង់បុព្វលាភស្រូវសរីរាង្គ។ តាមទស្សនៈរបស់ក្រុមហ៊ុននាំចេញ ដោយសារតែគាត់បានចាប់ផ្តើមរៀបចំកិច្ចព្រមព្រៀងជាមួយអតិថិជនក្នុងការផ្តល់អង្ករសរីរាង្គ វាក៏មានសារៈសំខាន់ផងដែរ ដើម្បីប្រាកដថា គាត់នឹងចាប់យកការផ្គត់ផ្គង់នេះពីអ្នកផលិតមួយចំនួនតូច ដែលមានប្រព័ន្ធត្រួតពិនិត្យគុណភាពផ្ទៃក្នុងនៅនឹងកន្លែង និងអាចផ្គត់ផ្គង់ស្រូវសរីរាង្គបាន ។ ដូច្នេះ ផលិតកម្មកសិកម្មតាមកិច្ចសន្យានេះគឺចាំបាច់សម្រាប់ភាគីទាំងពីរ និងមានការពាក់ព័ន្ធយ៉ាងខ្លាំងនៅក្នុងករណីនេះ។

ក្រុមហ៊ុនផ្តល់សំបកបាវ និងការបណ្តុះបណ្តាលបច្ចេកទេសទៅដល់ប្រធានសហគមន៍ស្តីពីការវាយតម្លៃគុណភាពស្រូវ។ ក្រុមហ៊ុនក៏ទទួលខុសត្រូវផងដែរក្នុងការដឹកជញ្ជូនផលិតផលពីចំណុចប្រមូលផលដែលបានព្រមព្រៀងនៅក្នុងភូមិ ទៅកាន់រោងម៉ាស៊ីនកិនស្រូវនេះ។ សហគមន៍ទទួលបន្ទុកត្រួតពិនិត្យផ្ទៃក្នុង និងការប្រមូលស្រូវ (ពីកសិករទៅដាក់កន្លែងប្រមូលផ្តុំ) និងការត្រួតពិនិត្យគុណភាព។ លើសពីនេះទៀត សហគមន៍បានបង្កើតសហភាពសហគមន៍ (ជាលើកដំបូងដែលបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា) តាមរយៈការដែលពួកគេធ្វើអញ្ញមញ្ញកម្មធនធាន ដើម្បីប្រមូលផ្តុំបុគ្គលិកជំនាញអចិន្ត្រៃយ៍ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងការធ្វើអធិការកិច្ចគ្រប់គ្រងផ្ទៃក្នុង ចងក្រងទិន្នន័យពីការគ្រប់គ្រងផ្ទៃក្នុង និងការទំនាក់ទំនងជាមួយស្ថាប័នចេញវិញ្ញាបនប័ត្របញ្ជាក់។

កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាមានប្រភេទពូជស្រូវផ្សេងៗគ្នា (ស្រូវក្រអូប ស្រូវស) កំណត់កម្រិតគុណភាពខុសៗគ្នា និងកំណត់ប្រព័ន្ធកំណត់តម្លៃដោយផ្អែកលើតម្លៃយោង + បុព្វលាភ។ បុព្វលាភប្រែប្រួលស្របតាមកម្រិតគុណភាព។ តម្លៃយោងផ្អែកលើតម្លៃតាមរោងម៉ាស៊ីននៅតាមខេត្តជិតៗ ដូចជាខេត្តកំពង់ធំ (តម្លៃយោងមាននៅខាងលើតម្លៃនៅតាមកសិដ្ឋានបានផ្តល់ដោយអ្នកប្រមូលទិញនៅក្នុងស្រុកក្នុងខេត្តព្រះវិហារ) ហើយបុព្វលាភសម្រាប់ស្រូវសរីរាង្គត្រូវដាក់បញ្ចូលបន្ថែម។

ឧទាហរណ៍ សម្រាប់ស្រូវក្រអូបស្ទូត (ការប្រមូលផល ឆ្នាំ ២០១៦) តម្លៃដែលបង់ដោយក្រុមហ៊ុន AMRU សម្រាប់ស្រូវសរីរាង្គអាចមានចំនួនប្រមាណពី ២៦% ទៅ ៤០% (អាស្រ័យលើកម្រិតគុណភាព) នៅខាងលើតម្លៃដែលបានផ្តល់ដោយអ្នកប្រមូលទិញក្នុងស្រុកសម្រាប់ស្រូវធម្មតាដូចគ្នា។ ផ្នែកមួយនៃតម្លៃបន្ថែមនេះបូករួមទាំងការចំណាយលើការគ្រប់គ្រងរបស់សហគមន៍ និងសហភាព ប៉ុន្តែភាគច្រើនត្រូវបានចាប់យកដោយកសិករ។

### ការពន្យល់បន្ថែម ២.១.ឃ

### គម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាចិញ្ចឹមជ្រូករបស់ក្រុមហ៊ុន ស៊ីភី កម្ពុជា

ក្រុមហ៊ុន CP Cambodia Co. Ltd គឺជាក្រុមហ៊ុនឯកជនដ៏ធំមួយក្នុងចំណោមក្រុមហ៊ុនដទៃទៀតដែលដឹកនាំផលិតកម្មកសិកម្មតាមកិច្ចសន្យានាំមុខគេជាមួយកសិករខ្នាតតូចលើកសិដ្ឋានផលិតមាន់ និងចិញ្ចឹមជ្រូក។ ក្រុមហ៊ុននេះកាន់កាប់ដោយអ្នកវិនិយោគិនជនជាតិថៃហើយមានទីតាំងស្ថិតនៅក្នុងស្រុកអង្គស្នួលខេត្តកណ្តាល។ មានរោងជ្រូកប្រហែល ៨០០ កន្លែងដែលបានចុះកិច្ចសន្យាក្នុងប្រទេសនៅឆ្នាំ ២០១៥-២០១៦។ ក្រុមហ៊ុន CP យល់ព្រមជួលកសិករជាប់កិច្ចសន្យា ឲ្យចិញ្ចឹមកូនជ្រូកពី ៥៥០ ដល់ ៦០០ ក្បាល។ ក្រុមហ៊ុន CP ទទួលខុសត្រូវលើការផ្តល់កូនជ្រូក ទំងន់ ១៥-២០ គីឡូក្រាម ចំណីសត្វ ថ្នាំ វ៉ាក់សាំង និងសម្ភារចាំបាច់នានាសម្រាប់ការចិញ្ចឹមជ្រូកជូនដល់កសិករជាប់កិច្ចសន្យា ផ្តល់យោបល់ស្តីពីនីតិវិធីចិញ្ចឹមជ្រូក រួមទាំងបច្ចេកទេសចិញ្ចឹម ការប្រើប្រាស់ថ្នាំ ការចាក់ថ្នាំបង្ការ និងការរៀបចំទ្រុង ហើយយល់ព្រមផ្តល់សំណងដល់កសិករជាប់កិច្ចសន្យា។ ចំណែកឯកសិករជាប់កិច្ចសន្យាត្រូវទទួលខុសត្រូវក្នុងការផ្តល់រោងជ្រូកដើម្បីចិញ្ចឹមកូនជ្រូករហូតដល់ពេលកំណត់។ រោងជ្រូកត្រូវសាងសង់ឡើងស្របតាមលក្ខណៈបច្ចេកទេសដែលបានផ្តល់ដោយក្រុមហ៊ុន CP ។ កសិករត្រូវពិនិត្យដោយប្រុងប្រយ័ត្ននូវរាល់ធាតុទាំងអស់ដែលបានផ្តល់ និងទទួលស្គាល់ការទទួលយក។ កសិករត្រូវរក្សាកំណត់ត្រានៃការចិញ្ចឹមជ្រូក ព្រមទាំងបញ្ជីសារពើភ័ណ្ឌនៃចំណីជ្រូក ថ្នាំព្យាបាល ថ្នាំវ៉ាក់សាំងបង្ការ និងសម្ភារផ្សេងទៀតនៅក្នុងសំណុំបែបបទដែលអនុម័តដោយក្រុមហ៊ុន CP ។ កសិករត្រូវផ្តល់កម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាព ក្នុងការចិញ្ចឹមជ្រូក និងការសម្អាតរោងជ្រូក និងជួយដល់ក្រុមហ៊ុន CP ក្នុងការដឹកជញ្ជូនជ្រូកធំៗ។ កសិករត្រូវទទួលបានរង្វាន់លើកទឹកចិត្ត ស្របតាមអនុបាតផ្លាស់ប្តូរការចិញ្ចឹម (FCR) ។ ប្រសិនបើជ្រូកបំប៉ននេះឈឺ ឬមិនមានសុខភាពល្អ ឬទម្ងន់របស់វាតិចជាង ៧០ គីឡូក្រាម ក្រុមហ៊ុន CP នឹងបោះបង់ជ្រូកប្រភេទនេះចោល។ កិច្ចសន្យារួមមានបទបញ្ញត្តិសម្រាប់ការពិន័យក្នុងករណីកសិករជាប់កិច្ចសន្យារំលោភលើលក្ខខណ្ឌក្នុងកិច្ចសន្យា។ ក្រុមហ៊ុន CP មានសិទ្ធិបញ្ចប់កិច្ចសន្យាដោយគ្មានការជូនដំណឹងជាមុនណាមួយឡើយ។ ក្រុមហ៊ុន CP នឹងឲ្យកសិករជាប់កិច្ចសន្យាបង់ប្រាក់ពិន័យនោះ។ កិច្ចសន្យាធ្វើឡើងតែរវាងភាគីទាំងពីរដែលបាន ចុះហត្ថលេខាបញ្ជាក់ថាពួកគេយល់យ៉ាងហ្មត់ចត់អំពីលក្ខខណ្ឌនៃកិច្ចសន្យានៅចំពោះមុខសាក្សី។

### ការពន្យល់បន្ថែម ២.១.ង
### ការរៀបចំផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយសហគមន៍កសិកម្មត្នោតកំពង់ស្ពឺ (KAMPATRACO)

សហគមន៍កសិកម្មដើមត្នោតខេត្តកំពង់ស្ពឺ (KAMPATRACO) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១ និងមានទីតាំងស្ថិតនៅភូមិត្រពាំងអន្ទង ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ហើយមានអ្នកផលិតស្ករត្នោតតូចៗចំនួន១០២ នាក់ ដែលកំពុងផលិត និងលក់ស្ករត្នោតកំពង់ស្ពឺ ឲ្យទៅ KAMPATRACO ដែលលក់ស្ករត្នោតនោះដល់សមាជិកមួយចំនួនរបស់ KSPA (សមាគមលើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ) និងអ្នកមិនមែនជាសមាជិករបស់សមាគមផងដែរ ដូចជា Signature of Asia Co., Ltd (SOA) ។ ចំនួនប្រមាណ ១២០ តោន ត្រូវបានលក់ដោយ Kampatraco នៅឆ្នាំ ២០១៦ ទៅឲ្យអ្នកទិញទាំងនោះ ដែលលក់វាយបន្តស្ករត្នោតក្នុងស្រុក ឬនាំចេញទៅក្រៅប្រទេស។

ស្ករត្នោតកំពង់ស្ពឺមានផលិតផលសម្គាល់ភូមិសាស្ត្រ KAMPATRACO សមាជិក និងអតិថិជនរបស់ខ្លួន (ប្រសិនបើពួកគេវេចខ្ចប់សារជាថ្មី ហើយប្រើឈ្មោះស្ករត្នោតកំពង់ស្ពឺ) ត្រូវបានជាប់កាតព្វកិច្ចជាសមាជិកនៃសមាគមទទួលបន្ទុកគ្រប់គ្រង ផលិតផលសម្គាល់ភូមិសាស្ត្រ ពោលគឺ សមាគមន៍លើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ និងដើម្បីគោរពតាមលក្ខណៈពិសេសសម្រាប់ការផលិតស្ករត្នោតកំពង់ស្ពឺនេះ។

នៅឆ្នាំ ២០១៦ KAMPATRACO បានចុះកិច្ចសន្យាជាមួយ SoA សម្រាប់ផលិត និងផ្គត់ផ្គង់ស្ករត្នោតមួយចំនួនធំ (២០០ តោន) ក្នុងចន្លោះខែមករា និងខែធ្នូ ឆ្នាំ ២០១៦ ។

ខាងក្រោមនេះជាកិច្ចព្រមព្រៀងសំខាន់ៗរបស់ភាគីទាំងពីរដោយផ្អែកលើកិច្ចសន្យាដែលបានចុះហត្ថលេខា៖

- តម្លៃស្ករត្នោតគឺថេរ (១.៣៥០ ដុល្លារ/តោន រួមទាំងការចំណាយលើប្រតិបត្តិការរបស់ KAMPATRACO)។
- គុណភាពនៃស្ករត្នោតនេះគឺផ្អែកលើសៀវភៅស្តីពីព័ត៌មានលម្អិតនៃស្ករត្នោតកំពង់ស្ពឺ។
- SoA ត្រូវកក់ប្រាក់ចំនួន ៣៩.០០០ ដុល្លារ ឲ្យទៅ KAMPATRACO បន្ទាប់ពីចុះហត្ថលេខាលើកិច្ចសន្យា។
- SoA ត្រូវទូទាត់ថ្លៃ ទៅឲ្យ KAMPATRACO ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីការចែកចាយស្ករត្នោត។
- ការបង់ប្រាក់នេះត្រូវបានធ្វើឡើងដោយការផ្ទេរប្រាក់តាមរយៈធនាគារ ហើយថ្លៃសេវាផ្ទេរប្រាក់ត្រូវបានបង់ដោយ Signature of Asia។
- KAMPATRACO ត្រូវបង់ប្រាក់ក្នុងចន្លោះ ៤.៤០០-៤.៦០០ រៀល/គីឡូក្រាម នៃស្ករត្នោតទៅឲ្យសមាជិករបស់សហគមន៍ ហើយរក្សាទុក ១០០ រៀល/គីឡូក្រាម ជាការគាំទ្ររបស់សហគមន៍ ហើយបង់ទៅឲ្យ KSPA ចំនួន ១០០ រៀល/គីឡូក្រាម។

KAMPATRACO ផ្តល់ការគាំទ្រផ្ទាល់ខ្លះៗដល់កសិករ ដូចជាការបណ្តុះបណ្តាលបច្ចេកទេសដោយអនុវត្តតាមសៀវភៅស្តីពីព័ត៌មានលម្អិតនៃស្ករត្នោតកំពង់ស្ពឺ ការគាំទ្រឥណទាន (២០០.០០០ រៀល/គ្រួសារ) ។ល។

នៅក្រោមកិច្ចសន្យានេះ KAMPATRACO អាចផ្គត់ផ្គង់ត្រឹមតែប្រមាណ ១០៦ តោនស្ករត្នោតប៉ុណ្ណោះ (៥៣% នៃចំនួនសរុបដែលបានចុះកិច្ចសន្យា) ប៉ុន្តែទោះបីជាបរិមាណនេះមិនអាចសម្រេចបានក៏ដោយ ក៏មិនមានជម្លោះរវាងភាគីទាំងពីរដែរ ដោយសារពួកគេបានជួប និងពិភាក្សាដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។

ក្នុងករណីនេះ សហគមន៍ដើរតួនាទីជាអន្តរការីរវាងអ្នកផលិត និងក្រុមហ៊ុន ដែលកំពុងទិញ និងស្វែងរកទីផ្សារស្ករត្នោត ដោយធានាបណ្តាញទីផ្សារសម្រាប់អ្នកផលិត និងពង្រឹងអំណាចតថ្លៃរបស់អ្នកផលិតខ្នាតតូច។

## ការពន្យល់បន្ថែម ២.១.ច
## ករណីនៃការរៀបចំផលិតកម្មកសិកម្មតាមកិច្ចសន្យាអន្តរការីសម្រាប់ផលិតផលសម្គាល់ភូមិសាស្ត្រ ដោយសហគមន៍កសិកម្មម្រេចកំពត (KAMPACO)

សហគមន៍កសិកម្មម្រេចកំពត (KAMPACO) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៩ និងមានទីតាំងស្ថិតនៅក្នុងស្រុកកំពង់ត្រាច ខេត្តកំពត។ បច្ចុប្បន្ននេះមានអ្នកផលិតម្រេចចំនួន ១៨៥ នាក់ ដែលកំពុងផលិត និងលក់ម្រេចកំពតទៅឲ្យ KAMPACO ដែលបន្ទាប់មក ក្រុមហ៊ុនលក់ម្រេចទាំងនោះទៅឲ្យក្រុមហ៊ុនឯកជនចំនួន១៦ក្រុមហ៊ុន ក្នុងនាមជា ឈ្មួញ។ ប្រមាណជា ៥០ ទៅ ៦០ តោន នៃម្រេចកំពតត្រូវបានលក់ដោយ KAMPACO ឆ្នាំ ២០១៥ និង ២០១៦ ទៅឲ្យឈ្មួញទាំងនោះ ហើយពួកគេលក់រាយនូវម្រេចទាំងនោះនៅក្នុងទីផ្សារក្នុងស្រុកឬនាំចេញទៅកាន់ទីផ្សារពិភពលោក។ម្រេចកំពតមានផលិតផលសម្គាល់ភូមិសាស្ត្រ(GI) សមាជិក KAMPACO និងអតិថិជនរបស់ខ្លួន (ប្រសិនបើពួកគេវេចខ្ចប់សារជាថ្មី) ត្រូវបានជាប់កាព្វកិច្ចជាសមាជិកនៃសមាគមទទួលបន្ទុកគ្រប់គ្រង ផលិតផលសម្គាល់ភូមិសាស្ត្រពោលគឺ សមាគមលើកកម្ពស់ម្រេចកំពតនិងដើម្បីគោរពតាមលក្ខណៈពិសេសសម្រាប់ការផលិតម្រេចកំពតនេះ។

តាមប្រតិបត្តិការ KAMPACO បានរៀបចំចុះកិច្ចសន្យាជាមួយសមាជិករបស់ខ្លួនដោយផ្អែកលើលក្ខណៈពិសេសខាងក្រោម៖ KAMPACO ផ្តល់ឥណទាន វគ្គបណ្តុះបណ្តាលស្តីពីគុណភាពផលិតផល (ផ្អែកលើសៀវភៅស្តីពីព័ត៌មានលម្អិតសម្រាប់ ផលិតផលសម្គាល់ភូមិសាស្ត្រ ម្រេចកំពត) ។ ម្រេចត្រូវបានប្រមូលទិញពីសមាជិកកសិករដោយសហគមន៍ (KAMPACO) ដោយផ្អែកលើតម្លៃថេរ (បច្ចុប្បន្នកំណត់រហូតដល់ឆ្នាំ ២០១៨ គឺត្រឹមតម្លៃ ១៥ ដុល្លារ/គីឡូក្រាមសម្រាប់ម្រេចខ្មៅ ហើយ ២៥ ដុល្លារ/គីឡូក្រាម សម្រាប់ម្រេចក្រហម និង ២៨ ដុល្លារ/គីឡូក្រាម សម្រាប់ម្រេចស។ សមាជិកដែលបានចុះកិច្ចសន្យាម្នាក់ៗទទួលខុសត្រូវ គោរពតាមលក្ខខណ្ឌតម្រូវលើគុណភាពផលិតផល ដូចដែលបានកំណត់នៅក្នុងសៀវភៅស្តីពីព័ត៌មានលម្អិតរបស់សមាគមលើកកម្ពស់ម្រេចកំពត (ឧ. លក្ខខណ្ឌតម្រូវសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ)។

នៅផ្នែកលក់ KAMPACO មានកិច្ចសន្យាដែលកំពុងអនុវត្តជាមួយក្រុមហ៊ុនចំនួន ១៦ ក្រុមហ៊ុន (ឈ្មួញ) ដែលបានបញ្ជាក់លក្ខខណ្ឌដូចខាងក្រោមនេះ៖

ការកំណត់តម្លៃថេរជាមុនរហូតដល់ឆ្នាំ ២០១៨ (ម្រេចខ្មៅគឺ ១៥ ដុល្លារ/គីឡូក្រាម ម្រេចក្រហមគឺ ២៥ ដុល្លារ/គីឡូក្រាម ម្រេច-សគឺ ២៨ ដុល្លារ/គីឡូក្រាម)។ តម្លៃនេះប្រហាក់ប្រហែលគ្នាទៅនឹងតម្លៃច្រកទ្វារកសិដ្ឋាន។

តម្លៃដែលបានរៀបរាប់ខាងលើគឺរាប់បញ្ចូលទាំងថ្លៃសេវា ដែលត្រូវបានបង់ដោយអ្នកផលិតម្រេចកំពតទាំងអស់នៃសមាគមលើកកម្ពស់ម្រេចកំពតសម្រាប់ប្រើឈ្មោះម្រេចកំពត (ថ្លៃចំណាយលើការបញ្ជាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ការផ្សព្វផ្សាយ និងសកម្មភាពការពារនានា)។ ការចំណាយលើការដឹកជញ្ជូនសម្រាប់ការចែកចាយនីមួយៗត្រូវបង់ដោយក្រុមហ៊ុនដែលជាអ្នកទិញ។

KAMPACO ទទួលខុសត្រូវលើគុណភាពផលិតផលដែលផ្អែកលើសៀវភៅស្តីពីព័ត៌មានលម្អិតរបស់សមាគមលើកកម្ពស់ម្រេចកំពត។

ក្រុមហ៊ុនត្រូវបង់ប្រាក់កក់ ២០% នៃតម្លៃសរុបដល់ KAMPACO ។

ក្នុងករណីនេះ សហគមន៍ដើរតួនាទីជាអន្តរការីរវាងអ្នកផលិត និងក្រុមហ៊ុនដែលកំពុងទិញ និងស្វែងរកទីផ្សារម្រេចកំពតដោយធានាទីផ្សារសម្រាប់អ្នកផលិត និងពង្រឹងអំណាចតថ្លៃរបស់អ្នកផលិតខ្នាតតូច។ ក្នុងករណីនេះ ដោយសារតែគេរក្សាឈ្មោះម្រេចកំពត ដែលមានតម្រូវការខ្ពស់ និងការការពារដែលផ្តល់ជូនដោយលក្ខខណ្ឌម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ខ្លួន អ្នកផលិតមានតួនាទីខ្លាំងក្នុងការចរចាតម្លៃ។

ការអនុវត្តន៍កិច្ចព្រមព្រៀងផ្ទាល់មាត់ចំពោះផលិតកម្ម និងការលក់ផលិតផលកសិកម្ម មាននៅក្នុងប្រទេសកម្ពុជាប៉ុន្តែមិនវានៅក្រៅផ្លូវការនៅឡើយទេ និងមិនបានចងក្រងជាឯកសារច្បាស់លាស់ផងដែរ។ ក្នុងករណីជាច្រើន វាធ្លាក់ដល់ការអនុវត្តទូលំទូលាយចំពោះប្រាក់កម្ចី ការផ្តល់បុរេហិរញ្ញប្បទានក្លាយជាកត្តាអូសទាញចម្បងសម្រាប់កសិករ និងការចែកចាយផលិតផល (ដោយមានព័ត៌មានលម្អិតស្តីពីគុណភាពមានកម្រិតដែលគេចង់បាន) ត្រូវបានគេមើលឃើញថាជាសំណងទៅវិញ។ ម្យ៉ាងវិញទៀត ចំនួនករណីផ្លូវការ ករណីធំៗ និងករណីទទួលបានជោគជ័យរបស់ផលិតកម្មកសិកម្មតាមកិច្ចនៅប្រទេសកម្ពុជានៅតែមានកម្រិតនៅឡើយ។ ប៉ុន្តែមិនមានការចាប់អារម្មណ៍ខ្លាំងសម្រាប់ម៉ូឌែលទេហើយចំនួននៃគំនិតផ្តួចផ្តើមថ្មីកំពុងមានផ្លែផ្កានាពេលបច្ចុប្បន្នសម្រាប់ដំណាំផ្សេងៗគ្នា។

## ២.២. សារសំខាន់នៃផ្នែកច្បាប់សម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា

យើងកត់សម្គាល់ឃើញថា អង្គការ UNIDROIT/FAO/IFAD ទើបតែបានសហការចេញផ្សាយសៀវភៅមគ្គុទេសក៍ច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងឆ្នាំ ២០១៥។ សៀវភៅមគ្គុទេសក៍នេះមិនត្រឹមតែជាឧបករណ៍ណែនាំគោលនយោបាយទេ ប៉ុន្តែក៏ជាឧបករណ៍ច្បាប់ទន់ (ច្បាប់មិនចងកាតព្វកិច្ច និងជាឧបករណ៍យោងសម្រាប់លើកស្ទួយការអនុវត្តល្អ ដែលស្របតាមលក្ខណៈវិនិច្ឆ័យអន្តរជាតិផងដែរ។ សេចក្តីយោង និងតំណភ្ជាប់អ៊ីនធឺណិតនៅក្នុងឯកសារនេះត្រូវបានសរសេរនៅក្នុងគន្លងនិទ្ទេសរបស់សៀវភៅណែនាំនេះ។ សៀវភៅមគ្គុទេសក៍ច្បាប់នេះក៏ជាសេចក្តីយោងដ៏សំខាន់មួយផងដែរ។នៅក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ ប្រភពច្បាប់ដែលគ្រប់គ្រងទំនាក់ទំនងរវាងអ្នកផលិតនិងអ្នកទិញ គឺទីមួយ គោលការណ៍ទូទៅនៃកិច្ចសន្យាដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ព្រមទាំងវិធាននិងការប្រើប្រាស់តាមទំនៀមទម្លាប់(មើលផ្នែក ២.២.១ខាងក្រោម) និងទីពីរច្បាប់ពិសេសទាក់ទងទៅនឹងវិស័យកសិកម្ម (មើលផ្នែក ២.២.២.នៅទំព័រទី ២៩)។

### ២.២.១. ច្បាប់ស្នូល

### ក្រមរដ្ឋប្បវេណី

កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា គឺជាកិច្ចសន្យាដំបូងគេ។ ក្រមរដ្ឋប្បវេណីកំណត់អំពីមូលដ្ឋានច្បាប់ឯកជន ដែលរាប់បញ្ចូលក្នុងការបង្កើតកិច្ចសន្យាដូចជា៖ គោលការណ៍ទូទៅ (ផ្នែក ១) កាតព្វកិច្ច(ផ្នែក ៤) និងកិច្ចសន្យាសំខាន់ៗ (ផ្នែក ៥)។

គោលការណ៍ទូទៅមាន៖ គោលការណ៍នៃភាពសុច្ចរិត និងភាពស្មោះត្រង់ គោលការណ៍សមភាព អាទិភាពចំពោះការរក្សាកិច្ចសន្យា និងប្រសិទ្ធភាពកិច្ចសន្យា និងការដោះស្រាយដោយភាពស្មោះត្រង់និងត្រឹមត្រូវ។ យើងកត់សម្គាល់ឃើញថា គូភាគីចង់សរសេរគោលការណ៍ទូទៅនៅក្នុងកិច្ចសន្យារបស់ពួកគេ ឬអនុវត្តគោលការណ៍ទាំងនេះនៅក្នុងទំនាក់ទំនងរបស់ពួកគេនៅក្នុងប្រការទូទៅ ឬប្រការណាមួយ។

ក្រមរដ្ឋប្បវេណីមានចែងគោលការណ៍ទូទៅផ្សេងៗគ្នា ដូចជា៖

- ការហាមឃាត់ "មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន" ឬ "គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់" ដូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ដោយសារផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចមានភាពមិនស្មើគ្នា ដែលធ្វើឱ្យខូចប្រយោជន៍របស់កសិករខ្នាតតូចដែលមិនទទួលបានព័ត៌មាន និងមានស្ថានភាពសេដ្ឋកិច្ចខ្សោយ ធៀបនឹងអ្នកទិញដែលមានក្រុមហ៊ុនមានដើមទុនច្រើន ដែលចង់ដាក់បទប្បញ្ញត្តិរបស់ពួកគេដោយសារពួកគេជាអ្នកលក់ផ្តាច់មុខ។

- គោលការណ៍នៃសេរីភាពក្នុងការជ្រើសរើស ក៏អាចហៅថា "គោលការណ៍ស្វ័យភាពនៃឆន្ទៈ" ឬ "គោលការណ៍ស្វ័យភាពនៃភាគី" គឺងាយក្លាយជាបញ្ហាផ្លូវច្បាប់នៅក្នុងស្ថានភាពដែលអ្នកទិញ/ពាណិជ្ជករ បង្កើត និងគាំទ្រអង្គការកសិករ។ ចំពោះទំនាក់ទំនងស្មើគ្នារវាងគូភាគីវិញក្រមរដ្ឋប្បវេណីរារាំងភាគីដែលខ្លាំងជាងមិនឱ្យទទួលបានផងប្រយោជន៍ច្រើនហួសហេតុពីភាគីទន់ខ្សោយ (ដែលត្រូវបានបង្ខំឱ្យទទួលយកលក្ខខណ្ឌទាំងអស់)៖ "បើភាគីមួយធ្វើកិច្ចសន្យាដោយទាញយកផលប្រយោជន៍ពីភាពលំបាកផ្នែកសេដ្ឋកិច្ច ការមិនដឹង ឬការខ្វះបទពិសោធន៍របស់ភាគីម្ខាងទៀត និងទទួលបានអត្ថប្រយោជន៍ច្រើនហួសហេតុពីកិច្ចសន្យា នោះភាគីដែលខាតប្រយោជន៍អាចលុបចោលកិច្ចសន្យាដោយផ្អែកលើវិការៈនៃការបង្ហាញឆន្ទៈបាន" ។

- គោលការណ៍នៃសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ៖ ច្បាប់កម្ពុជាបានផ្តល់ភាពខ្ពង់ខ្ពស់ដល់សណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ ដែលកម្រិតលើគោលការណ៍ស្វ័យភាពនៃភាគី។ បទប្បញ្ញត្តិរបស់កិច្ចសន្យាដែលផ្ទុយនឹង "ច្បាប់ ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ" ត្រូវចាត់ទុកជាមោឃៈ។ លើសពីនេះទៀត ប្រសិនបើអ្នកផលិតប្រើបុគ្គលិក អ្នកផលិតនោះត្រូវគោរពតាមច្បាប់ការងារ និងគោលការណ៍សិទ្ធិមនុស្ស ដូចបានកំណត់នៅក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទោះបីជាត្រូវបង្កើនផលិតភាពរបស់ខ្លួនក៏ដោយ ក៏អ្នកផលិតមិនត្រូវធ្វើឱ្យប៉ះពាល់ដល់បរិស្ថានជាដាច់ខាត។

កាតព្វកិច្ច គឺជាសញ្ញាណស្នូលរបស់កិច្ចសន្យា។ យោងតាមក្រមរដ្ឋប្បវេណី កាតព្វកិច្ច គឺជា "ទំនាក់ទំនងគតិយុត្តិដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត"។ តាមរយៈកាតព្វកិច្ចទាំងនេះ ផ្នែក ៤ បានកំណត់មូលដ្ឋាននៃកិច្ចសន្យា និងបញ្ហាផ្នែកច្បាប់ស្នូលរបស់កិច្ចសន្យា (ចាប់ពីការបង្កើតកិច្ចសន្យារហូតដល់ការដោះស្រាយវិវាទ) ដូចជា ខ្លឹមសារ និងគោលបំណង ប្រសិទ្ធភាព ការអនុវត្ត ឬការមិនអនុវត្ត និងមធ្យោបាយដោះស្រាយរបស់កិច្ចសន្យា។ ក្រមរដ្ឋប្បវេណីកំណត់និយមន័យ កិច្ចសន្យាថា "ជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច"។

ដើម្បីធ្វើឱ្យប្រតិបត្តិការសេដ្ឋកិច្ចដែលស្មុគស្មាញនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា ទទួលបានជោគជ័យ យើងមិនត្រឹមតែតម្រូវឱ្យមានកិច្ចសន្យារវាងអ្នកទិញ និងកសិករនោះទេ ប៉ុន្តែយើងក៏ត្រូវពិចារណាអំពីទំនាក់ទំនងជុំវិញផ្សេងទៀតរវាងកសិករ និងភាគីទីបីដែលទាមទារឱ្យធ្វើកិច្ចសន្យាផងដែរ ដូចជា៖ កិច្ចសន្យា

ការងាររវាងកសិករ និងបុគ្គលិករបស់ខ្លួន កិច្ចសន្យាធានារ៉ាប់រងដំណាំរវាងកសិករ និង ឬ កិច្ចសន្យាប្រាក់កម្ចីរវាងកសិករ និងធនាគារជាដើម។ ល។

លើសពីនេះទៀត កិច្ចសន្យារវាងអ្នកទិញ និងកសិករនេះក៏ជាសមាសភាពនៃកិច្ចសន្យាផងដែរ ដោយសារវាជាកិច្ចសន្យាការងារ (អ្នកទិញបង់ប្រាក់ឱ្យកសិករដើម្បីឱ្យផលិតផលិតផល) និងកិច្ចសន្យាលក់ទិញ (កសិករលក់ផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញ)៖ កិច្ចសន្យាការងារ គឺជា "កិច្ចសន្យាដែលភាគីម្ខាង (អ្នកចុះកិច្ចសន្យា) មានកាតព្វកិច្ចត្រូវបំពេញការងារដែលបានព្រមព្រៀងគ្នា ហើយភាគីម្ខាងទៀត (ម្ចាស់ប្រាក់) មានកាតព្វកិច្ចបង់ប្រាក់សម្រាប់លទ្ធផលការងារនោះ" និង កិច្ចសន្យាលក់ទិញ គឺជា "កិច្ចសន្យាដែលភាគីម្ខាង (អ្នកលក់) មានកាតព្វកិច្ចផ្ទេរកម្មសិទ្ធិ ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតទៅឱ្យភាគីម្ខាងទៀត (អ្នកទិញ) ហើយអ្នកទិញត្រូវមានកាតព្វកិច្ចបង់ថ្លៃទិញទៅឱ្យអ្នកលក់វិញ"។

### វិធាន និងការប្រើប្រាស់តាមទំនៀមទម្លាប់

កម្ពុជា គឺជាប្រទេសសម្បូរទៅដោយប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌។ ប្រព័ន្ធច្បាប់បច្ចុប្បន្ន គឺជាប្រព័ន្ធច្បាប់ចម្រុះ ដែលជាការបញ្ចូលទំនៀមទម្លាប់របស់ប្រទេសកម្ពុជា ប្រព័ន្ធច្បាប់ប្រទេសបារាំង (ឥទ្ធិពលពីអាណានិគមបារាំង) និងប្រព័ន្ធច្បាប់ទូទៅដែលជាឥទ្ធិពលកើតឡើងពីការផ្តល់ជំនួយពីបរទេសដល់ការធ្វើកំណែទម្រង់ច្បាប់ និងតុលាការនៅប្រទេសកម្ពុជា។

ដូច្នេះ វិធាន និងការអនុវត្តតាមទំនៀមទម្លាប់ គឺជាប្រភពបន្ទាប់បន្សំ៖ ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៨៨ បានចែងថា៖ "កិច្ចសន្យាទាំងឡាយដែលមិនស្របនឹងច្បាប់ របៀបរៀបរយសាធារណៈ និងទំនៀមទម្លាប់ដ៏ល្អប្រពៃ ត្រូវចាត់ទុកជាមោឃៈ" ហើយប្រសិនបើកិច្ចសន្យាមិនមានអត្ថន័យច្បាស់លាស់ទេ គេត្រូវធ្វើការបកស្រាយកិច្ចសន្យានោះឱ្យស្របតាមការអនុវត្ត ឬទំនៀមទម្លាប់ទូទៅនៃទីកន្លែងបង្កើតកិច្ចសន្យានោះ ប៉ុន្តែការបកស្រាយនេះមិនត្រូវផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះទេ។ ប្រសិនបើមានភាពមិនច្បាស់លាស់ គេត្រូវបកស្រាយកិច្ចសន្យានេះជាគុណប្រយោជន៍ដល់ភាគីកូនបំណុល"។

ប៉ុន្តែច្បាប់នេះមិនត្រូវបានយកមកអនុវត្តទេ នៅពេលក្រមរដ្ឋប្បវេណីថ្មីបានចូលជាធរមានក្នុងឆ្នាំ ២០១១ ត្រូវបានយកមកជាក់ជំនួសច្បាប់នេះ ហើយមិនមានការយោងច្បាប់ទំនៀមទម្លាប់ណាមួយដូចក្រឹត្យពីមុនទេ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ដោយសារតែមានការលំបាកយល់និងការអនុវត្តរបស់ក្រមរដ្ឋប្បវេណីថ្មី គូរភាគី ភាគីទីបី ចៅក្រម មេធាវី និងអ្នកអនុវត្តផ្សេងទៀតនៅតែចាត់ទុកវិធាន និងការអនុវត្តតាមទំនៀមទម្លាប់ថាជាមូលដ្ឋានច្បាប់សម្រាប់បញ្ហាកិច្ចសន្យា រួមទាំងនៅក្នុងទំនាក់ទំនងផលិតកម្មកសិកម្មតាមកិច្ចសន្យាផងដែរ។ ជាការពិតណាស់ ទំនៀមទម្លាប់របស់ប្រទេសកម្ពុជានៅតែត្រូវបានប្រើដោយភាគីកិច្ចសន្យា ហើយវាមានតម្លៃស្នូល និងមានតួនាទីសំខាន់ក្នុងការអនុវត្តច្បាប់ ក្នុងករណីកិច្ចសន្យាធ្វើឡើងមិនមែនជាលាយលក្ខណ៍អក្សរ។ កង្វះខាតនៃបទប្បញ្ញត្តិច្បាប់ត្រូវបានរារាំងដោយការអនុវត្តមិនដូចគ្នាដែលមាននៅតាមភូមិស្រុកនីមួយៗ។

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួននៃវិធានទំនៀមទម្លាប់៖

- កិច្ចសន្យាអាចត្រូវបានចរចាផ្ទាល់មាត់ បន្ទាប់មកសរសេរឡើង និងចុះហត្ថលេខាឱ្យស្របតាមទំនៀមទម្លាប់ក្នុងស្រុក
- ពាក់ព័ន្ធនឹងកម្មសិទ្ធិលើដីរបស់សហគមន៍ជនជាតិភាគតិចដែលសិទ្ធិរបស់សមាជិកសហគមន៍ និងសហគមន៍ទាំងមូល ត្រូវបានច្បាប់ទទួលស្គាល់ ហើយកម្មសិទ្ធិគឺជាទំនួលខុសត្រូវរបស់អំណាចប្រពៃណី និងយន្តការធ្វើការសម្រេចចិត្តតាមទំនៀមទម្លាប់របស់សហគមន៍ ក៏ដូចជាច្បាប់ដែលយកមកគ្រប់គ្រងផងដែរ

ស្របតាមប្រពៃណីវិញ ការដោះស្រាយវិវាទត្រូវធ្វើឡើងដោយចាស់ទុំនៅក្នុងភូមិ ដែលនេះជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

## ២.២.២. ច្បាប់ពិសេសដែលពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យាពាក់ព័ន្ធនឹងបរិបទកសិកម្ម

ប្រទេសកម្ពុជាពុំទាន់មានក្រមកសិកម្មនៅឡើយទេ។ ការអភិវឌ្ឍក្របខណ្ឌច្បាប់និងបទបញ្ញត្តិដែលទាក់ទងទៅនឹងវិស័យកសិកម្មគឺស្ថិតនៅចំណុចចាប់ផ្តើមប៉ុណ្ណោះ។ ប៉ុន្តែក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (ក្រសួងកសិកម្ម) បានចាប់ផ្តើមធ្វើសេចក្តីព្រាងនិងរៀបចំច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗមួយចំនួនដែលទាក់ទងទៅនឹងវិស័យកសិកម្មដើម្បីពង្រឹងវិស័យកសិកម្ម។ សម្រាប់បញ្ហាទំនាក់ទំនងរវាងអ្នកផលិត និងអ្នកទិញនៅក្នុងប្រធានបទផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ យើងនឹងផ្តោតតែទៅលើអត្ថបទច្បាប់ចុងក្រោយដែលទើបតែបង្កើតនិង ដែលពាក់ព័ន្ធប៉ុណ្ណោះ។ ច្បាប់ពិសេសទាក់ទងនឹងវិស័យកសិកម្មដែលប៉ះពាល់ដល់ផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានបញ្ជាក់ដោយ៖

- ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការដាក់ឱ្យដំណើរការមុខងារសហគមន៍កសិកម្ម សហភាពសហមន៍កសិកម្ម និងសហគមន៍សិកម្មជាមុន ត្រូវបានអនុម័តនៅខែកក្កដា ឆ្នាំ ២០០១ ប៉ុន្តែចូលជាធរមាននៅខែមិថុនា ឆ្នាំ ២០១៣។ ព្រះរាជក្រឹត្យនេះអនុញ្ញាតឱ្យក្រុមកសិករបង្កើតសហគ្រាសផ្អែកលើការងារកសិកម្ម ដោយកសិករអាចធ្វើជាម្ចាស់រួមគ្នា គ្រប់គ្រង និងពិនិត្យតាមដានតាមរយៈភាគហ៊ុន ឬអាជីវកម្មរួម និងទទួលផលប្រយោជន៍។
- ច្បាប់ស្តីពីការបង្កើតសហគមន៍កសិកម្ម ត្រូវបានអនុម័តនៅខែឧសភា ឆ្នាំ ២០១៣ និងប្រកាសឱ្យប្រើនៅខែមិថុនា ឆ្នាំ ២០១៣៖ រាជរដ្ឋាភិបាលកម្ពុជា "បានលើកទឹកចិត្តដល់ការបង្កើតសមាគមសហគមន៍កសិកម្ម ឬអង្គការកសិកម្ម ដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍវិស័យកសិកម្មផ្អែកលើទំនាក់ទំនង"។ ស្របតាមគោលនយោបាយនេះ ច្បាប់ស្តីពីការបង្កើតសហគមន៍កសិកម្មអនុញ្ញាតឱ្យកសិកររៀបចំចងក្រងជាសហគមន៍ស្របច្បាប់ និងបង្កើតជាសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្ម។ ច្បាប់នេះកំណត់និយមន័យសហគមន៍កសិកម្មថា ជានីតិបុគ្គលឯកជនដែលបង្កើតឡើងមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្ម។

### ពាក់ព័ន្ធនឹងសម្ភារកសិកម្ម

បច្ចុប្បន្ននេះផលិតកម្ម និងពាណិជ្ជកម្មគ្រាប់ពូជត្រូវបានគ្រប់គ្រងជាចម្បងដោយច្បាប់ និងបទប្បញ្ញត្តិដូចខាងក្រោម៖

- អនុក្រឹត្យលេខ៦៩ ស្ដីពីបមាណីនិងការគ្រប់គ្រងសម្ភារកសិកម្ម ដែលត្រូវបានអនុម័តនៅក្នុងខែតុលា ឆ្នាំ១៩៩៨ បានកំណត់ថាជាក្របខណ្ឌច្បាប់សម្រាប់សម្ភារ និងផលិតផលកសិកម្មនៅក្នុង វិស័យពាណិជ្ជកម្ម។ អនុក្រឹត្យមានបំណងជានាឱ្យបាននូវធាតុចូលសម្ភារកសិកម្មដែលមានគុណភាពខ្ពស់ដូចជា ជី គ្រាប់ពូជ ថ្នាំសម្លាប់សត្វល្អិត ដើម្បីបង្កើនផលិតភាពកសិកម្ម។ អនុក្រឹត្យចែងថា សម្ភារកសិកម្មទាំងអស់ដែលបានផលិត ឬបាននាំចូល ត្រូវតែចុះបញ្ជីជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្រសួងកសិកម្ម) ។ លើសពីនេះទៀត បុគ្គលណាដែលមានបំណងផលិត នាំចូល ឬនាំចេញសម្ភារទាំងនេះត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយព្រមទាំងត្រូវអនុលោមតាមស្តង់ដាគុណភាពដែលចេញដោយក្រសួងនេះផងដែរ។

- អនុក្រឹត្យលេខ ១៥ ស្ដីពីការត្រួតពិនិត្យភូតគាមអនាម័យ ចុះខែមីនា ឆ្នាំ ២០០៣។ អនុក្រឹត្យនេះកំណត់នូវក្របខណ្ឌគតិយុត្តសម្រាប់ការត្រួតពិនិត្យភូតគាមអនាម័យ និងមានគោលបំណងបង្ការការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយទៀតក្នុងប្រទេស ចេញចូល ឬឆ្លងកាត់ប្រទេសតាមគ្រប់មធ្យោបាយ ដើម្បីការពារផលិតកម្មកសិកម្ម និងជីវៈចម្រុះ។

- ច្បាប់ស្ដីពីការគ្រប់គ្រងគ្រាប់ពូជដំណាំ និងសិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំ ត្រូវបានអនុម័តនៅខែមិថុនា ឆ្នាំ ២០០៨ បានធ្វើនិយ័តកម្មផលិតកម្ម និងពាណិជ្ជកម្មគ្រាប់ពូជ និងការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

ក្រសួងកសិកម្មកំពុងខិតខំប្រឹងប្រែងធ្វើសេចក្ដីព្រាងច្បាប់ និងបទប្បញ្ញត្តិដើម្បីបន្ថែមក្របខណ្ឌច្បាប់ដែលមានស្រាប់ដែលគ្រប់គ្រងវិស័យពូជដើម្បីអនុវត្តស្តង់ដារ និងវិញ្ញាបនបត្របញ្ជាក់ពូជ ច្បាប់ថ្មីទាំងនេះរួមមាន៖

- សេចក្ដីព្រាងស្តង់ដារស្ដីពីពូជដំណាំជាតិ កំណត់ស្តង់ដារអប្បបរិមាដែលតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ពូជសម្រាប់ពូជសុទ្ធ និងកំណត់អត្តសញ្ញាណពូជដោយផ្ដោតលើស្តង់ដារស្រូវ ពោត សណ្ដែកបាយ សណ្ដែកសៀង គ្រាប់ល្ពៅ។ ឯកសារនេះនឹងបង្ហាញពីលក្ខខណ្ឌតម្រូវ លក្ខខណ្ឌ និងនីតិវិធីនៃការផលិតពូជ និងវិញ្ញាបនបត្របញ្ជាក់ពូជ។

សេចក្ដីព្រាងប្រកាសស្ដីពីនីតិវិធីសម្រាប់ការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ មានគោលបំ ណងផ្ដល់នីតិវិធីសម្រាប់ការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជណាមួយ រួមទាំងពូជដែលមានស្រាប់ និងពូជថ្មីដែលស្របតាមការគ្រប់គ្រងគុណភាពសម្រាប់គោលបំណងនៃការគ្រប់គ្រង និងការធ្វើទីផ្សារសម្រាប់ការផលិតគ្រាប់ពូជ ដើម្បីការពារផលិតកម្មកសិកម្ម និងបង្កើនផលិតភាពកសិកម្ម។

### ពាក់ព័ន្ធនឹងការការពារបរិស្ថាន

ប្រទេសកម្ពុជាមានច្បាប់ស្តីពីជីវសុវត្ថិភាពដែលបានអនុម័តនៅក្នុង ខែកុម្ភៈ ឆ្នាំ២០០៨។ គោលបំណងសំខាន់នៃច្បាប់នេះគឺដើម្បីអនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាពនិងដើម្បី៖

ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវចម្រុះ និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលបណ្តាលមកពីការផលិត ការដឹកជញ្ជូនឆ្លងដែន ការអភិវឌ្ឍ ការលើកដាក់ ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និងការបញ្ចេញសារពាង្គកាយកែច្នៃបង្កើតឡើងដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប

ធានាប្រសិទ្ធភាពនៃការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ជីវចម្រុះប្រកបដោយនិរន្តរភាព ព្រមទាំងចំពោះហានិភ័យដល់សុខភាពមនុស្ស។

លើសពីនេះ អនុក្រឹត្យស្តីពីយន្តការ និងនីតិវិធីសម្រាប់អនុវត្តច្បាប់ស្តីពីជីវសុវត្ថិភាពត្រូវបានដាក់ចេញ ដែលដោះស្រាយលក្ខខណ្ឌតម្រូវលម្អិតដើម្បីគ្រប់គ្រងចលនាសារពាង្គកាយកែច្នៃរស់ និងហានិភ័យ។ គោលបំណងនៃអនុក្រឹត្យនេះ គឺ៖ (i) ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវចម្រុះ បរិស្ថាន និងសុខភាពមនុស្ស (ii) ធានាប្រសិទ្ធភាពនៃការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ជីវចម្រុះប្រកបដោយនិរន្តរភាព (iii) លើកកម្ពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើបសំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ (iv) ដើម្បីការពារបរិស្ថាន និងសុខភាពមនុស្ស។

តាមក្រសួងបរិស្ថាន ច្បាប់ និងអនុក្រឹត្យទាំងនេះគ្រប់គ្រងលើការនាំចេញ និងនាំចូលសារពាង្គកាយកែច្នៃរស់ (LMOs) ។ ដំណើរការនាំចូល LMO មកព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមានការត្រួតពិនិត្យជាពីរកម្រិត៖ (i) គណៈកម្មាធិការជាតិសម្រាប់ LMO និង (ii) ក្រុមការងារបច្ចេកទេសសម្រាប់ការវាយតម្លៃហានិភ័យដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធនានា។ គណៈកម្មាធិការនេះបានបញ្ជូនលទ្ធផលនៃការវាយតម្លៃហានិភ័យទៅក្រសួងបរិស្ថាន ដែលចេញសេចក្តីសម្រេចចុងក្រោយដើម្បីអនុញ្ញាត ឬមិនអនុញ្ញាតឱ្យនាំចូល LMO ផ្អែកលើលទ្ធផលនៃការវាយតម្លៃហានិភ័យនោះ។

### ពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា (សូមមើលឧបសម្ព័ន្ធ ១) ដែលបានអនុម័តកាលពីខែ កុម្ភៈ ឆ្នាំ ២០១១ កំណត់ក្របខណ្ឌនៃការអនុវត្តសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះ មានគោលបំណងបួនដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវ និងភាពជឿទុកចិត្តគ្នារវាងភាគីអ្នកផលិត និងភាគីអ្នកទិញ ដោយឈរលើគោលការណ៍ស្មើភាព និងយុត្តិធម៌
- ធានាឱ្យមានភាពច្បាស់លាស់អំពីតម្លៃ ការប្រមូលទិញ និងការផ្គត់ផ្គង់ផលិតផលកសិកម្ម តាមបរិមាណ និងគុណភាព
- បង្កើនការប្រមូលទិញ ការកែច្នៃ និងការនាំចេញផលិតផលកសិកម្ម
- រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

អនុក្រឹត្យមានចែងអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងក្របខណ្ឌអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា (ហៅថា "ផលិតកម្មកសិកម្មផ្អែកលើកិច្ចសន្យា") តួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋ ("តភ្ជាប់រវាងអ្នកវិនិយោគ និងកសិករ អ្នកផលិតក្រុមហ៊ុនកែច្នៃ ក្នុងក្របខណ្ឌនៃផលិតកម្មកសិកម្មផ្អែកលើកិច្ចសន្យា") កាតព្វកិច្ចរបស់អ្នកផលិតកាតព្វកិច្ចរបស់អ្នកទិញ និងការដោះស្រាយវិវាទផងដែរ។

ចំណែកឯក្រមរដ្ឋប្បវេណីបានចែងអំពីសេរីភាពក្នុងការជ្រើសរើសថា ជាគោលការណ៍សំខាន់នៅក្នុងគ្រប់ទម្រង់កិច្ចសន្យាទាំងអស់ - "កិច្ចសន្យា គឺជាឆន្ទៈត្រូវគ្នាដែលធ្វើឡើងរវាងភាគីពីរនាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច"។ "កិច្ចសន្យាមានអានុភាពដោយសារសំណើ និងអ្នកទទួល(ស្នីការ)ត្រូវគ្នា" - ដោយចាត់ទុកកិច្ចសន្យានៃផលិតកម្មកសិកម្មផ្អែកលើកិច្ចសន្យាជាកិច្ចសន្យាលក់ អនុក្រឹត្យចែងថា "កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងក្នុងទម្រង់ជាលិខិតយថាភូត"។
ជាក់ស្តែង យោងតាមមាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី ចែងថា *"កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើងឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែ ភាគីអាចកំណត់ធ្វើលិខិតយថាភូត ឬលិខិតឯកជន ជាល័ក្ខខ័ណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន"។*

**ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់អ្នកផលិត និងអ្នកទិញ ភាគីទាំងពីរត្រូវមានកាតព្វកិច្ចអនុវត្តតាមលក្ខខណ្ឌដែលបានសរសេរនៅក្នុងកិច្ចសន្យា៖**

អ្នកទិញនេះត្រូវពន្យល់ឱ្យបានច្បាស់លាស់អំពីទំនិញ (ដូចជាបរិមាណគុណភាព ទីកន្លែង និងកាលបរិច្ឆេទនៃការប្រគល់ និងការទទួលទំនិញ) ផ្តល់សម្ភារកសិកម្ម និង/ឬ សេវាបច្ចេកទេស និង/ឬ ការជំនួយដទៃទៀតដែលបានព្រមព្រៀងគ្នាដើម្បីសម្រេចបាននូវលទ្ធផលដែលអ្នកចង់បាន និង/ឬ កក់ប្រាក់ជាមុន។ ចំណែកឯអ្នកផលិតត្រូវបន្តសកម្មភាពផលិតកម្មដោយផ្អែកតាមរដូវកាល និងពេលវេលាដែលកំណត់ផ្គត់ផ្គង់ឱ្យទាន់ពេលវេលាដោយមានកម្រិត បរិមាណគុណភាព និងត្រូវតាមពេលវេលា ព្រមទាំងទទួលយកការទូទាត់ប្រាក់នៃតម្លៃផលិតផលដូចដែលបានចែងក្នុងកិច្ចព្រមព្រៀង។ ដោយសារការសម្រេចចុងក្រោយអំពីបរិមាណ និងតម្លៃមិនទាន់ច្បាស់នៅឡើយ អាចធ្វើឱ្យមានការចុះខ្សោយដល់កសិករដែលគាត់រំពឹងថានឹងរក្សាបរិមាណនឹងតម្លៃ ឱ្យស្ថិតក្នុងកម្រិតអប្បរមា ដោយសារគាត់ត្រូវមានកាព្វកិច្ចបង់ឥណទានដូចដែលគាត់បានចុះកិច្ចសន្យាក្នុងដំណើរប្រតិបត្តិការនេះ។

តួនាទីយ៉ាងសំខាន់របស់រដ្ឋក្នុងការគាំទ្រដល់កិច្ចព្រមព្រៀងរបស់ផលិតកម្មកសិកម្មតាមកិច្ចសន្យា៖

- ភ្ជាប់ទំនាក់ទំនងរវាង កសិករ និងអ្នកវិនិយោគទុន អ្នកផលិត និងប្រតិបត្តិករ
- លើកកម្ពស់ និងលើកទឹកចិត្តឱ្យមានការបង្កើតសមាគម សហគមន៍កសិកម្ម អង្គការកសិកម្មជាមូលដ្ឋានដើម្បីធ្វើកសិកម្មផ្អែកតាមកិច្ចសន្យា។
- ពង្រឹងស្តង់ដារ ចំណាត់ថ្នាក់ និងគុណភាពនៃផលិតផលកសិកម្ម ដើម្បីអនុលោមស្របតាមតម្រូវការទីផ្សារ និងបទដ្ឋានអន្តរជាតិ។
- ចូលរួមក្នុងការដោះស្រាយបញ្ហា និងជម្លោះដែលមានការទាក់ទងទៅនឹងការអនុវត្តនៃផលិតកម្មកសិកម្មផ្អែកតាមកិច្ចសន្យាស្តីពីមូលដ្ឋានគ្រឹះមួយនៃផលប្រយោជន៍ និងច្បាប់ដែលមានស្រាប់សម្រាប់ភាគីក្នុងកិច្ចសន្យា។
- ជួយសម្រួលដល់លទ្ធភាពទទួលបានសិទ្ធិកាន់កាប់ដីស្របច្បាប់ ទៅដល់ភាគីផលិត និងភាគីធ្វើកសិកម្ម និងផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធ្វើអាជីវកម្មកសិកម្ម និងកសិឧស្សាហកម្ម។
- ផ្តល់លទ្ធភាពទទួលបានការគាំទ្រផ្នែកបច្ចេកទេសដូចជា ពូជដំណាំដែលមានគុណភាពល្អ ប្រភេទពូជសត្វក្នុងទឹក ប្រភេទពូជរុក្ខជាតិ ពូជសត្វ មធ្យោបាយក្នុងការផលិត ជីដែលមានគុណភាពខ្ពស់ និងថ្នាំសម្លាប់សត្វល្អិត។
- ពង្រឹងភាពខ្លាំងលើផ្នែកផលិតកម្ម ពិពិធកម្មកសិកម្ម និងការប្រកួតប្រជែងក្នុងការផលិត ហើយកែប្រែផលិតផលដែលមានតម្លៃទាបទៅជាផលិតផលដែលមានតម្លៃខ្ពស់ ដើម្បីតម្រូវតាមទីផ្សារក្នុងស្រុក និងការនាំចេញទៅក្រៅប្រទេស ជួយសម្រួលដល់ អាជីវកម្មកសិកម្ម កសិ-ឧស្សាហកម្ម និងការនាំចេញទៅក្រៅប្រទេស ពង្រឹងនិងពង្រីកសមត្ថភាព ហើយសម្រួលដល់ការពិនិត្យមើលផ្នែកអនាម័យ និងភូតគាមអនាម័យ។

យន្តការដោះស្រាយវិវាទ៖ លើសពីនេះទៀត អនុក្រឹត្យបានបញ្ជាក់ពី "ស្ថាប័ន និងយន្តការធ្វើការសម្របសម្រួល" ចំពោះតួនាទី និងទំនួលខុសត្រូវរបស់រដ្ឋ។ ហើយអនុក្រឹត្យក៏បានបង្កើតគណៈកម្មាធិការសម្របសម្រួលមួយដែលហៅថា "គណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម"។

អនុក្រឹត្យក៏បានចែងអំពីយន្តការដោះស្រាយវិវាទតាមរយៈ ការបង្ហាញថាវិវាទណាដែលទាក់ទងនឹងការអនុវត្តនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវតែដោះស្រាយប្រកបដោយការយោគយល់គ្នាស្របតាមលក្ខខណ្ឌដែលបានផ្តល់ឱ្យក្នុងកិច្ចសន្យា។ ក្នុងករណីដែលដំណោះស្រាយប្រកបដោយការយោគយល់គ្នាមិនអាចដោះស្រាយបានដោយស្ថាប័នជំនាញទេ វិវាទនោះអាចនឹងត្រូវបានដោះស្រាយតាមឆន្ទៈរបស់ភាគី ដោយការគោរពតាមយន្តការដែលបានបង្ហាញក្នុងអនុក្រឹត្យ។ ដូច្នេះ ភាគីទាំងអស់អាចឯកភាពគ្នាទៅតាមដំណោះស្រាយណាមួយ ( ការចរចា ការសម្រុះសម្រួល តាមប្រព័ន្ធតុលាការ ឬមានជាអាជ្ញាកណ្តាល) ដោយគ្មានការប្តឹងតវ៉ាទៅគណៈកម្មាធិការសម្របសម្រួល។

## ២.៣. គោលនយោបាយ និងវិធានការគាំទ្រសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា

### ២.៣.១. ផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងយុទ្ធសាស្ត្រ និង គោលនយោបាយរដ្ឋាភិបាល

ផលិតកម្មកសិកម្មតាមកិច្ចសន្យា គឺត្រូវបានចែងយ៉ាងច្បាស់នៅក្នុងគោលនយោបាយផ្សេងៗ ឬ ឯកសារយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាឧបករណ៍ប្រកបដោយសក្តានុពលក្នុងការបង្កើនការធ្វើពាណិជ្ជកម្មនៃផលិតផលកសិកម្ម និងក្នុងការគាំទ្រគោលនយោបាយមួយចំនួនក្រោមការលើកកម្ពស់នៃវិស័យកសិកម្មនេះ។ ការលើកស្ទួយវិស័យកសិកម្ម រាជរដ្ឋាភិបាលនឹងបន្តជំរុញ ការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ដែលនឹងជួយបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាជួយបង្កើនចំណូលដល់ប្រជាកសិករ។ កន្លងមកនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពីការលើកកម្ពស់នៃផលិតកម្មស្រូវ និងការនាំចេញអង្ករ (ឆ្នាំ ២០១០) ដោយបានជម្រុញដល់កសិករខ្នាតតូចប្រមូលផ្តុំជាក្រុមកសិករស្របច្បាប់ (អង្គការកសិករ) ធ្វើជាដៃគូផលិត និងផ្គត់ផ្គង់លក់ផលិតផលកសិកម្មទៅឲ្យក្រុមហ៊ុនប្រមូលទិញតាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ស្រដៀងគ្នានេះដែរ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ឆ្នាំ ២០១៤-២០១៨ បានសង្កត់ធ្ងន់ពីតម្រូវការសម្រាប់ការពង្រឹងភាពជាដៃគូរវាង កសិករ ឈ្មួញ និងឧស្សាហកម្មកែច្នៃស្រូវ ក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមវិធីដែលអាចធ្វើទៅបានដើម្បីសម្រេចបានការងារនេះ (សូមមើល ផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍ របស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ ២០១៤ ទំព័រ ៩៥-៩៦ ដែលមានជាភាសាអង់គ្លេសកថាខណ្ឌ ៣.៥០) ។

គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ (ដែលរួមបញ្ចូលទាំងការអភិវឌ្ឍវិស័យកសិ- ឧស្សាហកម្មដែលជាផ្នែកមួយនៃវិសាលភាពរបស់គោលនយោបាយនេះ) ក៏បានបញ្ជាក់ពីបញ្ហាប្រឈមនៃការបង្កើតភាពជឿទុកចិត្តនិងខ្សែសង្វាក់ផ្គត់ផ្គង់ទាន់ពេលវេលា សម្រាប់ឧស្សាហកម្មកែច្នៃកសិកម្ម (ទំព័រទី ១០ នៅក្នុងកំណែជាភាសាអង់គ្លេស) ។ អាស្រ័យហេតុនេះតាមយន្តការរបស់អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាបង្ហាញឱ្យឃើញពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលបំណងឆ្លើយតបតាមគោលនយោបាយខាងលើ ជាពិសេស ការផ្សារភ្ជាប់រវាងកសិករខ្នាតតូចជាមួយក្រុមហ៊ុនប្រមូលទិញ ឬ កែច្នៃខ្នាតធំៗ ក្នុងការទិញលក់ផលិតផលកសិកម្ម ដើម្បីធានាបានទាំងបរិមាណ គុណភាព និងពេលវេលា និងដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ និងចូលរួមកាត់បន្ថយហានិភ័យរបស់កសិករខ្នាតតូច តាមរយៈការដាំដុះ/ចិញ្ចឹមសត្វ ដែលមានផែនការ និងទីផ្សារច្បាស់លាស់ ។ ទោះជាយ៉ាងណាក៏ដោយដើម្បីធ្វើឱ្យផលិតកម្មកសិកម្មតាមកិច្ចសន្យាដំណើរការប្រកបដោយប្រសិទ្ធិភាព ការយកចិត្តទុកដាក់យ៉ាងឆាប់រហ័សត្រូវធ្វើឡើងដើម្បីបង្កើត និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាក់លាក់ផ្សេងៗ។ ហើយជាចុងក្រោយវានឹងត្រូវបានគូសបញ្ជាក់ដែលថាផលិតកម្មកសិកម្មតាមកិច្ចសន្យា គឺមិនមែនមានគោលបំណងសម្រាប់ខ្លួនឯងនោះទេប៉ុន្តែវាជាឧបករណ៍ដែលអាចត្រូវបានធ្វើឱ្យប្រសើរឡើង និងត្រូវបានលើកកម្ពស់នៅពេលណាដែលមានការជាប់ពាក់ព័ន្ធ (សូមមើលជាពិសេស ផ្នែក ១.៣ ផលិតកម្មកសិកម្មតាមកិច្ចសន្យា សម្រាប់គំរូអាជីវកម្មណាមួយ? ។

## ២.៣.២.វិធានការគាំទ្រសាធារណៈចំពោះការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា ការចូលរួម និងការគាំទ្រដែលអាចកើតមាននៃសេវាកម្ម ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្នុងការអភិវឌ្ឍតាមពជាដៃគូ សម្រាប់ការចរចានៅលើផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការដោះស្រាយជម្លោះ

ផ្អែកលើអនុក្រឹត្យលេខ ៣៦ អនក្រ.បក ភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសារាចរណែនាំលេខ ១៥៦ សរណន.កសក. ស្តីអំពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០១៧ (ជាពិសេសនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត) អាចស្នើសុំការគាំទ្រមួយចំនួន ដើម្បី៖

កំណត់រកដៃគូដែលមានសក្តានុពល (តម្រូវឱ្យនាយកដ្ឋានកសិ-ឧស្សាហកម្មមានឆន្ទៈក្នុងការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយនឹងកសិករខ្នាតតូច ឬសហគមន៍កសិកម្ម/ អង្គការកសិករ និង កំណត់រកភាគីអ្នកទិញដែលមានសក្តានុពល) ។

ចូលរួមក្នុងការចរចាលើលក្ខខណ្ឌរបស់កិច្ចសន្យា (ប្រសិនបើភាគីណាមួយចង់ចូលរួម) និងផ្តល់យោបល់នៅក្នុងដំណើរការនេះ។

ធ្វើជាសាក្សី ឬគាំទ្រហត្ថលេខានៃកិច្ចសន្យានោះ។

ដើរតួនាទីជាអ្នកសម្របសម្រួល ឬសម្រុះសម្រួលមួយនៅក្នុងការដោះស្រាយជម្លោះ ប្រសិនបើជាហត្ថលេខីនៃកិច្ចសន្យានោះ (ភាគីទាំងពីរ) យល់ព្រមប្រើប្រាស់សេវាកម្មរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឬគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យា?) អ្នកសម្របសម្រួល [សូមមើលផ្នែក ៤.១៣ និង ៦.២.២ នៅក្នុងសៀវភៅណែនាំនេះ] ។

### វិធានការគាំទ្រទូទាំងប្រទេស និងជាអចិន្ត្រៃយ៍ផ្សេងទៀត

នាពេលបច្ចុប្បន្ននេះ លើសពីការគាំទ្រដែលអាចធ្វើបាននៅក្នុងការចរចាសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការអនុវត្តដែលបានរៀបរាប់ខាងលើមិនមានវិធានការគាំទ្រទូទាំងប្រទេស និងជាអចិន្ត្រៃយ៍បន្ថែមទៅនឹងការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យានោះនៅឡើយទេ។ ប៉ុន្តែវិធានការបែបនេះអាចនឹងត្រូវបានសម្រេចនាពេលអនាគតហើយធ្វើបច្ចុប្បន្នភាពលើការគាំទ្រសម្រាប់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ដើម្បីការបង្កើតគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា និងអាចទទួលបានតាមរយៈការទំនាក់ទំនងជាមួយនាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដែលជាចំណុចបង្គោលសម្រាប់ការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ។

**ការពន្យល់បន្ថែម ២.៣.ក ៖ ការគាំទ្រដែលអាចមានពីគម្រោងរបស់រដ្ឋាភិបាលស្តីពីបណ្តាញកសិករខ្នាតតូចទៅកាន់ទីផ្សារតាមរយៈប្រតិបត្តិការផលិតកម្មកសិកម្មតាមកិច្ចសន្យា**

**សារតៈ** ចាប់តាំងពីឆ្នាំ ២០១៦ នាយកដ្ឋានកសិ-ឧស្សាហកម្មបានទទួលថវិការពីរាជរដ្ឋាភិបាលកម្ពុជាចំនួន ១០០លានរៀលជារៀងរាល់ឆ្នាំ ដើម្បីធ្វើការគាំទ្រដល់វេទិការផ្សព្វផ្សាយសម្រាប់ក្រុមហ៊ុនឯកជន និងកសិករខ្នាតតូច សម្រាប់ការលក់ និងការទិញផលិតផលកសិកម្មតាមរយៈប្រតិបត្តិការ ផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ទោះយ៉ាងណាក៏ដោយថវិការនៅតែមានកម្រិត សម្រាប់ការផ្តល់ជូនសេវាកម្មទាំងនេះនៅទូទាំងប្រទេស។

**ការគ្របដណ្តប់ភូមិសាស្ត្រ ៖** ទូទាំងប្រទេស (២៥ ខេត្ត)។

**រយៈពេលនៃការអនុវត្ត៖** ចាប់ផ្តើមពីឆ្នាំ ២០១៦។

**ការគាំទ្រសិទ្ធិទទួលបានដែលអាចធ្វើទៅបាន ទាក់ទងនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា៖** នាយកដ្ឋានកសិ-ឧស្សាហកម្ម អាចផ្តល់ការគាំទ្រជា ៥ ជំហានដូចខាងក្រោម៖

(១) កំណត់នូវតំបន់មានសក្តានុពល និងផលិតផលមានសក្តានុពល (២) តភ្ជាប់កសិករខ្នាតតូច និងក្រុមហ៊ុនឯកជនតាមរយៈវេទិការ ផលិតកម្មកសិកម្មតាមកិច្ចសន្យា (៣) ជួយសម្រួលដល់ការចរចា (៤) ជួយក្នុងការបង្កើតសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកិច្ចសន្យា និង (៥)ការគាំទ្រកិច្ចព្រមព្រៀង លើផលិតកម្មកសិកម្មតាមកិច្ចសន្យា។

**បែបបទ និងទំនាក់ទំនង៖** បេក្ខភាពដែលមានចំណាប់អារម្មណ៍ក្នុងប្រតិបត្តិការ ផលិតកម្មកសិកម្មតាមកិច្ចសន្យានឹងដាក់ពាក្យសុំតាម នាយកដ្ឋានកសិ-ឧស្សាហកម្ម ឬ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ការិយាល័យសម្រាប់កសិ-ឧស្សាហកម្ម) ។

## វិធានការគាំទ្រគម្រោងជាមូលដ្ឋាន

ក្នុងករណីខ្លះ ភាគីពាក់ពន្ធ័សេដ្ឋកិច្ច ( ភាគីអ្នកទិញ និង / ឬ អ្នកផលិតខ្នាតតូច ឬសហគមន៍កសិកម្ម) មានឆន្ទះក្នុងការបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលប្រហែលជានឹងអាចទាញការគាំទ្រពីគម្រោងអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ដែលជាញឹកញាប់ត្រូវបានអនុវត្តន៍ជាមួយដៃគូរអភិវឌ្ឍន៍ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ។ នៅក្នុងករណីទាំងនេះការគាំទ្រដែលបានស្នើសុំអាចនឹងមិនអាចទទួលបាននៅទូទាំងប្រទេស ប៉ុន្តែអាចទទួលបានតែតំបន់ភូមិសាស្ត្រណាដែលគ្របដណ្តប់ដោយគម្រោងដែលបានផ្តល់ឱ្យ។ ហើយគម្រោងទាំងនោះក៏ប្រហែលជាមិនអាចមានជានិរន្តរដែរ ប៉ុន្តែវាមានតែក្នុងរយៈពេលនៃគម្រោងនោះតែប៉ុណ្ណោះ ហើយគម្រោងទាំងនោះអាចត្រូវបានស្នើសុំសម្រាប់ខ្សែសង្វាក់តម្លៃជាក់លាក់មួយដោយផ្អែកលើវិសាលភាពនៃគម្រោងនោះ។

នៅក្នុងឯកសារនេះ យើងមិនអាចផ្តល់នូវបញ្ជីដែលរៀបរាប់អស់គ្រប់យ៉ាងអំពីការផ្តល់ការគាំទ្រសម្រាប់ភាគីពាក់ព័ន្ធបានទេ ហើយត្រូវបានណែនាំឱ្យទំនាក់ទំនងទៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម ឬ មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត ដើម្បីទទួលបានព័ត៌មានថ្មីៗ។

## ២.៣.៣. ផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្លងប្រទេស៖

**អាចមានការគាំទ្រពីរដ្ឋាភិបាលកម្ពុជាលើកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់ផលិតកម្មកសិកម្មតាមកិច្ចសន្យាស្ថិតក្រោម ACMECS** អនុស្សរណៈនៃការយោគយល់គ្នាមួយបានធ្វើការចុះហត្ថលេខានៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើកកម្ពស់ ផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្លងដែន ក្រោម"យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច Ayeyawaddy Chao Phraya MekongEconomic Cooperation Strategy "(ACMECS)។ យោងតាមអនុស្សរណៈយោគយល់គ្នានេះ រដ្ឋាភិបាលនៃព្រះរាជាណាកម្ពុជានឹងអនុញ្ញាត និងជួយសម្រួលក្នុងការនាំចូលដោយក្រុមហ៊ុនស្របច្បាប់មកពីប្រទេសថៃដែលមានដូចជា គ្រាប់ពូជ សំណាបជី គ្រឿងចក្រ និងឧបករណ៍ប្រើប្រាស់នានា ហើយសម្ភារផ្គត់ផ្គង់ចាំបាច់ផ្សេងទៀតសម្រាប់សកម្មភាពផលិតកម្មកសិកម្មតាមកិច្ចសន្យារបស់ខ្លួនក្រោមគម្រោងក្នុងព្រះរាជាណាចក្រកម្ពុជា នេះបើយោងតាមបទប្បញ្ញត្តិ និងច្បាប់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងទទួលខុសត្រូវចំពោះការផ្តល់ការលើកទឹកចិត្ត ពន្ធឯកសិទ្ធិរួមបញ្ចូលទាំង ការហូតពន្ធការបង់ពន្ធ ឬ ប្រភេទអ្វីផ្សេងទៀតនៃថ្លៃនាំចូលគ្រឿងចក្រ ឧបករណ៍ គ្រាប់ពូជសំណាបជី និងសម្ភារដែលត្រូវបានប្រើដោយក្រុមហ៊ុនថៃ ដើម្បីធ្វើដំណើរការផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងព្រះរាជាណាចក្រកម្ពុជា។ ការគ្របដណ្តប់ភូមិសាស្ត្រនៃអនុស្សរណៈយោគយល់គ្នានេះ គឺគ្របដណ្តប់លើបណ្តាខេត្តចំនួន ៧ ដែលមានទីតាំងស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា និងថៃ មានឈ្មោះដូចជា៖ ខេត្តកោះកុង ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យឧត្តរមានជ័យ ពោធិ៍សាត់ និង ខេត្តព្រះវិហារ។ រយៈពេលនៃការអនុវត្ត អនុស្សរណៈនេះគឺគិតចាប់ពីថ្ងៃចុះហត្ថលេខាសម្រាប់រយៈពេលដំបូង ៥ (ប្រាំ) ឆ្នាំហើយវាអាចត្រូវបន្តទៀតដោយមានឯកភាពគ្នារវាងភាគីចុះកិច្ចសន្យានោះ។ ភាគីទាំងពីរបានបង្កើតឡើង គណៈកម្មាធិការធ្វើការទ្វេភាគីចម្រុះរួចរាល់ (JBWC) ដែលនឹងដើរតួនាទីមួយក្នុងការជួយដល់ការអនុវត្តនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា។ បញ្ជីបច្ចុប្បន្ននៃផលិតផលកសិកម្មដែលមានសក្តានុពល សំណុំបែបបទកម្មវិធីផលិតកម្មកសិកម្មតាមកិច្ចសន្យានិងទម្រង់ស្តង់ដារបស់ ផលិតកម្មកសិកម្មតាមកិច្ចសន្យាកំពុងត្រូវបានពិភាក្សា។ ព័ត៌មានបន្ថែមស្តីពីបែបបទអាចត្រូវបានផ្តល់ដោយនាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលជាលេខាធិការដ្ឋានសម្រាប់ JBWC។

# ផ្នែកទី៣៖ នីតិវិធីសម្រាប់ការសម្របសម្រួលដល់ការចរចាផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការចុះបញ្ជីកិច្ចសន្យា

## ៣.១. តើនរណាអាចផ្តល់ការគាំទ្រសម្រាប់ការបង្កើតកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា

### ៣.១.១. សេវាគាំទ្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានស្នើដល់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចដែលមានបំណងបង្កើតផលិតកម្មកសិកម្មតាមកិច្ចសន្យា

**នាយកដ្ឋានកសិ-ឧស្សាហកម្មជាស្ថាប័នបង្គោលមួយសម្រាប់សេវារបស់ក្រសួងកសិកម្មពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា**

យោងតាមអនុក្រឹត្យលេខ៣៦អនក្រ.បក ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ចុះខែកុម្ភៈ ឆ្នាំ២០១១ (មាត្រា ១០) និងសារាចរណែនាំលេខ ១៩៦សរណន.កសក.ស្តីអំពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ នាយកដ្ឋានកសិឧស្សាហកម្ម (DAI) ដើរតួជាស្ថាប័នបង្គោលតំណាងឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ឬហៅថា (CFCC) ។

សម្រាប់ភាគីរាជរដ្ឋាភិបាល/វិស័យសាធារណៈ នាយកដ្ឋានកសិ-ឧស្សាហកម្មគឺជាស្ថាប័ននាំមុខក្នុងការទំនាក់ទំនង ការសម្របសម្រួល ការផ្តល់សេវាស្ថិតក្រោមសមត្ថភាពរបស់ខ្លួន ដើម្បីបង្កើតឲ្យមានផលិតកម្មកសិកម្មផ្អែកតាមកិច្ចសន្យា។

នៅក្នុងការអនុវត្តជាក់ស្តែង នាយកដ្ឋានកសិ-ឧស្សាហកម្ម (ដោយផ្ទាល់ ឬតាមរយៈការចល័តការិយាល័យកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត) អាចផ្តល់ការគាំទ្រដូចខាងក្រោមដល់ភាគីពាក់ព័ន្ធ(ភាគីអ្នកផលិតឬភាគីអ្នកទិញ) ដែលមានបំណងចង់បង្កើតភាពជាដៃគូផ្អែកលើកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា៖

- ជួយភាគីពាក់ព័ន្ធដើម្បីកំណត់អត្តសញ្ញាណដៃគូ ប្រសិនបើភាគីអ្នកទិញដែលមានសក្តានុពលស្វែងរកក្រុមភាគីអ្នកផលិតដើម្បីឲ្យធ្វើការជាមួយ)
- ផ្តល់ទម្រង់ពាក្យស្នើសុំកិច្ចសន្យាផលិតកម្មកសិកម្ម និងចូលរួមសម្របសម្រួលក្នុងការពិភាក្សាលើលក្ខខណ្ឌនានានៅក្នុងកិច្ចសន្យា ដោយធានាថារាល់សំណួរសំ ខាន់ៗទាំងអស់ត្រូវបានពិភាក្សា និងបានផ្តល់ចម្លើយ (សូមមើលផ្នែកទី ៤ នៃសៀវភៅណែនាំស្តីពីទម្រង់ពាក្យស្នើសុំគម្រូស្តង់ដារ កិច្ចសន្យាផលិតកម្មកសិកម្ម ឧបសម្ព័ន្ធទី ៤និងសំណួរពាក់ព័ន្ធកិច្ចសន្យាត្រូវមានចម្លើយដល់ពួកគេ)
- ចូលរួមដឹកនាំសម្របសម្រួលរៀបចំកិច្ចសន្យា/ការសម្របសម្រួលក្នុងករណីមានជម្លោះក្នុងពេលអនុវត្តកិច្ចសន្យា

## នីតិវិធីដើម្បីគៀងគរការគាំទ្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ដើម្បីគៀងគរការគាំទ្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអ្នកពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចមានការចាប់អារម្មណ៍ក្នុងការបង្កើតភាពជាដៃគូតាមរយៈយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- អ្នកដាក់ពាក្យសុំ ( ដែលអាចជាភាគីអ្នកផលិត ឬ ភាគីអ្នកទិញ ) ត្រូវទាក់ទងមកនាយកដ្ឋានកសិ-ឧស្សាហកម្ម ដោយផ្ទាល់នៅរាជធានីភ្នំពេញ តាមអាសយដ្ឋានទំនាក់ទំនងដែលបានបង្ហាញខាងក្រោម ឬ នៅថ្នាក់ខេត្តតាមរយៈការិយាល័យកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។
- អ្នកដាក់ពាក្យសុំនឹងត្រូវបានណែនាំឲ្យប្រើសំណុំបែបបទពាក្យសុំកិច្ចសន្យាផលិតកម្មកសិកម្ម (សូមមើលឧបសម្ព័ន្ធទី ២ និង ៣ នៅក្នុងសៀវភៅណែនាំនេះ) និងគំរូស្តង់ដា កិច្ចសន្យាផលិតកម្មកសិកម្ម (សូមមើលឧបសម្ព័ន្ធទី ៤) ដើម្បីស្នើសុំការគាំទ្រសម្រាប់ការជួយសម្របសម្រួលរៀបចំបង្កើតកិច្ចសន្យាផលិតកម្មកសិកម្ម និងដើម្បីធ្វើការវាយតម្លៃដំណាក់កាលចាប់ផ្តើមនៃការបង្កើតគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យា និងជួយសម្រួលដល់ការទទួលបានការគាំទ្រឬការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ប្រសិនបើមាន។ លើសពីនេះទៀត អ្នកដាក់ពាក្យសុំ (ឧទាហរណ៍ក្រុមហ៊ុនមួយដែលមានឆន្ទៈក្នុងការស្វែងរកប្រភពសក្តានុពលផលិតផលកសិកម្ម) អាចទាក់ទងទៅនាយកដ្ឋានកសិ-ឧស្សាហកម្មនៅដំណាក់កាលដំបូងដើម្បីស្នើសុំព័ត៌មានទូទៅស្តីពីកិច្ចសន្យាផលិតកម្មកសិកម្មនៅក្នុងប្រទេសកម្ពុជា និងអាចផ្តល់នូវព័ត៌មានអំពីសក្តានុពលតំបន់ផលិតកម្ម សក្តានុពលអ្នកផលិត និង សក្តានុពលផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ដ៏មានសក្តានុពលដែលត្រូវបានកំណត់អត្តសញ្ញាណរួចរាល់ និងបានពិភាក្សាជាបឋមលើលក្ខខណ្ឌនានានៃកិច្ចសន្យានេះ...
- **បន្ទាប់ពីនោះ មន្ត្រីមកពីនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តសាមី (ការិយាល័យកសិ-ឧស្សាហកម្ម) នឹងជួបប្រជុំជាមួយអ្នកដាក់ពាក្យសុំដើម្បីផ្តល់ព័ត៌មាន និងការអន្តរាគមន៍លើដំណាក់កាលដូចខាងក្រោម៖**
    ១. **ជួបជាមួយអ្នកដាក់ពាក្យសុំដើម្បីទទួលបានព័ត៌មានស្តីពីការជំរុញទឹកចិត្ត និងគម្រោងរបស់គាត់ ហើយផ្តល់ព័ត៌មានអំពីការធ្វើកិច្ចសន្យាផលិតកម្មកសិកម្មនៅក្នុងបរិបទជាភាសាខ្មែរសម្រាប់សំណុំបែបបទពាក្យសុំ ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងគំរូស្តង់ដារ កិច្ចសន្យាផលិតកម្មកសិកម្ម។**
    ២. **ពិនិត្យមើលលទ្ធភាពគូភាគីដែលបានស្នើសុំអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម (សូមមើលផ្នែក ៣.២ នៅទំព័រដូចខាងក្រោម)។**
    ៣. **ជួយកំណត់អត្តសញ្ញាណដៃគូដែលមានសក្តានុពល ប្រសិនបើចាំបាច់។**
    ៤. **ផ្តល់ព័ត៌មានស្តីពីការគាំទ្រដែលអាចធ្វើបានផ្សេងទៀតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីគម្រោង ឬពីស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀតដែលអ្នកដាក់ពាក្យសុំអាចប្រើប្រាស់បាន។**

៥. ជួយសម្រួលដល់ការចរចារវាងភាគីទាំងពីរដើម្បីកំណត់លក្ខខណ្ឌពេញលេញនៃកិច្ចសន្យា និងប្រាកដថាសំណួរដែលពាក់ព័ន្ធទាំងអស់ត្រូវបានដោះស្រាយនៅក្នុងកិច្ចសន្យានេះ (សូមមើលផ្នែកទី ៤ នៃសៀវភៅនេះ)។

៦. យល់ព្រម ចេញលិខិតទទួលស្គាល់ កិច្ចព្រមព្រៀងនៃកិច្ចសន្យាផលិតកម្មកសិកម្មបន្ទាប់ពីភាគីទាំងពីរបានចុះហត្ថលេខារួចរាល់ និងបានអនុវត្តតាមគោលការណ៍ណែនាំដោយនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តសាមុី។

អាសយដ្ឋានទំនាក់ទំនង នាយកដ្ឋានកសិ-ឧស្សាហកម្ម៖
ផ្ទះលេខ ២៤២ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទលេខ +៨៥៥ (0)២៣ ២១៣ ១៤៥, +៨៥៥(0) ១២ ៣៨ ៦៣ ៩៧, +៨៥៥(0)១៧ ៥៩ ៦៩ ១៦,
+៨៥៥(0)១២ ៤១ 0៥ 0៨
អ៊ីមែល៖ dai-maff@camnet.com.kh, pheachkong@gmail.com, yihak77@gmail.com,
omsovannak@gmail.com

## ៣.១.២. ស្ថាប័នផ្សេងទៀតដែលអាចផ្តល់ការគាំទ្រ និងយោបល់

មានភាពច្បាស់ណាស់ថាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទមិនបានផ្តាច់មុខលើការផ្តល់សេវាប្រឹក្សាយោបល់ដល់អាជីវកម្មឬអង្គការកសិករដែលមានបំណងបង្កើតភាពជាដៃគូពាណិជ្ជកម្ម / ខ្សែសង្វាក់ផ្គត់ផ្គង់ដែលផ្អែកលើកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យានោះទេ។ អង្គភាពផ្សេងទៀតអាចត្រូវបានប្រមូលផ្តុំដោយអ្នកពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចដើម្បីគាំទ្រដល់ការបង្កើតភាពជាដៃគូផលិតកម្មកសិកម្មតាមកិច្ចសន្យា នៅក្នុងវិធីជាច្រើនដែលអាចត្រូវបានបំពេញបន្ថែមដល់សេវារបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ឧទាហរណ៍៖

- គម្រោង អង្គការជាតិ ឬអន្តរជាតិអាចផ្តល់ជំនាញ (ជាញឹកញាប់ ផ្អែកលើបទពិសោធន៍អន្តរជាតិ) និងក្នុងករណីខ្លះ ការគាំទ្របន្ថែម (សម្ភារ ឬពាក់ព័ន្ធនឹងការកសាងសមត្ថភាព)។
- សហភាពនៃអង្គការកសិករអាចបង្កើតសេវាដើម្បីគាំទ្រដល់សមាជិករបស់ខ្លួនក្នុងការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងរបស់ពួកគេ និងតភ្ជាប់ជាមួយដៃគូដែលមានសក្តានុពល។
- អង្គការពាណិជ្ជកម្ម ជាពិសេស នៅពេលដែលផ្តោតលើសង្វាក់តម្លៃជាក់លាក់ ដូចជា សហព័ន្ធស្រូវអង្ករកម្ពុជា (ឬការរៀបចំដែលមានភាពសមមូលសម្រាប់សង្វាក់តម្លៃផ្សេងទៀត) អាចផ្តល់វេទិកាដើម្បីជួយដល់អ្នកផលិត និងអ្នកទិញក្នុងការទទួលបានទំនាក់ទំនង និងកំណត់ដៃគូពាណិជ្ជកម្មពាក់ព័ន្ធ។ ក្នុងករណីមួយចំនួនដែលពួកគេអាចបង្កើត "ក្រមប្រតិបត្តិ" ដើម្បីឲ្យមានស្តង់ដារក្នុងការអនុវត្តន៍ និងធានាឲ្យបាននូវទំនាក់ទំនងពាណិជ្ជកម្មទូលំទូលាយ។
- ជាការពិតណាស់ មេធាវី ឬក្រុមហ៊ុនផ្តល់ប្រឹក្សាក៏អាចត្រូវបានប្រមូលផ្តុំដោយអ្នកពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចដើម្បីផ្តល់យោបល់លើការបង្កើតកិច្ចសន្យាផងដែរ។

នៅក្នុងដំណាក់កាលនៃការអនុវត្តន៍កិច្ចសន្យានេះអង្គភាពផ្សេងទៀតក៏អាចដើរតួនាទីជាក់លាក់ផងដែរ ហើយអាចត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចសន្យា ឧទាហរណ៍ដូចជា៖

- អង្គភាពផ្តល់ព័ត៌មានទីផ្សារ/ពិនិត្យតម្លៃអាចធ្វើជាអាជ្ញាកណ្តាលចំពោះតម្លៃ (ប្រសិនបើកិច្ចសន្យាមិនបានផ្អែកលើតម្លៃថេរទេនោះ ប៉ុន្តែត្រូវប្រើសេចក្តីយោងតម្លៃដែលបានឯកភាពគ្នា សូមមើលផ្នែក ៤.៧.នៅក្នុងសៀវភៅនេះ) ។
- មន្ទីរពិសោធន៍ ស្ថាប័នអធិការកិច្ច ឬស្ថាប័នចេញវិញ្ញាបនប័ត្រអាចជួយកំណត់លក្ខណៈវិនិច្ឆ័យ និងវិធីសាស្ត្រក្នុងការវាយតម្លៃគុណភាពផលិតផល ឬអាចធ្វើជាអាជ្ញាកណ្តាលក្នុងករណីមានវិវាទពាក់ព័ន្ធនឹងការវាយតម្លៃគុណភាពផលិតផលដែលបានបញ្ជូន។

## ៣.២. ការជ្រើសរើសដៃគូ[6] (អ្នកទិញ/អ្នកផលិត)

ភាគីទាំងពីរដែលបានចូលរួមនៅក្នុងគម្រោងភាពជាដៃគូនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវទទួលបានព័ត៌មានពីគ្នាទៅវិញទៅមក ហើយភាគីនីមួយៗត្រូវធ្វើការសម្រេចចិត្តដោយផ្ទាល់ ដើម្បីចូលខ្លួនក្នុងកិច្ចសន្យាជាមួយនឹងដៃគូដែលបានស្នើឡើងនោះ។

ជាផ្នែកមួយនៃការគាំទ្រដល់ផលិតកម្មកសិកម្មតាមកិច្ចសន្យា សេវារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម និង មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តសាម៉ី) អាចឆ្លុះបញ្ចាំងពីដៃគូដែលមានសក្តានុពល (ទាំងភាគីអ្នកផលិត និងភាគីអ្នកទិញ) និងអាចផ្តល់ជាគំនិតទៅឲ្យភាគីពាក់ព័ន្ធទាំងឡាយស្តីពីភាគីម្ខាងទៀត។ ដោយសារ ពិសេសសម្រាប់ភាគីអ្នកផលិត វាមិនមែនជាការងាយស្រួលក្នុងការវាយតម្លៃភាពជឿទុកចិត្តរបស់ក្រុមហ៊ុនដែលបានស្នើកិច្ចសន្យា ភាគីអ្នកផលិត (តាមរយៈសហគមន៍របស់ពួកគេ ឬអង្គការផលិតកររបស់ពួកគេ ប្រសិនបើមាន ឬអាចធ្វើទៅបានតាមរយៈអាជ្ញាធរមូលដ្ឋាន ប្រសិនបើពួកគេមានទំនាក់ទំនងជាមួយក្រុមហ៊ុនក្នុងនាមជាភាគីអ្នកផលិត) ត្រូវបានលើកទឹកចិត្តស្នើសុំជំនួយពីសេវារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីផ្ទៀងផ្ទាត់ពីភាពជឿទុកចិត្តនៃដៃគូរបស់ពួកគេ។

ពីរផ្នែកខាងក្រោមនេះត្រូវបានបញ្ជាក់អំពីលក្ខណៈវិនិច្ឆ័យមួយចំនួនដែលអាចចាត់ទុកថាជាការវាយតម្លៃលើភាពជឿទុកចិត្តរបស់ភាគីទាំងពីរ។

### ៣.២.១. ការប៉ាន់ប្រមាណលើការជឿទុកចិត្តលើក្រុមហ៊ុន (ភាគីអ្នកទិញ)

តារាងខាងក្រោមបញ្ជាក់អំពីបញ្ជីត្រួតពិនិត្យលក្ខណៈវិនិច្ឆ័យ ដែលអាចធ្វើទៅបានដែលអាចត្រូវបានពិចារណា និង វាយតម្លៃដោយអ្នកផលិត (ឬដោយសេវាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដើម្បីជួយពួកគេក្នុងការសម្រេចចិត្ត) មុនពេលដែលពួកគេចូលរួមនៅក្នុងកិច្ចព្រមព្រៀងនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយក្រុមហ៊ុន។

[6] ធាតុផ្សំមួយចំនួននៅក្នុងផ្នែកនេះមានការជំរុញដោយ "ការណែនាំសម្រាប់សម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មត្រឹមត្រូវ" ដ៏ល្អ ដែលត្រូវបានបោះពុម្ពផ្សាយដោយសេវាកម្មពង្រីកបន្ថែមរបស់កសិកម្ម និងរុក្ខាប្រមាញ់ជាតិ (NAFES) និងគម្រោងកសិកម្មពង្រីកបន្ថែមរបស់ឡាវ (LEAP) នៅក្នុងប្រទេសឡាវ ក្នុងខែមិថុនា ឆ្នាំ ២០១២ ។

**តារាង ៣.២.ក.៖ បញ្ជីត្រួតពិនិត្យជាមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យសម្រាប់ពិចារណា ក្នុងពេលប៉ាន់ប្រមាណលើភាពអាចជឿទុកចិត្តរបស់ភាគីអ្នកទិញ (ក្រុមហ៊ុនកសិ-ឧស្សាហកម្ម)**

| ល.រ | លក្ខណៈវិនិច្ឆ័យ | ប្រភពផ្ទៀងផ្ទាត់ | ចម្លើយ | | | សម្គាល់/យោបល់ |
|---|---|---|---|---|---|---|
| | | | ត្រូវ | មិនត្រូវ | មិនច្បាស់ | |
| **១. អត្តសញ្ញាណស្ថាប័នក្រុមហ៊ុន និងការចុះឈ្មោះ** | | | | | | |
| ១.១. | ឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុនដែលគេស្គាល់ | ឯកសារចុះបញ្ជី | | | | |
| ១.២. | ក្រុមហ៊ុនបានចុះឈ្មោះនៅកម្ពុជា | ប័ណ្ណប៉ាតង់/ចុះបញ្ជីជាមួយMOC | | | | ប្រសិនបើមិនមាន សូមមើលនីតិវិធីជាក់ស្តែងផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ការឆ្លងកាត់ប្រទេស (?) |
| ១.៣. | បានកំណត់អត្តសញ្ញាណអ្នកតំណាងដែលបានផ្តល់សិទ្ធិ | លិខិតប្រគល់សិទ្ធិ | | | | |
| ១.៤. | អាជ្ញាប័ណ្ណ/លិខិតអនុញ្ញាតដែលពាក់ព័ន្ធ | សួរក្រុមហ៊ុន | | | | |
| **២. កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន** | | | | | | |
| ២.១. | ក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះល្បីល្បាញ | | | | | |
| ២.២. | ក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះល្អ | | | | | |
| ២.៣. | ក្រុមហ៊ុនបានអនុវត្តអាជីវកម្មរួចមកហើយនៅក្នុងប្រទេសផ្សេង | | | | | |
| ២.៤. | ក្រុមហ៊ុនបានអនុវត្តអាជីវកម្មរួចមកហើយនៅក្នុងខេត្តផ្សេង | | | | | |
| ២.៥. | ការបញ្ជាក់ CSR | សួរក្រុមហ៊ុន | | | | |
| **៣. ភាពជឿទុកចិត្តផ្នែកហិរញ្ញវត្ថុ** | | | | | | |
| ៣.១. | ដើមទុនផ្ទាល់របស់ក្រុមហ៊ុនមាន | | | | | |
| ៣.២. | ចំណូលរបស់ក្រុមហ៊ុន | | | | | |
| ៣.៣. | អចលនវត្ថុនៅក្នុងប្រទេស (ដី/ដើមឈើ...) | | | | | |
| ៣.៤. | ដឹងពីបទពិសោធនៃការក្ស័យធន ឬការបង់ប្រាក់យឺតយ៉ាវរបស់ក្រុមហ៊ុនផ្គត់ផ្គង់ | | | | | |
| ៣.៥. | មានរបាយការណ៍ចំណូលអាក្រក់ទេ? | ធនាគារ?/ការិយាល័យឥណទាន? | | | | |
| ៣.៦. | ការរៀបចំការផ្តល់ហិរញ្ញប្បទានដែលបានស្នើឡើង? ជាក្រុមហ៊ុនផ្តល់មូលនិធិដោយខ្លួនឯង ឬទទួលបានប្រាក់កម្ចី? | | | | | |
| **៤. ភាពជឿទុកចិត្តផ្នែកពាណិជ្ជកម្ម/អាជីវកម្ម** | | | | | | |
| ៤.១. | ក្រុមហ៊ុនមានទីផ្សារល្អ និងអាចជឿទុកចិត្តបានសម្រាប់ផលិតផល | អាចពិនិត្យកិច្ចសន្យាជាមួយអតិថិជន | | | | |
| ៤.២. | ក្រុមហ៊ុនបានបញ្ជាក់យ៉ាងច្បាស់អំពីទិន្នផល និងប្រាក់ចំណេញនៃផលិតផលក្នុងបរិបទខ្នាតតូចនៅក្នុងប្រទេសកម្ពុជា | ការសិក្សាពីលទ្ធភាពរបស់ក្រុមហ៊ុនសម្រាប់គម្រោង។ | | | | |

### ៣.២.២. ការកំណត់អត្តសញ្ញាណតំបន់ និងអ្នកផលិតដែលមានសក្តានុពល

នៅក្នុងដំណាក់កាលដំបូងវិនិយោគិន/ ក្រុមហ៊ុននឹងចាប់ផ្តើមកំណត់អត្តសញ្ញាណបឋមនៃតំបន់ដែលមានសក្តានុពលសម្រាប់ផលិតកម្មដំណាំ/សត្វដែលពួកគេមានបំណងចង់ផ្គត់ផ្គង់។ នាយកដ្ឋានកសិ-ឧស្សាហកម្ម ឬ សេវាផ្សេងទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចជួយឲ្យក្រុមហ៊ុនស្វែងរកព័ត៌មានតំបន់កសិកម្ម។ បន្ទាប់មកដំណើរការកំណត់អត្តសញ្ញាណគឺត្រូវបានអនុវត្តបន្តនៅថ្នាក់ខេត្តឬថ្នាក់ស្រុកក្នុងតំបន់ដែលបានកំណត់ជាមុនតាមការសមស្រប។

ការគាំទ្រពី នាយកដ្ឋានកសិ-ឧស្សាហកម្ម និង មន្ទីរកសិកម្មកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត ពិតជានឹងផ្តល់ព័តមានដ៏មានប្រយោជន៍ក្នុងដំណាក់ការនេះ ដើម្បីពង្រឹងចំណេះដឹងអំពីស្ថានភាពកសិកម្ម ដែលមិនត្រឹមតែផ្តោតទៅលើចំណេះដឹងផ្នែកបច្ចេកទេសនោះទេ គឺថែមទាំងពង្រឹងចំណេះដឹងស្តីពីអត្ថិភាពមួយចំនួនដូចជា៖ អង្គការ ឬសហគមន៍កសិករ ឬក៏បញ្ហាសេដ្ឋកិច្ចសង្គម(លទ្ធភាពដីដែលទំនេរ ពលកម្ម ទុន ចំណាកស្រុកជាបណ្តោះអាសន្ន ។ល។ )

កសិករខ្លួនឯងផ្ទាល់ ( ឬ អ្នកតំណាងកសិករ) ត្រូវចូលរួម និងធ្វើការវាយតម្លៃសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីបំពេញលក្ខខណ្ឌនៃផលិតកម្មដំណាំ/សត្វ និងត្រូវចេះប៉ាន់ស្មានសកម្មភាពដែលខ្លួនអាចធ្វើបាន។

តារាងខាងក្រោមនេះបង្ហាញអំពីបញ្ជីផ្ទៀងផ្ទាត់ជាមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យ ដែលអាចយកមកពិចារណាក្នុងការវាយតម្លៃអំពី អ្នកផលិត / អង្គការអ្នកផលិត។

**តារាង ៣.២.ខ.៖ បញ្ជីត្រួតពិនិត្យជាមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យសម្រាប់ពិចារណា ក្នុងពេលប៉ាន់ប្រមាណភាពសមរម្យរបស់អ្នកផលិត**

| ល | លក្ខណៈវិនិច្ឆ័យ | ចម្លើយ | | | ចំណាប់អារម្មណ៍ / មតិ |
|---|---|---|---|---|---|
| | | ត្រូវ | មិនត្រូវ | មិនច្បាស់? | |
| ១.លក្ខខណ្ឌកសិអេកូឡូស៊ី | | | | | |
| ១.១ | លទ្ធភាពដីដែលទំនេរ? | | | | |
| | ↳ ផ្ទៃដី និង ស្ថានភាពបច្ចុប្បន្ន ( ដីដែលមិនបានប្រើ? ដែលបានប្រើសម្រាប់ដំណាំផ្សេងៗ? ធ្លាប់បានប្រើហើយសម្រាប់ដំណាំដូចគ្នា → គ្រាន់តែប្តូរទិសដៅទីផ្សារ)... | | | | |
| | ↳ គុណភាពដី | | | | |
| ១.២ | អំណោយផលអាកាសធាតុ? | | | | |
| ១.៣ | មានប្រពន្ធ័ធារាសាស្ត្រ? | | | | (ប្រសិនបើមានការទាក់ទងនឹងដំណាំ) |
| ១.៤ | ហានិភ័យដែលអាចមាន (សត្វល្អិត/ជំងឺ... វត្តមាននៃដំណាំឬសត្វផ្សេងៗដែលនៅក្បែរដែលអាចនាំជំងឺមក...) | | | | |
| ១.៥ | ប្រសិនបើចាំបាច់ ៖ សិទ្ធិក្នុងការទទួលបានវិញ្ញាបនប័ត្រជាក់លាក់ណាមួយ (ឧ. វិញ្ញាបនប័ត្រសរីរាង្គ...) | | | | |
| ២. សមត្ថភាពបច្ចេកទេស | | | | | |
| ២.១ | ភាពស៊ាំរបស់កសិករជាមួយនឹងផលិតកម្ម ឬ ដំណាំដែលបានស្នើរឡើង( ឬ ជាមួយនឹង ផលិតកម្ម ឬដំណាំដែលស្រដៀងគ្នា)? | | | | |
| ២.២ | លទ្ធភាពដែលអាចប្រើប្រាស់សេវាបច្ចេកទេស / សេវាកម្មបន្ថែម | | | | |
| ៣. លក្ខខណ្ឌសេដ្ឋកិច្ចសង្គម | | | | | |
| ៣.១ | ពលកម្ម និង ពេលវាលាដែលមាន (ការគិតអំពីសកម្មភាពតាមដំណាក់កាល ចំណាកស្រុកដែលអាចមានសកម្មភាពផ្សេងទៀតនៅហ្នឹងកន្លែង ឬក្រៅកន្លែង )។ | | | | |
| ៣.២ | លទ្ធភាពដែលមានសម្រាប់ឧបករណ៍ចាំបាច់ ឬទុន?លទ្ធ | | | | |
| | ភាពទទួលបានឥណទាន? | | | | |
| ៣.៣ | ប្រាក់ចំណូលដែលរំពឹងថាកើតមាន និង តម្លៃនៃឱកាស | | | | |
| ៣.៤ | ផលប៉ះពាល់ទៅលើសកម្មភាពកសិដ្ឋានផ្សេងទៀត ឬ ប្រភពចំណូល | | | | |
| ៤. អង្គការកសិករ ( ប្រសិនបើដឹងមុនថាកិច្ចសន្យានឹងត្រូវចុះហត្ថលេខជាមួយសហគមន៍/ អង្គការកសិករ ) | | | | | |
| ៤.១ | អត្ថិភាពនៃ ក្រុម / សហគមន៍កសិករ | | | | |
| ៤.២. | ការចុះបញ្ជី អង្គការកសិករ ផ្លូវការ (នីតិបុគ្គល ៖ អាចចុះហត្ថលេខាលើកិច្ចសន្យា) | | | | |
| ៤.៣ | បទពិសោធន៍របស់ អង្គការកសិករ ក្នុងការផ្តល់សេវាកម្មបច្ចេកទេសដល់សមាជិក។ | | | | |
| ៤.៤ | សមត្ថភាពធ្វើផែនការ និងបទពិសោធន៍ពីការប្រមូលផលិតផលនិងពាណិជ្ជភាវូបនីយកម្មនៃអង្គការកសិករ។ | | | | |
| ៤.៥ | អត្ថិភាព និង គុណភាពនៃការគ្រប់គ្រង/ គណនេយ្យហិរញ្ញវត្ថុ ។ល។ | | | | |
| ៤.៦ | ភាពជឿជាក់របស់សមាជិកមកលើអង្គការកសិកររបស់ពួកគេ។ | | | | |

## ៣.៣. ការចុះបញ្ជីកិច្ចសន្យា៖ គុណសម្បត្តិ គុណវិបត្តិ និងដំណើរការនៃការចុះបញ្ជីកិច្ចសន្យា

### ៣.៣.១. ហេតុអ្វីគួរចុះបញ្ជីកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ / នាយកដ្ឋានកសិ-ឧស្សាហកម្ម?

យោងទៅតាមគោលការណ៍ច្បាប់ស្តីពីការធ្វើការសម្រេចចិត្ត ( ចែងក្នុងក្រមរដ្ឋប្បវេណី) វាជាតម្រូវការចាំបាច់តាមផ្លូវច្បាប់សម្រាប់ភាគីអ្នកផលិត ឬ ក្រុមហ៊ុនឯកជនដែលចង់ដាក់ពាក្យសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីទទួលបានការអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា ឬ ចង់ឲ្យកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យារបស់ពួកគេ ទទួលបានការទទួលស្គាល់ ឬ ដឹងឮពី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ[7]។ ប៉ុន្តែក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ លើកទឹកចិត្តយ៉ាងខ្លាំង និងអញ្ជើញភាគីដែលមានឆន្ទៈក្នុងការអភិវឌ្ឍទៅលើកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីទាក់ទងរាល់សេវាកម្មរបស់ខ្លួនសម្រាប់ទទួលបានការណែនាំ និងការចុះបញ្ជីកិច្ចសន្យា។

**ដំណើរការនេះអាចនឹងមានភាពចាំបាច់ ប្រសិនបើរាល់ភាគីដែលកំពុងចុះកិច្ចសន្យាចង់ប្រើប្រាស់សេវាកម្មជាក់លាក់ណាមួយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្តន៍កិច្ចសន្យា ឧទាហរណ៍ ដូចជា ការប្រើប្រាស់ការសម្របសម្រួល ឬ ការផ្សះផ្សាវិវាទ ពីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទក្នុងករណីមានជម្លោះ ឬ ក៏ត្រូវការសេវាកម្មផ្សេង ទៀត ដែលបានរៀបរាប់ក្នុងផ្នែក ២.៣.២ នៃសៀវភៅណែនាំនេះ។**

ការណែនាំ និងការយល់ព្រមពីក្រសួង **កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ក៏បង្ហាញនូវផលប្រយោជន៍ និងគុណសម្បត្តិផ្សេងទៀតដូចដែលបានរៀបរាប់ក្នុងតារាងខាងក្រោម។

[7] កិច្ចព្រមព្រៀងស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលបានចុះហត្ថលេខាឡើងដោយគ្មានការយល់ព្រមជាមុនពី MAFF នឹងនៅតែមានសុពលភាពតាមផ្លូវច្បាប់ ហើយនឹងមិនត្រូវបានចាត់ទុកជាមោឃៈដោយតុលាការឡើយ។

តារាង ៣.៣.ក.៖ គុណសម្បត្តិ និងគុណវិបត្តិនៃការចុះបញ្ជីកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| . ក្រុមហ៊ុនពាណិជ្ជកម្មកសិកម្មអាចទទួលបានព័ត៌មានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទៅលើតំបន់ផលិតកម្មដែល មានសក្តានុពល និងទទួលបានការគាំទ្រដើម្បីកំណត់អ្នកផលិត ដែលសាកសមអំពី (សហគមន៍កសិកម្ម, អង្គការកសិករ, សមាគមឬក្រុមកសិករស្របច្បាប់ផ្សេងៗទៀត )<br><br>. សេវាកម្មរបស់ក្រសួងកសិកម្មរុក្ខា ប្រមាញ់និងនេសាទ/នាយកដ្ឋានកសិ-ឧស្សាហកម្មអាចនឹងពិនិត្យលើភាពជឿជាក់របស់ក្រុមហ៊ុនដែលអាចទុកចិត្តបានទៅលើក្រុមហ៊ុននោះ និងបង្កើន សន្តិសុខសម្រាប់ខាងអ្នកផលិត។<br><br>. ការយល់ព្រមក្នុងការចូលរួមពីភាគីទីបីដែលមានភាពអព្យាក្រឹត្យ (ដូចជាក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ) បង្កើតឱ្យមាន ការទុកចិត្តពីភាគីផ្សេងៗក្នុងកិច្ចសន្យា និងពង្រឹងការប្តេជ្ញាចិត្ត របស់ពួកគេ។<br>. ភាគីទាំងអស់អាចទទួលការគាំទ្រកំឡុងពេលធ្វើការចរចា និង ធ្វើការព្រាងក្រដាសកិច្ចសន្យា ហើយ និងពិនិត្យលក្ខខណ្ឌនៃកិច្ច សន្យាឲ្យមានគុណភាព និងប្រាកដនិយម។<br><br>. ភាគីទាំងអស់អាចទទួលបានការជួយសម្រួល ឬ សម្រុះសម្រួលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងករណីមានជម្លោះ។<br><br>. ការចុះឈ្មោះជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជារឿងចាំបាច់ក្នុងការទទួលបានការគាំទ្របន្ថែមទៀត ឬ ការលើកទឹកចិត្តពី រាជរដ្ឋាភិបាល។<br><br>. អនុលោមទៅតាមតម្រូវការច្បាប់ផ្សេងៗទៀតដែលបានបញ្ជាក់ក្នុងការធានាសន្តិសុខរវាងភាគីអ្នកផលិតនិងអ្នកទិញ។<br><br>. ការចុះឈ្មោះកិច្ចសន្យាជួយឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលបានពត៌មានពី ផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងការត្រួតពិនិត្យ ការទទួលបទពិសោធន៍ និង ការវាយការណ៍ ដើម្បីធ្វើឱ្យប្រសើរឡើងលើគោលនយោបាយ។ | • តម្រូវការក្នុងការប្រមូលសេវាកម្មរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិ-ឧស្សាហកម្ម/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) អាចត្រូវចំណាយពេល និង អាចធ្វើ ឲ្យមានការយឺតដល់ដំណើការចរចា និង ការចុះហត្ថលេខាលើកិច្ចសន្យា<br><br>ត្រូវមានការរំពឹងទុកជាមុនឲ្យបានច្រើន! |

**ទោះបីជាមិនទាន់ចុះបញ្ជីកិច្ចសន្យាក៏ដោយ ក្រុមហ៊ុនទាំងអស់ដែលទាក់ទងជាមួយនឹង ផលិតកម្មកសិកម្មតាមកិច្ចសន្យាទាំងអស់ ត្រូវផ្តល់ព័ត៌មានទៅកាន់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ / នាយកដ្ឋានកសិ-ឧស្សាហកម្ម /មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលកំពុងដំណើរការ ឬ កំពុងធ្វើការចរចា ។**

## ៣.៣.២. នីតិវិធីដើម្បីចុះបញ្ជីកិច្ចសន្យាផលិតកម្មកសិកម្ម

ភាគីពាក់ពន្ធ័ទាំងអស់ដែលមានបំណងចង់បានការយល់ព្រម និងចុះបញ្ជីសម្រាប់កិច្ចព្រមព្រៀងពីផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តតាម (តាំងពីដំណាក់កាលមុនដំបូងនៃការចរចាពីកិច្ចសន្យាផលិតកម្មកសិកម្ម) នីតិវិធីដើម្បីទទួលការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដូចដែលបានរៀបរាប់ខាងលើក្នុងសៀវភៅណែនាំក្នុង "ផ្នែក ៣.១.១ សេវាកម្មគាំទ្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានស្នើរជូនទៅដល់ភាគីពាក់ពន្ធ័ខាងផ្នែកសេដ្ឋកិច្ចដែលមានឆន្ទៈក្នុងការអភិវឌ្ឍទៅលើ ផលិតកម្មកសិកម្មតាមកិច្ចសន្យា ទំព័រ ៣៨ ។

ប្រសិនបើនីតិវិធីទាំងអស់ខាងលើនោះត្រូវបានអនុវត្តតាម។ បន្ទាប់មក ភាគីទាំងអស់បានចុះហត្ថលេខលើកិច្ចព្រមព្រៀងស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ហើយបន្ទាប់មកទៀត សាក្សីបានចុះហត្ថលេខា (ប្រសិនបើមាន)។ ភាគីណាមួយក៏ដោយនៃភាគីទាំងពីរ ( ប៉ុន្តែជាញឹកញាប់ ភាគីអ្នកទិញ) ត្រូវផ្ញើរច្បាប់ដើមចំនួន ៥ ច្បាប់នៃឯកសារកិច្ចសន្យា (ប៉ុន្តែអាចត្រូវការច្បាប់ដើមបន្ថែមទៀត ក្នុងករណីដែលមានការចូលរួមពីភាគីទីបី – សូមមើល ផ្នែក ៤.១៤.២. លេខឯកសារថតចម្លងក្នុងសៀវភៅណែនាំនេះ ទំព័រ ១១១) ទៅកាន់ មន្ទីរកសិកម្ម ឬ នាយកដ្ឋានកសិ-ឧស្សាហកម្ម[8] ជាមួយនឹងលិខិតអមឯកសារសំរាប់ស្នើរសុំការយល់ព្រម និងការចុះបញ្ជីកិច្ចសន្យាពីសេវាកម្មរបស់ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ។

មន្ត្រីពាក់ព័ន្ធនឹងពិនិត្យមើលកិច្ចសន្យាឡើងវិញ និងចុះហត្ថលេខា ក៏ដូចជាបោះត្រាលើច្បាប់ដើមទាំងនោះ។ សេវាកម្មរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរក្សាទុកឯកសារច្បាប់ដើម ៣ ច្បាប់ ហើយផ្ញើរទៅឲ្យអ្នកទិញមួយច្បាប់ និងអ្នកផលិតមួយច្បាប់ទៀត (អាចត្រូវការច្បាប់ដើមបន្ថែមទៀត ក្នុងករណីដែលមានការចូលរួមពីភាគីទីបី)។

ដំណើរការនៃការយល់ព្រម និងការចុះបញ្ជីកិច្ចសន្យា អាចនឹងត្រូវចំណាយពេលប្រហែលប្រាំពីរថ្ងៃនៃថ្ងៃធ្វើការ (អាចនឹងមានការប្រែប្រួល) ចាប់ពីថ្ងៃដែលភាគីទាំងអស់ផ្ញើរកិច្ចសន្យា ដើម្បីសុំការយល់ព្រម និងការចុះបញ្ជីរហូតដល់ថ្ងៃដែលគេអាចទទួលច្បាប់ដើមមកវិញដោយមានការយល់ព្រមពីសេវាកម្មរបស់ នាយកដ្ឋានកសិ-ឧស្សាហកម្ម /មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ប្រសិនបើការអនុវត្តកិច្ចសន្យាត្រូវចាប់ផ្តើម ហើយភាគីទាំងអស់ ចង់រក្សារទុកឯកសារបម្រុងច្បាប់ដើមនៃកិច្ចសន្យា នៅពេលដែលភាគីទាំងនោះផ្ញើរឯកសារបម្រុងច្បាប់ដើម ដែលចាំបាច់មួយចំនួនសម្រាប់ដំណើរការចុះបញ្ជី នោះភាគីទាំងអស់អាចនឹងត្រូវចុះហត្ថលេខាលើឯកសារបម្រុងពីរច្បាប់ដើមបន្ថែមទៀត ( មួយច្បាប់សម្រាប់ភាគីនីមួយៗ) ដែលពួកគេនឹងរក្សាវាទុក។ ហើយឯកសារច្បាប់ដើមត្រូវបញ្ជូនមកសេវាកម្មរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដំណើរការចុះបញ្ជី។

[8] កម្រិតដែលត្រូវផ្ញើរអាស្រ័យលើតម្លៃប៉ាន់ប្រមាណរបស់កិច្ចសន្យា។ តម្លៃប៉ាន់ប្រមាណជាក់ស្តែងខាងលើ (ដែលត្រូវសម្រេចដោយ MAFF) អ្នកស្នើសុំចាំបាច់ត្រូវផ្ញើរទៅ DAI នៅរាជធានីភ្នំពេញដោយផ្ទាល់ និងមិនត្រូវផ្ញើរទៅ មន្ទីរកសិកម្ម ឡើយ។

# ផ្នែកទី ៤ ៖ ខ្លឹមសារកិច្ចសន្យា និងយោបល់សម្រាប់ការចរចា និងការសរសេរកិច្ចសន្យា៖

សំនួរគន្លឹះដែលកិច្ចសន្យាត្រូវដោះស្រាយ និងចម្លើយ ឬ ម៉ូឌែលដែលអាចប្រើបាន មិនមានម៉ូឌែលស្តង់ដារសម្រាប់កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាទេ។ តាមនិយមន័យ កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺជាលទ្ធផលនៃការចរចារវាងភាគីពីរ ឬ ច្រើន ហើយវាត្រូវច្នៃប្រឌិតទៅតាមករណីជាក់ស្តែង និងដោះស្រាយទៅតាមស្ថានភាពនិងតម្រូវការជាក់លាក់របស់ភាគីពាក់ព័ន្ធ។ អាស្រ័យហេតុនេះ ផ្នែកនេះនឹងមិនផ្តល់ជាម៉ូឌែលស្តង់ដារនៃកិច្ចសន្យាដើម្បីជាដំណោះស្រាយតែមួយទេ។ ផ្នែកនេះនឹងគ្រាន់តែលើកយកសំនួរគន្លឹះខ្លះៗដែលកិច្ចសន្យាត្រូវតែលើកយកមកដោះស្រាយ។ ចម្លើយនៃសំនួរទាំងនោះត្រូវយកមកពិភាក្សា និងមានការចរចារវាងភាគីនៃកិច្ចសន្យា។

ផ្ទុយពីការយល់ព្រមផ្ទាល់មាត់ "ចាប់ដៃគ្នា" ដែលទទួលស្គាល់ទម្លាប់ដែលមានស្រាប់ កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា គួរតែធ្វើឡើង *"ជាលាយលក្ខណ៍អក្សរ ត្រង់ៗ និងសាមញ្ញ[...] ដើម្បីឲ្យមានភាពច្បាស់លាស់ ពេញលេញ អាចអនុវត្តបាន និងមានប្រសិទ្ធភាពសម្រាប់បណ្តាភាគី"*[៩]។

ទម្រង់នៃកិច្ចសន្យាដែលបានស្នើដោយនាយកដ្ឋានកសិ-ឧស្សាហកម្ម (សូមមើលឧបសម្ព័ន្ធ ៤ និងការអភិវឌ្ឍក្នុងផ្នែក ៤.១ ខាងក្រោម) គឺគ្រាន់តែជាទម្រង់ទូទៅប៉ុណ្ណោះ៖ ទម្រង់នេះផ្តល់ជាគំនិតសម្រាប់រចនាសម្ព័ន្ធនៃកិច្ចសន្យា ដែលរួមមានក្បាលជំពូក ឬប្រធានបទនៃប្រការ ដោយឆ្លើយតបទៅនឹងសំនួរគន្លឹះដែលត្រូវដោះស្រាយនៅក្នុងកិច្ចសន្យា។

កថាខណ្ឌខាងក្រោមនេះ (ពី ៤.២ ដល់ ៤.១៤) ផ្តល់នូវចម្លើយដែលអាចប្រើការបាន ឬម៉ូឌែលអាចប្រើបាន ឬជម្រើសនានាសម្រាប់សំនួរគន្លឹះនីមួយៗ ព្រមទាំងមានយោបល់និងការវិភាគខ្លះៗអំពីគុណសម្បត្តិនិងគុណវិបត្តិនៃជម្រើសផ្សេងៗគ្នា។

## ៤.១.ទម្រង់នៃកិច្ចសន្យា ( គំរូ)

នាយកដ្ឋានកសិ-ឧស្សាហកម្មរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ (ជាការសាកល្បង[១០]) នូវរចនាសម្ព័ន្ធនៃកិច្ចសន្យាដូចមានបង្ហាញនៅខាងក្រោម។ បណ្តាភាគីមិនមានកាតព្វកិច្ចដើម្បីធ្វើតាមលក្ខខណ្ឌទាំងនេះទេ។ ទម្រង់ផ្សេងទៀតនៃកិច្ចសន្យាអាចមានភាពស្របច្បាប់ដូចគ្នា។ រចនាសម្ព័ន្ធដែលលើកជាយោបល់ខាងក្រោមនេះ គ្រាន់តែជាអ្វីគួរពិចារណា និងជាអនុសាសន៍តែប៉ុណ្ណោះ (វាក៏នៅតែអាចកែសម្រួលបន្ថែមបាន) ដើម្បីគ្របដណ្តប់លើចំណុចសំខាន់ៗ ដែលត្រូវពិភាក្សានិងឯកភាពគ្នានៅពេលចរចាលើកិច្ចសន្យា។ ព័ត៌មានលម្អិតអំពីតួនាទីនិងភារកិច្ចទទួលខុសត្រូវរបស់ភាគីទាំងពីរ ដែលមិនបានពិភាក្សាគ្នានិងឯកភាពគ្នាជាមុន អាចក្លាយជាចំណុចវិវាទ ហេតុនេះហើយគេគួរពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយនូវការរៀបចំចំណុចសំខាន់ៗ ការអនុវត្តន៍ដំណោះស្រាយទុកជាមុន ប្រសិនបើវិវាទកើតឡើង។

---

[៩] ឯកសារយោង៖ UNIDROIT, FAO និង IFAD (២០១៥)៖ "Legal Guide on Contract Farming" ទំព័រ ៦៧។

[10] ជាផ្នែកមួយដ៏សំខាន់របស់ "Support to the Commercialization of Cambodian Rice Project"។

## ៤.១.១. ទិដ្ឋភាពទូទៅនៃរចនាសម្ព័ន្ធកិច្ចសន្យា

ខាងក្រោមនេះគឺជារចនាសម្ព័ន្ធរួមនៃកិច្ចសន្យា៖

| រចនាសម្ព័ន្ធសម្រាប់កិច្ចសន្យាផលិតកម្មកសិកម្ម |
|---|
| ចំណងជើងកិច្ចសន្យា |
| ឈ្មោះនិងអាសយដ្ឋាន /ព័ត៌មាននៃកិច្ចសន្យា នៃភាគីហត្ថលេខី |
| ឯកសារយោងផ្លូវច្បាប់ |
| ប្រការ ១៖ គោលបំណងនៃកិច្ចសន្យា |
| ប្រការ ២៖ រយៈពេលនៃកិច្ចសន្យា |
| ប្រការ ៣៖ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកផលិត |
| ប្រការ ៤៖ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ |
| ប្រការ ៥៖ ការរៀបចំផ្នែកភស្តុភារសម្រាប់ការប្រមូលផល / ការប្រមូលផល |
| ប្រការ ៦៖ លក្ខខណ្ឌគុណភាព/លក្ខណៈបច្ចេកទេស |
| ប្រការ ៧៖ តម្លៃ |
| ប្រការ ៨៖ វិធីទូទាត់ប្រាក់ |
| ប្រការ ៩៖ ហានិភ័យនិងប្រធានសក្តិ |
| ប្រការ ១០៖ ការបញ្ចប់កិច្ចសន្យា |
| ប្រការ ១១៖ ការដោះស្រាយវិវាទ |
| ប្រការ ១២៖ ការបង្កើតកិច្ចសន្យានិងភាសា |
| កាលបរិច្ឆេទនិងហត្ថលេខានៃភាគីចុះកិច្ចសន្យា |
| ហត្ថលេខារបស់សាក្សី |
| ឧបសម្ព័ន្ធ |

## ៤.១.២. មតិយោបល់លើខ្លឹមសារនៃផ្នែកនីមួយៗដែលបានរំពឹងទុក

តារាង ៤.១ ក. ខាងក្រោម ផ្តល់នូវព័ត៌មានលម្អិតអំពីអ្វីដែលបានរំពឹងទុកនៅក្នុងផ្នែកនីមួយៗនៃទម្រង់កិច្ចសន្យាខាងលើ។

តារាង ៤.១ ក ៖ ខ្លឹមសារដែលរំពឹងទុករបស់ផ្នែកនីមួយៗនៃគំរូកិច្ចសន្យា និងមតិយោបល់

| ផ្នែក/ប្រការ | ការពន្យល់ / មតិយោបល់ / ឧទាហរណ៍ |
|---|---|
| **ចំណងជើងកិច្ចសន្យា** | ចំណងជើងខ្លីនៃកិច្ចសន្យា (គួរមានលេខយោង ដើម្បីងាយគ្រប់គ្រងលេខកិច្ចសន្យា)៖<br>*ឧទាហរណ៍៖*<br>**« កិច្ចសន្យាផលិតកម្មកសិកម្មលេខ ......**<br>**សម្រាប់ផលិតកម្ម *[ ឈ្មោះផលិតផល]* »** |
| ឈ្មោះនិងអាសយដ្ឋាន / ព័ត៌មានរបស់អ្នកចុះហត្ថលេខាលើកិច្ចសន្យា | ខាងក្រោមចំណងជើង សូមសរសេរ "ធ្វើឡើងរវាង" និងឈ្មោះអ្នកចុះហត្ថលេខា។ ត្រូវមានផ្តល់គ្រប់ព័ត៌មានឲ្យបានច្បាស់ដើម្បីងាយកំណត់អត្តសញ្ញាណអ្នកចុះហត្ថលេខា ៖ មិនត្រឹមតែឈ្មោះ និងអាសយដ្ឋានទេ ប៉ុន្តែត្រូវមានលេខចុះបញ្ជី និងឈ្មោះតំណាង (សម្រាប់នីតិបុគ្គល) ឬថ្ងៃខែឆ្នាំកំណើត និងលេខអត្តសញ្ញាណប័ណ្ណ (សម្រាប់រូបវន្តបុគ្គល)។<br><br>*ឧទាហរណ៍៖*<br>**« ធ្វើឡើងរវាង៖**<br>***[ ឈ្មោះក្រុមហ៊ុនចុះកិច្ចសន្យា]* ចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា លេខ *[ លេខចុះបញ្ជី]* មានអាសយដ្ឋាននៅ *[ អាសយដ្ឋានរបស់ក្រុមហ៊ុន]* តំណាងដោយលោក/លោកស្រី *[ ឈ្មោះតំណាងស្របច្បាប់ ឬអ្នកដែលមានសិទ្ធិចុះហត្ថលេខាលើកិច្ចសន្យា]* ទូរស័ព្ទលេខ *[ បញ្ចូលលេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែល]* ហៅកាត់ថា ភាគីអ្នកទិញ។**<br><br>**និង »**<br><br>ប្រសិនបើអ្នកផលិតគឺជាកសិករលក្ខណៈផ្ទាល់ខ្លួន៖<br>**« *[ ឈ្មោះអ្នកផលិត]* កើតនៅ *[ បញ្ចូលថ្ងៃខែឆ្នាំកំណើត]* (កាន់អត្តសញ្ញានប័ណ្ណលេខ ៖ *[ បញ្ចូលលេខអត្តសញ្ញាណប័ណ្ណ ]* មានអាសយដ្ឋានអចិន្ត្រៃយ៍នៅ *[ បញ្ចូលអាសយដ្ឋាន]* លេខទូរស័ព្ទ ៖ *[ បញ្ចូលលេខទូរស័ព្ទ ]*, ហៅកាត់ថា ភាគីអ្នកផលិត។**<br><br>ប្រសិនបើអ្នកផលិតគឺជាអង្គការកសិករ៖<br>« *[ឈ្មោះអង្គការអ្នកផលិត]* ចុះបញ្ជីជាមួយ *[បញ្ចូលស្ថាប័ននៃនីតិបុគ្គលដែលបានចុះបញ្ជីជាអង្គការកសិករ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងមហាផ្ទៃ ឬក្រសួងធនធានទឹក ...]* មានលេខ *[លេខបញ្ជី]* ទីតាំងស្ថិតនៅ *[អាសយដ្ឋានរបស់អង្គការកសិករ]* តំណាងដោយលោក / លោកស្រី *[ឈ្មោះតំណាង ដែលនឹងចុះហត្ថលេខាលើកិច្ចសន្យា]* ទំនាក់ទំនងតាម *[បញ្ចូលលេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែល បើមាន]* ហៅកាត់ថា អ្នកផលិត។ |
| **យោង** | កិច្ចសន្យាអាចរៀបរាប់អំពីសារតាផ្នែកច្បាប់ឬក្របខណ្ឌការងារដែលបានបង្កើតកិច្ចសន្យានេះ ដូចជា ក្រមរដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ក្របខណ្ឌគតិយុត្តិជាក់លាក់ស្តីពីកសិកម្មចុះកិច្ចសន្យា (អនុក្រឹត្យលេខ ៣៦) ជាដើម ។ ឯកសារទាំងនេះអាចពាក់ព័ន្ធនឹងនីតិវិធីនៃការ |

| | |
|---|---|
| | ពង្រឹងការអនុវត្តច្បាប់។<br>ឧទាហរណ៍ យោងអនុក្រឹត្យស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា៖<br><br>**« បានឃើញ៖**<br>**- អនុក្រឹត្យ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១ ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា »** |
| **ប្រការ ១៖ គោលបំណងនៃកិច្ចសន្យា** | ប្រការដំបូងបង្ហាញអំពីគោលបំណងនៃកិច្ចសន្យា។ ឧទាហរណ៍៖<br>**« កិច្ចសន្យានេះធ្វើឡើងពាក់ព័ន្ធនឹងការផលិតរបស់អ្នកផលិត និងការទិញរបស់អ្នកទិញ *[ បញ្ចូលបរិមាណនិងឯកតា – ដូចជា ១០០ តោន]* នៃ *[ បញ្ចូលប្រភេទនៃផលិតផលដែលត្រូវផ្គត់ផ្គង់–* *ឧទាហរណ៍ ស្រូវផ្កាម្លិះស្រស់]* ។**<br>ព័ត៌មានលម្អិតនៃលក្ខណៈបច្ចេកទេសគុណភាព មានរៀបរាប់នៅក្នុងប្រការ ៦ ប៉ុន្តែប្រភេទនៃផលិតផលត្រូវមានបញ្ជាក់នៅទីនេះ (រួមមានពូជ ទម្រង់នៃផលិតផល – កម្រិតនៃការកែច្នៃ ដូចជាស្រូវ "ស្ងួត" ឬ "សើម" ... – ជាដើម។<br>[សម្គាល់៖ សូមមើល ផ្នែក ៤.៣ ប្រភេទនៃផលិតផលនិងបរិមាណដែលត្រូវផ្គត់ផ្គង់ (ទំព័រ ៥៨)]។ |
| **ប្រការ ២៖ រយៈពេលនៃកិច្ចសន្យា** | បញ្ជាក់អំពីរយៈពេលនៃកិច្ចសន្យា (ពីថ្ងៃចុះកិច្ចសន្យា រហូតដល់ថ្ងៃចុងក្រោយនៃការផ្គត់ផ្គង់ផលិតផល។ កិច្ចសន្យាក៏អាចបញ្ជាក់ឲ្យច្បាស់លាស់នៅទីនេះ ប្រសិនបើវាគឺសម្រាប់តែការផលិតតែមួយវដ្តផលិតកម្ម ឬសម្រាប់ច្រើនវដ្តផលិតកម្ម។ |
| **ប្រការ ៣៖ សិទ្ធិនិងកាតព្វកិច្ចភាគីអ្នកផលិត** | សិទ្ធិនិងកាតព្វកិច្ចដោយឡែក និងបញ្ជីនៃចំណុចពាក់ព័ន្ធ (ខាងក្រោម គឺជាឧទាហរណ៍តែប៉ុណ្ណោះ – ដែលត្រូវកែតម្រូវ អាស្រ័យទៅតាមការចរចានៃកិច្ចសន្យា) ៖<br>**« អ្នកផលិតមានសិទ្ធិដូចតទៅ ៖ [ + រៀបរាប់ជាចំណុចៗ ] ៖**<br>**• សិទ្ធិដើម្បីទទួលការគាំទ្រពីអ្នកទិញ ដូចបានកំណត់នៅក្នុងប្រការ ៤**<br>**• សិទ្ធិដើម្បីទទួលការទូទាត់ប្រាក់សម្រាប់ផលិតផលដែលអាចទទួលយក ដែលបានផ្គត់ផ្គង់ តាមលក្ខខណ្ឌខាងក្រោម នៃតម្លៃនិងការទូទាត់ប្រាក់ ដូចបានបញ្ជាក់នៅក្នុងកិច្ចសន្យា។**<br>**• សិទ្ធិដើម្បីតវ៉ា និងមានអ្នកសម្របសម្រួល/មជ្ឈិតករ តាមការឯកភាពនៅក្នុងប្រការ ១១ ក្នុងករណីដែល អ្នកទិញមិនបំពេញកាតព្វកិច្ច ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យាបច្ចុប្បន្ន។**<br>**ភាគីអ្នកផលិតមានកាតព្វកិច្ចដូចតទៅ [ + រៀបរាប់ជាចំណុចៗ] ៖**<br>**• ផលិតនិងផ្គត់ផ្គង់ផលិតផលដូចមានកំណត់នៅក្នុងប្រការ ១ ជូនអ្នកទិញ ដូចមានកំណត់នៅក្នុងកិច្ចសន្យានេះ។**<br>**• ធានាថាគុណភាពនៃផលិតផលដែលផ្តល់ជូន គឺស្របទៅតាមលក្ខណៈបច្ចេកទេសដូចមានកំណត់នៅក្នុងប្រការ ៦។**<br>**• អនុវត្តតាមវិធីសាស្ត្រនៃការផលិត ដូចបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ [ ១៨៥] ។**<br>[សម្គាល់៖ នៅលើចំណុចនេះ សូមមើលផ្នែក ៤.៤ កាតព្វកិច្ចពាក់ព័ន្ធនឹងវិធីសាស្ត្រ |

| | |
|---|---|
| | ផលិត និងការផ្ទៀងផ្ទាត់ (ទំព័រ ៦៦)]។<br>• អនុញ្ញាតឲ្យបុគ្គលិកអ្នកទិញចូល និងត្រួតពិនិត្យទីតាំងរបស់អ្នកផលិតដើម្បីផ្ទៀងផ្ទាត់ការអនុលោមតាមលក្ខខណ្ឌដែលបានឯកភាព និងលក្ខខណ្ឌដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាបច្ចុប្បន្ន។<br>• ផ្តល់ការផលិតស្របតាមនីតិវិធីដែលបានកំណត់នៅក្នុងប្រការ ៥។<br>• ទូទាត់សងប្រាក់បុរេប្បទានដែលបានទទួលពីអ្នកទិញស្របតាមនីតិវិធី ដែលបានបង្កើតនៅក្នុងកិច្ចសន្យាបច្ចុប្បន្ន។<br>• អនុវត្តតាមលក្ខខណ្ឌផ្សេងទៀតនៃកិច្ចសន្យាបច្ចុប្បន្ន។<br>• ទទួលខុសត្រូវលើការសងប្រាក់ជំងឺចិត្ត ជូនអ្នកទិញក្នុងករណីមិនអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាបច្ចុប្បន្ន ចំនួន <*បញ្ចូលទឹកប្រាក់ដែលត្រូវសងនិងប្រភេទរូបិយប័ណ្ណ*>។ » |
| ប្រការ ៤៖ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ | ស្រដៀងគ្នានឹងប្រការ ៣ ដែរ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ អាចមានចែងដូចខាងក្រោម (ឧទាហរណ៍ តែប៉ុណ្ណោះ – ត្រូវអាស្រ័យទៅតាមការចរចា)៖<br>« ភាគីអ្នកទិញមានសិទ្ធិដូចខាងក្រោម [ + រៀបរាប់ជាចំណុចៗ]៖<br>• សិទ្ធិចូល និងត្រួតពិនិត្យទីតាំងរបស់អ្នកផលិតដើម្បីផ្ទៀងផ្ទាត់ការអនុលោមតាមលក្ខខណ្ឌដែលបានឯកភាព និង លក្ខខណ្ឌដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាបច្ចុប្បន្ន។<br>• សិទ្ធិទទួលបានផលិតផលស្របតាមកិច្ចសន្យាបច្ចុប្បន្ន។<br>• សិទ្ធិដើម្បីបដិសេធផលិតផលមួយផ្នែកឬទាំងស្រុង ក្នុងករណី មិនអនុលោមតាមលក្ខណៈបច្ចេកទេសគុណភាព ឬរបៀបផលិតដែលបានកំណត់នៅក្នុងកិច្ចសន្យាបច្ចុប្បន្ន។<br>• សិទ្ធិដើម្បីតវ៉ា និងមានអ្នកសម្របសម្រួល/មជ្ឈត្តករ តាមការឯកភាពនៅក្នុងប្រការ ១១ ក្នុងករណីដែល អ្នកផលិតមិនបំពេញកាតព្វកិច្ច ដូចមានបញ្ជាក់នៅក្នុងកិច្ចសន្យាបច្ចុប្បន្ន។<br>ភាគីអ្នកទិញមានកាតព្វកិច្ចដូចខាងក្រោម [ + រៀបរាប់ជាចំណុចៗ] ៖<br>• ផ្តល់ធាតុចូលសម្រាប់អ្នកផលិត [ + រៀបរាប់ជាចំណុចៗ]។<br>• ផ្តល់ប្រាក់បុរេប្បទានដូចខាងក្រោមទៅអ្នកផលិត៖ [ + រៀបរាប់ពីប្រាក់បុរេប្បទាន] ។<br>• ផ្តល់ការបណ្តុះបណ្តាល ឬការគាំទ្របច្ចេកទេស [ +រៀបរាប់ពីការបណ្តុះបណ្តាល ឬការគាំទ្របច្ចេកទេស] ។<br>• ប្រមូល (ការអនុវត្តតាមនីតិវិធីដែលបានរៀបរាប់នៅក្នុងប្រការ ៥) និងការទិញផលិតផល ដែលបានផ្តល់ដោយអ្នកផលិត ស្របតាមលក្ខខណ្ឌគុណភាព ដែលបានកំណត់នៅក្នុងប្រការ ៦ យ៉ាងតិចក្នុងបរិមាណដែលបានកំណត់ក្នុងប្រការ ១។<br>[សម្គាល់៖ ពាក់ព័ន្ធទំហំ៖ សូមមើលរូបភាព ៤.៣ ក នៅទំព័រ ៦០] |

| | |
|---|---|
| | • បង់ថ្លៃទំនិញដែលបានប្រគល់តាមតម្លៃដែលបានកំណត់ស្របតាមប្រការ ៧ ទៅតាមវិធីទូទាត់ប្រាក់ដែលបានបញ្ជាក់ក្នុងប្រការ ៨។<br>• អនុវត្តតាមគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាបច្ចុប្បន្ន។<br>• ទទួលខុសត្រូវចំពោះការសងជំងឺទៅអ្នកផលិត ក្នុងករណីមិនអនុវត្តតាមលក្ខខណ្ឌចែងក្នុងកិច្ចសន្យាបច្ចុប្បន្ន ចំនួន *<បញ្ចូលចំនួនទឹកប្រាក់និងរូបិយប័ណ្ណ។>* »<br>ពាក់ព័ន្ធនឹងការគាំទ្ររបស់អ្នកទិញចំពោះអ្នកផលិត ប្រសិនបើការគាំទ្រគឺនៅកម្រិតធម្មតា វាអាចមានរៀបរាប់នៅក្នុងប្រការនេះ។ ក្នុងករណីភាគច្រើន គួរមានប្រការបន្ថែម ឬរៀបរាប់ក្នុងឧបសម្ព័ន្ធដើម្បីលម្អិត (ធាតុចូលដែលត្រូវផ្តល់ គុណភាពនៃធាតុចូល ពេលដែលត្រូវផ្តល់ធាតុចូល របៀបទូទាត់ប្រាក់សម្រាប់ធាតុចូល ... ដូចគ្នានេះដែរ សម្រាប់ការគាំទ្រផ្នែក បច្ចេកទេស។). [សូមមើលផ្នែក ៤.២ ការគាំទ្ររបស់អ្នកទិញ៖ ធាតុចូល/បុរេហិរញ្ញប្បទាន / យោបល់បច្ចេកទេស (ទំព័រ ៥៦)]។ |
| **ប្រការ ៥៖ ការរៀបចំផ្នែកភស្តុភារសម្រាប់ការប្រមូលផល/ការប្រមូលផលិតផល** | កិច្ចសន្យាត្រូវបញ្ជាក់អំពីព័ត៌មានលម្អិតនៃការរៀបចំ (និងការទូទាត់ចំណាយ) នៃការប្រមូលផលិតផល (ផែនការប្រមូល ចំណុចប្រមូល ការទទួលខុសត្រូវលើការដឹកជញ្ជូន ទៅមកពីចំណុចប្រមូលផល...)។ ចំណុចត្រូវឆ្លុះបញ្ចាំង គឺមានរៀបរាប់នៅក្នុងផ្នែក ៤.៨ ស្តីពីការគ្រប់គ្រងប្រតិបត្តិការ៖ ការដឹកជញ្ជូន ការប្រគល់ ការទទួល ...(ទំព័រ ៨៦)។<br>កិច្ចការទាំងនេះអាចដោះស្រាយនៅក្នុងប្រការនេះ ឬអាចនៅក្នុងឧបសម្ព័ន្ធ ប្រសិនបើត្រូវការរៀបរាប់លម្អិត។ |
| **ប្រការ ៦៖ លក្ខខណ្ឌគុណភាព/លក្ខណៈបច្ចេកទេស** | កំណត់លក្ខណៈបច្ចេកទេសគុណភាពនៃផលិតផល (ប្រាប់កម្រិត បើអាចធ្វើបាន)។ បើត្រូវការព័ត៌មានលម្អិតបន្ថែម គួរប្រើឧបសម្ព័ន្ធសម្រាប់ផ្តល់ព័ត៌មានលម្អិតចាំបាច់។<br>សូមមើលជម្រើសនិងយោបល់នៅក្នុងផ្នែក ៤.៤ គុណភាព៖ លក្ខណៈបច្ចេកទេសផលិតផល និងវិធីសាស្ត្រនៃការផ្ទៀងផ្ទាត់ (ទំព័រ ៦៣)។ |
| **ប្រការ ៧៖ ការកំណត់តម្លៃ** | កំណត់តម្លៃ ឬវិធីសាស្ត្រដែលនឹងអនុវត្តដើម្បីកំណត់តម្លៃនៅពេលប្រមូលផល ឬប្រគល់ផលិតផល។ សូមមើលជម្រើសដែលអាចធ្វើបាន និងយោបល់នៅក្នុង ផ្នែក ៤.៧ តម្លៃ និងឯកសារយោងតម្លៃ (ទំព័រ ៦៨)។ |
| **ប្រការ ៨៖ វិធីសាស្ត្រទូទាត់ប្រាក់** | បញ្ជាក់នៅចំណុចនេះអំពីវិធីសាស្ត្រ និងរយៈពេលនៃការទូទាត់ប្រាក់សម្រាប់ផលិតផលដែលបានប្រគល់រួច។<br>សម្រាប់បញ្ហានេះ សូមមើលយោបល់នៅ ផ្នែក ៤.៩ វិធីសាស្ត្រនិងពេលវេលាសម្រាប់ការទូទាត់ប្រាក់ ទំព័រ ៩០។ |
| **ប្រការ ៩៖ ហានិភ័យ និងប្រធានសក្តិ** | កិច្ចសន្យានេះអាចរៀបរាប់អំពីស្ថានភាពឬព្រឹត្តិការណ៍ដែលមិនអាចគ្រប់គ្រងបានដោយភាគីទាំងពីរ ប៉ុន្តែដែលអាចប៉ះពាល់ដល់ការបំពេញការងាររបស់ភាគីទាំងពីរ។ ករណីទាំងនេះ ហៅថា "ប្រធានសក្តិ" ហើយវាអាចរឹតត្បិតដល់សមត្ថភាពរបស់ភាគីក្នុងការបំពេញការងារចំពោះភាគីម្ខាងទៀត។<br>ប្រការនេះត្រូវរៀបរាប់អំពីស្ថានភាពដែលអាចចាត់ទុកជា "ប្រធានសក្តិ" (អាចបញ្ជាក់ផង |

| | |
|---|---|
| | ដែរថា នរណាមានសិទ្ធិបញ្ជាក់អំពីប្រធានសក្តិ – ក្នុងករណីភាគីទាំងពីរមិនឯកភាពគ្នាអំពីលក្ខណៈនៃស្ថានភាព) និងកំណត់អំពីអ្វីដែលអាចកើតឡើងនៅពេលបន្ទាប់មកទៀត៖ ការលុបចោលកិច្ចសន្យា ការទូទាត់សងប្រាក់វិញ ឬការមិនទទួលបានប្រាក់បុរេប្រទាន...។<br>ប្រការនេះក៏អាចបញ្ជាក់អំពីវិធានការដែលត្រូវចាត់ (និងដោយភាគីណា) ដើម្បីបង្ការការធានាលើហានិភ័យទាំងនោះ (ដូចជា ការផ្តល់ហិរញ្ញវត្ថុ ការធានារ៉ាប់រង...)។<br>សូមមើល ផ្នែក ៤.១០ ស្ថានភាពដែលមិនអាចបំពេញកាតព្វកិច្ចបាន ដូចជា ៖ គ្រោះភ័យធម្មជាតិ ឬប្រធានសក្តិ ទំព័រ ៩៥។ |
| **ប្រការ ១០៖ ការបញ្ចប់កិច្ចសន្យា** | រៀបរាប់អំពីស្ថានភាពដែលឈានដល់ការបញ្ចប់កិច្ចសន្យា។<br>សូមមើល ផ្នែក ៤.១១ រយៈពេល ការបន្ត និងការបញ្ចប់កិច្ចសន្យា ទំព័រ ១០១។ |
| **ប្រការ ១១៖ ការដោះស្រាយវិវាទ** | យន្តការផ្សេងៗគ្នាដែលមានស្រាប់សម្រាប់ដោះស្រាយវិវាទក្នុងកិច្ចសន្យា។<br>ប្រការនេះត្រូវបញ្ជាក់អំពីវិធីសាស្ត្រក្នុងការដោះស្រាយវិវាទ ដែលភាគីទាំងពីរយល់ព្រមប្រើក្នុងករណីមានវិវាទកើតឡើង។<br>សូមមើល ផ្នែក ៤.១៣. ការដោះស្រាយវិវាទ ទំព័រ ១១០ និង ផ្នែក ៦. នៃសៀវភៅនេះ។ |
| **ប្រការ ១២៖ ការបង្កើតកិច្ចសន្យានិងភាសា** | ប្រការចុងក្រោយនេះបង្ហាញអំពីភាសាសម្រាប់ប្រើប្រាស់ក្នុងកិច្ចសន្យា និងចំនួនច្បាប់ដែលត្រូវថតចម្លង (និងអ្នកដែលទទួលបានសេចក្តីចម្លង)...។<br><br>*ឧទាហរណ៍ ៖*<br>**« កិច្ចសន្យានេះធ្វើឡើងដោយស្ម័គ្រចិត្ត ពុំមានការបង្ខិតបង្ខំពីភាគីណាឡើយ។ កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរ។ ក្នុងករណីមានវិវាទកើតឡើង ការដោះស្រាយវិវាទនឹងធ្វើឡើងជាភាសាខ្មែរ។**<br>**កិច្ចសន្យានេះត្រូវបានបោះពុម្ពនិងចុះហត្ថលេខាលើច្បាប់ដើមចំនួនប្រាំច្បាប់ (គ្រប់ច្បាប់មានតម្លៃស្មើគ្នា) សម្រាប់រក្សាទុកដោយ ៖**<br>**១. ភាគីអ្នកផលិត ១ (មួយ) ច្បាប់**<br>**២. ភាគីអ្នកទិញ ១ (មួយ) ច្បាប់**<br>**៣. សាលាឃុំ ១ (មួយ) ច្បាប់**<br>**៤. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសាម៉ី ១ (មួយ) ច្បាប់**<br>**៥. នាយកដ្ឋានកសិ-ឧស្សាហកម្ម ១ (មួយ) ច្បាប់ »**<br><br>សូមមើល ផ្នែក ៤.១៤. លក្ខខណ្ឌច្បាប់ផ្សេងទៀត (ចំនួនច្បាប់ចម្លង ភាសា...), ទំព័រ ១១៣។ |
| **កាលបរិច្ឆេទ និងហត្ថលេខាភាគីនៃកិច្ចសន្យា** | *ឧទាហរណ៍៖*<br>**« ធ្វើនៅ [ ទីកន្លែង] នៅ [ ថ្ងៃខែឆ្នាំ]** |

| | |
|---|---|
| | សម្រាប់ភាគីអ្នកទិញ៖      សម្រាប់ភាគីអ្នកផលិត៖<br><br>________________________________<br><br>______________________________<br><br>[ បញ្ចូលនាមត្រកូលនិងនាមខ្លួន]      [ បញ្ចូលនាមត្រកូលនិងនាមខ្លួន]<br>[ មុខតំណែង]      [ + មុខតំណែងនិងឈ្មោះអង្គការ<br>កសិករ<br>តំណាងភាគីអ្នកទិញ      បើ " ភាគីអ្នកផលិត គឺជាអង្គករកសិករ] |
| **ហត្ថលេខាសាក្សី** | កិច្ចសន្យានេះអាចចុះហត្ថលេខាបន្ថែមដោយសាក្សីមួយឬច្រើន ជាសាក្សីអព្យាក្រិត្យដើម្បីដឹងលឺថា ភាគីទាំងពីរបានយល់ព្រមតាមលក្ខខណ្ឌនៃកិច្ចសន្យាដោយស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំ។<br>ក្នុងករណីភាគីណាមួយមិនចេះអាន ខ្លឹមសារនៃកិច្ចសន្យានេះត្រូវអានលឺៗ ដោយភាគីទីបីដែលជាសាក្សីអព្យាក្រិត្យ ដើម្បីបញ្ជាក់ថាគេយល់កិច្ចព្រមព្រៀង។ ក្នុងករណីនេះ គួរសរសេរ បញ្ជាក់ នៅខាងលើហត្ថលេខារបស់សាក្សី៖<br>**« អត្ថបទនៃកិច្ចសន្យាត្រូវបានអានឮៗ ឲ្យភាគីទាំងពីរស្តាប់ ហើយក៏បានយល់ព្រមលើកិច្ចសន្យានេះ ដោយមិនមានការបង្ខិតបង្ខំ។ »**<br>ទោះវាមិនមែនជាកាតព្វកិច្ច កិច្ចសន្យានេះគួរបញ្ជាក់ដោយអាជ្ញាធររដ្ឋ (អាជ្ញាធរមូលដ្ឋាន) ដោយសាការី ឬមេធាវី។ |
| **ឧបសម្ព័ន្ធ** | ដើម្បីជៀសវាងរៀបរាប់វែងពេកក្នុងអត្ថបទនៃកិច្ចសន្យា គេគួរដាក់ព័ត៌មានលម្អិត ឬការបរិយាយទៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា ដោយគ្រាន់តែប្រាប់សេចក្តីយោងទៅឧបសម្ព័ន្ធនោះនៅក្នុងអត្ថបទតែប៉ុណ្ណោះ (ឧទាហរណ៍ ៖ **« អ្នកផលិតត្រូវគោរពយ៉ាងម៉ឺងម៉ាត់ចំពោះវិធីសាស្រ្តផលិត ដូចមានលម្អិតនៅក្នុងឧបសម្ព័ន្ធ *[ X]* »**)។ ឧបសម្ព័ន្ធអាចរួមមានដូចជា៖<br>• ព័ត៌មានលម្អិតនៃវិធីសាស្រ្តផលិតដែលត្រូវអនុវត្តតាម ដោយអ្នកផលិត (ទន្ទឹមនេះ គេក៏អាចបង្កើតប្រការបន្ថែមនៅក្នុងអត្ថបទនៃកិច្ចសន្យា)។<br>• ទីតាំង/ព្រំប្រទល់ (អាចភ្ជាប់ជាមួយផែនទី) នៃដីដាំដុះនៅក្នុងកិច្ចសន្យា។<br>• បញ្ជីអ្នកផលិត ផ្ទៃក្រឡា បរិមាណដែលបានសន្យា (ជាពិសេសនៅពេលកិច្ចសន្យាធ្វើឡើងជាមួយអង្គការអ្នកផលិត)។<br>• ព័ត៌មានលម្អិតនៃលក្ខណៈបច្ចេកទេសគុណភាពសម្រាប់កម្រិតនៃផលិតផល។<br>• ព័ត៌មានលម្អិតនៃវិធីទូទាត់ប្រាក់សម្រាប់ផលិតផលដែលបានប្រគល់។<br>• ព័ត៌មានលម្អិតនៃនីតិវិធីនៃការរៀបចំ (ភស្តុភារ) នៃការប្រមូលផលិតផល បញ្ជីនិងទីតាំងនៃចំណុចប្រមូលផ្តុំ...ជាដើម |

នៅក្នុងប្រការ ៣ និង ៤ ស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកផលិតនិងអ្នកទិញ ទម្រង់ទ្រាយនៃកិច្ចសន្យាដែលបានស្នើដោយក្រសួងកសិកម្មរួមមាន ការរៀបរាប់អំពីការទទួលខុសត្រូវរបស់ភាគីនីមួយៗ ដែលត្រូវទូទាត់លើការខូចខាត ឬការសងជំងឺចិត្ត ទៅភាគីផ្សេងទៀត ក្នុងករណីមិនអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យា។ គេគួរកំណត់ដែនកំណត់នៃការទទួលខុសត្រូវ ដើម្បីការពារភាគីទាំងពីរ ពីការទាមទារប្រាក់សំណងហួសហេតុពេក។ ទឹកប្រាក់អតិបរិមានៃការទទួលខុសត្រូវអាចត្រូវបានកំណត់ទៅតាមតម្លៃនៃកិច្ចសន្យា ឬតម្លៃបន្ថែមជាក់លាក់ ទៅតាមការរំពឹងថា កិច្ចសន្យានេះនឹងអាចរកប្រាក់បានប៉ុន្មានសម្រាប់ភាគីនីមួយៗ។

## ៤.២. ការគាំទ្ររបស់អ្នកទិញ៖

## ធាតុចូល / បុរេហិរញ្ញប្បទាន / យោបល់បច្ចេកទេស

ជាគោលការណ៍ កិច្ចសន្យាផលិតកម្មកសិកម្ម មិនមែនគ្រាន់តែជាកិច្ចសន្យាធម្មតាដើម្បីទិញកសិផលទេ។ វាបង្កប់នូវសេវាកម្មដែលផ្តល់ដោយភាគីអ្នកទិញ ចំពោះភាគីអ្នកផលិត ជាផ្នែកមួយនៃកិច្ចសន្យា ឬភាពជាដៃគូ។ នៅក្នុងទម្រង់នៃកិច្ចសន្យាដែលបានស្នើឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទការគាំទ្រ និងសេវាកម្មទាំងនេះ គួរតែមានកត់ត្រានៅក្រោមប្រការ៤ ពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទិញ (សូមមើលតារាង ៤.១.ក. នៅក្នុងទំព័រមុននេះ) ហើយអាចមានលម្អិតបន្ថែមទៀតនៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា។

ការគាំទ្រពីភាគីអ្នកទិញរួមមាន ៖ ការផ្តល់ធាតុចូល និង / ឬ ការផ្តល់សេវាកម្ម និង /ឬ បុរេហិរញ្ញប្បទាន និង / ឬ ការបណ្តុះបណ្តាល / ការគាំទ្រផ្នែកបច្ចេកទេស។ ការគាំទ្រធម្មតា ដែលកិច្ចសន្យាអាចពាក់ព័ន្ធមានដូចខាងក្រោម។ ការប្តេជ្ញាចិត្តរបស់អ្នកទិញ គួរមានបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យា ហើយត្រូវតែជាផ្នែកមួយនៃការចរចា។

### ៤.២.១. ធាតុចូលឬការផ្គត់ផ្គង់សម្ភារ

ភាគីអ្នកទិញអាចផ្តល់ធាតុចូលដល់ភាគីអ្នកផលិត ដូចជា ៖

សម្រាប់ការដាំបន្លែ ៖

- គ្រាប់ពូជ ឬកូនបន្លែ
- ជី
- ថ្នាំសម្លាប់សត្វល្អិត...

សម្រាប់ផលិតកម្មសត្វ ៖

- សត្វ (ដូចជា កូនមាន់ កូនជ្រូក កូនត្រី...)
- ចំណីសត្វ
- វ៉ាក់សាំង
- ថ្នាំ...

ធាតុចូលអាចផ្តល់ដោយឥតគិតថ្លៃ (ប៉ុន្តែអាចកាត់សងមកក្នុងថ្លៃផលិតផលដែលបានប្រគល់) ឬ កាត់នៅពេលគិតប្រាក់ ឬបង់ភ្លាមៗ នៅពេលកសិករទទួលបានធាតុចូលទាំងនោះ ឬ (ជាញឹកញាប់) ជាប្រាក់បុរេប្បទានដែលកាត់មកវិញពីថ្លៃផលិតផល នៅពេលកសិករផ្តល់ផលិតផលចុងក្រោយ។

ក្នុងករណីខ្លះ អ្នកទិញអាចគិតអត្រាការប្រាក់ខ្លះៗ នៅលើថ្លៃចំណាយដំបូងនៃធាតុចូល សម្រាប់ជាថ្លៃសេវាឥណទានរបស់អ្នកទិញ។

### ៤.២.២. ការផ្តល់សេវាកម្ម

ដូចគ្នានឹងធាតុចូលដែរ សេវាកម្មក៏អាចផ្តល់ផងដែរ ឧទាហរណ៍ ការរៀបចំដី ឬការប្រមូលផល (សម្រាប់ដំណាំ) ឬ សេវាកម្មព្យាបាលសត្វ ឬការបង្កាត់ពូជ (សម្រាប់ផលិតកម្មសត្វ)។ ដូចគ្នានឹងធាតុចូលដែរ សេវាកម្មអាចត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ ឬ គិតថ្លៃពីកសិករតាមរបៀបជាប្រាក់បុរេប្បទានសម្រាប់កាត់កងនៅពេលទូទាត់ប្រាក់នៅពេលក្រោយ បន្ទាប់ពីបានទទួលផលិតផលពីកសិករ។

### ៤.២.៣. បុរេហិរញ្ញប្បទាន ឬសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត

អ្នកទិញក៏អាចស្នើសុំសេវាកម្មបុរេហិរញ្ញប្បទាន។ ជាញឹកញាប់ បុរេហិរញ្ញប្បទានគឺសម្រាប់ធាតុចូល ឬ សេវាកម្មដែលផ្តល់ជាវត្ថុ (ដូចជា នៅក្នុងផ្នែក ៤.២.១. និងផ្នែក ៤.២.២. ដែលបានរៀបរាប់ខាងលើ)។ ប៉ុន្តែនៅក្នុងករណីខ្លះទៀត ប្រាក់បុរេប្រទានអាចផ្តល់ជូនបាន បន្ទាប់មកកាត់កងយកវិញនៅពេលទូទាត់ប្រាក់ថ្លៃផលិតផលដែលបានផ្តល់ជូន ដោយគិត ឬ ដោយមិនគិតការប្រាក់។

### ៤.២.៤. ការបណ្តុះបណ្តាលឬការគាំទ្រផ្នែកបច្ចេកទេស

ការគាំទ្រសំខាន់ដែលតែងមានដាក់បញ្ចូលក្នុងកិច្ចសន្យាផលិតកម្មកសិកម្មគឺ ការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស (ឬការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម) ឬ ការគាំទ្រផ្នែកបច្ចេកទេស។ នេះជាការចាំបាច់ណាស់ នៅពេលការផលិតគឺជាបច្ចេកទេសថ្មីសម្រាប់កសិករ ឬ នៅពេលអ្នកទិញចង់ឲ្យការផលិតធ្វើឡើងដោយអនុវត្តតាមវិធីសាស្ត្រ ឬ ស្តង់ដារជាក់លាក់។ ការបណ្តុះបណ្តាលអាចធ្វើឡើងមួយលើក នៅពេលចាប់ផ្តើមកិច្ចសន្យា ប៉ុន្តែជាញឹកញាប់ គេធ្វើច្រើនដំណាក់កាល ច្រើនជំហាន នៅក្នុងការផលិត។

ជំនួស ឬ បន្ថែមពីលើការបណ្តុះបណ្តាល អ្នកទិញអាចផ្តល់ជំនួយបច្ចេកទេស។ ក្នុងករណីនេះ វាជាអន្តរាគមន៍ដែលមិនមានការគ្រោងទុកជាមុន ប៉ុន្តែអ្នកទិញមានក្រុមអ្នកបច្ចេកទេសកសិកម្ម (ឬ បសុពេទ្យសម្រាប់ព្យាបាលសត្វ) ដែលអាចចុះមកជួយតាមតម្រូវការរបស់អ្នកផលិត នៅពេលគេជួបបញ្ហា។

**ប្រសិនបើការបណ្តុះបណ្តាល ឬការគាំទ្រផ្នែកបច្ចេកទេស គឺជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់អ្នកទិញ វាជាការសំខាន់ដែលត្រូវកំណត់និងបញ្ជាក់ឲ្យច្បាស់អំពីសេវាកម្មដែលត្រូវផ្តល់ជូន ៖**

**សម្រាប់ការបណ្តុះបណ្តាល សូមបញ្ជាក់ (នៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា)៖**

**☐ មាតិកានៃការបណ្តុះបណ្តាល**

☐ ពេលវេលានិងរយៈពេលនៃការបណ្តុះបណ្តាល

☐ ប្រវត្តិនៃគ្រូត្រូវចុះមកបង្រៀន...

ប្រសិនបើការគាំទ្ររួមមាន ការគាំទ្រផ្នែកបច្ចេកទេសតាមតម្រូវការជាក់ស្តែង ត្រូវបញ្ជាក់ឲ្យច្បាស់អំពីលក្ខខណ្ឌនៃការបញ្ជូនក្រុមជំនាញនិងការឆ្លើយតប

☐ វិធីសាស្ត្រនៃការបញ្ជូនក្រុមគាំទ្របច្ចេកទេសរបស់អ្នកទិញ

☐ ការពន្យាពេលអតិបរិមានៃការឆ្លើយតបសម្រាប់សេវាកម្មដែលត្រូវផ្តល់ជូន

☐ ឧបសគ្គដែលអាចកើតមាន...

## ៤.៣. ប្រភេទផលិតផល និងបរិមាណដែលត្រូវផ្គត់ផ្គង់

### ៤.៣.១. ប្រភេទផលិតផល

គោលបំណងនៃកិច្ចសន្យា (ក្នុងប្រការ ១ នៅក្នុងទម្រង់នៃកិច្ចសន្យាដែលបានស្នើដោយនាយកដ្ឋានកសិ-ឧស្សាហកម្ម ) បញ្ជាក់អំពីប្រភេទផលិតផលដែលត្រូវផលិត និងប្រគល់ដោយភាគីអ្នកផលិតជូនដល់ភាគីអ្នកទិញ។ ដោយមិនចាំបាច់លម្អិតអំពីលក្ខណៈបច្ចេកទេសគុណភាព (ដែលត្រូវបានដោះស្រាយនៅក្នុងប្រការមួយផ្សេងទៀត និងមានរៀបរាប់នៅក្នុងផ្នែក ៤.៤. នៅក្នុងគោលការណ៍ណែនាំនេះ) វាបង្ហាញអំពីលក្ខណៈនៃផលិតផលសម្រាប់កិច្ចសន្យាដែលត្រូវចុះហត្ថលេខា។

គេមិនត្រឹមតែបញ្ជាក់អំពីប្រភេទនៃការផលិតនោះទេ (ស្រូវ ពោត មាន់ ) ប៉ុន្តែក៏ត្រូវបញ្ជាក់អំពីទម្រង់នៃផលិតផល ឬ កម្រិតនៃការកែច្នៃ (ឧទាហរណ៍ ៖ ស្រូវប្រមូលផលថ្មីៗ, ស្រូវស្ងួត, អង្ករ...) និងពូជផងដែរ (ឧទាហរណ៍ ៖ *ផ្កាម្លិះ* ឬ *អ៊ីអ៊ែរ ៦៦* សម្រាប់ស្រូវ...)។

ព័ត៌មានលម្អិតបន្ថែម នឹងត្រូវផ្តល់ជូននៅក្នុងផ្នែកស្តីពីលក្ខណៈបច្ចេកទេសគុណភាព ដែលនឹងរៀបរាប់ពេញលេញនៅក្នុងប្រការស្តីពីគោលបំណងនៃកិច្ចសន្យា។

### ៤.៣.២. ការបញ្ជាក់បរិមាណ

កិច្ចសន្យាត្រូវមានបញ្ជាក់អំពីគុណភាពផលិតផលដែលត្រូវផ្តល់ (និងរយៈពេលនៃការប្រគល់ - ផ្នែក ៤.៨.)។

នៅក្នុងទម្រង់ដែលបានស្នើឡើងដោយនាយកដ្ឋានកសិ-ឧស្សាហកម្ម គេអាចរៀបរាប់អំពីគុណភាពនៅក្នុងពីរប្រការ៖ *ប្រការ ៣ ស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកផលិត* និង *ប្រការ ៤ ស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ* ៖ ក្នុងប្រការ ៣ វាគឺជាការប្តេជ្ញាចិត្តរបស់ភាគីអ្នកផលិតដើម្បីផលិតនិងលក់ទៅភាគីអ្នកទិញ ហើយប្រការ ៤ រៀបរាប់អំពីការប្តេជ្ញាចិត្តរបស់ភាគីអ្នកទិញដែលនឹងទិញពីភាគីអ្នកផលិត។ ប្រការទាំងពីរត្រូវមានលក្ខណៈជាប្រព័ន្ធលម្អិត និងស្របជាមួយគ្នា (ដូចជា បរិមាណដែលបានប្តេជ្ញាចិត្តដោយអ្នកផលិតនិងអ្នកទិញ)។

ជម្រើសផ្សេងៗទៀតគឺអាចប្រើប្រាស់បាន ដើម្បីកំណត់បរិមាណផលិតផល៖

- បរិមាណឬទំហំមិនប្រែប្រួលមួយ។
- រង្វង់ប្រហែលនៃបរិមាណ យ៉ាងតិច និងយ៉ាងច្រើនបំផុត ដែលអ្នកផលិតសន្យាផលិតនិងផ្គត់ផ្គង់ទៅអ្នកចុះកិច្ចសន្យាទិញ។
- បរិមាណយ៉ាងតិចបំផុត ជាមួយនឹងជម្រើសនៃការទិញ ដែលលើសពីបរិមាណអប្បបរិមាដែលបានសន្យា (ក្នុងលក្ខខណ្ឌដដែល ឬ លក្ខខណ្ឌផ្សេង)។
- រាល់ការផលិត (ការយកចិត្តទុកដាក់៖ នៅក្នុងករណីនេះ កិច្ចសន្យាត្រូវបញ្ជាក់ឲ្យច្បាស់អំពីផ្ទៃក្រឡា និងព្រំប្រទល់នៃស្រែចំការសម្រាប់ការផលិត និងដំណើរការនៃការប្រមូលផល)។

តារាង ៤.៣.ក. ខាងក្រោម សង្ខេបអំពីគុណសម្បត្តិនិងគុណវិបត្តិនៃជម្រើសនីមួយៗ សម្រាប់ការបញ្ជាក់អំពីបរិមាណឬទំហំ។

តារាង ៤.៣.ក.៖ ការពិនិត្យមើលជម្រើសផ្សេងៗដើម្បីកំណត់បរិមាណនៅក្នុងកិច្ចសន្យា

| របៀបកំណត់បរិមាណ | ការពន្យល់ | គុណសម្បត្តិ/គុណវិបត្តិ, លក្ខខណ្ឌដែលវាពាក់ព័ន្ធ |
|---|---|---|
| បរិមាណថេរ | បរិមាណគឺត្រូវទៅតាមចំនួនដែលបានរៀបរាប់នៅក្នុងកិច្ចសន្យា។ | មិនខ្វល់ចំពោះទិន្នផលកសិផលប្រែប្រួល។ អ្នកផលិតអាចលក់ទិន្នផលលើសទៅអ្នកទិញផ្សេង។ |
| បរិមាណប្រែប្រួល៖ ពីចំនួន ***x*** (យ៉ាងតិច) ទៅ ***y*** (យ៉ាងច្រើន) | អ្នកផលិតប្តេជ្ញាចិត្តផលិតយ៉ាងតិចចំនួន ***x*** (ឯកតា) ហើយអាច ផលិតរហូតដល់ ***y*** (ឯកតា)។ អ្នកទិញសន្យាទិញយ៉ាងតិច ***x*** (ឯកតា) រហូតដល់ ***y*** (ឯកតា)។ | កំណត់បរិមាណប្រែប្រួល (អប្បបរិមា និងអតិបរិមា) ធ្វើឲ្យងាយពិចារណាអំពីការប្រែប្រួលក្នុងការផលិតនិងផ្តល់កម្រិតសន្តិសុខដែលអាចទទួលយកបានសម្រាប់ភាគីទាំងពីរ។ ប៉ុន្តែអត្រាប្រែប្រួលនិងការសន្យាជាក់លាក់ត្រូវរៀបចំឡើងដោយប្រុងប្រយ័ត្ន (ផ្នែកអនុសាសន៍មាននៅខាងក្រោម)។ |
| អត្រាថេរ + ជម្រើសនៃការទិញ | ភាគីទាំងពីរសន្យាចំពោះគុណភាពអប្បរមាដែលត្រូវលក់ / ទិញ នៅក្នុងលក្ខខណ្ឌនៃកិច្ចសន្យា។ ការពង្រីកបរិមាណអាចពិចារណាបានប្រសិនបើមានផលិតផលបន្ថែមទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា។ | ជម្រើសនេះគឺស្រដៀងគ្នានឹងជម្រើស "បរិមាណថេរ" លើកលែងតែថា វាអាចផ្តល់លទ្ធភាពសម្រាប់អ្នកផលិតលក់បានកាន់តែច្រើន ប្រសិនបើផលិតបានច្រើន ហើយប្រសិនបើអ្នកទិញយល់ព្រមទទួលយក។ ប៉ុន្តែវាអាចជាករណីនេះស្រាប់ទៅហើយ គ្រាន់តែមិនដែលនិយាយអំពីវានៅក្នុងកិច្ចសន្យា។ នៅពេលគេប្រមូលផល អ្នកចុះកិច្ចសន្យាអាចទិញបរិមាណបន្ថែម។ |
| ការផលិតទាំងអស់ | អ្នកចុះកិច្ចសន្យាយល់ព្រមទិញទាំងអស់នូវការផលិត ទោះមានប៉ុន្មានក៏ដោយ។ | ប្រព័ន្ធនេះគឺមានភាពពាក់ព័ន្ធ និងគួរអនុវត្ត ប្រសិនបើអ្នកផលិតមិនមានឱកាសទីផ្សារផ្សេងទៀត សម្រាប់ផលិតផលដែលកំពុងលក់ទៅអ្នកចុះកិច្ចសន្យា។ ក្នុងករណីនោះ វាផ្តល់នូវសន្តិសុខដោយមិនព្រួយអំពីការ ផលិតបានច្រើន ប៉ុន្តែគ្មានទីផ្សារ។ ប្រសិនបើការផលិត ក៏មានទីផ្សារក្នុងស្រុក (ឈ្មួញ ឬអ្នកទិញអាចទិញផលិតផល) តម្រូវការសម្រាប់អ្នកផលិតដើម្បីទទួលបានការធានា គឺមិនសូវរឹងមាំ។ ប៉ុន្តែអ្នកចុះកិច្ចសន្យាអាចសុខចិត្តយល់ព្រមនឹងប្រការនេះ ដើម្បីបង្កើនបរិមាណនៃផលិតផលដែលគាត់នឹងទទួលបាន។ វាមានប្រសិទ្ធភាពប្រសិនបើអ្នកប្រមូលទិញគឺកំពុងម៉ៅ កសិផលឈរ (មិនទាន់កាត់ នៅក្នុងស្រែឬចំការ) និងគ្រប់គ្រងដោយខ្លួនឯងលើការប្រមូលផល។ ទូទៅជាងនេះទៅទៀត នៅក្នុងម៉ូឌែលដែលមានភាពចម្រុះខ្លាំង (នៅពេលអ្នកទិញ កំពុងដើរតួជាអ្នកគ្រប់គ្រងបច្ចេកទេសលើដំណាំ ហើយកំពុងផ្គត់ផ្គង់ធាតុចូល) វាជាការធម្មតាដែលកិច្ចសន្យាត្រូវរៀបរាប់អំពីការផលិត ដែលនឹងត្រូវលក់ទៅឲ្យអ្នកម៉ៅ។ |

## ការប្រែប្រួលបរិមាណ

ដោយហេតុថា ទិន្នផលកសិកម្មអាចប្រឈមនឹងគ្រោះភ័យនិងការប្រែប្រួលដូច្នេះគួរកំណត់បរិមាណដែលអាចប្រែប្រួលបាន ជាជាងបរិមាណថេរ។

ប្រសិនបើជ្រើសរើសយកជម្រើសនេះ ត្រូវយកចិត្តទុកដាក់លើពីរចំណុច ៖

- និយមន័យនៃកម្រិតប្រែប្រួល (អប្បបរិមា និងអតិបរិមា) ត្រូវតែមានភាពសមហេតុផល និងសមស្រប។ វាគួរតែឆ្លុះបញ្ចាំងអំពីការប្រែប្រួលនៃស្រែចំការនោះ ហើយវាជាភាពល្អៀងធម្មតា មិនមែនជាការឧបមាហួសហេតុ ឬ ជាគ្រោះមហន្តរាយ ដែលជាស្ថានភាពអនុវត្តទៅតាមប្រការជាក់លាក់នៃកិច្ចសន្យា (សូមមើលផ្នែក ៤.១០.)។ ទំហំអប្បបរិមាដែលបានកំណត់ ត្រូវតែមានគ្រប់គ្រាន់ដើម្បីធានាការផ្គត់ផ្គង់ច្រើនដល់អ្នកទិញ។ ទំហំអតិបរិមាក៏ត្រូវតែកំណត់ផងដែរ ដើម្បីជៀសវាងឬកាត់បន្ថយផលិតផលសល់នៅអ្នកផលិត ប៉ុន្តែ ក៏នៅតែអាចស្របយកបាន ដោយអ្នកចុះកិច្ចសន្យា។ យើងអាចនិយាយបានថា ទំហំអតិបរិមាអាចនៅចន្លោះពី ២០ % ទៅដល់ ៦០ % ពីលើកម្រិតអប្បបរិមា។
- ការបង្កើតកិច្ចសន្យា ត្រូវមានភាពច្បាស់លាស់ ព្រោះអាចមានការបកស្រាយខុសៗគ្នាអំពីទំហំប្រែប្រួល។ ឧទាហរណ៍ តើអ្នកចុះកិច្ចសន្យាត្រូវតែទិញផលិតផលដែលអ្នកផលិតផ្តល់ឲ្យ នៅក្នុងព្រំដែនអតិបរិមានោះ ឬយ៉ាងណា ឬ តើអ្នកចុះកិច្ចសន្យាត្រូវតែទិញ តែចំនួនអប្បបរិមានៃកិច្ចសន្យា ហើយអាចសម្រេចចិត្តទិញ ឬ មិនទិញតាមកម្រិតប្រែប្រួលដែលបានកំណត់ ប៉ុន្តែលើសការសន្យាអប្បបរិមា? រូបភាព ៤.៣.ក. ខាងក្រោម ផ្តល់នូវការបំភ្លឺនិងអនុសាសន៍ខ្លះៗ អំពីបញ្ហានេះ។

**រូបភាព ៤.៣.ក**
**អត្ថន័យមិនច្បាស់លាស់នៃបរិមាណដែលអាចប្រែប្រួលបាននៅក្នុងកិច្ចសន្យា**

នៅក្នុងកិច្ចសន្យារវាងអ្នកនាំអង្ករចេញ និងអង្គការកសិករ បរិមាណត្រូវបានកំណត់នៅក្នុងផ្នែកស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីនីមួយៗ ៖

> « **ប្រការ ៣ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកផលិត៖**
>
> ភាគីអ្នកផលិតសន្យាលក់ស្រូវ *ផ្កាម្លិះ* ចំនួន ៦០ ទៅ ៩០ តោន ទៅឲ្យអ្នកទិញ »
>
> [...]
>
> « **ប្រការ ៤ សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ៖**
>
> អ្នកទិញសន្យាទិញស្រូវ *ផ្កាម្លិះ* ចំនួន ៦០ ទៅ ៩០ តោន ពីអ្នកផលិត។»

ការកំណត់ខាងលើនេះ គឺអាចប្រែប្រួលទៅតាមការបកស្រាយ និងអាចនាំឲ្យមានវិវាទ។ ឧទាហរណ៍ បើភាគីអ្នកផលិតផ្តល់ស្រូវបាន ៧០ តោន (ស្របតាមលក្ខខណ្ឌគុណភាព និងលក្ខខណ្ឌនៃការផ្តល់) ហើយភាគីអ្នកទិញយល់ព្រមទិញ ៦០ តោន មានន័យថា អ្នកទិញ មិនរំលោភលើការសន្យាខាងលើទេ ៖ ទិញ ៦០ តោន គឺស្របតាមការសន្យានៅក្នុងកិច្ចសន្យា។ ជាមួយនឹងការប្រើប្រាស់ពាក្យខាងលើ ពាក្យថា "ប្រែប្រួល ឬ ចន្លោះ" អាចត្រូវបានបកស្រាយថាជា ទំហំអប្បបរិមា + ជម្រើសនៃការទិញបន្ថែម។

វិធីមួយទៀតសម្រាប់សរសេរប្រការ ៤ គឺ « ភាគីអ្នកទិញសន្យាទិញស្រូវ *ផ្កាម្លិះទាំងអស់* គិតជាតោន (ស្របតាមលក្ខខណ្ឌគុណភាព និងលក្ខខណ្ឌនៃការប្រគល់ ដូចមានចែងក្នុងកិច្ចសន្យានេះ ក្នុងតម្លៃដែលបានកំណត់ ) រហូតដល់ចំនួនច្រើនបំផុតត្រឹម ៩០ តោន»។ ជាមួយនឹងការកែសម្រួលពាក្យនេះ ប្រសិនបើអ្នកផលិត ប្រគល់ស្រូវ ៧០ តោន (ស្របតាមលក្ខខណ្ឌគុណភាព និងលក្ខខណ្ឌនៃការប្រគល់) នោះអ្នកទិញ មានកាតព្វកិច្ចទិញយកទាំងអស់ ហើយការប្រើប្រាស់ពាក្យនេះ មានការខុសគ្នាជាច្រើនពីរបៀបសរសេរនៅមុននេះ។

នេះបង្ហាញឲ្យឃើញអំពីភាពចាំបាច់នៃការប្រើប្រាស់ពាក្យពេចន៍ ច្បាស់លាស់ ដើម្បីជៀសវាងវិវាទ ដោយសារការបកស្រាយខុសគ្នាអំពីពាក្យ អប្បបរិមា និងអតិបរិមា នៅក្នុងកិច្ចសន្យា។

### ហានិភ័យនៃការមិនឈានដល់បរិមាណអប្បបរិមា

ប្រសិនបើអ្នកផលិតចង់ជ្រើសរើសយកបរិមាណថេរ ឬបរិមាណអប្បបរិមានៅក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម គេគួរតែប្រាកដថា គេអាចសម្រេចផែនការបានយ៉ាងងាយស្រួល ទោះទិន្នផលមិនសូវល្អក៏ដោយ។ ការមិនផ្គត់ផ្គង់គ្រប់ចំនួនគឺជាការរំលោភលើកិច្ចសន្យា។ ដូចនេះគួរប្រុងប្រយ័ត្នអំពីការកំណត់ចំនួនអប្បបរិមា។

ទោះបានរៀបរាប់ខាងលើ គេមិនគួរបារម្ភពេកទេ ហើយក៏មិនគួរទុទិដ្ឋិនិយមពេកដែរ អំពីបរិមាណដែលបានរំពឹងទុក ព្រោះសមត្ថភាពផលិតមានកម្រិតខ្លាំងពេក អាចធ្វើឲ្យអ្នកទិញ មិនសូវចាប់អារម្មណ៍។

ក្រៅពីនេះ គេគួរចងចាំក្នុងចិត្តថា ប្រការជាក់លាក់នឹងគ្របដណ្តប់ទៅលើស្ថានភាពនៃគ្រោះធម្មជាតិ (ឬ "ប្រធានសក្តិ") ដែលអនុគ្រោះចំពោះអ្នកផលិត ដែលផ្គត់ផ្គង់មិនបានគ្រប់ចំនួន តាមការសន្យា ដោយសារការផលិត រងឥទ្ធិពលពីកត្តាខាងក្រៅដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់បណ្តាភាគី (សូមមើល ផ្នែក ៤.១០.) ។សូមកត់សម្គាល់ផងដែរថា ក្នុងករណីសហករកសិកម្ម ឬអង្គការកសិករ ដែលចុះហត្ថលេខាលើកិច្ចសន្យាជាមួយអ្នកទិញ ហានិភ័យមិនមែនជាកង្វះលទ្ធភាពផ្គត់ផ្គង់ទេ ហើយវាមិនពាក់ព័ន្ធនឹងកង្វះទិន្នផលឡើយ ហានិភ័យគឺថា កសិករម្នាក់ៗ សមាជិករបស់សហគមន៍ ឬអង្គការកសិករ មិនផ្តល់ផលិតផលទៅសហករ ឬអង្គការកសិករ ដើម្បីប្រមូលលក់ទៅក្រៅ។ ផ្នែកទី ៦ នៃគោលការណ៍ណែនាំនេះ គឺរៀបរាប់អំពីការគ្រប់គ្រងផ្ទៃក្នុងសម្រាប់ផលិតកម្មកសិកម្ម ជាមួយសហករ ឬអង្គការកសិករ។

### ហានិភ័យនៃការមានទិន្នផលលើស

ម្យ៉ាងទៀត អ្នកផលិតត្រូវពិចារណាអំពីហានិភ័យនៃការមានផលលើស មានន័យថា មានទិន្នផលលើសពីចំនួនដែលភាគីអ្នកទិញសន្យាទិញ។

នៅពេលភាគីអ្នកផលិតមានឱកាសច្រើនដើម្បីលក់ផលិតផល ទៅអ្នកទិញផ្សេងទៀត ឬ ឈ្មួញកណ្តាលនៅក្នុងមូលដ្ឋាន ហានិភ័យគឺមានតិចតួច ដោយសារអ្នកផលិត នឹងអាចលក់កសិផលដែលលើសចំនួននោះ (នៅតម្លៃថោកជាងតម្លៃក្នុងកិច្ចសន្យា ប៉ុន្តែនៅតែអាចទទួលយកបាន)។ នេះអាចជាករណីស្រូវនៅក្នុងប្រទេសកម្ពុជា។

ប៉ុន្តែហានិភ័យ មានច្រើនប្រសិនបើមិនមានទីផ្សារក្នុងមូលដ្ឋានសម្រាប់ផលិតផល មានន័យថា ប្រសិនបើការតភ្ជាប់គ្នាជាមួយទីផ្សារទូលាយ អាចធ្វើបានតែតាមរយៈអ្នកចុះកិច្ចសន្យា (ដូចជា ករណី ឈើ ឬដើមឈើដាំសម្រាប់ផលិតក្រដាស ឬគ្រឿងទេស ឬ ផលិតផលសម្រាប់ការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ជាដើម) ។ ករណីនេះ អ្នកផលិត ត្រូវប្រាកដថា បរិមាណដែលបានកំណត់នៅក្នុងកិច្ចសន្យា មិនចង្អៀតពេក ហើយនឹងមិននាំឲ្យខ្វះទីផ្សារសម្រាប់ទិន្នផលដែលលើស។ ការសន្យារបស់អ្នកចុះកិច្ចសន្យា ដើម្បីទិញ ផលិតផលទាំងអស់ អាចជាការជម្រើសល្អ សម្រាប់ករណីនេះ។

## ៤.៣.៣. ឯកតា និងវិធីសាស្ត្រវាស់វែង

### ឯកតា

ឯកតាដែលបានប្រើនៅក្នុងកិច្ចសន្យាត្រូវតែមានអត្ថន័យច្បាស់លាស់ និងមានអត្ថន័យពិសេសប្លែកពីគេសម្រាប់ភាគីដែលពាក់ពន្ធ័ទាំងអស់។ បើស្តាប់មើលទៅវាពិតជាមានភាពច្បាស់លាស់ណាស់ ប៉ុន្តែមានពេលខ្លះកិច្ចព្រមព្រៀងក៏ត្រូវបានធ្វើឡើងដោយឯកតា ឬ រង្វាស់បែបបុរាណផងដែរ ហើយពេលខ្លះវាមិនស៊ីគ្នាទៅនឹងបរិមាណនៅក្នុងតំបន់មួយ ឬ ពីតំបន់មួយទៅតំបន់មួយផ្សេងទៀតនោះទេ។ ភាគីទាំងសងខាងគួរតែប្រាកដថាពួកគេប្រើប្រពន្ធ័ដូចគ្នាជាសំអាង។ ប្រពន្ធ័ម៉ែត្រទ្រីក (ឬ ប្រពន្ធ័ឯកតាអន្តរជាតិ) ត្រូវបានណែនាំឱ្យប្រើប្រាស់ ធ្វើជាសំអាងដើម្បីកុំឱ្យមានការបកស្រាយផ្សេងពីនេះ។

ក្នុងករណីភាគច្រើន ការសន្យាទៅលើបរិមាណត្រូវបានរៀបចំដោយផ្អែកលើ ទម្ងន់ (ដោយប្រើ គីឡូក្រាម ឬ តោនតាមការនិយម)។ ប៉ុន្តែក្នុងករណីខ្លះ វាមានភាពត្រឹមត្រូវជាងក្នុងការប្រើប្រាស់បរិមាណជាទំហំ (ម៉ែត្រគូប) ឬ លេខឯកតា (ឧទា. "ក្បាល" សម្រាប់ផលិតកម្មសត្វពាហនៈ)។ ចំណុចទាំងនេះគួរតែត្រូវបានពិភាក្សា និងឯកភាពដោយភាគីទាំងពីរ។

### ការថ្លឹងទម្ងន់/ជញ្ជីង

បញ្ហារសើបជាច្រើនដែលបង្កឱ្យកើតមានជម្លោះជាញឹកញាប់គឺកាថ្លឹងទម្ងន់។ ជញ្ជីងផ្សេងគ្នាអាចត្រូវបានប្រើសម្រាប់ថ្លឹងទម្ងន់ផលិតផល ហើយជញ្ជីងទាំងនោះប្រហែលជាមិនបានក្រិតតាមខ្នាតត្រឹមត្រូវឥតខ្ចោះនោះទេ ហើយវាអាចមានចំណុចលំអៀងបន្តិចបន្តួច (ឬជួនកាលខុសគ្នាខ្លាំងក៏មាន)។

កិច្ចសន្យាអាចបញ្ជាក់អំពីទីកន្លែងដែលត្រូវថ្លឹងផលិតផលទាំងនោះ និងអំពីជញ្ជីដែលត្រូវប្រើសម្រាប់កាថ្លឹង។ ជាទូទៅ ការក្រិតខ្នាតជញ្ជីង គឺជាផ្នែកមួយនៃសេវាកម្មដែលអាចត្រូវបានផ្តល់ដោយមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តក្នុងប្រទេសកម្ពុជា (សេវាមាត្រសាស្ត្រ)។ ប៉ុន្តែវាមិនត្រូវបានប្រើយ៉ាងទូលំទូលាយទេ ហើយវាក៏មិនអាចទៅរួចនោះដែរក្នុងការប្រើជញ្ជីងដែលមានការបញ្ជាក់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ។

អ្វីដែលកិច្ចសន្យាអាចបញ្ជាក់បានគឺនៅក្នុងករណីមានជម្លោះកើតឡើងទាក់ទងនឹងការថ្លឹងទម្ងន់ដោយសារតែការប្រើជញ្ជីងខុសគ្នាជម្លោះនោះអាចនឹងត្រូវដោះស្រាយនៅស្ថាប័នឯករាជ្យមួយ ដោយប្រៀបធៀបការថ្លឹងដែលបានធ្វើឡើងដោយភាគីទាំងពីរជាមួយនឹងការថ្លឹងនៅលើជញ្ជីងដែលបានក្រិតខ្នាត និងបានបញ្ជាក់ដោយសេវាមាត្រសាស្ត្រនៃក្រសួងឧស្សាហកម្ម និងសិប្បកម្មឬដោយភាគីទីបីដែលបានឯកភាពគ្នាដូចជាស្ថាប័នចេញវិញ្ញាបនប័ត្របញ្ជាក់ជាដើម។ ប្រសិនបើមិនបានបញ្ជាក់នៅក្នុងកិច្ចសន្យាទេ ហើយប្រសិនបើមានជម្លោះកើតឡើងទាក់ទងនឹងការថ្លឹងទម្ងន់ វិធីសាស្ត្រដែលត្រូវដោះស្រាយជម្លោះនោះនឹងត្រូវធ្វើដោយការសម្រេចចិត្តរបស់ស្ថាប័នស្រម្រុះសម្រួលឬអាជ្ញាកណ្តាលដែលបានជ្រើសរើសក្នុងកិច្ចសន្យា (អត្ថបទនិយាយអំពីដំណោះស្រាយជម្លោះ / វិវាទ ( សូមមើល ផ្នែក៤.១២ខាងក្រោម)។

# ៤.៤. គុណភាព៖ លក្ខណៈបច្ចេកទេសនៃផលិតផល និងវិធីសាស្ត្រផ្ទៀងផ្ទាត់

## ៤.៤.១. លក្ខណៈបច្ចេកទេសនៃផលិតផល

វាចាំបាច់ក្នុងការកំណត់អំពីលក្ខណៈបច្ចេកទេសផ្នែកគុណភាពឱ្យច្បាស់លាស់សម្រាប់ផលិតផលដែលត្រូវបញ្ជូនចេញ[11]។ ជារឿយៗ គុណភាពរបស់ផលិតផលគឺជាប្រភពនៃជម្លោះនៅក្នុងការអនុវត្តន៍កិច្ចសន្យាផលិតកម្មកសិកម្មហើយការកំណត់ច្បាស់លាស់និងហ្មត់ចត់លើគុណភាពអប្បបរមាតាមលក្ខខណ្ឌតម្រូវ (ការផ្ទៀងផ្ទាត់) គឺជាវិធីល្អបំផុតដើម្បីទប់ស្កាត់ជម្លោះបែបទាំងនេះ។

នៅក្នុងលក្ខណៈបច្ចេកទេសផ្នែកគុណភាព ត្រូវមានរៀបរាប់អំពីប្រភេទ / ទ្រង់ទ្រាយនៃផលិតផលដែលគេរំពឹងទុក ហើយត្រូវកំណត់ភាគរយអនុគ្រោះនៃបញ្ហាពីខាងក្រៅ (ឧទា. ដូចជា មានដុំថ្ម ឬ ធូលីលាយចូលគ្នាក្នុងផលិតផលស្រូវ...)។ ប៉ុន្តែលក្ខណៈបច្ចេកទេសផ្នែកគុណភាពអាចនឹងមានកម្រិតខ្ពស់ជាងនេះ និងមានរួមបញ្ចូលលក្ខណៈវិនិច្ឆ័យមួយចំនួន (ការដែលមិនអាចដាក់ចូលក្នុងបញ្ជីធម្មតាបាន ដោយអាស្រ័យលើប្រភេទនៃផលិតផលទាំងនោះ)។

លក្ខណៈបច្ចេកទេសនៃគុណភាពដែលមាននៅក្នុងលក្ខណៈវិនិច្ឆ័យ + តម្លៃគោលដៅមួយ។ វាត្រូវតែអាចវាស់ស្ទង់បាន។ តម្លៃគោលដៅអាចជាកម្រិតមួយ (តម្លៃអប្បបរមា ឬ អតិបរមា) ឬ តាមជួរ (ដែលបានកំណត់ដោយកម្រិតអប្បបរមា និងអតិបរមា)។

*ឧទាហរណ៍៖*




[11] ករណីលើកលែងតែមួយគត់ អាចជាករណីដែលការគ្រប់គ្រងបច្ចេកទេសលើការផលិតត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹងដោយអ្នកទិញ (មានរួមបញ្ចូល "ម៉ូលមជ្ឈការ" នៃផលិតកម្មកសិកម្មតាមកិច្ចសន្យា - Cf. ផ្នែក ១.១.២ ម៉ូឌែលផ្សេងគ្នានៃផលិតកម្មកសិកម្មតាមកិច្ចសន្យា)។ ក្នុងករណីដូចនេះ គុណភាពនៃផលិតកម្មគឺអាស្រ័យលើអ្នកចុះកិច្ចសន្យាទាំងស្រុង ដែលគេជាអ្នកគ្រប់គ្រង (ប្រសិនបើមិនមានការគ្រប់គ្រង) រាល់ប្រតិបត្តិការបច្ចេកទេសទាំងអស់របស់ផលិតកម្ម។

កិច្ចសន្យាអាចនឹងកំណត់ត្រឹមតែលក្ខខណ្ឌតម្រូវនៃគុណភាពអប្បបរមាប៉ុណ្ណោះ (ក្នុងករណីដែលផលិតផលណាមួយអនុលោមតាមកម្រិតអប្បបរមានេះ វានឹងទទួលយកដោយអ្នកទិញ ហើយផលិតផលណាមួយដែលមិនអនុលោមតាមនឹងត្រូវបានច្រានចោល)។ ឬវាអាចកំណត់ជាចំណាត់ថ្នាក់ផ្សេងគ្នាចំពោះគុណភាព ហើយគុណភាពដែលទាបបំផុតគឺត្រូវស្ថិតនៅក្នុងលក្ខខណ្ឌតម្រូវអប្បបរមា (លើសពីកម្រិតគុណភាពដែលផលិតផលត្រូវបានច្រានចោល) ហើយគុណភាពដែលមានកម្រិតខ្ពស់ជាងនេះត្រូវមានតម្លៃខ្ពស់ជាង (សូមមើលផ្នែក ៤.៧.៧ ការកែប្រែតម្លៃតាមគុណភាព)។

**ការពន្យល់បន្ថែម ៤.៤.ក.**

**ឧទាហរណ៍នៃលក្ខណៈបច្ចេកទេសគុណភាពសម្រាប់ស្រូវ**

តារាងខាងក្រោមនេះបង្ហាញអំពីលក្ខណៈបច្ចេកទេសនៃគុណភាពសម្រាប់ស្រូវ។ ក្នុងករណីនេះ កិច្ចសន្យាបានកំណត់ចំណាត់ថ្នាក់មួយចំនួននៃគុណភាព ដែលនឹងត្រូវបានបញ្ជាទិញក្នុងតម្លៃផ្សេងៗគ្នា។ សម្រាប់ថ្នាក់នីមួយៗ តម្លៃគោលដៅផ្សេងគ្នាៗត្រូវបានផ្តល់ជូនផ្អែកលើលក្ខណៈវិនិច្ឆ័យ។

| ចំណាត់ថ្នាក់ | ពូជសុទ្ធ | មានសំណើម | អត្រាបាក់ | សារធាតុខាងក្រៅ |
|---|---|---|---|---|
| អេ ១ (A1) | ៩០-១០០ % | ១៣-១៤.៩ % | ១-១៥ % | ≤ ០.៥ % |
| ប៊ី ១ (B1) | ៨២-៨៩ % | ១៣-១៤.៩ % | ១៥-២០ % | ≤ ០.៥ % |
| ស៊ី ១ (C1) | ៩០-១០០ % | ១៣-១៤.៩ % | ២១-៣០ % | ≤ ០.៥ % |
| ស៊ី ២ (C2) | ៩០-១០០ % | ១៣-១៤.៩ % | ៣១-៣៥ % | ≤ ០.៥ % |
| អេ ២ (A2) | ៩០-១០០ % | ១៥-១៩ % | ១៥-១៩ % | ≤ ០.៥ % |
| ប៊ី ២ (B2) | ៨២-៨៩ % | ១៥-១៩ % | ១៥-២០ % | ≤ ០.៥ % |
| ឌី ១ (D1) | ៩០-១០០ % | ១៥-១៩ % | ៣១-៣៥ % | ≤ ០.៥ % |
| ឌី ២ (D2) | ៩០-១០០ % | ១៥-១៩ % | ៣៦-៣៧ % | ≤ ០.៥ % |

លក្ខណៈបច្ចេកទេសលម្អិតអាចត្រូវបានសរសេរនៅក្នុងកិច្ចសន្យាដោយផ្ទាល់ ឬនៅក្នុងឧបសម្ព័ន្ធរបស់កិច្ចសន្យា (រួមជាមួយឯកសារយោងរបស់ឧបសម្ព័ន្ធនៃកិច្ចសន្យានេះ)។

បើចាំបាច់ លក្ខខណ្ឌ ឬលក្ខណៈវិនិច្ឆ័យដែលបានប្រើអាចកំណត់នៅក្នុងកិច្ចសន្យា (ឬនៅក្នុងឧបសម្ព័ន្ធរបស់កិច្ចសន្យា)។

ប្រសិនបើស្តង់ដារជាផ្លូវការមានស្រាប់សម្រាប់ផលិតផល នោះយើងត្រូវយោងទៅតាមស្តង់ដារជាផ្លូវការដែលមានស្រាប់នោះ (សន្មត់ថាភាគីទាំងពីរបានដឹងហើយ នៅក្នុងករណីនេះ) និងមិនមានការរៀបរាប់លម្អិតអំពីគុណភាពនៅក្នុងកិច្ចសន្យា។

មុនពេលទទួលយកលក្ខណៈបច្ចេកទេសផ្នែកគុណភាពដែលទាមទារដោយអ្នកទិញ អ្នកផលិតគួរតែសួរខ្លួនឯង ថាតើកម្រិតគុណភាពដែលត្រូវការនោះអាចសម្រេចបាននៅក្នុងស្ថានភាពកសិដ្ឋានរបស់គាត់ដែរ ឬទេ៖

□ ថាតើគាត់បានផលិតនូវផលិតផលដូចគ្នាទៅនឹងកម្រិតគុណភាពដូចគ្នាដែរ ឬទេ ហើយថាតើគាត់អាចធានាថា វាពិតជាធ្វើបានទៀងទាត់ដែរ ឬអត់?

□ បើមិនមានទេ តើការគាំទ្រផ្នែកបច្ចេកទេស (ឬធាតុចូលដែលបានផ្គត់ផ្គង់ឲ្យ) ធ្វើឡើងដោយអ្នកចុះកិច្ចសន្យា បានផ្តល់សន្តិសុខគ្រប់គ្រាន់ដើម្បីបំពេញនូវតម្រូវការដែរ ឬទេ?

□ វាជាការចាំបាច់ក្នុងការកំណត់កត្តាចម្បងដែលកំពុងគ្រប់គ្រងគុណភាព និងពិនិត្យមើលថាតើអ្នកផលិតអាចគ្រប់គ្រងវាបានដែរ ឬទេ។

□ កត្តាអាកាសធាតុ/ជម្ងឺ/សត្វល្អិតអាចជះឥទ្ធិពលមិនត្រឹមតែទៅលើទិន្នផលប៉ុណ្ណោះទេ ថែមទាំងលើគុណភាពទៀតផង។ កត្តាហានិភ័យទាំងនេះអាចត្រូវបានពិចារណា (សូមមើលផ្នែក ៤.១០ ហានិភ័យធម្មជាតិ/ករណីប្រធានសក្តិ) ហើយការអនុគ្រោះលើកម្រិតគុណភាពអាចត្រូវបានណែនាំនៅក្នុងករណីអសមត្ថភាពដើម្បីសម្រេចបានពេញលេញទៅលើលក្ខណៈបច្ចេកទេសចំពោះកត្តានានាហួសពីការគ្រប់គ្រងរបស់អ្នកផលិត។

## ៤.៤.២. វិធីសាស្ត្រផ្ទៀងផ្ទាត់

បន្ថែមទៅនឹងលក្ខណៈវិនិច្ឆ័យនិងតម្លៃគោលដៅគេបានផ្តល់អនុសាសន៍ថា ត្រូវបង្ហាញវិធីសាស្ត្រដែលបានប្រើសម្រាប់ការផ្ទៀងផ្ទាត់នេះ (វិធីសាស្ត្រធ្វើតេស្ត) និងនៅក្នុងករណីមួយចំនួនប្រភេទនៃឧបករណ៍វាស់វែងក៏ត្រូវបានប្រើប្រាស់។ វាចាំបាច់ប្រសិនបើមានវិធីសាស្ត្រផ្សេងៗគ្នាក្នុងការវាស់វែងលក្ខណៈវិនិច្ឆ័យជាក់លាក់មួយដែលអាចមានលទ្ធផលខុសគ្នាតិចតួច។

ជាឧទាហរណ៍ការផ្ទៀងផ្ទាត់ពូជស្រូវសុទ្ធល្អអាចធ្វើបានតាមរយៈការពិនិត្យរូបរាងរបស់គ្រាប់ស្រូវ ឬ ការធ្វើតេស្តដោយស្ទោរ ឬ ការធ្វើតេស្តអាល់កាឡាំង ឬ ដោយការធ្វើតេស្តឌីអិនអេ ។ ជាការពិតណាស់វិធីសាស្ត្រទាំងអស់មិនមានភាពត្រឹមត្រូវដូចគ្នាទេ ហើយការចំណាយក៏មិនដូចគ្នាដែរ។ (គួរចំណាំថាប្រសិនបើវិធីសាស្ត្រធ្វើតេស្តមានតម្លៃថ្លៃ ឬ តម្រូវឲ្យមានឧបករណ៍ជាក់លាក់កិច្ចសន្យាត្រូវកំណត់អ្នកដែលត្រូវទទួលបន្ទុកសម្រាប់ការអនុវត្តន៍ការធ្វើតេស្តគុណភាពនេះ និងអ្នកដែលត្រូវបង់ប្រាក់សម្រាប់ការចំណាយលើការធ្វើតេស្ត)។

## ៤.៥. កាតព្វកិច្ចពាក់ព័ន្ធនឹងវិធីសាស្ត្រ និងការផ្ទៀងផ្ទាត់ផលិតកម្ម

បន្ថែមពីលើលក្ខណៈបច្ចេកទេសដែលទាក់ទងនឹងគុណភាពផលិតផល (និងការដែលអាចផ្ទៀងផ្ទាត់បានផ្អែកលើការពិនិត្យផលិតផល) កិច្ចសន្យាក៏អាចកំណត់កាតព្វកិច្ចសម្រាប់អ្នកផលិតពាក់ព័ន្ធនឹងវិធីសាស្ត្រផលិតកម្មដែរ។ នេះអាចរួមបញ្ចូលច្បាប់ផ្សេងៗជាច្រើនដើម្បីអនុវត្តន៍ទាក់ទងនឹងផលិតកម្ម ឧទាហរណ៍ថា៖

- ការហាមឃាត់នៃការប្រើប្រាស់ប្រភេទថ្នាំសម្លាប់សត្វល្អិត ឬធាតុចូលផ្សេងៗ ឬផ្ទុយពីកាតព្វកិច្ចក្នុងការប្រើប្រាស់ធាតុចូលជាក់លាក់នោះ។
- កាតព្វកិច្ច ឬការហាមឃាត់មិនឲ្យប្រើប្រភេទឧបករណ៍មួយចំនួនសម្រាប់ទុកដាក់ផលិតផល។
- កាតព្វកិច្ចដែលត្រូវអនុវត្តតាមដំណើរការមួយចំនួនសម្រាប់ការប្រមូលផល/ក្រោយប្រមូលផល។

ច្បាប់សម្រាប់វិធីសាស្ត្រផលិតកម្មទាំងនេះអាចត្រូវបានកំណត់ជាពិសេស និងដើម្បីតម្រូវការរបស់អ្នកទិញ ឬអាចជាច្បាប់សាធារណៈ ឬ ច្បាប់ទូទៅដែលត្រូវបានអនុវត្តតាមដើម្បីធ្វើឲ្យផលិតផលអនុលោមតាមស្លាកសញ្ញា ឬយីហោគុណភាពដែលអ្នកទិញចង់បាន៖ ឧទាហរណ៍ ដើម្បីទទួលបានការបញ្ជាក់សរីរាង្គ (សូមមើលឧទាហរណ៍នៃការពន្យល់បន្ថែម ក្នុងការពន្យល់បន្ថែម ២.១.គ.) ឬដើម្បីឲ្យមានសិទ្ធិប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (សូមមើលការពន្យល់ករណីនៃឧទាហរណ៍ក្នុងការពន្យល់បន្ថែម ២.១.ច ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ផលិតផលម្រេចកំពត)។

អាស្រ័យលើហេតុផលទាំងនេះ៖ ការផ្ទៀងផ្ទាត់អំពីអនុលោមភាពអាចធ្វើឡើងដោយអ្នកទិញខ្លួនឯង ឬដោយស្ថាប័នចេញវិញ្ញាបនប័ត្របញ្ជាក់ដែលជាភាគីទីបី (ឧទាហរណ៍សម្រាប់ករណីនៃផលិតកម្មសរីរាង្គ)។

មុនពេលទទួលយកវិធីសាស្ត្រណាមួយដែលបានដាក់ឲ្យអនុវត្ត អ្នកផលិតត្រូវសួរខ្លួនឯងថា៖

☐ តើគាត់មានលទ្ធភាពទទួលបានការប្រើប្រាស់ធាតុចូល ឬឧបករណ៍ដែលចាំបាច់ដែរ ឬទេ (ប្រសិនបើមិនបានផ្តល់ដោយអ្នកចុះកិច្ចសន្យា)?

☐ តើមានហានិភ័យណាមួយដែលជាផលប៉ះពាល់អវិជ្ជមានដល់ការអនុវត្តដែលបានស្នើកើតឡើងលើផលិតកម្ម/ទិន្នផលដែរ ឬទេ?

☐ តើមានហានិភ័យណាមួយដែលជាផលប៉ះពាល់អវិជ្ជមានដល់ការអនុវត្តដែលបានស្នើកើតឡើងលើបរិស្ថាន ឬមធ្យោបាយផលិតកម្មដែរ ឬទេ (ឧ. សារធាតុពុល ការបំពុលដី ឬទឹក ឬការបាត់បង់ជីជាតិដីជាដើម)?

អ្នកផលិតអាចស្វែងរកយោបល់ពីអ្នកជំនាញ (ឧទាហរណ៍ ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំខេត្ត) នៅពេលមានចម្ងល់ណាមួយ។

## ៤.៦. កាតព្វកិច្ចផ្សេងទៀតរបស់អ្នកផលិត ( ឧ. ព័ត៌មានពាក់ព័ន្ធដែលត្រូវផ្តល់ស្តីពីផលិតផលគម្រូនៃផលិតកម្ម មុខងារសេវាកម្ម ។ល។)

កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចរួមបញ្ចូលលក្ខខណ្ឌតម្រូវបន្ថែមនៅពេលណាមួយ ឬ កាតព្វកិច្ចនានាពីភាគីអ្នកផលិត។ ឧទាហរណ៍ វាអាចជាកាតព្វកិច្ចក្នុងការកត់ត្រា និងចងក្រងឯកសារស្តីពីវិធីសាស្ត្រនៃផលិតកម្ម (បើទោះបីជាមិនមានលក្ខខណ្ឌតម្រូវជាក់លាក់ទាក់ទងនឹងវិធីសាស្ត្រផលិតក៏ដោយ ដែលអាចនឹងធ្លាក់នៅក្រោមចំណុច ផ្នែក ៤.៥ ខាងលើ ស្តីពីកាតព្វកិច្ចទាក់ទងនឹងវិធីសាស្ត្រផលិតកម្ម និងការផ្ទៀងផ្ទាត់)។ ឬ វាអាចរួមបញ្ចូលទាំងការផ្តល់សេវាកម្មផ្សេងៗ ដែលមាននៅក្នុងកិច្ចសន្យា ដែលអ្នកផលិតត្រូវអនុវត្តតាម។ ឧទាហរណ៍មួយចំនួននៃកាតព្វកិច្ចបន្ថែមបែបនេះត្រូវបានបង្កើតដូចខាងក្រោម។

### ៤.៦.១. កាតព្វកិច្ចព័ត៌មាន

ក្នុងករណីខ្លះ អ្នកចុះកិច្ចសន្យាគ្រាន់តែចង់ដឹងបន្ថែមទៀតអំពីរបៀបដែលទទួលបានផលិតផល (បើទោះបីជាគេមិនដាក់បញ្ចូលកាតព្វកិច្ចណាមួយនៅលើវិធីសាស្ត្រផលិតកម្មក៏ដោយ)៖ ឧទាហរណ៍បរិមាណនៃដីដែលត្រូវបានប្រើការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រឬមិនបានប្រើចំនួន / ប្រភេទ / កាលបរិច្ឆេទនៃការព្យាបាល ។ល។ ឬ ប្រសិនបើដំណាំឬផលិតកម្មសត្វត្រូវរងនឹងជម្ងឺមួយចំនួនក្នុងអំឡុងពេលដំណាក់កាលផលិតកម្ម។ ជួនកាលព័ត៌មានប្រភេទនេះមានសារៈសំខាន់សម្រាប់អ្នកចុះកិច្ចសន្យាដោយសារគេអាចត្រូវកែតម្រូវវិធីសាស្ត្រកែច្នៃបាន។ ប្រភេទជាច្រើនផ្សេងទៀតនៃតម្រូវការព័ត៌មានគឺទាក់ទងទៅនឹងសមត្ថភាពផ្ទៀងផ្ទាត់។ ឧទាហរណ៍ប្រសិនបើមានកសិករផ្សេងៗគ្នាស្ថិតនៅក្រោមកិច្ចសន្យាដូចគ្នា (កិច្ចសន្យាជាមួយនឹងអង្គការកសិករ) ឬ តំបន់ផលិតកម្មផ្សេងៗគ្នាអ្នកចុះកិច្ចសន្យាអាចស្នើសុំពីភាពខុសគ្នាទាំងនោះចំពោះផលិតផលដែលបានមកពីកសិដ្ឋានផ្សេងគ្នា ឬ តំបន់ផ្សេងគ្នា។ នេះនឹងតម្រូវឲ្យមានការកំណត់ឧបករណ៍ជាមូលដ្ឋានគ្រឹះសម្រាប់សមត្ថភាពផ្ទៀងផ្ទាត់ ស្ថិតក្រោមការទទួលខុសត្រូវរបស់ភាគីអ្នកផលិត (គឺអង្គការកសិករ)។

### ៤.៦.២. កាតព្វកិច្ចចូលរួមប្រជុំ និងការបណ្តុះបណ្តាល

នៅក្នុងករណីមួយចំនួនអ្នកចុះកិច្ចសន្យាត្រូវមានអនុសាសន៍ជាក់លាក់ ឬ បង្កើតឲ្យមានការបណ្តុះបណ្តាលដល់អ្នកផលិតនៅក្នុងដំណាក់កាលពិតប្រាកដណាមួយសម្រាប់វិធីសាស្ត្រផលិតកម្ម។ អ្នកចុះកិច្ចសន្យាអាចត្រូវទាមទារឲ្យមានវត្តមានរបស់អ្នកផលិតទាំងអស់សម្រាប់វគ្គបណ្តុះបណ្តាល/ផ្តល់ព័ត៌មាន។ កាតព្វកិច្ចនៃការចូលរួមនោះអាចជាលក្ខខណ្ឌតម្រូវដែលបានរៀបរាប់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យានេះ។ ក្នុងករណីនេះអ្នកផលិតត្រូវបានផ្តល់ឲ្យនូវភស្តុតាងនៃការចូលរួម ( ឬ បញ្ជីវត្តមាននឹងត្រូវបង្កើតឡើង និងចុះហត្ថលេខាដោយអ្នកចុះកិច្ចសន្យា និងរក្សាទុកនៅកម្រិតអង្គការកសិករក្នុងករណីមានកិច្ចសន្យាជាមួយអង្គការកសិករ) ដូច្នេះភាគីអ្នកផលិតអាចបង្ហាញពីអនុលោមភាពរបស់ខ្លួនតាមកាតព្វកិច្ចនេះ។

### ៤.៦.៣. សេវាកម្មពាក់ព័ន្ធដែលត្រូវអនុវត្តដោយអ្នកផលិត

ភាគីអ្នកផលិតអាចទាមទារសេវាផ្សេងទៀតជាពិសេសក្នុងករណីមានចុះកិច្ចសន្យាជាមួយអង្គការកសិករ។ ឧទាហរណ៍វាអាចរួមបញ្ចូលទាំងសេវាភស្តុភារ ឬ សម្របសម្រួលដូចជាការរៀបចំឲ្យមានការប្រមូលផ្តុំផលិតផលទៅដាក់នៅចំណុចដែលបានព្រមព្រៀងគ្នា ឬ ការវាយតម្លៃនៃភាពទុំនៃផលិតផលនៅក្នុងវាលស្រែ ការកំណត់កាលបរិច្ឆេទនៃការប្រមូលផល និងការទំនាក់ទំនងនៃការធ្វើផែនការប្រមូលផលទៅឲ្យអ្នកទិញ (នេះអាចជាការចាំបាច់ និងមានសារៈសំខាន់ក្នុងករណីត្រូវការផលិតផលស្រស់/ខូចគុណភាព) ។

> កាតព្វកិច្ចបន្ថែមអាចបង្កើតឲ្យមានការចំណាយខ្លះៗ។ ប្រសិនបើចាំបាច់ត្រូវធ្វើដូចនេះមែន ការចំណាយអាចត្រូវគ្របដណ្តប់ដោយតម្លៃដែលបង់សម្រាប់ផលិតផលដែលបានបញ្ជូនចេញ (ក្នុងករណីដែលអ្នកផលិតត្រូវប្រាកដថា មានតម្លៃគ្រប់គ្រាន់សម្រាប់ការចំណាយទាំងនេះ)។ ឬកិច្ចសន្យាក៏អាចកំណត់បុព្វលាភបន្ថែមជាក់លាក់សម្រាប់ការចំណាយលើសេវាទាំងនេះដែរ។ ឧទាហរណ៍ កិច្ចសន្យាខ្លះរួមបញ្ចូលទាំងការទូទាត់លើ "ថ្លៃសេវា" ទៅដល់អង្គការកសិករ (ចំពោះតួនាទីរបស់ខ្លួននៃការសម្របសម្រួលជាមួយកសិករ និងការប្រមូលយកផលិតផល) ដែលជាតម្លៃបន្ថែមដល់ការទូទាត់ប្រាក់សម្រាប់ផលិតផលដែលបានបញ្ជូនចេញ។
> (ផលិតកម្មកសិកម្មតាមកិច្ចសន្យា. ផ្នែកទី ៧ នៃសៀវភៅណែនាំនេះ)

## ៤.៧. តម្លៃ និងការយោងតម្លៃ

កិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវកំណត់ទាំងតម្លៃ (តម្លៃថេរ) ឬ វិធីដែលតម្លៃផលិតផលត្រូវបានកំណត់ (និងនៅពេលវេលាជាក់លាក់ ប្រសិនបើមិនបានចុះហត្ថលេខាលើកិច្ចសន្យា)។
ប្រព័ន្ធទាំងប្រាំនៃការកំណត់តម្លៃមានបង្ហាញដូចខាងក្រោម៖

- តម្លៃថេរ
- តម្លៃទីផ្សារ
- តម្លៃទីផ្សារ + ថ្លៃបុព្វលាភ
- តម្លៃអប្បបរមាដែលមានការធានា
- តម្លៃអប្បបរមាដែលមានការធានា + ថ្លៃបុព្វលាភ។

ជម្រើសទាំងប្រាំនេះត្រូវបានបង្កើតឡើងក្នុងកថាខណ្ឌដូចខាងក្រោម (៤.៧.១ ដល់ ៤.៧.៥)។ កថាខណ្ឌបន្ថែម (៤.៧.៦) ផ្តោតលើការជ្រើសរើស និងការប្រើប្រាស់ប្រភពត្រឹមត្រូវនៃព័ត៌មានដែលត្រូវប្រើជាសេចក្តីយោងក្នុងករណីដែលកិច្ចសន្យាត្រូវបានកំណត់នៅលើប្រព័ន្ធតម្លៃអថេរ។ កថាខណ្ឌចុងក្រោយ (៤.៧.៧) នៅក្នុងផ្នែកនេះ ៤.៧ និយាយអំពីការកែតម្រូវតម្លៃដែលបានបង់ចំពោះគុណភាពនៃផលិតផលដែលបានបញ្ជូនចេញ។

## ៤.៧.១. តម្លៃថេរ

នៅក្នុងប្រព័ន្ធតម្លៃថេរតម្លៃនៃផលិតផលត្រូវបានកំណត់ជាមុន ចាប់ពីពេលចុះហត្ថលេខាលើកិច្ចសន្យារួចមក។ វាត្រូវបានទទួលយកដោយភាគីទាំងពីរហើយជាប់ជាកាតព្វកិច្ចត្រូវអនុវត្ត។

### ក្នុងករណីណាដែលប្រព័ន្ធតម្លៃថេរមានលក្ខណៈសមស្រប?

កិច្ចសន្យាតម្លៃថេរ អាចដំណើរការយ៉ាងល្អសម្រាប់ផលិតកម្មដែលកសិករមិនមានឱកាសច្រើនសម្រាប់លក់។ ប្រសិនបើគ្មានអ្នកប្រមូលផ្សេងទៀត / អ្នកទិញ ក្រៅពីក្រុមហ៊ុនដែលផ្តល់ការប្រើប្រាស់ទីផ្សារតាមរយៈកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាទេគេអាចបង្កើតតម្លៃកំណត់ថេរជាមុនដូច្នេះមិនមានការភ្ញាក់ផ្អើល និងជម្លោះកើតឡើងឡើយទៅតាមវិធីដែលតម្លៃត្រូវបានបង្កើតឡើង។

ក្រៅពីនេះប្រសិនបើមិនមានការបញ្ជាទិញផ្សេងទៀតពីអ្នកទិញដទៃទៀត/អ្នកប្រមូលផ្សេងទៀតទេ នោះនឹងមិនមានហានិភ័យនៃការលក់តែម្ខាងដោយកសិករឡើយ ដោយសារអ្នកទិញផ្សេងទៀតបានផ្តល់ជូនតម្លៃល្អ។ កិច្ចសន្យាតម្លៃថេរ ក៏អាចប្រែប្រួលគួរឲ្យកត់សម្គាល់ផងដែរសម្រាប់ផលិតផលថ្មីដែលកសិករមិនទាន់បានប្រើក្នុងការផលិត (ហើយម្យ៉ាងទៀតពួកគេមិនបានដឹងច្បាស់អំពីទីផ្សារ)។

ផ្ទុយទៅវិញ ប្រសិនបើកសិករមានទំនាក់ទំនងជាមួយអ្នកទិញដែលមានសក្តានុពលជាច្រើនទៀតដែលពួកគេចាប់អារម្មណ៍លើផលិតផលដូចគ្នា ជាដៃគូរបស់ពួកគេសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យាប្រព័ន្ធតម្លៃថេរអាចលំបាកក្នុងការអនុវត្តន៍ប្រសិនបើនៅពេលប្រមូលផល / ការបញ្ចូលតម្លៃថេរនៅក្នុងកិច្ចសន្យាស្ថិតនៅក្រោមតម្លៃដែលបានផ្តល់ជូនដោយអ្នកទិញផ្សេងទៀត។ ហានិភ័យនៃការលក់តែម្ខាង (កសិករនឹងមិនធ្វើតាមកិច្ចសន្យាកំហុសលើការបញ្ជូនផលិតផលទៅឲ្យអ្នកទិញ) គឺមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងស្ថានភាពបែបនេះ។ ហានិភ័យនេះមានកម្រិតខ្ពស់ណាស់ ប្រសិនបើកិច្ចសន្យានោះត្រូវបានចុះហត្ថលេខារវាងអង្គការកសិករ / សហគមន៍កសិករជាមួយអ្នកទិញ ក្នុងនាមអង្គការកសិករ / សហគមន៍កសិករត្រូវតស៊ូការពារការលក់តែម្ខាងពីសមាជិករបស់ខ្លួន និងធានាថាវាពិតជាអាចប្រមូលផលិតកម្ម (សូមមើលផ្នែកទី ៦នៃគោលការណ៍ណែនាំទាំងនេះ) ។

**តម្លៃថេរអាចនឹងត្រូវបានទទួលយក ទោះជានៅក្នុងស្ថានភាពដែលមានអ្នកទិញមានសក្តានុពលផ្សេងទៀតក៏ដោយ ប្រសិនបើលក្ខខណ្ឌនៃកិច្ចសន្យា និងជាពិសេស ការគាំទ្របច្ចេកទេស និង/ឬ ធាតុចូលដែលបានផ្តល់ដោយអ្នកចុះកិច្ចសន្យាអនុញ្ញាតឲ្យកសិករផលិតប្រភេទផលិតផល ឬគុណភាពដែលពួកគេមិនអាចផលិតបានដោយគ្មានកិច្ចសន្យា។ ជារួម បើសិនភាគលាភសុទ្ធដែលទទួលបានដោយកសិករខ្ពស់ជាងអ្វីដែលពួកគេត្រូវមានដោយគ្មានកិច្ចសន្យា (ព្រោះប្រភេទ ឬគុណភាពនៃផលិតកម្មរបស់ពួកគេបានផ្លាស់ប្តូរដោយសារតែផលិតកម្មកសិកម្មតាមកិច្ចសន្យា) ពួកគេមានភក្តីភាពចំពោះអ្នកចុះកិច្ចសន្យានេះ (បើទោះបីជាអ្នកទិញផ្សេងទៀតអាចផ្តល់តម្លៃខ្ពស់ដល់ពួកគេនៅពេលប្រមូលផលក៏ដោយ)។ [សូមមើលការពន្យល់បន្ថែម ចំណុច ៤.៧.ក. ខាងក្រោម]។**

ការពន្យល់បន្ថែម ៤.៧.ក.
កិច្ចសន្យាតម្លៃថេរដែលទទួលបានជោគជ័យសម្រាប់ពូជស្រូវទំនើបក្រអូប

ករណីជោគជ័យនៃកិច្ចសន្យាតម្លៃថេរ សម្រាប់ផលិតកម្មស្រូវ ត្រូវបានចាត់ទុកជាបទពិសោធន៍មួយផ្នែកនៃការគាំទ្រចំពោះពាណិជ្ជូបនីយកម្មនៃគម្រោងស្រូវអង្ករកម្ពុជា រវាងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឬអ្នកនាំចេញ និងអង្គការកសិករជាច្រើន។ អ្នកចុះកិច្ចសន្យាបានផ្តល់គ្រាប់ពូជថ្មីដល់កសិករដែលជាពូជស្រូវក្រអូបមិនធ្វើរស្មីសំយោគរយៈពេលខ្លី។ ពូជនេះអាចដាំបាននៅរដូវប្រាំង ហើយអាចជំនួសពូជអ៊ីអ៊ែរ សម្រាប់ប្រើនៅរដូវដូចគ្នា និងមានផលិតភាពដូចគ្នា។

នៅក្នុងកិច្ចសន្យា ក្រុមហ៊ុនផ្តល់តម្លៃថេរ ១,០០០ រៀល/kg ដែលថ្លៃជាងប្រហែល ២០ ទៅ ២៥% នៃតម្លៃធម្មតារបស់ស្រូវអ៊ីអ៊ែរ។ ទោះតម្លៃនេះថោកសម្រាប់ស្រូវក្រអូបក្តី (គិតនៅពេលអនុវត្តកិច្ចសន្យា) កសិករពេញចិត្តយ៉ាងខ្លាំង ដោយហេតុថា ចំណូលដែលរកបាននោះ គឺខ្ពស់ជាងចំណូលពីមុនពេលមានកិច្ចព្រមព្រៀងផលិតកម្មកសិកម្ម។ នេះពិតជាដំណោះស្រាយឈ្នះឈ្នះ។

### តើតម្លៃថេរ គួរកំណត់យ៉ាងដូចម្តេច?

ប្រសិនបើកិច្ចសន្យាគឺអាស្រ័យលើតម្លៃថេរ វាគួរតែមានភាពងាយស្រួលសម្រាប់ជំនះឧបសគ្គ និងបញ្ហាប្រឈមរបស់អ្នកផលិត និងអ្នកទិញ។

#### ទស្សនៈរបស់ភាគីអ្នកផលិត

តាមទស្សនៈរបស់ភាគីអ្នកផលិត តម្លៃថេរគួរតែពិចារណាទៅតាមថ្លៃដើមនៃការផលិត (រាល់ការចំណាយលើធាតុចូល និងសេវាកម្មចាំបាច់ដើម្បីផលិតបាននូវផលិតផល រួមមាន ថ្លៃឈ្នួលកម្មករ ការជួលដី – ឬ ការបោះបង់ឱកាសផ្សេង ពីការជួលដីនេះទៅឲ្យអ្នកដទៃ ដែលជាកម្មសិទ្ធិរបស់ភាគីអ្នកផលិត – ការចំណាយលើសេវាកម្មហិរញ្ញវត្ថុ – ដូចជា ការប្រាក់ដែលអ្នកផលិតទៅខ្ចីពីអ្នកដទៃ ដើម្បីមកចុះកិច្ចសន្យា និងទូទាត់ថ្លៃផលិត រហូតដល់ពេលទទួលបានប្រាក់ពីផលិតផលដែលបានផ្តល់ជូន –និងការកែច្នៃ ការទុកដាក់ ការដឹកជញ្ជូនផលិតផល អាស្រ័យទៅតាមការកំណត់នៅក្នុងកិច្ចសន្យា ដោយបញ្ជាក់ពីពេលវេលា និងទីតាំងនៃការប្រគល់ទំនិញ) និងការទុកប្រាក់ចំណេញមួយចំនួនជាថ្លៃពលកម្មរបស់ភាគីអ្នកផលិត។

ជាការពិតណាស់ ចំណូលដុលរបស់ភាគីអ្នកផលិត គួរជាការឆ្លុះបញ្ចាំងរវាងតម្លៃនិងបរិមាណដែលបានលក់។ ការប៉ាន់ស្មានលើប្រាក់ចំណូលដែលនឹងរកបានពីកិច្ចសន្យា ត្រូវតែយកមកពិចារណា អំពីលទ្ធភាពពិតប្រាកដ ដើម្បីឈានដល់ទំហំផលិតដែលបានរំពឹងទុក (សូមមើលយោបល់ស្តីពីការប៉ាន់ស្មានលើបរិមាណ នៅក្នុងផ្នែក ៤.៣.២. នៅក្នុងទំព័រមុននេះ)។ ប្រសិនបើកិច្ចសន្យាកំណត់អំពីបម្រែបម្រួលនៃបរិមាណ នោះគេគួរផ្ទៀងផ្ទាត់ថា ប្រសិនបើមានទិន្នផលទាប គេអាចមានចំណូលសមរម្យសម្រាប់កសិករដែរឬទេ។

ទន្ទឹមនេះ ត្រូវពិចារណាអំពីលក្ខខណ្ឌនៃការផលិត (និងការចំណាយ) ដែលមិនអាចប៉ាន់ស្មានទុកមុនបានទាំងស្រុង។ សកម្មភាពបន្ថែម (ពីលើផែនការសកម្មភាពផលិតស្តង់ដារ) អាចត្រូវមានជាចាំបាច់ នៅក្នុងដំណើរការនៃការផលិត ដូចជារបៀបដោះស្រាយពេលមានសត្វល្អិតបំផ្លាញ ប្រព័ន្ធស្រោចស្រពបន្ថែម ក្នុងករណីមានភាពរាំងស្ងួត...។ ភារកិច្ចបន្ថែមទាំងនេះ ឬលក្ខខណ្ឌធាតុចូល សុទ្ធតែត្រូវមានការចំណាយ ដូចនេះ គួរគិតគូរដល់ថ្លៃសម្រាប់ការផលិត ដើម្បីត្រៀមទប់ទល់នឹងការចំណាយដែលមើលមិនឃើញទាំងនោះ។

#### ទស្សនៈរបស់ភាគីអ្នកទិញ

ពីទស្សនៈរបស់ភាគីអ្នកទិញ ម៉ូដែលតម្លៃថេរមានប្រសិទ្ធភាព ប្រសិនបើភាគីអ្នកទិញក៏មានតម្លៃថេរជាមួយនឹងកិច្ចសន្យា ជាមួយអតិថិជនរបស់ខ្លួន។ បើពុំនោះទេ វាមានន័យថា ភាគីអ្នកទិញត្រូវធានាខុសត្រូវលើហានិភ័យនៃការឡើងចុះថ្លៃ ដែលអាចមានការឡើងថ្លៃ ប្រសិនផលិតផល អាចប្រែប្រួលខ្លាំងទៅតាមទីផ្សារអន្តរជាតិ។ ប្រសិនបើភាគីអ្នកទិញនាំមកនូវតម្លៃបន្ថែមខ្លាំង ដោយការកែច្នៃ ឬ មានម៉ាកយីហោផលិតផល ហើយផលិតផលមានទីផ្សារពិសេស ឬ ផលិតផលមានភាពប្លែកពីផលិតផលដទៃទៀត ដូច្នេះហានិភ័យនៃការជ្រើសរើសតម្លៃថេរអាចនឹងជាជម្រើសរឹងមាំសម្រាប់ភាគីអ្នកទិញ។

ទោះយ៉ាងណា ការកំណត់តម្លៃថេរជាមុន វាគឺជាការភ្នាល់គ្នាលើអនាគត (សម្រាប់ភាគីទាំងពីរ) ។ អ្នកទិញអាចឈ្នះ ប្រសិនបើ តម្លៃទីផ្សារគឺខ្ពស់ជាងតម្លៃថេរនៅពេលទិញ ឬ គេអាចចាញ់នៅក្នុងស្ថានភាពផ្ទុយពីនេះ។

### ៤.៧.២. តម្លៃតាមទីផ្សារ

ជម្រើសសំខាន់ផ្សេងទៀតសម្រាប់ម៉ូដែលផលិតកម្មកសិកម្ម គឺកិច្ចសន្យាដែលឈរលើ**តម្លៃទីផ្សារ**។ ក្នុងជម្រើសនេះ កិច្ចសន្យាមិនបញ្ជាក់ទុកជាមុនអំពីតម្លៃដែលនឹងត្រូវទូទាត់ដោយភាគីអ្នកទិញ ជូនភាគីអ្នកផលិតសម្រាប់ផលិតផលដែលប្រគល់ជូនទេ **ប៉ុន្តែត្រូវបញ្ជាក់អំពីវិធីដែលនឹងត្រូវប្រើប្រាស់ដើម្បីកំណត់តម្លៃនៅពេលប្រគល់ទំនិញ** (ឬ ការទូទាត់ប្រាក់)។

**នៅពេលធ្វើប្រតិបត្តិការ តម្លៃនឹងត្រូវកំណត់អាស្រ័យលើទីផ្សារបច្ចុប្បន្ន។ នេះតម្រូវឲ្យមានការកំណត់និយមន័យនៃសេចក្តីយោងច្បាស់លាស់ ដែលនឹងត្រូវយល់ព្រមយកមកប្រើប្រាស់ ដោយភាគីទាំងពីរ ដើម្បីជាប្រភពព័ត៌មានសម្រាប់កំណត់តម្លៃ។ ផ្នែក ៤.៧.៦. ផ្តល់នូវយោបល់ជាក់លាក់ខ្លះៗ និងយោបល់ពាក់ព័ន្ធនឹងសេចក្តីយោងនៃតម្លៃ។**

#### តើប្រព័ន្ធកំណត់តម្លៃទីផ្សារ គួរយកមកប្រើនៅពេលណា ?

កិច្ចសន្យាដែលមានតម្លៃទីផ្សារ អាចធ្វើឲ្យកសិករមានហានិភ័យ ដោយសារការឡើងចុះនៃទីផ្សារ។ កសិករតែងត្រូវបានអ្នកដទៃប្រើប្រាស់ ឲ្យប្រឈមមុខនឹងហានិភ័យ ប៉ុន្តែអាស្រ័យលើភាពងាយប្រសើរឡើងវិញ (សមត្ថភាពដោះស្រាយហានិភ័យនៃតម្លៃទាប ដែលអាស្រ័យលើកម្រិតដើមទុន និងភាពចម្រុះនៃប្រភពចំណូល) គេគួរប្រើប្រព័ន្ធកំណត់តម្លៃដែលងាយស្មានដឹងមុន ប្រសិនបើកសិករងាយរងគ្រោះខ្លាំង។

**ប្រព័ន្ធកំណត់តម្លៃតាមទីផ្សារ អាចនឹងមិនពាក់ព័ន្ធនឹងការផលិតដែលកសិករត្រូវបានប្រើប្រាស់ ហើយក្នុងករណី មានទីផ្សារក្នុងមូលដ្ឋានដែលងាយប្រែប្រួលពីកត្តាផ្សេងទៀតផងនោះ (ដូចជា កសិករអាចមានអ្នកទិញផ្សេងទៀត) ។ ក្នុងករណីនោះ គុណសម្បត្តិនៃជម្រើសកំណត់តម្លៃតាមទីផ្សារ គឺជាជម្រើសដែលកាត់បន្ថយហានិភ័យនៃការលក់ទៅឲ្យអ្នកដទៃ (ដែលអាចខ្ពស់ជាងរបៀបកំណត់តម្លៃថេរ ហើយនៅពេលតម្លៃទីផ្សារថ្លៃជាងតម្លៃក្នុងកិច្ចសន្យា)។**

**ការកំណត់តម្លៃតាមទីផ្សារ គឺមិនសូវពាក់ព័ន្ធទេ នៅពេលមិនមានទីផ្សារក្នុងស្រុកសម្រាប់ផលិតផលនេះ (ជាពិសេស ប្រសិនបើការផលិតនេះជាការផលិតថ្មីសម្រាប់កសិករ)។ ក្នុងករណីនោះ ហានិភ័យនៃការលក់ទៅក្រៅគឺមិនមានទេ ហើយវាក៏ពិបាកនឹងឯកភាពទៅលើតម្លៃទីផ្សារក្នុងមូលដ្ឋានដែរ នៅពេលប្រមូលផល ឬពេលប្រគល់ទំនិញ**[12]**។**

[12] ទោះបី មិនមានសេចក្តីយោងក្នុងមូលដ្ឋានសម្រាប់ប្រើប្រាស់ ដូចជា មានតម្លៃទីផ្សារអន្តរជាតិ ដូចមានពន្យល់នៅក្នុង ផ្នែក ៤.៧.៦.

កិច្ចសន្យាកំណត់តម្លៃតាមទីផ្សារ មិនមែនមានន័យថា តួលេខនៃតម្លៃគឺត្រូវបានប្រើប្រាស់ដោយផ្ទាល់ជាតម្លៃដែលត្រូវទូទាត់ទៅឲ្យអ្នកផលិតទេ។ វិធីសាស្រ្តដើម្បីគណនាតម្លៃក្នុងកិច្ចសន្យាអាចជា រូបមន្តដែលគណនាទៅតាមឯកសារយោងតម្លៃ ប៉ុន្តែក៏ត្រូវរួមផ្សំនឹងកត្តាផ្សេងៗទៀត ដូចជា ៖

☐ ឯកសារយោងនៃតម្លៃស្រូវដែលព្រមទិញដោយអ្នកប្រមូលទិញក្នុងមូលដ្ឋាន + ការប៉ាន់ស្មាននៃការចំណាយលើការដឹកជញ្ជូន ប្រសិនបើអ្នកផលិត ត្រូវដឹកទៅដល់កន្លែងអ្នកទិញ

☐ ភាគរយនៃតម្លៃយោងអន្តរជាតិ សម្រាប់ផលិតផលកែច្នៃរួច (ដូចជា តម្លៃស្រូវ = x% នៃតម្លៃដឹកតាមនាវា (FOB) សម្រាប់ពូជអង្ករដដែល)...

### ៤.៧.៣. តម្លៃតាមទីផ្សារ + ថ្លៃបុព្វលាភ

កត្តាប្រែប្រួលនៃកិច្ចសន្យាតម្លៃទីផ្សារគឺជម្រើស **តម្លៃតាមទីផ្សារ + ថ្លៃបុព្វលាភ** ។

សម្រាប់ការកំណត់តម្លៃតាមទីផ្សារ តម្លៃត្រូវបានកំណត់ដោយអាស្រ័យទៅតាមសេចក្តីយោងតម្លៃដែលបានឯកភាពគ្នា (ដូចជា ជាមួយរូបមន្តនៃការគណនា) ប៉ុន្តែតម្លៃទីផ្សារ ត្រូវបានបង្កើនដោយ ប្រាក់បន្ថែមថេរ (ឬប្រែប្រួល) ឬ "បុព្វលាភ" ដែលត្រូវទូទាត់ទៅឲ្យអ្នកផលិត។ នេះគឺជាការលើកទឹកចិត្តដើម្បីធ្វើឲ្យប្រាកដថាមានភក្តីភាពពីអ្នកផលិត ហើយ/ឬ អាចទូទាត់ប្រាក់ទៅតាមគុណភាពជាក់លាក់ ឬ តម្លៃនៃផលិតផល ដែលទីផ្សារក្នុងមូលដ្ឋានអាចនឹងមិនឲ្យតម្លៃ។

➨ តម្លៃដែលទូទាត់ទៅឲ្យអ្នកផលិតគឺ ៖

*តម្លៃសម្រាប់អ្នកផលិត = តម្លៃតាមទីផ្សារ + ថ្លៃបុព្វលាភ។*

បុព្វលាភអាចជាតម្លៃដាច់ខាត ឬជាភាគរយបន្ថែមនៃតម្លៃទីផ្សារ។

➨ នៅក្នុងករណីដែលបុព្វលាភត្រូវបានកំណត់ជាតម្លៃដាច់ខាត (តម្លៃក្នុងមួយឯកតាបរិមាណ)[13]៖

*តម្លៃសម្រាប់អ្នកផលិត = តម្លៃទីផ្សារ + x (រៀល/kg)*

➨ ក្នុងករណីថ្លៃបុព្វលាភប្រែប្រួល៖

*តម្លៃសម្រាប់អ្នកផលិត = តម្លៃទីផ្សារ + x %*

តម្លៃទីផ្សារ + ថ្លៃបុព្វលាភ គឺតែងប្រើប្រាស់សម្រាប់ផលិតកម្មនៃផលិតផលសរីរាង្គដែលមានការទទួលស្គាល់ដែលក្នុងនោះ ពាណិជ្ជករក្នុងមូលដ្ឋានប្រហែលជាមិនចេញថ្លៃលើពីផលិតផលធម្មតាទេ ប៉ុន្តែ អ្នកចុះកិច្ចសន្យា អាចចេញថ្លៃ ព្រោះវាជាការតភ្ជាប់ទៅទីផ្សារជាក់លាក់ [សូមមើល ការពន្យល់បន្ថែមលេខ ៤.៧.ខ ខាងក្រោម]។

[13] ករណីនេះ មានរៀបរាប់បន្ថែមនៅក្នុង ការពន្យល់បន្ថែម ៤.៧.ខ. ទំព័របន្ទាប់។

ការពន្យល់បន្ថែម ៤.៧.ខ.

« តម្លៃទីផ្សារ + ថ្លៃបុព្វលាភ » ម៉ូដែលសម្រាប់ការផ្គត់ផ្គង់ស្រូវសរីរាង្គ

ករណីជោគជ័យនៃផលិតកម្មកសិកម្ម ជាមួយនឹងប្រព័ន្ធ តម្លៃទីផ្សារ + ថ្លៃបុព្វលាភ ត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃគម្រោងគាំទ្រពាណិជ្ជនីយនីយកម្មស្រូវអង្ករកម្ពុជា រវាងអ្នកនាំអង្ករចេញធំៗ និងសហគមន៍កសិកម្មចំនួនប្រាំបី នៅក្នុងខេត្តព្រះវិហារ សម្រាប់ការផលិតនិងការផ្គត់ផ្គង់ស្រូវសរីរាង្គ។

ស្រូវសរីរាង្គអាចលក់ទៅទីផ្សារអន្តរជាតិក្នុងតម្លៃបុព្វលាភខ្ពស់។ ទោះអ្នកនាំចេញ មានជោគជ័យក្នុងការរកឃើញទីផ្សារអង្ករសរីរាង្គនៅសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិកក៏ដោយ វាជាការសំខាន់ដែលត្រូវរក្សាការផ្គត់ផ្គង់ឲ្យបានល្អ (ដែលអាចមានការទទួលស្គាល់ដោយ អង្គភាពចេញវិញ្ញាបនបត្រអន្តរជាតិសម្រាប់ ស្របទៅតាមស្តង់ដារសរីរាង្គរបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។)។

ទន្ទឹមនេះ ការអនុលោមតាមស្តង់ដារសរីរាង្គអាចនាំឲ្យមានការថយចុះផលិតភាពខ្លះៗ ហើយក្រៅពីនេះ ក៏ត្រូវមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង (ការចំណាយលើការត្រួតពិនិត្យ ផ្ទៃក្នុងដើម្បីផ្ទៀងផ្ទាត់ការអនុលោមតាមស្តង់ដារសរីរាង្គ)។ សហគមន៍កសិកម្មអាចស្ទាក់ស្ទើរចិត្តក្នុងការវិនិយោគបែបនោះ ព្រោះថា មិនមានការធានាថា ស្រូវសរីរាង្គមានតម្លៃខ្ពស់នោះទេ។

សម្រាប់ករណីនេះ កិច្ចសន្យាផលិតកម្មកសិកម្មគឺមានភាពពាក់ព័ន្ធខ្លាំងណាស់ សម្រាប់ភាគីទាំងពីរ ដែលត្រូវធានានូវកិច្ចសន្យារបស់គេ។

កិច្ចសន្យាផលិតកម្មកសិកម្ម ដែលចុះហត្ថលេខាដោយអ្នកនាំចេញ និងសហគមន៍ កាលពីឆ្នាំ ២០១៤ គឺគណនាតាមរបៀប តម្លៃទីផ្សារ + ថ្លៃបុព្វលាភ។

កាលពីឆ្នាំ ២០១៤ កម្រិតថ្លៃបុព្វលាភគឺមានចន្លោះ ពី +៧០ ទៅ +២០០ រៀល/kg អាស្រ័យទៅលើកម្រិតគុណភាពនៃស្រូវដែលបញ្ជូនឲ្យ។

ផ្នែកមួយនៃតម្លៃបន្ថែមចេញមកពីការទទួលស្គាល់ថាជាស្រូវសរីរាង្គ ត្រូវបានចែករំលែកជាមួយគ្នា ក្នុងចំណោមកសិករដែលនាំឲ្យមានភាពជាដៃគូឈ្នះឈ្នះ។ តម្លៃតាមទីផ្សារ + ថ្លៃបុព្វលាភ គឺងាយសម្របសម្រួលនៅក្នុងករណីនេះ ហើយវាកាត់បន្ថយហានិភ័យ នៃការលក់ទៅខាងក្រៅ ដោយហេតុថា តម្លៃដែលបានផ្តល់សម្រាប់ស្រូវសរីរាង្គ តែងខ្ពស់ជាងតម្លៃដែលប្រមូលទិញដោយឈ្មួញកណ្តាល សម្រាប់ស្រូវប្រភេទដូចគ្នា ដោយចាត់ទុកថាជាស្រូវធម្មតា។

នៅឆ្នាំខាងក្រោមនេះ កិច្ចសន្យារវាងអ្នកទិញ និងសហគមន៍ ត្រូវបានកែសម្រួលឡើងវិញ ដោយមានការបង្កើនបរិមាណនិងថ្លៃបុព្វភាពកាន់តែច្រើន (ពី +១២៥ ទៅ +២៦០ រៀល ក្នុងមួយគីឡូក្រាម)។

ពេលខ្លះ កិច្ចសន្យាផលិតកម្មកសិកម្ម គឺជាវិធីសម្រាប់អ្នកទិញ ដែលមិនត្រឹមតែធានាបាននូវការផ្គត់ផ្គង់ប៉ុណ្ណោះទេ ប៉ុន្តែក៏ស្គាល់កាន់តែច្បាស់អំពីផលិតផលដែលខ្លួនកំពុងទិញ (ងាយស្រួលតាមដានថយក្រោយ និងមានព័ត៌មានល្អស្តីពីវិធីសាស្ត្រនៃការផលិត ជាដើម)។ នេះអាចជាលក្ខខណ្ឌសម្រាប់ក្រុមហ៊ុនទិញ ដែលត្រូវអនុវត្តតាមសម្រាប់ការទទួលស្គាល់តាមស្តង់ដារអន្តរជាតិ ដែនជួយឲ្យងាយរកបានទីផ្សារ ឬតម្លៃកាន់តែល្អ។ ប៉ុន្តែប្រសិនបើ ត្រូវមានការខិតខំបន្ថែមពីអ្នកផលិត (យ៉ាងហោចណាស់ កត់ត្រាការអនុវត្តន៍ និងផ្តល់មកជាមួយនឹងផលិតផល និងព័ត៌មានខ្លះអំពីវិធីសាស្ត្រផលិត) នោះគេគួរផ្តល់ការលើកទឹកចិត្តសម្រាប់ការងារបន្ថែមនេះ។ តម្លៃបុព្វលាភគួរតែមានផ្តល់នៅក្នុងករណីនេះ។ការពន្យល់បន្ថែម ៤.៧.គ. ខាងក្រោមនេះគឺជាឧ. អំពីករណីដែលអ្នកទិញ ស្នើសុំឲ្យផ្តល់ឯកសារផលិត ប៉ុន្តែមិនផ្តល់ការលើកទឹកចិត្តចំពោះការខិតខំ។

ការពន្យល់បន្ថែម ៤.៧.គ.

ករណីបរាជ័យ៖ « តម្លៃទីផ្សារ » ក្នុងពេលដែលតម្រូវឲ្យកសិករធ្វើការងារច្រើនពេក

នៅក្នុងករណីផ្សេងទៀតដែលសម្របសម្រួលដោយគម្រោង SCCRP ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញ បានចុះកិច្ចសន្យាជាមួយអង្គការកសិករដើម្បីផ្គត់ផ្គង់ស្រូវធម្មតា។ គេយល់ព្រមទូទាត់តាមតម្លៃទីផ្សារ (ដោយប្រើរោងម៉ាស៊ីនកិនស្រូវផ្សេងទៀត នៅក្បែរទីតាំងរបស់អ្នកទិញ ជាតម្លៃយោង)។ ក្រៅពីស្រូវ អ្នកទិញក៏រំពឹងថា អង្គការកសិករផ្តល់ព័ត៌មានអំពីវិធីសាស្ត្រផលិត (ការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ...) ដែលតម្រូវឲ្យកសិករធ្វើការបន្ថែម ដើម្បីប្រមូលទិន្នន័យ ពីសមាជិក និងបូកសរុបព័ត៌មានទាំងអស់។

កសិករមិនទទួលបានប្រាក់បុព្វលាភចំពោះការងារបន្ថែមនេះទេ ដែលធ្វើឲ្យកសិករមិនមានទឹកចិត្ត លើកិច្ចសន្យានេះ។ ភាពជាដៃគូ គឺមិនសូវមានភាពជោគជ័យទេ ហើយក៏មិនបានបន្តកិច្ចសន្យាទៀតដែរ។

## ៤.៧.៤. តម្លៃអប្បបរមាដែលបានធានា ឬ តម្លៃទីផ្សារ ប្រសិនបើលើសនេះ

ជម្រើសនៃ **ការធានាតម្លៃអប្បបរិមា** គឺជាការលាយចូលគ្នានៃតម្លៃថេរ និងតម្លៃតាមទីផ្សារ។

នៅក្នុងម៉ូដែលនេះ តម្លៃទីផ្សារត្រូវបានប្រើប្រាស់ (ដូចមានចែងនៅក្នុង ផ្នែក ៤.៧.២. ខាងលើ) ប៉ុន្តែតម្លៃដែលបានបង់ មិនអាចស្ថិតនៅក្រោមកម្រិតអប្បបរិមាដែលបានធានាទេ។ ប្រសិនបើតម្លៃទីផ្សារ (ឬតម្លៃដែលបានគណនា ស្របតាមរូបមន្តដែលបានឯកភាព និងអាស្រ័យលើយោងតម្លៃទីផ្សារ) គឺទាបជាងកម្រិតអប្បបរិមា នោះទឹកប្រាក់ដែលត្រូវទូទាត់ នឹងធ្វើឡើងទៅតាមតម្លៃអប្បបរិមាដែលបានធានា។

- ប្រសិនបើតម្លៃទីផ្សារ ខ្ពស់ជាងកម្រិតអប្បបរិមាដែលបានធានា តម្លៃដែលត្រូវទូទាត់ទៅអ្នកផលិតគឺ ៖

  *តម្លៃសម្រាប់អ្នកផលិត = តម្លៃតាមទីផ្សារ*

- ប្រសិនបើតម្លៃទីផ្សារស្មើ ឬទាបជាង តម្លៃអប្បបរិមាដែលបានធានា តម្លៃដែលត្រូវទូទាត់ឲ្យអ្នកផលិតគឺ៖

  *តម្លៃសម្រាប់អ្នកផលិត = តម្លៃអប្បបរិមាដែលបានធានា*

តម្លៃអប្បបរិមាដែលបានធានា គឺតែងតែជាជម្រើសល្អ សម្រាប់អ្នកផលិត ព្រោះថា វាផ្តល់នូវការធានាតម្លៃអប្បបរិមាសម្រាប់អ្នកផលិត (ដែលអាចទូទាត់ថ្លៃផលិត និងនៅសល់ប្រាក់ចំណេញសុទ្ធសមរម្យ សម្រាប់កម្លាំងពលកម្មរបស់កសិករ)។ ស្របពេលនេះដែរ នៅពេលដែលតម្លៃប្រែប្រួលទៅតាមតម្លៃទីផ្សារ នៅពេលដែលវាឡើងថ្លៃ ហានិភ័យនៃការលក់ទៅក្រៅ គឺអាស្រ័យទៅតាមឱកាសទីផ្សារល្អជាង នៅខាងក្រៅកិច្ចសន្យា។ កត្តាគិតគូនៅក្នុង ផ្នែកស្តីពី "របៀបកំណត់តម្លៃថេរ" (ក្នុងផ្នែក ៤.៧.១) នៅតែអាចអនុវត្តបាន នៅពេលធ្វើការធានាលើតម្លៃអប្បបរិមា។

គេប្រើប្រាស់ការធានាតម្លៃអប្បបរិមាជាញឹកញាប់នៅក្នុងដំណើរការទទួលស្គាល់នៃពាណិជ្ជកម្ម សមធម៌។

ដើម្បីធានាតម្លៃអប្បបរិមា គេតែងយកចិត្តទុកដាក់លើចំណុចមួយចំនួន ពីសំណាក់អ្នកចុះកិច្ចសន្យា ជាមួយអ្នកផលិត ព្រមទាំងត្រូវពិនិត្យឆន្ទៈក្នុងការបង្កើតភាពជាដៃគូយូរអង្វែងជាមួយពួកគេ។ វាអាចជាទ្រព្យដ៏សំខាន់សម្រាប់ការទទួលខុសត្រូវផ្នែកសង្គម និងមុខមាត់របស់សាជីវកម្ម។

## ៤.៧.៥. តម្លៃអប្បបរមាដែលបានធានា ឬតម្លៃទីផ្សារ ប្រសិនបើលើសនេះ + បុព្វលាភ

ជម្រើសនៃ**ការធានាតម្លៃអប្បបរិមា + បុព្វលាភ** គឺជាភាពចម្រុះនៃប្រព័ន្ធដែលបានរៀបរាប់នៅក្នុងផ្នែក ៤.៧.៣. និង ៤.៧.៤. បុព្វលាភត្រូវបានបន្ថែមទៅក្នុងតម្លៃទីផ្សារ ប៉ុន្តែតម្លៃទីផ្សារដែលបានអនុវត្តនោះនឹងមិនស្ថិតនៅក្រោមតម្លៃអប្បបរិមាដែលបានធានាទេ។

➡ ប្រសិនបើតម្លៃទីផ្សានៅខាងក្រោមកម្រិតអប្បបរិមាដែលបានធានា តម្លៃដែលត្រូវទូទាត់ទៅអ្នកផលិតគឺ ៖

*តម្លៃសម្រាប់អ្នកផលិត = តម្លៃតាមទីផ្សារ + បុព្វលាភ*

➡ ប្រសិនបើតម្លៃទីផ្សារស្មើ ឬនៅក្រោមកម្រិតអប្បបរិមាដែលបានធានា តម្លៃដែលត្រូវទូទាត់ទៅអ្នកផលិត គឺ (ប្រសិនបើគេបានឯកភាពថា តម្លៃដែលបានធានា គឺមិនរាប់បញ្ចូលបុព្វលាភ សូមមើល ចំណុចត្រូវយកចិត្តទុកដាក់ ខាងក្រោម )៖

*តម្លៃសម្រាប់អ្នកផលិត = តម្លៃអប្បបរិមាដែលបានធានា + បុព្វលាភ។*

ប្រព័ន្ធនេះគឺអាចការពារខ្លាំងបំផុតសម្រាប់អ្នកផលិត ។ វាអាចពិបាកទ្រទ្រង់សម្រាប់អ្នកទិញ ប្រសិនបើគាត់ស្វែងរកទីផ្សារផលិតផលដែលមានការប្រកួតប្រជែងខ្លាំង។ ប៉ុន្តែប្រព័ន្ធនេះ អាចប្រែប្រួល ក្នុងករណីទីផ្សារពិសេស ហើយបើការអនុវត្តន៍ល្អ (ការទទួលខុសត្រូវផ្នែកសង្គម) របស់ក្រុមហ៊ុននោះ ទទួលបានការឲ្យតម្លៃពីអតិថិជន និងអ្នកប្រើប្រាស់ (ដូចជា តាមរយៈការចេញវិញ្ញាបនបត្រ ពាណិជ្ជកម្មសមធម៌)។

នៅក្នុងម៉ូដែលនៃការធានាតម្លៃអប្បបរិមា + ថ្លៃបុព្វលាភ វាជាការសំខាន់ដែលត្រូវបញ្ជាក់ឲ្យច្បាស់ថា តើ តម្លៃធានាអប្បបរិមា មានបញ្ចូល ឬគ្មានបញ្ចូលថ្លៃ បុព្វលាភ។ ការកំណត់រូបមន្តមិនច្បាស់លាស់អាចនាំឲ្យមានការបកស្រាយខុសគ្នា និងវិវាទ។ ជាទូទៅ តម្លៃដែលបានធានា ត្រូវបានចាត់ទុកថា មិនទាន់បានបូកបញ្ចូលថ្លៃបុព្វលាភទេ (មានន័យថា មិនទាន់គិតថ្លៃបុព្វលាភ)។

ឧទាហរណ៍ ៖ សម្រាប់តម្លៃដែលបានធានា ៩៨ ដុល្លា ក្នុងមួយតោននៃផលិតផល + បុព្វលាភ ៨ ដុល្លារ ក្នុងមួយតោននៃផលិតផល៖

☐ ប្រសិនបើតម្លៃដែលបានធានា គឺមានរាប់បញ្ចូលទាំងថ្លៃបុព្វលាភ ភាគីអ្នកផលិតនឹងទទួលបាន ៩៨ ដុល្លាក្នុងមួយតោន រាល់ពេលដែលតម្លៃគឺនៅក្រោម ៩០ ដុល្លា ក្នុងមួយតោន។ ពួកគេនឹងទទួលបាន ៩៩ ដុល្លាក្នុងមួយតោន នៅពេលតម្លៃទីផ្សារគឺ ៩១ ដុល្លា ក្នុងមួយតោន, ១០០ ដុល្លាក្នុងមួយតោន នៅពេលតម្លៃគឺ ៩២ ដុល្លា ជាដើម។

☐ ប្រសិនបើតម្លៃដែលបានធានាគឺមិនរាប់បញ្ចូលថ្លៃបុព្វលាភទេ ភាគីអ្នកផលិតនឹងទទួលបាន មិនតិចជាងប្រាក់ធានាចំនួន ៩៨ ដុល្លាក្នុងមួយតោន + ៨ ដុល្លារក្នុងមួយតោន នៃបុព្វលាភ ដែលមានន័យថា ប្រាក់ធានាសរុបគឺ ១០៦ ដុល្លាក្នុងមួយតោន។

## សង្ខេប៖ ការប្រៀបធៀបរវាងរបៀបកំណត់តម្លៃទាំង ៥ ប្រភេទ

តារាង ៤.៧.ក៖ការសង្ខេប និងការប្រៀបធៀបប្រព័ន្ធតម្លៃនៅក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យា

| របៀបកំណត់តម្លៃ | គុណសម្បត្តិ | គុណវិបត្តិ | ករណីគួរប្រើ |
|---|---|---|---|
| ១. តម្លៃថេរ | សន្តិសុខនៃតម្លៃសម្រាប់អ្នកផលិត។ ហានិភ័យនៃការឡើងចុះតម្លៃ បានផ្ទេរទៅឲ្យអ្នកទិញ។ | នៅពេលតម្លៃទីផ្សារឡើងហួសពីតម្លៃថេរ ហានិភ័យនៃការលក់ចេញក្រៅ គឺខ្ពស់ បើអ្នកផលិតអាចរកបានអ្នកទិញផ្សេងទៀត។ | គួរប្រើក្នុងករណីការផលិតថ្មី ដែលមិនទាន់មានឱកាសទៅលក់នៅកន្លែងផ្សេង ហើយមិនសូវចង់ចាប់ផ្តើមផលិតប្រសិនបើមិនមានការធានាលើតម្លៃ។ |
| ២. តម្លៃតាមទីផ្សារ | កាត់បន្ថយហានិភ័យនៃការលក់ទៅខាងក្រៅ នៅពេលអ្នកផលិតមានទំនាក់ទំនងជាមួយ អ្នកទិញផ្សេងទៀត ដែលអាច និងបើតម្លៃទីផ្សារគឺខ្ពស់។ | ហានិភ័យនៃការឡើងចុះតម្លៃ គឺធ្លាក់មកលើអ្នកផលិត។ ប្រសិនបើអ្នកទិញមិនផ្តល់ការលើកទឹកចិត្ត ក្រៅពីតម្លៃទេ (ដូចជា បុរេហិរញ្ញប្បទាន លទ្ធភាពទទួលបានធាតុចូល...) ដូចនេះ កិច្ចសន្យាផលិតកម្មកសិកម្ម ពុំទាក់ទងដល់កសិករទេ។ | អាចពាក់ព័ន្ធសម្រាប់ការផលិតអ្វីដែលកសិករធ្លាប់ផលិត និងក្នុងករណីមិនមានឥទ្ធិពលពីទីផ្សារក្នុងស្រុក (ការប្រជែងទិញដោយអ្នកទិញផ្សេងទៀត) ។ ប៉ុន្តែ គួរនាំមកនូវអត្ថប្រយោជន៍ផ្សេងទៀតដល់អ្នកផលិត។ |
| ៣. តម្លៃទីផ្សារ + ថ្លៃបុព្វលាភ | កាត់បន្ថយហានិភ័យនៃការលក់ចេញទៅខាងក្រៅ៖ ថ្លៃបុព្វលាភគឺជាការលើកទឹកចិត្តដើម្បីធានាភក្តីភាពពីអ្នកផលិត ហើយអាចទូទាត់ប្រាក់បន្ថែមលើគុណភាពជាក់លាក់។ | ហានិភ័យនៃការឡើងចុះតម្លៃ គឺធ្លាក់ទៅលើអ្នកផលិត ប៉ុន្តែអាចប៉ះប៉ូវដោយប្រាក់បុព្វភាព។ | សមរម្យសម្រាប់ការឲ្យតម្លៃលើគុណភាពជាក់លាក់ ដែលអ្នកទិញផ្សេងទៀតមិនឲ្យតម្លៃ (ដូចជា ការផលិតបែបសរីរាង្គ)។ |
| ៤. ការធានាតម្លៃអប្បបរិមា | ហានិភ័យ នៃការឡើងចុះតម្លៃ ត្រូវបានផ្ទេរមួយផ្នែកទៅអ្នកទិញ ដោយធានានូវកម្រិតទូទាត់ប្រាក់សមរម្យជូនកសិករ។ | ពិបាកសម្រាប់អ្នកទិញ ក្នុងការទ្រទ្រង់នៅក្នុងទីផ្សារដែលមានការប្រកួតប្រជែងខ្លាំង។ | ការធានាតម្លៃអប្បបរិមាដល់អ្នកផលិត គឺជាការបង្ហាញការប្តេជ្ញាចិត្តរបស់អ្នកទិញ និងលើទឹកចិត្តសម្រាប់ភាពជាដៃគូនិងភក្តីភាពយូរអង្វែង។ វាអាចជាភស្តុតាងនៃការទទួលខុសត្រូវផ្នែកសង្គមរបស់អ្នកទិញ។ |
| ៥. ការធានាតម្លៃអប្បបរិមា +ថ្លៃបុព្វលាភ | ផ្តល់សុវត្ថិភាពនិងការលើកទឹកចិត្តដល់អ្នកផលិត។ប្រព័ន្ធនេះអាចជួយកសាងទំនាក់ទំនងនៃការទុកចិត្តគ្នារឹងមាំ និងមានភាពជាដៃគូយូរអង្វែង។ | ពិបាកសម្រាប់អ្នកទិញ ប្រសិនបើអនុវត្តនៅក្នុងទីផ្សារដែលមានការប្រកួតប្រជែង។ | ល្អបំផុតសម្រាប់អ្នកផលិត។ សមរម្យណាស់ប្រសិនបើអ្នកទិញអាចឲ្យតម្លៃទៅលើភាពជាដៃគូជាមួយអតិថិជនរបស់ខ្លួន និងអ្នកប្រើប្រាស់ (ការទទួលខុសត្រូវផ្នែកសង្គម និងពាណិជ្ជកម្មត្រឹមត្រូវ)។ |

រូបភាព៤.៧.ក.(ផ្ទុយគ្នា)បង្ហាញអំពីរបៀបដែលតម្លៃដែលទូទាត់ទៅឲ្យអ្នកផលិត ប្រែប្រួលទៅតាមតម្លៃទីផ្សារនៅក្នុងវិធីកំណត់តម្លៃទី ៥ (តម្លៃតាមទីផ្សារ, តម្លៃថេរ, តម្លៃតាមទីផ្សារ + ថ្លៃបុព្វលាភ, ការធានាតម្លៃអប្បបរិមា, និង ការធានាតម្លៃអប្បបរិមា+ បុព្វលាភ)។

ក្នុងករណីតម្លៃថេរ តំបន់ដែលមានពណ៌ប្រផេះ គឺជាពេលដែលមានហានិភ័យខ្ពស់នៃការលក់ចេញក្រៅ ដោយហេតុថា តម្លៃថេរ គឺទាបជាងតម្លៃទីផ្សារ។

ខ្សែកោងបង្ហាញអំពីដំណាក់កាលនៃតម្លៃដែលទូទាត់ទៅអ្នកផលិត នៅក្នុងប្រព័ន្ធដែលមានការធានា តម្លៃ នៅពេលតម្លៃទីផ្សារធ្លាក់ចុះក្រោមតម្លៃដែលបានធានា។

រូបភាព៤.៧.ខ៖ ការពន្យល់អំពីភាពខុសគ្នានៃតម្លៃនៅក្នុងរបៀបទាំង ៥ នៃការកំណត់តម្លៃ



## ៤.៧.៦. ឯកសារយោង និងរូបមន្តដែលត្រូវប្រើ ពេលមានតម្លៃផ្សេងគ្នា(/តម្លៃទីផ្សារ)

ប្រព័ន្ធកំណត់តម្លៃណាមួយ ដែលប្រើប្រាស់សម្រាប់កំណត់ "តម្លៃតាមទីផ្សារ" (មានន័យថា គ្រប់ប្រព័ន្ធកំណត់តម្លៃទាំងអស់ ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌមុនៗ ៤.៧.១. ដល់ ៤.៧.៥. លើកលែងតែ ម៉ូដែល "តម្លៃថេរ" ) ត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់អំពីប្រភពព័ត៌មានដែលនឹងត្រូវប្រើប្រាស់ជាសេចក្តីយោង សម្រាប់អ្វីដែលហៅថា "តម្លៃតាមទីផ្សារ"។ វាអាចជា**សេចក្តីយោងតម្លៃក្នុងមូលដ្ឋាន**ឬ**សេចក្តីយោងតម្លៃថ្នាក់ជាតិ** ឬ **អន្តរជាតិ** (សូមមើលខាងក្រោម)។

ក្រៅពីប្រភពព័ត៌មានតម្លៃដែលបានប្រើប្រាស់ វាក៏ត្រូវបញ្ជាក់ឲ្យច្បាស់អំពីម៉ោងនិងពេលវេលា ដែលចាត់ទុកថាជាសេចក្តីយោងសម្រាប់យកមកប្រើប្រាស់ និងរបៀបគណនាតម្លៃសម្រាប់យកមកគណនាជាសេចក្តីយោងសម្រាប់តម្លៃក្នុងកិច្ចសន្យា។

### សេចក្តីយោងតម្លៃក្នុងមូលដ្ឋាន

សេចក្តីយោងតម្លៃក្នុងមូលដ្ឋាន គឺជាតម្លៃដែលអនុវត្តដោយភាគីពាក់ព័ន្ធផ្សេងទៀត (ជាគោលការណ៍នៅក្នុងតំបន់ដូចគ្នា ក្នុងនាមជាអ្នកចុះហត្ថលេខាលើកិច្ចសន្យា) សម្រាប់ផលិតផលដដែល ដែលបានចុះហត្ថលេខានៅក្នុងកិច្ចសន្យា។ ផលិតដូចគ្នា មានន័យថាផលិតផលដែលប្រើប្រាស់ជាសេចក្តីយោង ត្រូវមានគុណភាពដូចគ្នា (ដូចជាពូជដូចគ្នា) និងកម្រិតនៃការកែច្នៃផលិតផលនោះ សម្រាប់ផ្តល់ជូនដោយអ្នកផលិតទៅឲ្យអ្នកទិញចុះកិច្ចសន្យា។ ឧទាហរណ៍ ប្រសិនបើផលិតផល ត្រូវផ្តល់ដោយកសិករនៅក្នុងកិច្ចសន្យាគឺជាស្រូវស្ងួត (សំណើម ១៤% ) ពូជ *ផ្ការំដួល*[14] នោះតម្លៃយោងគឺជាតម្លៃស្រូវ*ផ្ការំដួល* ស្ងួត។

ចេញពីទស្សនៈនៃការបង្ហាញក្នុងរូបភាព វាងាយស្រួលប្រើសេចក្តីយោងតម្លៃក្នុងមូលដ្ឋាន (= តម្លៃយោងសម្រាប់ផលិតផលដូចគ្នា នៅក្នុងតំបន់ភូមិសាស្ត្រផលិតក្បែរគ្នា – ជម្រើស ១ ខាងលើ)។ វាឆ្លើយតបទៅនឹងតម្លៃដែលអ្នកទិញផ្សេងទៀតទិញផលិតផលដដែលពីកសិករផ្សេង ដូច្នេះ ការយោងនេះ គឺអាចអនុវត្តដោយផ្ទាល់ទៅនឹងតម្លៃដែលបានកំណត់ជាតម្លៃដែលត្រូវបង់នៅក្រោមកិច្ចសន្យានេះ។ ប៉ុន្តែវិធីនេះ អនុវត្តបានតែចំពោះទីផ្សារក្នុងមូលដ្ឋានសម្រាប់ផលិតផលនៅក្នុងកិច្ចសន្យាតែប៉ុណ្ណោះ (អាចនិយាយម្យ៉ាងទៀតបានថាអ្នកផលិតមានឱកាសជួបជាមួយអ្នកទិញផ្សេងទៀត ក្រៅពីអ្នកចុះកិច្ចសន្យា)។

[14] ជាមួយការកំណត់លក្ខណៈបច្ចេកទេសបន្ថែម ដូចជា ភាពសុទ្ធ អត្រាបាក់គ្រាប់អង្ករ...

ដោយហេតុថាមានអ្នកទិញច្រើននៅក្នុងមូលដ្ឋាន កិច្ចសន្យាត្រូវបញ្ជាក់ឲ្យច្បាស់ថា ត្រូវយកមួយណាជាការយោងតម្លៃ និងរបៀបណា ឬប្រមូលព័ត៌មានដោយនរណា។

គេមិនត្រឹមតែជ្រើសរើសយកតែមួយប្រភពទេ ប៉ុន្តែត្រូវជ្រើសរើសយ៉ាងតិចបីឬបួនប្រភពព័ត៌មាន។ ប្រសិនបើមានប្រភពព័ត៌មានផ្សេងៗគ្នា ត្រូវបញ្ជាក់ថាគួរប្រើព័ត៌មានមួយណា ឧទាហរណ៍ វាអាចជា <u>តម្លៃមធ្យមដែលផ្តល់មកពីអ្នកទិញក្នុងមូលដ្ឋានចំនួនបីនាក់</u> ឬវាអាចជា <u>តម្លៃខ្ពស់ជាងគេក្នុងចំណោមអ្នកទិញបីនាក់។</u> គួរកត់សម្គាល់ថា ដើម្បីជៀសវាងការប៉ុនប៉ងលក់ចេញទៅខាងក្រៅ គេគួរប្រើប្រាស់តម្លៃដែលខ្ពស់ជាងគេ ជាតម្លៃយោង ជាជាងតម្លៃមធ្យម។ នេះពិតជាជម្រើសល្អសម្រាប់អ្នកផលិត។

បញ្ជីនៃអ្នកទិញដែលត្រូវប្រើជាសេចក្តីយោង ត្រូវមានការឯកភាពដោយភាគីទាំងពីរ។ ពួកគេត្រូវតែបានជ្រើសរើសឲ្យបានល្អ៖ ត្រូវតែជាប្រភេទផលិតផលដូចគ្នា ទៅនឹងផលិតផលក្នុងកិច្ចសន្យា (ប្រសិនបើគេមិនទិញប្រភេទផលិតផលដូចគ្នា គេមិនអាចប្រើជាសេចក្តីយោងបានទេ ដូចមានពន្យល់បន្ថែមនៅក្នុង ការពន្យល់បន្ថែមលេខ ៤.៧.ឃ)។ គេត្រូវតែផ្ទៀងផ្ទាត់ថា អ្នកទិញទាំងនេះ ពិតជាយល់ព្រមបង្ហាញទិន្នន័យស្តីពីតម្លៃទិញ នៅពេលត្រូវការវា។

ការពន្យល់បន្ថែម ៤.៧.ឃ.

**ករណីឯកសារយោងស្តីពីតម្លៃដែលមិនអាចអនុវត្តបាន៖ ការផ្លាស់ប្តូរមានភាពជាក់លាក់ខ្លាំងពេក និងមិនត្រូវបានបញ្ជាទិញដោយឈ្មួញផ្សេងទៀតដែលត្រូវគេរំពឹងថាត្រូវប្រើប្រាស់ជាតម្លៃយោងទីផ្សារ**

កាលពីឆ្នាំ ២០១៤ ក្នុងចំណោមករណីសាកល្បងកិច្ចសន្យាផលិតកម្មកសិកម្មរបស់គម្រោង SCCRP ម្ចាស់រោងម៉ាស៊ីនកិនស្រូវបានចុះកិច្ចសន្យាជាមួយអង្គការកសិករសម្រាប់ផ្គត់ផ្គង់ពូជមិនធម្មតាមួយដែលកំណត់ដោយអ្នកទិញ និងអ្នកផលិត។ ពូជនោះឈ្មោះ *"ផ្កាស្រងែ"* (គួរកត់សម្គាល់ថា កិច្ចសន្យា ដំបូងបានពិចារណាទៅលើពូជផ្សេងទៀត ប៉ុន្តែទីបំផុត បានប្តូរពូជនោះវិញ ដោយសារខ្វះគ្រាប់ពូជដែលមានគុណភាព )។

នៅពេលប្រមូលផល អង្គការកសិករបានជួបការលំបាក ដោយសារតែតម្លៃដែលបានផ្តល់ដោយឈ្មួញកណ្តាល សម្រាប់ស្រូវ*ផ្កាស្រងែ* (ប្រមូលទិញក្នុងភូមិ) គឺស្មើទៅនឹងតម្លៃដែលផ្តល់ឲ្យដោយរោងម៉ាស៊ីនដែរ សម្រាប់ការដឹកទៅដល់រោងម៉ាស៊ីន។ កិច្ចសន្យាបានចែងថា តម្លៃនឹងត្រូវកំណត់ទៅតាមតម្លៃដែលផ្តល់ជូនដោយរោងម៉ាស៊ីនកិនស្រូវ ៣ ទៅ ៥ ផ្សេងទៀត (បានដាក់ឈ្មោះនៅក្នុងកិច្ចសន្យា និងយល់ព្រមដោយភាគីទាំងពីរ) ដែលនៅជិតទីតាំងរបស់អ្នកទិញ។ គួរឲ្យស្តាយ នៅពេលទិញ រោងម៉ាស៊ីនកិនស្រូវទាំងនោះ មិនទិញស្រូវពូជ *ផ្កាស្រងែ* ទេ។ ដូច្នេះ សេចក្តីយោងដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺមិនអាចអនុវត្តបានទេ។

➥ ត្រូវប្រាកដថា សេចក្តីយោង ពិតជានឹងអាចប្រើប្រាស់បាន សម្រាប់ផ្តល់ជាសេចក្តីយោងតម្លៃ សម្រាប់ផលិតផលដូចគ្នា (ពូជដូចគ្នា) នៅពេលប្រគល់នាពេលអនាគត។

មិនត្រូវមានទំនាក់ទំនងជិតស្និទរវាងភាគីណាមួយក្នុងកិច្ចសន្យា ជាមួយនឹងអ្នកទិញដែលបានជ្រើសរើសជាសេចក្ដីយោងឡើង ពុំនោះទេ អាចមានភាពលម្អៀងក្នុងតម្លៃដែលបានបញ្ជាក់។

សំនួរដែលត្រូវពិនិត្យបញ្ជាក់ នៅពេលជ្រើសរើសប្រភពព័ត៌មានក្នុងមូលដ្ឋានអំពីតម្លៃ ដើម្បីធ្វើជាសេចក្ដីយោង៖

☐ តើអ្នកទិញក្នុងមូលដ្ឋានដែលបានរកឃើញនោះ នឹងត្រូវប្រើជាសេចក្ដីយោងសម្រាប់ទិញផលិតផលប្រភេទដូចគ្នានឹងផលិតផល នៅក្នុងកិច្ចសន្យាឬទេ (ឧទាហរណ៍ ពូជដូចគ្នា...) ។ ប្រសិនបើមិនដូចគ្នាទេ មិនត្រូវប្រើប្រភពនេះទេ ហើយភាគីទាំងពីរ ត្រូវស្វែងរកប្រភពមួយទៀត។

☐ តើអាចមានអ្នកទិញផ្សេងទៀតដែលអាចជ្រើសរើសជាការយោងតម្លៃ និងមិនពាក់ព័ន្ធនឹងភាគីក្នុងកិច្ចសន្យា (មិនមានទំនាក់ទំនងអាជីវកម្ម ឬជាសាច់ញាតិ)? [កត់សម្គាល់ថា ពេលខ្លះ ក្រុមហ៊ុនផ្សេងគ្នា មានម្ចាស់តែមួយ!]

### តម្លៃយោងថ្នាក់ជាតិ / អន្តរជាតិ

តម្លៃយោងថ្នាក់ជាតិ / អន្តរជាតិ គឺជាតម្លៃនៃផលិតផលកែច្នៃរួច និងមានគោលដៅទីផ្សារនៅថ្នាក់ជាតិ / អន្តរជាតិ។ វាអាចដាក់បញ្ចូលថ្លៃដឹកជញ្ជូន សម្រាប់ផលិតផលដែលបានកែច្នៃរួច នៃផលិតផលដដែល។ គេអាចរកបានប្រភពព័ត៌មានជាច្រើន អាស្រ័យទៅតាមប្រភេទផលិតផល ជាពិសេសមុខទំនិញសម្រាប់ទីផ្សារអន្តរជាតិ[15] ។ ការពន្យល់បន្ថែម ៤.៧.ង ខាងក្រោម ផ្ដល់នូវឧទាហរណ៍ នៃការយោងប្រភពតម្លៃសម្រាប់ទំនិញពាណិជ្ជកម្មអន្តរជាតិ។

សម្រាប់អង្ករ វិបសាយ "Live Rice Index" អាចផ្ដល់តម្លៃយោងប្រចាំថ្ងៃ និងប្រចាំសប្ដាហ៍ នៅលើទីផ្សារអន្តរជាតិសម្រាប់អង្ករក្រអូបគ្រាប់វែងរបស់កម្ពុជា ដែលអាចជាចំណុចវាស់វែងទៅនឹងតម្លៃទូទាត់ប្រាក់នៅក្នុងកិច្ចសន្យា។ ក្នុងករណីដូច្នេះ តម្លៃយោងនឹងមិនត្រូវបានប្រើប្រាស់ដោយផ្ទាល់ជាតម្លៃដែលត្រូវអនុវត្តនៅក្នុងកិច្ចសន្យាទេ ប៉ុន្តែ តម្លៃដែលអ្នកចុះកិច្ចសន្យាទូទាត់ទៅឲ្យអ្នកផលិត អាចជារូបមន្ត ដែលប្រើតម្លៃយោងនេះជាទិន្នន័យប្រែប្រួលមួយ។

[15] កត់សម្គាល់ថា ប្រភពព័ត៌មានខ្លះ ស្ដីពីតម្លៃទីផ្សារ អាចគិតថ្លៃ ហើយតម្រូវឲ្យអ្នកប្រើប្រាស់បង់ថ្លៃទិញដើម្បីអាចចូលប្រើទិន្នន័យបាន។ ពេលខ្លះ ទិន្នន័យដូច្នេះ មានការផ្ទៀងផ្ទាត់។ បើក្នុងករណីនេះ ត្រូវប្រាកដថា អ្នកផលិតអាចចូលប្រើទិន្នន័យ តាមរយៈអ្នកជាវម្នាក់ទៀត ចំពោះសេវាកម្មដែលមានឯករាជ្យភាពពីអ្នកចុះកិច្ចសន្យា។

### ការពន្យល់បន្ថែម ៤.៧.៦.

### ឧទាហរណ៍អំពីប្រភពនៃព័ត៌មានស្តីពីតម្លៃទីផ្សារអន្តរជាតិសម្រាប់ផលិតផលពាណិជ្ជកម្មអន្តរជាតិ

ព័ត៌មានសាធារណៈដែលអាចទុកចិត្តបាន អាចរកមើលបានសម្រាប់តម្លៃទំនិញកែច្នៃនៅទីផ្សារអន្តរជាតិ។ ព័ត៌មានទាំងនេះមានបច្ចុប្បន្នភាពប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍។

ឧទាហរណ៍ ព័ត៌មានស្តីពីតម្លៃ FOB សម្រាប់អង្ករគ្រាប់វែងរបស់កម្ពុជា អាចរកមើលបាននៅលើវិបសាយ Live Rice Index។ វាក៏អាចមាននៅលើវិបសាយរបស់សហព័ន្ធស្រូវអង្ករកម្ពុជាផងដែរ (CRF)។

▼ *ឧទាហរណ៍នៃព័ត៌មាននៅលើ Live Rice Index (liversiceindex.com).*

| CAMBODIA - LONG GRAIN FRAGRANT RICE | CHANGE | PRICE |
|---|---|---|
| Phka Malis/Phka Rumduol (Wet Season) 5% Broken STX | -30 | $820 |
| Sen Kra Ob/Sen Pidao (Dry Season) 5% Broken STX | -10 | $740 |
| Fragrant 100% Broken A1 Super | -10 | $450 |

Email: info@livericeindex.com

| Cambodian Weekly FOB Indication price Week 31st : 27/07/15 - 02/08/15 | |
|---|---|
| | FOB (USD per ton) |
| I.Cambodian Long Grain Fragrant | |
| 1.PremiumJasmine Rice 5% (Purity 90%) | 850 |
| 2.Jasmine Rice 5% (Purity 85%) | 820 |
| 3.Premium Sen Kra-Ob 5% ( Purity 90%) | 780 |

*ឧទាហរណ៍នៃព័ត៌មានតម្លៃនៅលើវិបសាយ CRF (www.crf.org.kb)* ▲

ប្រភពព័ត៌មានស្រដៀងគ្នានឹងតម្លៃដែលមានសម្រាប់កសិផលផ្សេងទៀត ដូចជា កៅស៊ូ (ឧ. ព័ត៌មានកៅស៊ូអន្តរជាតិ– *http://rubberboard.org.in/internationalrubberprice.asp*), កាហ្វេ (ឧ. អង្គការកាហ្វេអន្តរជាតិ – *www.ico.org* ), អំពៅ (ឧ. *http://www.sugaronline.com* ),

*ឧទាហរណ៍នៃព័ត៌មានតម្លៃ នៅលើវិបសាយតម្លៃកៅស៊ូអន្តរជាតិ* ▶

| Rubber Price as on 28/9/2015 per 100 Kg BANGKOK | | | | | |
|---|---|---|---|---|---|
| CATEGORY | | IN RS | | IN USD | |
| | | Price | Change | Price | Change |
| RSS-1 | ▲ | 9,001.00 | +58.00 | 136.15 | +0.88 |
| RSS-2 | ▲ | 8,892.00 | +58.00 | 134.50 | +0.88 |
| RSS-3 | ▲ | 8,791.00 | +58.00 | 133.00 | +0.88 |
| RSS-4 | ▲ | 8,737.00 | +58.00 | 132.20 | +0.88 |
| RSS-5 | ▲ | 8,655.00 | +58.00 | 130.95 | +0.88 |
| SMR-20 | • | - | 0.00 | - | 0.00 |
| Latex(60% drc) | • | - | 0.00 | - | 0.00 |

កត់សម្គាល់ថា តែងមានផលិតផលជាច្រើនប្រភេទ នៅលើវិបសាយនេះ។ ប្រសិនបើប្រភពព័ត៌មានទាំងនេះត្រូវបានប្រើជាតម្លៃយោង គេត្រូវបញ្ជាក់ឲ្យច្បាស់៖

- ប្រភព (អាសយដ្ឋានវិបសាយ ឧទាហរណ៍ ព័ត៌មានរបស់អង្គការប្រមូលផ្តុំ)
- ភាពបែងពិតប្រាកដនិងប្រភេទនៃផលិតផលដែលប្រើជាតម្លៃយោង
- ទីកន្លែងនៃសម្រង់តម្លៃ ប្រសិនបើមានតម្លៃយោងច្រើន
- ម៉ោងនិងរយៈពេលសម្រាប់ពិចារណា (ឧទាហរណ៍ ៖ ត្រូវប្រើសន្ទស្សន៍ប្រចាំថ្ងៃ ឬ ប្រចាំសប្តាហ៍ ឬ ប្រចាំខែ?)

**ការសង្ខេប៖ ការប្រៀបធៀបរវាងការយោងតម្លៃទាំងពីរប្រភេទ**

តារាង ៤.៧.ខ.៖ ការយោងស្ដីពីតម្លៃក្នុងមូលដ្ឋាន ឬតម្លៃទីផ្សារអន្តរជាតិ

| ការយោងតម្លៃ | ការពន្យល់ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|---|
| ១. ការយោងតម្លៃក្នុងមូលដ្ឋាន | តម្លៃគឺសម្រាប់ផលិតផលដូចគ្នា (វត្ថុធាតុដើម) ក្នុងតំបន់នៃកិច្ចសន្យា។ ឧ. តម្លៃស្រូវម្លិះដែលមានគុណភាពដូចគ្នា ក្នុងឃុំដូចគ្នា ឬស្រុកដូចគ្នា ក្នុងកិច្ចសន្យា។ | ▪ តម្លៃយោងអាចប្រៀបធៀបគ្នាដោយផ្ទាល់សម្រាប់ការផលិត និងការដឹកជញ្ជូនដល់អ្នកទិញ។ វាងាយអនុវត្តសម្រាប់កំណត់តម្លៃទូទាត់ក្នុងកិច្ចសន្យា។<br>▪ ភាគីទាំងពីរអាចរកនិងមើលព័ត៌មានបាន។ | ▪ ព័ត៌មានស្ដីពីតម្លៃក្នុងមូលដ្ឋាន តែងមិនបានប្រមូលនិងផ្សព្វផ្សាយដោយភាគីណាមួយទេ។ ព័ត៌មានតែងប្រមូលនិងអង្កេតមើលដោយភាគីចុះហត្ថលេខា។ តួលេខដែលផ្ដល់ដោយអ្នក ផលិត ឬដោយអ្នកទិញ អាចមានទំនាស់ជាមួយអ្នកផ្សេងទៀត។<br>▪ អាចមានការខ្វែងគំនិតរវាងអ្នកទិញ (ឬអ្នកផលិត) ជាមួយតួអង្គផ្សេងទៀត នៅក្នុងខ្សែសង្វាក់តម្លៃ ដើម្បីផ្ដល់តម្លៃក្លែងក្លាយដើម្បីជាខ្នាតវាស់ធៀប។ |
| ២. ការយោងតម្លៃទីផ្សារជាតិឬអន្តរជាតិ | តម្លៃផលិតផលកែច្នៃរួចសម្រាប់ទីផ្សារជាតិឬអន្តរជាតិ (ដូចជាតម្លៃទីផ្សារអន្តរជាតិ – ដឹកជញ្ជូន – សម្រាប់ស្រូវម្លិះកម្ពុជា)។ | ▪ តម្លៃយោងដែលបានប្រើគឺជារង្វាស់ បង្កើតឡើងដោយការប្រមូលព័ត៌មានពីភាគីទីបី។ វាមិនអាចកំណត់ដោយភាគីណាមួយដែលចុះហត្ថលេខាលើកិច្ចសន្យាទេ។<br>▪ តួលេខដែលផ្សព្វផ្សាយត្រូវងាយផ្ទៀងផ្ទាត់ ហើយត្រូវអាចទុកចិត្តបាន។ | ▪ តួលេខដែលបានផ្ដល់ គឺមិនមែនសម្រាប់វត្ថុធាតុដើមទេ (ផលិតផលដែលផ្ដល់ដោយអ្នកផលិតទៅអ្នកទិញ៖ ឧ. *ស្រូវ*) ប៉ុន្តែវាជាផលិតផលកែច្នៃនិងធ្វើពាណិជ្ជកម្មអន្តរជាតិ (ឧ. អង្ករ)។ តួលេខតម្លៃយោងគឺមិនអាចប្រើបានដោយផ្ទាល់ទេ ប៉ុន្តែត្រូវបំប្លែងទៅជាផលិតផលដើម ដោយប្រើរូបមន្តដែលមានការឯកភាពគ្នា (ឧ. ផលិតផលដើមទូទាត់ឲ្យកសិករ គឺស្មើនឹង ៦០% នៃតម្លៃFOB)...<br>▪ ការទទួលបានព័ត៌មានតម្លៃ (ជាទូទៅតាមរយៈអ៊ីនធឺណិត) អាចពិបាកសម្រាប់កសិករខ្នាតតូច។<br>▪ ការទទួលបានទិន្នន័យមិនមែនគ្មានការគិតថ្លៃទេ (អាចត្រូវបង់ថ្លៃជាវសម្រាប់ចូលប្រើទិន្នន័យពេញលេញ)។ |

## ម៉ោងនិងរយៈពេលប្រើប្រាស់តម្លៃយោង

គ្រាន់តែកំណត់ប្រភពព័ត៌មានតម្លៃ វាមិនគ្រប់គ្រាន់ទេ។ កិច្ចសន្យាផលិតកម្មកសិកម្មត្រូវតែបញ្ជាក់ថា ត្រូវមើលតម្លៃយោងញឹកញាប់ប៉ុណ្ណា និងមើលនៅពេលណា សម្រាប់ប្រើប្រាស់ក្នុងការទូទាត់ប្រាក់មួយណា។ កិច្ចសន្យាក៏ត្រូវកំណត់ថា ត្រូវប្រើតម្លៃយោងយ៉ាងដូចម្ដេច។ ឧទាហរណ៍ ប្រសិនបើមានតម្លៃច្រើនប្រភេទ

(មកពីប្រភពផ្សេងគ្នា នៃអ្នកទិញក្នុងមូលដ្ឋាន ឬ តម្លៃខុសគ្នានៅពេលខុសគ្នា ឧទាហរណ៍ ៧ ថ្ងៃជាប់គ្នា តម្លៃប្រែប្រួល ៧ លើក ) កិច្ចសន្យាគួរបញ្ជាក់ឲ្យច្បាស់ថា តើត្រូវប្រើតម្លៃមធ្យម ឬតម្លៃខ្ពស់បំផុត ក្នុងចំណោមតម្លៃទាំងនោះ ឬមានវិធីណាផ្សេងទៀត។

មានជម្រើសច្រើនណាស់ សម្រាប់បញ្ហានេះ។ ឧទាហរណ៍ វាអាចជា៖

- ជាប្រចាំថ្ងៃ ៖ តម្លៃយោងនឹងត្រូវបើកមើលរាល់ថ្ងៃ ហើយតម្លៃដែលត្រូវយកមកប្រើ ក៏ប្រែប្រួលរាល់ថ្ងៃដូចគ្នា។
- ជាប្រចាំសប្ដាហ៍ ៖ តម្លៃដែលត្រូវយកមកប្រើនៅក្នុងកិច្ចសន្យា នឹងត្រូវកំណត់មួយសប្ដាហ៍ម្ដង។ គេអាចជ្រើសរើសយកថ្ងៃទីមួយនៃសប្ដាហ៍ ឬយកតម្លៃមធ្យមនៃសប្ដាហ៍មុន ឬយកតាមតម្លៃខ្ពស់បំផុតកាលពីសប្ដាហ៍មុន។

## រូបមន្តសម្រាប់គណនាតម្លៃត្រូវទូទាត់ជាក់ស្ដែង អាស្រ័យទៅតាមតម្លៃយោងជាតិ ឬ អន្តរជាតិ

ដូចបានបញ្ជាក់ពីខាងលើ ប្រសិនបើប្រើប្រាស់តម្លៃយោងជាតិឬអន្តរជាតិ តួលេខនៃតម្លៃយោង គឺមិនអាចប្រើប្រាស់បានដោយផ្ទាល់ទេ។ គេត្រូវគណនារកតម្លៃក្នុងមូលដ្ឋានសម្រាប់ជាផលិតផលដើម ដោយកាត់ចេញតម្លៃផ្សេងៗសិន ដូចជា តម្លៃដឹកជញ្ជូនតាមនាវា (ការនាំចេញ) សម្រាប់ផលិតផលដែលកែច្នៃរួច។

គេអាចប្រើវិធីសាស្ត្រពីរ ដើម្បីកែសម្រួលតម្លៃដើម្បីគណនារកតម្លៃផលិតផលដើម សម្រាប់គិតពីអ្នកទិញ ដោយប្រើប្រាស់តម្លៃយោងមកពីផលិតផលសម្រេច ៖

- វិធីសាស្ត្រប៉ាន់ប្រមាណថ្លៃដើម
- វិធីសាស្ត្រប្រវត្តិសាស្ត្រ

## វិធីសាស្ត្រប៉ាន់ប្រមាណថ្លៃដើម

នៅក្នុងវិធីសាស្ត្រនេះ យើងព្យាយាមប៉ាន់ប្រមាណទិន្នផលកែច្នៃ (តើត្រូវការផលិតផលដើមប៉ុន្មានដើម្បីផលិតបានផលិតផលសម្រេច ១ តោន សម្រាប់នាំចេញ ហើយប្រើជាតម្លៃយោងមួយ) និងគណនារាល់ការចំណាយផ្សេងទៀត (លើកលែងតែថ្លៃសម្ភារធាតុដើមដែលយើងចង់គណនា) ដែលត្រូវគាំទ្រដោយអ្នកចុះកិច្ចសន្យា ( ឬដោយភ្នាក់ងារក្នុងបណ្ដាញខាងក្រោមនៃខ្សែសង្វាក់តម្លៃ) រហូតដល់ផលិតផលត្រូវបានលើកសម្រាប់នាំចេញ (វាក៏ត្រូវគិតទាំងថ្លៃចំណេញសម្រាប់អ្នកចុះកិច្ចសន្យាផងដែរ)។ ម្យ៉ាងទៀត ចំណូលដែលរំពឹងថារកបាន ក៏ត្រូវគណនា (ចំណូលពីផលិតផលសម្រេច ក្នុងតម្លៃយោង + ចំណូលដែលអាចរកបានពីអនុផល)។ គម្លាតទឹកប្រាក់រវាង (ចំណូល) និង (ថ្លៃដើម + ប្រាក់ចំណេញរំពឹងទុក) នឹងប្រាប់ថាទឹកប្រាក់ដែលត្រូវបង់សម្រាប់ផលិតផលដើមត្រូវចំណាយអស់ប៉ុន្មាន ដើម្បីផលិតបានផលិតផលសម្រេច ១ តោន។ ចេញពីការគណនានេះ យើងអាចកាត់ចេញតម្លៃសម្រាប់ផលិតផលដើម អាស្រ័យទៅតាមតម្លៃដឹកជញ្ជូនតាមនាវានៃផលិតផលសម្រេច។ ការពន្យល់ (ទ្រឹស្ដី) អំពីវិធីសាស្ត្រនេះ គឺមានបង្ហាញនៅក្នុង"ការពន្យល់បន្ថែម ៤.៧.ច" នៅទំព័របន្ទាប់។ គេត្រូវកត់សម្គាល់ផងដែរថា ទ្រឹស្ដីនេះពុំងាយអនុវត្តទេ។ តាមពិតទៅ វាជាការពិបាកណាស់ក្នុងការដកស្រង់យកតួលេខពាក់ព័ន្ធនឹងទិន្នផលកែច្នៃ ការចំណាយលើប្រតិបត្តិការ និងភស្តុភារ ពីអ្នកទិញ។

## វិធីសាស្ត្រប្រវត្តិសាស្ត្រ

វិធីសាស្ត្រប្រវត្តិសាស្ត្រ គឺពាក់ព័ន្ធនឹងការពិនិត្យមើលកំណត់ត្រានៃតម្លៃថ្នាក់ជាតិ ឬ អន្តរជាតិ ដែលប្រើជាតម្លៃយោងក្នុងរយៈពេលមធ្យម ឬ រយៈពេលវែង និងដើម្បីរកមើលតម្លៃទាំងនេះ ដែលទូទាត់នៅក្នុងមូលដ្ឋានដើម្បីទិញវត្ថុធាតុដើម នៅក្នុងកាលបរិច្ឆេទដូចគ្នា។ ទោះគេងាយរកឃើញកំណត់ត្រាប្រវត្តិសាស្ត្រសម្រាប់ផលិតផលនាំចេញក៏ដោយ តម្លៃក្នុងមូលដ្ឋានសម្រាប់វត្ថុធាតុដើម ប្រហែលជាមិនបានកត់ត្រាបានល្អទេ។ ប៉ុន្តែគេអាចព្យាយាមកសាងព័ត៌មានទាំងនេះឡើងវិញ ដោយការពិនិត្យមើលឯកសាររបស់ភាគីពាក់ព័ន្ធ ឬ ដោយសារសួរផ្ទាល់មាត់។ អាស្រ័យលើឯកសារសម្រាប់តម្លៃយោងជាតិ ឬអន្តរជាតិសម្រាប់ផលិតផលនាំចេញ និងតម្លៃក្នុងមូលដ្ឋានសម្រាប់ផលិតផលដើម គេអាចព្យាយាមរកការសន្និដ្ឋានមួយបាន។

ប្រសិនបើផលធៀប $\frac{\text{តម្លៃផលិតផលដើមក្នុងមូលដ្ឋាន}}{\text{តម្លៃយោង}}$ មិនប្រែប្រួលច្រើនទេ ដូច្នេះយើងអាចកំណត់កត្តាដើម្បីរកតម្លៃក្នុងមូលដ្ឋានដែលមានភាពត្រឹមត្រូវ ដោយឈរលើតម្លៃយោងជាតិ ឬ អន្តរជាតិ ។ សូមមើល ការពន្យល់ (បែបទ្រឹស្តី) នៃវិធីសាស្ត្រនៅក្នុង "ការពន្យល់បន្ថែម ៤.៧.ឆ" ទំព័រ ៨៥។

តម្លៃយោងអន្តរជាតិ ពេលខ្លះ ប្រើប្រាស់ដើម្បីកំណត់តម្លៃមូលដ្ឋាន (តម្លៃយោង x មេគុណ) ដែលត្រូវបំពេញដោយបុព្វលាភ និង/ឬទឹកប្រាក់ធានាអប្បបរិមា។ ហើយវាក៏ងាយស្រួលប្រើ ប្រសិនបើផលិតផលដែលលក់ដោយអ្នកផលិតទៅអ្នកចុះកិច្ចសន្យា គឺមានកម្រិតដូចគ្នា នឹងការកែច្នៃជាផលិតផលនាំចេញ។ តម្លៃយោងដូច្នេះ គឺតែងប្រើប្រាស់នៅក្នុងពាណិជ្ជត្រឹមត្រូវ ក្នុងវិស័យគ្រាប់កាហ្វេ ដែលក្នុងនោះ ក្រុមអ្នកផលិត ផ្គត់ផ្គង់កាហ្វេខ្ចីទៅអ្នកទិញ ក្នុងទម្រង់សម្រាប់នាំចេញ។ នៅក្នុងកិច្ចសន្យាត្រឹមត្រូវសម្រាប់កាហ្វេ តម្លៃនឹងត្រូវគណនាដូចខាងក្រោម ៖

*តម្លៃត្រូវទូទាត់ = តម្លៃធានា ឬតម្លៃយោង FOB ( យកមួយណាដែលខ្ពស់ជាង) + បុព្វលាភ*

## ការពន្យល់បន្ថែម ៤.៧.ច.

### ឧទាហរណ៍សាមញ្ញនៃភាពល្អិតល្អន់នៃរូបមន្តបម្លែងតម្លៃ FOB ទៅជាតម្លៃដែលអាចប្រើបានសម្រាប់ផលិតផលដើម នៅក្នុងកិច្ចសន្យា

*(សម្គាល់៖ តួលេខខាងក្រោមគឺជាឧទាហរណ៍ សម្រាប់តែការពន្យល់អំពីវិធីសាស្ត្រតែប៉ុណ្ណោះ)*

នេះជាករណីកិច្ចសន្យារវាងអង្គការកសិករនិងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ អង្គការកសិករ ត្រូវដឹកស្រូវទៅរោងម៉ាស៊ីន។ តម្លៃដែលត្រូវកំណត់ គឺជាតម្លៃស្រូវនៅមាត់ច្រករោងម៉ាស៊ីន។ តម្លៃដែលប្រើជាតម្លៃយោង គឺជាតម្លៃ "ស្រូវក្រអូបគ្រាប់វែងរបស់កម្ពុជា ផ្កាម្លិះ ឬ ផ្ការំដួល (រដូវវស្សា ) បាក់ ៥% " ដូចមានបង្ហាញនៅក្នុងវិបសាយ Live Rice Index (សូមមើល ការពន្យល់បន្ថែម ៤.៧.ង ទំព័រ ៨០)។

| CAMBODIA - LONG GRAIN FRAGRANT RICE | CHANGE | PRICE |
|---|---|---|
| Phka Malis/Phka Rumduol (Wet Season) 5% Broken STX | -30 | $820 |
| Sen Kra Ob/Sen Pidao (Dry Season) 5% Broken STX | -10 | $740 |
| Fragrant 100% Broken A1 Super | -10 | $450 |

ឧ. តម្លៃយោង FOB ៨២០ $/តោន

ដើម្បីប៉ាន់ស្មានតម្លៃស្រូវនៅមុខរោងម៉ាស៊ីនឲ្យបានត្រឹមត្រូវសម្រាប់កសិករ ដោយឈរលើតម្លៃ FOB យើងត្រូវពិចារណានូវកត្តាខាងក្រោម៖

| Miller incomes | | | |
|---|---|---|---|
| | Quantity | Unit value | Amount |
| 5% broken rice | 1.00 t | $ 820.00 | $ 820.00 |
| Broken rice | 0.30 t | $ 280.00 | $ 84.00 |
| Rice bran | 0.20 t | $ 160.00 | $ 32.00 |
| **TOTAL incomes** | | | **$ 936.00** |
| **Miller costs (out of paddy purchase)** | | | |
| | Quantity | Unit value | Amount |
| milling and operation | 2.00 t | $ 65.00 | $ 130.00 |
| logistic transport | 1.00 t | $ 40.00 | $ 40.00 |
| **TOTAL costs out of paddy purchase** | | | **$ 170.00** |
| Miller expected profit | 1.00 t | $ 20.00 | **$ 20.00** |
| **Amount remaining to pay the paddy** | | | |
| Incomes | | | $ 936.00 |
| Costs | | | - $ 170.00 |
| Expected profit | | | - $ 20.00 |
| **Amount remaining to pay the paddy** | | | **$ 746.00** |
| **Price that can be paid for paddy** | | | |
| Volume of paddy to purchase: | | | 2,000 kg |
| **Price defined for paddy based on FOB refere** | | | **0.37 $/kg** |

១. ទិន្នផលនៃការកិនស្រូវ៖ ត្រូវការស្រូវប៉ុន្មាន គ.ក្រ ដើម្បីបានអង្ករ ១,០០០ kg (បាក់ ៥% ដូចតម្លៃយោងនេះ)។

➡ ឧ. ត្រូវការស្រូវ ២,០០០ គ.ក្រ ដើម្បីបានស្រូវ ១,០០០ គ.ក្រ ដែលមានគុណភាពខ្ពស់។

២. ពិចារណាអំពីការកែច្នៃ ការដឹកជញ្ជូន និងចំណាយផ្សេងទៀតក្នុងប្រតិបត្តិការរបស់រោងម៉ាស៊ីន/អ្នកនាំចេញ (ភ្លើង ពលកម្ម ប្រតិបត្តិការ សេវាហិរញ្ញវត្ថុ ពន្ធ ដឹកជញ្ជូន)...

t ➡ ឧ. ៦៥ $/តោន នៃការកែច្នៃស្រូវ

+ ៤០ $/តោន សម្រាប់ដឹកជញ្ជូន លើកដាក់ គយ...

៣. ពិចារណាលើការទទួលបានតម្លៃមកពីអនុផល (ចុងអង្ករ ក ១,០០០ គ.ក្រនៃអង្ករគុណភាពល្អ, និងមានចុងអង្ករ ៣០០ គ.ក្រ ដែលអាចរកបាន ២៨០ $/តោន (នៅរោងម៉ាស៊ីន), និងកន្ទក់ ២០០ គ.ក្រ ដែលមានតម្លៃ ១៦០ $/តោន (នៅរោងម៉ាស៊ីន)។

អាស្រ័យលើកត្តាទាំងនេះ៖ ដូចរៀបរាប់ខាងលើ យើងអាចគណនាចំណូលដែលបានរំពឹងទុករបស់រោងម៉ាស៊ីន សម្រាប់ការទិញស្រូវ ២ តោន ដែលមាន ១ តោន គុណភាពល្អ (បាក់ ៥% ) សម្រាប់នាំចេញ + អនុផល ។ យើងអាចប៉ាន់ស្មានការចំណាយ និងប្រាក់ចំណេញដែលបានរំពឹងទុករបស់រោងម៉ាស៊ីន ហើយដកទឹកប្រាក់សេសសល់ចេញ សម្រាប់ជាការគណនាការទូទាត់លើស្រូវ ២,០០០ តោន។

ផ្អែកលើការប៉ាន់ប្រមាណនេះ៖ គេអាចដករូបមន្តសាមញ្ញមួយ៖ សម្រាប់តម្លៃ FOB នៃ ៨២០ $/តោន, តម្លៃស្រូវនៅរោងម៉ាស៊ីន អាចកំណត់នៅត្រឹម ៣៧០ $/តោន មានន័យថា ស្រូវអាចទូទាត់នៅរោងម៉ាស៊ីនត្រឹម ៤៥ % នៃតម្លៃ FOB សម្រាប់ការបាក់ ៥% ។

[កត់សម្គាល់ថា សមាមាត្រផ្ទាល់ (ដូចជា "៤៥%") មិនឆ្លុះបញ្ចាំងអំពីការគណនាពិតប្រាកដ ដែលរួមផ្សំជាមួយនឹង ការចំណាយថេរ និងការចំណាយប្រែប្រួល ស្របទៅតាមបរិមាណ ប៉ុន្តែវាអាចប្រើជាការគណនាតម្លៃប្រហាក់ប្រហែល ដើម្បីធ្វើឲ្យងាយស្រួលដល់ប្រព័ន្ធ។

ការពន្យល់បន្ថែម ៤.៧.ឆ.

## ឧទាហរណ៍ជាទ្រឹស្តីនៃការវិភាគលើឯកសារតម្លៃកន្លងមក ដើម្បីកំណត់រកតម្លៃ FOB ដែលអាចអនុវត្តបានសម្រាប់ផលិតផលដើម នៅក្នុងកិច្ចសន្យា

*(សម្គាល់៖ តួលេខតម្លៃក្នុងមូលដ្ឋានខាងក្រោម គឺជាឧទាហរណ៍សម្រាប់ការពន្យល់លើវិធីសាស្ត្រ ប៉ុណ្ណោះ)*

ដើម្បីបង្កើតទំនាក់ទំនងរវាងតម្លៃយោងទីផ្សារអន្តរជាតិ ជាមួយនឹងតម្លៃក្នុងមូលដ្ឋានសម្រាប់ផលិតផលដើម យើងអាចប្រៀបធៀបឯកសារយោងតម្លៃទីផ្សារអន្តរជាតិ ទៅនឹងតម្លៃក្នុងមូលដ្ឋានដែលធ្លាប់បានទូទាត់សម្រាប់ផលិតផលដើមកាលពីពេលកន្លងមក។

ឧទាហរណ៍ តារាងខាងក្រោម ប្រៀបធៀបអំពីតម្លៃយោងទីផ្សារអន្តរជាតិសម្រាប់អង្ករដែលបាក់ ៥% ជាមួយនឹងតម្លៃក្នុងមូលដ្ឋាននៃអង្ករ ដែលបានកត់ត្រាទុកនៅក្នុងមូលដ្ឋាន។

ឧទាហរណ៍ គេសង្កេតឃើញថា ផលធៀបតម្លៃស្រូវក្នុងមូលដ្ឋាន ជាមួយនឹងតម្លៃយោងសម្រាប់អង្ករ មិនប្រែប្រួលច្រើនទេ។ ដូចឃើញនៅក្នុងជួរពណ៌ប្រផេះ នៅក្នុងតារាង វាប្រែប្រួលតែពី ៤៦.៩% ទៅ ៤៨.៦% ហើយជាមធ្យមគឺ ៤៧.៩% នៅក្នុងចន្លោះពេលនេះ។

**Historical records**

| Dates | Nov-14 | Dec-14 | Jan-15 | Feb-15 | Mar-15 | Apr-15 | May-15 | Jun-15 | Jul-15 | Aug-15 | Average |
|---|---|---|---|---|---|---|---|---|---|---|---|
| Reference price (1) $/t | $419.00 | $410.70 | $409.70 | $409.50 | $400.70 | $392.40 | $382.40 | $370.50 | $387.70 | $375.70 | $395.83 |
| Local row product price (2) $/t | $203.00 | $199.00 | $195.00 | $195.00 | $192.00 | $184.00 | $183.00 | $180.00 | $185.00 | $181.00 | $189.70 |
| Ratio Local row / Ref price | 48.4% | 48.5% | 47.6% | 47.6% | 47.9% | 46.9% | 47.9% | 48.6% | 47.7% | 48.2% | 47.9% |

(1) Rice, 5 percent broken milled white rice, Thailand nominal price quote, US Dollars per Metric Ton (Source: World Bank)

(2) White rice paddy

ក្នុងករណីនេះ វាជាការសមរម្យដែលត្រូវប្រើតម្លៃយោង FOB សម្រាប់អង្ករ ដើម្បីកំណត់តម្លៃស្រូវក្នុងមូលដ្ឋាន។ ឧទាហរណ៍ ៤៨% នៃតម្លៃ FOB សម្រាប់អង្ករដែលមានអត្រាបាក់ ៥% ... ឬ លើសនេះបន្តិច (៤៩% ឬ ៥០%) ប្រសិនបើយើងចង់ផ្តល់គុណសម្បត្តិឬការលើកទឹកចិត្តបន្ថែមដល់អ្នកផលិត។

### ៤.៧.៧. ការប្រែប្រួលនៃតម្លៃទៅតាមគុណភាព

ក្នុងកិច្ចសន្យាខាងលើ គេអាចរៀបរាប់អំពីកម្រិតផ្សេងៗនៃគុណភាពរបស់ផលិតផលដែលត្រូវប្រគល់ និងតម្លៃផ្សេងៗស្របទៅតាមកម្រិតគុណភាព។

ក្នុងករណីនោះ ប្រការដែលរៀបរាប់អំពីលក្ខខណ្ឌគុណភាព (សូមមើលផ្នែក ៤.៤. នៅក្នុងគោលការណ៍ណែនាំនេះ) គួរកំណត់ឲ្យបានច្បាស់លាស់អំពីកម្រិតផ្សេងៗគ្នា លក្ខណៈវិនិច្ឆ័យ និងតម្លៃគោលដៅប្រើប្រាស់ដើម្បីកំណត់កម្រិតគុណភាពនៃផលិតផលដែលប្រគល់ជូន ព្រមទាំងវិធីសាស្ត្រ និងនីតិវិធីប្រើប្រាស់សម្រាប់គ្រប់គ្រងគុណភាព។

សម្រាប់កម្រិតគុណភាពនីមួយៗ កិច្ចសន្យាអាចបញ្ជាក់អំពីតម្លៃរបស់វា (ក្នុងករណីតម្លៃថេរ – សូមមើលផ្នែក ៤.៧.១. ទំព័រ ៦៩) ឬ (ក្នុងករណីតម្លៃប្រែប្រួល – សូមមើល ផ្នែក ៤.៧.២. ដល់ ៤.៧.៥. ទំព័រ ៧១-៧៥) បុព្វភាពសម្រាប់ផលិតផលដែលមានគុណភាពខ្ពស់ ( ឬ ច្រាសពីនេះវិញ ដូចជា ការបញ្ចុះតម្លៃសម្រាប់គុណភាពទាប)។ ក្នុងករណីនេះ កិច្ចសន្យានេះ ត្រូវបញ្ជាក់ឲ្យច្បាស់អំពីកម្រិតដែលត្រូវពិចារណាសម្រាប់តម្លៃយោង និងបុព្វលាភដែលអនុវត្តចំពោះគុណភាពល្អ និងការបញ្ចុះតម្លៃចំពោះគុណភាពអន់។

## ៤.៨. ការគ្រប់គ្រងការប្រតិបត្តិការ៖ ការដឹកជញ្ជូន ការប្រគល់ ការទទួល ។ល។

ការរៀបចំសម្រាប់ការដឹកជញ្ជូន និងការផ្ទេរ-ប្រគល់កសិផល គឺជាការងារដ៏សំខាន់ ដែលត្រូវបំភ្លឺឲ្យច្បាស់លាស់សម្រាប់អ្នកផលិត និងអ្នកទិញ។ បែបបទ និងការកំណត់ពេល ត្រូវពិភាក្សាឲ្យបានច្បាស់លាស់ និងឯកភាពគ្នាជាផ្នែកមួយនៃកិច្ចសន្យា។ នេះគឺសំខាន់ណាស់និងជាចំណុចរសើបផងដែរ នៅពេលដែលផលិតផលដែលត្រូវប្រគល់នោះ គឺជាផលិតផលស្រស់ និងងាយខូច ដែលត្រូវផ្ទេរ-ប្រគល់ឲ្យបានឆាប់រហ័សពីកសិដ្ឋានទៅរោងចក្រកែច្នៃ (ឬបណ្តាញចែកចាយ)។ ការរៀបចំដើម្បីមានមធ្យោបាយសមរម្យក្នុងការដឹកជញ្ជូនកសិផលទាន់ពេល គឺជាកត្តាដ៏សំខាន់មួយសម្រាប់ការអនុវត្តជោគជ័យ លើកិច្ចសន្យាផលិតកម្មកសិកម្ម ជាពិសេស ដើម្បីរក្សាបានគុណភាពនៃផលិតផល រហូតដល់ចំណុចផ្ទេរប្រគល់ និងរក្សាបានតម្លៃខ្ពស់បំផុត[16]។ ទោះយ៉ាងណា កិច្ចការនេះមិនមែនសុទ្ធតែមានការកំណត់បានល្អិតល្អន់នោះទេ អំពីពេលវេលានៃការចរចាកិច្ចសន្យា និងពេលចុះហត្ថលេខាលើកិច្ចសន្យា ហើយរហូតដល់ខ្វះតែប៉ុន្មានថ្ងៃដល់ពេលប្រមូលផលទើបនឹកឃើញចំណុចលម្អិតដែលត្រូវមានក្នុងកិច្ចសន្យា។ ផ្នែក ៥.២. ទំព័រ ១២៣-១៣០ ផ្តល់នូវយោបល់ខ្លះៗអំពីរបៀបបញ្ចប់ការរៀបចំសម្រាប់ការប្រមូលផលិតផល និងប្រតិបត្តិការ។

ខាងក្រោមនេះ ជាបញ្ជីត្រួតពិនិត្យដែលរៀបរាប់អំពីចំណុចគន្លឹះ ដែលត្រូវពិភាក្សា និងបញ្ជាក់ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងរវាងអ្នកទិញ និងអ្នកផលិត។ កថាខណ្ឌខាងក្រោមនេះ ផ្តល់នូវការបំភ្លឺ ការឆ្លុះបញ្ចាំង និងយោបល់បន្ថែមសម្រាប់ចំណុចទាំងនេះ។

[16] សូមមើល ផ្នែក ៤.៧.៧. ការលៃតម្រូវតម្លៃទៅតាមគុណភាព។

បញ្ជីត្រួតពិនិត្យដែលត្រូវបំភ្លឺនៅក្នុងកិច្ចសន្យា ពាក់ព័ន្ធនឹងការគ្រប់គ្រងការប្រមូលនិងការដឹកជញ្ជូនផលិតផល៖

□ តើបរិមាណផលិតផលទាំងអស់ដែលបានចែងក្នុងកិច្ចសន្យា នឹងត្រូវប្រគល់តែមួយលើក ឬច្រើនលើក? (សម្គាល់៖ ក្នុងករណីភាគច្រើន មានដឹកច្រើនជើង ជាពិសេស បើបរិមាណច្រើន។)

□ ក្នុងការដឹកមួយជើង តើមានការកំណត់បរិមាណអប្បបរិមា ឬអតិបរិមាឬទេ? (ជាទូទៅ កិច្ចសន្យាអាចបញ្ជាក់អំពីបរិមាណអប្បបរិមា ដើម្បីបន្ថយថ្លៃដឹកជញ្ជូន ឲ្យនៅត្រឹមកម្រិតអាចទទួលយកបាន)។

□ តើមានចំនួនដឹកជញ្ជូនអប្បបរិមា និង/ឬអតិបរិមាសម្រាប់ការដឹកជញ្ជូនទេ នៅក្នុងកិច្ចសន្យា?

□ តើមានចំណុចប្រគល់ផលិតផល តែមួយ ឬច្រើនកន្លែង?

□ តើចំណុចប្រគល់ ស្ថិតនៅទីណា?

□ តើនរណាទទួលបន្ទុករៀបចំការដឹកជញ្ជូនពីចំការទៅកន្លែងប្រគល់?

□ តើនរណាទទួលបន្ទុកលើការចំណាយថ្លៃដឹកជញ្ជូនពីចំការទៅកន្លែងប្រគល់?

□ តើនរណាទទួលបន្ទុករៀបចំការលើកកសិផលទៅលើរថយន្ត (ឬឡានផ្សេងទៀត) នៅកន្លែងប្រគល់?

□ តើនរណាទទួលបន្ទុកចេញថ្លៃលើកដាក់លើរថយន្ត (ឬរថយន្តផ្សេងទៀត) នៅកន្លែងប្រគល់?

□ តើនរណាទទួលបន្ទុករៀបចំការដឹកជញ្ជូនពីកន្លែងប្រគល់ទៅរោងចក្រកែច្នៃ/ឃ្លាំង/កន្លែងចែកចាយ?

□ តើអ្វីជាវិធីសម្របសម្រួលនិងប្រាស្រ័យទាក់ទងគ្នា រវាងអ្នកផលិត និងអ្នកទិញ ដើម្បីរៀបចំការប្រមូល (របៀបណា និងនៅពេលណា ដែលគួរជូនដំណឹងដល់អ្នកទិញ អំពីកម្រិតបរិមាណជាក់លាក់ដែលត្រូវប្រមូលនិងប្រគល់ នៅពេលណា នៅកន្លែងណា?)។

□ ការទទួលខុសត្រូវក្នុងករណីភាគីណាមួយមិនអនុវត្តតាមកាលវិភាគប្រគល់តាមការកំណត់ ឧទាហរណ៍ ប្រសិនបើអ្នកផលិតយកផលិតផលទៅដល់កន្លែងប្រគល់ ហើយអ្នកទិញមិនទាន់មកដល់ផលិតផលទាន់ពេល តើអ្នកទិញត្រូវទទួលខុសត្រូវចំពោះការថយចុះគុណភាពឬទេ (ជាពិសេសផលិតផលដែលងាយខូច) ថ្លៃចំណាយបន្ថែមដោយសារការជួលឃ្លាំង ឬផ្ញើផលិតផល ...។ ម្យ៉ាងទៀត ប្រសិនបើអ្នកទិញបញ្ជូនឡានទៅកន្លែងទទួល ប៉ុន្តែផលិតផលមិនទាន់មកដល់ តើអ្នកផលិតត្រូវទទួលខុសត្រូវលើការចេញថ្លៃជួលរថយន្តនោះទេ?

### ៤.៨.១. ចំនួនគំរូស្តង់ដារនៃការប្រគល់ និង/ឬបរិមាណនៃការប្រគល់

ក្រៅពីបរិមាណដែលអ្នកផលិតសន្យាផ្គត់ផ្គង់ទៅអ្នកទិញ កិច្ចសន្យាក៏អាចបញ្ជាក់អំពីចំនួនដងនៃការប្រគល់ (រាល់ផលិតផលដែលត្រូវប្រគល់ ត្រូវដឹកតែមួយលើក ឬច្រើនលើក?)។ បើពុំនោះទេ ក្នុងករណីភាគច្រើន កិច្ចសន្យា មិនបញ្ជាក់ច្បាស់លាស់អំពីចំនួនដើង (ឬការប្រមូល) ប៉ុន្តែវាអាចបញ្ជាក់អំពីបរិមាណអប្បបរិមា ក្នុងមួយដើង ឬ ការប្រមូល ម្តងៗ។ ពេលខ្លះ វាមិនមែនជាការសន្សំសំចៃទេ ក្នុងការដឹករថយន្តតូចៗ ច្រើនដង ដូច្នេះ ត្រូវកំណត់បរិមាណអប្បបរិមា សម្រាប់ដើងនីមួយៗ។

### ៤.៨.២. ចំណុចប្រគល់ទំនិញ

កិច្ចសន្យាត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទីតាំងដែលត្រូវប្រគល់ផលិតផលដល់អ្នកទិញ។ ប្រសិនបើមិនកំណត់នៅក្នុងកិច្ចសន្យាទេ ត្រូវពិភាក្សាគ្នាឲ្យបានច្បាស់និងយល់ព្រម មុនពេលប្រមូលផល។ ចំណុចប្រមូលផ្តុំ ត្រូវនៅជិតកន្លែងផលិត (ពេលខ្លះ អ្នកទិញ ទិញផលិតផលមិនទាន់កាត់ និងគ្រប់គ្រងការប្រមូលផលដោយខ្លួនឯង ក្នុងករណីនេះ កន្លែងប្រគល់គឺជាវាលស្រែចំការដែលគេដាំ ឬ ផលិត)។

ក្នុងករណីផ្សេងទៀត អ្នកផលិតត្រូវទទួលខុសត្រូវលើការដឹកផលិតផលទៅដល់កន្លែងអ្នកទិញ (រោងចក្រកែច្នៃ)។ផ្ទុយពីនេះ ទីតាំងដែលផលិតផលនឹងត្រូវប្រគល់ អាចជាកន្លែងប្រមូលផ្តុំ ជាទូទៅ វាស្ថិតនៅជិតទីតាំងផលិត ទីកន្លែងដែលផលិតផលមកពីទីតាំងផលិតផ្សេង (ចំការ...) នឹងត្រូវប្រមូលផ្តុំ និងជាកន្លែងដែលអ្នកទិញ មកទទួលផលិតផលទាំងនេះ។ ករណីនេះ កើតមានញឹកញាប់ ជាពិសេសប្រសិនបើ អ្នកចុះហត្ថលេខាលើកិច្ចសន្យានេះ គឺជាអង្គការអ្នកផលិត ដែលនឹងកំណត់ទីតាំងសមាជិកម្នាក់ៗ សម្រាប់យកផលិតផលមកទីតាំងនេះ។ អ្នកផលិតនិងអ្នកទិញ ត្រូវឯកភាពគ្នា អំពីទីតាំង ដែលត្រូវយកមកប្រមូលផ្តុំគ្នា ដោយសមាជិកក្រុម សមាគម ឬសហករ ដើម្បីអ្នកទិញ មកទទួលផលិតផល។

ទីតាំងនៃកន្លែងទទួលអាចគិតលើកត្តាដូចខាងក្រោម ៖

- ផ្លូវដែលរថយន្តអាចចូលដល់៖ កន្លែងទទួល ត្រូវមានផ្លូវដែលរថយន្តធំអាចចូលដល់។

ភាពជិតនៃទីតាំងប្រមូល អាចកាត់បន្ថយចម្ងាយផ្លូវដឹកជញ្ជូនតិចៗច្រើនដើង។ ដើម្បីកាត់បន្ថយការចំណាយថ្លៃដឹកជញ្ជូន គេគួរកំណត់ទីតាំងប្រមូលណាដែលនៅជិតកន្លែងផលិតរបស់កសិករ ប៉ុន្តែត្រូវធានាថា យ៉ាងហោចណាស់អាចដឹកបានពេញមួយរថយន្តក្នុងមួយលើក (ឬ ថា រថយន្តនោះអាចលើកដាក់ច្រើនកន្លែងជិតៗនោះ ហើយអាចពេញបានដែរ នៅតាមផ្លូវតែមួយ)។

## ៤.៨.៣. ការរៀបចំការដឹកជញ្ជូន

ការទទួលខុសត្រូវសម្រាប់ការទូទាត់ថ្លៃដឹកជញ្ជូន (រួមមាន ថ្លៃលើកឡើង និងដាក់ចុះពីរថយន្ត) និងការរៀបចំការប្រគល់ផលិតផល ពីស្រែចំការ ទៅកន្លែងទទួល និងពីកន្លែងទទួលទៅរោងចក្រកែច្នៃ គួរត្រូវបានពិចារណា និងឯកភាពគ្នា ដោយភាគីទាំងពីរ ក្នុងពេលចរចាលើកិច្ចសន្យា ហើយការយល់ព្រមទាំងសងខាង ត្រូវតែបានធ្វើឡើងជាលាយលក្ខណ៍អក្សរ។ នៅក្នុងតំបន់ខ្លះ មានការខ្វះកម្លាំងលើកកសិផលឡើងលើរថយន្ត សម្រាប់ករណីនេះ អ្នកផលិត ត្រូវជូនដំណឹង ឬ ត្រូវប្រាប់ឲ្យដឹងទៅអ្នកទិញ ដើម្បីមានពេលគ្រប់គ្រាន់ស្វែងរកកម្មករមកពីកន្លែងផ្សេង ឬ អ្នកផលិតអាចជួយរកទីកន្លែងដែលអាចមានកម្មករលើកផលិតផល។ ទោះយ៉ាងណា កិច្ចសន្យាត្រូវបញ្ជាក់ថា នរណាទទួលបន្ទុកចេញថ្លៃលើក និងដាក់ចុះពីរថយន្ត។

នៅពេលដឹកដល់កន្លែងរបស់អ្នកទិញ (រោងចក្រកែច្នៃ) នៅរដូវប្រមូលផលច្រើន អាចមានការអូសបន្លាយពេលខ្លះ (រង់ចាំ) សម្រាប់ផលិតផលដែលបានផ្តល់ដោយអ្នកផលិត ដែលត្រូវចាត់ចែងដោយអ្នកទិញ។ នេះអាចធ្វើឲ្យអ្នកផលិតត្រូវចំណាយប្រាក់ ហើយ ប្រសិនបើជាបញ្ជូនផលិតផលស្រស់ ការរង់ចាំអាចប៉ះពាល់ដល់គុណភាពនៃផលិតផល។ អ្នកផលិតអាចចរចាអំពីអាទិភាពនៃការទទួលនៅកន្លែងអ្នកទិញសម្រាប់ផលិតផលណាដែលត្រូវពិនិត្យ និងទទួល ទៅតាមអាទិភាព ដោយមិនចាំបាច់រង់ចាំ។ អាទិភាពនេះគួររៀបរាប់នៅក្នុងកិច្ចសន្យា ប្រសិនបើបានចរចារួច។ គេត្រូវកំណត់ថា អាចអូសបន្លាយយ៉ាងយូររយៈពេលប៉ុន្មាន ដែលអ្នកទិញត្រូវមកទទួលយកផលិតផលដែលបានដឹកទៅដល់។

សម្រាប់ការផលិតតាមរដូវដែលមានការផលិតខ្ពស់ ភាគីទាំងពីរត្រូវឯកភាពគ្នាអំពីការចំណាយធនធាន ហើយត្រូវរៀបចំទុកមុន ដើម្បីចាត់ចែងមានប្រសិទ្ធភាពនៅរដូវដែលមានកសិផលច្រើន ដើម្បីងាយចាត់ចែង ដូចជា ធនធានមនុស្សសម្រាប់ពិនិត្យគុណភាព និងគ្រប់គ្រងការដឹកជញ្ជូន ការលើកដាក់ និងការគ្រប់គ្រងប្រតិបត្តិការនានា ដើម្បីជៀសវាងការអូសបន្លាយពេល។

## ៤.៨.៤. ការត្រួតពិនិត្យគុណភាព

ពេលវេលា និងវិធីសាស្ត្រ ដើម្បីគ្រប់គ្រងគុណភាពមុននិងពេលប្រគល់ទំនិញ ក៏ត្រូវកំណត់ឲ្យបានច្បាស់លាស់ និងឯកភាពដោយភាគីទាំងពីរ។ នេះជាការសំខាន់ណាស់ ព្រោះថា ការគ្រប់គ្រងលើការប្រគល់ផលិតផល តែងត្រូវធ្វើឲ្យបានឆាប់រហ័ស ហើយការគ្រប់គ្រងគុណភាពអាចត្រូវការពេលវេលាយូរ។

នៅក្នុងករណីដែលមានអ្នកផលិតជាក្រុមការផ្ទៀងផ្ទាត់ និងការរៀបចំគុណភាពនៃផលិតផលដែលបានប្រគល់ដោយសមាជិក អាចធ្វើឡើងដោយផ្ទៃក្នុង មុនពេលប្រគល់ទៅអ្នកទិញ (សូមមើល ផ្នែក ៧.៣.៣. ទំព័រ ១៥៦)។ នេះនឹងជួយពន្លឿនដំណើរការទទួលទំនិញដោយអ្នកទិញ។

គេអាចត្រូវការជំនាញដើម្បីធ្វើការប៉ាន់ប្រមាណគុណភាព នៅក្នុងទីតាំងរបស់អ្នកសម្របសម្រួលក្នុងមូលដ្ឋាន (តំណាងអង្គការកសិករ...) ដែលអាចផ្តល់ដោយអ្នកទិញ។

លក្ខណៈវិនិច្ឆ័យផ្នែកគុណភាព និងវិធីសាស្ត្រត្រួតពិនិត្យគុណភាព មានរៀបរាប់នៅក្នុងផ្នែក ៤.៤. ទំព័រ ៤.៤។ យោបល់ខាងលើស្តីពីនីតិវិធីសម្រាប់ការផ្ទៀងផ្ទាត់គុណភាពក៏មានផ្តល់ជូននៅក្នុងផ្នែក ៥.២.៣. ទំព័រ ១២៧។

### ៤.៨.៥. ការសម្របសម្រួល និងបែបបទទំនាក់ទំនង

ដើម្បីធានាគុណភាពនៃកសិផល អ្នកផលិតត្រូវមានសកម្មភាពជាមួយអ្នកទិញមុនពេលប្រមូលផល។ អ្នកទិញគួរមកទីតាំងផលិត មុនពេលប្រមូលផល ដើម្បីត្រួតពិនិត្យមើលការផលិត និងធ្វើការសម្រេចចិត្តរួមគ្នាជាមួយអ្នកផលិត ពាក់ព័ន្ធនឹងកាលបរិច្ឆេទប្រមូលផល។ ជាពិសេស ក្នុងករណីលក់ទិន្នផលស្រស់ អ្នកផលិតត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ចំពោះពេលវេលានៃការប្រគល់ទំនិញទៅដល់កន្លែងកែច្នៃ ឬកន្លែងរបស់អ្នកទិញ ឬកន្លែងដែលបានឯកភាពគ្នា។ សូមមើលអនុសាសន៍លម្អិតអំពីការសម្របសម្រួលសម្រាប់ការប្រមូលយកផលិតផល នៅក្នុងផ្នែក ៥.២ ទំព័រ ១២៣-១៣០ ។

## ៤.៩. របៀប និងពេលទូទាត់ប្រាក់

ទោះបរិមាណ គុណភាព និងតម្លៃនៃផលិតផលដែលត្រូវផ្តល់ មានរៀបរាប់រួចស្រេចក៏ដោយ (នៅក្នុងផ្នែក ៤.៣, ៤.៤., និង ៤.៧) កិច្ចសន្យាផលិតកម្មកសិកម្ម ក៏ត្រូវបញ្ជាក់ច្បាស់លាស់អំពីនីតិវិធី នៃការទូទាត់ប្រាក់សម្រាប់ទំនិញដែលបានប្រគល់រួច។ ពេលខ្លះ មានការធ្វេសប្រហែសនៅផ្នែកនេះ ដែលនាំឲ្យមានការខ្វែងគំនិតគ្នាដោយសារមិនបានបញ្ជាក់នៅក្នុងដំណាក់កាលចរចាកិច្ចសន្យា។

**សំនួរខាងក្រោមនេះ ត្រូវឆ្លើយនៅក្នុងកិច្ចសន្យា៖**

### ៤.៩.១. ចំនួនដំណាក់កាល និងពេលទូទាត់ប្រាក់

#### ចំនួនដង ឬពេលចេញវិក្កយបត្រ និងការទូទាត់ប្រាក់

ប្រសិនបើផលិតផលនៃកិច្ចសន្យាត្រូវបានផ្តល់ជូនតែមួយលើក ការទូទាត់ប្រាក់គ្រប់ចំនួន គួរធ្វើតែមួយលើកដែរ (លើកលែងតែប្រាក់ដែលបានបង់មុនរួច មុនពេលប្រមូលផល និងប្រគល់ទំនិញ)។ ទោះយ៉ាងណា ករណីនេះ មិនត្រូវបានគេអនុវត្តគ្រប់ពេលទេ។

ផលិតផលស្រស់ឬផលិតផលដែលឆាប់ខូច (ដូចជា បន្លែ ឬផ្លែឈើ) ដែលមិនទុំ ឬអាចប្រមូលផលបានក្នុងពេលតែមួយ បរិមាណដែលបានឯកភាពគ្នា គួរមានការផ្គត់ផ្គង់ទៅអ្នកទិញច្រើនដង និងញឹកញាប់ (ដូចជា ប្រចាំថ្ងៃ ឬ ២-៣ ថ្ងៃម្តង ឬសម្រាប់រយៈពេលច្រើនអាទិត្យ ឬច្រើនខែ) – សូមមើលផ្នែក ៤.៨. ខាងលើ ។ ក្នុងករណីទាំងនោះ ការទូទាត់ប្រាក់ អាចធ្វើឡើងនៅពេលប្រគល់ទំនិញម្តងៗ ឬមួយជុំនៃការផ្តល់ទំនិញម្តង (ដូចជា ការប្រគល់ទំនិញលើកនេះ នឹងត្រូវទូទាត់ប្រាក់នៅពេលប្រគល់ទំនិញលើកក្រោយ បន្ទាប់នេះ )។ ប៉ុន្តែដើម្បីកុំឲ្យខាតពេលក្នុងប្រតិបត្តិការ ភាគីទាំងពីរ អាចគិតប្រាក់នៅពេលប្រគល់ទំនិញបានច្រើនលើកក៏បាន នៅក្នុងវិក្កយប័ត្រតែមួយ (ឧទាហរណ៍ ចេញវិក្កយប័ត្រតែម្តង សម្រាប់មួយអាទិត្យ ឬមួយខែ សម្រាប់ទំនិញដែលបានប្រគល់នៅក្នុងមួយអាទិត្យ ឬមួយខែ)។ ប្រសិនបើ មានការលំបាកក្នុងលំហូរទឹកប្រាក់សម្រាប់ភាគីអ្នកទិញ គេអាចដោះស្រាយតាមរយៈការទូទាត់ប្រាក់មុនពេលប្រមូលផល ត្រូវកាត់នៅពេលប្រមូលផលរួច ដូចមានណែនាំ (ករណីកិច្ចសន្យាជាមួយអង្គការកសិករ) នៅក្នុងផ្នែក ៧.៤. បញ្ហាលំហូរសាច់ប្រាក់/ការពន្យាពេលទូទាត់ប្រាក់នៅក្នុងអង្គការកសិករ ទំព័រ ១៥៧។

### ពេលទូទាត់ប្រាក់

ការកំណត់ពេលវេលានៃការទូទាត់ប្រាក់ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យា។ ការទូទាត់ប្រាក់អាចធ្វើនៅពេលប្រគល់ទំនិញភ្លាម។ ពេលវេលានៃការទូទាត់ប្រាក់គឺត្រូវធ្វើភ្លាម ប៉ុន្តែត្រូវមានកំណត់នៅក្នុងកិច្ចសន្យា។ ក្នុងករណីផ្សេងទៀត ប្រសិនបើពេលចេញវិក្កយប័ត្រនិងទូទាត់ប្រាក់ មិនធ្វើឡើងនៅពេលប្រគល់ទំនិញទេ (នៅពេលបូកសរុបចូលទៅក្នុងវិក្កយប័ត្រតែមួយ សម្រាប់ទំនិញច្រើនដើង) ដូច្នេះកិច្ចសន្យាត្រូវបញ្ជាក់អំពីការពន្យាពេលដែលត្រូវផ្តល់ទៅអ្នកទិញដើម្បីរៀបចំទូទាត់ប្រាក់សម្រាប់វិក្កយប័ត្របូកសរុបនោះ។

ការពន្យាពេលនេះ អាចបញ្ជាក់អំពីចំនួនថ្ងៃធ្វើការ ឬ ថ្ងៃប្រតិទិន ឬនៅក្នុងចំនួនសប្តាហ៍ ឬ ចំនួនខែ។ គេក៏អាចបញ្ជាក់អំពីការពិន័យសម្រាប់ការទូទាត់ប្រាក់យឺត (ដូចជា យឺតជាងការកំណត់នៅក្នុងកិច្ចសន្យា) ក្រោយពេលបានទទួលវិក្កយប័ត្រ សម្រាប់ភាគីអ្នកទិញសងថ្លៃសេវាហិរញ្ញវត្ថុ ជាពិសេស ប្រសិនបើគេទទួលប្រាក់កម្ចីដែលត្រូវសងរយៈពេលយូរ។

## ៤.៩.២. មធ្យោបាយទូទាត់ប្រាក់

គេអាចប្រើមធ្យោបាយទូទាត់ប្រាក់ផ្សេងៗគ្នា ដែលគួរមានរៀបរាប់នៅក្នុងកិច្ចសន្យា៖ ការទូទាត់ប្រាក់អាចធ្វើឡើងតាមរបៀប ៖

- ជាសាច់ប្រាក់
- ជាសែក (មូលប្បទានបត្រ)
- ការផ្ទេតាមធនាគារទៅគណនីអ្នកផលិត ឬ
- តាមសេវាផ្ទេរប្រាក់តាមទូរស័ព្ទ [17]។

ជម្រើសណាមួយនៃវិធីទូទាត់ប្រាក់ អាស្រ័យលើការសម្រេចចិត្តរបស់ភាគីទាំងពីរ ហើយគួរពិភាក្សាគ្នា។ ទោះយ៉ាងណា ថ្លៃសេវាប្រតិបត្តិការ សន្តិសុខ និងលទ្ធភាពតាមដានលើការទូទាត់ប្រាក់ គឺជាការសំខាន់ដែលគួរពិចារណា ដោយអ្នកចុះហត្ថលេខាលើកិច្ចសន្យា នៅពេលធ្វើការសម្រេចចិត្តលើចំណុចនេះ។

ម្យ៉ាងទៀត ភាគីអ្នកផលិតតែងចង់បានប្រាក់នៅពេលប្រគល់ទំនិញ (ភ្លាមៗ) ប្រសិនបើគេមិនប្រាកដអំពីការទទួលប្រាក់នៅធនាគារនៅពេលក្រោយ ឬថាគេអាចពិបាកប្តូរសែកយកជាលុយវិញ។

ម្យ៉ាងទៀត ការទូទាត់ជាសាច់ប្រាក់ (ត្រូវតែរាប់ប្រាក់ និងអាចត្រូវការពេលច្រើន នៅពេលអ្នកផលិតប្រគល់ទំនិញទៅកន្លែងទទួលតែមួយ) ហើយអ្នកទទួលប្រាក់ក៏ត្រូវកាន់ប្រាក់ច្រើនតាមខ្លួន នៅទីជនបទឬដាច់ស្រយាល ដែលអាចមានហានិភ័យលើសន្តិសុខ។ លើសពីនេះ ការទូទាត់ជាសាច់ប្រាក់ត្រូវមានបង្កាន់ដៃ និងចុះហត្ថលេខា ដែលអាចជាប្រភពនៃកំហុស ផ្ទុយទៅវិញ ការបង់ប្រាក់តាមធនាគារអាចទុកចិត្តជាងសម្រាប់ការផ្ទៀងផ្ទាត់ប្រភព (អាស្រ័យលើរបាយការណ៍ធនាគារ / ឯកសារផ្ទេរប្រាក់) ដើម្បីបញ្ជាក់ថា បានផ្ទេររួច និងតាមចំនួនទឹកប្រាក់ត្រឹមត្រូវ។

នៅពេលទឹកប្រាក់នៃប្រតិបត្តិការមានចំនួនច្រើន ការទូទាត់តាមធនាគារ (សែក ឬផ្ទេរតាមធនាគារ) គួរជ្រើសរើសយកមកប្រើ។ តារាង ៤.៩.ក ខាងក្រោម ផ្តល់នូវការសង្ខេបអំពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសទូទាត់ប្រាក់នីមួយៗ។

[17] បច្ចុប្បន្ន នៅប្រទេសកម្ពុជា ចាប់ផ្តើមមានសេវាផ្ទេរប្រាក់តាមទូរស័ព្ទ ទំនើប ឬកម្មវិធីទូរស័ព្ទទំនើប។

**តារាង ៤.៩.ក.៖ ការពិនិត្យមើលជម្រើសផ្សេងៗនៃមធ្យោបាយទូទាត់ប្រាក់**

| ជម្រើសទូទាត់ | គុណសម្បត្តិ | គុណវិបត្តិ | ករណីសមរម្យ |
|---|---|---|---|
| ១. សាច់ប្រាក់ | • ទូទាត់បានភ្លាមៗដល់កសិករ (ដូចជាកសិករមិនមានទម្លាប់ប្រើធនាគារ ព្រោះគេមិនទុកចិត្តសែក ឬធនាគារ)។<br>• អ្នកផលិតមិនចាំបាច់មានគណនីធនាគារ។ | • ត្រូវការពេលរាប់លុយ។<br>• ត្រូវរៀបចំបង្កាន់ដៃ (អាចមានកំហុស)។<br>• ហានិភ័យផ្នែកសន្តិសុខ ប្រសិនបើកាន់ទឹកប្រាក់ច្រើន ជាពិសេសនៅតំបន់ដាច់ស្រយាល។ | • សមស្របសម្រាប់ទឹកប្រាក់តិចតួច ដោយប្រគល់ប្រាក់ភ្លាមដល់កសិករខ្នាតតូច។ |
| ២. សែក | • ងាយតាមដានការទូទាត់ប្រាក់<br>• មានសុវត្ថិភាព<br>• អ្នកផលិតមិនចាំបាច់មានគណនីធនាគារ។ | • សែកអាចនឹងមិនមានលុយ។<br>• ចំណាយលើសែកនិងពេលទៅបើកលុយ (ទោះទឹកប្រាក់តិចឬច្រើន) – ជាពិសេសបើធនាគារនៅឆ្ងាយពីអ្នកផលិត។ | • វិធីមានសុវត្ថិភាពសម្រាប់ទូទាត់ប្រាក់។<br>• សមរម្យពេលទឹកប្រាក់មានចំនួនច្រើន ហើយបើអ្នកផលិតងាយប្រើសេវាធនាគារដើម្បីបើកប្រាក់ពីសែក។ |
| ៣. ការផ្ទេរតាមធនាគារ | • ងាយតាមដានការទូទាត់ប្រាក់<br>• មានសុវត្ថិភាព | • អស់ថ្លៃសេវាផ្ទេរប្រាក់<br>• អ្នកផលិតត្រូវមានគណនីធនាគារ<br>• អ្នកទិញអាចបើកប្រាក់បានតែថ្ងៃធ្វើការ ហើយអាចអូសបន្លាយពេល ដូចជាចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក។ | • សមរម្យសម្រាប់ករណីដែលអ្នកផលិតមានគណនីធនាគារ។<br>• ជាវិធីទូទាត់មានសុវត្ថិភាពជាងគេ។<br>• សមរម្យសម្រាប់ការផ្ទេរទឹកប្រាក់ច្រើន។ |
| ៤. ការផ្ទេរតាមទូរស័ព្ទដៃ | • ងាយតាមដានការទូទាត់ប្រាក់<br>• មានសុវត្ថិភាព<br>• អាចបង់ប្រាក់ភ្លាមៗនៅកន្លែង | • អ្នកផលិតខ្លះពុំសូវចេះប្រើបច្ចេកវិទ្យាថ្មីៗ ឬមិនទាន់មានកម្មវិធីនេះលើទូរស័ព្ទ | • គួរស្រាវជ្រាវបន្ថែម ប៉ុន្តែអាចជាវិធីល្អសម្រាប់គួបផ្សំគ្នាជាមួយភាពស្និទស្នាល ការតាមដាន និងសុវត្ថិភាព។ |

**ព័ត៌មានលម្អិតធនាគារ៖**

ប្រសិនបើជ្រើសរើសយកការផ្ទេរប្រាក់តាមធនាគារ ត្រូវសរសេរព័ត៌មានលម្អិតធនាគារទៅក្នុងកិច្ចសន្យា ។ ព័ត៌មានខាងក្រោមនេះ គួរមានផ្តល់អំពីធនាគារ៖

- ឈ្មោះធនាគារ៖ ______________________________
- ការិយាល័យសាខាធនាគារ៖ ______________________________
- អាសយដ្ឋានធនាគារ៖ ______________________________
- ម្ចាស់គណនី៖ ________________ (ឈ្មោះរបស់អ្នកចុះហត្ថលេខាលើកិច្ចសន្យា)
- លេខគណនី៖ ______________________________
- រូបិយប័ណ្ណ៖ ________________ (ឧទាហរណ៍ ប្រាក់រៀល ឬប្រាក់ដុល្លារ...)
- លេខកូដ SWIFT ៖ ______________________________

កិច្ចសន្យាក៏គួរកំណត់អំពីថ្លៃសេវាកម្មធនាគារសម្រាប់ការទូទាត់ជាសែកឬការផ្ទេរប្រាក់។ ជាធម្មតា តម្លៃទាំងនេះ គឺជាកាតព្វកិច្ចរបស់អ្នកប្រគល់ប្រាក់ (= អ្នកទិញ)។ បើពុំនោះទេ ត្រូវសរសេរឲ្យច្បាស់ក្នុងកិច្ចសន្យា។

### ៤.៩.៣. ការចេញវិក្កយបត្រ និងទម្រង់ភស្តុតាងការទូទាត់ប្រាក់

ភាគីទាំងពីរត្រូវតែអាចបញ្ជាក់ថា ផលិតផលបានប្រគល់ជូនរួច ហើយប្រាក់ក៏បានទូទាត់រួចដែរ។ យ៉ាងហោចណាស់ កិច្ចសន្យាផលិតកម្មកសិកម្មអាចបញ្ជាក់ថា បង្កាន់ដៃប្រគល់ទំនិញ (បង្កាន់ដៃប្រគល់-ទទួល) និងការបង្កាន់ដៃទទួលប្រាក់ត្រូវតែបានរៀបចំឡើង ហើយត្រូវចុះហត្ថលេខា និងចម្លងជូនសម្រាប់រក្សាទុកដោយភាគីទាំងពីរ។ ទ្រង់ទ្រាយនៃបង្កាន់ដៃទទួលប្រាក់អាចភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យា ឬ អាចពិភាក្សាគ្នានៅពេលក្រោយដោយភាគីទាំងពីរ។

ទម្លាប់បន្ថែមសម្រាប់ការគ្រប់គ្រងប្រតិបត្តិការនិងការទូទាត់ប្រាក់គឺមានផ្តល់ជាយោបល់នៅក្នុង ផ្នែក ៥.២.៥. ទំព័រ ១៤១។

កិច្ចសន្យាផលិតកម្មកសិកម្ម មិនចាំបាច់ផ្តល់ព័ត៌មានលម្អិតច្រើនទេ ប៉ុន្តែ យ៉ាងហោចណាស់ គួរមានរៀបរាប់អំពីឯកសារផ្សេងៗ (លិខិតផ្ទេរប្រគល់ បង្កាន់ដៃទទួលប្រាក់ វិក្កយប័ត្រ...) ដែលនឹងត្រូវប្រើប្រាស់ដើម្បីគ្រប់គ្រងប្រតិបត្តិការ។

ក្នុងករណីកិច្ចសន្យាធ្វើជាមួយអង្គការកសិករ ឬសហករកសិកម្ម យើងមានផ្តល់យោបល់បន្ថែមនៅក្នុងផ្នែក ៧ នៃសៀវភៅណែនាំនេះ សម្រាប់ការគ្រប់គ្រងប្រតិបត្តិការ រវាងកសិករនិងអង្គការកសិករ ឬ សហករកសិកម្ម និងរវាងអង្គការកសិករ ឬសហករកសិកម្ម ជាមួយនឹងអ្នកប្រមូលទិញ។

### ៤.៩.៤. ជម្រើសផ្សេងទៀតដែលអាចពិចារណា

#### ការកាត់ប្រាក់ចេញពីប្រាក់ទទួលកាលពីលើកមុន

ជាផ្នែកមួយនៃកិច្ចសន្យា ប្រសិនបើ អ្នកទិញកំពុងផ្តល់ឥណទានជាសាច់ប្រាក់ ឬ ជាវត្ថុទៅអ្នកផលិត (ដូចជា គ្រាប់ពូជ ឬ ជី ត្រូវបានផ្តល់ជូនដោយអ្នកទិញ ដើម្បីអ្នកផលិតខ្ចីសិន – សូមមើលផ្នែក ៤.២. ការគាំទ្ររបស់អ្នកទិញ៖ ធាតុចូល/បុរេហិរញ្ញប្បទាន / យោបល់បច្ចេកទេស) ករណីនេះ កិច្ចសន្យាគួរបញ្ជាក់ឲ្យច្បាស់អំពីរបៀបទូទាត់សងវិញពីថ្លៃឥណទានទាំងនោះ។ ជាទូទៅ ការសងឥណទាន ត្រូវធ្វើឡើងដោយការកាត់ប្រាក់នៅពេលប្រគល់ទំនិញ។ ប្រសិនបើ ផលិតកម្មមានការទូទាត់ប្រាក់តែមួយលើក ដូច្នេះការកាត់ប្រាក់ក៏ធ្វើឡើងតែមួយលើកដែរ ដោយមិនចាំបាច់មានលម្អិតព័ត៌មានច្រើន។

ប៉ុន្តែប្រសិនបើការប្រគល់ទំនិញនិងការទូទាត់ប្រាក់ ធ្វើឡើងច្រើនលើកតាមជើងនៃការប្រគល់ទំនិញ បន្ទាប់មក ទម្រង់នៃការទូទាត់សង គួរមានបញ្ជាក់លម្អិត។ គេអាចប្រើជម្រើសជាច្រើន។ ឧទាហរណ៍ខ្លះៗ មានផ្តល់នៅការពន្យល់បន្ថែមខាងក្រោម។ ប៉ុន្តែនេះគ្រាន់តែជាឧទាហរណ៍ខ្លះៗ នៅពេលចរចាកិច្ចសន្យា អ្នកប្រមូលទិញ និងអ្នកផលិតអាចកែសម្រួលវិធីសាស្រ្ត ដែលសមស្របសម្រាប់ពួកគេ។

| ជម្រើសដែលប្រើបាន សម្រាប់កាត់ប្រាក់បុរេប្រទានទៅសងអ្នកចុះកិច្ចសន្យាវិញ |
|---|
| ▪ **ជម្រើស ១៖ ការទូទាត់សងឲ្យអស់សិន**<br>ការទូទាត់សងត្រូវធ្វើឡើងនៅពេលប្រគល់ទំនិញទាល់តែអស់សិន៖ ការប្រគល់ទំនិញលើកដំបូងៗ គឺសម្រាប់ការសងប្រាក់ឥណទាន រហូតដល់សងអស់ថ្លៃដែលត្រូវសង។ |
| ▪ **ជម្រើស ២៖ ការកាត់ប្រាក់ថេររាល់ពេលប្រគល់ទំនិញម្តងៗ៖**<br>ប្រសិនបើភាគីអាចគណនាជាមុននូវចំនួនជើងនៃការប្រគល់ទំនិញ នោះគេអាចកាត់ប្រាក់ក្នុងចំនួនថេរ នៅរាល់ពេលប្រគល់ទំនិញម្តងៗ។ ឧទាហរណ៍ គេអាចកាត់ប្រាក់ ៥ ដង ដោយម្តងៗ កាត់ ២០% ពីថ្លៃទំនិញប្រគល់ក្នុងមួយលើក។ |
| ▪ **ជម្រើស ៣៖ ទឹកប្រាក់ថេរ រហូតទូទាត់សងគ្រប់**<br>ដោយឈរលើការប៉ាន់ប្រមាណបរិមាណផលិតផលដែលត្រូវប្រគល់ (សូមមើលផ្នែក ៤.៣.២. ការបញ្ជាក់អំពីបរិមាណ) ចំនួនទឹកប្រាក់ដែលត្រូវកាត់ ត្រូវគណនាទៅតាមឯកតាផលិតផលប្រគល់ក្នុងជើងនីមួយៗ។ ឧទាហរណ៍ ប្រសិនបើអ្នកផលិតជំពាក់ ៥ លានរៀល នៃថ្លៃធាតុចូល ហើយរំពឹងថានឹងប្រគល់ផលិតផល ១០ តោន នោះគេអាចប្រើវិធីកាត់ប្រាក់ ៥០០,០០០ ក្នុងមួយតោន។ ប៉ុន្តែប្រសិនបើមានទិន្នផលលើស ១០ តោន គេត្រូវមិនត្រូវកាត់ប្រាក់លើទិន្នផលដែលលើសពី ១០ តោននោះទេ។ ផ្ទុយមកវិញ ប្រសិនបើអ្នកផលិត មានទិន្នផលមិនគ្រប់ ១០ តោនទេ គាត់ត្រូវបន្ថែមប្រាក់បង្គ្រប់ការសងទៅឲ្យអ្នកប្រមូលទិញនោះ។ |

#### ការចរចាដែលអាចធ្វើបានសម្រាប់លំហូរប្រាក់បុរេប្រទាន

នៅពេលកិច្ចសន្យាត្រូវបានធ្វើជាមួយអង្គការកសិករ ឬ សហករកសិកម្ម ដែលទិញផលិតផលពីសមាជិក (ដែលជាអ្នកផលិត) និងលក់ទៅឲ្យអ្នកទិញ ការទូទាត់ប្រាក់អាចធ្វើឡើងបន្ទាប់ពីប្រគល់ទំនិញបានពីរ ឬ បីថ្ងៃ (ជាពិសេស ប្រសិនបើបើកប្រាក់តាមធនាគារ ឬ តាមសែក) ប៉ុន្តែកសិករ ចង់ទទួលបានប្រាក់ក្រោយប្រគល់ទំនិញភ្លាម។ ការទូទាត់ប្រាក់បុរេប្រទានរយៈពេលខ្លី អាចចរចាគ្នាបាន នៅក្នុងកិច្ចសន្យា ដើម្បីផ្តល់ដោយអ្នកប្រមូលទិញ រយៈពេលពីរ ឬ បីថ្ងៃមុនពេលប្រមូលផល និងប្រគល់ទំនិញ ហើយកាត់សងវិញនៅក្នុងការទូទាត់ប្រាក់ចុងក្រោយ។ ព័ត៌មានលម្អិតគឺមានផ្តល់នៅក្នុងផ្នែកស្តីពីលំហូរសាច់ប្រាក់ នៅក្នុងផ្នែក ៧ (ផ្នែក ៧.៤. បញ្ហានៃលំហូរសាច់ប្រាក់ / ការពន្យាពេលទូទាត់ប្រាក់ នៅក្នុងសហករ / អង្គការកសិករ)។

## ៤.១០. ករណីពិសេសដែលមិនអាចអនុវត្តកាតព្វកិច្ច៖ ហានិភ័យធម្មជាតិ/ប្រធានសក្តិ

កិច្ចសន្យាផលិតកម្មកសិកម្ម អាចងាយរងគ្រោះដោយសារស្ថានភាព ដែលធ្វើឲ្យភាគីណាមួយ មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន ឬ មានបញ្ហាប្រឈមខ្លាំង ដែលមើលមិនឃើញនៅពេលចុះកិច្ចសន្យា (សូមមើលផ្នែក ៤.១០.១. ខាងក្រោម)។ នៅពេលមានព្រឹត្តិការណ៍ដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ភាគីព្រឹត្តិការណ៍ទាំងនោះ ក៏ប៉ះពាល់ដល់កិច្ចសន្យាដែរ (សូមមើលផ្នែក ៤.១០.២. ពីទំព័រ ១០១)។

### ៤.១០.១. ព្រឹត្តិការណ៍ដែលហួសពីសមត្ថភាពគ្រប់គ្រង

ព្រឹត្តិការណ៍ដែលហួសពីសមត្ថភាពគ្រប់គ្រងហៅថា“ ប្រធានសក្តិ” គឺជាប្រការផ្លូវច្បាប់ដែលអនុញ្ញាតឲ្យភាគីព្យួរ ឬបញ្ចប់កាតព្វកិច្ចរបស់គេ ប្រសិនបើស្ថានភាពអាក្រក់ហួសពីសមត្ថភាពគ្រប់គ្រងកើតឡើង។ ប្រធានសក្តិគឺជាមូលដ្ឋានផ្នែកច្បាប់ សម្រាប់ការលើកលែងពីការទទួលខុសត្រូវ។ ប្រការស្តីពីប្រធានសក្តិ អាចប្រែប្រួលទៅតាមច្បាប់នៃប្រទេស។ ទោះកម្ពុជាប្រើច្បាប់ស៊ីវិល (Civil law) ប៉ុន្តែមិនមានសេចក្តីយោងច្បាស់លាស់ទេអំពីការគ្រប់គ្រងនៅពេលមានករណីប្រធានសក្តិ ហើយក៏មិនមាននិយមន័យច្បាស់លាស់អំពីប្រធានសក្តិនៅក្នុងច្បាប់នេះដែរ ក្រមរដ្ឋប្បវេណី ឬ អត្ថបទច្បាប់ផ្សេងទៀត។

ប៉ុន្តែក្រមរដ្ឋប្បវេណី មានចែងនៅក្នុងប្រការខ្លះៗ អលទ្ធភាពក្នុងការអនុវត្ត នៅពេល “ប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព។” និងអំពី “អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ត្រូវបានវាយតម្លៃថា មិនអាចធ្វើកើត តាមស្ថានភាពសង្គម ឬ សេដ្ឋកិច្ច។និង “ក្នុងករណីដែលភាគីម្ខាងទៀតគ្មានកំហុស ឬមានមូលហេតុក្នុងការខូចខាត ឬមិនបានសងវត្ថុដែលជាកម្មវត្ថុនោះ ភាគីដែលមានសិទ្ធិរំលាយ គ្មានករណីកិច្ចក្នុងការសងជាប្រាក់នូវតម្លៃនៃវត្ថុនោះឡើយ”

ដោយហេតុថា ប្រធានសក្តិ គឺហួសពីសមត្ថភាព ឬអលទ្ធភាពក្នុងការអនុវត្ត គឺជាករណីដែលនឹងត្រូវបកស្រាយតែដោយចៅក្រមប៉ុណ្ណោះ ដូច្នេះ ភាគីទាំងពីរត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីព្រឹត្តិការណ៍ហួសពីការគ្រប់គ្រង។ បន្ទាប់មក វាជាការសំខាន់ដែលត្រូវយល់អំពីស្ថានភាពហួសពីការគ្រប់គ្រង ដូចជា (ក) ការទទួលស្គាល់តាមផ្លូវច្បាប់ (ខ) និងផលវិបាកមកលើកិច្ចសន្យា។

#### ក) ឧទាហរណ៍នៃ “ព្រឹត្តិការណ៍ហួសពីការគ្រប់គ្រង”

បន្ទាប់ពីចុះកិច្ចសន្យាផលិតកម្មកសិកម្ម ការអនុវត្តអាចរងការប៉ះពាល់ដោយព្រឹត្តិការណ៍ដែលហួសពីការគ្រប់គ្រងដោយភាគីទាំងពីរ ដោយសារកត្តាខាងក្រៅបានប៉ះពាល់លើលទ្ធភាពរបស់អ្នកផលិតក្នុងការបំពេញកាតព្វកិច្ច។ ព្រឹត្តិការណ៍សាមញ្ញៗ មានដូចជា ៖

**ព្រឹត្តិការណ៍ធម្មជាតិ** ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត គ្រោះអគ្គិភ័យ រញ្ជួយដី ការប្រែប្រួលអាកាសធាតុភ្លាមៗ ការឡើងកម្តៅយ៉ាងចម្លែក ឬចុះកម្តៅយ៉ាងចម្លែក សត្វល្អិត មេរោគបំផ្លាញដំណាំ ជំងឺរាតត្បាត ឬសត្វល្អិតចង្រៃវាយប្រហារមកលើសត្វ ទាំងនោះសុទ្ធជាព្រឹត្តិការណ៍ដែលអាចបំផ្លាញ ទំនិញមួយផ្នែក ឬទាំងស្រុង។ នៅក្នុងន័យនេះ ការប្រែប្រួលអាកាសធាតុអាចជាកត្តាច្បាស់លាស់ ដែលប៉ះពាល់ដល់សមត្ថភាពគ្រប់គ្រង។

**កត្តាផ្សេងទៀត៖** កត្តាដែលមានឥទ្ធិពលមកលើសមត្ថភាពរបស់ភាគីក្នុងការអនុវត្តកិច្ចសន្យាមាន ៖

- ការផ្លាស់ប្តូរច្បាប់ ឬគោលនយោបាយលើវិស័យកសិកម្ម បរិស្ថាន សុខាភិបាល ដែលអនុវត្តជាទូទៅមកលើថ្នាក់ជាតិ និងអន្តរជាតិ
- កុប្បកម្ម បដិវត្ត ការបះបោរ ឬជម្លោះប្រដាប់អាវុធ
- ព្រឹត្តិការណ៍សង្គមដូចជា កូដកម្ម វិធានការរបស់សហជីពពលកម្ម ឬសេចក្តីសម្រេចដែលប៉ះពាល់ដល់ដំណើរការផលិតកម្ម ឬការដឹកជញ្ជូន និងទីកន្លែងរក្សាទុក
- សេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការហាមឃាត់ការនាំចេញផលិតផលកសិកម្មណាមួយ
- ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចលើប្រទេសណាមួយ
- កូដកម្មនៅក្នុងឧស្សាហកម្មប្រាស្រ័យទាក់ទង ឬដឹកជញ្ជូន
- ការលប់បំបាត់ភ្លាមៗលើរូបិយប័ណ្ណ ឬការបង្កកការផ្ទេរប្រាក់ ...

### ខ) ការទទួលតាមផ្លូវច្បាប់ចំពោះ "ព្រឹត្តិការណ៍ដែលហួសពីការគ្រប់គ្រង"

ទោះពាក្យថា "ប្រធានសក្តិ" ត្រូវបានប្រើប្រាស់នៅក្នុងច្បាប់កម្ពុជា រួមទាំងក្រមរដ្ឋប្បវេណី ប៉ុន្តែមិនមាននិយមន័យតាមផ្លូវច្បាប់នៃព្រឹត្តិការណ៍ "ប្រធានសក្តិ" ទេ ។

តាមច្បាប់បារាំង ក្រមរដ្ឋប្បវេណី បញ្ជាក់អំពីការខូចខាតដែលមិនមែនដោយសារករណីប្រធានសក្តិថា "មិនមានកន្លែងសម្រាប់ការខូចខាតទេ នៅពេល កូនបំណុលត្រូវបានរារាំងពីការផ្តល់ ឬបំពេញកាតព្វកិច្ចដោយសារករណីប្រធានសក្តិ ឬកាលៈទេសៈដែលមិនអាចព្យាករទុកមុនបាន ហើយកូនបំណុលត្រូវបានរារាំងពីការផ្តល់ ឬបំពេញកាតព្វកិច្ចដែលត្រូវបំពេញ ឬត្រូវបានហាមធ្វើ"[18]។

ប្រធានសក្តិគឺជាគោលគំនិតផ្នែកច្បាប់។ វាប៉ាន់ប្រមាណទៅលើវិសាលភាពនៃការគ្រប់គ្រងនៃតុលាការក្នុងការបង្កើតករណី មានន័យថា ចៅក្រមមានការទទួលខុសត្រូវក្នុងការបញ្ជាក់ថា ព្រឹត្តិការណ៍មួយជាករណីប្រធានសក្តិ [19] ដែលកំណត់អត្ថន័យពាក្យប្រធានសក្តិ ថាជាព្រឹត្តិការណ៍ ដែលមានលក្ខខណ្ឌដូចខាងក្រោម ៖

- ព្រឹត្តិការណ៍ដែល "**មិនអាចទប់ទល់បាន**"៖ នេះបញ្ជាក់ច្បាស់លាស់អំពីការខុសគ្នាពីប្រធានសក្តិ និងការមិនអាចទស្សន៍ទាយទុកមុនបាន។ ប្រសិនបើព្រឹត្តិការណ៍ គ្រាន់តែពិបាកអនុវត្តកិច្ចសន្យា ឬកាន់តែចំណាយច្រើនជាងមុន នោះកាតព្វកិច្ចនៅតែត្រូវអនុវត្តតាមដដែល និង
- ព្រឹត្តិការណ៍ដែល " **ពុំអាចយកឈ្នះបាន**" ៖ ព្រឹត្តិការណ៍ដែលមិនអាចទស្សន៍ទាយទុកមុនបាន និងមិនអាចជៀសផុត និង
- ព្រឹត្តិការណ៍ជា " **កត្តាខាងក្រៅ**" ៖ ព្រឹត្តិការណ៍ត្រូវតែហួសពីសមត្ថភាពគ្រប់គ្រងរបស់កូនបំណុល។

---

[18] ក្រមរដ្ឋប្បវេណីបារាំង ប្រការ ១១៤៨ ការបកប្រែក្រៅផ្លូវការ

[19] Cass. civ ២ , ១១ juillet ២០០២.

នៅប្រទេសកម្ពុជា ច្បាប់ករណី មិនទាន់បានចេញផ្សាយនៅឡើយ ដូច្នេះ ភាគីទាំងពីរគប្បីកំណត់នៅក្នុងកិច្ចសន្យា និងបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអ្វីជាព្រឹត្តិការណ៍ហួសពីការគ្រប់គ្រង។ ភាគីទាំងពីរក៏គួរបញ្ជាក់ថា ការរៀបរាប់ក្នុងកិច្ចសន្យា គ្រាន់តែជាឧទាហរណ៍ខ្លះតែប៉ុណ្ណោះ "ដូចជា" "ការរំលេញចេញខ្លះៗ ក្នុងចំណោមព្រឹត្តិការណ៍ ជាច្រើនទៀត " " រួមមាន មួយចំនួនដូចជា " ឬដោយគ្រាន់តែបន្ថែមពាក្យ "ជាដើម" ឬដោយបន្ថែមការបរិយាយដើម្បីសង្កត់ធ្ងន់ថា មិនទាន់បានរៀបរាប់អស់នៅឡើយ។

ក្នុងការអនុវត្តន៍ជាក់ស្តែងភាគច្រើន "ព្រឹត្តិការណ៍ដែលហួសពីសមត្ថភាពគ្រប់គ្រង" អាចទទួលស្គាល់ដោយភាគីទាំងពីរ (និង បើអាចមានវត្តមានអាជ្ញាធររដ្ឋបាល) និងផលវិបាកមកលើកាតព្វកិច្ចរបស់ភាគីនីមួយៗ អាចទទួលយកជាផ្លូវការ និងដោយការយោគយល់គ្នា នៅក្នុងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា រវាងភាគីទាំងពីរ នៅពេលស្ថានភាពកើតឡើង (ភាគីនីមួយៗ នៅលើច្បាប់ដើម + សេចក្តីចម្លងផ្សេងទៀតសម្រាប់ស្ថាប័នពាក់ព័ន្ធ ក្នុងត្រួតពិនិត្យមើលការអនុវត្តកិច្ចសន្យា ដូចជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ នាយកដ្ឋានកសិ-ឧស្សាហកម្ម )។ នៅក្នុងផ្នែកទី ៥ នៃឯកសារនេះ គោលការណ៍ណែនាំជាក់ស្តែង ត្រូវបានផ្តល់ជាយោបល់សម្រាប់ស្ថានភាពទាំងនោះ ដូចជានៅក្នុងការពន្យល់បន្ថែម ៥.១.ខ. ទំព័រ ១១៨ ៖ "ឧទាហរណ៍នៃទម្រង់របាយការណ៍សម្រាប់ការប៉ាន់ប្រមាណលើការខូចខាត និងការឲ្យរួចខ្លួនចំពោះកាតព្វកិច្ចរបស់ភាគីអ្នកផលិត"។

### គ) ផលវិបាកនៃការទទួលស្គាល់ព្រឹត្តិការណ៍ហួសពីសមត្ថភាពគ្រប់គ្រង

ផលវិបាកដែលអាចកើតមានចំពោះការទទួលស្គាល់ព្រឹត្តិការណ៍ហួសពីសមត្ថភាពគ្រប់គ្រង មានដូចខាងក្រោម ៖

- ការអនុគ្រោះចំពោះការមិនអនុវត្តន៍កាតព្វកិច្ច៖ កត្តាសំខាន់ដែលត្រូវពិចារណាចំពោះករណីប្រធានសក្តិគឺ គួរឆ្លុះបញ្ចាំងអំពីការប៉ះពាល់ទៅលើការអនុវត្តន៍កាតព្វកិច្ចរបស់ភាគីទាំងពីរ មុនពេលអនុវត្តប្រការនេះ។ កិច្ចសន្យា ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីករណីដែលចាត់ទុកថា មិនអាចអនុវត្តកាតព្វកិច្ចបាន។ តាមការពិត ការទទួលស្គាល់អំពីករណីប្រធានសក្តិ គឺជាការលើកលែងពីការជាប់ពិរុទ្ធភាពរបស់ភាគី ដែលមិនអនុវត្តកាតព្វកិច្ច ហើយវាមិនយុត្តិធម៌ទេ ដែលត្រូវឲ្យភាគីនោះទទួលខុសត្រូវ ចំពោះកាតព្វកិច្ចដែលមិនអាចអនុវត្តបាន។ គួរកត់សម្គាល់ថា ប្រសិនបើប្រការនេះយល់ថាករណីប្រធានសក្តិគឺទូទៅពេក ហើយមិនមានការពន្យល់បន្ថែមអំពីការទទួលខុសត្រូវរបស់គូភាគី គេគួរបកស្រាយស្របទៅតាមច្បាប់រដ្ឋប្បវេណីកម្ពុជា។ ការវិភាគបានបង្ហាញថា ការមិនដាក់បញ្ចូលប្រការនេះទៅក្នុងកិច្ចសន្យា ដោយគេយល់ឃើញថា វាកម្រកើតមាន នៅក្នុងបរិបទនៃកិច្ចសន្យាពាណិជ្ជកម្ម។

- ការព្យួរកាតព្វកិច្ច៖ គូភាគីអាចចង់រក្សាទំនាក់ទំនង ទោះជួបស្ថានភាពលំបាក និងចង់បំពេញកាតព្វកិច្ច ជាជាងការរកហេតុផល។ ដូច្នេះ កិច្ចសន្យា គួរបញ្ជាក់អំពីការផ្អាកអនុវត្តកាតព្វកិច្ច គ្រាន់

តែជាបណ្តោះអាសន្ន ក្នុងមួយរយៈពេលប៉ុណ្ណោះ។ កិច្ចសន្យាអាចបញ្ជាក់លម្អិតអំពីការពន្យាពេលបណ្តោះអាសន្ន ដូចជា ៖គូភាគីគួរបញ្ជាក់អំពីការពន្យាពេល ដើម្បីជៀសវាងភាពមិនច្បាស់លាស់នៅក្នុងការបកស្រាយលើកិច្ចសន្យា។

- ការបញ្ចប់កិច្ចសន្យាក្រោយរយៈពេលផ្អាក៖ កិច្ចសន្យាអាចផ្តល់ទៅតែភាគីមួយឬពីរប៉ុណ្ណោះ នៅពេលបញ្ចប់កិច្ចសន្យា អាស្រ័យទៅតាមករណីប្រធានសក្តិ។ សិទ្ធិនេះអាចកើតមានបន្ទាប់ពីការផុតរលត់ទៅនៃរយៈពេល ផ្អាក ឬភ្លាមៗប្រសិនបើ ការអនុវត្តការងារមិនអាចធ្វើបាន។ កិច្ចសន្យាអាចរៀបរាប់អំពីព្រឹត្តិការណ៍ដែលអនុញ្ញាតឲ្យមានការបញ្ចប់កិច្ចសន្យាដោយស្វ័យប្រវត្តិ និងអលទ្ធភាពក្នុងការអនុវត្តបានដោយសារករណីប្រធានសក្តិ។

ក្រោយពេលកំណត់និយមន័យនៃព្រឹត្តិការណ៍ដែលហួសពីសមត្ថភាពគ្រប់គ្រង កិច្ចសន្យាគួរបញ្ជាក់អំពីវិធានការដែលនឹងត្រូវអនុវត្ត ក្នុងករណីប្រធានសក្តិកើតឡើង ដូចជា ៖

➡ ការបញ្ចប់កិច្ចសន្យា

➡ ការផ្អាក ឬការពន្យាពេលបន្ថែមក្នុងការអនុវត្តកិច្ចសន្យា។

## ៤.១០.២. ការផ្លាស់ប្តូរស្ថានភាពដែលលែងអាចអនុវត្តកាតព្វកិច្ចបាន

ដើម្បីជៀសវាងការបកស្រាយខុសគ្នា និងទំនាស់នៅពេលមានការប្រែប្រួលស្ថានភាព ភាគីទាំងពីរគួរយល់ឲ្យច្បាស់អំពីការទទួលស្គាល់ផ្នែកច្បាប់ (ក) និងផលវិបាកមកលើកិច្ចសន្យា (ក)។

### ក) ការទទួលស្គាល់ផ្នែកច្បាប់លើការប្រែប្រួលស្ថានភាព

ការប្រែប្រួលស្ថានភាពមិនមែនមានន័យថា ត្រូវឈប់អនុវត្តកាតព្វកិច្ចទេ ប៉ុន្តែប្រសិនបើវាកែប្រែទាំងស្រុង និងផ្លាស់ប្តូរតុល្យភាពនៃទំនាក់ទំនងរបស់គូភាគី ជាធម្មតា វាអាចធ្វើឲ្យមានហេតុផលសម្រាប់ការមិនអនុវត្តកាតព្វកិច្ច។ ទោះយ៉ាងណា វាអាចមានការប្រែប្រួល និងបង្កឲ្យមានមូលហេតុដើម្បីមិនអាចអនុវត្តកាតព្វកិច្ចបាន ហើយក៏នឹងប៉ះពាល់ដល់របបផ្នែកច្បាប់ ដោយសារតែករណីប្រធានសក្តិ ដែលជាការផ្តល់សិទ្ធិដល់ភាគីមួយក្នុងការបញ្ចប់កិច្ចសន្យា ឬ ស្តារតុល្យភាពសមស្របនៃកិច្ចសន្យា តាមរយៈការប្រគល់កាតព្វកិច្ច ឬ ប្រគល់សិទ្ធិក្នុងការចរចាឡើងវិញ លើលក្ខខណ្ឌនៃកិច្ចសន្យា ឬ អាចកែសម្រួលកិច្ចសន្យាទៅតាមស្ថានភាពជាក់ស្តែង។ ភាគីទាំងពីរគួរប្រមើលមើលអំពីផលវិបាកនៃករណីប្រធានសក្តិ និងកែសម្រួលកិច្ចសន្យាឡើងវិញ។ ប្រការនេះ មិនមែនជាការរារាំងការអនុវត្តកាតព្វកិច្ចរបស់គូភាគីទេ ប៉ុន្តែវាគ្រាន់តែជាសិទ្ធិ ឬ ករណីដែលអាចចរចាឡើងវិញលើលក្ខខណ្ឌខ្លះៗនៃកិច្ចសន្យា ដើម្បីស្របទៅតាមព្រឹត្តិការណ៍។

### ខ) ផលវិបាកនៃការទទួលផ្នែកច្បាប់ចំពោះការប្រែប្រួលស្ថានភាព

ព្រឹត្តិការណ៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាការផ្លាស់ប្តូរស្ថានភាព មិនមែនមានន័យថា មានហេតុផលសម្រាប់ការមិនអនុវត្តកាតព្វកិច្ចទេ ដោយហេតុថា ប្រធានសក្តិមិននាំឲ្យមានសិទ្ធិចរចាឡើងវិញ ឬ បញ្ចប់កិច្ចសន្យាឡើយ។

- **សិទ្ធិឬភារកិច្ចដើម្បីចរចាឡើងវិញ៖** បណ្តាភាគីប្រហែលនៅតែមានបំណងបន្តទំនាក់ទំនង ទោះមានស្ថានភាពដែលមិនរំពឹងទុក បានកើតឡើង និងរារាំង ឬរឹតត្បិតដល់ការអនុវត្តកាតព្វកិច្ចខ្លះក៏ដោយ។ ដូច្នេះ ប្រការនៃកិច្ចសន្យាដំបូង អាចផ្តល់នូវសិទ្ធិឬភារកិច្ចដើម្បីចរចាឡើងវិញ បន្ទាប់ពីព្រឹត្តិការណ៍ជាក់លាក់បានកើតឡើង។ នេះជាមូលហេតុដែលកិច្ចសន្យាត្រូវមានប្រការស្តីពីស្ថានភាពលើកលែងដែលមិនអាចចាត់ទុកថា មិនអាចអនុវត្តកាតព្វកិច្ចបាន។ ប្រសិនបើមិនមានប្រការដូច្នេះ គូភាគីអាចសម្រេចចិត្តដើម្បីកែសម្រួលកិច្ចព្រមព្រៀងឡើងវិញ ឬធ្វើកិច្ចព្រមព្រៀងបន្ថែម ដោយមានការឯកភាពទាំងអស់គ្នា ដើម្បីដាក់បញ្ចូលបន្ថែម។
- **ការរំលាយកិច្ចសន្យា៖** នៅពេលគូរភាគីចង់ដាក់បញ្ចូលសិទ្ធិដើម្បីចរចា គេក៏គួរតែបញ្ជាក់អំពីផលវិបាកនៃការមិនចរចាគ្នា ដោយមានសេចក្តីទុកចិត្តគ្នា ឬឈានដល់កិច្ចព្រមព្រៀងមួយ ដោយសារការបញ្ចប់កិច្ចសន្យា។

ប្រសិនបើកិច្ចសន្យាមិនមានប្រការស្តីពីភារកិច្ចចរចាឡើងវិញ ឬការបញ្ចប់កិច្ចសន្យា ការឆ្លើយតបក៏អាចនឹងក្លាយជាការមិនយល់ព្រមផ្តល់សំណង នៅពេលស្ថានភាពអលទ្ធភាពក្នុងការអនុវត្តកើតឡើង។

## ៤.១០.៣. ការបង្ការស្ថានភាពអាក្រក់តាមរយៈការបែងចែកហានិភ័យ

កិច្ចសន្យាផលិតកម្មកសិកម្ម គឺងាយរងគ្រោះណាស់ ហើយកាតព្វកិច្ចអាចប្រែទៅជាលែងអាចអនុវត្តបាន ឬ អាចមានបញ្ហាប្រឈមច្រើនជាងការរំពឹងទុក នៅពេលចុះកិច្ចសន្យានេះ។ ការប៉ាន់ស្មានទុកហានិភ័យ គឺជាការសំខាន់សម្រាប់លទ្ធភាពសេដ្ឋកិច្ចនៃការផលិតកសិផល ដែលអាចដោះស្រាយបានតាមរយៈការធានារ៉ាប់រងក្នុងកិច្ចសន្យា (ក) និង / ឬ យន្តការបន្ធូរបន្ថយហានិភ័យ (ខ)។

### ក) ការធានារ៉ាប់រង

សកម្មភាពរបស់អ្នកផលិត គួរតែត្រូវបានធានា ដើម្បីបង្ការពីបរាជ័យ ការធ្លាក់ទៅក្នុងបំណុល ជាពិសេសដោយសារព្រឹត្តិការណ៍ធម្មជាតិ ដែលអាចនាំឲ្យឈានដល់ការក្ស័យធន។ អ្នកផលិតវិនិយោគទៅលើគ្រឿងចក្រ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនឆ្នាំ និងយូរជាងរយៈពេលនៃកិច្ចសន្យាផលិតកម្មកសិកម្ម។ ហេតុនេះ គូភាគី ជាពិសេសអ្នកផលិត អាចឆ្លើយតបទៅនឹងតម្រូវការនេះ តាមរយៈការចុះកិច្ចសន្យាធានាជាឯកជន ដើម្បីទប់ទល់នឹងព្រឹត្តិការណ៍អាក្រក់។

ដោយសារច្បាប់ធានារ៉ាប់រង ជារឿងថ្មីនៅកម្ពុជា [20] ការធានារ៉ាប់រង គឺជារឿងមិនធម្មតាសម្រាប់ប្រជាជនកម្ពុជា។ ភាគីទាំងសងខាងអាចដាក់បញ្ចូលកាតព្វកិច្ចនៃកិច្ចសន្យា ដោយការធានារ៉ាប់រង និងបញ្ជាក់អំពីអ្នកផ្តល់

[20] ច្បាប់ធានារ៉ាប់រងថ្មីនៅកម្ពុជា– ប្រកាសឲ្យប្រើកាលពីថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០១៤ ជំនួសច្បាប់ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០០ និងអនុក្រឹត្យស្តីពីការធានារ៉ាប់រងដែលបានអនុម័តកាលពីថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ដែលនៅចូលជាធរមាន – ផ្តល់នូវការកែប្រែដូចខាងក្រោម ៖ ការការពារ

ធានារ៉ាប់រង និងបញ្ជាក់អំពីប្រភេទនៃការធានារ៉ាប់រង (ដូចជា សម្រាប់ទីកន្លែងណា ដំណាំអ្វី សត្វអ្វី និងការធានាលើការទទួលខុសត្រូវ ឬសុខភាព ឬអាយុជីវិត) ។ កិច្ចសន្យាដែលមានការធានារ៉ាប់រង គឺជាការងារច្បាប់ស្មុគស្មាញ ដូច្នេះ ត្រូវមានការធានា ហើយត្រូវមានលក្ខខណ្ឌធានាអប្បបរិមា ដូចជា ហានិភ័យដែលត្រូវធានា (អគ្គីភ័យ ចោរកម្ម ជំងឺ ព្រិល...)។

ក្នុងន័យនេះ គួរកត់សម្គាល់ថា អ្នកធានារ៉ាប់រងបានចាប់ផ្តើមវិធានការការពារ ដោយការមិនដាក់បញ្ចូលព្រឹត្តិការណ៍ដែលមានអាកាសធាតុអាក្រក់ធ្ងន់ធ្ងរ ដើម្បីការពារអាជីវកម្មរបស់គេ ពីការខូចខាតដោយសារអាកាសធាតុដែលមិនអាចមើលឃើញ ដែលជាស្ថានភាពកើតឡើងកាន់តែញឹកញាប់ដោយសារការប្រែប្រួលអាកាសធាតុពិភពលោក។ គូភាគីត្រូវប្រុងប្រយ័ត្ន នៅពេលធ្វើកិច្ចសន្យាធានារ៉ាប់រងចំពោះបញ្ហានេះ។

បច្ចុប្បន្ន អនុសាសន៍ស្តីពីការធានារ៉ាប់រងលើហានិភ័យ ដោយកិច្ចសន្យាធានារ៉ាប់រង គឺពិបាកអនុវត្តសម្រាប់អ្នកផលិត ដោយសារមិនមាន (ឬខ្វះ) សេវាកម្មធានារ៉ាប់រងលើដំណាំនៅក្នុងប្រទេសកម្ពុជា។

សន្ទស្សន៍នៃការធានារ៉ាប់រងលើដំណាំ គឺទើបតែចាប់ផ្តើមសាកល្បងនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែវាអាចនឹងកាន់តែមានច្រើននៅឆ្នាំខាងមុខ។ នៅពេលសេវាកម្មនេះមានកាន់តែច្រើន គូភាគីគួរពិចារណាដាក់បញ្ចូលសេវាធានារ៉ាប់រងទាំងនោះ ទៅជាផ្នែកមួយនៃកិច្ចសន្យា។

### ខ) យន្តការបន្ធូរបន្ថយហានិភ័យ

គូរភាគីអាចសម្របសម្រួលនូវយន្តការបន្ធូរបន្ថយហានិភ័យ ដោយការដាក់បញ្ចូលការកែសម្រួលទៅតាមពេលវេលា ឬ ការកែសម្រួលប្រការនៅក្នុងកិច្ចសន្យារបស់ពួកគេ។ នៅពេលភាគីព្រាងកិច្ចសន្យា និងដាក់បញ្ចូលកាតព្វកិច្ច ពួកគេគួរបែងចែកហានិភ័យដែលនឹងធ្លាក់ទៅលើភាគីតែមួយ។ ហានិភ័យសំខាន់ដែលភាគីអាចជួបប្រទះ នៅពេលអនុវត្តកិច្ចសន្យា ត្រូវបានបែងចែកចេញជាពីរប្រភេទ៖

- **" ហានិភ័យនៃការផលិត"** គឺជាហានិភ័យនៃការបាត់បង់ឬខ្វះក្នុងផលិតកម្ម ដោយសារព្រឹត្តិការណ៍ដែលបានរំពឹង ឬដែលមិនបានរំពឹងទុក ដែលបានកើតឡើងក្នុងពេលផលិត។ ជាធម្មតា កិច្ចសន្យានឹងមានប្រការដែលបញ្ជាក់អំពីភាគីដែលទទួលបន្ទុកលើហានិភ័យនៃការខាតបង់ និងភាគីដែលធានាលើបរិមាណចាំបាច់សម្រាប់បំពេញលក្ខខណ្ឌនៃកិច្ចសន្យា។
- "**ហានិភ័យពាណិជ្ជកម្ម**" គឺជាហានិភ័យនៃតម្លៃទីផ្សាររបស់កសិផលនៅពេលប្រគល់ទំនិញ ឬ ទីផ្សារអាចមានតម្លៃទាបឬខ្ពស់ជាងការរំពឹងទុករបស់គូភាគី នៅពេលកំណត់តម្លៃ ឬ រូបមន្ត សម្រាប់គណនាហើយបន្ទាប់មក មិនអាចរកបានចំណូលដូចការរំពឹងទុក។ គួរកត់សម្គាល់ថា ទឹកចិត្តមួយនៃការចុះកិច្ចសន្យាផលិតកម្មកសិកម្ម គឺសម្រាប់អ្នកទិញដែលត្រូវគ្រប់គ្រងហានិភ័យពាណិជ្ជកម្ម ដោយយល់ព្រមទៅលើតម្លៃថេរមួយ ទៅតាមរូបមន្តដែលបានគណនាតម្លៃទុកមុន។ នេះនឹងការពារអ្នកផលិតពីការឡើងចុះតម្លៃ និងការអនុលោមទៅតាមបរិមាណ គុណភាព ស្តង់ដារផលិតដែលបានកំណត់ទុកមុនដែលកាត់បន្ថយដល់ការមិនទទួលទិញផលិតផល ដោយអតិថិជនគោលដៅក្នុងខ្សែសង្វាក់តម្លៃ។

---

កាន់តែល្អសម្រាប់អ្នកអនុវត្តគោលនយោបាយ ដែលជាការគ្រប់គ្រងកាន់តែច្រើនឡើងសម្រាប់អង្គបញ្ញត្តិករ, ក្រុមហ៊ុនដោះស្រាយវិវាទ និងការលក់ទ្រព្យសកម្មរបស់ក្រុមហ៊ុន និងដំណើរការរំលាយក្រុមហ៊ុននិងបទបញ្ញត្តិកាន់តែច្បាស់លាស់សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងដើម្បីប្រតិបត្តិការនៅកម្ពុជា។

ហានិភ័យពាណិជ្ជកម្ម ត្រូវបានគ្រប់គ្រង និងបន្ធូរបន្ថយតាមរយៈយន្តការកំណត់តម្លៃ ដែលបានចែង នៅក្នុងកិច្ចសន្យា។ ជាការពិតណាស់ ប្រសិនបើគូភាគីអាចធ្វើផែនការបានកាន់តែច្រើន អំពីយន្តការ ដើម្បីការពារកិច្ចសន្យា សំដៅការពារប្រយោជន៍ទៅវិញទៅមក ទោះតម្លៃឡើងចុះ នោះគូភាគីនឹងកាន់ តែអាចរក្សាបានទំនាក់ទំនងកិច្ចសន្យាកាន់តែយូរអង្វែង។

**គួរតែកត់សម្គាល់ផងដែរថា និយមន័យនៃកម្រិតប្រែប្រួលនៃបរិមាណផលិតផលដែលត្រូវប្រគល់ (ជាជាង បរិមាណថេរ) ក៏គួរពិចារណា (តាមលទ្ធភាព) ដើម្បីបន្ធូរបន្ថយហានិភ័យ និងការប្រែប្រួលបរិមាណ ផលិតផល (ផ្នែក ៤.៣.២. ទំព័រ ៥៨)។**

## ៤.១១. រយៈពេល ការបន្ត និងការបញ្ចប់កិច្ចសន្យា

បញ្ហានៃរយៈពេលកិច្ចសន្យា (សូមមើលផ្នែក ៤.១១.១. ខាងក្រោម),ការបញ្ចប់កិច្ចសន្យា (ផ្នែក ៤.១១.២. ខាងក្រោម) និងការបន្តកិច្ចសន្យា (សូមមើលផ្នែក ៤.១១.៣. ទំព័របន្ទាប់) គឺជាផ្នែកសំខាន់នៅក្នុងកិច្ចសន្យា ផលិតកម្មកសិកម្ម។ ដូច្នេះភាគីទាំងពីរ ត្រូវដឹងថាទំនាក់ទំនងក្នុងកិច្ចសន្យា ចាប់ផ្តើមនៅពេលណា និងបញ្ចប់ នៅពេលណា។

### ៤.១១.១. រយៈពេលនៃកិច្ចសន្យា

ប្រការស្តីពីរយៈពេលនៃកិច្ចសន្យា គឺជាការអនុវត្តន៍សាមញ្ញក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម។ ដើម្បីកំណត់រយៈ ពេលនៃកិច្ចសន្យា ភាគីទាំងពីរត្រូវពិចារណាលើវដ្តផលិតកម្មនៃទំនិញ និងកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ។ រយៈពេល គឺសំខាន់ណាស់ សម្រាប់អ្នកផលិតដើម្បីសម្រេចគោលដៅផលិត ដែលបានវិនិយោគជាយូរមកហើយ ដូចជា ការទិញគ្រឿងចក្រ ការសាងសង់អគារ និងកន្លែងថ្មីៗ។ បន្ទាប់មក ដើម្បីបានចំណេញផ្នែកសេដ្ឋកិច្ច ការវិនិយោគ ទាំងនោះត្រូវមានទំនាក់ទំនងយូរអង្វែងក្នុងកិច្ចសន្យា រវាងអ្នកផលិត និងអ្នកទិញ។ មូលហេតុនៃការជ្រើសរើស យកជម្រើសណាមួយ គឺអាស្រ័យទៅលើលក្ខណៈនៃផលិតផលកសិកម្ម និងឆន្ទៈរបស់គូភាគី។ ប្រការស្តីពី រយៈពេល អាចព្រាងតាមច្រើនវិធី៖ អាចជាទម្រង់រយៈពេលខ្លី និងរយៈពេលវែង៖

- **កិច្ចសន្យារយៈពេលខ្លី គឺមានរយៈពេលគិតជាខែ និងយោងតាមរដូវនៃដំណាំ។ កិច្ចសន្យាសម្រាប់ ដំណាំរយៈពេលខ្លីមានដូចជា បន្លែ និងដំណាំតាមចំការ ដែលអាចមានរយៈពេលតាមរដូវកាល។ ឧទាហរណ៍ កិច្ចសន្យាដាំពោត (ដំណាំប្រចាំឆ្នាំ) គឺកំណត់ត្រឹមតែមួយឆ្នាំ (លើកលែងតែកំណត់ផ្ទុយ ពីនេះ)។**
- **កិច្ចសន្យារយៈពេលវែងតែងកំណត់រយៈពេលច្រើនឆ្នាំ ឬ មិនកំណត់ពេលបញ្ចប់កិច្ចសន្យា។** ឧទាហរណ៍ កិច្ចសន្យាស្តីពីកាតព្វកិច្ចហិរញ្ញវត្ថុចំនួនច្រើននៅលើភាគីមួយ (ជាទូទៅសម្រាប់អ្នកផលិត) អាចធ្វើឲ្យមានទំនាក់ទំនងយូរអង្វែង និងអាចបន្តនៅក្រោយពេលបានទិញរួច។ គួរកត់សម្គាល់ថា កិច្ចសន្យា ផលិតកម្មកសិកម្មរយៈពេលវែង មានរយៈពេលវែងដោយសារការទុកចិត្ត និងទំនុកចិត្តចំពោះគ្នាទៅវិញ ទៅមក ហើយមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ដើម្បីសហការ និងអនុញ្ញាតឲ្យភាគីនីមួយៗ អនុវត្ត កាតព្វកិច្ចបានសមរម្យ។

## ៤.១១.២ ការបន្តកិច្ចសន្យា

នៅពេលផុតកំណត់កិច្ចសន្យារយៈពេលមានកំណត់ គូភាគីនឹងអាចបន្តកិច្ចសន្យា។ ការបន្តកិច្ចសន្យាអាចមានទម្រង់ផ្សេងៗគ្នា៖ កិច្ចសន្យាដដែលទាំងស្រុង (ក) ឬ កិច្ចសន្យាបន្តបន្ថែមទៅលើកិច្ចសន្យាដំបូង (ខ)។

### ក) ការបន្តដោយការរក្សាកិច្ចសន្យាដដែលទាំងស្រុង

គូភាគីអាចធ្វើផែនការថា កិច្ចសន្យាអាចបន្តដោយការយល់ព្រមបន្តជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាបញ្ចប់នៅកាលបរិច្ឆេទបានកំណត់ស្រាប់ លើកលែងតែគូរភាគីយល់ព្រមបន្តមុនពេលកិច្ចសន្យានេះ ផុតកំណត់។

**ប្រសិនបើបានបន្ត កិច្ចសន្យានេះត្រូវបន្តតាមលក្ខខណ្ឌ"ចាស់" ដដែល ប៉ុន្តែគូរភាគី អាចធ្វើការចរចាដើម្បីធ្វើវិសោធនកម្មលើចំណុចពាក់ព័ន្ធណាមួយ មុនពេលផុតកំណត់។**

> ការពន្យល់បន្ថែម ៤.១១.ក
>
> ផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមរដូវកាល ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រុមហ៊ុន AMRU Rice (Cambodia) និងសហគមន៍កសិកម្មនៅខេត្តព្រះវិហារ
>
> ក្នុងករណីកិច្ចសន្យាផលិតកម្មកសិកម្មរវាង AMRU Rice (Cambodia) Co. Ltd និងសហគមន៍កសិករក្នុងខេត្តព្រះវិហារ (ដូចមានរៀបរាប់នៅក្នុងការពន្យល់បន្ថែម ២.១.គ ទំព័រ ២២), កិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវបានចុះហត្ថលេខាសម្រាប់តែមួយរដូវ ហើយចរចាឡើងវិញជាប្រចាំឆ្នាំ ប៉ុន្តែភាគីទាំងពីរមានបំណងកសាងទំនាក់ទំនងរយៈពេលយូរអង្វែង ហើយគោលការណ៍ចម្បងនៃទំនាក់ទំនងរយៈពេលវែងនេះ ត្រូវបានកំណត់នៅក្នុងអនុស្សារណៈនៃការយោគយល់គ្នា ច្រើនឆ្នាំ ចុះហត្ថលេខាដោយភាគីទាំងពីរ។
>
> ក្នុងករណីនេះ វាជាដំណោះស្រាយល្អ ដើម្បីមានទំនុកចិត្តគ្រប់គ្រាន់ជាមួយគ្នា សម្រាប់ភាគីទាំងពីរ ចូលរួមវិនិយោគលើភាពជាដៃគូរយៈពេលវែង ទោះលក្ខខណ្ឌលម្អិតនៃកិច្ចសន្យា អាចកែសម្រួលពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ ដើម្បីសម្របតាមទីផ្សារ ស្ថានភាពអ្នកផលិត និងមេរៀនជាក់ស្តែងបន្ទាប់ពីការអនុវត្តនៃឆ្នាំកន្លងទៅ។

### ខ) កិច្ចសន្យាបន្តបន្ថែមទៅលើកិច្ចសន្យាដំបូង

កិច្ចសន្យាផលិតកម្មកសិកម្មក៏ត្រូវធ្វើវិសោធនកម្មឡើងវិញ ប្រសិនបើភាគីទាំងពីរ មិនបានសម្រេចគោលដៅក្នុងរយៈកន្លងទៅ។

ក្នុងករណីបន្តកិច្ចសន្យាចាស់ ច្រើនឆ្នាំ អ្នកផលិតអាចជឿជាក់ថា ទំនាក់ទំនងក្នុងកិច្ចសន្យាជាមួយអ្នកទិញក្លាយជាទំនាក់ទំនងរយៈពេលវែង។ ដូច្នេះ ដោយសារមានទុកចិត្តគ្នាល្អ និងដោយសារមិនមានឥរិយាបទប្រែប្រួល អ្នកទិញអាចមិនបញ្ចប់កិច្ចសន្យាភ្លាមៗទេ ហើយក៏តែងទុកពេលវេលាសមរម្យមុននឹងបញ្ចប់កិច្ចសន្យាមុនឈានដល់ថ្ងៃផុតកំណត់។ រយៈពេលជូនដំណឹងសមរម្យគឺអាស្រ័យទៅលើរយៈពេលនៃកិច្ចសន្យា ជាពិសេសពាក់ព័ន្ធនឹងផលិតកម្មកសិកម្ម និងការវិនិយោគជាក់លាក់របស់អ្នកផលិត។

ប្រសិនបើកិច្ចសន្យាធ្វើតែមួយរយៈពេល (ដូចជាមួយរដូវម្តង) គេគួរសរសេរឲ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យា និងបញ្ជាក់ថា "កិច្ចសន្យាអាចបន្តបានលុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរ" ដើម្បីជៀសវាងការបកស្រាយលើការបន្តកិច្ចសន្យាថ្មីលើកិច្ចសន្យាចាស់។

## ៤.១១.៣. ការបញ្ចប់កិច្ចសន្យា

កិច្ចសន្យាផលិតកម្មកសិកម្ម ក៏អាចដកកាតព្វកិច្ចរបស់គូរភាគីចេញពីកិច្ចសន្យាដែរ ប៉ុន្តែសិទ្ធិដែលត្រូវបំពេញជាបន្ត នៅតែបន្ត (ការទាមទារការខូចខាត ការដោះស្រាយវិវាទ...) ព្រមទាំងប្រការជាក់លាក់ផ្សេងទៀត ដែលតម្រូវឲ្យភាគីទាំងពីរជាប់កាតព្វកិច្ច ទោះកិច្ចសន្យានេះ បានបញ្ចប់ទៅហើយ និងបានប្រគល់គ្រាប់ពូជ និងដំណាំហើយក៏ដោយ។ ប្រការផ្សេងទៀត ដែលពាក់ព័ន្ធនឹងការរក្សាការសម្ងាត់ ក៏ជាប្រការមិនមានទីបញ្ចប់ដែរ ឬ ក៏ត្រូវបន្ថែមប្រការស្តីពីការរក្សាការសម្ងាត់។ ការបញ្ចប់កិច្ចសន្យា អាចកើតឡើងជាធម្មតា (ក) ដូចដែលបានកំណត់ដោយគូភាគី ឬ ដោយមុនកំណត់ (ខ)[21]។

### ក) ការបញ្ចប់ធម្មតា

**ការបញ្ចប់ដោយស្វ័យប្រវត្តិ៖** កិច្ចសន្យាដែលមានរយៈពេលមានកំណត់ បញ្ចប់ដោយស្វ័យប្រវត្តិ និងដោយមិនមានការជូនដំណឹងជាមុន នៅកាលបរិច្ឆេទដែលបានចែងក្នុងកិច្ចសន្យា។ គូភាគីក៏អាចបញ្ចប់នៅពេលបានបញ្ចប់កាតព្វកិច្ចក្នុងកិច្ចសន្យា។

**ការបញ្ចប់ដោយមានការជូនដំណឹង៖** កិច្ចសន្យារវាងគូរភាគី ដែលបញ្ចប់កាតព្វកិច្ចរៀងខ្លួន អាចបញ្ចប់ទំនាក់ទំនងក្នុងកិច្ចសន្យា។ ដើម្បីមានភាពច្បាស់លាស់ នៅក្នុងកិច្ចសន្យា គេអាចបញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន និងលក្ខខណ្ឌនៃនីតិវិធី សម្រាប់ការបញ្ចប់កិច្ចសន្យា។ ជាធម្មតា គូរភាគីបញ្ជាក់អំពីរយៈពេលជាក់លាក់ដែលត្រូវជូនដំណឹងទុកជាមុន ក្នុងករណីដែលកិច្ចសន្យា មិនមានកំណត់រយៈពេល ដូច្នេះគេអាចជូនដំណឹងដើម្បីបញ្ចប់កិច្ចសន្យា មុនដល់ថ្ងៃផុតកំណត់។ បន្ទាប់មក ភាគីដែលមានបំណងបញ្ចប់កិច្ចសន្យា ត្រូវជូនដំណឹងទៅភាគីម្ខាងទៀត។ ដើម្បីឲ្យមានប្រសិទ្ធភាព ការជូនដំណឹងក៏ត្រូវបំពេញតាមលក្ខខណ្ឌខ្លះៗ ដូចនៅក្នុងទម្រង់។ ជាទូទៅ ការជូនដំណឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយពេលខ្លះត្រូវមានសំបុត្របដិសិទ្ធិ ឬ សាលាក្រមតុលាការ។ ការជូនដំណឹង គឺត្រូវការជាពិសេស ហើយប្រសិនបើកិច្ចសន្យាមានរយៈពេលកាន់តែវែង ការជូនដំណឹងក៏ត្រូវធ្វើឡើងជាមុនច្រើនថ្ងៃដែរ។

ប្រសិនអ្នកទទួលការជូនដំណឹងមិនជំទាស់នឹងការជូនដំណឹងក្នុងពេលកំណត់ទេ មានន័យថា គេយល់ព្រមចំពោះការជូនដំណឹងបញ្ចប់កិច្ចសន្យា។ ទោះបីជាអ្នកទទួលការជូនដំណឹងជំទាស់ការជូនដំណឹងមិនសមរម្យក៏ដោយ ភាគីបញ្ចប់កិច្ចសន្យានៅតែអាចប្រើទម្រង់មួយផ្សេងទៀតដើម្បីជូនដំណឹង។

[21] ការបញ្ចប់កិច្ចសន្យាដោយកសារវំលោភសេចក្តីទុកចិត្ត (ផ្នែក ៤.១២.) ប្រធានសក្តិ និងការផ្លាស់ប្តូរស្ថានភាព (ផ្នែក ៤.១០.) មិនមានរៀបរាប់នៅក្នុងជំពូកនេះទេ ដោយសារមានការបញ្ជាក់ច្បាស់លាស់ នៅក្នុងជំពូកផ្សេងទៀតនៃសៀវភៅណែនាំនេះ។

### ខ) ការបញ្ចប់កិច្ចសន្យាមុនកាលកំណត់

**ការរំលោភកិច្ចសន្យា៖** នៅពេលភាគីមួយមិនគោរពកិច្ចសន្យា វាជាការរំលោភលើកិច្ចសន្យា ហើយជាហេតុផលសម្រាប់ការបញ្ចប់កិច្ចសន្យា។ ការរំលោភកិច្ចសន្យាអាចបណ្តាលមកពីភាគីមួយមិនបំពេញតាមកាតព្វកិច្ច ឬមិនអនុវត្តបានពេញលេញ។ កិច្ចសន្យាផលិតកម្មកសិកម្មភាគច្រើនមានប្រការដែលអនុញ្ញាតឲ្យគូរភាគីបញ្ចប់កិច្ចសន្យាបាន។ ភាគីទាំងពីរ ឬ ភាគីតែមួយ អាចបញ្ចប់កិច្ចសន្យាបាន។

**ការបាត់បង់ការទុកចិត្ត៖** កិច្ចសន្យាផលិតកម្មកសិកម្ម ជាពិសេសកិច្ចសន្យារយៈពេលវែង អាចមានហានិភ័យនៃការបាត់បង់ការទុកចិត្ត ហើយមិនអាចបន្តកិច្ចសន្យាបាន។ ភាគីទាំងពីរអាចបញ្ចប់កិច្ចសន្យាដោយការបាត់បង់ទំនុកចិត្ត។ គេគួរព្រាងប្រការដែលបញ្ជាក់អំពីការអនុញ្ញាតឲ្យបញ្ចប់កិច្ចសន្យា ដើម្បីជៀសវាងភាពមិនច្បាស់លាស់ និងប្រការសម្រាប់អាកប្បកិរិយាឱកាសនិយម។ ព្រឹត្តិការណ៍ទាំងនោះ អាចរួមមានដូចជា នៅពេលភាគីមួយត្រូវស្ថិតនៅក្រោមការអនុវត្តន៍ដីការតុលាការ ឬ នីតិវិធីនៃការក្ស័យធន។ ប្រការក៏គួរបញ្ជាក់អំពីរបៀបប្រើប្រាស់សិទ្ធិ។

**បញ្ជាក់អំពីព្រឹត្តិការណ៍ឬស្ថានភាពដែលអាចនាំឲ្យឈានដល់ការបញ្ចប់កិច្ចសន្យា (ដូចជា ការមិនអនុវត្តន៍កាតព្វកិច្ចរបស់ភាគីណាមួយ ឬការបាត់បង់ទំនុកចិត្ត ដោយសារ៖ ភាគីមួយស្ថិតនៅក្រោមការអនុវត្តន៍សាលក្រមតុលាការ ឬកំពុងប្រកាសការក្ស័យធន។**

## ៤.១២.ដំណោះស្រាយសម្រាប់ការរំលោភកិច្ចសន្យា

មធ្យោបាយដោះស្រាយគឺការការពារ និងវិធានការផ្លូវច្បាប់ ចែងដោយច្បាប់ និងបទបញ្ញត្តិកិច្ចសន្យា។ ជាទូទៅវិធានការលំនាំដើម មិនអាចធ្វើឲ្យភាគីទាំងឡាយពេញចិត្តទាំងស្រុងឡើយ ដូចនេះ ពួកគាត់នឹងបែរទៅជាបង្កើតមធ្យោបាយដោះស្រាយកិច្ចសន្យាបន្ថែមផ្សេងៗទៀត ដើម្បីការពារផលប្រយោជន៍របស់ភាគីរងគ្រោះនៅពេលភាគីម្ខាងទៀតមិនអនុវត្តតាមមធ្យោបាយដោះស្រាយ ឬ ក្នុងករណីភាគីម្ខាងទៀត មិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួនដែលចែងក្នុងកិច្ចសន្យា។ ភាគីទាំងឡាយ អាចបង្កើតនូវមធ្យោបាយដោះស្រាយផ្សេងៗគ្នា អាស្រ័យលើស្ថានភាពបំពានកិច្ចសន្យា ប្រសិនបើពួកគាត់មិនប្រព្រឹត្តខុសពីច្បាប់អនុវត្តទូទៅ។ នៅពេលមានការបំពានលើកិច្ចសន្យាកើតឡើងដោយសារព្រឹត្តិការណ៍ ដែលហួសពីការគ្រប់គ្រងនោះនឹងមានលេសនៃការមិនអនុវត្តកាតព្វកិច្ចក្នុងកាលៈទេសៈធម្មតា ដូចដែលបានរៀបរាប់ខាងលើរួចហើយនៅក្នុងផ្នែក ៤.១០.១។

នៅក្នុងចំណុចនេះ យើងនឹងផ្តោតសំខាន់លើមធ្យោបាយដោះស្រាយការបំពានលើកិច្ចសន្យាដោយមិនអនុវត្តកាតព្វកិច្ចក្នុងការលៈទេសៈធម្មតា តាមរយៈការបង្ហាញអំពីមធ្យោបាយដោះស្រាយតាមផ្លូវច្បាប់ ដែលចែងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា (ផ្នែកខាងក្រោម ៤.១២.១) និងបង្ហាញអំពីចំណុចបន្ទាប់ទីពីរស្តីអំពីប្រភេទចម្បងនៃមធ្យោបាយដោះស្រាយ (ផ្នែក ៤.១២.២ ចាប់ពីទំព័រ ១០៦)។

### ៤.១២.១.ដំណោះស្រាយតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជា

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សង្កត់ធ្ងន់លើជំពូកពេញលេញស្តីពីមធ្យោបាយដោះស្រាយការបំពានលើកិច្ចសន្យា[22]។

ការមិនអនុវត្តកាតព្វកិច្ច ត្រូវបានកំណត់និយមន័យថា *"ជាការខកខានមិនបានអនុវត្តកាតព្វកិច្ចចែងនៅក្នុងកិច្ចសន្យារបស់កូនបំណុល"*[23]។

ការមិនអនុវត្តតាមកាតព្វកិច្ច មានកំណត់ដូចនៅក្នុងករណីខាងក្រោម៖

- ការពន្យារពេលអនុវត្តអាចជា៖ (i) កាតព្វកិច្ចត្រូវអនុវត្តនៅពេលជាក់លាក់ណាមួយ នៅពេលជាក់លាក់នោះមកដល់ តែមិនបានអនុវត្តកាតព្វកិច្ច ឬ (ii) កាតព្វកិច្ចត្រូវបានអនុវត្តនៅពេលវេលាមួយមិនច្បាស់លាស់ ប៉ុន្តែកូនបំណុលដឹងថាជាពេលត្រូវអនុវត្ត ហើយគាត់មិនបំពេញកាតព្វកិច្ចនោះឲ្យហើយ ឬ (iii) ពុំមានពេលវេលាណាមួយ ត្រូវបានកំណត់ចំពោះការអនុវត្ត ហើយកូនបំណុលទទួលបានការស្នើសុំឲ្យអនុវត្ត។
- ការអនុវត្តមិនអាចធ្វើទៅបាន មានន័យថា៖ មិនអាចអនុវត្តបានដោយសារកត្តាផ្លូវកាយ ឬ សង្គម ឬ សេដ្ឋកិច្ច។ គូភាគីក៏អាចកំណត់ពេលវេលាចំពោះការអនុវត្តមិនអាចធ្វើទៅបានផងដែរ។
- ការអនុវត្តមិនទាន់ពេញលេញ៖ សំដៅលើការអនុវត្តតែមួយផ្នែក (ការអនុវត្តពេញលេញ រួមជាមួយនឹងគោលបំណងនៃកាតព្វកិច្ច ពុំបានអនុវត្តពេញលេញ)។
- ការមិនអនុវត្តផ្សេងទៀត សំដៅលើការបំពានលើកាតព្វកិច្ចណាមួយមានចែងនៅក្នុងកិច្ចសន្យា។

នៅពេលមិនមានការបំពេញកាតព្វកិច្ច *"ម្ចាស់បំណុល អាចទាមទារឲ្យមានការអនុវត្ត ការសងជំងឺចិត្ត ឬ ការបញ្ឈប់កិច្ចសន្យាជាក់លាក់ណាមួយ"*[24]។ ដូច្នេះ កូនបំណុលដែលបំពានលើកិច្ចសន្យា ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្ត។ មធ្យោបាយដោះស្រាយ មានច្រើនចំណុចដែលអាចអនុវត្តទៅបាន ដូចនេះ ម្ចាស់បំណុល អាចជ្រើសរើសមធ្យោបាយដោះស្រាយណាមួយ ឬមធ្យោបាយដែលរៀបរាប់ខាងលើ ប្រសិនបើភាគីមិនស្ថិតនៅក្នុងជម្លោះជាមួយគ្នា។ ហេតុដូច្នេះ ម្ចាស់បំណុល អាចទាមទារសំណងជំងឺចិត្ត ជំនួសឱ្យការអនុវត្ត ឬ ទាំងសំណងជំងឺចិត្ត និងការអនុវត្តបាន ប្រសិនបើពុំមានភាពមិនសមស្របគ្នាណាមួយរវាងការទាមទារទាំងពីរនោះ[25]។

ដើម្បីឲ្យកូនបំណុលអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនដែលពុំទាន់បានធ្វើ ម្ចាស់បំណុលអាចស្នើសុំសេចក្តីបង្គាប់ចំពោះការអនុវត្តខានពុំបានពីតុលាការ លើកលែងតែពុំមានការអនុញ្ញាតចំពោះប្រភេទកាតព្វកិច្ចអនុវត្តខានពុំបាន[26]។

---

[22] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី ៤ ដំណោះស្រាយការបំពានលើកិច្ចសន្យា។

[23] មាត្រា ៣៨៩ នៃក្រមរដ្ឋប្បវេណី។

[24] ប្រការ ៣៩០ នៃក្រមរដ្ឋប្បវេណី។

[25] ប្រការ ៣៩៧ នៃក្រមរដ្ឋប្បវេណី។

[26] ប្រការ ៣៩៦ នៃក្រមរដ្ឋប្បវេណី។

## ៤.១២.២. ប្រភេទសំខាន់ៗនៃដំណោះស្រាយ[27]

នៅក្នុងការកំណត់ចែងដោយច្បាប់ គូភាគី មានសិទ្ធិក្នុងការជ្រើសរើសមធ្យោបាយដោះស្រាយ ដើម្បីកំណត់ឋានានុក្រម និងរៀបចំតាមលំដាប់លំដោយរបស់ខ្លួន និងដើម្បីកំណត់តាមមធ្យោបាយផ្សេងៗគ្នាផងដែរ។

គូភាគីនៅក្នុងកិច្ចសន្យា អាចជ្រើសរើសថាតើគួរបញ្ចូលលក្ខខណ្ឌ និងអាចអនុវត្តមធ្យោបាយដោះស្រាយណាខ្លះនៅក្នុងកិច្ចសន្យា ឬត្រូវបង្វែរជម្រើសនោះឲ្យភាគីរងគ្រោះសម្រេចវិញ ឬយ៉ាងណា។ មធ្យោបាយដោះស្រាយ ត្រូវបានចែកចេញជាប្រភេទសំខាន់ៗ ដូចជា៖ (ក) មធ្យោបាយដោះស្រាយប្រហាក់ប្រហែលគ្នា (ខ) ការពន្យារពេលអនុវត្ត (គ) ការកាត់បន្ថយតម្លៃ (ឃ) ការបញ្ឈប់ ឬការលុបចោល (ង) ការប្រគល់សងវិញ (ច) ការសងជំងឺចិត្ត។

### ក) មធ្យោបាយដោះស្រាយប្រហាក់ប្រហែលគ្នា

សំដៅលើការផ្តល់នូវអត្ថប្រយោជន៍ប្រហាក់ប្រហែលគ្នា ឬ ស្មើភាពគ្នា ដែលរំពឹងពីការអនុវត្តលើកិច្ចសន្យា។ គូភាគីមានសិទ្ធិក្នុងការអនុវត្ត ការជួសជុល ការជំនួសផលិតផល និងប្រើប្រាស់វិធានការកែតម្រូវពាក់ព័ន្ធនឹងដំណើរការផលិតកម្ម និងផលិតផលស្អាត។ មធ្យោបាយដោះស្រាយទាំងនេះ មានគោលបំណងដើម្បីសម្រេចបាននូវសមិទ្ធផលឲ្យច្រើនតាមតែអាចធ្វើទៅបាន ដែលគូភាគីបានព្យាករណ៍ ដោយអនុវត្តលើដំណោះស្រាយដែលសមស្របបំផុតចំពោះកាតព្វកិច្ចដំបូង។

| មធ្យោបាយដោះស្រាយរបស់ផលិតករចំពោះករណីអ្នកទិញបំពានលើកិច្ចសន្យាមានដូចខាងក្រោម | មធ្យោបាយដោះស្រាយរបស់អ្នកទិញចំពោះករណីផលិតករបំពានលើកិច្ចសន្យាមានដូចខាងក្រោម |
|---|---|
| ពន្យារពេលទូទាត់តម្លៃ | ការបំពានលើកាតព្វកិច្ចពាក់ព័ន្ធនឹងដំណើរការ |
| ការខកខានមិនបានផ្តល់ធាតុចូលសមស្រប | ផលិតផលមិនសមស្រប |
| បដិសេធមិនទទួលយកទំនិញសមស្រប | ការខកខានក្នុងការចែកចាយផលិតផល |

[27] គោលការណ៍ណែនាំស្របតាមច្បាប់ស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា UNIDROIT, FAO, IFAD, Rome ឆ្នាំ២០១៥។

### ខ) ការផ្អាកបណ្តោះអាសន្ន

ចំពោះការអនុវត្តន៍កាតព្វកិច្ចជាមធ្យោបាយដោះស្រាយ អាចត្រូវប្រើប្រាស់ ចំពោះករណីការបំពានរំពឹងទុកជាមុន នៅពេលស្ថានភាព និងកាលៈទេសៈបច្ចុប្បន្នបង្ហាញយ៉ាងច្បាស់ថា ម្ចាស់បំណុល នឹងមិនមានលទ្ធភាព ឬ មិនចង់អនុវត្តតាមកាតព្វកិច្ចក្នុងកិច្ចសន្យារបស់ខ្លួន។ ឧទាហរណ៍ ដោយហេតុថាទឹកជំនន់បានបំផ្លាញដល់កសិផល ដូចនេះ ច្បាស់ណាស់ដែលផលិតករ នឹងមិនអាចមានលទ្ធភាពផ្តល់ផលិតផលគ្រប់គ្រាន់ តាមការព្រមព្រៀងនៅក្នុងកិច្ចសន្យាឡើយ ដូច្នេះ អ្នកទិញ អាចផ្អាកកាតព្វកិច្ចរបស់ខ្លួនក្នុងការបន្តផ្តល់គ្រាប់ពូជបាន។

| **មធ្យោបាយដោះស្រាយរបស់ផលិតករចំពោះករណីអ្នកទិញបំពានលើកិច្ចសន្យាមានដូចខាងក្រោម** | **មធ្យោបាយដោះស្រាយរបស់អ្នកទិញចំពោះករណីផលិតករបំពានលើកិច្ចសន្យាមានដូចខាងក្រោម** |
|---|---|
| ការខកខានមិនបានផ្តល់ធាតុចូលសមស្រប | ការខកខានមិនបានចែកចាយផលិតផលពេញលេញ |
| ការពន្យាពេលក្នុងការផ្តល់សម្បទានដល់វិស័យផលិតកម្ម | ការខកខានមិនបានចែកចាយផលិតផលសមស្រប |
| ការពន្យារពេលទូទាត់តម្លៃ | |

### គ) មធ្យោបាយដោះស្រាយចំពោះការកាត់បន្ថយតម្លៃ

មានគោលបំណងរក្សាការពារសមតុល្យដោះដូរទំនិញ និងសមតុល្យកំណត់តម្លៃឡើងវិញ រវាងតម្លៃដែលបានអនុវត្តពេលដោះដូរទំនិញរួច និងត្រូវប្រើប្រាស់ក្នុងករណីមានការបំពានលើការចែកចាយមិនសមស្រប ឬ បានតែមួយផ្នែក នៅពេលការអនុវត្តទាំងពីរនេះ មានកំហុស ឬមិនមានភាពពេញលេញ កូនបំណុល នឹងមិនមានចំណាប់អារម្មណ៍ (មិនទទួលបាន) ចំពោះការអនុវត្តជាក់លាក់ ឬ ការបញ្ឈប់កិច្ចសន្យាណាមួយឡើយ។ ឧទាហរណ៍ ការកាត់បន្ថយតម្លៃ អាចត្រូវស្នើសុំឡើងដោយអ្នកទិញ នៅពេលកាតព្វកិច្ចចំពោះគុណភាព ឬ បរិមាណមិនមានភាពសមស្របនៅពេលចែកចាយផលិតផល។

| **មធ្យោបាយដោះស្រាយរបស់ផលិតករចំពោះករណីអ្នកទិញបំពានលើកិច្ចសន្យាមានដូចខាងក្រោម** | **មធ្យោបាយដោះស្រាយរបស់អ្នកទិញចំពោះករណីផលិតករបំពានលើកិច្ចសន្យាមានដូចខាងក្រោម** |
|---|---|
| ពុំមានឧទាហរណ៍ពាក់ព័ន្ធ | ការចែកចាយផលិតផលមិនសមស្រប |
| | ការចែកចាយផលិតផលបានតែមួយផ្នែក |
| | ការខកខានមិនបានចែកចាយផលិតផលកសិកម្មសមស្រប |

### ឃ) ការបញ្ឈប់ ឬ ការលុបចោលកិច្ចសន្យា

ជាមធ្យោបាយដោះស្រាយកើតឡើងដោយសារការបំពានខុសខ្លាំង ដែលពុំអាចបន្តទំនាក់ទំនងកិច្ចសន្យាបាន។ ការលុបចោលកិច្ចសន្យា គឺជាមធ្យោបាយដោះស្រាយធ្ងន់ធ្ងរបំផុតចំពោះការបំពានរបស់ភាគីណាមួយ ដោយសារតែមធ្យោបាយដោះស្រាយនេះ ឆ្លុះបង្ហាញអំពីភាពបរាជ័យនៃទំនាក់ទំនងកិច្ចសន្យា៖ មធ្យោបាយដោះស្រាយបញ្ចប់តួនាទីកិច្ចសន្យារវាងគូភាគីទាំងពីរ។ ផលវិបាកនៃការបញ្ចប់កិច្ចសន្យានេះ គឺពាក់ព័ន្ធនឹងការរំលាយទំនាក់ទំនងកិច្ចសន្យា ហេតុដូចនេះ កាតព្វកិច្ចដើមរបស់គូភាគី ក៏ត្រូវរំលាយផងដែរ។ ជាទូទៅ គូភាគីកំណត់ ខពិន័យលុបចោលកិច្ចសន្យា ដែលផ្តល់សិទ្ធិឯកតោភាគីក្នុងការបញ្ឈប់កិច្ចសន្យា ចំពោះករណីមានការបំពានខុសខ្លាំង។

| មធ្យោបាយដោះស្រាយរបស់ផលិតករចំពោះករណីអ្នកទិញបំពានលើកិច្ចសន្យាមានដូចខាងក្រោម | មធ្យោបាយដោះស្រាយរបស់អ្នកទិញចំពោះករណីផលិតករបំពានលើកិច្ចសន្យាមានដូចខាងក្រោម |
|---|---|
| ការខកខានមិនបានទូទាត់ | ការបំពានលើកាតព្វកិច្ចពាក់ព័ន្ធនឹងដំណើរការ |
| ការខកខានមិនបានផ្តល់ធាតុចូលសមស្រប | ផលិតផលមិនសមស្រប |
| បដិសេធមិនទទួលយកទំនិញសមស្រប | ការខកខានមិនបានចែកចាយផលិតផល |
| ការខកខានមិនបានទិញទំនិញទាំងអស់/ភាគរយទិញទំនិញ | |

### ង) ការប្រគល់សងវិញ

គឺជាមធ្យោបាយដោះស្រាយ អនុវត្តចំពោះករណីបញ្ចប់កិច្ចសន្យា ដែលភាគីម្ខាងបង្កឡើងឲ្យមានការបំពានខុសខ្លាំង ផ្ទុយពីភាគីម្ខាងទៀត ដែលបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានពេញលេញ ឬ ត្រឹមតែមួយផ្នែក។ មធ្យោបាយដោះស្រាយនេះ បង្កើតឡើងដើម្បីប្រគល់ភាគីរងគ្រោះវិញនូវអ្វីដែលគាត់មាន មុនពេលបង្កើតកិច្ចសន្យានេះឡើង។ ការប្រគល់សងវិញ អាចធ្វើទៅបានស្របតាមគុណតម្លៃប្រហាក់ប្រហែលគ្នា ឬ ជារូបិយវត្ថុ។ ដើម្បីបង្ការកុំឲ្យមានរឿងអយុត្តិធម៌ ភាគីដែលប្រព្រឹត្តខុស ពុំមានសិទ្ធិក្នុងការបន្តរក្សាទុកទំនិញ ឬ រូបិយវត្ថុ ជាកម្មសិទ្ធិរបស់ខ្លួនឡើយ ពោលគឺត្រូវប្រគល់ទំនិញ ឬ រូបិយវត្ថុនោះទៅឲ្យម្ចាស់ដើមវិញ ដែលជាភាគីមិនបំពានកិច្ចសន្យា។

| មធ្យោបាយដោះស្រាយរបស់ផលិតករចំពោះករណីអ្នកទិញបំពានលើកិច្ចសន្យាមានដូចខាងក្រោម | មធ្យោបាយដោះស្រាយរបស់អ្នកទិញចំពោះករណីផលិតករបំពានលើកិច្ចសន្យាមានដូចខាងក្រោម |
|---|---|
| ខកខានមិនបានទូទាត់ | ខកខានមិនបានចែកចាយផលិតផល |

### ច) សំណងការសងថ្លៃជំងឺចិត្ត

គឺជាមធ្យោបាយដោះស្រាយ ដែលអាចទាមទារបានដោយភាគីរងគ្រោះនៅពេលមានការបំពានលើកិច្ចសន្យាកើតឡើង។ ការសងថ្លៃជំងឺចិត្ត គឺជាសំណងទូទាត់ជាតម្លៃរូបិយវត្ថុ ដែលមានគោលបំណងទូទាត់សងដល់ភាគីមិនបំពានកិច្ចសន្យា ចំពោះការបាត់បង់កើតឡើងចេញពីការបំពាន។ ការទូទាត់ថ្លៃសងជំងឺចិត្ត មានពីរប្រភេទ ដែលភាគីមិនបំពានកិច្ចសន្យា អាចមានសិទ្ធិទទួលបាន៖ ថ្លៃសងជំងឺចិត្តរំពឹងទុក ដែលមានគោលបំណងរ៉ាប់រងលើការបាត់បង់ដោយផ្ទាល់ និងតាមភាពចាំបាច់ នៅពេលមានការបំពានកិច្ចសន្យា និងកត្តានានាដែលភាគីរងគ្រោះបានរំពឹងទុក និងទទួលពីកិច្ចសន្យា ព្រមទាំងថ្លៃសងជំងឺចិត្តមិនចំពោះ ដែលមានគោលបំណងទូទាត់ដល់ភាគីរងគ្រោះដោយប្រយោល ជាជាងការបាត់បង់កិច្ចសន្យា។ ឧទាហរណ៍ ការបាត់បង់ប្រាក់ចំណូលអាជីវកម្ម ដោយសារម៉ាស៊ីនមិនបានចែកចាយ។ ប៉ុន្តែនៅក្នុងករណីមុន ដើម្បីទទួលបានថ្លៃសងជំងឺចិត្តសម្រាប់ប្រភេទនៃការបាត់បង់នេះ ភាគីមិន បំពានកិច្ចសន្យាត្រូវបង្ហាញថា ភាគីបំពានកិច្ចសន្យាបានដឹងអំពីកាលៈទេសៈ ឬ លក្ខខណ្ឌចាំបាច់ពិសេស នៅ កំឡុងពេលធ្វើកិច្ចសន្យានេះឡើង។

| មធ្យោបាយដោះស្រាយរបស់ផលិតករចំពោះករណីអ្នកទិញបំពានលើកិច្ចសន្យាមានដូចខាងក្រោម | មធ្យោបាយដោះស្រាយរបស់អ្នកទិញចំពោះករណីផលិតករបំពានលើកិច្ចសន្យាមានដូចខាងក្រោម |
|---|---|
| ការពន្យាពេលទូទាត់ | ការបំពានលើកាតព្វកិច្ចពាក់ព័ន្ធនឹងដំណើរការ |
| ការខកខានមិនបានផ្តល់ធាតុចូលសមស្រប | ផលិតផលមិនសមស្រប |
| ការបដិសេធមិនទទួលទំនិញសមស្រប | ការខកខានមិនបានចែកចាយផលិតផល |

## ៤.១៣. ការដោះស្រាយវិវាទ

ទំនាក់ទំនងកិច្ចសន្យាទាំងឡាយ អាចបង្កឲ្យមានជម្លោះនានាកើតឡើង ដោយសារករណីមិនអនុវត្តដែលចេញពីការបំពានលើកាតព្វកិច្ចរបស់គូភាគី ឬកើតចេញពីកត្តាខាងក្រៅ ដែលពុំផ្អែកលើឥរិយាបថរបស់ គូភាគី។ ហេតុដូច្នេះ **កិច្ចសន្យា គួរតែបង្កើតឡើងនូវវិធីសាស្រ្ត និងយន្តការដើម្បីដោះស្រាយវិវាទ**[28]។ បទបញ្ញត្តិទាំងនេះ បន្ថែមភាពច្បាស់លាស់ចំពោះនីតិវិធីចម្បង សម្រាប់ការបកស្រាយ និងវិធីសាស្រ្តអនុវត្ត កិច្ចសន្យាដើម្បីដោះស្រាយវិវាទ។ ផ្នែកទី ៦ នៃសៀវភៅណែនាំនេះ បង្ហាញអំពីសេចក្តីពិពណ៌នាយ៉ាងទូលំទូលាយចំពោះយន្តការខុសៗគ្នា ដែលអាចនឹងត្រូវប្រើប្រាស់ (និងមានជាឯកសារយោងនៅក្នុងកិច្ចសន្យា) សម្រាប់ការដោះស្រាយវិវាទ។ យន្តការដោះស្រាយវិវាទផ្អែកតាមអនុក្រឹត្យលេខ៣៦ស្តីពីផលិតកម្មតាមកិច្ចសន្យាត្រង់មាត្រា៧ និងមាត្រា១១ បានបង្ហាញពីយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយមានយន្តការ៣ដំណាក់កាលគឺ ទី១៖ តាមរយៈការចរចាររវាងគូភាគីជាមុនសិន ដោយផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។ទី២៖ ក្នុងករណីមិនអាចដោះស្រាយបាន ភាគីវិវាទអាចស្នើសុំទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសាម៉ី ដើម្បីធ្វើជាភាគីទី៣ ដឹកនាំអន្តរាគមន៍សម្របសម្រួលផ្សះផ្សាដោះស្រាយវិវាទនោះ។ ទី៣៖ ប៉ុន្តែប្រសិនបើករណីវិវាទនេះនៅតែមិនអាចដោះស្រាយបាន នោះភាគីវិវាទនឹងអនុវត្តតាមរយៈគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម។ ។ សូមបញ្ជាក់ថា គូភាគីចុះកិច្ចសន្យាអាចទទួលបានយន្តការដោះស្រាយវិវាទដូចបានជម្រាបជូនខាងលើនេះ ក្នុងករណីគូភាគីចុះកិច្ចសន្យានោះបានចុះបញ្ជីការនៅនាយកដ្ឋានកសិ-ឧស្សាហកម្ម ឬ នៅ PDAFF។ គោលបំណងរបស់យន្តការនេះ គឺ ដើម្បីជួយភាគីអ្នកផលិត(កសិករ)និងភាគីអ្នកទិញផលិតផលកសិកម្ម ទទួលបានសេវាដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តែទោះជាយ៉ាងណា យន្តការដោះស្រាយវិវាទទាក់ទងនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា មានលទ្ធភាព និងជម្រើសផ្សេងៗគ្នាជាច្រើនបានបង្កើតឡើង ដើម្បីលើកឡើងអំពីជម្លោះមាននៅក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យា (ដូចមានចែងលម្អិតនៅក្នុងផ្នែក ៦ នៃសៀវភៅណែនាំនេះ)។ ប៉ុន្តែ កិច្ចសន្យា ត្រូវកំណត់ច្បាស់លាស់ទៅលើយន្តការមួយណាដែលនឹងត្រូវប្រើប្រាស់ឬ នៅពេលចាំបាច់ត្រូវធ្វើមជ្ឈត្តការលើជម្លោះ។
គេអាចព្រមព្រៀងលើការអនុវត្តច្រើនជាងមួយជំហានហើយកិច្ចសន្យាអាចចែង (ឧទាហរណ៍) ថា ជាបឋម គូភាគី ត្រូវស្វែងរកដំណោះស្រាយសមស្របមួយ បន្ទាប់មក អាចស្វែងរកអ្នកផ្សះផ្សា ឬអ្នកបញ្ចុះបញ្ចូលឲ្យសះជាគ្នា (ចាំបាច់ត្រូវកំណត់ ឧទាហរណ៍ អាជ្ញាធរមូលដ្ឋាន ឬមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (NCAC) សម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យា រួចបន្ទាប់មកទៀត ប្រសិនបើ វិវាទនៅតែពុំអាចដោះស្រាយបាន ត្រូវបញ្ជូនទៅអង្គភាពធ្វើសេចក្តីសម្រេចចិត្ត (យន្តការមជ្ឈត្តការ ឬតុលាការ)។
វាជាប្រការសំខាន់ ដែលប្រភពជំនួយចុងក្រោយដែលបានជ្រើសតាំង (នៅក្នុងកិច្ចសន្យា) ក្នុងការដោះស្រាយជម្លោះ អាចជាអង្គភាពធ្វើសេចក្តីសម្រេចចិត្ត (សំដៅចំពោះអ្នកដែលអាចធ្វើមជ្ឈត្តការ និងអាចធ្វើសេចក្តីសម្រេចចិត្តបង្គាប់ ពាក់ព័ន្ធនឹងបញ្ហាជម្លោះយ៉ាងពិតប្រាកដ។) ប្រសិនបើប្រភពជំនួយចុងក្រោយ ត្រូវបានបង្ហាញនៅក្នុងកិច្ចសន្យា បើពុំដូច្នោះទេ ជានិច្ចកាល គេអាចលើកអំពីជម្លោះនោះឡើងនៅឯតុលាការ (ប្រព័ន្ធតុលាការ)។

[28] សូមមើលលម្អិតនៅផ្នែកទី ៦ នៃសៀវភៅណែនាំបច្ចុប្បន្ន។

## ៤.១៤. លក្ខខណ្ឌផ្នែកច្បាប់ផ្សេងទៀត (ចំនួនសេចក្តីចម្លង ភាសា)

ផ្នែកចុងក្រោយនៃកិច្ចសន្យា (ជាទូទៅ ហៅថា "បទបញ្ញត្តិផ្សេងៗ") ផ្តល់នូវបទបញ្ញត្តិ ឬ ការចង្អុលបង្ហាញនានា ដូចខាងក្រោម៖

### ៤.១៤.១ ច្បាប់ជាធរមាន

ច្បាប់អនុវត្តទូទៅនៃកិច្ចសន្យា គឺជាច្បាប់ដែលមានចែងនៅក្នុងកិច្ចសន្យា។ នៅក្នុងករណីដែលពុំមានច្បាប់ណាមួយបានកំណត់ច្បាស់លាស់ដោយគូភាគី នោះតុលាការ ត្រូវអនុវត្តតាមច្បាប់ប្រទេសណាដែលសមស្របចំពោះការអនុវត្តជាក់ស្តែង ដោយយោងតាមលក្ខណៈ និងកាលៈទេសៈជុំវិញ។ កិច្ចសន្យាពាណិជ្ជកម្ម ត្រូវបានសន្មតថា មានលក្ខណៈពាក់ព័ន្ធខ្លាំងនឹងច្បាប់ប្រទេសដែលភាគីនោះត្រូវអនុវត្តតាមកាតព្វកិច្ច ឬ ភាគីនោះមានកន្លែងអាជីវកម្មរបស់ខ្លួន។

សម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងប្រទេសកម្ពុជា ជាលទ្ធផល ប្រសិនបើពុំមានបញ្ជាក់អំពីច្បាប់ជាក់លាក់ណាមួយទេ នោះនឹងត្រូវអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ទោះជាយ៉ាងណា ដើម្បីចៀសវាងចម្ងល់ណាមួយ គូភាគី ត្រូវបានផ្តល់អនុសាសន៍ឲ្យបញ្ជាក់អំពីលក្ខខណ្ឌនានាឲ្យបានច្បាស់លាស់នៅក្នុងកិច្ចសន្យា។ ជាប្រការសំខាន់ក្នុងការពិចារណាថា ច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវបានណែនាំឲ្យគូភាគីអនុវត្ត ជាពិសេស អ្នកធ្វើស្រែចំការ ដែលជាទូទៅត្រូវបានចាត់ទុកថាជាភាគីទន់ខ្សោយ។ ការអនុវត្តនីតិកម្មនៃព្រះរាជាណាចក្រកម្ពុជា ជំរុញឲ្យមានការទទួលបានចំណេះដឹងខាងច្បាប់ យុត្តិធម៌ និងការការពារប្រកបដោយនីតិវិធី ទាំងក្នុងកំឡុងពេលអនុវត្តនីតិវិធីដោះស្រាយវិវាទ និងនៅក្នុងដំណាក់កាលអនុវត្តក្នុងករណីមានជម្លោះ។ ប្រយោគ និងរូបមន្តទូទៅ ដែលអាចប្រើដើម្បីបញ្ជាក់អំពីឯកសារយោងចំពោះច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅក្នុងកិច្ចសន្យា អាចមានជាឧទាហរណ៍ដូចខាងក្រោម៖

"កិច្ចព្រមព្រៀងនេះ ត្រូវគ្រប់គ្រង បកស្រាយ និងអនុវត្ត ដោយផ្អែកលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា"

### ៤.១៤.២. ចំនួនសេចក្តីចម្លង

ចំនួនឯកសារដើម ដែលគូភាគីចុះហត្ថលេខា អាចមានបង្ហាញនៅក្នុងកិច្ចសន្យា ដែលមានប្រយោគដូចជា៖ កិច្ចសន្យានេះ ត្រូវបានធ្វើឡើងនៅក្នុង "បញ្ចូលលេខ" ឯកសារចម្លងច្បាប់ដើម។ " យ៉ាងហោចណាស់ ឯកសារដើមនៃកិច្ចសន្យា ត្រូវតែផ្តល់ជូនភាគីនីមួយៗ។ លើសពីនេះ ឯកសារចម្លងច្បាប់ដើម/ឯកសារចម្លង អាចរក្សាទុកជាមួយនឹងភាគីទីបី (អាជ្ញាធរមូលដ្ឋាន នាយកដ្ឋានកសិ-ឧស្សាហកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃខេត្តសាម៉ី និង / ឬ មេធាវី...)

### ៤.១៤.៣. ភាសាក្នុងកិច្ចសន្យា

ផ្នែកចុងក្រោយនៃកិច្ចសន្យា (ជាទូទៅ ហៅថា "បទបញ្ញត្តិផ្សេងៗ") ផ្តល់នូវបទបញ្ញត្តិ ឬ ការចង្អុលបង្ហាញនានាដូចខាងក្រោម៖

ជាលទ្ធផល នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា កិច្ចសន្យាជាភាសាខ្មែរ មានអាទិភាពជាងទម្រង់កំណែភាសាផ្សេងៗទៀត។ ទោះជាយ៉ាងណា គេអាចប្រើភាសាផ្សេងទៀត សម្រាប់ការបកប្រែមិនផ្លូវការនៃកិច្ចសន្យាបាន។

### ៤.១៤.៤. ការចុះហត្ថលេខាលើកិច្ចសន្យា

នៅក្នុងកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ត្រូវមានការចុះហត្ថលេខា ( ឬ ផ្តិតមេដៃ) ពីគូភាគី ហើយត្រូវបង្ហាញកាលបរិច្ឆេទ និងទីកន្លែងបង្កើតកិច្ចសន្យានេះឡើងផងដែរ។ ជាការអនុវត្តល្អ គូភាគី គួចុះហត្ថលេខា (ឬ ផ្តិតមេដៃ) ជាមួយនឹងវត្តមានរបស់សាក្សី ដែលត្រូវចុះហត្ថលេខាលើឯកសារផងដែរ។

ដូចដែលបានថែងរួចនៅក្នុងតារាង ៤.១.ក ទំព័រ ៤៩ មានការផ្តល់អនុសាសន៍ឲ្យសាក្សីចុះហត្ថលេខាទទួលស្គាល់ថា ភាគីទាំងពីរ បានយល់ព្រមលើលក្ខខណ្ឌនានានៅក្នុងកិច្ចសន្យាដោយពុំមានការបង្ខំ និងការរឹតត្បិតឡើយ។ នៅក្នុងករណីភាគីម្ខាងទៀត ពុំចេះអក្សរ នោះខ្លឹមសារនៃកិច្ចសន្យា តម្រូវឲ្យភាគីទីបីអានឲ្យលឺៗ ដើម្បីផ្ទៀងផ្ទាត់ការយល់ឃើញ និងការព្រមព្រៀងរបស់ភាគីពុំចេះអក្សរ។ នៅក្នុងករណីនេះ ជាប្រការសមស្របដែលត្រូវសរសេរជាលក្ខណ៍អក្សរនៅលើហត្ថលេខារបស់សាក្សី៖ "អត្ថបទនៃកិច្ចសន្យា ត្រូវបានអានលឺៗទៅកាន់ភាគីទាំងពីរ ហើយភាគីទាំងពីរ បានយល់ព្រមដោយគ្មានការបង្ខំ និងការរឹតត្បិតអ្វីឡើយ ទៅលើលក្ខខណ្ឌនៃកិច្ចសន្យា។" ហត្ថលេខារបស់សាក្សីជាភាគីទីបី ក្លាយជាចំណុចដ៏សំខាន់នៅក្នុងករណីនេះ។



◁ *ការចុះហត្ថលេខានៃកិច្ចសន្យាផលិតកម្មកសិកម្មស្តីពីការផលិតនិងផ្គត់ផ្គង់ស្រូវសើរីង្គរាំង ក្រុមហ៊ុន អេមរុ រ៉ាយស៍ (AMRU) និងសហគមន៍កសិកម្មពីខេត្តព្រះវិហារ នៅក្នុងឆ្នាំ ២០១៤ (រូបថត៖ SNEC គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ/អង្ករកម្ពុជា)*

ទោះបីជាមិនតម្រូវដោយច្បាប់ក្តី កិច្ចសន្យា អាចត្រូវបានចុះហត្ថលេខាយល់ព្រមដោយអាជ្ញាធររដ្ឋសាធារណៈ (អាជ្ញាធរមូលដ្ឋាន) ឬ ដោយសារការី ឬ មេធាវី។



*ឧទាហរណ៍នៃកិច្ចសន្យា ចុះហត្ថលេខា* ▷

នៅពេលអង្គការកសិករចុះហត្ថលេខាលើកិច្ចសន្យានោះកិច្ចសន្យាពុំចាំបាច់ចុះហត្ថលេខាដោយរាល់សមាជិកទាំងអស់របស់អង្គការកសិករឡើយ (ប៉ុន្តែ ត្រូវចុះដោយតំណាងស្របច្បាប់)។ ទោះជាយ៉ាងណា មានការផ្តល់អនុសាសន៍ឲ្យបន្ថែមឧបសម្ព័ន្ធរួមជាមួយនឹងការប្តេជ្ញាចិត្តរបស់បុគ្គល (ប្តេជ្ញាចិត្តចំពោះបរិមាណផលិតផលដើម្បីចែកចាយ និង/ឬផ្ទៃខាងលើដែលធ្វើឡើងសម្រាប់វិស័យផលិតកម្មស្ថិតក្រោមកិច្ចព្រមព្រៀងផលិតផលកសិកម្ម)អនុវត្តនិងចុះហត្ថលេខាដោយសមាជិកគ្រប់រូប (សូមមើលផ្នែក ៧ នៃសៀវភៅណែនាំនេះដែលសង្កត់ធ្ងន់លើផលិតកម្មកសិកម្មតាមកិច្ចសន្យាជាមួយនឹងអង្គការកសិករ និងជាពិសេសនោះគឺផ្នែក ៧.២ ទំព័រ ១៥១)

# ផ្នែកទី ៥ ៖ ក្នុងពេល និងក្រោយពេលអនុវត្តកិច្ចសន្យា៖ ការត្រួតពិនិត្យ និងការវាយតម្លៃ

បន្ទាប់ពីការចុះកិច្ចសន្យារវាងភាគីទាំងពីរ ការតាមដាន និងការប៉ាន់ប្រមាណអំឡុងពេលនៃការអនុវត្តកិច្ចសន្យាគឺជារឿងសំខាន់ ដើម្បីធ្វើឱ្យប្រាកដថា គ្រប់លក្ខខណ្ឌនៃការព្រមព្រៀងដែលមានចែងនៅក្នុងកិច្ចសន្យានោះ ត្រូវបានអនុវត្តតាម ដោយភាគីទាំងពីរ ឬបើមានការទាមទារឱ្យកែប្រែលក្ខខណ្ឌមួយចំនួននោះ ភាគីទាំងពីរអាចពិភាក្សា និងព្រមព្រៀងគ្នាទាន់ពេលវេលា ដើម្បីចៀសវាងនូវជម្លោះដោយប្រការណាមួយ។ ការប៉ាន់ប្រមាណបន្ទាប់ពីការបញ្ចប់លើការអនុវត្តកិច្ចសន្យាក៏ត្រូវធ្វើដែរ ក្នុងគោលបំណងប៉ាន់ប្រមាណពីផលប្រយោជន៍ ដែលភាគីទាំងពីរទទួលបានពីកិច្ចសន្យា ក៏ដូចជាដើម្បីកំណត់នូវភាពលំបាកនានាដែលបានជួបប្រទះ និងធ្វើការកែលម្អឱ្យប្រសើរឡើងតាមតែអាចធ្វើទៅបាន។ ផ្នែកនេះ នឹងបង្ហាញអំពីវិធីសាស្ត្រ ដើម្បីតាមដាន និងប៉ាន់ប្រមាណការអនុវត្តកិច្ចសន្យារវាងភាគីទាំងពីរ។

## ៥.១. ក្នុងអំឡុងពេលនៃការផលិត៖

តាមដាន និងប្រាស្រ័យទាក់ទង ដើម្បីប្រមើលមើលអំពីភាពលំបាកនានា ដែលអាចនឹងកើតមានឡើងក្នុងអំឡុងពេលនៃការផលិត ការតាមដាន និងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកផលិត ក្នុងការទប់ស្កាត់ហានិភ័យ និងដោះស្រាយបញ្ហា គួរតែត្រូវធ្វើឡើងឱ្យបានទៀងទាត់ដោយ ( ឬ ជាមួយ ) ភាគីទាំងពីរ។ ក្នុងករណីជាច្រើន ការតាមដាននេះ នឹងត្រូវធ្វើឡើងដោយភាគីពាក់ព័ន្ធសេដ្ឋកិច្ចខ្លួនឯង ដូចជា ៖

- ដោយកំណត់ត្រាផ្ទាល់របស់អ្នកផលិត
- ឬដោយការចុះត្រួតពិនិត្យរបស់អ្នកទិញលើអ្នកលក់
- ឬដោយអ្នកតំណាងក្រុម នៅក្នុងករណីដែលកិច្ចសន្យាត្រូវបានធ្វើឡើងតាមរយៈអង្គការកសិករ ឬក្រុមអ្នកផលិត
- ឬដោយការតំណាងរួមគ្នារវាងអ្នកតំណាងរបស់អង្គការកសិករ និងអ្នកតំណាងរបស់អ្នកទិញ

ក្នុងករណីមួយចំនួន ការតាមដានលើការអនុវត្តកិច្ចសន្យា ក៏អាចមានការចូលរួមពីភាគីទីបី (ឧទាហរណ៍ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសាមី ឬ អង្គការ/គម្រោងដែលគាំទ្រលើផ្នែកនេះ ឬ ក៏អាជ្ញាធរមូលដ្ឋានជាដើម)។ លើកលែងតែមានការចែងក្នុងកិច្ចសន្យាផ្សេងពីនេះភាគីនីមួយៗត្រូវទទួលខុសត្រូវក្នុងការចំណាយខ្លួនឯងសម្រាប់ការចូលរួមក្នុងការតាមដានការអនុវត្តកិច្ចសន្យា។ ប្រសិនបើភាគីទីបីចូលរួមផងដែរនោះ ការចំណាយផ្សេងៗ អាចត្រូវទទួលខុសត្រូវដោយភាគីទីបីខ្លួនឯងផ្ទាល់ (នេះអាចជាករណីសម្រាប់ការគាំទ្រដែលផ្តល់ដោយគម្រោង ឬ ស្ថាប័នសាធារណៈណាមួយ) ឬ ក៏កិច្ចសន្យាគួរតែចែងអំពីការចំណាយផ្សេងៗសម្រាប់សេវាតាមដាននេះ និងត្រូវកំណត់អំពីភាគី ដែលត្រូវទទួលខុសត្រូវលើការចំណាយទាំងនោះផងដែរ។

## ៥.១.១. តាមដាន និងកត់ត្រាអំពីការអនុវត្តនៃការប្តេជ្ញាចិត្តរបស់ភាគីអ្នកទិញ

ប្រសិនបើមានចែងស្តីអំពីលក្ខខណ្ឌណាមួយក្នុងកិច្ចសន្យា អ្នកទិញអាចជាអ្នក ដែលផ្តល់ការគាំទ្របច្ចេកទេស (ការបណ្តុះបណ្តាល/ផ្តល់យោបល់ផ្នែកបច្ចេកទេសផ្សេងៗ) គាំទ្រផ្នែកហិរញ្ញវត្ថុ ឬ ផ្តល់ជាវត្ថុធាតុដើមនានាសម្រាប់ផលិតកម្ម។ វាគឺជារឿងសំខាន់ ដែលត្រូវចងក្រងឱ្យមានជាឯកសារស្តីពីការអនុវត្តជាក់ស្តែងនៃការគាំទ្រទាំងអស់នោះ។ បង្កាន់ដៃប្រគល់វត្ថុធាតុដើម ឬ សម្ភារផ្សេងៗ ឬ មួយបង្កាន់ដៃបង់ប្រាក់ជាមុន។ល។ ត្រូវតែធ្វើឱ្យបានត្រឹមត្រូវជាពីរច្បាប់ (មួយច្បាប់សម្រាប់ភាគីនីមួយៗ) ហើយត្រូវរក្សាឱ្យបានត្រឹមត្រូវទុកជាភស្តុតាង។ ក្រៅពីនេះ ក្រដាសតាមដានការអនុវត្តកិច្ចសន្យារបស់អ្នកទិញ ត្រូវរៀបរៀងឡើង និងធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ ដូចក្នុងឧទាហរណ៍ខាងក្រោមនេះ ៖

**តារាង ៥.១.ក ៖ ឧទាហរណ៍នៃបញ្ជីត្រួតពិនិត្យដើម្បីតាមដានការអនុវត្តការប្តេជ្ញាចិត្តរបស់ផលិតករដែលពាក់ព័ន្ធនឹងវិធីសាស្ត្រផលិតកម្ម**

| ល.រ | ខសន្យាដែលត្រូវតាមដាន (ក) | ប្រភពព័ត៌មាន/ការបញ្ជាក់/ឯកសារគាំទ្រដែលត្រូវភ្ជាប់ (ខ) | អ្វីខ្លះ? (គ) | ពេលណា? (ឃ) | កំណត់សម្គាល់/បញ្ហាផ្សេងៗ (ង) | ដំណោះស្រាយដែលព្រមព្រៀង (ច) | ហត្ថលេខានៃភាគីទាំងពីរ (ឆ) |
|---|---|---|---|---|---|---|---|
| ១.១ | ការគាំទ្របច្ចេកទេស | | | | | | |
| *ឧទា* | *១.១.១ ការបណ្តុះបណ្តាលលើការផលិត* | *បញ្ជីវត្តមាននៃវគ្គបណ្តុះបណ្តាល* | | | | | |
| *ឧទា* | *១.១.២ ការគាំទ្របច្ចេកទេសតាមតម្រូវការ* | *ទម្រង់ស្នើសុំការគាំទ្រ និង ការបញ្ជាក់នៃការផ្តល់ឱ្យ* | | | | | |
| ១.២ | ការគាំទ្រដោយវត្ថុធាតុដើម | | | | | | |
| *ឧ.* | *១.២.១ គ្រាប់ពូជ/ កូនរុក្ខជាតិ* | *បង្កាន់ដៃប្រគល់ , ការាងឈ្មោះកសិករដែលទទួល* | | | | | |
| *ឧ.* | *១.២.២ ជី* | *បង្កាន់ដៃប្រគល់ , ការាងឈ្មោះកសិករដែលទទួល* | | | | | |
| ១.៣ | ការគាំទ្រហិរញ្ញវត្ថុ | | | | | | |
| *ឧ.* | *១.៣.១ កម្ចីសម្រាប់ទិញគ្រាប់ពូជ* | *បញ្ជីចំណាយ និង វិក្កយបត្រ (ឬភស្តុតាងនៃការចំណាយ) ឬក៏បញ្ជីនៃវត្ថុធាតុដើមដែលបានទទួលដោយមានការបញ្ជាក់ពីតម្លៃប្រសិនបើកម្ចីនោះមិនមែនជាប្រាក់* | | | | | |

សម្គាល់៖ តារាងនេះអាចយកជាមូលដ្ឋានដើម្បីបង្កើតជាបញ្ជីត្រួតពិនិត្យពេញលេញមួយ សម្រាប់ត្រួតពិនិត្យការអនុវត្តខសន្យារបស់អ្នកទិញ។ បញ្ជីត្រួតពិនិត្យនេះគួរធ្វើជាពីរច្បាប់ (មួយច្បាប់សម្រាប់អ្នកទិញ និងមួយច្បាប់ទៀតសម្រាប់អ្នកផលិត ឬអង្គការកសិករ ហើយចុះហត្ថលេខាដោយភាគីទាំងពីរតាមដំណាក់កាលនីមួយៗ ឧទាហរណ៍ ជូរនីមួយៗ ត្រូវនឹងខសន្យាមួយ)។ បន្ទាប់មក ភាគីនីមួយៗអាចរក្សាទុកវាជាភស្តុតាងនៃការអនុវត្តខសន្យា (ឯកសារនេះអាចធ្វើជាឯកសារយោងក្នុងករណីមានការខ្វែងគំនិតគ្នា)។

អក្សរពណ៌ទឹកក្រូច គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ (ក្នុងករណីនេះ សម្រាប់ការដាំដុះរុក្ខជាតិ)

(ក) រៀបរាប់គ្រប់ខសន្យាទាំងអស់ដែលបានប្តេជ្ញាដោយអ្នកទិញនៅក្នុងកិច្ចសន្យា (ឧ. ផ្តល់គ្រាប់ពូជ ផ្តល់វត្ថុធាតុដើមផ្សេងៗទៀត ...)។

(ខ) បង្ហាញពីប្រភពនៃការបញ្ជាក់ផ្សេងៗ (ឯកសារ) ដែលអាចភ្ជាប់មកជាមួយនឹងបញ្ជីត្រួតពិនិត្យនេះ (បង្កាន់ដៃប្រគល់វត្ថុធាតុដើម...)

(គ) ពណ៌នាពីការជួយគាំទ្រ ឬវត្ថុធាតុដើមដែលត្រូវផ្តល់ឱ្យ (រួមទាំងបរិមាណនៃវត្ថុធាតុដើម ឬតម្លៃសរុបនៃកម្ចីផ្សេងៗ ...)

(ឃ) បង្ហាញពីកាលបរិច្ឆេទនៃការអនុវត្ត ឬការប្រគល់

(ង) ប្រសិនបើជួបប្រទះនឹងវិបត្តិ ឬបញ្ហាផ្សេងៗ វាអាចបង្ហាញនៅក្នុងកូលោននេះ

(ច) ដំណោះស្រាយដែលព្រមព្រៀងគ្នាដោយភាគីទាំងពីរក្នុងការដោះស្រាយបញ្ហាដែលអាចនឹងកើតមានអាចសរសេរនៅទីនេះ ហើយចុះហត្ថលេខាដោយភាគីទាំងពីរ។ បន្ទាប់ពីចុះហត្ថលេខារួច ឯកសារនេះត្រូវបានចាត់ទុកជាវិសោធនកម្មមួយទៅលើកិច្ចសន្យាដែលមាន។ ជាជម្រើស ឬលើសពីនេះទៀតនោះ សេចក្តីបន្ថែមលើកិច្ចសន្យាកាន់តែផ្លូវការ អាចត្រូវចុះហត្ថលេខា (ដោយមានហត្ថលេខារបស់សាក្សី/ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត) ដើម្បីបំពេញបន្ថែមលើកិច្ចសន្យាដើម។

(ឆ) ភាគីទាំងពីរចុះហត្ថលេខាលើចំណុចនីមួយៗ។

ទាក់ទងនឹងការផ្គត់ផ្គង់វត្ថុធាតុដើម វាអាចជាការប្រសើរ ប្រសិនបើយកនូវគំរូនៃវត្ថុធាតុដើមដែលបានចែកចាយ ទុកក្នុងកាបូបឬស្រោមសំបុត្រដែលបិទជិត (ដែលចុះហត្ថលេខាដោយភាគីទាំងពីរ)

ម្យ៉ាងទៀត ភាគីទាំងពីរអាចរក្សាទុកនូវគំរូដែលបិទជិតនោះ ម្នាក់មួយ ឬក៏ភាគីទីបី (ជាតួយ៉ាងដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ) ជាអ្នករក្សាទុក

ក្នុងករណីដែលមានទំនាស់កើតឡើងលើគុណភាពនៃវត្ថុធាតុដើមដែលបានផ្គត់ផ្គង់ក្រោយពីយកវាទៅប្រើប្រាស់ (ឧទារហណ៍ អត្រាដុះនៃគ្រាប់ពូជខ្សោយ ឬអប្រសិទ្ធភាពនៃការថែទាំ ឬដាក់ជីជាដើម)គំរូដែលបានរក្សាទុកនោះ អាចយកទៅប្រើប្រាស់និងវិភាគ / ធ្វើតេស្ត ដែលជាផ្នែកមួយនៃដំណើការរកដំណោះស្រាយនៃជម្លោះ។

ប៉ុន្តែជាការពិតណាស់ អ្នករក្សាទុកត្រូវឱ្យប្រាកដថា លក្ខខណ្ឌនៃការរក្សាទុកនូវគំរូនោះមានភាពសមស្រប ហើយមិនប៉ះពាល់ដល់លក្ខណៈនៃគ្រាប់ពូជឬផលិតផល ដើម្បីឱ្យវាអាចយកទៅធ្វើជាប្រភពដែលអាចទុកចិត្តបានសម្រាប់ធ្វើការបញ្ជាក់បន្ថែមប្រសិនបើចាំបាច់។

## ៥.១.២. ការត្រួតពិនិត្យ និងកត់ត្រាអំពីការអនុវត្តតាមការប្តេជ្ញាចិត្តរបស់អ្នកផលិតក្នុងពេលផលិត

ដូចគ្នាដែរ ខ សន្យារបស់អ្នកផលិតដែលទាក់ទងនឹងដំណើរការនៃការផលិតគួរតែធ្វើការតាមដាន និងចងក្រងឱ្យមានជាឯកសារ។ នៅទីនេះ យើងមិននិយាយអំពីការចែកចាយផលិតផលទេ ដែលវានឹងមានបញ្ជាក់នៅត្រង់ផ្នែកទី ៥.២. (ពីទំព័រទី ១២៣) ប៉ុន្តែយើងនិយាយពីខសន្យា ដែលធ្វើការប្តេជ្ញាដោយអ្នកផលិតលើវិធីសាស្ត្រនៃការផលិតប៉ុណ្ណោះ ប្រសិនបើមាន (សូមមើល ផ្នែកទី ៤.៥ ទំព័រទី ៦៦)។ តារាង ៥.១.ខ. ខាងក្រោមនេះផ្តល់ជាឧទាហរណ៍នៃបញ្ជីត្រួតពិនិត្យ។

ប្រសិនបើខសន្យាដែលពាក់ព័ន្ធនឹងវិធីសាស្ត្រផលិតទាំងនោះ ឆ្លើយតបទៅនឹងស្តង់ដារសាធារណៈ ដែលទាមទារឱ្យមានការបញ្ជាក់ណាមួយ (ឧទាហរណ៍ ស្តង់ដារសរីរាង្គរបស់សហភាពអឺរ៉ុប ស្តង់ដារ ជីអេភី (GAP) ពិភពលោក ឬ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ...)។ ដូច្នេះ យន្តការនៃការបញ្ជាក់នោះ នឹងត្រូវបានអនុវត្ត ហើយវាអាចនឹងមិនត្រូវការឧបករណ៍ត្រួតពិនិត្យបន្ថែមទៀតឡើយ។ ប្រសិនបើមានផលិតកម្មមួយត្រូវបានគេជឿជាក់ថា បានអនុលោមតាមស្តង់ដារជាក់លាក់ណាមួយ ប៉ុន្តែក្នុងដំណាក់កាលផលិតកម្ម វាត្រូវបានគេរកឃើញថា មិនបានគោរពតាមស្តង់ដារទៀតនោះទេ ដូច្នេះការផ្តល់យោបល់ឱ្យជូនដំណឹងទៅកាន់អ្នកទិញភ្លាមៗ អាចត្រូវបានធ្វើឡើង ដោយគ្មានការពន្យាពេល ដើម្បីស្វែងរកដំណោះស្រាយសម្រាប់ការលក់ផលិតផលនោះ បើមិនដូច្នោះទេអ្នកទិញអាចស្វែងរកអ្នកផ្គត់ផ្គង់ផ្សេងទៀត។

**ការពន្យល់បន្ថែម ៥.១.ក**

**ការកែតម្រូវភ្លាមៗរបស់អ្នកផលិត និងបរិមាណដែលពាក់ព័ន្ធ ក្នុងដំណាក់កាលផលិតកម្ម ផ្អែកលើការគ្រប់គ្រងការអនុលោមតាមស្តង់ដារ**

ក្នុងករណីដែលកិច្ចសន្យាត្រូវធ្វើឡើងដោយ ក្រុមហ៊ុន អេមរុ រ៉ាយស៍ (AMRU Rice) ជាមួយនិង សហគមន៍កសិកម្មសម្រាប់ការផ្គត់ផ្គង់ស្រូវសរីរាង្គ កុងត្រានោះបង្ហាញអំពីបញ្ជីនៃអ្នកផលិត ផ្ទៃដី និងទិន្នផលរំពឹងទុក។

សហគមន៍មានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្ទាល់ខ្លួនរបស់គេ (ដែលបន្ទាប់មកត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យខាងក្រៅរបស់អង្គភាពបញ្ជាក់គុណភាពបន្ថែមទៀតសម្រាប់ការបញ្ជាក់សរីរាង្គ)។

ក្នុងពេលអនុវត្តអធិការកិច្ច សហគមន៍បានរកឃើញពីភាពបដិលោមដែលបណ្តាលឱ្យមានការដកចេញនូវអ្នកផលិតមួយចំនួនពីគ្រោងការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យានៃស្រូវសរីរាង្គ។ សហគមន៍បានជូនដំណឹងភ្លាមៗដល់ដៃគូរបស់គេ (ក្រុមហ៊ុន អេមរុ រ៉ាយស៍) និងផ្តល់នូវបញ្ជីកសិករដែលធ្វើបច្ចុប្បន្នភាពរួចហើយ ផ្ទៃដី និងទិន្នផលរំពឹងទុកដែលត្រូវធ្វើឱ្យបាន។

ក្នុងខែកក្កដា ឆ្នាំ ២០១៦ សហគមន៍ចំនួន១២បានចុះហត្ថលេខាលើកិច្ចសន្យាផលិតកម្មកសិកម្មដោយក្នុងនោះមានកសិករ១.៦៥៦រូប។ ប៉ុន្តែ បន្ទាប់ពីការតាមដានផ្ទៃក្នុងជុំទីមួយ មានកសិករ៦៩រូប ត្រូវបានរកឃើញថាមិនអនុលោមតាមតម្រូវការសរីរាង្គដែលកំណត់ ដូច្នេះហើយសហគមន៍បានផ្ញើបញ្ជីថ្មីដែលមានកសិករ ១.៥៨៧ រូប ដែលនៅសល់ ទៅឱ្យក្រុមហ៊ុន អេមរុ រ៉ាយស៍។

តម្លាភាព និងការជូនដំណឹងឆាប់រហ័សជារឿងសំខាន់ ដូច្នេះ យ៉ាងហោចណាស់អ្នកទិញអាចប្រមើលមើល និងពិចារណាប៉ាន់ប្រមាណអំពីស្ថានភាពនោះ (ជាពិសេសខណៈដែលក្រុមហ៊ុនធ្វើផែនការប្រគល់ទំនិញដល់អតិថិជនរបស់គេ)។ វាប្រសើរជាងការរង់ចាំរហូតដល់ពេលប្រមូលផលទើបជូនដំណឹង ហើយវាបានពង្រឹងនូវភាពជឿជាក់គ្នារវាងភាគីទាំងពីរ។

តារាង ៥.១.៦ ៖ ឧទាហរណ៍នៃបញ្ជីត្រួតពិនិត្យដើម្បីតាមដានការអនុវត្តការប្តេជ្ញាចិត្តរបស់ផលិតករដែលពាក់ព័ន្ធនឹងវិធីសាស្ត្រផលិតកម្ម

| លរ | ខសន្យាដែលត្រូវពិនិត្យ [ក] | ប្រភពព័ត៌មាន/ការបញ្ជាក់/ឯកសារគាំទ្រដែលត្រូវភ្ជាប់ [ខ] | អ្វីខ្លះ? [គ] | ពេលណា? [ឃ] | កំណត់សម្គាល់/បញ្ហាផ្សេងៗ [ង] | ដំណោះស្រាយដែលព្រមព្រៀង [ច] (ក្នុងករណីខុសពីកិច្ចសន្យា) | ហត្ថលេខានៃភាគីទាំងពីរ [ឆ] |
|---|---|---|---|---|---|---|---|
| ១.១ | ការរៀបចំដី | | | | | | |
| *ឧ.* | *១.១.១.* | *ភស្តុតាងនៃការទិញ* | | | | | |
| ១.២ | គ្រាប់ពូជដែលបានប្រើ | | | | | | |
| *ឧ.* | *១.២.១. ប្រើប្រាស់គ្រាប់ពូជដែលបានបញ្ជាក់* | *ភស្តុតាងនៃការទិញ* | | | | | |
| ១.៣ | ការប្រើប្រាស់ជី | | | | | | |
| *ឧ.* | *១.៣.១. ជីសរីរាង្គបាសាល់ (Basal)* | *សៀវភៅកសិករ* | | | | | |
| ១.៤ | ការថែទាំ/ ការត្រួតពិនិត្យសត្វល្អិត | | | | | | |
| *ឧ.* | *១.៤.១. ធ្វើតាមការអនុវត្ត អាយភីអឹម (IPM)* | *សៀវភៅកសិករ* | | | | | |

សម្គាល់៖ តារាងនេះគ្រាន់តែជាឧទាហរណ៍មួយ និងអាចធ្វើជាមូលដ្ឋានដើម្បីបង្កើតជាបញ្ជីត្រួតពិនិត្យពេញលេញមួយនៃការអនុវត្តខសន្យារបស់កសិករពាក់ព័ន្ធនឹងដំណើរការផលិត។ បញ្ជីត្រួតពិនិត្យនេះអាចថតចម្លងចេញជាពីរច្បាប់ (មួយច្បាប់សម្រាប់អ្នកទិញ និងមួយច្បាប់ទៀតសម្រាប់អ្នកផលិត ឬអង្គការកសិករ (FO) ហើយចុះហត្ថលេខាដោយភាគីទាំងពីរតាមដំណាក់កាលនីមួយៗ (ឧទាហរណ៍ ជួរនីមួយៗត្រូវនឹងខសន្យាមួយ)។ បន្ទាប់មក ភាគីនីមួយៗអាចរក្សាទុកវាជាភស្តុតាងនៃការអនុវត្តខសន្យា (ឯកសារនេះអាចធ្វើជាឯកសារយោងក្នុងករណីមានការខ្វែងគំនិតគ្នា)។

តារាងនេះអាចបង្កើតឡើង និងបំពេញដោយភាគីណាមួយ ឬបំពេញរួមគ្នាដោយភាគីទាំងពីរ ឬក៏បំពេញដោយអ្នកសម្របសម្រួល ឬអ្នកប៉ាន់ប្រមាណមកខាងក្រៅ អំឡុងពេលនៃការអនុវត្តកិច្ចសន្យា។ កម្មវត្ថុនៃបញ្ជីត្រួតពិនិត្យនេះ គឺដើម្បីធ្វើឱ្យប្រាកដថាគ្រប់ចំណុចព្រមព្រៀងទាំងអស់ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន ហើយភាពលំបាក ឬវិបត្តិនានាដែលកើតឡើងក្នុងដំណាក់កាលផលិត អាចលើកឡើង ពិភាក្សាគ្នា ហើយដោះស្រាយដោយភាគីទាំងពីរ។

អក្សរពណ៌ទឹកក្រូច គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ (ក្នុងករណីនេះ សម្រាប់ការដាំដុះរុក្ខជាតិ)

(ក) រៀបរាប់គ្រប់ខសន្យាទាំងអស់នៅក្នុងកិច្ចសន្យាដែលបានដាក់ដោយអ្នកផលិត ពាក់ព័ន្ធនឹងវិធីសាស្ត្រផលិត

(ខ) បង្ហាញពីប្រភពនៃការផ្ទៀងផ្ទាត់ (ឯកសារ) ដែលអាចភ្ជាប់មកជាមួយនឹងបញ្ជីត្រួតពិនិត្យនេះ

(គ) ឧទាហរណ៍បង្ហាញពីផលិតផល និងវត្ថុរាសដែលបានប្រើ (ជី...)

(ឃ) បង្ហាញពីកាលបរិច្ឆេទនៃការអនុវត្តប្រតិបត្តិការ (ការដាក់ជី ការថែទាំ...)

(ង) ប្រសិនបើជួបប្រទះនឹងវិបត្តិ ឬបញ្ហាផ្សេងៗ អាចបង្ហាញនៅក្នុងកូឡោននេះបាន

(ច) ដំណោះស្រាយដែលព្រមព្រៀងគ្នាដោយភាគីទាំងពីរ ដើម្បីដោះស្រាយបញ្ហាដែលអាចនឹងកើតមាន អាចសរសេរនៅទីនេះ ហើយចុះហត្ថលេខាដោយភាគីទាំងពីរ។ បន្ទាប់ពីចុះហត្ថលេខារួច ឯកសារនេះត្រូវបានចាត់ទុកជាវិសោធនកម្មមួយទៅលើកិច្ចសន្យានេះ។ ជាជម្រើស ឬលើសពីនេះទៀតនោះ សេចក្តីបន្ថែមលើកិច្ចសន្យាកាន់តែផ្លូវការ អាចចុះហត្ថលេខាដោយសាក្សី និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបំពេញបន្ថែមលើកិច្ចសន្យាដើម។

(ឆ) ភាគីទាំងពីរចុះហត្ថលេខាលើចំណុចនីមួយៗ។

### ៥.១.៣. ការប្រាស្រ័យទាក់ទង ការរាយការណ៍ក្នុងករណីមានបញ្ហា ឬស្ថានភាពមិនរំពឹងទុក

**បញ្ហាដែលមិនអាចដឹងជាមុននៅក្នុងកិច្ចសន្យា**

អំឡុងពេលនៃការអនុវត្តកិច្ចសន្យា អ្នកពាក់ព័ន្ធអាចប្រឈមមុខនឹងសំណួរនានាដែលពួកគេមិនបានដឹងមុនខណៈពេលដែលចុះកិច្ចសន្យា និងទាមទារឱ្យមានការឯកភាពគ្នារវាងភាគីទាំងពីរ។ ក្នុងករណីនេះ គេគួរលើកបញ្ហាដែលកត់សម្គាល់ឃើញនោះមកពិភាក្សាគ្នាឱ្យបានភ្លាមៗ ដើម្បីចៀសវាងពីប្រភពនៃការខ្វែងគំនិតគ្នាដែលអាចកើតមាន។ ពេលដែលគេបានរកឃើញ ឬ កត់សម្គាល់ឃើញថា មានចំណុចមួយចំនួនមិនបានបង្ហាញនៅក្នុងកិច្ចសន្យា ភាគីទាំងពីរគួរពិភាក្សានិងព្រមព្រៀងគ្នាលើការបញ្ជាក់បន្ថែម ឬ ការបន្ថែមប្រការនានា ទៅក្នុងវិសោធនកម្មលើកិច្ចសន្យានោះ។ ការឯកភាព (សេចក្តីបន្ថែមលើកិច្ចសន្យា) ត្រូវតែចុះហត្ថលេខាដោយភាគីទាំងពីរ យកល្អជាងនេះ ត្រូវមានហត្ថលេខាសាក្សីបន្ថែមទៀត និងមានការព្រមព្រៀងគ្នាដូចនឹងកិច្ចសន្យាដើម (សូមមើល ផ្នែកទី ៤.១៤.៤. ទំព័រទី ១១២)។

**ការប្រាស្រ័យទាក់ទង និងការប៉ាន់ប្រមាណពីការខូចខាត ក្នុងករណីនៃព្រឹត្តិការណ៍ហួសពីការគ្រប់គ្រង**

គេអាចជួបប្រទះស្ថានភាពដែលមិនអាចដឹងមុនមួយចំនួន ដែលវាប៉ះពាល់ដល់សមត្ថភាពរបស់ភាគីមួយក្នុងការបំពេញតាម ខ សន្យារបស់ខ្លួន៖ ឧទាហរណ៍ លក្ខខណ្ឌអាកាសធាតុមិនអំណោយផល ទឹកជំនន់ ភាពរាំងស្ងួត ការបំផ្លិចបំផ្លាញរបស់សត្វល្អិតដែលមិនអាចគ្រប់គ្រងបាន ការមិនអាចរកវត្ថុធាតុដើមបាននៅលើទីផ្សារ (ដូចជាវ៉ាក់សាំងសម្រាប់សត្វចិញ្ចឹមជាដើម)។ល។ ករណីនេះអាចស្ថិតនៅក្រោមករណី "ប្រធានសក្តិ" (សូមមើល ផ្នែកទី ៤.១០ ទំព័រទី ៩៥)។ ប៉ុន្តែ វានៅតែជារឿងសំខាន់សម្រាប់អ្នកផលិតដើម្បីទាក់ទងទៅអ្នកទិញភ្លាមៗលើបញ្ហាបែបនេះ ដើម្បីស្វែងរកដំណោះស្រាយប្រសិនបើអាច ម្យ៉ាងទៀត យ៉ាងហោចណាស់ឱ្យអ្នកលក់វាស់ស្ទង់ឱ្យបានហ្មត់ចត់នៅផ្នែកខាងគេដែរ។

សម្រាប់អ្នកផលិត និងអង្គការអ្នកផលិត៖ ចូរជូនដំណឹងដល់អ្នកទិញរបស់អ្នក ក្នុងករណីមានបញ្ហាដែលអាចប៉ះពាល់ដល់ទំហំ ឬគុណភាពនៃផលិតកម្ម ដែលអ្នកនឹងអាចប្រគល់បាន នៅពេលដែលអ្នកកំណត់ឃើញបញ្ហាភ្លាម។ កុំរង់ចាំរហូតដល់ពេលប្រគល់ទំនិញ។ ប្រសិនបើយើងជូនដំណឹងបានមុន វានឹងផ្តល់ភាពងាយស្រួលសម្រាប់អ្នកទិញ ដើម្បីសម្របខ្លួនទៅនឹងស្ថានភាពនោះ និងដោះស្រាយបញ្ហាជាអតិថិជនរបស់គេ ហើយភាពលំបាកនានាដែលបានជួបប្រទះ នឹងមានគ្រោះថ្នាក់តិចជាងមុនចំពោះការជឿជាក់របស់ដៃគូនិងភាពជាដៃគូរបស់អ្នក ជាជាងលាក់បាំងបញ្ហារហូតដល់នាទីចុងក្រោយ!



ក្នុងករណីមានគ្រោះធម្មជាតិ ឬព្រឹត្តិការណ៍ណាមួយដែលចាប់ទុកថាជាករណីប្រធានសក្តិ ដែលប៉ះពាល់ដល់ផលិតកម្ម ភាគីទាំងពីរគួរចុះទៅទីតាំងផលិត (វាលស្រែ) ជាមួយគ្នា ហើយវាយតម្លៃពីស្ថានភាពនោះដោយមានវត្តមានរបស់ភាគីទីបីដែលគួរទុកចិត្តបាន (ដូចជាអាជ្ញាធរមូលដ្ឋាន ឬ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ដែលអាចបញ្ជាក់បានថា ផលដែលបាត់បង់គឺហួសពីការគ្រប់គ្រងបានរបស់កសិករ និងបញ្ជាក់ពីនិទណ្ឌភាពរបស់ភាគីនីមួយៗពីការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងប្រការនៃកិច្ចសន្យាដែលពាក់ព័ន្ធនឹង "ហានិភ័យ និងប្រធានសក្តិ" (សូមមើលតារាង ៤.១.ក. ទំព័រ ៥០ និង ផ្នែកទី ៤.១០.១ ទំព័រ ៩៥-៩៧)។ ដោយផ្អែកលើវិសាលភាពនៃការខូចខាត កសិករអាចត្រូវបានរួចផុតទាំងស្រុង ឬ រួចផុតផ្នែកខ្លះពីការបំពេញកាតព្វកិច្ចរបស់ខ្លួន។

*◁ ក្នុងដីទំនាបព្រៃនប់ (ខេត្តព្រះសីហនុ) គណៈកម្មការដែលមានអាជ្ញាធរមូលដ្ឋានចូលរួម វាយតម្លៃផលខូចខាតក្រោយពីវាលស្រែត្រូវបានជន់លិចក្នុងឆ្នាំ ២០១៣ (រូបថត: MOWRAM / GRET គម្រោងស្តារឡើងវិញដីទំនាបព្រៃនប់)។*

ក្នុងករណីមានការខូចខាតផលិតកម្ម ដោយសារគ្រោះធម្មជាតិ ការបំផ្លិចបំផ្លាញដោយសត្វល្អិតធ្ងន់ធ្ងរ ឬជម្ងឺលើសត្វចិញ្ចឹម។ វាសំខាន់ណាស់ក្នុងការប៉ាន់តម្លៃ និងចងក្រងជាឯកសារពីករណីនោះជាផ្លូវការ ខណៈដែលហេតុការណ៍និងផលប៉ះពាល់របស់វានៅអាចមើលឃើញ។ ការចុះទៅវាលស្រែរួមគ្នា (ដោយភាគីទាំងពីរ និង/ឬ មានភាគីទីបី) គួរតែធ្វើខណៈដែលផលខូចខាតនៅមើលឃើញ ហើយការប៉ាន់ប្រមាណគួរតែចងក្រងឯកសារជារបាយការណ៍ដែលចុះហត្ថលេខាដោយភាគីទាំងពីរ និង/ឬ ភាគីទីបី យ៉ាងហោចណាស់មានច្បាប់ដើមពីរច្បាប់ (យកល្អបីច្បាប់ មួយច្បាប់ទៀតរក្សាទុកដោយភាគីទីបី)។

### ៥.១.៥. ឧទាហរណ៍នៃទម្រង់របាយការណ៍សម្រាប់ការវាយតម្លៃការខូចខាត និងការអនុគ្រោះពីការអនុវត្តកាតព្វកិច្ចសម្រាប់អ្នកផលិតក្នុងករណី "ប្រធានសក្តិ" ដូចជា គ្រោះធម្មជាតិជាដើម

**របាយករណ៍ លើការប៉ាន់ប្រមាណនៃផលខូតខាតដោយ ( ទឹកជំនន់ / រាំងស្ងួត /... ) លើផលិតកម្ម ________**

កាលបរិច្ឆេទ៖ ___ / ___/២០___

យោង៖ កិច្ចសន្យាផលិតកម្មកសិកម្ម លេខ៖ ________ ចុះហត្ថលេខាថ្ងៃទី___ / ___/២០___ រវាង ________________________________________ និង ________________________________________។

សមាសភាពនៃគណៈកម្មការ

- លោក / លោកស្រី ____________ អ្នកតំណាង តំណាងភាគីអ្នកផលិត
- លោក / លោកស្រី ____________ អ្នកតំណាងភាគីអ្នកទិញ
- លោក / លោកស្រី ____________ អ្នកតំណាងក្រុមប្រឹក្សាឃុំ (ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ឬ...)

តំបន់ត្រូវពិនិត្យ៖ (ពណ៌នាពីតំបន់នោះ និងផ្ទៃរបស់វា មានភ្ជាប់ផែនទីប្រសិនបើអាច)

ព្រឹត្តិការណ៍៖ (ទឹកជំនន់ / រាំងស្ងួត / ...) បង្ហាញពីកំណត់ត្រាភ្លៀងធ្លាក់ ឬការបង្ហាញស្តីពីព្រឹត្តិការណ៍។

ការប៉ាន់ប្រមាណផលខូចខាត៖

- មានការប៉ាន់ស្មានថា ផលិតកម្ម ១០០% ត្រូវបាត់បង់លើផ្ទៃដី ________ ហិចតា
- មានការប៉ាន់ស្មានថា ផលិតកម្ម ____% ត្រូវបាត់បង់លើផ្ទៃដី ________ ហិចតា
- ...

សរុប បរិមាណនៃផលិតកម្មដែលបាត់បង់តាមការប៉ាន់ប្រមាណមានប្រមាណ _________ តោន។

មានការព្រមព្រៀងគ្នារវាងភាគីទាំងពីរដែលកាតព្វកិច្ចនៃការប្រគល់ទំនិញដែលបានចែងក្នុងកិច្ចសន្យាផលិតកម្មកសិកម្មស្តីអំពី...................... លេខ__________ រវាង________________ និង ________________ ត្រូវបន្ថយតាមបរិមាណខាងលើ។ បរិមាណកែប្រែដែលត្រូវប្រគល់ស្ថិតក្រោមកិច្ចសន្យាផលិតកម្មកសិកម្មលេខ ______________ បច្ចុប្បន្ននេះគឺ _________ តោន (ឬឯកតាផ្សេងទៀត)។

ធ្វើនៅ៖ ________ (បញ្ចូលទីតាំង) ថ្ងៃទី ____/____ / ២០___ (បញ្ចូលថ្ងៃខែ)។

ហត្ថលេខា៖

| ____________________ | ____________________ | ____________________ |
|---|---|---|
| តំណាងកសិករ | តំណាងអ្នកទិញ | អាជ្ញាធរមូលដ្ឋាន/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសាម៉ី |

### ៥.១.៤. ការកែតម្រូវផ្សេងទៀតដើម្បីដោះស្រាយស្ថានការណ៍ដែលមើលមិនឃើញ

គេអាចកំណត់ និងគិតទុកមុននូវបញ្ហាមួយចំនួន ដោយប្រើប្រាស់ការតាមដាន និងការប្រាស្រ័យទាក់ទងល្អរវាងភាគីទាំងពីរអំឡុងពេលនៃការអនុវត្តកិច្ចសន្យា។ ការស្វែងយល់ពីគ្នាបានច្បាស់លាស់រវាងភាគីទាំងពីរនឹងអនុញ្ញាតឱ្យស្វែងរកដំណោះស្រាយ និងការសម្របសម្រួល និងកែប្រែលក្ខខណ្ឌនានាក្នុងកិច្ចសន្យានៅពេលចាំបាច់ ប្រសើរជាងលាក់បាំងបញ្ហាហើយប្រឈមមុខនឹងជម្លោះ នៅពេលដែលការប្រគល់ទំនិញចូលមកដល់។ ការជូនដំណឹងដោយមិនពន្យាពេល នៅពេលមានបញ្ហា ព្យាយាមព្យាករណ៍អំពីការលំបាកនានា និងស្វែងរកដំណោះស្រាយ គឺជារឿងដែលគួរតែធ្វើ។ ចៀសវាងនូវជម្លោះ ហើយពង្រឹងទំនុកចិត្ត។ ជួនកាលភាគីទាំងពីរអាចប្រឈមនឹងការលំបាកផ្សេងៗ ប៉ុន្តែព័ត៌មាន និងកិច្ចសន្ទនាល្អៗអាចជួយសម្របសម្រួល និងស្វែងរកដំណោះស្រាយល្អៗដល់ទាំងអ្នកផលិត និងអ្នកទិញ។

**ការបង្ហាញពីករណី ៥.១.គ**

**ការសម្រុះសម្រួលក្នុងពេលអនុវត្តដើម្បីដោះស្រាយបញ្ហាដែលភាគីទាំងពីរកំពុងប្រឈមមុខ**

ក្នុងឆ្នាំ ២០១៤ ក្រុមអ្នកផលិតដែលចូលរួមក្នុងកិច្ចសន្យាដើម្បីផ្គត់ផ្គង់ស្រូវ បានជួបនឹងបញ្ហានៃការគ្រប់គ្រងការប្រមូលផល ដែលនាំឱ្យគុណភាពស្រូវធ្លាក់ចុះជាងការរំពឹងទុក។ ផ្នែកមួយដ៏សំខាន់នៃស្រូវដែលបានផលិតរួចមានគុណភាពទាបជាងកម្រិតទាបបំផុតដែលបានកំណត់នៅក្នុងកិច្ចសន្យា។

ម្យ៉ាងទៀត អ្នកទិញ (រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញ) មានបញ្ហាជាមួយនឹងលំហូរសាច់ប្រាក់ដែលអាចបង្វិលបាន។

ភាគីទាំងពីរបានយល់ព្រមលើការសម្របសម្រួលដូចតទៅ៖ កម្រិតគុណភាពបន្ថែម (គុណភាពទាបជាងមុន) ត្រូវបានដាក់ទៅក្នុងលើកិច្ចសន្យា ដែលអនុញ្ញាតឱ្យកសិករលក់ស្រូវស្ទើរតែទាំងអស់ ហើយផ្គត់ផ្គង់ត្រឹមតែបរិមាណដែលរំពឹងទុកប៉ុណ្ណោះ ប៉ុន្តែការពន្យាពេលបន្ថែមចំពោះការទូទាត់ប្រាក់ (ពន្យាពីរបីថ្ងៃជំនួសឱ្យការទូទាត់ភ្លាមៗ) ទទួលបានការយល់ព្រមពីភាគីអ្នកផលិត។

## ៥.២. ពេលប្រមូលផល/ពេលប្រគល់ទំនិញ៖ ការធានាភាពរលូន

ពីរបីថ្ងៃ ឬ ពីរបីសប្តាហ៍មុនពេលប្រគល់ទំនិញ (រដូវប្រមូលផលផលិតផលបន្លែ) គួតែរៀបចំកិច្ចប្រជុំសម្របសម្រួលមួយរវាងភាគីទាំងពីរ ដើម្បីបញ្ជាក់ និងកែតម្រូវតួលេខស្តីពីបរិមាណដែលគេរំពឹងទុកថានឹងអាចផ្គត់ផ្គង់ និងដើម្បីពិភាក្សាលម្អិតអំពីការរៀបចំជាក់ស្តែង និងការរៀបចំភស្តុភារចំពោះការប្រមូល និងការប្រគល់ទំនិញ។ បញ្ហាជាច្រើនដែលត្រូវដោះស្រាយមានដូចជា៖ ពេលវេលាប្រមូលផលដែលល្អបំផុត ការចល័តម៉ាស៊ីនប្រមូលផល ការសម្ងួត ការបែងចែកការដឹកជញ្ជូន ការស្តុកទុក កៃច្នៃដើម្បីគ្រប់គ្រងគុណភាព ពេលវេលាប្រគល់ទំនិញ ទីតាំងទទួលទំនិញ។ ល។ កិច្ចសន្យាគួរតែបានកំណត់បញ្ហាមួយភាគធំទាំងនោះ (សូមមើលដោយកត់សម្គាល់ផ្នែកទី ៤.៨. ទំព័រ ៨៦-៩០) ប៉ុន្តែជាទូទៅ មិនមានការដាក់បញ្ចូលព័ត៌មានលម្អិតទៅក្នុងកិច្ចសន្យា ហើយចាំបាច់ត្រូវពិភាក្សា និងមានការព្រមព្រៀងគ្នាដើម្បីឱ្យការអនុវត្តបានរលូន។

បញ្ហាចម្បងដែលគួរតែពិភាក្សាសម្រេច និងត្រួតពិនិត្យឱ្យបានច្បាស់នៅដំណាក់កាលនេះ មានដូចខាងក្រោម៖

### ៥.២.១. ការកំណត់ពេលប្រមូលផល និងការប្រគល់ទំនិញ

កិច្ចសន្យាផលិតកម្មកសិកម្មជាទូទៅបង្ហាញពីរយៈពេលនៃការប្រមូលផល ប៉ុន្តែដោយមានការកំណត់ច្បាស់លាស់ (ចំនួនខែ ឬ ចំនួនសប្តាហ៍...)។នៅពេលប្រមូលផល ឬ ពេលប្រគល់ទំនិញខិតជិតមកដល់ គួតែធ្វើផែនការលម្អិតអំពីកាលបរិច្ឆេទប្រមូលផល និងការប្រមូលទិញ ដោយមានកាលវិភាគប្រចាំថ្ងៃចំពោះការប្រមូលទិញ។ អ្នកទិញគួរចុះទៅពិនិត្យទីតាំងផលិតកម្មជាមួយនឹងអ្នកផលិត ហើយវាយតម្លៃដំណាក់កាលនៃដំណាំទុំ ( ឬ ការលូតលាស់របស់សត្វ ឬ កាបំប៉នផលិតកម្មសត្វចិញ្ចឹម។ល។) ហើយនិងកំណត់កាលបរិច្ឆេទល្អបំផុតសម្រាប់ការប្រមូលផល / ប្រមូលទិញ។ កាលវិភាគនេះ គួររាប់បញ្ចូលទាំងពេលវេលាល្អបំផុតដើម្បីបង្កើនគុណភាពផលិតផលជាអតិបរមា ប៉ុន្តែឧបសគ្គរាំងស្ទះដល់ដំណើរការជាយថាហេតុ (កត្តាកំណត់នានា ដូចជា ភាពអាចរកបាននៃកម្លាំងពលកម្ម មានឧបករណ៍សម្រាប់ប្រមូលផលឬដឹកជញ្ជូន។ល។)។

នៅក្នុងករណីជាច្រើន ប្រសិនបើការប្រមូលទំនិញធ្វើត្រឹមតែម្តង ឬ ពីរបីដង ការព្រមព្រៀងលើកាលបរិច្ឆេទនៃការប្រមូលទំនិញត្រូវបានធ្វើដោយក្រៅផ្លូវការនិងដោយផ្ទាល់មាត់ (ឧទាហរណ៍ តាមរយៈទូរសព្ទ)។ ប៉ុន្តែដើម្បីចៀសផុតពីការឈ្លោះទាស់ទែងគ្នា យកល្អភាពគីទាំងពីរគួរតែសរសេរជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាលើផែនការប្រមូលទិញជាក់លាក់មួយ។ ការធ្វើបែបនេះ ប្រសិនបើកិច្ចសន្យានោះធ្វើឡើងតាមរយៈអង្គការកសិករ និងចូលរួមដោយអ្នកផលិត និងប្រតិបត្តិការនៃការប្រមូលផលិតផលជាច្រើនទៀត។នៅក្នុងករណីនោះ ផែនការត្រូវតែបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលានិងទីតាំងនៃការប្រគល់ទំនិញនីមួយៗ បរិមាណប៉ាន់ស្មាននៃទំនិញដែលត្រូវប្រមូលយកឱ្យបានច្បាស់លាស់ ហើយថាតើអ្នកផលិតណាខ្លះដែលត្រូវតែយកទំនិញរបស់ខ្លួនមកតាមថ្ងៃ និងទីតាំងដែលបានកំណត់ឱ្យ។

> ផែនការច្បាស់លាស់នៃការប្រមូលទំនិញ គឺពិតជាចាំបាច់ណាស់ ហើយត្រូវតែគោរពតាមយ៉ាងតឹងរ៉ឹង ក្នុងករណីដែលទំនិញនោះត្រូវរក្សានូវភាពស្រស់ និងទំនិញដែលងាយនឹងរលួយ។ បើពុំដូច្នោះទេ ការសម្របសម្រួលប្រតិបត្តិការប្រមូលទំនិញនឹងធូរលុង ហើយភ្លាមៗនោះនឹងនាំឱ្យបាត់បង់តម្លៃនៃទំនិញ ហើយអាចនឹងនាំឱ្យកើតមានជម្លោះលើការទទួលខុសត្រូវចំពោះការបាត់បង់ទាំងនោះថែមទៀតផង។

## ៥.២.២. តស្កុតារសម្រាប់ការប្រមូលផល និងការប្រគល់ទំនិញ

### ការជ្រើសរើសទីតាំងសម្រាប់ប្រមូលយកទំនិញ

ជួនកាលអ្នកផលិតទទួលខុសត្រូវនាំយកផលិតផលរបស់ខ្លួនទៅកាន់ទីតាំងរបស់អ្នកទិញ ( រោងចក្រកែច្នៃ )។ ប៉ុន្តែមានករណីភាគច្រើន អ្នកទិញនឹងមកប្រមូលយកផលិតផលពីតំបន់ផលិតកម្ម។ កន្លែងដែលផលិតផលត្រូវប្រមូលយក និងប្រគល់ពីអ្នកផលិតទៅកាន់អ្នកទិញ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់[29] ។

ការជ្រើសរើសទីតាំង ត្រូវតែពិចារណាលើកត្តាផ្សេងៗ ដូចជា ៖

- អាចឱ្យឡាន/រ៉ឺម៉កសណ្តោងចេញចូលបាន (គិតពីទំហំនិងទម្ងន់របស់ឡានលើផ្លូវជនបទ រួមទាំង
- ទម្ងន់ផ្ទុកអតិបរមាដែលស្ពានអាចទ្រទ្រង់បាន)
- ទីតាំងនៅក្បែរនឹងកន្លែងផលិត
- លទ្ធភាពដែលអាចរកទីដែលមានដំបូល ឬមានបរិក្ខារសម្រាប់រក្សាទំនិញបណ្តោះអាសន្ន
- ជាឧទាហរណ៍ ប្រសិនបើទំនិញនោះត្រូវរក្សាឱ្យផុតពីពន្លឺថ្ងៃ ឬទឹកភ្លៀង។

ប្រសិនបើមានអ្នកផលិតច្រើននៅលើផ្ទៃដីធំ គេអាចកំណត់កន្លែងប្រមូលយកទំនិញច្រើនកន្លែង ដើម្បីកាត់បន្ថយនូវការរៀបចំបែបបទនៃការប្រមូល (និងកាត់បន្ថយថ្លៃចំណាយផងដែរ)។ បរិមាណដើម្បីប្រមូលនៅតាមទីតាំង និងពេលដែលបានកំណត់ គួរតែបញ្ជាក់ដោយគិតពីទម្ងន់ផ្ទុកបានរបស់ឡាន។ ដើម្បីសន្សំថ្លៃចំណាយ វាមានសារសំខាន់ណាស់ក្នុងការកាត់បន្ថយចម្ងាយពីកសិដ្ឋានទៅកន្លែងប្រមូលយកទំនិញ (ដែលជាកន្លែងដែលទំនិញត្រូវដឹកជញ្ជូនក្នុងបរិមាណតិច ហើយជាទូទៅគឺតម្លៃដឹកជញ្ជូនថ្លៃជាង) ប៉ុន្តែក៏ដើម្បីចៀសវាងពីការចល័តឡានដែលនឹងមិនអាចផ្ទុកដល់សមត្ថភាពអតិបរមារបស់ឡាន។

> ប្រសិនបើមានទីតាំងប្រមូលទំនិញច្រើនកន្លែង ចូរធ្វើបញ្ជីនៃទីតាំងទាំងអស់និងកំណត់វាឱ្យបានច្បាស់លាស់ (ដាក់ឈ្មោះឬលេខឱ្យទីតាំងនីមួយៗ ហើយគូសវានៅលើផែនទី) ដូច្នេះវាងាយស្រួលដើម្បីមើលទៅទីតាំងនោះនៅក្នុងកាលវិភាគប្រមូលទំនិញ។

### មធ្យោបាយដឹកជញ្ជូន[30]

ជាគោលការណ៍ ភាគីអ្នកផលិតត្រូវទទួលខុសត្រូវលើការដឹកជញ្ជូនផលិតផលពីវាលស្រែ(ឬទីតាំងផលិត) ទៅកាន់កន្លែងប្រមូលយក។ ប្រសិនបើកិច្ចសន្យាត្រូវបានធ្វើជាមួយនឹងអង្គការកសិករ នោះអង្គការកសិករគួរបញ្ជាក់ជាផ្ទៃក្នុងឱ្យច្បាស់ជាមួយនឹងសមាជិករបស់ខ្លួន លើការរៀបចំដឹកជញ្ជូនផលិតផលរបស់គេទៅកាន់កន្លែងប្រមូលយក។ដូច្នេះ អ្នកទិញត្រូវទទួលខុសត្រូវរៀបចំដឹកជញ្ជូនពីទីតាំងប្រមូលនោះ ទៅកាន់ឃ្លាំង ឬរោងចក្ររបស់ខ្លួន ដែលដឹកដោយឡានដឹកទំនិញរបស់ខ្លួន ឬដោយឡានជួល។

ប្រសិនបើ អ្នកផលិតត្រូវដឹកជញ្ជូនផលិតផលទៅកាន់ទីតាំងរបស់អ្នកទិញ ដូច្នេះវាក៏សំខាន់សម្រាប់អ្នកផលិតផងដែរ (ជាពិសេស ក្នុងករណីដែលពាក់ព័ន្ធនិងអង្គការកសិករ) ដែលត្រូវកសាងផែនការមួយឱ្យបានច្បាស់លាស់ក្នុងការប្រមូលនិង ប្រគល់ទំនិញ ដើម្បីអាចកក់ឡានបានតាមតម្រូវការ។

---

[29] វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថាក្នុងករណីនៃផលិតផលសរីរាង្គ ទីតាំងប្រមូលយកត្រូវតែកំណត់និងដាក់ស្នើទៅអង្គភាពបញ្ជាក់គុណភាពមុនការធ្វើសវនកម្ម ដោយសារតែទីតាំងនោះត្រូវតែត្រួតពិនិត្យដោយអង្គភាពបញ្ជាក់គុណភាព ដើម្បីឱ្យប្រាកដថា ទីតាំងប្រមូលទំនិញនោះអនុលោមតាមកត្តាតម្រូវ ដោយផ្អែកលើស្តង់ដារសរីរាង្គ (គួរកត់សម្គាល់ថា ដើម្បីរារាំងនូវហានិភ័យនៃការចម្លងរោគផ្សេងៗ)។

[30] សូមមើលទៅផ្នែកទី ៤.៨.៣. ទំព័រ ៨៥

### ឧបករណ៍ប្រមូលផល

ប្រសិនបើត្រូវការប្រើឧបករណ៍ឬម៉ាស៊ីនពិសេសណាមួយដើម្បីប្រមូលផល ដូចជា៖ ម៉ាស៊ីនច្រូតស្រូវ (ដែលកសិករម្នាក់ៗអាចនឹងមិនមានផ្ទាល់ខ្លួន) ការរៀបចំផែនការច្រូតកាត់ច្បាស់លាស់នឹងជួយរៀបចំចល័តម៉ាស៊ីនទាំងនោះកក់សេវាជាមុន ហើយក៏បង្កើនប្រសិទ្ធភាពប្រើប្រាស់ម៉ាស៊ីននោះផងដែរ។ ប៉ុន្តែផ្ទុយពីនេះវិញ ប្រសិនបើមានឧបសគ្គមិនអាចរកឧបករណ៍ទាំងនេះបាន ការធ្វើផែនការប្រមូលយកផលត្រូវតែកែសម្រួលឡើងវិញ។ នេះគឺជាហេតុផលមួយទៀតដែលត្រូវគិតទុកជាមុន និងត្រៀមលក្ខណៈទុកជាមុនឱ្យបានគ្រប់គ្រាន់សម្រាប់ការប្រមូលផល ប្រសិនបើតម្រូវការទាំងអស់នេះត្រូវពឹងផ្អែកលើអ្នកផ្តល់សេវាខាងក្រៅ។

### បាវ និងកុងតឺន័រ

ប្រសិនបើមានការទាមទារឱ្យប្រើប្រាស់បាវ ឬ ឧបរណ៍សម្រាប់ច្រក (កុងតឺន័រ) ជាក់លាក់ណាមួយសម្រាប់វេចខ្ចប់ផលិតផលដែលទើបប្រមូលបាន មុនពេលដឹកជញ្ជូន ត្រូវប្រាកដថាបាវនិងឧបករណ៍សម្រាប់ច្រកទាំងនេះមកដល់ទាន់ពេលវេលា។ ក្នុងករណីខ្លះ អ្នកទិញជាអ្នកផ្តល់របស់ទាំងនេះ (ឧទាហរណ៍ សម្រាប់ផលិតផលសរីរាង្គ វាត្រូវការប្រើប្រាស់បាវថ្មីដែលផលិតពីវត្ថុធាតុដែលទទួលបានសិទ្ធិអនុញ្ញាត)។

### កម្លាំងពលកម្មសម្រាប់លើកឡើង/ចុះពីឡាន

ជាទូទៅគេយល់ (ហើយច្រើនតែបញ្ជាក់យ៉ាងច្បាស់ក្នុងកិច្ចសន្យា)ច្បាស់ថាអ្នកផលិតទទួលខុសត្រូវនាំយកផលិតផលរបស់គេមកដល់ទីតាំងប្រមូលយក បន្ទាប់មកអ្នកទិញទទួលខុសត្រូវលើការដឹកជញ្ជូនបន្តទៀត (ឧទា.រៀបចំឡាន) ។ ប៉ុន្តែ "តើអ្នកណាទទួលខុសត្រូវលើកឡើងឡាន" ជួនកាលជាបញ្ហាដែលភាគីទាំងអស់មិនបានចរចាគ្នា។

តាមធម្មតា គេយល់ថាភាគីដែលទទួលខុសត្រូវចំពោះឡានដឹកជញ្ជូនក៏ត្រូវទទួលខុសត្រូវលើការលើកដាក់ទំនិញឡាននោះដែរ។ ប៉ុន្តែដើម្បីចៀសពីជម្លោះណាមួយ ជានិច្ចកាលត្រូវបញ្ជាក់ឱ្យច្បាស់លើចំណុចនេះក្នុងពេលចរចាកិច្ចសន្យា ឬយ៉ាងហោចណាស់ខណៈដែលធ្វើផែនការលម្អិតសម្រាប់ប្រមូលទំនិញ។



*ការលើកដាក់ស្រូវនៅកន្លែងប្រមូលយកនៅព្រះវិហារ ▷*
*(រូបថត៖ អេមរុ ភិយស៍)*

## ទំនួលខុសត្រូវក្នុងករណីដែលភាគីណាមួយមិនអនុលោមតាមកាលវិភាគប្រគល់ទំនិញ និងគំរូដែលបានព្រមព្រៀងគ្នា

ការមិនអនុលោមតាមគំរូនិងពេលវេលាគ្រប់គ្រងការប្រមូលនិងការប្រគល់ទំនិញ អាចនាំឱ្យភាគីមួយ ឬ ច្រើន ខាតបង់។ ប្រសិនបើនីតិវិធីសម្រាប់ការគ្រប់គ្រងការប្រគល់ទំនិញ (ដោយមានកំណត់ទីតាំងនិងពេលវេលា) ត្រូវបានកំណត់ច្បាស់លាស់ នោះទំនួលខុសត្រូវក្នុងករណីដែលមានការមិនអនុលោមតាម ក៏ងាយស្រួលក្នុងការកំណត់ផងដែរហើយសំណងក៏អាចទាមទារបានសម្រាប់ការខាតបង់ជាបន្តបន្ទាប់ (ប្រសិនបើភាគីទាំងពីរមិនបានព្រមព្រៀងគ្នាលើការប៉ាន់ប្រមាណការខាតបង់ និងការសងសំណង ករណីនេះអាចបញ្ចូលទៅយន្តការដោះស្រាយជម្លោះ)។

ឧទាហរណ៍អំពីស្ថានភាពដែលអាចកើតមាននៅក្នុងការគ្រប់គ្រងការប្រគល់ទំនិញ និងការគ្រប់គ្រងហានិភ័យនៃការខាតបង់ ឬ ការចំណាយផ្សេងៗដែលពាក់ព័ន្ធ ដោយមិនបានគិតទុកជាមុន ៖

ឧទាហរណ៍ទី១៖ អ្នកផលិតនាំយកផលិតផលតាមពេល និងទីតាំងកំណត់ (កន្លែងប្រមូលយក) ប៉ុន្តែឡានរបស់អ្នកទិញមិនទាន់មកដល់ទីនោះ ដូច្នេះភាគីអ្នកផលិតអាចប្រឈមនឹងត្រូវចំណាយបន្ថែមទៀត នៅទីតាំងប្រមូលយកផលិតផលនោះ ដូចជា សំណងសម្រាប់ពេលវេលាដែលចំណាយលើការមើលថែទាំផលិតផលរបស់ខ្លួននិងថ្លៃស្តុក ជាដើម។ល។ ហើយគុណភាពនៃផលិតផលក៏អាចថយចុះដែរ (ជាពិសេសផលិតផលដែលអាចរលួយ ឬ ផលិតផលដែលមិនអាចរក្សាបានល្អពីពន្លឺថ្ងៃ/ភ្លៀងជាដើម)។

ឧទាហរណ៍ទី២៖ អ្នកទិញបញ្ជូនឡានទៅដឹកទំនិញនៅកន្លែង និងតាមពេលវេលាដែលបានព្រមព្រៀងគ្នា ប៉ុន្តែទំនិញមិនទាន់បានមកដល់ទីតាំងប្រមូលនោះទេ។ ដូច្នោះអ្នកទិញអាចនឹងប្រឈមមុខនឹងការបង់ថ្លៃចំណាយបន្ថែមឱ្យអ្នកបើកបរសម្រាប់ពេលវេលាដែលពួកគេត្រូវរង់ចាំនៅទីនោះ។

ឧទាហរណ៍ទី៣៖ ស្ពានបាក់នៅតាមបណ្តោយផ្លូវរវាងអ្នកផលិតនិងអ្នកទិញដែលនាំឱ្យមានការពន្យាពេលទៅយកទំនិញ។ ករណីនេះ ច្បាស់ណាស់វាមិនមែនជាទំនួលខុសត្រូវរបស់ភាគីណាមួយឡើយ ប៉ុន្តែទោះយ៉ាងណាក៏ដោយត្រូវតែមានការបញ្ជាក់ ហើយវាអាចនឹងមានផលវិបាកដល់ភាគីទាំងពីរថែមទៀតផង។ ស្ថានភាពបែបនេះអាចនឹងកើតមានឡើង ហើយត្រូវតែទទួលស្គាល់។

## ៥.២.៣ ការវាយតម្លៃគុណភាពនៅពេលប្រគល់ទំនិញក្នុងពេលផលិត

ប្រសិនបើកិច្ចសន្យាផលិតកម្មកសិកម្មដាក់បញ្ចូល (ជាទូទៅមានករណីនេះ) លក្ខខណ្ឌតម្រូវគុណភាពជាក់លាក់មួយចំនួនសម្រាប់ផលិតផលដែលត្រូវប្រគល់ឱ្យ (សូមមើលផ្នែកទី ៤.៤. ទំព័រទី ៦៣-៦៥) បន្ទាប់មក ការរៀបចំការផ្ទៀងផ្ទាត់គុណភាពត្រូវតែកំណត់ឱ្យបានច្បាស់លាស់។ នេះមិនមែនសំដៅតែទៅលើវិធីសាស្ត្រ និងឧបករណ៍ដែលគួរប្រើដើម្បីពិនិត្យពីគុណភាព (ដែលគួរតែមានចែងបញ្ជាក់នៅក្នុងកិច្ចសន្យាជាមួយនឹងព័ត៌មានលម្អិតគុណភាព) នោះទេ ប៉ុន្តែក៏គួរតែបញ្ជាក់ពីទីតាំងនិងពេលវេលានៃការគ្រប់គ្រងគុណភាព បុគ្គលិកបម្រុងសម្រាប់ការរៀបចំសង្វាក់នៃផលិតផលជាដើមផងដែរ។ ការបង្ហាញពីករណី ៥.២.ក. (ទំព័របន្ទាប់) បង្ហាញពីរបៀបនៃការគ្រប់គ្រងគុណភាពមិនបានល្អ (មិនមានប្រសិទ្ធភាពនិងពេលវេលាខ្លី) បាននាំឱ្យបរាជ័យក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ប៉ុន្តែមានផលិតកម្មមាននៅទីនោះដែរ។ ជាក់ស្តែងនេះគឺជាបញ្ហាសំខាន់ ជាពិសេសចំពោះផលិតផលស្រស់ៗ និងផលិតផលដែលអាចរលួយ។

សូមកត់សម្គាល់ថា ជួនកាលក្នុងការព្រមព្រៀងនៅក្នុងកិច្ចសន្យា មិនបានរាប់បញ្ចូលគ្រប់គុណភាពស្រូវទាំងអស់ដែលអាចផ្គត់ផ្គង់បានដោយអ្នកផលិត និងទិញយកដោយអ្នកទិញនោះឡើយ។ ក្នុងករណីនេះ អ្នកផលិតគួរតែស្នើសុំទៅអ្នកទិញ ហើយសម្រេចថាតើអ្នកទិញអាចទិញស្រូវមានគុណភាពគ្រប់ប្រភេទ ហើយព្រមព្រៀងគ្នាលើតម្លៃក្នុងអំឡុងនៃរដូវប្រមូលផលដែរ ឬ ទេ។

**ការបង្ហាញពីករណី ៥.២.ក.**

**ការបរាជ័យនៃកិច្ចសន្យាដោយសារមិនមាននីតិវិធីគ្រប់គ្រាន់សម្រាប់គ្រប់គ្រងគុណភាព**

នៅឆ្នាំ ២០១៣ រោងម៉ាស៊ីនកិនស្រូវ និងឈ្មួញនាំចេញបានបញ្ជាក់ពីការចង់ទិញស្រូវប្រមាណជា ៦០០ តោនពីសហគមន៍កសិករ ដោយមានបញ្ជាក់ពីលក្ខណៈតម្រូវលើគុណភាពយ៉ាងច្បាស់លាស់ (ភាពសុទ្ធនៃពូជអត្រាបាក់នៃគ្រាប់អង្ករ បរិមាណសំណើម...)។ តម្លៃទិញដែលបានផ្តល់ឱ្យគឺខ្ពស់ជាងតម្លៃដែលផ្តល់ដោយឈ្មួញក្នុងតំបន់។
ដោយសារតែស្រូវលក់នៅពេលសើម ដូច្នេះត្រូវតែដឹកជញ្ជូនទៅកាន់កន្លែងសម្ងួតចន្លោះពី ២៤-៤៨ ម៉ោង បន្ទាប់ពីប្រមូលផល។ ប៉ុន្តែអង្គភាពត្រួតពិនិត្យគុណភាពមិនបានរៀបចំត្រឹមត្រូវនោះទេ។ នៅពេលប្រមូលផលអ្នកទិញ បានបញ្ជូនបុគ្គលិកតែពីរនាក់ដើម្បីទៅទិញស្រូវពីសហគមន៍ ហើយអ្នកទាំងពីរនាក់នោះទៅពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀតដើម្បីត្រួតពិនិត្យគុណភាពរបស់ស្រូវ។ ប៉ុន្តែដំណើរការដូចដែលរៀបរាប់នេះ មានភាពយឺតយ៉ាវខ្លាំងពេក ដូច្នេះកសិករមិនអាចរង់ចាំហើយទុកឱ្យស្រូវរបស់គេនៅសើមបានឡើយ (បើស្រូវដូចនេះវាខូចគុណភាព) ហើយកសិករភាគច្រើនជាចុងក្រោយត្រូវលក់ស្រូវរបស់គេទៅឱ្យឈ្មួញក្នុងស្រុកទោះបីជាតម្លៃទាបជាងក៏ ដោយ។ ទីបំផុត មានស្រូវតែ ១០០ តោនប៉ុណ្ណោះ ដែលទិញបានពីស្រូវសរុប ៦០០ តោន ហើយការបរាជ័យនេះទំនងជាមកពីខ្វះការរៀបចំនីតិវិធីត្រួតពិនិត្យគុណភាព ហើយក៏ដោយសារចំណាយពេលច្រើនពេកផងដែរ។

ក្នុងករណីនៃកិច្ចសន្យាធ្វើឡើងតាមរយៈអង្គការកសិករ គុណភាពនៃផលិតផលអាចត្រូវត្រួតពិនិត្យមុនដោយអង្គការកសិករជាមួយនឹងសមាជិករបស់ខ្លួន ហើយបន្ទាប់មកត្រួតពិនិត្យដោយអ្នកទិញ ដោយការយកសំណាកមួយចំនួនទៅពិនិត្យមើលថាគុណភាពនៃផលិតផលដែលត្រូវវាយតម្លៃដោយអង្គការកសិករ ត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងកិច្ចសន្យាដែរឬទេ។ សម្រាប់គោលបំណងនេះ អង្គការកសិករនឹងចាត់តាំងគណៈកម្មាធិការមួយ (ដោយមានសមាសភាពមកពីសមាជិករបស់ខ្លួនខ្លះ ឬបើអាចមកពីអ្នកខាងក្រៅខ្លះ) ដើម្បីអនុវត្តការប៉ាន់ប្រមាណគុណភាព។ គណៈកម្មាធិការនេះត្រូវតែទទួលការបណ្តុះបណ្តាលសម្រាប់អនុវត្តតួនាទីនេះ។

វគ្គបណ្តុះបណ្តាលអាចផ្តល់ដោយអ្នកទិញ ដូច្នេះគេនឹងច្បាស់ថាវិធីសាស្ត្រដែល បានប្រើ អនុលោមតាមនីតិវិធីរបស់ខ្លួន។ សូមកត់សម្គាល់ថា វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគុណភាព នេះអាចបញ្ជាក់នៅក្នុងកិច្ចសន្យាពេលដែលមានការគាំទ្រផ្តល់ដោយអ្នកទិញ។ (សូមមើលដោយពិស្តារនៅក្នុងផ្នែកទី ៧.៣. ទំព័រ ១៦៨ ស្តីពីបញ្ហានៃការគ្រប់គ្រងគុណភាពជាមួយនឹងសហគមន៍ និងអង្គការកសិករ)។

## ៥.២.៤. កំណត់ហេតុផ្ទេរប្រគល់ទំនិញ

ព័ត៌មាននៃការប្រគល់ទំនិញចាំបាច់ណាស់ ព្រោះគេប្រើវាជាឯកសារយោងសម្រាប់ការទូទាត់ប្រាក់។ ទម្រង់នៃលិខិតបញ្ជាក់ពីការប្រគល់ទំនិញគួរតែបង្កើតឡើងនិងព្រមព្រៀងរវាងភាគីទាំងពីរ។ សម្រាប់ប្រតិបត្តិការប្រគល់ទំនិញម្តងៗ លិខិតបញ្ជាក់ពីការប្រគល់ទំនិញគួរតែចេញជាពីរច្បាប់ ហើយចុះហត្ថលេខាដោយភាគីទាំងពីរ (អ្នកទិញ និងអ្នកផលិត)។ ភាគីនីមួយៗ គួររក្សាទុកមួយច្បាប់ម្នាក់។

លិខិតបញ្ជាក់ពីការប្រគល់ទំនិញ គួរតែបញ្ជាក់ដោយមានលេខ និងបង្ហាញសេចក្តីបញ្ជាក់ដូចខាងក្រោម ៖

- យោងទៅលើកិច្ចសន្យា (លេខកិច្ចសន្យា)
- កាលបរិច្ឆេទ (និងម៉ោង ប្រសិនបើអាច) នៃការប្រគល់
- ទីកន្លែងប្រគល់
- សភាពនៃផលិតផលដែលបានប្រគល់
- បរិមាណនៃផលិតផលដែលបានប្រគល់
- កម្រិតគុណភាព
- តម្លៃដែលបានព្រមព្រៀងគ្នាអាស្រ័យលើគុណភាពផលិតផល

សមាសភាពពិស្តាររបស់បណ្តុំនៃផលិតផលដែលបានប្រគល់ឱ្យ អាចនឹងភ្ជាប់ទៅជាមួយនឹងលិខិតបញ្ជាក់ពីការប្រគល់ទំនិញ (ឧទាហរណ៍ ចំនួនបាវ បរិមាណក្នុងបាវនីមួយៗ ក្នុងករណីនៃអង្គការអ្នកផលិត ឈ្មោះអ្នកផលិតសម្រាប់បណ្តុំនៃផលិតផលនីមួយៗ ...)[31]។

អ្នកដែលទទួលខុសត្រូវ គួរតែដឹងឱ្យច្បាស់ពីរបៀបបំពេញ និងចុះបញ្ជីលិខិតបញ្ជាក់ពីការប្រគល់ទំនិញទាំងនេះ។ ប្រសិនបើចាំបាច់ គួរតែបណ្តុះបណ្តាលពួកគេឱ្យធ្វើការងារនេះ។

## ៥.២.៥. តម្លៃ និងការទូទាត់ប្រាក់

### តម្លៃ

តម្លៃ ឬ គំរូនៃការកំណត់តម្លៃត្រូវតែអនុវត្តឱ្យបានតាមដែលមានចែងនៅក្នុងកិច្ចសន្យា ហើយមិនគួរពិភាក្សាគ្នាជាថ្មីនៅពេលប្រមូលផលនោះឡើយ។ ប៉ុន្តែប្រសិនបើនៅពេលតម្លៃមិនបានកំណត់ឱ្យនៅថេរបែរជាផ្អែកលើឯកសារយោង នោះវាត្រូវតែតម្រូវឱ្យភាគីទាំងពីរស្វះស្វែងរកព័ត៌មានចុងក្រោយអំពីឯកសារយោងពីតម្លៃដែលប្រើចំរដូវប្រមូលផល/រដូវប្រគល់ទំនិញ (ឬ ក្នុងថ្ងៃមុនប៉ុន្មានថ្ងៃ) ហើយផ្ទៀងផ្ទាត់ថាពួកគេបានព្រមព្រៀងគ្នាលើតួលេខដូចគ្នា ឬ ទេ។ ប្រសិនបើមានភាពខុសគ្នាលើឯកសារយោងនៃតម្លៃដែលរកបានដោយភាគីណាមួយ ភាគីទាំងពីរគួរតែពិភាក្សាគ្នាហើយស្វែងរកការព្រមព្រៀងរួមគ្នាមួយលើឯកសារយោងនោះ។

[31] នេះអាចចាំបាច់នៅពេលដែលលក្ខខណ្ឌតម្រូវភាពអាចវាស់វែងបានខ្ពស់ ឧទាហរណ៍ ផលិតផលដែលមកជាមួយនឹងការបញ្ជាក់ ដូចជាផលិតផលសរីរាង្គ ឬសូចនាករភូមិសាស្ត្រផលិតផល។

### ការពន្យល់បន្ថែម ៥.២.ខ.

### កិច្ចព្រមព្រៀងស្តីពីការយោងតម្លៃ៖ ការពន្យល់ជាក់ស្តែងនៅក្នុងកិច្ចសន្យាសម្រាប់ការផ្គត់ផ្គង់ស្រូវនៅខេត្តព្រះវិហារ

នៅក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម ដែលបានចុះហត្ថលេខារវាង ក្រុមហ៊ុន AMRU Rice និងសហគមន៍ផ្គត់ផ្គង់ស្រូវនៅខេត្តព្រះវិហារ ប្រព័ន្ធតម្លៃគឺផ្អែកលើគំរូ "តម្លៃទីផ្សារ + បុព្វលាភ" (សូមមើលផ្នែកទី ៤.៧.៣. ទំព័រ ៨១)។ ឯកសារយោងតម្លៃដែលប្រើគឺជា "តម្លៃទីផ្សារខ្ពស់បំផុតដែលផ្តល់ដោយរោងម៉ាស៊ីនកិនស្រូវធំៗចំនួន៣ ពីខេត្តជុំវិញខេត្តកំពង់ធំ (ព្រមព្រៀងដោយភាគីទាំងពីរ) សម្រាប់ស្រូវប្រភេទប្រហាក់ប្រហែលគ្នា (ធម្មតា) ក្នុងរយៈពេល៧ថ្ងៃ មុនពេលចាប់ផ្តើមប្រមូលស្រូវ"។

ដូច្នេះ តាមការអនុវត្ត នៅមុនរដូវប្រមូលផលចូលមកដល់ តំណាងរបស់សហគមន៍ផ្ទៀងផ្ទាត់តម្លៃដែលបានលើកឡើងដោយរោងម៉ាស៊ីន (ហើយគេក៏ផ្ទៀងផ្ទាត់ជាមួយនឹងឈ្មួញក្នុងតំបន់សម្រាប់ធ្វើជាតម្លៃយោងផ្ទាល់ខ្លួនផងដែរ) ហើយបន្ទាប់មកគេក៏ដាក់ស្នើតម្លៃនោះជាតម្លៃយោងសម្រាប់រដូវប្រមូលផលនោះ។ ចំណែកឯខាងក្រុមហ៊ុន AMRU Rice វិញ ក៏ធ្វើការប៉ាន់ប្រមាណដោយខ្លួនឯងផងដែរ ហើយដោយផ្អែកលើ "ការស្ទាបស្ទង់តម្លៃ" របស់គេ ភាគីទាំងពីរជួបគ្នាដើម្បីផ្ទៀងផ្ទាត់តួលេខគ្នាទៅវិញទៅមក ហើយព្រមព្រៀងលើតម្លៃយោងរួមមួយសម្រាប់រដូវកាលនោះ។

## ការទូរទាត់ប្រាក់

ការទូទាត់តម្លៃទំនិញដែលប្រគល់រួចហើយ ត្រូវតែអនុលោមតាមបែបបទដែលបានកំណត់នៅក្នុងកិច្ចសន្យា (ដោយគិតពីពេលទូទាត់ របៀបទូទាត់។ល។) ការផ្តល់យោបល់ផ្សេងៗអំពីជម្រើស / បែបបទនៃការទូទាត់ប្រាក់ដែលអាចធ្វើបាន ត្រូវបានធ្វើរួចជាស្រេចនៅក្នុងផ្នែកទី ៤.៩. នៃសៀវភៅនេះ (ទំព័រ ៩០-៩៤)។ សូមកត់សម្គាល់ថា គុណសម្បត្តិ និងគុណវិបត្តិនៃការទូទាត់ជាសាច់ប្រាក់ ដោយសែក ឬ ការផ្ទេរតាមធនាគារ ត្រូវបានបង្ហាញនៅក្នុងតារាង ៤.៩.ក. ទំព័រ ៩០។

ក្នុងករណីមួយចំនួន ជាពិសេសពេលដែលទំនិញបានប្រគល់ក្នុងរយៈច្រើនថ្ងៃហើយបានទូទាត់ប្រាក់ជាមួយគ្នាក្នុងពេលតែមួយ អ្នកផលិតត្រូវបានតម្រូវឱ្យចេញវិក្កយបត្រដើម្បីស្នើការទូទាត់ថ្លៃទំនិញដែលបានប្រគល់រួចហើយ រួមជាមួយប័ណ្ណកត់ត្រាការប្រគល់ទំនិញទាំងអស់។ តារាង ៥.២.ក. ខាងក្រោមនេះ ផ្តល់ការបង្ហាញបន្ថែមទៀតថាតើប្រព័ន្ធនៃការចេញវិក្កយបត្រ និងវិក្កយបត្រទូទាត់ប្រាក់ណាខ្លះ ដែលសាកសមនឹងស្ថានភាពខុសៗគ្នា។

តារាង ៥.២.ក. ៖ លិខិតផ្ទេរប្រគល់ និងបង្កាន់ដៃទូទាត់ប្រាក់ ឬតម្រូវការសម្រាប់ការចេញវិក្កយបត្រដែលផ្អែកលើស្ថានភាពជាក់ស្តែង

| | ការទូទាត់ភ្លាមពេលប្រគល់ទំនិញ | ទូទាត់ជាតែម្តងសម្រាប់ការប្រគល់ទំនិញច្រើនលើក ឬក៏ពន្យាពេលទូទាត់ |
|---|---|---|
| **អ្នកផលិតដាច់ដោយឡែកពីគ្នា** | ប្រសិនបើកិច្ចសន្យាធ្វើឡើងជាមួយអ្នកផលិតផ្សេងៗពីគ្នា ហើយការទូទាត់ត្រូវធ្វើភ្លាមបន្ទាប់ពីប្រគល់ទំនិញ ប្រហែលជាមិនចាំបាច់បង្កើតទម្រង់នៃការទូទាត់នោះឡើយ។ ការគ្រប់គ្រងការប្រគល់ និងការទូទាត់ប្រាក់អាចធ្វើឡើងដោយដោយគ្រាន់តែមានវិក្កយបត្រប្រគល់ និងវិក្កយបត្រទូទាត់ប្រាក់ ជាការស្រេច (ធ្វើជាពីរច្បាប់ ហើយចុះហត្ថលេខានិងរក្សាទុកដោយ ភាគីទាំងពីរ)។ | ប្រសិនបើការទូទាត់ប្រាក់មិនបានធ្វើសម្រាប់ការប្រគល់ទំនិញមួយលើកៗនោះទេ ប៉ុន្តែការទូទាត់ប្រាក់ត្រូវធ្វើឡើងតែម្តងសម្រាប់ប្រតិបត្តិការច្រើនដងវិញ យកល្អគួរតែមានទម្រង់នៃវិក្កយប័ត្រទូទាត់ប្រាក់ដែលយោងទៅតាមវិក្កយបត្រប្រគល់ទំនិញទាំងអស់ ដែលមិនទាន់បានទូទាត់។ វិក្កយប័ត្រប្រគល់ទំនិញជាច្រើនច្បាប់គួរតែភ្ជាប់មកជាមួយនឹងវិក្កយប័ត្រទូទាត់ (ឬវិក្កយប័ត្រប្រគល់ទំនិញគួរតែបង់លេខ ហើយវិក្កយប័ត្រទូទាត់គួរតែយោងទៅតាមទៅវិក្កយបត្រប្រគល់ទំនិញទាំងនោះ។ |
| អង្គការកសិករ (អង្គការកសិករ) / សហគមន៍កសិកម្ម (AC) | ក្នុងករណីដែលកិច្ចសន្យាធ្វើជាមួយនឹងអង្គការកសិករ អ្នកផលិតជាច្រើននាក់អាចនឹងនាំយកទំនិញរបស់គេមកកាន់ទីតាំងប្រគល់ទំនិញ ហើយវិក្កយប័ត្រនឹងចេញដាច់ដោយឡែកពីគ្នាសម្រាប់ទំនិញដែលនាំមកដោយអ្នកផលិតម្នាក់ៗ ដែលជាសមាជិកនៃ អង្គការកសិករ/សហគមន៍កសិកម្ម។ ប៉ុន្តែភាគីចុះកិច្ចសន្យាដែលជាអង្គការកសិករ/សហគមន៍កសិកម្ម គួរតែជាអ្នកចេញវិក្កយបត្រសម្រាប់ទូទាត់គ្រប់ទំនិញទាំងអស់ដែលបានប្រគល់ យោងទៅតាមវិក្កយបត្រទទួលទំនិញនីមួយៗ។ | ប្រសិនបើការទូទាត់មិនត្រូវបានធ្វើឡើងសម្រាប់ការប្រគល់ទំនិញមួយលើកៗទេ ប៉ុន្តែការទូទាត់ប្រាក់ត្រូវធ្វើឡើងតែម្តងសម្រាប់ប្រតិបត្តិការច្រើនដងវិញ នោះ អង្គការកសិករ/សហគមន៍កសិកម្ម គួរតែជាអ្នកចេញវិក្កយបត្រសម្រាប់ទូទាត់គ្រប់ទំនិញទាំងអស់ដែលបានប្រគល់ យោងទៅតាមវិក្កយប័ត្រទទួលទំនិញនីមួយៗ។ |

## ៥.៣. ក្រោយការអនុវត្ត៖ ការប៉ាន់ប្រមាណលទ្ធផល កំណត់រកបញ្ហាដើម្បីកែលម្អកិច្ចសន្យាថ្មី

ក្រោយពីការអនុវត្តត្រូវបានបញ្ចប់ហើយកិច្ចសន្យាត្រូវបានបិទ ប្រសិនបើអ្នកទិញនិងអ្នកផលិតចង់បន្តភាពជាដៃគូ ហើយចុះកិច្ចសន្យាផលិតកម្មកសិកម្មជាថ្មីឡើងវិញ សម្រាប់វដ្តផលិតកម្មបន្តទៀតនោះពួកគេត្រូវចំណាយពេលដើម្បីជួបគ្នា[32] ហើយពិនិត្យឡើងវិញនូវការអនុវត្តកិច្ចសន្យាលើកមុន ដើម្បីកំណត់រាល់ការលំបាក បញ្ហា និងបទពិសោធន៍ទាំងអស់ ជាមួយនឹងវត្ថុបំណងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌនានារបស់ផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងភាគីទាំងពីរក្នុងរដូវកាល ឬ វដ្តផលិតកម្មបន្តបន្ទាប់ទៀត។

ដើម្បីវិភាគការអនុវត្តកិច្ចសន្យា និងប៉ាន់ប្រមាណលទ្ធផល និងការពេញចិត្ត យើងអាចបង្កើតរចនាសម្ព័ន្ធប៉ាន់ប្រមាណដំណើរការក្នុងក្រុមសំណួរធំៗចំនួន៣ គឺ៖

- ការគោរពលក្ខខណ្ឌនៃកិច្ចសន្យា
- ការកំណត់ចំណុចផ្សេងៗដែលត្រូវមានការព្រមព្រៀងរវាងភាគីទាំងពីរ ប៉ុន្តែមិនមានចែងជាលក្ខខណ្ឌក្នុងកិច្ចសន្យា។
- ការពេញចិត្តរបស់ភាគីទាំងអស់ (អត្ថប្រយោជន៍ផ្សេងៗ / គោលដៅចុងក្រោយនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា បានទៅដល់ឬអត់)។

ទិដ្ឋភាពទាំងបីយ៉ាងនេះ គឺបានពាក់ព័ន្ធគ្នាដោយផ្នែកៗ មិនទាំងស្រុងនោះទេ។ ឧទាហរណ៍ លក្ខខណ្ឌនៃកិច្ចសន្យា ត្រូវបានគេគោរពដោយពេញលេញ តែភាគីម្ខាង (ទាំងពីរ ឬ ទាំងអស់) មិនពេញចិត្តនឹងការអនុវត្តទេ មានន័យថា គេមិនបានចរចាឱ្យបានល្អិតល្អន់លើកិច្ចសន្យានោះឡើយ ឬ ក៏មិនល្អិតល្អន់លើចំណុចសំខាន់ៗមួយចំនួន។

### ៥.៣.១. ប៉ាន់ប្រមាណលើការគោរពលក្ខខណ្ឌនៃកិច្ចសន្យា

ទិដ្ឋភាពដំបូងនៃការប៉ាន់ប្រមាណការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មនេះ គឺត្រូវពឹងផ្អែកលើការពិនិត្យឲ្យល្អិតល្អន់នៃការគោរពជាក់ស្តែងចំណុចនីមួយៗនៃកិច្ចសន្យា។

ការពិនិត្យនេះអាចធ្វើបានដោយងាយស្រួល ដោយគ្រាន់តែប្រើបញ្ជី/តារាងផ្ទៀងផ្ទាត់សាមញ្ញមួយដើម្បីពិនិត្យចំណុចនីមួយៗឡើងវិញ ដែលរាប់បញ្ចូលទាំងការបញ្ជាក់អំពីការអនុលោមរបស់ទំនិញដែលបានប្រគល់ឱ្យ (ជាបរិមាណ និងគុណភាព) ទៅលើតម្លៃដែលបានបង់ ពេលវេលានៃការទូទាត់។ល។ តារាង ៥.៣.ក. នៅទំព័របន្ទាប់នេះ បានបង្ហាញពីគំរូនៃបញ្ជីត្រួតពិនិត្យបែបនេះ។ វាផ្អែកលើឧទាហរណ៍បែបប្រឌិតអំពីការចិញ្ចឹមមាន់ ប៉ុន្តែវាអាចយកទៅប្រើបានចំពោះកិច្ចសន្យាដទៃ។

[32] ជាអនុសាសន៍ មុនពេលជួបជាមួយនឹងដៃគូរបស់គេ ភាគីម្ខាងៗត្រូវត្រៀមការពិនិត្យផ្ទៃក្នុងឡើងវិញរៀងៗខ្លួនជាមុនសិន។ ជាពិសេស អង្គការកសិករ គួរតែពិនិត្យផ្ទៃក្នុងឡើងវិញជាមុន ហើយកំណត់ការលំបាក បញ្ហា និងបញ្ហាដែលគេចង់លើកឡើងមកពិភាក្សា។

គេគួរតែទុកកន្លែងទំនេរមួយនៅក្នុងបញ្ជីត្រួតពិនិត្យនេះសម្រាប់មតិកែលម្អ និងកំណត់សម្គាល់។ ជាការពិតណាស់ ប្រសិនបើបរិមាណមួយចំនួនអាចងាយស្រួលប៉ាន់ប្រមាណ (ឧទាហរណ៍ ចំនួន) គូភាគីអាចនឹងមានជម្រើសខុសៗគ្នាពាក់ព័ន្ធនឹងការគោរព ឬ មិនគោរពតាមលក្ខខណ្ឌនៃប្រការជាក់លាក់នានានៃកិច្ចសន្យាដែលអាចបង្ហាញពីការបកស្រាយខុសៗពីគ្នា។ នេះអាចជាស្ថានភាពដែលតែងតែកើតឡើង។ ប្រសិនបើការបកស្រាយខុសៗពីគ្នាអាចនឹងកើតមានឡើង នោះមានន័យថាការប្រើប្រាស់ពាក្យក្នុងកិច្ចសន្យាត្រូវតែកែលម្អយ៉ាងណាដើម្បីធ្វើឱ្យចំណុចនីមួយៗងាយស្រួលយល់។ ការវិភាគនេះនឹងមានប្រយោជន៍ ដើម្បីធ្វើឱ្យកិច្ចសន្យាប្រសើរឡើងប្រសិនបើភាគីដែលចុះកិច្ចសន្យា ចង់បន្តភាពជាដៃគូរបស់គេ។

ត្រូវតែលើកហេតុផលមកពិភាក្សា ប្រសិនបើចំណុចមួយចំនួនមិនត្រូវបានគោរពតាម។ ជាឧទាហរណ៍ ប្រសិនបើអ្នកផលិតមិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវទាក់ទងនឹងវិធីសាស្ត្រនៃការផលិត ត្រូវតែធ្វើការកត់សម្គាល់អំពីឧបសគ្គ ហើយកិច្ចសន្យាបន្ទាប់ទៀតនឹងអាចជួយដោះស្រាយវាបាន។ ឬ ក៏ចំណុចខ្លះអាចត្រូវបានលុបចេញពីកិច្ចសន្យាថ្មី ប្រសិនបើវាពិបាកនឹងធ្វើឱ្យបានជោគជ័យ ហើយវាមិនសំខាន់ខ្លាំងសម្រាប់អ្នកទិញនោះទេ។ ឧទាហរណ៍មួយទៀត ប្រសិនបើកម្រិតនៃគុណភាពដែលទាមទារនៅក្នុងកិច្ចសន្យាមិនអាចធ្វើសម្រេចបាន ដំណោះស្រាយអាចស្វែងរកបានដោយមានការគាំទ្របន្ថែម ដែលផ្តល់ដោយអ្នកទិញនៅក្នុងដំណាក់កាលនៃភាពជាដៃគូថ្មី (វគ្គបណ្តុះបណ្តាលបន្ថែម អាចផ្តល់វត្ថុធាតុដើមដែលមានគុណភាពល្អជាងមុន។ល។)

តារាង ៥.៣.ក. ៖ បញ្ជីត្រួតពិនិត្យសម្រាប់ការពិនិត្យមើលការអនុវត្តជាក់ស្តែងចំពោះលក្ខខណ្ឌនៃកិច្ចសន្យា (ឧ. ការចិញ្ចឹមមាន់)

| ប្រធានបទ/មាត្រា | ខ្លឹមសារ (១) | ការអនុវត្តអនុលោមតាម | យោបល់/កំណត់សម្គាល់ | ការកែលម្អដែលត្រូវធ្វើ |
|---|---|---|---|---|
| មាត្រា ៣. កាតព្វកិច្ចនៃអ្នកផលិត | *គោរពតាមលក្ខណៈពិសេសនៃការសាងសង់ទ្រុងមាន់* | ◉◉◉○○ | *លក្ខណៈពិសេសមិនត្រូវបានគោរពតាមទាំងស្រុងទេ យោងលើអ្នកទិញ (ចំនួនមាន់ច្រើនពេកក្នុងមួយម$^2$)។ ប៉ុន្តែលក្ខណៈនោះមិនបានបញ្ជាក់ឱ្យច្បាស់គ្រប់គ្រាន់ ហើយអ្នកផលិតយល់មិនគ្រប់ជ្រុងជ្រោយ ។* | *ត្រូវធ្វើការពណ៌នាពីតម្រូវការឱ្យច្បាស់លាស់ជាងនេះ ។* |
| | *ប្រើតែចំណីដែលផ្តល់ដោយអ្នកទិញ ។* | ◉◉◉◉◉ | | |
| មាត្រា ៤. ការគាំទ្រដែលត្រូវផ្តល់ដោយអ្នកទិញ | *ផ្តល់វគ្គបណ្តុះបណ្តាល* | ◉◉◉○○ | *ការបណ្តុះបណ្តាលត្រឹមតែកន្លះថ្ងៃ ។ មិនបានធ្វើឱ្យអ្នកផលិតពេញចិត្ត ។* | *បញ្ជាក់ពីពេលវេលាដែលត្រូវការនិងខ្លឹមសារនៃវគ្គបណ្តុះបណ្តាលដែលត្រូវផ្តល់នៅក្នុងកិច្ចសន្យា ។* |
| | *ផ្តល់ថ្នាំវ៉ាក់សាំងប្រឆាំងជម្ងឺ ញូកើសសម្រាប់មាន់បានអាយុ១ថ្ងៃ ។* | ◉◉◉◉◉ | | |
| | *ផ្តល់ចំណីទាន់ពេលវេលា* | ◉◉◉◉◉ | | |
| | *ផ្តល់ពេទ្យសត្វដើម្បីជួយក្នុងករណីមានជម្ងឺផ្ទុះឡើង (ក្នុងរយៈពេល២៤ម៉ោង)* | ◉◉◉○○ | *ករណីខ្លះ ពេទ្យសត្វខាងក្រុមហ៊ុនមក២ថ្ងៃក្រោយពីអ្នកផលិតទូរស័ព្ទប្រាប់ទៅក្រុមហ៊ុន ។* | |
| មាត្រា ៥. ការរៀបចំបែបបទសម្រាប់ប្រមូលផល | *ថ្ងៃនៃការប្រមូលផលបានព្រមព្រៀងគ្នាមួយសប្តាហ៍មុន ។* | ◉◉◉◉◉ | | |
| | *ពេលមកកាន់ទីតាំងរបស់អ្នកផលិត អ្នកទិញត្រូវមានឡានដឹក ។* | ◉◉◉◉◉ | | |
| | *អ្នកទិញត្រូវផ្តល់កេះ* | ◉◉◉◉◉ | | |
| មាត្រា ៦. គុណភាព | *ត្រូវប្រគល់មាន់ឱ្យនៅពេលវាមានអាយុចន្លោះពី ២ខែ ទៅ ២ខែកន្លះ* | ◉◉◉◉◉ | | |
| | *ទម្ងន់អប្បបរមា១,៣គក* | ◉◉◉◉○ | *មាន់មួយចំនួនតូចទម្ងន់តិចជាង ១,៣គកបន្តិច តែទទួលយកដោយអ្នកទិញ ។* | |
| | *ទម្ងន់មធ្យម មិនតិចជាង ១,៤៥ គក* | ◉◉○○○ | *ទម្ងន់មធ្យមត្រឹមតែ១,៣៥គក* | |
| មាត្រា ៧. តម្លៃ | *តម្លៃថេរ ៥.០០០រ/គក សម្រាប់មាន់រស់* | ◉◉◉◉◉ | | |
| មាត្រា ៨. ការទូទាត់ | *ការទូទាត់ជាសាច់ប្រាក់* | ◉◉◉◉◉ | | |
| | *ទូទាត់នៅថ្ងៃប្រមូលទិញ* | ◉◉◉○○ | *លុយតែងតែមិនមានគ្រប់គ្រាន់ទាន់ពេល ហើយការទូទាត់យឺតយ៉ាវ ។* | |

(សំណេរ *ពណ៌ទឹកក្រូច* គ្រាន់តែជាឧទាហរណ៍ប្រឌិតឡើងសម្រាប់កិច្ចសន្យាចិញ្ចឹមមាន់ប៉ុណ្ណោះ) ។

[១] បន្ថែមមួយបន្ទាត់សម្រាប់ចំណុចនីមួយៗនៅខាងក្រោមម្រាត្រាឬផ្នែកដែលផ្តល់ឱ្យ ដើម្បីឱ្យអាចមានការវាយតម្លៃពិស្តារ ។

[២] ការរៀបចំទម្រង់បំពេញអាចធ្វើជាការពន្យល់បន្ថែម មែន/មិនមែន ដើម្បីគូសធីក ឬអាចធ្វើឱ្យមានគុណភាពជាងនេះបន្តិច (គឺ មិនគោរពតាម / គោរពតាមខ្លះៗ / គោរពតាមភាគច្រើន / គោរពតាមទាំងស្រុង) ឬក៏ឱ្យជាពិន្ទុ ឧទាហរណ៍ពី ០-៥ (០ = មិនអនុវត្ត ៥ = អនុវត្តទាំងស្រុង) ។

## ៥.៣.២. កំណត់រកចំណុចដែលមិនបានដាក់បញ្ចូលក្នុងកិច្ចសន្យាចាស់ ដែលត្រូវដាក់បញ្ចូលថ្មី

ជាញឹកញាប់ណាស់ (ជាពិសេសប្រសិនបើកិច្ចសន្យានោះត្រូវគេអនុវត្តជាលើកដំបូង) ការសម្រេចមួយចំនួនលើការខ្វែងគំនិតគ្នាអាចកើតមានឡើងអំឡុងពេលអនុវត្ត មិនមែនព្រោះតែមិនគោរពលក្ខខណ្ឌក្នុងកិច្ចសន្យាទេ ប៉ុន្តែព្រោះមានសំណួរសំខាន់ៗមួយចំនួនមិនបានលើកឡើងនៅក្នុងកិច្ចសន្យា ។ ខណៈដែលភាគីទាំងពីរជួបគ្នាដើម្បីធ្វើការវាយតម្លៃរួមគ្នាលើការអនុវត្តកិច្ចសន្យានោះ គេអាចរំលឹកឡើងវិញពី "សាវតា" នៃការអនុវត្ត និងបញ្ហាដែលគេបានជួបប្រទះ (ជួនកាលជម្លោះដែលគេមាន) ដែលអាចស្តែងចេញកង្វះខាតបែបៗនោះក្នុងការសរសេរកិច្ចសន្យា។ ជួនកាល ភាពមិនច្បាស់លាស់នៃកិច្ចសន្យា ត្រូវបានបង្ហាញដោយការពិភាក្សា និងការព្រមព្រៀងគ្នា (ជាទូទៅដោយផ្ទាល់មាត់) ដែលធ្វើឡើងក្នុងដំណាក់កាលអនុវត្ត ។ ប្រសិនបើកិច្ចសន្យាត្រូវធ្វើជាថ្មីសម្រាប់វដ្តផលិតកម្មថ្មី ចំណុចដែលគេបានបញ្ជាក់ឱ្យច្បាស់លាស់អំឡុងពេលអនុវត្តនៃវដ្តផលិតកម្មចាស់ទាំងនេះ អាចដាក់បញ្ចូលទៅក្នុងកិច្ចសន្យាដែលកែប្រែថ្មីដើម្បីធ្វើឱ្យវាច្បាស់លាស់ជាងមុន។ វាក៏អាចធ្វើឱ្យគ្រោងការណ៍នៃផលិតកម្មកសិកម្មតាមកិច្ចសន្យាប្រសើរឡើងដែរ គឺកសិករដែលចុះកិច្ចសន្យាថ្មីនឹងបានទទួលផលប្រយោជន៍ពីបទពិសោធន៍នៃអ្នកត្រួសត្រាយផ្លូវមុន!

## ៥.៣.៣. ប៉ាន់ប្រមាណកម្រិតនៃការពេញចិត្ត

ផលិតកម្មកសិកម្មតាមកិច្ចសន្យាមួយដែលអាចចាត់ទុកជាជោគជ័យបានមិនមែនគិតត្រឹមតែលក្ខខណ្ឌដែលចែងក្នុងកិច្ចសន្យាត្រូវបានគោរពតាមនោះទេ តែភាគីទាំងពីពេញចិត្តនឹងលទ្ធផល និងការប៉ាន់ស្មានដែលគេបានទទួលផលប្រយោជន៍ពីការចងសម្ព័ន្ធភាពនោះ។ ដូចមានបង្ហាញនៅខាងលើ វាក៏អាចទៅរួចដែរដែលលក្ខខណ្ឌនៃកិច្ចសន្យាមិនត្រូវបានគេគោរពទាំងស្រុង តែភាគីទាំងពីរបែរជាសប្បាយចិត្តចំពោះភាពជាដៃគូជាង។ ផ្ទុយមកវិញ វាអាចដែរដែលគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាទាំងអស់ត្រូវបានគេគោរពតាម ប៉ុន្តែមិនអាចនាំមកនូវការពេញចិត្តដល់ភាគីម្ខាងឬទាំងសងខាងឡើយ។ ជាជាងការគោរពពេញលេញទៅលើលក្ខខណ្ឌនៃកិច្ចសន្យា ការពេញចិត្ត (ចំណាប់អារម្មណ៍ដែលបានបង្ហាញ) គឺជាធាតុយ៉ាងសំខាន់ដែលអាចនាំឱ្យការចុះកិច្ចសន្យាលើភាពជាដៃគូជាថ្មីទៅរួចបាន ។

ដូចដែលបានបញ្ជាក់មកនេះ ភាគីនីមួយៗគួរតែពិនិត្យឡើងវិញនូវវត្ថុបំណងខាងដើមរបស់ខ្លួនខណៈដែលចូលទៅធ្វើការព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា ហើយវាយតម្លៃមើលថាតើវត្ថុបំណងទាំងនោះបានជោគជ័យដែរ ឬ ទេ (ហើយប្រសិនបើមិនបានទេ តើមានចន្លោះប្រហោងសម្រាប់កែលម្អដើម្បីធ្វើឱ្យវាសម្រេចបានក្នុងដំណាក់កាលនៃការចាប់ដៃគូបន្ទាប់ ឬ ទេ) ។

វត្ថុបំណងខាងដើមអាចមានចម្រុះគ្នាបន្តិច (ដូចមានបង្ហាញនៅក្នុង ផ្នែកទី ១.២ និង ១.៣. នៅក្នុងសៀវភៅនេះ ទំព័រ ១២-១៤) ហើយដូចរៀបរាប់មកហើយ គឺគ្មានទម្រង់ជាស្តង់ដារមួយដើម្បីវាយតម្លៃវានោះទេ ។ ជាការពិតណាស់ ការទាញផលប្រយោជន៍បានពីគ្រោងការណ៍នៃផលិតកម្មកសិកម្មតាមកិច្ចសន្យា គួរតែជាផ្នែកមួយដែលត្រូវរៀបចំជាប្រព័ន្ធវាយតម្លៃការពេញចិត្តមួយ (សម្រាប់ទាំងភាគីអ្នកទិញ និងភាគីអ្នកផលិត) ។ ប៉ុន្តែទិដ្ឋភាពផ្សេងទៀត ក៏គួរតែពិចារណាផងដែរ ដូចជាសុវត្ថិភាព ឬ ផលប្រយោជន៍ផ្សេងៗទៀតដែលបានអនុញ្ញាតដោយកិច្ចសន្យា ។

## ការវាយតម្លៃផលចំណេញ

គេគួរតែធ្វើការវិភាគសេដ្ឋកិច្ចនៃផលិតកម្មមួយស្ថិតក្រោមផលិតកម្មកសិកម្មតាមកិច្ចសន្យា សម្រាប់អ្នកផលិតដោយគិតគូរពីថ្លៃចំណាយនិងចំណូល ដែលអាចយកទៅគណនាជាប្រាក់ចំណេញសុទ្ធសម្រាប់កសិករ។ បន្ទាប់មកប្រាក់ចំណេញសុទ្ធនេះ គេអាចយកទៅប្រៀបធៀបគ្នាជាមួយនឹងសេណារីយ៉ូដែលគ្មានផលិតកម្មកសិកម្មតាមកិច្ចសន្យា ប្រសិនបើមានការប្រើប្រាស់ធនធាន ( ដី មូលធន កម្លាំងពលកម្ម ) សម្រាប់ការផលិតដែលជាប់កិច្ចសន្យាត្រូវបានយកទៅប្រើប្រាស់តាមរបៀបផ្សេងទៀត ទោះបីប្រើប្រាស់សម្រាប់ការផលិតដូចគ្នា (តែជាមួយនឹងទីផ្សារខុសគ្នា ហើយអាចប្រើទិចនិកខុសគ្នាផងដែរ) ឬ ម្យ៉ាងទៀត ប្រើសម្រាប់ការផលិត ឬ សកម្មភាពមួយផ្សេងទៀត (បន្តកសិដ្ឋានឬបិទកសិដ្ឋាន) ។

ប្រសិនបើអ្នកផលិត បានចុះកិច្ចសន្យាតាមរយៈអង្គការកសិករ លទ្ធផលសេដ្ឋកិច្ចសម្រាប់អង្គការកសិករនោះត្រូវតែធ្វើការវាយតម្លៃ (ការប្រៀបធៀបនៅ ផ្នែកទី ៧.៥. ទំព័រទី ១៥៧-១៦៤) ។

## ការវាយតម្លៃសុវត្ថិភាព

ការគណនាផលចំណេញខាងលើអាចត្រូវធ្វើឱ្យមានគុណភាពផងដែរ ។ ប្រសិនបើលទ្ធផលសេដ្ឋកិច្ចនៃកិច្ចសន្យាត្រូវយកទៅប្រៀបធៀបគ្នានឹងអ្វីដែលអ្នកផលិតអាចមានដោយមិនចាំបាច់ចុះកិច្ចសន្យា ធាតុដែលយកទៅប្រៀបធៀបអាស្រ័យលើកត្តាបរិបទជុំវិញ (គួរកត់សម្គាល់គឺកត្តាទីផ្សារ) ។ ឧទាហរណ៍ ៖ ប្រសិនបើកិច្ចសន្យានោះជាកិច្ចសន្យាដែលផ្តល់តម្លៃថេរ វាអាចកើតឡើងបានថា នៅពេលប្រមូលផល អ្នកផលិតអាចលក់បានតម្លៃខ្ពស់ជាង ប្រសិនបើលក់ទៅឱ្យអ្នកផ្សេង ក្រៅពីគម្រោងដែលផ្តល់ដោយផលិតកម្មកសិកម្មតាមកិច្ចសន្យា ប៉ុន្តែវាមានហានិភ័យដែលត្រូវប្រឈមបើជួបស្ថានភាពផ្ទុយពីនេះវិញ គឺតម្លៃទីផ្សារទាបជាង (សូមមើលតារាង ៤.៧.ក ទំព័រទី ៧០) ។ ដូច្នេះកិច្ចសន្យានេះអាចនឹងមិនផ្តល់ប្រាក់បំណាច់ខ្ពស់ជាងជាប្រព័ន្ធបានទេ ប៉ុន្តែជូនកាលវាផ្តល់សុវត្ថិភាពខ្ពស់ជាង ។

**ផលប៉ះពាល់ដែលអាចកើតមានលើការទប់ស្កាត់ហានិភ័យ អាចវាស់វែងបានមិនត្រឹមតែលើតម្លៃនៃទំនិញដែលបានលក់ចេញទេ ប៉ុន្តែក៏អាចវាស់វែងលើប្រាក់ចំណូលសរុបសម្រាប់កសិដ្ឋានទាំងមូលផងដែរ ។ ការព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលបានធ្វើឡើងលើផលិកម្មថ្មីមួយសម្រាប់កសិករ ដែលអាចឱ្យគាត់ធ្វើពិពិធកម្មលើសកម្មភាពនៃការផលិតនោះ ហើយឱ្យក្លាយជាធន់ជាងមុន ។**

### ការវាយតម្លៃផលប្រយោជន៍ផ្សេង ៗទៀត

កិច្ចសិន្យានេះ អាចផ្តល់ផលប្រយោជន៍ដទៃផ្សេងទៀតដែលមិនបានសម្គាល់ដោយផ្ទាល់ក្នុងការវិភាគងាយៗពីថ្លៃចំណាយនិងចំណូល ។ ឧទាហរណ៍ ខាងភាគីអ្នកផលិត អ្នកផលិតអាចទទួលបានចំណេះដឹងផ្នែកបច្ចេកទេសពីវគ្គបណ្តុះបណ្តាលដែលទទួលបានពីដៃគូរបស់ខ្លួន ឬក៏អាចប្រើប្រាស់វត្ថុធាតុដើមជាក់លាក់ណាមួយដែលគាត់អាចរកបានដោយខ្លួនឯង ឬ អាចប្រើឧបករណ៍ដែលអាចយកទៅប្រើសម្រាប់ដំណាំឬការផលិតដទៃទៀត ឬម្យ៉ាងទៀតបានប្រើប្រាស់វត្ថុធាតុដើមដោយបណ្តាក់គេ ខណៈដែលធនធានហិរញ្ញវត្ថុអាចជាកត្តាមានកម្រិតដើម្បីធ្វើសកម្មភាពរបស់គាត់ ជាដើម ។ល។ ករណីខ្លះ ការផលិតនៅក្រោមកិច្ចសន្យា ក៏អាចបង្កើតផលប្រយោជន៍តាមផលិតផល ឬផលប្រយោជន៍បន្ថែមដែលអាចមានតម្លៃដល់ការផលិតផ្សេងទៀតនៅលើកសិដ្ឋានរបស់គាត់ ហើយគេអាចនឹងមិនបានគិតគូរដល់ក្នុងការវាយតម្លៃសេដ្ឋកិច្ច ឧទាហរណ៍ លាមកសត្វប្រើធ្វើជាជី បង្កើនជីជាតិដីដោយសំបកនៃដំណាំ ឬក្រោយពេលប្រមូលផល កាលសំណល់អាចយកធ្វើជាចំណីសត្វ ជាដើម ។ ល ។

## ៥.៣.៤. ការដកពិសោធន៍ដើម្បីកែលម្អដំណាក់កាលក្រោយ (ឬបញ្ចប់ភាពជាដៃគូ!)

បន្ទាប់ពីគេបានធ្វើការពិនិត្យឡើងវិញចប់សព្វគ្រប់ដូចដែលបានបញ្ជាក់ខាងលើនេះហើយ ភាគីទាំងពីរគួរតែច្របាច់បញ្ចូលគ្នានូវការអង្កេតរបស់ពួកគេ សន្និដ្ឋានគោលបំណងដើម្បីបន្តឬបញ្ចប់ភាពជាដៃគូជាមួយគ្នា និងសំយោគធាតុផ្សេងៗទាំងអស់ដែលគេបានកត់សម្គាល់ឃើញ ដើម្បីធ្វើឱ្យកិច្ចសន្យាប្រសើរឡើងប្រសិនបើគេសម្រេចថានឹងធ្វើវាជាថ្មី ។

# ផ្នែកទី ៦៖ ការដោះស្រាយជម្លោះក្នុងពេលអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

នៅពេលចុះកិច្ចសន្យាផលិតកម្មកសិកម្ម គូភាគីគួរគិតដល់ការខ្វែងគំនិតគ្នា ដែលអាចកើតឡើង ហើយមិនអាចដោះស្រាយបានដោយខ្លួនឯងផ្ទាល់។ ដូច្នេះ នៅពេលចរចា និងព្រាងកិច្ចសន្យា គូភាគីគួរគិតអំពីវិធីដោះស្រាយវិវាទដែលមិនអាចដោះស្រាយបានដោយខ្លួនឯង និងដែលត្រូវការអន្តរាគមន៍ពីភាគីទីបី។ មានជម្រើសជាច្រើនដែលអាចប្រើបានសម្រាប់ដោះស្រាយវិវាទ៖ តាមរយៈនីតិវិធីតុលាការដែលគូភាគីត្រូវចូលខ្លួនទៅដោះស្រាយនៅផ្លូវតុលាការ (សូមមើលផ្នែក ៦.១) ឬ ដោះស្រាយក្រៅប្រព័ន្ធតុលាការ សូមមើលផ្នែក ៦.១ ខាងក្រោម)។

## ៦.១. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖

### ជម្រើសផ្សេងៗសម្រាប់ការដោះ-ស្រាយវិវាទ

ការជ្រើសរើសយកការដោះស្រាយវិវាទតាមយន្តការក្រៅប្រព័ន្ធតុលាការ គឺអាស្រ័យលើការព្រមព្រៀងរបស់គូភាគី ហើយការជ្រើសរើសយន្តការដោះស្រាយវិវាទប្រភេទណាមួយគឺអាស្រ័យលើលក្ខណៈនៃវិវាទ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានច្រើនប្រភេទ (សូមមើលផ្នែក ៦.១.១. ខាងក្រោម)។ នៅក្នុងប្រទេសកម្ពុជា ក៏មានអង្គភាពក្រៅប្រព័ន្ធតុលាការផ្សេងៗជាច្រើន ដើម្បីគ្រប់គ្រងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះផងដែរ (ដូចមាន នៅក្រោមផ្នែក ៦.១.២. ពីទំព័រ ១៣៨)។

### ៦.១.១.ការដោះស្រាយវិវាទអនុលោមតាមអនុក្រឹត្យលេខ ៣៦ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

អនុក្រឹត្យលេខ ៣៦ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលបានអនុម័តកាលពីខែកុម្ភៈ ឆ្នាំ ២០១១ បានបង្កើតនូវគណៈកម្មការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ហៅកាត់ថា CFCC សម្រាប់ដោះស្រាយវិវាទដែលកើតចេញពីការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម[33]។

គណៈកម្មការនេះ មានសមាជិកមកពីក្រសួងនានា និងដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបង្កើតឡើង។ គណៈកម្មការសម្របសម្រួលនេះ ទទួលខុសត្រូវលើការ *"រៀបចំ និងសម្របសម្រួលជម្លោះ ឬទំនាស់កើតចេញពីកិច្ចសន្យាផលិតកម្មកសិកម្មដែលមិនអាចដោះស្រាយបាននៅស្ថាប័នជំនាញ និងដែលត្រូវការដោះស្រាយកម្រិតអន្តរស្ថាប័ន*[34]។

តួនាទីរបស់គណៈកម្មការមិនមែនផ្តល់ដំណោះស្រាយទេ វាគ្រាន់តែសម្របសម្រួល និងផ្សះផ្សាដល់គូភាគី ពោលគឺជាការសម្រុះសម្រួលលើបែបបទ និងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម។ បន្ទាប់មក ប្រសិនបើគូភាគីមិនយល់ព្រមលើការសម្រុះសម្រួល ឬដំណោះស្រាយជម្លោះដោយមានការជំនួយពីគណៈកម្មការសម្របសម្រួលទេនោះ គណៈកម្មការសម្របសម្រួល មិនមានអំណាចចេញមជ្ឈត្តវិនិច្ឆ័យទេ និងមិនអាចផ្តល់ដំណោះស្រាយដោយចិត្តឯងបានទេ។ គូភាគីអាចបន្តការដោះស្រាយវិវាទតាមរយៈមជ្ឈត្តករ ឬតុលាការបាន។

អនុក្រឹត្យក៏បានបញ្ជាក់ផងដែរថា គូភាគីត្រូវឯកភាពគ្នាជាមុនអំពីវិធីដើម្បីដោះស្រាយជម្លោះក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម ។ ប្រសិនបើមិនឯកភាពគ្នា ភាគីជម្លោះគួរអនុវត្តតាមវិធានរបស់ណៈកម្មការសម្របសម្រួល [35]។

យន្តការដោះស្រាយវិវាទផ្អែកតាមអនុក្រឹត្យលេខ៣៦ស្តីពីផលិតកម្មតាមកិច្ចសន្យាត្រង់មាត្រា៧ និងមាត្រា ១១ បានបង្ហាញពីយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយមានយន្តការ៣ដំណាក់កាលគឺ៖

ទី១៖ តាមរយៈការចរចាររវាងគូភាគីជាមុនសិន ដោយផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

ទី២៖ ក្នុងករណីមិនអាចដោះស្រាយបាន ភាគីវិវាទអាចស្នើសុំទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសាមុី ដើម្បីធ្វើជាភាគីទី៣ ដឹកនាំអន្តរាគមន៍សម្របសម្រួលផ្សះផ្សាដោះស្រាយវិវាទនោះ។

ទី៣៖ ប៉ុន្តែប្រសិនបើករណីវិវាទនេះនៅតែមិនអាចដោះស្រាយបាន នោះភាគីវិវាទនឹងអនុវត្តតាមរយៈគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម។ សូមបញ្ជាក់ថា គូភាគីចុះកិច្ចសន្យាអាចទទួលបានយន្តការដោះស្រាយវិវាទដូចបានជម្រាបជូនខាងលើនេះ ក្នុងករណីគូភាគីចុះកិច្ចសន្យានោះ បានចុះបញ្ជីការនៅនាយកដ្ឋានកសិ-ឧស្សាហកម្ម ឬ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសាមុី។ គោលបំណងរបស់យន្តការនេះ គឺ ដើម្បីជួយភាគីអ្នកផលិត(កសិករ)និងភាគីអ្នកទិញផលិតផលកសិកម្ម ទទួលបានសេវាដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការតាម រយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៦.១.២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការតាមជម្រើសផ្សេងទៀត

មជ្ឈត្តកម្ម ការចរចា និងការសម្រុះសម្រួល គឺជាទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលឃើញញឹកញាប់ជាងគេ។ នៅក្នុងប្រទេសកម្ពុជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្រៅផ្លូវការ ធ្លាប់បានអនុវត្តជាច្រើនសតវត្សមកហើយ។ ទោះយ៉ាងណា រហូតមកដល់ពេលថ្មីៗនេះ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនត្រូវ បានបញ្ចូលជាផ្នែកមួយនៃរបបនៃដោះស្រាយវិវាទជាផ្លូវការឡើយ។ បច្ចុប្បន្នប្រទេសកម្ពុជាបានចាប់ផ្តើមបញ្ចូលបច្ចេកទេសដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទៅក្នុងប្រព័ន្ធតុលាការរបស់ខ្លួន[36]។

ជម្រើសប្រើប្រាស់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺអាស្រ័យទៅតាមលក្ខណៈនៃវិវាទ និងដើម្បីស្តារទំនាក់ទំនងល្អឡើងវិញរវាងភាគីទាំងពីរ។ នោះគឺព្រោះថាដំណើរការដោះស្រាយវិវាទនេះអាចរក្សាការសម្ងាត់ផ្ទុយពីការដោះស្រាយតាមប្រព័ន្ធតុលាការដែលត្រូវធ្វើឡើងជាសាធារណៈ[37]។ ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាទីកន្លែងសមរម្យសម្រាប់គូភាគីក្នុងការពិភាក្សា លើបញ្ហាដែលមិនទាន់បានដោះស្រាយ និងបញ្ហាយល់ច្រឡំផ្សេងៗ ក្នុងបរិយាកាសធូរស្រាល គ្មានការបំភិតបំភ័យ[38] ។ វិធីនេះអាចជាដំណោះស្រាយឈ្នះៗដែលអនុញ្ញាតឲ្យភាគីទាំងពីរ ឆ្ពោះទៅមុខដោយមានការយោគយល់គ្នា[39]។ កត្តាលើកទឹកចិត្តដែលជំរុញឲ្យមានការកើនឡើងនូវការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរនោះគឺរយៈពេលវែងនៃប្រព័ន្ធតុលាការ និងការចំណាយច្រើន ដែលខុសពីការដោះស្រាយក្រៅតុលាការដែលមានចំណាយទាប និងរយៈពេលខ្លី។

[36] សេចក្តីផ្តើមនៃច្បាប់កម្ពុជា, ហោ ប៉េង , គង់ ផល្លះ, Jorg Menzel, Konrad Adenauer Stiftung, ២០១២។

[37] National Arbitration Forum, "Business-to-Business: Mediation/Arbitration vs. Litigation" accessed from http://www.adrforum.com/users/naf/resources/GeneralCommercialWP.pdf.

[38] Goldberg ,"Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum", p.១៤.

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានច្រើនវិធី។ ដើម្បីជ្រើសរើសយកវិធីណាមួយ គូភាគីត្រូវដាក់បញ្ចូលលក្ខខណ្ឌនៅក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម ឬធ្វើកិច្ចសន្យាដាច់ដោយឡែកមួយទៀត ហើយជាទូទៅគឺនៅក្រោយពេលវិវាទកើតឡើង។ ពេលបញ្ហាកើតឡើង គូភាគីគួរព្យាយាមដោះស្រាយតាមការចរចាគ្នា (ក) បន្ទាប់មកការសម្រុះសម្រួល ឬការផ្សះផ្សា (ខ) ហើយចុងក្រោយ បើនៅតែមិនឯកភាពគ្នា គេអាចប្រើមជ្ឈត្តកម្ម (គ)។

## ក) ការចរចា

ការចរចាគឺជាទម្រង់មួយនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេនៅកម្ពុជា ដែលក្នុងនោះភាគីទាំងពីរប្រើប្រាស់សម្រាប់ដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលគ្នា ដោយមិនចាំបាច់មានជំនួយពីភាគីទីបី។ នៅក្នុងប្រទេសកម្ពុជា ការស្ទង់មតិលើក្រុមហ៊ុនតូចៗបានរកឃើញថា ការចរចាគឺជាវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេក្នុងការដោះស្រាយវិវាទ[41] ។

ជាទូទៅ ការចរចាគឺជាជំហានដំបូងនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហើយតាមរយៈនោះគូភាគីចូលរួមដោះស្រាយវិវាទដោយខ្លួនឯង និងមិនចាំបាច់មានអន្តរាគមន៍ពីភាគីទីបី ដែលផ្ទុយពីទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃផ្សេងទៀត (ការសម្រុះសម្រួល ការផ្សះផ្សា និងមជ្ឈត្តកម្ម)។ គូភាគីជាការពិតណាស់ ការចរចាគឺធ្វើឡើងដោយមានមូលដ្ឋានលើគោលការណ៍ទូទៅ កាតព្វកិច្ចច្បាប់ និងខ្លឹមសារនៃកិច្ចសន្យាផ្ទាល់ខ្លួនឯង។

ការចរចាអាចជាធ្វើឡើងជាទម្រង់ផ្លូវការ (ការប្រជុំ ការព្រមព្រៀងជាលាយលក្ខណ៍អក្សរ) ឬ ធម្មតា (តាមទូរស័ព្ទ អ៊ីមែល ឬ សំបុត្រ) ។ នៅក្នុងប្រទេសកម្ពុជា ការចរចាភាគច្រើនជួបគ្នាផ្ទាល់ ប៉ុន្តែក៏អាចចរចាតាមទូរស័ព្ទដែរ[42]។

គុណសម្បត្តិទីមួយនៃការចរចាគឺការសន្សំសំចៃប្រាក់៖ ថ្លៃចំណាយនៃការចរចាគឺទាបជាងវិធីសាស្ត្រផ្សេងទៀតនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការរក្សាភាពឯកជន៖ ការចរចាអាចជាដំណើរការជាលក្ខណៈឯកជន។ ការដោះស្រាយបានលឿន៖ គូភាគីមិនចាំបាច់រង់ចាំចៅក្រម មជ្ឈត្តករ អ្នកសម្រុះសម្រួល មកស្តាប់ ឬធ្វើការជំនុំជម្រះឡើយ។

ជាធម្មតា ការចរចាគឺជាជម្រើសល្អបំផុត មុនដាក់ពាក្យបណ្តឹង ឬ ប្រើមជ្ឈត្តករ។

---

[39] Ibid.

[40] សេចក្តីផ្តើមនៃច្បាប់កម្ពុជា, ហោ ប៉េង , គង់ ផល្លាក់, Jorg Menzel, Konrad Adenauer Stiftung, ២០១២។

[41] បណ្តុំពិនិត្យបរិយាកាសអាជីវកម្មតាមខេត្ត នៅក្នុងប្រទេសកម្ពុជា ៖ វិធានការអភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិ, World Bank/IFC-MPDF និង AusAid/The Asia Foundation, ៤០ (២០០៧) [ហៅកាត់ថា បណ្តុំពិនិត្យបរិយាកាសអាជីវកម្ម ]។ ការស្ទង់មតិបានរកឃើញថា ៩២% នៃក្រុមហ៊ុនកម្ពុជា ជ្រើសរើសយកការចរចា ជាជម្រើសទីមួយ។ មានតែ ១% នៃក្រុមហ៊ុន ជ្រើសរើសតុលាការដើម្បីដោះស្រាយ។

[42] Steven M. Auster millerAlternative Dispute Resolution: Cambodia A Textbook of Essential Concept( USAID, ២០១០).

### ខ) ការសម្រុះសម្រួល និងការផ្សះផ្សា

ជារឿយៗ ការផ្សះផ្សា និងការសម្រុះសម្រួលគឺជាជំហានបន្ទាប់ ក្រោយគូភាគីចរចាគ្នាមិនបានសម្រេច។ ការផ្សះផ្សា និងការសម្រុះសម្រួល អាចត្រូវបានឱ្យនិយមន័យជាលក្ខណៈទូលាយថាជាការចរចាដែលមានការសម្រួល ឬ ការជួយជ្រោមជ្រែង[43]។ វិធីសាស្ត្រនៃការកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងនេះ គឺជាផ្នែកមួយនៃវប្បធម៌កម្ពុជា និងជាប្រពៃណីនៃប្រព័ន្ធច្បាប់ហើយរហូតដល់សព្វថ្ងៃ វានៅតែដើរតួសំខាន់ក្នុងការដោះស្រាយវិវាទ។ ការស្ទង់មតិមួយរបស់ធនាគារពិភពលោក លើក្រុមហ៊ុនតូចៗនៅក្នុងប្រទេសកម្ពុជា បានរកឃើញថា ការសម្រុះសម្រួលជាជម្រើសនិយមប្រើបំផុត ក្រោយពីការចរចាគ្នា[44] ។

ពាក្យថា សម្រុះសម្រួល និងការផ្សះផ្សា ត្រូវបានគេយល់ច្រឡំអស់រយៈពេលជាច្រើនឆ្នាំហើយពាក្យទាំងពីរនេះត្រូវបានគេប្រើសំដៅដល់ការចរចាដែលមានភាគីទីបីអព្យាក្រឹត ជាជំនួយនៅក្នុងដំណើរការ។ បច្ចុប្បន្ន ការផ្សះផ្សានិងការសម្រុះសម្រួល ត្រូវបានគេប្រើជំនួសឱ្យគ្នាទៅវិញទៅមកដើម្បីសំដៅទៅលើដំណើរការដូចគ្នា។ ទោះអ្នកខ្លះបានព្យាយាមស្វែងរកភាពខុសគ្នា ប៉ុន្តែមិនមានការបញ្ជាក់ជាអន្តរជាតិថាពាក្យទាំងពីរខុសគ្នាយ៉ាងណានោះទេ [45]។ ទោះបីជាការសម្រុះសម្រួល និងការផ្សះផ្សា ពាក់ព័ន្ធនឹងភាគីជម្លោះពីរ ឬ ច្រើន ដែលព្យាយាមចរចាដោយមានជំនួយពីភាគីទីបីក៏ដោយ ក៏យន្តការទាំងពីរនេះអាចមានលក្ខណៈខុសគ្នាដូចខាងក្រោម ៖

- **ការសម្រុះសម្រួល** ជាដំណើរការដែលមានការចូលរួមរបស់ភាគីទីបី ហៅថា "អ្នកសម្រុះសម្រួល" ដើម្បីជួយសម្របសម្រួលដល់ការសន្ទនារវាងគូភាគី និងជួយជ្រោមជ្រែងគូភាគីទាំងពីរដោះស្រាយវិវាទដោយមានការយោគយល់គ្នា។

- **ការផ្សះផ្សា** ជាដំណើរការដែលភាគីទីបី ហៅថា "អ្នកផ្សះផ្សា" ត្រូវជួបជាមួយភាគីជម្លោះដាច់ដោយឡែកពីគ្នា។ វាខុសពីការសម្រុះសម្រួល ដែលអ្នកសម្រុះសម្រួលត្រូវជួបភាគីជម្លោះទាំងអស់គ្នាដើម្បីស្វែងរកកិច្ចខិតខំប្រឹងប្រែងរបស់គូភាគីក្នុងការដោះស្រាយវិវាទ[46]។

នៅក្នុងប្រពៃណីខ្មែរ ការផ្សះផ្សា និងការសម្រុះសម្រួល ត្រូវបានធ្វើឡើងដោយភាគីទីបី ដូចជា ព្រះសង្ឃ អាចារ្យ (អ្នកដែលមានចំណេះដឹង) បុគ្គលណាមួយដែលភាគីទុកចិត្ត ប្រធានភូមិ ឬព្រះមហាក្សត្រ និងជាផ្លូវការដែលគេធ្វើឡើងដោយការតែងតាំងមន្ត្រីរដ្ឋ និងចៅក្រម។ ក្នុងការអនុវត្តជាក់ស្តែង ការដោះស្រាយវិវាទតាមរយៈការ ផ្សះផ្សា តែងធ្វើឡើងក្នុងជីវភាពប្រចាំថ្ងៃដែរ[47]។

---

[43] Patterson et al., supra note ៩, at ៥៣.

[44] បណ្ណពិន្ទុបរិយាកាសអាជីវកម្ម, កំណត់សម្គាល់ ៣, ទំព័រ ៤០។ ការស្ទង់មតិបានរកឃើញថា ក្រុមហ៊ុនក្នុងស្រុក ជ្រើសរើសយកការសម្រុះសម្រួលជាជម្រើសទីពីរល្អបំផុត មុនទៅតុលាការ។

[45] Steven M. Auster millerAlternative Dispute Resolution: Cambodia A Textbook of Essential Concept( USAID, ២០១០).

[46] Raquel Z. YRIGOYEN FAJARDO, គង់ រាឌី និងផាន់ ស៊ិន ស្តីពីច្រកផ្លូវទៅយុត្តិធម៌ ៖ លទ្ធភាពទទួលយុត្តិធម៌ ជាមួយនឹងការផ្តោតលើអ្នកក្រ ស្ត្រី និងជនជាតិភាគតិច ( UNDP-ក្រសួងយុត្តិធម៌,២០០៥) ទំព័រ.៣៣.

[47] សេចក្តីផ្តើមនៃច្បាប់កម្ពុជា, ហោ ប៉េង , គង់ ផល្លះ, Jorg Menzel, Konrad Adenauer Stiftung, ២០១២

អ្នកសម្រុះសម្រួល ឬអ្នកផ្សះផ្សា ដឹកនាំភាគីវិវាទទាំងពីរមកជួបគ្នា និងព្យាយាមស្វែងរកដំណោះស្រាយ ឬការព្រមព្រៀងគ្នា ដែលភាគីទាំងពីរអាចទទួលយក ឬ បដិសេធ។ បន្ទាប់មក លើកទឹកចិត្តឲ្យគូភាគីវិវាទសន្ទនាគ្នា ដើម្បីឆ្ពោះទៅរកដំណោះស្រាយដែលអាចទទួលយកទាំងអស់គ្នា។ អ្នកសម្រុះសម្រួល ឬ អ្នកផ្សះផ្សា ផ្តល់ការពិចារណាជុំវិញកាលៈទេសៈ ស្ថានភាពជុំវិញវិវាទ រួមមានទិដ្ឋភាពបច្ចេកទេស សេដ្ឋកិច្ច និងសង្គម ដើម្បីជម្រុញឱ្យភាគីនីមួយៗយល់អំពីទិដ្ឋភាពរបស់ភាគីម្ខាងទៀត។ បន្ទាប់មក គូភាគីអាចជ្រើសរើសអ្នកសម្រុះសម្រួល ឬ អ្នកផ្សះផ្សាដែលមានលក្ខណសម្បត្តិទៅតាមស្ថានភាពវិវាទ និងការទុកចិត្តរបស់ភាគីទាំងពីរ។

គូភាគីអាចចែងនៅក្នុងកិច្ចសន្យាអំពីកាតព្វកិច្ចក្នុងការការផ្សះផ្សា ឬ សម្រុះសម្រួល។ កត្តាពីរដែលគួរពិចារណានៅក្នុងខសន្យានោះគឺ ៖ ទីមួយគឺ ការបង្ហាញឆន្ទៈជាក់លាក់ក្នុងការដាក់ជម្លោះទៅដោះស្រាយតាមរយៈការផ្សះផ្សា ឬ ការសម្រុះសម្រួល។ ទីពីរ ប្រសិនបើគូភាគីយល់ព្រមលើចំណុចនេះ គេត្រូវប្រាកដថា ការសម្រុះសម្រួល ឬ ការផ្សះផ្សា ត្រូវបានកំណត់ជាលក្ខខណ្ឌមុនដែលត្រូវបំពេញមុននឹងអាចឈានដល់មជ្ឈត្តកម្ម ឬដំណើរការក្តីនៅតុលាការសម្រាប់វិវាទនេះ[48]។

ប្រសិនបើគូភាគីមានបំណងប្រើការសម្រុះសម្រួល ឬការផ្សះផ្សាដើម្បីដោះស្រាយ ពួកគេគួរបញ្ជាក់នៅក្នុងកិច្ចសន្យាផលិតផលកម្មកសិកម្ម (នៅក្នុងផ្នែកស្តីពីការដោះស្រាយជម្លោះ – សូមមើល ផ្នែក ៤.១៣ ទំព័រ __ នៅក្នុងសៀវភៅនេះ)។ ប្រការនៅក្នុងកិច្ចសន្យាក៏គួរបញ្ជាក់ទីកន្លែងសម្រាប់ដោះស្រាយ ភាសាដែលត្រូវប្រើសម្រាប់ការសម្រុះសម្រួល ឬការផ្សះផ្សា នីតិវិធី និងពេលវេលា ព្រមទាំងកំណត់អ្នកសម្រុះសម្រួល ឬអ្នកផ្សះផ្សា ឬក៏បញ្ជាក់អំពីវិធីជ្រើសរើសអ្នកសម្រុះសម្រួល ឬអ្នកផ្សះផ្សា និងភាពចាំបាច់សម្រាប់ភាគីទាំងពីរឯកភាពគ្នា (ជាលាយលក្ខណ៍អក្សរ) អំពីការជ្រើសរើសយកអ្នកសម្រុះសម្រួល ឬអ្នកផ្សះផ្សា។

គេអាចប្រើប្រាស់ការសម្រុះសម្រួល ឬការផ្សះផ្សា តែក្នុងជម្លោះជាក់លាក់ណាមួយនៃកិច្ចសន្យា៖ ដូចជា ការដោះស្រាយការខ្វែងគំនិតអំពីរបៀបវាយតម្លៃគុណភាពផលិតផលដែលប្រគល់ជូន។

បន្ទាប់មក ការសម្រុះសម្រួល ឬការផ្សះផ្សារអាចពាក់ព័ន្ធនឹងកត្តាមួយចំនួន ដែលត្រូវដាក់បញ្ចូលនៅក្នុងប្រការនៃកិច្ចសន្យា ដូចជា វិសាលភាពនៃវិវាទដែលត្រូវប្រើការសម្រុះសម្រួល ឬការផ្សះផ្សា ការតែងតាំងនិងតួនាទីរបស់អ្នកសម្រុះសម្រួល ឬអ្នកផ្សះផ្សា ការអនុវត្តកិច្ចនិតិវិធី ការប្រាស្រ័យទាក់ទងគ្នារវាងគូភាគី ការដាក់ភស្តុតាង ការទម្លាយព័ត៌មានសម្ងាត់ ការតាក់តែង និងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការដោះស្រាយវិវាទ ការទទួលបន្ទុកលើចំណាយសម្រាប់ការសម្រុះសម្រួល ឬការផ្សះផ្សា និងសិទ្ធិក្នុងចាប់ផ្តើមដំណើរការ មជ្ឈត្តកម្ម ឬតុលាការ។ កាតព្វកិច្ចដើម្បីប្រើប្រាស់ការសម្រុះសម្រួល ឬការផ្សះផ្សា គឺអាស្រ័យលើកាតព្វកិច្ចក្នុងកិច្ចសន្យារបស់គូភាគី ទោះយ៉ាងណា នៅពេលប្រើប្រាស់ការសម្រុះសម្រួល ឬការផ្សះផ្សា ភាគីទាំងពីរមិនមានកាតព្វកិច្ចឈានដល់ការឯកភាពគ្នាទេ។ ដូច្នេះ គោលការណ៍ទូទៅត្រូវគ្រប់គ្រងលើទង្វើរបស់គូភាគី ជាពិសេសគឺការអនុវត្តដោយសុចរិត។ នៅពេលការសម្រុះសម្រួល ឬការផ្សះផ្សា នាំមកនូវការឯកភាពគ្នា ភាគីទាំងពីរគួរចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៃការដោះស្រាយវិវាទនោះ។ នៅក្នុងគ្រប់ករណី ការដោះស្រាយតែងតែមានកម្លាំងចាប់បង្ខំឱ្យអនុវត្ត និងគូភាគីត្រូវបានសង្ឃឹមថាយល់ព្រមអនុវត្តតាមស្ម័គ្រចិត្ត។

[48] ឧទាហរណ៍ គូភាគីអាចបង្កើតកន្លែង និងភាសាសម្រាប់ធ្វើការសម្រុះសម្រួល។

ដូច្នេះការសម្រុះសម្រួលនិងការផ្សះផ្សាមានអត្ថប្រយោជន៍មួយចំនួន៖ គូភាគីអាចរៀបចំនីតិវិធីបានដោយសេរីស្របតាមស្ថានភាពរបស់ពួកគេ ជាមួយនឹងបែបបទតិចតួច។ ម្យ៉ាងទៀត ការសម្រុះសម្រួល និងការផ្សះផ្សាត្រូវការពេលវេលាតិចតួច មិនសូវចំណាយប្រាក់ ហើយអាចដោះស្រាយបានទាំងវិវាទតូច និងធំ ដែលគូភាគីមិនចង់ដោះស្រាយតាមផ្លូវតុលាការ។

### គ) មជ្ឈត្តការ

មជ្ឈត្តការគឺជាជម្រើសទីបីនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការដែលត្រូវពិភាក្សា។ មជ្ឈត្តការ គឺជាដំណើរការដែលមានការចូលរួមពីភាគីទីបីអព្យាក្រឹត្យ ដើម្បីដោះស្រាយវិវាទ (ជាទូទៅហៅថា "មជ្ឈត្តករ" ហើយបើមានច្រើននាក់ ហៅថា "វេទិកាមជ្ឈត្តកម្ម" ឬ "តុលាការមជ្ឈត្តកម្ម")។ ភាគីទីបីដែលអព្យាក្រឹត អាចជាមជ្ឈត្តករតែម្នាក់ ឬ បើមានច្រើននាក់ ជាវេទិកាមជ្ឈត្តកម្ម[49] ។

មជ្ឈត្តការគឺខុសពីនីតិវិធីតុលាការ ត្រង់ថាមជ្ឈត្តការអាចមានលក្ខណៈចាប់បង្ខំឱ្យអនុវត្តតាម (មានជាញឹកញាប់) និងមិនមានលក្ខណៈចាប់បង្ខំឱ្យអនុវត្តតាម (មិនសូវញឹកញាប់) ពីព្រោះថាសារប្រយោជន៍របស់មជ្ឈត្តការគឺការអនុវត្តសេចក្តីសម្រេច។ គូភាគីមានភាពបត់បែនច្រើនដែលខុសពីដំណើរការតុលាការ ហើយគេអាចជ្រើសរើសទីកន្លែង និងពេលវេលាតាមតម្រូវការសម្រាប់ដំណើរការនីតិវិធី។ ម្យ៉ាងទៀត មជ្ឈត្តការក៏លឿនជាង និងចំណាយតិចជាងការឡើងតុលាការដែរ។

គូភាគីមានស្វ័យភាពធំធេងក្នុងការយល់ព្រមលើនីតិវិធីរបស់មជ្ឈត្តកម្ម និងអាចជ្រើសរើសមជ្ឈត្តករតាមរបៀបដូចគ្នានៅពេលដែលគេជ្រើសរើសអ្នកផ្សះផ្សា ឬ អ្នកសម្រុះសម្រួលដែរ។ ភាពខុសគ្នាសំខាន់រវាងមជ្ឈត្តការ និងការសម្រុះសម្រួលឬការផ្សះផ្សា គឺថាក្រោយពេលពិចារណាលើភស្តុតាងរួចមកមជ្ឈត្តករ**ធ្វើការសម្រេចចិត្ត និងមានអំណាចអនុញ្ញាតឱ្យមានសំណងការខូចខាតទៅភាគីណាមួយ** ខណៈដែលអ្នកសម្រុះសម្រួល មិនមានអំណាចដូច្នោះទេ ហើយគាត់គ្រាន់តែផ្តល់យោបល់សម្រាប់ដំណោះស្រាយប៉ុណ្ណោះ ដែលអាចធ្វើទៅបានតែប៉ុណ្ណោះ។

ដើម្បីជ្រើសរើសមជ្ឈត្តការ**គូភាគីត្រូវបង្ហាញឆន្ទៈនៅក្នុងខ្លឹមសារនៃកិច្ចសន្យាផលិតកម្មកសិកម្ម ឬ នៅក្នុងកិច្ចព្រមព្រៀង មួយទៀតដាច់ដោយឡែក ជាទូទៅក្រោយពេលជម្លោះបានកើតឡើង**។ ដើម្បីឲ្យខសន្យា មជ្ឈត្តកម្ម ឬ កិច្ចព្រម ព្រៀងមជ្ឈត្តកម្ម អាចអនុវត្តបាន វាត្រូវមានលក្ខខណ្ឌបំពេញជាមុន ដែលអាស្រ័យទៅតាមច្បាប់ជាធរមាន។ លក្ខខណ្ឌសំខាន់មួយដែលត្រូវមានក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្មគឺ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីធានាថាគូភាគីយល់ព្រមចំពោះមជ្ឈត្តការ។ ដើម្បីទទួលបានខសន្យាមជ្ឈត្តកម្មដែលអាចអនុវត្តបាន គូភាគីត្រូវយកចិត្តទុកដាក់ពិសេសលើការព្រាងខសន្យានេះ។ សន្យាមជ្ឈត្តកម្មត្រូវបញ្ជាក់ឲ្យច្បាស់អំពីឆន្ទៈក្នុងការទទួលយកមជ្ឈត្តការ និងផ្តល់ព័ត៌មានជាក់លាក់មួយចំនួន ដូចជារបៀបជ្រើសរើសមជ្ឈត្តករ។ ភាពលម្អិតនៃខសន្យានេះ គឺអាស្រ័យលើថាតើ គូភាគីចង់បានមជ្ឈត្តការចំពោះកិច្ច ឬ លក្ខណៈជាស្ថាប័ន។ មជ្ឈត្តកម្ម មានប្រភេទខុសគ្នា៖ មជ្ឈត្តការចំពោះកិច្ចដែលត្រូវរៀបចំដោយគូភាគី ឬ មជ្ឈត្តការជាស្ថាប័នដែលជាទូទៅត្រូវមានវិធានមជ្ឈត្តកម្ម គ្រប់គ្រងដំណើរការ និងផ្តល់ការធានាលើគុណភាព និងភាពដែលអាចអនុវត្តបាននៃមជ្ឈត្តវិនិច្ឆ័យបាន [50]។

[49] Steven M. Auster miller ការដោះស្រាយក្រៅប្រព័ន្ធតុលាការ៖ អត្ថបទស្តីពីគោលគំនិតសំខាន់ ( USAID, ២០១០) ទំព័រ ១៣៧ ចូលមើលតាម http://www.americanbar.org/content/dam/aba/directories/roli/cambodia/cambodia_adr_book_english_01_19_09.authcheckdam.pdf.

[50] ស្ថាប័នមជ្ឈត្តិកម្ម មានរៀបរាប់នៅក្នុងផ្នែក ៦.១.២. ការគ្រប់គ្រងដំណោះស្រាយវិវាទនៃសៀវភៅនេះ ទំព័រ__.

ម្យ៉ាងវិញទៀត នីតិវិធីមជ្ឈត្តការគឺជាការអនុវត្តយុត្តិធម៌សាធារណៈ ដែលខុសពីវិធីសាស្ត្រដោះស្រាយក្រៅប្រព័ន្ធតុលាការផ្សេងទៀត ដែលតាមរយៈនោះគូភាគីត្រូវបានរំពឹងថាគោរពតាមកិច្ចព្រមព្រៀងស្តីពីការដោះស្រាយវិវាទដោយការស្ម័គ្រចិត្ត។

សរុបមក គូភាគីនៅតែមានសិទ្ធិដាក់វិវាទទៅតុលាការ ប្រសិនបើមិនពេញចិត្តជាមួយនឹងការចរចា ការសម្រុះសម្រួល ការផ្សះផ្សា ឬ មជ្ឈត្តការ។

### ៦.១.៣.ជម្រើសផ្សេងទៀតដើម្បីគ្រប់គ្រងការដោះស្រាយវិវាទ

ការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការ ជាប្រពៃណីយូរណាស់មកហើយរបស់ប្រទេសកម្ពុជា។ ដោយយល់ឃើញសារសំខាន់នៃការដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ និងដើម្បីកែលម្អការទទួលបានយុត្តិធម៌សម្រាប់ពលរដ្ឋខ្មែរគ្រប់រូប រដ្ឋាភិបាលបានរៀបចំអង្គភាពក្រៅប្រព័ន្ធតុលាការដើម្បីគ្រប់គ្រងការដោះស្រាយនៅកម្រិតផ្សេងៗគ្នា៖ នៅថ្នាក់ឃុំ ថ្នាក់ស្រុក ៖ គណៈកម្មការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម (CCAPC) (ក) និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (NCAC)(ខ)។

#### ក) ថ្នាក់ឃុំ និងថ្នាក់ស្រុក៖« មណ្ឌលសេវាកម្មយុត្តិធម៌ »

*« មណ្ឌលសេវាកម្មយុត្តិធម៌ »* ត្រូវបានបង្កើតឡើងតាមរយៈប្រកាសអន្តរក្រសួងកាលពីឆ្នាំ ២០០៦ [52] ហើយមានភារកិច្ចផ្តល់ការបណ្តុះបណ្តាល និង/ឬផ្តល់យោបល់បច្ចេកទេស ដល់ក្រុមប្រឹក្សាឃុំស្តីពីការផ្សះផ្សា និងបញ្ហាច្បាប់ពាក់ព័ន្ធនឹងវិវាទ [53]៖

- ប៉ាន់ប្រមាណលើតម្រូវការសម្រាប់ព័ត៌មានផ្នែកច្បាប់នៅថ្នាក់ស្រុក និងថ្នាក់ឃុំ
- ផ្សព្វផ្សាយអំពីព័ត៌មានច្បាប់ចាំបាច់សម្រាប់សាធារណជននៅតាមស្រុក
- ផ្សះផ្សា និងសម្រុះសម្រួលវិវាទតាមសំណើរបស់គូរភាគី និង
- ផ្តល់សេវាបញ្ជូនបន្តទៅភាគីជម្លោះ ក្នុងករណីមិនអាចដោះស្រាយបាននៅថ្នាក់មូលដ្ឋាន

មន្ត្រី *"មណ្ឌលសេវាកម្មយុត្តិធម៌"* ត្រូវអនុវត្តតាមក្រមវិជ្ជាជីវៈ ដែលបានកំណត់ដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ដើម្បីធានាថាគេយល់នូវក្រមសីលធម៌ទាំងនោះ និងដឹងពីរបៀបអនុវត្ត។ មន្ត្រីត្រូវបំពេញភារកិច្ចដោយស្មោះត្រង់ បូរណភាព ទៀងត្រង់ គណនេយ្យភាព រក្សាការសម្ងាត់ តម្លាភាព និងមិនមានទំនាស់ផលប្រយោជន៍។ មណ្ឌលសេវាកម្មយុត្តិធម៌នៅតាមស្រុក ត្រូវដឹកនាំដោយប្រធានដែលបានការតែងតាំងពីក្រសួងយុត្តិធម៌ និងមានលេខាធិការម្នាក់ ប្រសិនបើចាំបាច់[54]។

---

[51] គង់ ផល្លាក់, "មិជ្ឈភាពទូទៅនៃប្រព័ន្ធច្បាប់និងយុត្តិធម៌នៅកម្ពុជា និងកិច្ចប្រឹងប្រែងថ្មីៗក្នុងកំណែទម្រង់ផ្នែកច្បាប់និងយុត្តិធម៌" នៅក្នុងសេចក្តីផ្តើមស្តីពីច្បាប់កម្ពុជា ( Konrad-Adenauer-Stiftung, ២០១២) ទំព័រ ១២។

[52] *ប្រកាសលេខ* ៨៥ប្រក./កសយ/មផ/២០០៦។

[53] ប្រកាសអន្តរក្រសួងលេខ ៨៥ប្រក./កសយ/មផ/២០០៦, មាត្រា ៣។

[54] ការដោះស្រាយជម្លោះនៅក្រោមប្រព័ន្ធយុត្តិធម៌ នៅថ្នាក់ជាតិ និងក្រោមជាតិ Hisham Mousar, ស្ថាប័នរដ្ឋសភានៃកម្ពុជា ខែមិថុនា ឆ្នាំ ២០១៥។

កាលពីឆ្នាំ ២០០៦ មជ្ឈមណ្ឌលយុត្តិធម៌ត្រូវបានអនុវត្តនៅក្នុងបួនស្រុក ជាគម្រោងសាកល្បង ហើយបានពង្រីកដល់ ៣១ ស្រុក កាលពីឆ្នាំ ២០១៣។ បច្ចុប្បន្ន មានតម្រូវការយ៉ាងច្រើនសម្រាប់សេវាកម្មយុត្តិធម៌ដែលផ្តល់ដោយមណ្ឌលសេវាកម្មយុត្តិធម៌នេះ និងមជ្ឈមណ្ឌលដោះស្រាយវិវាទសហគមន៍ ជាពិសេសក្នុងចំណោមក្រុមងាយរង [55] ។ ជម្លោះកើតឡើងជាញឹកញាប់ដែលបានបញ្ជូនមកមណ្ឌលសេវាកម្មយុត្តិធម៌ គឺករណីជម្លោះក្នុងកិច្ចសន្យា ឬបំណុល និងទំនាស់ដីធ្លី (សូមមើល រូបភាព ៦.១.ក. ទំព័របន្ទាប់)។ គួរកត់សម្គាល់ថាមណ្ឌលសេវាកម្មយុត្តិធម៌ មានសិទ្ធិទទួល និងផ្តល់ការផ្សះផ្សានិងការសម្រុះសម្រួល សម្រាប់ករណីកិច្ចសន្យាផលិតកម្មកសិកម្ម រួមមានបញ្ហាដី បំណុល និងបញ្ហាកិច្ចសន្យា។

រូបភាព ៦.១.ក.៖ ស្ថិតិនៃករណីដែលបានទទួលដោយ « មណ្ឌលសេវាកម្មយុត្តិធម៌ »




ប្រភព៖ ក្រសួងយុត្តិធម៌ របាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លេខ ០២ *STY*/១៤ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៤។

[55] ការប៉ាន់ប្រមាណប្រចាំប្រទេសកម្ពុជា UNDP ២០០៩។

### ខ) ថ្នាក់ជាតិ៖ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (NCAC)

បន្ទាប់ពីមានច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៦ ដែលបង្កើតក្របខ័ណ្ឌការងារសម្រាប់មជ្ឈត្តកម្មឯកជននៃជម្លោះពាណិជ្ជកម្ម ដោយអនុវត្តទៅតាមការអនុវត្តអន្តរជាតិ គេក៏មានទស្សនៈបង្កើតមជ្ឈមណ្ឌលជាតិមជ្ឈត្តការ (NAC) ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ។

បន្ទាប់មក មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (NCAC) ត្រូវបានអនុវត្តតាមរយៈអនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការនៃកម្ពុជា ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៩ ប៉ុន្តែត្រូវបានដាក់ឲ្យប្រើប្រាស់នៅខែមករា ឆ្នាំ ២០១៣។

NCAC មិនទាន់បានធ្វើមជ្ឈត្តកម្មទាក់ទងនឹងកិច្ចសន្យាផលិតកម្មកសិកម្មនៅឡើយ គិតមកត្រឹមដំណាច់ឆ្នាំ ២០១៥។ ទោះយ៉ាងណា កិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវបានចាត់ទុកជាបញ្ហាពាណិជ្ជកម្ម ហើយស្ថិតនៅក្រោមវិសាលភាពរបស់ NCAC។

លើសពីនេះទៀត ដោយមើលឃើញនូវការបង្កើនទំនុកចិត្តរបស់គូភាគីនិងសុវត្ថិភាពរបស់កិច្ចសន្យាផលិតកម្មកសិកម្ម គេបានផ្តល់ជាអនុសាសន៍ដើម្បីបង្កើតយន្តការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ជាពិសេសតាមរយៈដំណើរការមជ្ឈត្តកម្ម និងការពង្រឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដោយហេតុថា CCAP គឺជាយន្តការសម្រុះសម្រួល និងមិនមែនជាយន្តការមជ្ឈត្តកម្មទេ។ **គូភាគីទាំងអស់អាចបញ្ជូនសំណុំរឿងមក NCAC តែក្នុងករណីដែលគូភាគីជម្លោះយល់ព្រមប្រើ NCAC ជាមជ្ឈត្តករដើម្បីដោះស្រាយវិវាទតែតែប៉ុណ្ណោះ។** យន្តការនេះគួរបញ្ជាក់តាមរយៈប្រការនៅក្នុងកិច្ចសន្យា (សូមមើលគម្រូខាងក្រោម) ឬ តាមរយៈកិច្ចសន្យាជាក់លាក់ដែលបានចុះហត្ថលេខានៅពេលវិវាទកើតឡើង។ លើសពីនេះ យើងអាចកត់សម្គាល់ឃើញថា NCAC ឬ / និងមជ្ឈត្តកម្មដោះស្រាយវិវាទពាណិជ្ជកម្ម ដែលបានបញ្ជូនមកមជ្ឈមណ្ឌលនេះ ដោយផ្អែកលើការយល់ព្រមរបស់ភាគីជម្លោះ ហើយអនុវត្តតែតាមវិធានគតិយុត្ត (ច្បាប់) ដែលជ្រើសរើសដោយគូភាគីតែប៉ុណ្ណោះ។

**គម្រូនៃប្រការមជ្ឈត្តកម្ម NCAC ដែលអាចដាក់បញ្ចូលទៅក្នុងកិច្ចសន្យា៖**

*"រាល់វិវាទទាំងឡាយណាដែលកើតឡើងពី ឬជាប់ទាក់ទងនឹងកិច្ចសន្យានេះ រួមទាំងបញ្ហាពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យា ត្រូវដោះស្រាយជាចុងក្រោយដោយមជ្ឈត្តកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានមជ្ឈត្តកម្មនៃមជ្ឈមណ្ឌលមជ្ឈត្តកម្មពាណិជ្ជកម្មជាតិ (NCAC) ដែលនៅជាធរមាននៅពេលចាប់ផ្តើមមជ្ឈត្តកម្ម និងដោយអាស្រ័យទៅតាមសេចក្តីយោងនៅក្នុងប្រការនេះ ដែលវិធាន NCAC ត្រូវបានចាត់ទុកជាផ្នែកមួយនៃកិច្ចសន្យានេះ។*

*មជ្ឈត្តកររួមមានចំនួន ____________________ * នាក់។*

**សូមបញ្ជាក់ចំនួនសេស។*

*ភាសាដែលប្រើប្រាស់នៅក្នុងមជ្ឈត្តកម្មគឺភាសា ____________________ ។*

*ច្បាប់ជាធរមាន*

*កិច្ចសន្យានេះគ្រប់គ្រងដោយច្បាប់នៃ ____________________ ។*

**សូមបញ្ជាក់ប្រទេស ឬយុត្តាធិការ។*

---

[56] http://www.cambodiaip.gov.kh/DocResources/372a361b-7a97-44b3-9810-79e5e6ea85f4_c786a043-b88d-4f64-9429-60a330efdc5f-en.pdf

[57] ច្បាប់ស្តីពីមជ្ឈត្តិកម្មពាណិជ្ជកម្ម ជំពូក ៣។

NCAC អនុម័តបទបញ្ជាផ្ទៃក្នុង និងវិធានមជ្ឈត្តកម្មនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៤ ដែលបង្កើតនីតិវិធីដូចខាងក្រោម [58]។

ដើម្បីចាប់ផ្តើមដំណើរការមជ្ឈត្តកម្ម ដើមបណ្តឹងត្រូវជូនដំណឹងស្តីពីមជ្ឈត្តកម្មទៅ NCAC[59]។ បន្ទាប់មក អគ្គលេខារបស់ NCAC នឹងបញ្ជូនសេចក្តីជូនដំណឹងនោះទៅចុងចម្លើយ។ ដំណើរការមជ្ឈត្តកម្មចាប់ផ្តើមនៅថ្ងៃដែលចុងចោទទទួលបានការជូនដំណឹងពីអគ្គលេខាធិការដ្ឋាន[60]។
បន្ទាប់ពីចាប់ផ្តើមដំណើរការមជ្ឈត្តកម្ម វេទិកាមជ្ឈត្តកម្មនឹងត្រូវតែងតាំង។ វេទិកាមជ្ឈត្តកម្មត្រូវមានសមាសភាព ៣ រូប លើកលែងតែគូភាគីព្រមព្រៀងគ្នាចង់ផ្សេងពីនេះ[61]។ ប្រសិនបើ គូភាគីមិនឯកភាពលើចំនួនមជ្ឈត្តករ មជ្ឈត្តករចំនួនបីរូបនឹងត្រូវតែងតាំងស្របតាមវិធាន NCAC[62]។

នៅពេលតែងតាំងរួច សវនាការដំបូងនឹងត្រូវធ្វើឡើងដើម្បីកំណត់អំពីកាលវិភាគសម្រាប់នីតិវិធី[63]។ វេទិកាមជ្ឈត្តកម្មនឹងកំណត់ផងដែរថាតើនីតិវិធីគួរធ្វើឡើងតាមរយៈការដាក់ឯកសារ ឬក៏ត្រូវឲ្យមានការទាញហេតុផលផ្ទាល់មាត់[64]។

ក្នុងដំណើរការនីតិវិធីមជ្ឈត្តកម្មនេះ គូភាគីអាចស្នើសុំវិធានការការពារ តាមរយៈវិធានការបណ្តោះអាសន្ន។ វិធានបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ និងបន្ទាន់ ដែលមិនរារាំងដល់សេចក្តីសម្រេចស្ថាពរ ដែលមានអង្គហេតុច្បាស់លាស់ទេ។ វិធានការបណ្តោះអាសន្ន រួមមាន [65] ជាអាទិ៍ដូចជា ដីកាដើម្បី៖

ក. ថែរក្សា ឬបង្កង់ស្ថានភាពល្អិតណាមិនទាន់ដោះស្រាយជម្លោះចប់

ខ. ចាត់វិធានការបង្ការ ឬទប់ស្កាត់សកម្មភាពដែលអាចបង្ក (i) ការខូចខាតស្រាប់ឬចំពោះមុខ ឬ (ii) រារាំងដល់ដំណើរការមជ្ឈត្តកម្មនោះ

គ. ផ្តល់មធ្យោបាយការពារទ្រព្យសម្បត្តិ ដែលអាចនឹងសម្រេចនៅពេលក្រោយ ឬ

ឃ. រក្សាភស្តុតាងដែលអាចពាក់ព័ន្ធនឹងដំណោះស្រាយសម្រាប់ជម្លោះ។

[58] ហៅថា « វិធានមជ្ឈត្តិកម្មរបស់ NCAC »

[59] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ៧

[60] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ៧.៧.

[61] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ៩.

[62] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ១០.

[63] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ២០.២.

[64] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ២៤.១.

[65] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ២៨.២.

នៅពេលគូភាគីបានផ្តល់ភស្តុតាងរួចហើយ មជ្ឈត្តករនឹងប្រកាសបិទនីតិវិធី។ ពីចំណុចនោះមក មជ្ឈត្តករមានរយៈពេល ៤៥ ថ្ងៃ ដើម្បីផ្តល់សេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យ ទៅអគ្គលេខាធិការដ្ឋាន NCAC សម្រាប់ពិនិត្យពិច័យ[66]។ NCAC នឹងពិនិត្យមើលសេចក្តីនោះ និងផ្តល់យោបល់សម្រាប់កែសម្រួលពាក់ព័ន្ធនឹងទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ ប៉ុន្តែគេនឹងមិនពិនិត្យមើលអង្គហេតុនៃសំណុំរឿង ឬអំណះអំណាងនៃមជ្ឈត្តវិនិច្ឆ័យនោះទេ។ គោលបំណងនៃការផ្តល់ជូនសេចក្តីព្រាងនេះទៅ NCAC សម្រាប់ពិនិត្យពិច័យ គឺដើម្បីប្រាកដថា ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ គឺស្របតាមលក្ខខណ្ឌអប្បបរិមាដើម្បីអនុវត្តបាន ក្នុងករណីមានការប្តឹងផ្តល់ទៅតុលាការ។ ជាចុងក្រោយ វេទិកាមជ្ឈត្តកម្មជាអ្នកសម្រេចថា ទទួលយកយោបល់ទាំងនោះដែរឬទេ។

បន្ទាប់ពីការពិនិត្យពិច័យរបស់ NCAC វេទិកាមជ្ឈត្តកម្មនឹងចេញមជ្ឈត្តវិនិច្ឆ័យទៅគូភាគី ហើយគូភាគីមានរយៈពេល ៣០ ថ្ងៃដើម្បីស្នើសុំការកែប្រែ ការកែតម្រូវ ការបំភ្លឺ ឬការបកស្រាយលើមជ្ឈត្តវិនិច្ឆ័យនោះ[67]។ ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ឃើញថាការស្នើសុំនោះមានអំណះអំណាងគ្រប់គ្រាន់ គេនឹងអនុវត្តតាមការស្នើសុំនោះ។ ពេលក្រោយមកទៀត មជ្ឈត្តវិនិច្ឆ័យចូលជាធរមាន និងចងកាតព្វកិច្ចចំពោះគូភាគី។

គូភាគីគួរដឹងថា ក្រោមវិធាន NCAC បន្ទាប់ពីបានពិគ្រោះជាមួយគូភាគី មជ្ឈត្តវិនិច្ឆ័យអាចចេញបានតែជាភាសាអង់គ្លេស ឬ ភាសាខ្មែរតែប៉ុណ្ណោះ ទោះបីជានីតិវិធីធ្វើជាភាសាអ្វីក៏ដោយ[68]។

គួរកត់សម្គាល់ផងដែរថា ប្រសិនបើគូភាគីដាក់ពាក្យបណ្តឹងមកដោះស្រាយតាមមជ្ឈត្តកម្មក្រោមវិធាន NCAC គូភាគីត្រូវបង់កម្រៃសេវាមួយចំនួន។

យោងតាមតារាងតម្លៃរបស់ NCAC ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៤ កម្រៃសេវាទាំងនោះ រួមមាន៖

- កម្រៃសេវាចុះបញ្ជី ២៥០ ដុល្លារ ក្នុងបណ្តឹងមួយ ឬបណ្តឹងតបមួយ
- កម្រៃសេវាតែងតាំងមជ្ឈត្តករ ៣០០ ដុល្លារ សម្រាប់មជ្ឈត្តករម្នាក់ ហើយកម្រៃសេវាទាំងនេះត្រូវអនុវត្តចំពោះការតែងតាំងមជ្ឈត្តករដែលត្រូវធ្វើឡើងដោយគណៈកម្មការតែងតាំង ប្រសិនបើគូភាគីមិនអាចតែងតាំងមជ្ឈត្តករបានអនុលោមតាមតាមវិធាន NCAC
- កម្រៃសេវារដ្ឋបាលប្រែប្រួលទៅតាមទំហំនៃវិវាទសម្រាប់សេវាកម្ម
- កម្រៃសេវាវេទិកាមជ្ឈត្តកម្ម ដែលគិតថ្លៃទៅតាមទំហំវិវាទ និងចំនួនមជ្ឈត្តករ។

[66] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ៣៥.១.

[67] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ៣៨.

[68] វិធានមជ្ឈត្តិកម្មរបស់ NCAC, វិធានទី ១៨.៣.

## ៦.២. ការដោះស្រាយវិវាទតាមផ្លូវតុលាការ៖ ប្រព័ន្ធតុលាការ

តុលាការមានអំណាចដោះស្រាយវិវាទដោយពិនិត្យមើលថាតើបានអនុវត្ត និងប្រតិបត្តិតាមច្បាប់ត្រឹមត្រូវដែរ ឬទេ។ តុលាការនៅប្រទេសកម្ពុជាត្រូវបានរៀបចំឡើងដោយ មាន ៣ កម្រិត៖ដែលនៅកម្រិតទីមួយគឺ សាលាដំបូងរាជធានី ឬ សាលាដំបូងខេត្ត។ សាលាដំបូងខេត្តមានយុត្តាធិការលើដែនដីខេត្តទាំងមូល ហើយសាលាដំបូងរាជធានីមានយុត្តាធិការលើដែនដីរាជធានីទាំងមូល និងអនុវត្តលើគ្រប់វិស័យ។ នាពេលបច្ចុប្បន្ន សាលាដំបូងរាជធានីភ្នំពេញទទួលបន្ទុកដោះស្រាយករណីវិវាទពាណិជ្ជកម្មយ៉ាងច្រើន[69]។ នៅកម្រិតទីពីរ៖ សាលាឧទ្ធរណ៍។ សាលាឧទ្ធរណ៍មានតែមួយគត់ គឺនៅរាជធានីភ្នំពេញ។ កម្រិតខ្ពស់បំផុត៖ តុលាការកំពូល ក៏មានតែមួយ និងនៅភ្នំពេញដែរ។ សាលាឧទ្ធរណ៍ពិនិត្យមើលលើបញ្ហាទាំងអង្គច្បាប់ និងអង្គហេតុ រីឯតុលាការកំពូល នៅក្នុងករណីភាគច្រើន បើកសវនាការតែសម្រាប់សំនួរពាក់ព័ន្ធនឹងច្បាប់ប៉ុណ្ណោះ។ ការបង្កើតតុលាការពាណិជ្ជកម្មគឺជាបញ្ហាគន្លឹះមួយបន្ទាប់ពីកម្ពុជាក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភព លោក[70]។ ក្រសួងពាណិជ្ជកម្មកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម ដោយសហការជាមួយក្រសួងយុត្តិធម៌។ យោងតាមសេចក្តីព្រាងច្បាប់នេះ តុលាការពាណិជ្ជកម្មនឹងជាអង្គភាពដាច់ដោយឡែកពីសាលាដំបូងរាជធានី-ខេត្ត។ ទោះមិនទាន់មានដំណើរការដូចដែលបានគ្រោងទុកនៅឡើយ តុលាការនេះនឹងស្ថិតនៅទីក្រុងភ្នំពេញតែប៉ុណ្ណោះ ប៉ុន្តែមានវិសាលភាពលើដែនដីប្រទេសកម្ពុជាទាំងមូល[71] ។

ស្របតាមរដ្ឋធម្មនុញ្ញ ពលរដ្ឋកម្ពុជាទាំងអស់ មានសិទ្ធិតវ៉ា ប្តឹង ឬ ទាមទារប្រាក់សំណង ឬ ការខូចខាត ហើយការទាមទារទាំងនោះត្រូវធ្វើឡើងនៅក្រោមសមត្ថកិច្ចរបស់តុលាការ[72] ។ មុនពេលតុលាការពាណិជ្ជកម្មមានដំណើរការ គូភាគីនៃកិច្ចសន្យាផលិតកម្មកសិកម្ម គួរដោះស្រាយវិវាទតាមរយៈសាលាដំបូងរាជធានីខេត្តសិន។ គួរកត់សម្គាល់ផងដែរថា ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា[73]សង្កត់ធ្ងន់លើការដោះស្រាយដោយសន្តិវិធីសម្រាប់ការដោះស្រាយវិវាទ[74] ហើយត្រូវស្វែងរកការសម្រុះសម្រួលគ្នារវាងគូភាគីជាមុនសិន នៅមុន និងនៅគ្រប់ដំណាក់កាលនៃការដោះស្រាយវិវាទ។ នៅក្រោមបទប្បញ្ញត្តិទាំងនេះ តុលាការអាចលើកទឹកចិត្តឲ្យគូភាគីចរចាគ្នា ឬ ក៏អាចដើរតួនាទីសកម្មនៅក្នុងករណីនេះ។ ប្រសិនបើការចរចាទទួលបានជោគជ័យ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថាការឯកភាពគ្នាលើការដោះស្រាយនោះ អាចចាត់ទុកថាជាការវិនិច្ឆ័យដែលអាចអនុវត្តបាន។ ការដោះស្រាយដោយមានការចរចាគ្នា អាចបម្លែងទៅជាការផ្សះផ្សាតាមផ្លូវតុលាការ ដែលមានការកត់ត្រាទុកនៅក្នុងនីតិវិធីតុលាការ (កំណត់ហេតុស្តីពីការសះជា)[75]។ បន្ទាប់ពីបានអនុវត្តគ្រប់ជំហានរួចហើយការផ្សះផ្សានេះត្រូវបានអនុវត្ត

[69] BNG ការដោះស្រាយវិវាទនៅក្នុងប្រទេសកម្ពុជា ខែមករា ឆ្នាំ ២០០៦។

[70] កម្ពុជាបានក្លាយជាសមាជិក WTO តាំងពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។

[71] BNG ការដោះស្រាយវិវាទនៅក្នុងប្រទេសកម្ពុជា ខែមករា ឆ្នាំ ២០០៦។

[72] មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

[73] ក្រមនីតិវិធីរដ្ឋប្បវេណីចូលជាធរមានកាលពីខែកញ្ញា ឆ្នាំ ២០០៦

[74] មាត្រា ៩៧, ២២០, ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[75] មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ដូចជាសាលក្រមតុលាការដែរ[76]។ នេះមានន័យថា ប្រសិនបើភាគីណាមួយមិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ភាគីម្ខាងទៀតអាចប្តឹងទៅតុលាការដើម្បីអនុវត្តតាមកិច្ចសន្យា ដោយមិនចាំបាច់មានអង្គហេតុថ្មីនៃវិវាទឡើយ។ ការណ៍នេះគួរតែចូលរួមពង្រឹងដល់ប្រសិទ្ធភាព[77]។

ទីបញ្ចប់ ដំណោះស្រាយវិវាទតាមផ្លូវតុលាការ កម្រនឹងត្រូវបានប្រើប្រាស់ណាស់នៅក្នុងបរិបទនៃកសិកម្មតាមកិច្ចសន្យា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ផ្អែកលើមូលដ្ឋាននេះ ការទទួលបានការដោះស្រាយបញ្ហាពីចៅក្រម តែងមានរយៈពេលយូរ ហើយអាចចំណាយប្រាក់ច្រើន ដូច្នេះគូភាគីតែងតែចង់ចៀសវាង[78]។ កត្តាទាំងនេះ ធ្វើឲ្យគេមិនចង់ប្រើប្រព័ន្ធតុលាការ។ ទន្ទឹមនេះដែរ តុលាការក៏មានសំណុំរឿងច្រើន និងខ្វះធនធានមនុស្ស ដែលធ្វើឲ្យមនុស្សទូទៅមិនចង់ប្រើប្រព័ន្ធតុលាការនេះដើម្បីដោះស្រាយទំនាស់ ។

ទោះយ៉ាងណា នៅក្នុងដំណើរការតុលាការ គូរភាគីក៏ត្រូវមានមេធាវីតំណាង ដើម្បីដោះស្រាយនិងការពារសិទ្ធិ ដែលត្រូវចំណាយប្រាក់ជាច្រើន។ គុណសម្បត្តិនៃប្រព័ន្ធនេះគឺ ការអនុវត្តតាមសាលាក្រមរបស់តុលាការ។ ការអនុវត្តតាមសាលក្រមតុលាការ គឺជាដំណាក់កាលមួយកើតឡើង បន្ទាប់ពីសាលក្រម ចូលជាស្ថាពរ។

---

[76] Ibid.

[77] សេចក្តីផ្តើមនៃច្បាប់កម្ពុជា, ហោ ប៉េង , គង់ ផល្លៈ, Jorg Menzel, Konrad Adenauer Stiftung, ២០១២។

[78] មគ្គុទេសក៍ច្បាប់ស្តីពីកិច្ចសន្យាផលិតកម្មកសិកម្ម, UNIDROIT, FAO, IFAD, Rome ២០១៥។

## ៦.៣. តារាងសង្ខេប

**សង្ខេប៖ ការប្រៀបធៀបរវាងវិធីផ្សេងគ្នាសម្រាប់ដោះស្រាយវិវាទ**

**តារាង ៦.៣.ក.៖ ការប្រៀបធៀបរវាងប្រព័ន្ធដោះស្រាយវិវាទ**

| ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ | ការចរចា | ការសម្រុះសម្រួល | | ការផ្សះផ្សា | | មជ្ឈត្តកម្ម | | តុលាការ |
|---|---|---|---|---|---|---|---|---|
| | | អ្នកសម្រុះសម្រួលឯកជន | CCAPC | អ្នកផ្សះផ្សាឯកជន ឬ | មណ្ឌលសេវាកម្មយុត្តិធម៌ | មជ្ឈត្តករឯកជន | NCAC | |
| ពេលណា? | ការដោះស្រាយដំបូង ក្រៅប្រព័ន្ធតុលាការ | ដំណាក់កាលបន្ទាប់ ក្រោយចរចាមិនបានសម្រេច | | ដំណាក់កាលបន្ទាប់ ក្រោយចរចាមិនបានសម្រេច | | ដំណាក់កាលបន្ទាប់ ក្រោយការផ្សះផ្សា ឬសម្រុះសម្រួល មិនបានសម្រេច | | |
| ភាគីពាក់ព័ន្ធ? | មានតែភាគីជម្លោះ | ភាគីជម្លោះ+ អ្នកសម្រុះសម្រួល | | ភាគីជម្លោះ+ អ្នកផ្សះផ្សា | | ភាគីជម្លោះ+ មជ្ឈត្តករ | | ភាគីជម្លោះ+ ចៅក្រម + មេធាវី បើស្នើសុំ |
| តួនាទីរបស់ភាគីទីបី? | | អ្នកសម្រុះសម្រួលជួបគូភាគីរួមគ្នា និងព្យាយាមរកដំណោះស្រាយ ដោយពិចារណាលើផលប្រយោជន៍ និងសំណើរបស់គូភាគី។ គូភាគីជាអ្នកសម្រេច។ | | អ្នកផ្សះផ្សាជួបគូភាគី ដោយឡែកពីគ្នា និងនាំសំណើទៅមកដល់គូភាគី ដើម្បីគេដោះស្រាយជម្លោះ។ គូភាគីជាអ្នកសម្រេចចិត្តជ្រើសរើសដំណោះស្រាយ ដោយមានការជួយពីអ្នកផ្សះផ្សា។ | | មជ្ឈត្តករផ្តល់ដំណោះស្រាយ។ គូភាគីត្រូវគោរពតាមសេចក្តីសម្រេច។ | | ចៅក្រមចេញសាលក្រម។ គូភាគីត្រូវគោរពតាមសេចក្តីសម្រេច។ |
| ការចាប់ផ្តើមដំណើរការ? | ដោយស្ម័គ្រចិត្ត | ដោយស្ម័គ្រចិត្ត | | ដោយស្ម័គ្រចិត្ត | | ដោយស្ម័គ្រចិត្ត (ឬដោយកាតព្វកិច្ចគោរពច្បាប់ ឬកិច្ចសន្យាដែលមានជាមុន) | | ដោយស្ម័គ្រចិត្ត |
| លទ្ធផល? | ផ្អែកលើគូភាគី | ផ្អែកលើគូភាគី | | អ្នកផ្សះផ្សាអាចផ្តល់ដំណោះស្រាយ ប៉ុន្តែវាស្រេចតែគូភាគីទទួលយកឬទេ។ | | អាស្រ័យលើសេចក្តីសម្រេចរបស់មជ្ឈត្តករ | | អាស្រ័យការសម្រេចចិត្តរបស់ចៅក្រម |
| ការអនុវត្តលទ្ធផល? | កិច្ចព្រមព្រៀង គឺដូចជាកិច្ចសន្យា។ បើភាគីមួយមិនបំពេញតាម ភាគីមួយទៀត ត្រូវទៅតុលាការ។ | | | | | ត្រូវអនុវត្តតាមក្រុមមជ្ឈត្តករ ឬដោយមធ្យោបាយផ្ទាល់ផ្សេងទៀត | | ការសម្រេចចិត្តត្រូវតែអនុវត្តតាម |
| ការចំណាយ? | ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលចំណាយតិចជាងគេ | ចំណាយតិចជាងមជ្ឈត្តកម្ម | មិនដឹង ? | ចំណាយតិចជាងមជ្ឈត្តកម្ម | ? | ច្រើនជាងការផ្សះផ្សា ឬការសម្រុះសម្រួល | ថ្លៃបង្គួរ | ថ្លៃជាងគេ |
| រយៈពេល? | ខ្លី | ខ្លី | អាចយូរ | ខ្លី | ? | មធ្យម (លឿនជាងតុលាការ) | រយៈពេលខ្លី | រយៈពេលយូរ |

# ផ្នែកទី ៧៖ ការផ្គត់ផ្គង់អង្គការកសិករ/សហករដែលពាក់ព័ន្ធក្នុង ផលិតកម្មកសិកម្មតាមកិច្ចសន្យា

## ៧.១. ករណីមួយនៃ "គំរូអន្តរការី"៖ អង្គការកសិករមិនមែនជាអ្នកផលិតទេ ប៉ុន្តែដើរតួជាអន្តរការីឲ្យកសិករ និងអ្នកទិញ

ក្នុងករណីដែលផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវធ្វើឡើងរវាងអង្គការកសិករ និងអ្នកទិញ (ក្រុមហ៊ុន) ជាទូទៅ អង្គការកសិករដើរតួនាទីជាឈ្មួញកណ្តាល។ នៅក្នុងបរិបទកម្ពុជាបច្ចុប្បន្ន សហគមន៍កសិកម្ម (ឬធំទូលាយជាងនេះ អង្គការកសិករ) មិនមែនជាអ្នកផលិតដោយខ្លួនឯងទេ។ សមាជិករបស់គេ (កសិករ) គឺជាអ្នកផលិត ចំណែកឯអង្គការកសិករ/សហគមន៍កសិកម្ម ដើរតួនាទីជាឈ្មួញកណ្តាលរវាងអ្នកផលិតនិងអ្នកទិញ។ វាអាចចាត់ទុកជា "គំរូអន្តរការី" ដែលជាប្រភេទមួយនៅក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យា ដែលបានបង្ហាញនៅក្នុង ផ្នែកទី ១.១.២. (ជាពិសេសក្នុងតារាងនៃការបែងចែកប្រភេទផ្សេងៗរបស់ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ក្នុងផ្នែកនោះ) ។ ដូចដែលបានរៀបរាប់មកនេះ ខណៈដែលចុះកិច្ចសន្យាជាមួយនឹងអតិថិជនរបស់ខ្លួន (អ្នកទិញ) អង្គការកសិករគួរតែធានា (អាចតាមរយៈអនុកិច្ចសន្យា ឬលិខិតទាក់ទងគ្នា) នូវលទ្ធភាពរបស់ខ្លួនជាក់ស្តែងដើម្បីប្រមូលផលិតផលពីសមាជិករបស់ខ្លួន ។

## ៧.២. ធានាដល់ការប្តេជ្ញាចិត្ត និងការផ្គត់ផ្គង់ដោយសមាជិកអង្គការកសិករ

ក្នុងករណីដែលផលិតកម្មកសិកម្មតាមកិច្ចសន្យា ត្រូវធ្វើឡើងដោយអង្គការកសិករដើម្បីផ្គត់ផ្គង់ក្នុងបរិមាណច្រើន ហើយត្រូវធ្វើការជាមួយនឹងចំនួនសមាជិកនៃអង្គការកសិករច្រើនទៀតនោះ អ្នកដឹកនាំអង្គការកសិករគួរតែយល់ឱ្យបានច្បាស់ជាមុន នូវលទ្ធភាពនៃការផលិត និងខសន្យារបស់សមាជិកខ្លួនក្នុងការផ្គត់ផ្គង់ផលិតផលតាមតម្រូវការរបស់អ្នកទិញ មុនចុះកិច្ចសន្យា។ ការប្រជុំជាមួយនឹងសមាជិកអង្គការកសិករទាំងអស់ គួរតែរៀបចំឡើងដោយអ្នកដឹកនាំអង្គការកសិករ ដើម្បីបង្ហាញពីតម្រូវការរបស់អ្នកទិញ និងផលប្រយោជន៍ដែលសមាជិកម្នាក់ៗនឹងទទួលបានពីកិច្ចសហការនោះ។ សមាជិកទាំងនោះ ត្រូវតែបង្ហាញគំនិតរបស់ខ្លួនក្នុងកិច្ចប្រជុំនោះ ដើម្បីឱ្យច្បាស់ថា ពួកគេនឹងចូលរួម ឬ មិនចូលរួមក្នុងក្រុម ដើម្បីផលិតឱ្យតាមតាមលក្ខខណ្ឌដែលគេតម្រូវនោះ។ កិច្ចសហការជាមួយអ្នកទិញនេះ នឹងត្រូវធ្វើឡើងក្នុងរយៈពេលវែង។ សមាជិក គួរតែមានការប្តេជ្ញាចិត្តរយៈពេលវែងសម្រាប់កិច្ចសហការនេះ ប្រសិនបើគេយល់ព្រមធ្វើការជាមួយគ្នា។

ខណៈដែលសមាជិកយល់ព្រមចុះកិច្ចសន្យាជាមួយនឹងអ្នកទិញហើយ អ្នកដឹកនាំអង្គការកសិករដំណើរការការស្ទាបស្ទង់មតិជាមួយនឹងសមាជិកម្នាក់ៗដាច់ដោយឡែកដើម្បីបញ្ជាក់ម្តង ទៀតពីការប្តេជ្ញាចិត្តរបស់សមាជិកម្នាក់ៗនោះក្នុងការផលិតផលិតផលតាមលក្ខខណ្ឌ និងគុណភាពដែលគេ តម្រូវ នឹងដើម្បីដឹងឱ្យបានច្បាស់ពីលទ្ធភាពផលិតនៃសមាជិកម្នាក់ៗ ជាពិសេសបរិមាណដែលអាចផលិត និង លក់បានដោយសមាជិកម្នាក់ៗ ឧបសគ្គក្នុងអំឡុងពេលផលិត ការជួយគាំទ្រដែលត្រូវការ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ) និងបញ្ហាផ្សេងៗទៀតដែលអាចកើតឡើងនៅក្នុងដំណើរការផលិត។ អ្នកដឹកនាំអង្គការកសិករ ត្រូវតែប្រាកដថា គ្រប់សមាជិកទាំងអស់យល់ដូចគ្នា ហើយប្តេជ្ញានឹងអនុវត្តតាមលក្ខខណ្ឌ និងកត្តាតម្រូវផ្សេងៗ ដែលបានដាក់ឱ្យ។ វាជាការចាំបាច់ក្នុងការធ្វើកិច្ចសន្យាផ្ទៃក្នុង (ឬ លិខិតបញ្ជាក់ការប្តេជ្ញា) រវាងសមាជិកម្នាក់ៗ ជាមួយនឹងសហគមន៍/អង្គការកសិករក្នុងការធ្វើឱ្យការប្តេជ្ញានោះទៅជាផ្លូវការ ដើម្បីផ្គត់ផ្គង់នូវផលិតផលតាម ការទាមទារដោយកិច្ចសន្យាដែលធ្វើឡើងរវាងអង្គការកសិករ និងអ្នកទិញ។ អ្នកដឹកនាំអង្គការកសិករអាចត្រូវ ការអាជ្ញាធរមូលដ្ឋានដើម្បីទទួលស្គាល់

កិច្ចសន្យា ឬ ការប្តេជ្ញាទាំងនោះក្នុងនាមជាសាក្សី ដែលអាជ្ញាធរដដែលនោះ អាចជួយក្រៅផ្លូវការដើម្បីដោះស្រាយទំនាស់ជាមួយនឹងសមាជិកក្នុងករណីដែលមិនបានគោរពតាមខសន្យា។ កិច្ចសន្យាដែលបញ្ជាក់ពីការប្តេជ្ញានោះគួរតែបញ្ជាក់ឱ្យច្បាស់ពីប្រភេទនៃផលិតផល បរិមាណ និងគុណភាពដែលសមាជិកម្នាក់ៗត្រូវតែប្តេជ្ញាធ្វើឱ្យបាន រួមទាំងបញ្ជាក់ពីពេលវេលាដែលត្រូវប្រគល់ទំនិញឱ្យផងដែរ។ នៅផ្ទៃក្នុងអង្គការកសិករអាចបកស្រាយលម្អិត និងអនុម័តប្រព័ន្ធនៃការផ្តល់រង្វាន់លើកទឹកចិត្ត / ការដាក់ទណ្ឌកម្ម ដែលជាផ្នែកមួយនៃនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីជម្រុញឱ្យសមាជិកបំពេញតាមខសន្យារបស់គេ (ឧទាហរណ៍ ធ្វើការខិតខំឱ្យអស់លទ្ធភាពដើម្បីឈានដល់បរិមាណនៃផលិតកម្ម និងគុណភាពដែលរំពឹងទុក និងចៀសវាងការលក់ទៅឱ្យអ្នកផ្សេង)។ អ្នកដឹកនាំអង្គការកសិករ គួរតែប្រាកដថាកិច្ចសន្យាបញ្ជាក់ការប្តេជ្ញាផ្ទៃក្នុង មានភាពច្បាស់លាស់ ហើយសមាជិកទាំងអស់យល់ច្បាស់ ដើម្បីចៀសវាងការយល់ខុស។

### ការពន្យល់បន្ថែម ៧.២.ក.

**ទម្រង់មួយនៃកិច្ចសន្យារវាងគណៈកម្មាធិការគ្រប់គ្រងសហករកសិកម្មនិងសមាជិក សហករកសិកម្ម ស្តីពីផលិតកម្មស្រូវសរីរាង្គ**

អ្នកដឹកនាំសហគមន៍នៅខេត្តព្រះវិហារ មិនបានរៀបចំកិច្ចសន្យារវាងសហគមន៍ និងសមាជិកដើម្បីផលិតស្រូវសរីរាង្គសម្រាប់ក្រុមហ៊ុន AMRU។ ប៉ុន្តែពួកគេរៀបចំតារាងសាមញ្ញមួយដែលរៀបរាប់ឈ្មោះនៃគ្រួសារនីមួយៗ ផ្ទៃដីរបស់គេសម្រាប់ផលិតកម្ម ប្រភេទពូជ និងបរិមាណដែលត្រូវបានគេប៉ាន់ស្មានសម្រាប់លក់ឱ្យក្រុមហ៊ុន សម្រាប់អង្ករក្រអូបនិងអង្ករស។ សមាជិកម្នាក់ៗត្រូវតែផ្តិតមេដៃនៅលើតារាងនេះ។ តារាងនេះត្រូវបានប្រើជាឧបសម្ព័ន្ធរបស់កិច្ចសន្យាដែលចុះជាមួយនឹងក្រុមហ៊ុន AMRU។ អ្នកដឹកនាំសហគមន៍ប្រើតារាងនេះជាខសន្យារបស់សមាជិករបស់គេដើម្បីផលិតស្រូវឱ្យក្រុមហ៊ុន។គម្រូនៃតារាងនេះមាននៅខាងក្រោម ៖

**បញ្ជីឈ្មោះកសិករផលិតស្រូវសរីរាង្គសហគមន៍ក្របៅព្រហ្មទេពឆ្នាំ ២០១៥**

ភូមិក្របៅ ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ

Name List of Organic Rice Producer for Agricultural Cooperative of Krobao Pruntep 2015

Krabao Village, Kulen Thong commune, Kulen district, Preah Vihear Province

| ល.រ NO | លេខកូដCode | Name of farmer | ឈ្មោះកសិករ Farmer Name | Village | ភូមិ Village | ពូជ (Variety) | ប្រភេទស្រូវក្រអូប (Fragrant Rice) | | ប្រភេទស្រូវស (white Rice) | | ហត្ថលេខា/ស្នាមមេដៃSignature/ Thumbprint |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ទំហំផ្ទៃដី(ហិកតា) Land size (ha) | បរិមាណស្រូវដែលលក់(តោន) Estimated quatity for sale (Ton) | ទំហំផ្ទៃដី(ហិកតា) Land size (ha) | បរិមាណស្រូវដែលលក់(តោន) Estimated quatity for sale (Ton) | |
| 1 | AC001-1-5-223-1 | Noun Vandy | នួន វណ្ណឌី | 2 Kro bao | 2 ក្របៅ | ទូលៀស | 0.00 | 0.00 | 1.50 | 1.00 | |
| 2 | AC001-2-3-021-1 | Sok Poeun | សុខ ភឿន | 2 Kro bao | 2 ក្របៅ | រំដួល | 2 | 2 | 0 | 0 | |
| 3 | AC001-2-3-192-1 | Til SamAn | ទិល សំអាន | 2 Kro bao | 2 ក្របៅ | រំដួល | 1.5 | 3 | 0 | 0 | |
| 4 | AC001-2-3-081-1 | Pom Nhim | ពន់ ញឹម | 2 Kro bao | 2 ក្របៅ | រំដួល | 1.5 | 2 | 0 | 0 | |

តារាងប្រភេទនេះជាឧបករណ៍ល្អរួចជាស្រេចទៅហើយ។ ប៉ុន្តែ ជាការល្អ ត្រូវមានប្រយោគមួយនៅខាងលើតារាង (ឬកំណត់សម្គាល់សម្រាប់កូលោន "ហត្ថលេខា/ស្នាមមេដៃ") ដែលបញ្ជាក់ ដោយការចុះហត្ថលេខា (ឬផ្តិតមេដៃ) លើតារាងនេះ ថាអ្នកផលិតនីមួយៗបានប្តេជ្ញាថានឹងប្រគល់ផលិតផលដែលបានបង្ហាញនោះ (អនុលោមតាមគុណភាពដែលតម្រូវ)ទៅឱ្យអង្គការកសិករតាមកាលកំណត់ក្នុងកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងអង្គការកសិករនិងអ្នកទិញ ។

មុនពេលរដូវប្រមូលផលចូលមកដល់អ្នកដឹកនាំអង្គការកសិករត្រូវតែជួបប្រជុំ និងបញ្ជាក់ឡើងវិញពីលទ្ធភាពសមាជិកម្នាក់ៗក្នុងការផ្គត់ផ្គត់ផលិតផលដែលមានគុណភាពតាមការព្រមព្រៀងគ្នា។ ការធ្វើបែបនេះ អាចជួយអ្នកដឹកនាំដើម្បីកែសម្រួលការប៉ាន់ស្មានពីការផលិតជាក់ស្តែងដែលពាក់ព័ន្ធនឹងការប្តេជ្ញាដែលបានចុះហត្ថលេខាក្នុងកិច្ចសន្យា។ អ្នកដឹកនាំអង្គការកសិករ អាចកែសម្រួលបរិមាណដែលត្រូវលក់ដោយសមាជិកម្នាក់ៗ តាមករណីជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងបរិមាណនិងគុណភាពដែលបានព្រមព្រៀងក្នុងកិច្ចសន្យាទាំងមូលជាមួយអ្នកទិញ។ ការកែប្រែនេះត្រូវតែជូនដំណឹងដល់សមាជិកអំឡុងពេលប្រមូលផលជាពិសេសចំពោះសមាជិកដែលមានផលិតផលលើស ដើម្បីឱ្យពួកគេទុកផលិតផលរបស់គេសម្រាប់លក់ឱ្យអង្គការកសិករ។

អំឡុងពេលប្រតិបត្តិការគ្រប់សមាជិកទាំងអស់គួរតែទទួលដំណឹងឱ្យបានច្បាស់អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាដើម្បីប្រគល់ផលិតផល។ អ្នកដឹកនាំអង្គការកសិករ ត្រូវតែរៀបចំបញ្ជីផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ថាសមាជិកនីមួយៗបានផ្គត់ផ្គង់ទំនិញទៅតាមការសន្យារបស់គេ (សម្រាប់គ្រប់កន្លែងផ្គត់ផ្គង់ទំនិញ)។ ប្រសិនបើសមាជិកមិនបានផ្គត់ផ្គង់ផលិតផលតាមការសន្យានោះ ទេ សមាជិកគួរទទួលបានការជូនដំណឹងជាបន្ទាន់ពីអ្នកដឹកនាំអង្គការកសិករ។

ក្នុងផ្នែកមួយនៃកិច្ចសន្យា ប្រសិនបើកសិករទទួលបានវត្ថុធាតុដើមតាមរយៈអង្គការកសិករនោះ វាក៏សំខាន់សម្រាប់អង្គការកសិករដែរ ក្នុងការសុំឱ្យសមាជិករបស់ខ្លួន ចុះហត្ថលេខាលើវិក្កយប័ត្រទទួលសម្រាប់ការទទួលរបស់ម្តងៗ ដោយបញ្ជាក់ឱ្យច្បាស់នូវសភាព និងគុណភាពរបស់ដែលទទួលបាន ហើយបើអាច ត្រូវបញ្ជាក់អំពីតម្លៃនៃរបស់នោះផង (ជាពិសេសប្រសិនបើតម្លៃនេះត្រូវដកចេញពីថ្លៃសរុបដែលអ្នកផលិតនឹងទទួលបានពេលទូទាត់ថ្លៃទំនិញរបស់គេ)។ អ្នកដឹកនាំអង្គការកសិករ អាចរៀបចំតារាងមួយដើម្បីបូកសរុបគ្រប់វត្ថុធាតុដើមទាំងអស់ដែលបានទទួលដោយសមាជិកម្នាក់ៗ និងតម្លៃសរុបដែលគេរំពឹងថានឹងយកបានមកវិញពេលដែលប្រគល់ផលិតផល។ ប្រសិនបើគេគិតគួរដល់អត្រាការប្រាក់ទៀតនោះ គេក៏គួរតែគណនានិងបង្ហាញនៅលើក្រដាសបូកសរុបនេះ។

## ៧.៣. បញ្ហានៃការគ្រប់គ្រងគុណភាពនៅក្នុងអង្គការកសិករ

គុណភាពនៃផលិតផលគឺជាកង្វល់ដ៏ធំ របស់អង្គការកសិករ ដែលចុះកិច្ចសន្យាផលិតកម្មកសិកម្ម។ នៅក្នុងប្រទេសកម្ពុជា កសិករខ្នាតតូច មានបទពិសោធន៍ក្នុងការផលិតសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ សម្រាប់ទីផ្សារក្នុងស្រុក ប៉ុន្តែសម្រាប់ទីផ្សារលំដាប់ខ្ពស់ ឬ ទីផ្សារនាំចេញ (ដែលជាញឹកញាប់គឺជាគោលដៅរបស់អ្នកទិញនៅក្នុងកិច្ចសន្យាផលិតកម្មកសិកម្ម) ពួកគេមិនសូវបានដឹងអំពីគុណភាព ឬ ស្តង់ដារជាក់លាក់ទេ ហើយពួកគេអាចប្រើទម្លាប់ចាស់ដើម្បីប្រមូលផល និងរក្សាទុក។

អ្នកដឹកនាំអង្គការកសិករ (ដែលមានទំនាក់ទំនងផ្ទាល់ជាមួយតំណាងអ្នកទិញ និងយល់ច្បាស់អំពីលក្ខខណ្ឌគុណភាព) ត្រូវយកចិត្តទុកដាក់លើសមត្ថភាពរបស់អង្គការកសិករដើម្បីផ្គត់ផ្គង់តាមគុណភាពចាំបាច់ និងគួរព្យាយាមដើម្បី ៖

- ផ្សព្វផ្សាយអំពីលក្ខខណ្ឌគុណភាពទៅសមាជិក និងលើកកម្ពស់ទម្លាប់ផលិតកម្ម ដែលកសិករគួរគោរពតាម ដើម្បីបំពេញតាមលក្ខខណ្ឌគុណភាព
- តាមដាន ការអនុវត្តផលិតកម្មរបស់សមាជិក ក្នុងដំណាក់កាលផលិតកម្ម
- នៅដំណាក់កាលប្រមូលផល ត្រួតពិនិត្យគុណភាពផលិតផលដែលបានប្រគល់មកពីសមាជិក មុនពេលប្រគល់ទៅអ្នកទិញចុងក្រោយ។

ប្រសិនបើលក្ខខណ្ឌរបស់អ្នកទិញ ពាក់ព័ន្ធនឹងគុណភាព និង / ឬ ដំណើរការផលិត ត្រូវបានមើលឃើញថានឹងមានការលំបាក អង្គការកសិករអាចចរចា អំពីការគាំទ្រផ្នែកបច្ចេកទេសពីអ្នកទិញ ដូចបានកំណត់នៅក្នុងកិច្ចសន្យា ដើម្បីជួយអ្នកផលិតសម្រេចបានស្តង់ដារ (សូមមើលផ្នែក ៤.២.៤. ទំព័រ ៥៧)

## ៧.៣.១. ការរកឃើញ និងការលើកកម្ពស់ការអនុវត្តល្អដើម្បីលើកកម្ពស់គុណភាព

គុណភាពនៃផលិតផលគឺជាបញ្ហាដ៏សើបសម្រាប់អ្នកផលិត និងអ្នកទិញព្រោះវាជាការកំណត់តម្លៃនៃផលិតផល។ ដូច្នេះការកសាងការទុកចិត្ត និងភក្តីភាពក្នុងចំណោមសមាជិក និងអ្នកទិញគឺជាការសំខាន់ណាស់។

អ្នកដឹកនាំ អង្គការកសិករគួរជួបប្រជុំជាមួយសមាជិកទាំងអស់ ដើម្បីស្វែងយល់អំពីបរិមាណនិងគុណភាពដែលអ្នកទិញត្រូវការ។ ការប្រែប្រួលតម្លៃទៅតាមកម្រិតគុណភាព គួរមានភាពច្បាស់លាស់សម្រាប់សមាជិក មុនចាប់ផ្តើមការផលិត ដើម្បីឲ្យសមាជិកមានទឹកចិត្តធ្វើតាមអនុសាសន៍ ដែលនឹងនាំទៅរកកម្រិតគុណភាពដែលបានរំពឹងទុក ព្រមទាំងទទួលបានតម្លៃខ្ពស់ នៅពេលលក់។

ការអនុវត្តល្អ (ពាក់ព័ន្ធនឹងវិធីសាស្រ្តផលិត) ដែលនឹងនាំទៅរកគុណភាពល្អ គួរតែកំណត់ឲ្យបានច្បាស់លាស់ [កត់សម្គាល់ថា កិច្ចសន្យាផលិតកម្មកសិកម្ម អាចតម្រូវឲ្យអនុវត្តជាក់លាក់នៅក្នុងការផលិត សូមមើលផ្នែក ៤.៥. ទំព័ ៦៦] និងណែនាំដល់សមាជិកទាំងអស់ក្នុងអង្គការកសិករ (ដោយអ្នកដឹកនាំអង្គការកសិករ ឬ ដោយអ្នកទិញតែម្តង ប្រសិនបើកិច្ចសន្យាបញ្ជាក់ថា អ្នកទិញនឹងផ្តល់ការបណ្តុះបណ្តាញ / ការផ្សព្វផ្សាយបច្ចេកទេសដល់សមាជិកអង្គការកសិករ)។

ការបណ្តុះបណ្តាលដល់សមាជិកអំពីបច្ចេកទេសកែលម្អការផលិត និងស្តង់ដារគុណភាព គួរផ្តល់ដោយគណៈកម្មការគ្រប់គ្រងអង្គការកសិករ ឬ ដោយដៃគូបច្ចេកទេស មុនពេល ឬ ក្នុងវដ្តផលិតកម្ម [79] ។ ដូច្នេះសមាជិក ចាប់ផ្តើមអនុវត្តបច្ចេកទេសដើម្បីកែលម្អការផលិត និងគុណភាព តាំងពីដំណាក់កាលដំបូងនៃការផលិត។ ខ្លឹមសារនៃសៀវភៅបណ្តុះបណ្តាលបច្ចេកទេស គួរត្រូវបានត្រួតពិនិត្យមើលដោយអ្នកជំនាញពាក់ព័ន្ធ (ដូចជា ក្រុមបច្ចេកទេសរបស់អ្នកទិញ ឬ អ្នកជំនាញមកពីផ្នែកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ឬ ដៃគូរជំនាញផ្សេងទៀត)។ សមាជិកទាំងអស់ និងគណៈកម្មាការគ្រប់គ្រង គួរប្រាកដថា មធ្យោបាយនិងធាតុចូលដែលប្រើប្រាស់ (ដី គ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វល្អិត និងប្រព័ន្ធស្រោចស្រព...) គឺត្រឹមត្រូវតាមស្តង់ដារដែលបានកំណត់នៅក្នុងកិច្ចសន្យា។

[79] ការគាំទ្រទាន់ពេលវេលាក្នុងពេលផលិត គឺជាការសំខាន់ ប៉ុន្តែគួរផ្តល់យោបល់នៅតាមដំណាក់កាលនៃការផលិតផងដែរ។

## ៧.៣.២. ការតាមដានការអនុវត្តរបស់កសិករ

ប្រសិនបើការអនុលោមតាមអនុសាសន៍បច្ចេកទេសសម្រាប់វិធីសាស្ត្រ គឺជាកាតព្វកិច្ចនៅក្នុងកិច្ចសន្យា ដូច្នេះ ក្រោយពេលបញ្ចប់ការបណ្តុះបណ្តាល គួរមានផ្តល់សៀវភៅកត់ត្រាដល់សមាជិក ដើម្បីគេអាច (ឬត្រូវ) កត់ត្រាការអនុវត្តរបស់ពួកគេអំពីការអនុវត្ត ឬបច្ចេកទេសដែលបានអនុវត្ត និងធាតុចូលដែលបានប្រើ ដើម្បីបញ្ជាក់ថា គេអនុលោមតាមវិធីសាស្ត្រផលិតដែលបានឯកភាព។ សៀវភៅនេះ នឹងធ្វើជាភស្តុតាងដើម្បីបង្ហាញអ្នកទិញ ឬសវនករខាងក្រៅអំពីការអនុវត្តរបស់កសិករនៅក្នុងការផលិត។ ទន្ទឹមនេះ ឯកសារផ្សេងៗទៀត ក៏នឹងត្រូវធ្វើការពិនិត្យដោយសវនកម្មខាងក្រៅដែរ។

ក្រុមត្រួតពិនិត្យផ្ទៃក្នុង (ICS) គួរត្រូវបានបង្កើតឡើងដើម្បីផ្ទៀងផ្ទាត់ការអនុលោមតាមនៃសមាជិកម្នាក់ៗទៅតាមបទបញ្ជាផ្ទៃក្នុងដែលបានកំណត់ ឬស្តង់ដារដែលបានតម្រូវ។ ក្រុមត្រួតពិនិត្យផ្ទៃក្នុងក៏គួរតាមដាន យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ [80]៖ ពេលផលិត និងពេលប្រមូលផលទុក។ ក្រុម ICS ត្រូវជ្រើសរើសចេញមកពីគណៈកម្មការគ្រប់គ្រងអង្គការកសិករ ឬមកពីសមាជិកសកម្ម។ សៀវភៅកត់ត្រារបស់សមាជិកម្នាក់ៗ គឺជាឯកសារទីមួយដែលត្រូវត្រួតពិនិត្យ មុនពេលពិនិត្យមើលព័ត៌មានបន្ថែម។ ក្រុម ICS ត្រូវមកទីតាំងផលិតរបស់សមាជិកទាំងអស់។ ពួកគេសង្កេតមើល និងសួរសំនួរបន្ថែមទៅសមាជិកម្នាក់ៗនៅក្នុងទីវាល ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន ដែលសមាជិកផ្សេងបានសរសេរនៅក្នុងសៀវភៅ និងដើម្បីមកប្រមូលព័ត៌មានដែលខ្វះ។

ប្រសិនបើការអនុវត្តតាមទម្លាប់ខ្លះត្រូវបានហាមដាច់ខាតនៅក្នុងកិច្ចសន្យា (ដូចជាហាមប្រើថ្នាំសត្វល្អិតជាក់លាក់ណាមួយ) ក្រុម ICS គួរដាក់វិន័យម៉ឺងម៉ាត់ដល់សមាជិកណាដែលមិនអនុវត្តតាម។ គេគួរត្រូវដកចេញពីក្រុមកិច្ចសន្យា ប្រសិនបើមិនគោរពតាមបទបញ្ជាផ្ទៃក្នុង ឬស្តង់ដារដែលបានកំណត់ ហើយត្រូវរាយការណ៍ទៅអ្នកទិញអំពីបញ្ជីឈ្មោះសមាជិកថ្មីដែលអនុញ្ញាតឲ្យផលិត។

ក្នុងករណីសមាជិកត្រូវការការគាំទ្របន្ថែមដើម្បីកែលម្អការផលិត ក្រុម ICS គួរអាចផ្តល់យោបល់ក្នុងពេលចុះត្រួតពិនិត្យ។ ព័ត៌មានដែលខ្វះ នៅក្នុងសៀវភៅកត់ត្រារបស់កសិករ នឹងត្រូវបំពេញបន្ថែមដោយក្រុម ICS ។ ដូច្នេះ កសិករមានគ្រប់ព័ត៌មាននៅលើសៀវភៅ។ ក្នុងពេលចុះត្រួតពិនិត្យ ក្រុម ICS នឹងរកមើលឧបសគ្គដែលសមាជិកអាចនឹងជួបប្រទះ នៅពេលក្រោយ ដូចជា គុណភាពដី ប្រព័ន្ធស្រោចស្រព កម្លាំងពលកម្ម លំហូរសាច់ប្រាក់ ...។ ក្រុម ICS នឹងពិភាក្សាជាមួយគណៈកម្មការគ្រប់គ្រងអង្គការកសិករដើម្បីរកវិធីសមរម្យ ដើម្បីគាំទ្រសមាជិកដោះស្រាយបញ្ហាទាំងនោះ។

[80] អាស្រ័យលើប្រភេទនៃការផលិត និងលក្ខខណ្ឌបច្ចេកទេស។

## ៧.៣.៣. ការគ្រប់គ្រងក្នុងពេលផលិត / ពេលប្រមូលផល

មុនពេលប្រមូលផល ប្រសិនបើចាំបាច់[81] ការបណ្តុះបណ្តាលស្តីពីបច្ចេកទេសប្រមូលផល និងថៃទាំក្រោយពេលប្រមូលផល គួរផ្តល់ដល់សមាជិក។ កសិករនឹងត្រៀមឧបករណ៍ចាំបាច់ និងមធ្យោបាយដើម្បីកែលម្អគុណភាពនៃផលិតផលដើម្បីទទួលបានតម្លៃល្អ។ ក្នុងករណីខ្លះ គណៈកម្មការគ្រប់គ្រងអង្គការកសិករ គួរសម្របសម្រួល និងផ្តល់ការគាំទ្រដល់សមាជិកដើម្បីទទួលបានមធ្យោបាយបន្ថែមសម្រាប់កែលម្អគុណភាពផលិតផល៖ ម៉ាស៊ីនប្រមូលផល រថយន្តដឹក ម៉ាស៊ីនសម្ងួត និងកន្លែងស្តុក។

**អ្នកដឹកនាំអង្គការកសិករ និងក្រុម ICS គួរទទួលបានការគាំទ្រពីអ្នកជំនាញអំពីការវាយតម្លៃ គុណភាពមុនពេលប្រមូលផល/មុនពេលប្រមូលផលិតផល ។ ពួកគេគួរដឹងច្បាស់អំពីគុណភាពផ្សេងៗនៃផលិតផលដើម្បីធានាថា អង្គការកសិករទូទាត់ថ្លៃត្រឹមត្រូវទៅសមាជិក ដើម្បីមិនខាតបង់ប្រាក់ដោយសារការធ្វើចំណាត់ថ្នាក់គុណភាពខុសលើផលិតផលដែលសមាជិកបានប្រគល់មកឲ្យ។**

ដូច្នេះ អង្គការកសិករត្រូវរៀបចំក្រុមដើម្បីគ្រប់គ្រង និងប៉ាន់ប្រមាណលើគុណភាពផលិតផល ដើម្បីប្រៀបធៀបជាមួយនឹងការប៉ាន់ប្រមាណរបស់អ្នកទិញ។

គុណភាពផ្សេងៗគ្នាដែលបានកំណត់ដោយសមាជិកអង្គការកសិករ និងដោយអ្នកទិញ គួរតែដូចគ្នា។ វិធីសាស្ត្រនៃការប៉ាន់ប្រមាណគុណភាពគួរតែអនុម័តដោយអ្នកទិញ។

អ្នកទិញគួរបណ្តុះបណ្តាលអ្នកដឹកនាំអង្គការកសិករអំពីរបៀបប៉ាន់ប្រមាណគុណភាព ដើម្បីគេអនុវត្តតាមរបៀបដូចគ្នាជាមួយនឹងអ្នកទិញដែរ។



*បណ្តុះបណ្តាលពីការពិនិត្យគុណភាពដោយអ្នកទិញ ▷ ករណីកិច្ចសន្យាផលិតអង្ករសរីរាង្គរបស់ AMRU rice និងសហករនៅខេត្តព្រះវិហារ (រូបថត៖ SCCRP)*

អាស្រ័យលើស្ថានភាពក្នុងមូលដ្ឋាន (ភស្តុភារនិងពេលវេលាដែលមាន) អ្នកដឹកនាំអង្គការកសិករអាចសម្រេច ៖

១. ធ្វើការប៉ាន់ប្រមាណជាមុនអំពីគុណភាពផលិតផលដល់សមាជិកនៅផ្ទះ ឬកន្លែងស្តុក មុនដឹកទៅដល់ចំណុចប្រគល់សម្រាប់លក់។

២. ឬ ពិនិត្យគុណភាពតែនៅចំណុចប្រគល់។

[81] ដូចជារបៀបប្រមូលផល ទុកដាក់ក្រោយប្រមូល ដើម្បីរក្សាគុណភាពល្អ។ នេះគឺសំខាន់ណាស់សម្រាប់ស្រូវ ឬផ្លែឈើស្រស់។ វាអាចមិនសូវចាំបាច់ទេ ក្នុងករណីផលិតកម្មសត្វ (ដូចជាចិញ្ចឹមមាន់) ព្រោះគេប្រគល់នៅរស់។

ប្រសិនបើផលិតផលគឺងាយខូច អ្នកដឹកនាំអង្គការកសិករ មិនមានពេលចុះជួបសមាជិកច្រើនដងទេ (ដែលអាចនៅឆ្ងាយពីគ្នា) ដូច្នេះគួរពិនិត្យតែនៅចំណុចប្រគល់ (ជម្រើស ២) មានន័យថា បើមានផលិតផលខូច ត្រូវយកមកផ្ទះវិញដោយអ្នកផលិតផ្ទាល់ក៏ដោយ។

បើអាចធ្វើបាន (សម្រាប់ករណីផលិតផលស្ងួត ដែលអាចរក្សាទុកបានយូរ ដោយមិនធ្លាក់ថ្លៃ) ជម្រើស ១ អាចល្អជាង។ ដូច្នេះ ប្រសិនបើផលិតផលមិនឆ្លើយតបនឹងគុណភាពទេ អង្គការកសិករអាចជូនដំណឹងទៅសមាជិកថាមិនចាំបាច់ចំណាយពេល និងថ្លៃដឹកជញ្ជូនទៅកន្លែងប្រមូលផ្តុំលក់ ដោយឥតប្រយោជន៍ទេ (ហើយត្រូវចំណាយដឹកយកមកផ្ទះវិញទៀតផង)។ សមាជិកមិនចាំបាច់ខាតពេលនិងលុយក្នុងការដឹកទេ។

ករណីការប៉ាន់ប្រមាណគុណភាពធ្វើដោយអ្នកដឹកនាំអង្គការកសិករ ហើយសមាជិកមិនព្រមទទួលយក នោះសមាជិកក្រុម ICS ផ្សេងទៀត និងឬអ្នកគ្រប់គ្រងមកពីខាងក្រៅ អាចចូលជួយពិនិត្យបន្ថែមនិងកាត់សេចក្តី។

លទ្ធផលនៃការវាយតម្លៃនឹងត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដោយភ្នាក់ងារ នៅចំណុចប្រគល់។ លទ្ធផលនៃការប៉ាន់ប្រមាណគុណភាពទាំងពីរលើក អាចត្រូវបានប្រៀបធៀបជាមួយគ្នា ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ និងមិនលម្អៀង។

## ៧.៤. បញ្ហាលំហូរសាច់ប្រាក់/ការពន្យារពេលទូទាត់ប្រាក់នៅក្នុងអង្គការកសិករ

កសិករតែងតែត្រូវការលុយជាបន្ទាន់ ក្រោយពីនាំផលិតផលរបស់គេមកលក់ឱ្យអង្គការកសិករ ឬ អ្នកទិញដើម្បីចំណាយភ្លាមៗ សម្រាប់ថ្លៃប្រមូលផល និងសងកម្ចីដែលគេបានចុះកិច្ចសន្យាដើម្បីទិញវត្ថុធាតុដើម និងថ្លៃផលិតកម្មផ្សេងៗទៀត ...។

ជួនកាលអ្នកទិញ យកប្រាក់មកទូទាត់នៅនឹងកន្លែងប្រមូលទិញ ហើយអ្នកផលិតដែលនាំផលិតផលគេមក ក៏ទទួលបានការទូទាត់ដោយផ្ទាល់នៅនឹងកន្លែងប្រមូល។ ប៉ុន្តែករណីនេះមិនសូវជាកើតមាននោះទេ។ វាអាស្រ័យលើអ្វីដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យា (ដូចដែលបង្ហាញនៅក្នុង ផ្នែកទី ៤.៩. ក្នុងសៀវភៅនេះ ពីរទំព័រ ៩០ ដល់ ៩៤ គួរតែបញ្ជាក់ឱ្យច្បាស់លាស់នូវគំរូ និងពេលវេលានៃការទូទាត់)។ ប្រសិនបើអ្នកទិញទូទាត់ប្រាក់ភ្លាមៗនៅនឹងកន្លែងប្រគល់ទំនិញ វាអាចនឹងមិនមានភាពពិបាកជាមួយនឹងការគ្រប់គ្រងចរន្តសាច់ប្រាក់សម្រាប់អង្គការកសិករឡើយ ។

ប៉ុន្តែជាញឹកញាប់ ជាពិសេសប្រសិនបើជាប់ពាក់ព័ន្ធនឹងចំនួនលុយជាក់លាក់ណាមួយ គេចូលចិត្តធ្វើការទូទាត់ដោយសែក ឬ ការផ្ទេរតាមធនាគារទៅកាន់គណនីធនាគាររបស់អង្គការកសិករ។ ហើយក្នុងករណីនោះ ការទូទាត់ពីអ្នកទិញទៅកាន់អង្គការកសិករ អាចធ្វើឡើងក្នុងរយៈពេលតែពីរបីថ្ងៃក្រោយពីប្រគល់ទំនិញ ហើយការពន្យាពេលទូទាត់ពីអង្គការកសិករទៅសមាជិករបស់គេ អាចយូរជាងនេះបន្តិច ។

ម្យ៉ាងវិញទៀតសម្រាប់កសិករវិញ ការដាក់សម្ពាធឱ្យទូទាត់សងប្រាក់កម្ចី ជួនកាលករណីនោះកើតឡើងទោះបីជាការព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាឱ្យតម្លៃថ្លៃជាងក៏ដោយ សមាជិកនៃអង្គការកសិករអាចចង់លក់ទៅឱ្យអ្នកទិញផ្សេងទៀតជាងដើម្បីបានទូទាត់ប្រាក់ភ្លាមៗដល់ដៃ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់អង្គការកសិករដើម្បីប្រគល់ទំនិញតាមបរិមាណដែលបានសន្យាក្នុងកិច្ចសន្យា ។

ប្រសិនបើមានការព្យាករណ៍ការពន្យាពេលទូទាត់ប្រាក់ពីអ្នកលក់ទៅអង្គការកសិករ ដំណោះស្រាយគួរតែត្រូវពិចារណាដើម្បីឱ្យអង្គការកសិករអាចមានលុយគ្រប់គ្រាន់នៅក្នុងដៃសម្រាប់បង់ឱ្យសមាជិករបស់ខ្លួនភ្លាមៗ ឬក្រោយពីប្រគល់ទំនិញភ្លាមៗ ។

**មានជម្រើសដែលអាចទៅរួចចំនួន៣ដើម្បីដោះស្រាយបញ្ហានេះ ៖**

១) អង្គការកសិករអាចចរចាយកប្រាក់ពីអ្នកលក់ជាមុន នៅមុនពេលចាប់ផ្តើមប្រមូលទំនិញ។ ចំនួននៃប្រាក់ដែលត្រូវយកមុននោះ គួរតែអនុម័តតាមតម្រូវការ (សូមមើលការពន្យល់បន្ថែម ៧.៤.ក. ខាងក្រោម)។ ជាមួយនឹងប្រាក់យកមុននេះ អង្គការកសិករអាចចំណាយឱ្យកសិករពេលប្រគល់ទំនិញ។ វិក្កយបត្រត្រូវបង្កើតដោយអង្គការកសិករ សម្រាប់បញ្ជាក់ពីបរិមាណ និងប្រាក់ដែលទូទាត់ពិតប្រាកដទៅឱ្យអង្គការកសិករទៅតាមថ្ងៃជាបន្តបន្ទាប់ ដែលអាចឱ្យអង្គការកសិករបង្វិលមូលធនដែលកំពុងប្រើប្រាស់នោះ បន្តចំណាយសម្រាប់ការប្រគល់ទំនិញឱ្យសមាជិកផ្សេងទៀត។ នៅពេលចប់រដូវកាលប្រមូលទំនិញ ប្រាក់ដែលយកមកប្រើជាមុននោះ ត្រូវបានទូទាត់ដោយការកាត់ចេញពីវិក្កយបត្រចុងក្រោយដែលត្រូវនឹងការប្រគល់ទំនិញចុងក្រោយ ។

២) អង្គការកសិករអាចចរចាជាមួយនឹងសមាជិករបស់ខ្លួនឱ្យពួកគេទទួលយកការពន្យាពេល រវាងការប្រគល់ទំនិញពីកសិករទៅឱ្យអង្គការកសិករ ហើយពន្យាការទូទាត់ថ្លៃទំនិញដែលបានប្រគល់នោះទៅឱ្យកសិករដើម្បីទុកពេលឱ្យអង្គការកសិករទទួលបានការទូទាត់ប្រាក់ពីអ្នកទិញជាមុនសិន។ ជាទូទៅការធ្វើបែបនេះអាចទទួលយកបាន លុះត្រាតែការពន្យាការទូទាត់នោះមានរយៈពេលខ្លី (ត្រឹមពីរបីថ្ងៃ) ហើយប្រសិនបើតម្លៃដែលទទួលបានពេលលក់ទៅឱ្យអង្គការកសិករនោះខ្ពស់គួរឱ្យកត់សម្គាល់ជាងតម្លៃដែលកសិករគួរទទួលបានពីការលក់ទៅឱ្យអ្នកទិញផ្សេងទៀត។ បើមិនដូច្នោះទេ ហានិភ័យរបស់ភាគីអ្នកលក់មានខ្ពស់ខ្លាំងណាស់ ។

៣) ជម្រើសទី៣ គឺសម្រាប់អង្គការកសិករចរចាដើម្បីបានកម្ចីរយៈពេលខ្លីសម្រាប់រដូវប្រមូលផល[82]។ ដូចនឹងជម្រើសទីមួយ កម្ចីមិនទាមទារតម្លៃពេញសម្រាប់ផលិតផលទាំងអស់ដែលបានប្រគល់ទៅឱ្យអ្នកទិញ ។ វាគ្រាន់តែអាចទូទាត់លំហូរសាច់ប្រាក់ដែលត្រូវការសម្រាប់បរិមាណដែលត្រូវទិញពីកសិករក្នុងរយៈពេលពន្យា រវាងការប្រគល់ទំនិញ និងអ្នកលក់ (សូមមើល ការពន្យល់បន្ថែម ៧.៤.ក ខាងក្រោម) ។

[82] ដោយការគាំទ្រពីគម្រោង អេសស៊ីស៊ីអភី (SCCRP) ធនាគារអភិវឌ្ឍន៍ជនបទ បានបង្កើតជាយន្តការផ្តល់ឥណទានសម្រាប់ សហគមន៍កសិកម្ម (ឬអង្គការកសិករដែលបានចុះបញ្ជីស្របច្បាប់ផ្សេងៗទៀត) ដែលគេអាចកៀងគរបានសម្រាប់វត្ថុបំណងនេះ ។

### ការពន្យល់បន្ថែម ៧.៤.ក. ការគណនាដើមទុនចាំបាច់សម្រាប់ទូទាត់ប្រាក់ទៅឲ្យកសិករនៅពេលប្រគល់ទំនិញ និងការទូទាត់របស់អ្នកទិញទៅឲ្យអង្គការកសិករ បន្ទាប់ពីការពន្យាពេលប៉ុន្មានថ្ងៃ

ក្នុងករណីដែលកសិករត្រូវការការទូទាត់ជាបន្ទាន់បន្ទាប់ពីលក់ផលិតផលទៅឱ្យអង្គការកសិករ ឬអ្នកលក់ អ្នកដឹកនាំអង្គការកសិករគួរតែមានព័ត៌មានគន្លឹះ៣យ៉ាងហោចណាស់៣នៅក្នុងដៃដើម្បីគណនាដើមទុនដែលត្រូវការសម្រាប់ចំណាយឱ្យសមាជិករបស់ខ្លួន គឺ តម្លៃឯកតាសម្រាប់បង់ឱ្យសមាជិករបស់ខ្លួន បរិមាណនៃទំនិញដែលសមាជិកខ្លួនអាចប្រគល់ឱ្យបាន (បរិមាណខ្ពស់បំផុតនៅពេលប្រគល់) និងការពន្យាពេលចន្លោះពីការប្រគល់ទំនិញ និងការទូទាត់ថ្លៃទំនិញដែលទទួលបានពីអ្នកលក់ ។

ផែនការប្រគល់ទំនិញច្បាស់លាស់គឺត្រូវការដើម្បីកំណត់នូវបរិមាណខ្ពស់បំផុតដែលអាចប្រគល់បាន ដូចជាបរិមាណអតិបរមាដែលអង្គការកសិករនឹងត្រូវបង់ឱ្យសមាជិកនៅក្នុងអំឡុងនៃការពន្យាពេលសម្រាប់ទូទាត់ អនុវត្តដោយអ្នកទិញ ។

ឧទាហរណ៍ ៖

អង្គការកសិករមួយប្រគល់ផលិតផលស្រស់នៅពេលប្រមូលផលទៅឱ្យអ្នកលក់ជាប្រចាំថ្ងៃ ។ ការទូទាត់ថ្លៃទំនិញដល់សមាជិក ត្រូវធ្វើនៅថ្ងៃប្រគល់ទំនិញ។ ប៉ុន្តែការទូទាត់ថ្លៃទំនិញដែលទទួលបានពីអ្នកទិញ **គឺនៅប្រាំថ្ងៃក្រោយ** ។

ដើម្បី ទូទាត់លំហូរសាច់ប្រាក់ដែលត្រូវការ អ្នកដឹកនាំអង្គការកសិករត្រូវមើលទៅផែនការនៃការប្រមូលផលហើយកំណត់នូវ **បរិមាណអតិបរមានៃផលិតផលដែលអាចប្រគល់ឱ្យបានក្នុង៥ថ្ងៃបន្តបន្ទាប់គ្នា** ។

| ផែនការប្រមូលផល | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| កាលបរិច្ឆេទ | 06 | 07 | 08 | 09 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 |
| បរិមាណ | 8 t | 10 t | 12 t | 12 t | 15 t | 18 t | 15 t | 13 t | 10 t | 10 t | 8 t | 8 t | 6 t |
| កើន៥ថ្ងៃ | 8 t | 18 t | 30 t | 42 t | 57 t | 67 t | 72 t | **73 t** | 71 t | 66 t | 56 t | 49 t | 42 t |

ក្នុងឧទាហរណ៍ខាងលើនេះ ការប្រគល់ទំនិញដែលកើនខ្ពស់បំផុតក្នុងរយៈពេល៥ថ្ងៃជាបន្តបន្ទាប់មាន ៧៣តោន ។ ដូច្នេះអង្គការកសិករត្រូវការដើមទុនសម្រាប់ចំណាយលើតម្លៃផលិតផល ៧៣ តោន ។

ដូច្នេះ លំហូរសាច់ប្រាក់ដែលត្រូវការ គឺ ២៨០ ដុល្លារ/តោន x ៧៣ តោន = ២០.៤៤០ ដុល្លារ ។

ជាមួយនឹងការយកលុយមកប្រើជាមុនក្នុងរយៈពេលខ្លី ឬកម្ចី ២០.៤៤០ ដុល្លារ អង្គការកសិករគួរតែអាចចាត់ចែងបញ្ហាលំហូរសាច់ប្រាក់នេះបាន សម្រាប់ការទូទាត់ឱ្យសមាជិករបស់ខ្លួន (ផ្តល់បានលុះត្រាតែគេគោរពតាមផែនការប្រមូលផល ហើយអ្នកទិញក៏ត្រូវគោរពតាមការព្រមព្រៀងការពន្យារយៈពេល៥ថ្ងៃដើម្បីទូទាត់!)

នៅក្នុងបរិបទកម្ពុជា អង្គការកសិករតែងតែមានដើមទុនមានកម្រិតសម្រាប់ធ្វើការងាររបស់គេ ។ ប្រសិនបើអង្គការកសិករមានដើមទុនផ្ទាល់ខ្លួនគ្រប់គ្រាន់ ហើយអាចផ្តល់វត្ថុជាទ្រព្យបញ្ចាំបាននោះ អង្គការកសិករអាចខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុ[83] ដោយរួមជាមួយមកនូវផែនការពាណិជ្ជកម្មសមរម្យមួយនិងឯកសារដែលពាក់ព័ន្ធទាំងអស់ដែលគ្រឹះស្ថានហិរញ្ញវត្ថុត្រូវការ ។

[83] ដូចជាធនាគារអភិវឌ្ឍន៍ជនបទដែលបានលើកឡើងខាង លើជាឧទាហរណ៍

ប៉ុន្តែការខ្ចីលុយនឹងបង្កើតឱ្យមានការចំណាយផ្នែកហិរញ្ញវត្ថុ (ការប្រាក់លើប្រាក់កម្ចី) ដូច្នេះ អង្គការកសិករគួរពិចារណាពីការចំណាយទាំងនោះ ហើយបញ្ចូលការចំណាយនេះក្នុងការគណនាវិសាលភាពរបស់វា។ អ្នកដឹកនាំអង្គការកសិករគួរប៉ាន់ប្រមាណលំហូរសាច់ប្រាក់ដែលត្រូវការប្រើឱ្យបានល្អ សម្រាប់បង់ឱ្យសមាជិករបស់ខ្លួនឱ្យទាន់ពេលវេលាក្រោយពេលប្រមូលទំនិញ ដើម្បីអាចទៅចរចាយកប្រាក់ពីអ្នកទិញមកប្រើមុនបាន ឬដើម្បីយកកម្ចីពីធនាគារ ឬពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប្រសិនបើក្រៅតែពីសមាជិកត្រូវការលុយជាបន្ទាន់ ហើយអ្នកផ្សេងអាចរង់ចាំបាននោះ ចំនួននៃសាច់ប្រាក់ដែលត្រូវការ គួរតែកែសម្រួលតាមជាក់ស្តែង ហើយអង្គការកសិករអាចសម្រេចថាតើខ្លួនអាចដោះស្រាយបានដោយប្រើដើមទុនផ្ទាល់ខ្លួនឬទេឬខ្លួនត្រូវការខ្ចីលុយពីអ្នកទិញ ឬពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

## ៧.៥. ការធានារ៉ាប់រងលើការចំណាយផ្ទាល់របស់អង្គការកសិករ

អ្នកដឹកនាំអង្គការកសិករគួរគិតគូរអំពីការចំណាយលើការចំណាយប្រតិបត្តិការរបស់ខ្លួននៅពេលចាប់ផ្តើមវិនិយោគសកម្មភាពថ្មី។ ចំពោះករណីផលិតកម្មកសិកម្មតាមកិច្ចសន្យា មានការចូលរួមច្រើនពីអ្នកដឹកនាំអង្គការកសិករនៅក្នុងអង្គការ និងការចរចាជាមួយអ្នកទិញ។ ពួកគេត្រូវធ្វើការទាក់ទង និងធ្វើដំណើរទៅចូលរួមប្រជុំជាមួយអ្នកទិញមួយចំនួនដើម្បីកំណត់រកអ្នកទិញដែលមានសក្តានុពល និងដើម្បីចរចាការព្រមព្រៀងគ្នាទៅលើផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ពួកគេត្រូវធ្វើការស្ទង់មតិសមាជិករបស់ខ្លួនផងដែរដើម្បីប៉ាន់ប្រមាណសមត្ថភាពនៃការផ្គត់ផ្គង់របស់អង្គការកសិករ។ នៅពេលកិច្ចសន្យាត្រូវបានចុះហត្ថលេខា អ្នកដឹកនាំត្រូវគាំទ្រដល់សមាជិកដើម្បីបំពេញការប្តេជ្ញាចិត្តដែលបានចុះហត្ថលេខាជាមួយអ្នកទិញ (+ អាចរ៉ាប់រងការចំណាយលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដើម្បីតាមដានការអនុវត្ត និងគុណភាពរបស់កសិករ ដូចមាននៅក្នុងចំណុច ៧.៣. ទំព័រ ១៥៣-១៥៦)។ នៅពេលប្រមូលផលិតផល ការគ្រប់គ្រងរបស់អង្គការកសិករ នឹងត្រូវគ្រប់គ្រងលើភស្តុភារនៃការប្រមូល និងរៀបចំដឹកជញ្ជូននៅកន្លែងប្រមូល ដែលទាមទារពេលវេលា និងការចំណាយផងដែរ។ ដូច្នេះអង្គការកសិករត្រូវមានថវិកាដើម្បីរ៉ាប់រងលើការចំណាយរាល់មុខងារទាំងនោះ។ ការចំណាយទាំងនេះគួរបានមកពីអត្ថប្រយោជន៍នៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលបានចុះហត្ថលេខាជាមួយអ្នកទិញ (ទាំងដោយផ្ទាល់៖ ប្រាក់ចំណេញពីការលក់ផលិតផល ឬ ដោយមិនផ្ទាល់៖ ថ្លៃសេវាកម្មដែលបានទូទាត់មកវិញដោយសមាជិកទៅឲ្យអង្គការកសិករ ឬ ដោយអ្នកទិញទៅឲ្យអង្គការកសិករ ដោយបន្ថែមលើតម្លៃផលិតផលដែលបានព្រមព្រៀងរួច)។

## ៧.៥.១. ការចំណាយដែលត្រូវរ៉ាប់រងនៅក្នុងអង្គការកសិករ/ក្រុមកសិករ/សហករណ៍

អ្នកដឹកនាំអង្គការកសិករគួរវិភាគឲ្យបានល្អអំពីការចំណាយនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលបានស្នើស ម្រាប់អ្នកផលិត ប៉ុន្តែក៏សម្រាប់អង្គការកសិករផ្ទាល់ផងដែរដែលដើរតួជាស្ថាប័នសេដ្ឋកិច្ច។ ខាងក្រោមនេះជាបញ្ជីលើការចំណាយដែលអាចកើតឡើងចំពោះផលិតកម្មកសិកម្មតាមកិច្ចសន្យានៅថ្នាក់អង្គការកសិករ។ វាជារឿងសំខាន់ដើម្បីប៉ាន់ប្រមាណការចំណាយទាំងនេះឲ្យបានលម្អិត និងព្យាយាមគិតអំពីថវិកាពេញលេញនៃការចំណាយនានាដែលអង្គការកសិករនឹងត្រូវរ៉ាប់រងលើ៖

- ការចំណាយលើការធ្វើដំណើរ ចំណាយប្រចាំថ្ងៃ និងការស្នាក់នៅ របស់អ្នកដឹកនាំអង្គការកសិករដើម្បីចូលរួមប្រជុំសម្រាប់ការចរចាកិច្ចសន្យាជាមួយអ្នកទិញ
- ការចំណាយលើអ្នកដឹកនាំដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានដល់សមាជិក និងគៀងគរសមាជិកចូលរួមប្រជុំផលិតកម្មកសិកម្មតាមកិច្ចសន្យា
- ការចំណាយលើអ្នកដឹកនាំដើម្បីធ្វើបញ្ជីតម្រូវការសម្រាប់ការផ្គត់ផ្គង់ធាតុចូល និងតាមដានការដឹកជញ្ជូនធាតុចូល ប្រសិនបើកិច្ចសន្យានេះមានដាក់បញ្ចូល
- ការចំណាយលើគ្រូបណ្តុះបណ្តាលពីអ្នកផ្តល់សេវាកម្មដើម្បីពង្រឹងការផលិត និងគុណភាព (ប្រសិនបើមិនរ៉ាប់រងដោយអ្នកទិញ)
- ការចំណាយលើឯកសារ ឧបករណ៍ បរិក្ខាដែលចាំបាច់ដើម្បីផ្តល់ជូនសមាជិក និងដើម្បីកត់ត្រាព័ត៌មាន
- ការចំណាយលើការប្រាស្រ័យទាក់ទងជាមួយអ្នកទិញ និងអ្នកផ្តល់សេវាកម្មដទៃទៀត
- ការចំណាយសម្រាប់អ្នកដឹកនាំរបស់អង្គការកសិករ ឬការគ្រប់គ្រងផ្ទៃក្នុងក្រុមដើម្បីតាមដានអំឡុងពេលផលិត និងការប្រមូលផល។
- ការចំណាយសម្រាប់អ្នកដឹកនាំអង្គការកសិករ និងសេវាកម្មដទៃទៀតដើម្បីត្រួតពិនិត្យគុណភាព រួចប្រមូលផលិតផល សម្ងួត និងអាចវេចខ្ចប់ ឬធានាការកែច្នៃ ការស្តុកទុកបណ្តោះអាសន្ន ការគ្រប់គ្រង និងការដឹកជញ្ជូនមួយចំនួនចំពោះកន្លែងប្រមូលដែលបានព្រមព្រៀងជាមួយអ្នកទិញ។
- ការចំណាយផ្នែកហិរញ្ញប្បទាន ប្រសិនបើសហគមន៍ត្រូវការយកប្រាក់កម្ចីដើម្បីរ៉ាប់រងលើតម្រូវការលំហូរសាច់ប្រាក់
- ការចំណាយរដ្ឋបាលសម្រាប់ឯកសារផ្សេងៗ (ឧទាហរណ៍ ប្រសិនបើការចុះហត្ថលេខាលើឯកសារនានារបស់អជ្ញាធរមូលដ្ឋានដែលតម្រូវឲ្យបង់ប្រាក់)

ករណីអង្គការកសិករបានចុះហត្ថលេខាកិច្ចសន្យាជាមួយអ្នកទិញដើម្បីផ្គត់ផ្គង់ផលិតផលជាមួយវិញ្ញាបនបត្របញ្ជាក់លក្ខខណ្ឌតម្រូវពីសវនករខាងក្រៅ (ផលិតផលសរីរាង្គ ផលិតផលពាណិជ្ជកម្មប្រកបដោយសមធម៌...) ការចំណាយផ្សេងៗបន្ថែមទៀតគួរត្រូវពិចារណាផងដែរ៖

- ការចំណាយលើក្រុមអ្នកត្រួតពិនិត្យខាងក្នុង (ICS) ដើម្បីត្រួតពិនិត្យពាក្យសុំរបស់សមាជិកចំពោះលក្ខខណ្ឌតម្រូវដែលបានកំណត់
- ការចំណាយលើវិញ្ញាបនបត្របញ្ជាក់របស់សវនករខាងក្រៅ (ប្រសិនបើមិនរ៉ាប់រងដោយផ្ទាល់ពីអ្នកទិញ)។

**ការពន្យល់បន្ថែម ៧.៥.ក. ឧទាហរណ៍នៃការធ្វើគម្រោងថវិកា (ចំណាយ និងចំណូល) របស់សហគមន៍សម្រាប់ការប្រមូល និងការលក់ស្រូវ**

ការប៉ាន់ប្រមាណលំហូរសាច់ប្រាក់សម្រាប់ AC* ក្នុងការទិញផលិតផល ២០ តោនសម្រាប់ដឹកជញ្ជូនមួយជើង

| **ការចំណាយលើប្រតិបត្តិការ** | | **តម្លៃមួយឯកតា ($)** |
|---|---|---|
| **ចំណាយថេរ** | | |
| **សេវាកម្មដែលផ្តល់ដោយអ្នកដឹកនាំសហករណ៍កសិកម្មនិងបុគ្គលិកបន្ថែម** | | |
| សេវាកកម្មរបស់អ្នកដឹកនាំសហករណ៍កសិកម្ម(សមាជិក ៨ នាក់) សម្រាប់ប្រមូលផលិត | ៨ | ២៥ |
| ផល ២០ តោន | ១ | ១ |
| គណនីករ(ម្នាក់) សម្រាប់ធ្វើការលើផលិតផល ២០ តោន | ២ | ៤ |
| ការប៉ាន់ប្រមាណគុណភាព និងលទ្ធកម្ម (ពីរនាក់)/២០ តោន | ម៉ោង | ៥០ |
| ពលករ (លើកដាក់ និងដកចេញ) សម្រាប់ការងារ ២០ តោន | | ២០ |
| ប៉ាន់ប្រមាណការចំណាយលើម្ហូបអាហារសម្រាប់បុគ្គលិក ចំពោះការងារ ២០ តោន | ខែ | ៧០ |
| អត្រាការប្រាក់ (១% ក្នុងមួយខែ) សម្រាប់កម្ចី ៧,០០០ ដុល្លារ សម្រាប់លំហូរសាច់ប្រាក់ | | ១៧៩ |
| **ការចំណាយថេរសរុប** | | |
| **ចំណាយបន្ថែម** | | |
| ប៉ាន់ប្រមាណការចំណាយលើការដឹកជញ្ជូន ផលិតផល ២០ តោនមួយជើងដល់អ្នកទិញ | ១ | ១១០ |
| ក្រដាស មូលប្បទានប័ត្រធនាគារ វិក្កយបត្រ បង្កាន់ដៃ (ប្រហែល) | | ៣.០០ |
| ការទូទាត់ឲ្យសមាជិកសម្រាប់ផលិតផល ២០ តោន (ឧ. តម្លៃជា ០.២៨៤ ដុល្លារ ក្នុងមួយគីឡូងក្រាម | | ៥,៦៨០.០០ |
| **ចំណាយបន្ថែមសរុប** | | **៥,៧៩៣.០០** |
| **ចំណាយសរុប** | | **៥,៩៧៧.០០** |
| **ចំណូលសរុបពីការលក់ផលិតផល ២០ តោនទៅអ្នកទិញ** | | |
| តម្លៃប៉ាន់ប្រមាណ ០.៣ ដុល្លារ ក្នុងមួយគីឡូក្រាម | | ៦,០០០.០០ |
| **ប្រាក់ចំណេញសុទ្ធរបស់សហករណ៍កសិកម្មសម្រាប់ផលិតផល ២០ តោន** | | **២៨.០០** |
| AC* សហគមន៍កសិកម្ម | | |

ការចំណាយផ្សេងៗបន្ថែមគួរត្រូវពិចារណាទៅតាមលក្ខណៈបច្ចេកទេសនៃកិច្ចសន្យាដែលបានចុះហត្ថលេខាជាមួយអ្នកទិញ។ អ្នកដឹកនាំអង្គការកសិករគួរគណនា និងបានវិភាគការចំណាយទាំងនេះដើម្បីប្រាកដ ថាប្រាក់ចំណូល (ប្រាក់ចំណេញសម្រាប់អង្គការកសិករ) ពីផលិតកម្មកសិកម្មតាមកិច្ចសន្យានេះ អាចយ៉ាងតិចក៏រ៉ាប់រងលើការចំណាយលើមុខងារ និងដោយសង្ឃឹមថានឹងមានការចំណេញខ្លះចំពោះអង្គការកសិករដើម្បីឲ្យមានការអភិវឌ្ឍអាជីវកម្មបន្ថែមទៀត។

### ៧.៥.២. ធនធានដើម្បីទូទាត់លើការចំណាយ

យើងបង្កើតវិធីសាស្ត្របី ដែលអាចទៅរួចខាងក្រោមសម្រាប់អង្គការកសិករដើម្បីទទួលបានប្រាក់ចំណូលសម្រាប់រ៉ាប់រងទៅលើការចំណាយដែលពួកគេត្រូវប្រឈមចំពោះការអនុវត្តកិច្ចសន្យា៖

- **ជម្រើសទី១ ៖ ប្រាក់ចំណេញពាណិជ្ជកម្មទៅលើការប្រមូល និងលក់ផលិតផល**
  ក្នុងករណីនេះតម្លៃដែលបានទូទាត់ដោយអង្គការកសិករទៅអ្នកផលិតគឺទាបជាងតម្លៃដែលរ៉ាប់រងដោយអង្គការកសិករបន្តិចពីអ្នកទិញ។ ភាពខុសគ្នានៃការបង្កើតប្រាក់ចំណេញក្នុងមួយឯកតា។ ប្រាក់ចំណេញក្នុងមួយឯកតានេះត្រូវគុណជាមួយបរិមាណសរុបនៃផលិតផលដែលបានលក់ ដោយកំណត់ជាប្រាក់ចំណេញដុលសរុប។ ប្រាក់ចំណេញដុលសរុបនេះគួររ៉ាប់រងយ៉ាងតិចលើការចំណាយដែលពាក់ព័ន្ធជាមួយអង្គការកសិករដើម្បីគ្រប់គ្រងសកម្មភាព។ ផ្អែកលើការប៉ាន់ប្រមាណនៃការចំណាយទាំងនេះ (សូមមើលចំណុច ៧.៥.១. ខាងលើ) និងផ្អែកលើបរិមាណនៃផលិតផលដែលបានរំពឹងទុកដើម្បីធ្វើការប្រមូល និងលក់ ហើយអ្នកដឹកនាំអង្គការកសិករគួរគណនាប្រាក់ចំណេញដែលពួកគេត្រូវការដើម្បីផ្គត់ផ្គង់ទៅលើផលិតផលដែលពួកគេប្រមូលពីសមាជិក និងលក់ទីឲ្យអ្នកទិញ។ មានការបង្ហាញបែបអភិវក្សបន្តិចទៅលើសម្មតិកម្មនៃបរិមាណដែលបានលក់៖ ប្រសិនបើកិច្ចសន្យាត្រូវធ្វើឡើងសម្រាប់បរិមាណ[84] តាមលំដាប់ (រវាង x តោន និង y តោន) នោះគេនឹងយកសម្មតិកម្មទាបបំផុតដើម្បីគណនាប្រាក់ចំណេញក្នុងមួយឯកតាដែលត្រូវយកមកអនុវត្តដោយអង្គការកសិករ។ ប្រសិនបើកិច្ចសន្យាធ្វើឡើងសម្រាប់បរិមាណថេរ ប៉ុន្តែមានហានិភ័យមួយដែលបរិមាណជាក់ស្តែងដែលបានផ្គត់ផ្គង់អាចទាប នោះត្រូវកាត់បន្ថយសម្មតិកម្មបរិមាណដែលបានលក់ផងដែរ។ ចុងក្រោយ ចាប់ពីពេលចាប់ផ្តើម (ទោះបីមុនពេលចុះហត្ថលេខាលើកិច្ចសន្យា) ប្រាក់ចំណេញរបស់អង្គការកសិករ និងតម្លៃដែលបានទទួលដោយអ្នកផលិត គួរមានការកំណត់ និងព្រមព្រៀងគ្នាឲ្យបានច្បាស់លាស់។
- **ជម្រើសទី ២ ៖ ប្រាក់កម្រៃជើងសារ/សេវាកម្មដែលបានបង់ដោយអ្នកទិញទៅអង្គការកសិករ** ចំពោះតម្លៃដែលបានចរចានៃផលិតផល៖

  អង្គការកសិករអាចចរចាជាមួយអ្នកទិញដើម្បីរ៉ាប់រងលើការចំណាយសេវាកម្មដែលបានផ្តល់ដោយអ្នកដឹកនាំពាក់ព័ន្ធនឹងការសម្របសម្រួល ការជួយសម្រួល ការប្រជុំជាមួយសមាជិក និងដើម្បីគ្រប់គ្រងការប្រមូលផលិតផលនៅកន្លែងប្រមូល។ ថ្លៃសេវាកម្មសម្រាប់អង្គការកសិករត្រូវធ្វើការពិភាក្សាជាមួយអ្នកទិញ និងមានការព្រមព្រៀងនៅអំឡុងពេលចរចាផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ថ្លៃសេវាកម្មអាចជាតម្លៃថេរ (មិនផ្អែកលើបរិមាណដែលបានដឹកជញ្ជូន) ឬអាចជាបរិមាណបន្ថែមក្នុងមួយឯកតានៃផលិតផលដែលបានដឹកជញ្ជូនទៅឲ្យអ្នកទិញ។ ថ្លៃសេវាកម្មរបស់អង្គការកសិករនឹងត្រូវទូទាត់ដោយផ្ទាល់ពីអ្នកទិញដល់អង្គការកសិករដោយយោងទៅតាមលក្ខខណ្ឌនៃការព្រមព្រៀងដែលបានចុះហត្ថលេខារួច។ ត្រូវចំណាំថា នេះជាចំណុចសំខាន់ដែលការទូទាត់ថ្លៃសេវាកម្មនេះ ត្រូវមានតម្លាភាព៖ សមាជិករបស់អង្គការកសិករត្រូវយល់ឲ្យបានច្បាស់លាស់នៅផ្នែកនេះចំពោះការព្រមព្រៀងនេះ (ដូច្នេះមិនចាត់ទុកថាពាក់ព័ន្ធនឹងកម្រៃជើងសារឡើយ) ហើយមានការបង្ហាញថាការទូទាត់គឺធ្វើឡើងចំពោះអង្គការកសិករជាស្ថាប័នស្របច្បាប់ (ដោយផ្ញើរទៅគណនីធនាគាររបស់អង្គការកសិករ) និងមិនត្រូវទូទាត់ជាមួយអ្នកដឹកនាំជាលក្ខណៈបុគ្គលឡើង។

---

[84] សូមមើលចំណុច ៤.៣.២ ទំព័រ ៦៥ ដល់ ៧០ នៅក្នុងសៀវភៅណែនាំនេះ។

- **ជម្រើសទី ៣ ៖ ថ្លៃសេវាកម្មដែលទូទាត់ដោយអ្នកផលិតនៅក្នុងគម្រោងផលិតកម្មកសិកម្មតាមកិច្ចសន្យាទៅឲ្យអង្គការកសិករ។**

  នៅជម្រើសចុងក្រោយ សមាជិកនីមួយៗដែលចូលរួមក្នុងផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបង់ថ្លៃសេវាកម្មទៅឲ្យអង្គការកសិករដើម្បីចូលរួមចំណែកការចំណាយដែលអង្គការកសិករត្រូវចំណាយលើប្រតិបត្តិការ។ ករណីនេះ ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងខសន្យាផ្ទៃក្នុងដែលបានធ្វើឡើងរវាងអង្គការកសិករ និងសមាជិករបស់ខ្លួន។

# ជីវប្រវត្តិ / ឯកសារយោងសំខាន់


Agronomes et Vétérinaires Sans Frontières (2014): " L'agriculture sous contrat peut-elle contribuer au renforcement des agricultures paysannes et à la souveraineté alimentaire des populations du Sud ?", Coordination Sud, série « Les Notes de la C2A – Agriculture et Alimentation en question » No 16, Paris (France), Mars 2014.

Agronomes et Vétérinaires Sans Frontières (២០១៤)៖ "តើស្ថិតក្នុងលក្ខខណ្ឌបែបណាដែលផលិតកម្មកសិកម្មតាមកិច្ចសន្យាមានភាពអនុគ្រោះដល់កសិករនៅក្នុងបណ្តាប្រទេសស្ថិតក្នុងតំបន់ភាគខាងត្បូង?" Coordination Sud /C២A, ទីក្រុងប៉ារីស (ប្រទេសបារាំង) ខែធ្នូ ឆ្នាំ ២០១៤។

Austermiller, Steven M. (២០១០)៖ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ប្រទេសកម្ពុជា សៀវភៅស្តីពីគោលគំនិតសំខាន់ៗ" គណៈមេធាវីអាមេរិកកាំង អង្គការ USAID ប្រទេសកម្ពុជា ឆ្នាំ ២០១០។
មាននៅលើអ៊ិនធឺណិត៖
http//www.americanbar.org/content/dam/aba/directories/roli/cambodia/cambodia_adr_book_english_01_19_09.authcheckdam.pdf

BNG legal Cambodia (២០០៦)៖ "មគ្គុទ្ទេសស្តីពីការធ្វើអាជីវកម្មនៅកម្ពុជា" BNG Legal ឆ្នាំ ២០១០-២០១៦ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ឆ្នាំ ២០០៦។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http://realestate.com.kh/wp-content/uploads/sites/8/2016/03/BNG-Guide-to-Doing-Business-in-Cambodia-2016-Update.pdf

Cai, Junning; Ung, Luyna and al. (២០០៨), "ផលិតកម្មកសិកម្មស្រូវអង្ករនៅកម្ពុជា៖ ការពង្រឹងភាពអង់អាចដល់កសិករឱ្យដើរហួសពីកិច្ចសន្យារហូតឈានទៅដល់ឯករាជ្យភាព" វិទ្យាស្ថានធនាគារអភិវឌ្ឍអាស៊ី ទីក្រុងតូក្យូ (ប្រទេសជប៉ុន) ឆ្នាំ ២០០៨។

មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖

http://www.fao.org/uploads/media/ADBI%20contract%20farming%20rice%20cambodia.pdf

Da Silva, Carlos Arthur B. (២០០៥), "ការកើនឡើងនូវតួនាទីរបស់ផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងការអភិវឌ្ឍប្រព័ន្ធចំណីអាហារកសិកម្ម៖ កត្តាអូសទាញ ទ្រឹស្តី និងការអនុវត្ត" អង្គការ FAO, ទីក្រុង Rome (ប្រទេសអ៊ីតាលី) ខែកក្កដា ឆ្នាំ ២០០៥។
លើអ៊ិនធឺណិត៖ http://www.fao.org/fileadmin/user_upload/ags/publications/AGSF_WD_9.pdf

Dani, Selvie (២០១៤)៖ "Étude sur les Pratiques de l'Agriculture Contractuelle pour la Culture du Riz au Cambodge", Gembloux Agro Bio Tech, Université de Liège, Gembloux (Belgium), ២០១៤.

Eaton, Charles and Andrew W. Shepherd (២០០១)៖ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា – ភាពជាដៃគូសម្រាប់ការជឿនលឿនទៅមុខ៖ មគ្គុទ្ទេស" អង្គការ FAO ព្រឹត្តិបត្រលេខ ១៤៥ ស្តីពីសេវាកសិកម្ម ទីក្រុងរ៉ូម (ប្រទេសអ៊ីតាលី) ឆ្នាំ ២០០១ ។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http://www.fao.org/docrep/014/y0937e/y0937e00.pdf

អង្គការ FAO (២០១២)៖ "គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលមានការទទួលខុសត្រូវ" ហេដ្ឋារចនាសម្ព័ន្ធតាមទីជនបទរបស់អង្គការ FAO និងការបែងចែកកសិឧស្សាហកម្ម ទីក្រុងរ៉ូម (ប្រទេសអ៊ីតាលី) ឆ្នាំ ២០១២។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http://www.fao.org/docrep/016/i2858e/i2858e.pdf

Fullbrook, David (២០១៤)៖ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ អ្វីដែលដំណើរការ & អ្វីដែលអាចដំណើរការបានប្រសើរជាង" នាយកដ្ឋានផ្សព្វផ្សាយវិស័យកសិកម្ម និងសហគមន៍កសិកម្ម (DAEC) គម្រោងផ្សព្វផ្សាយវិស័យកសិកម្មប្រទេសឡាវ (LEAP) ទីក្រុងវៀងច័ន្ទ (ប្រទេសឡាវ) ខែឧសភា ឆ្នាំ ២០១៤។

Goldberg, Jordan (២០១៤)៖ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅលើប្រព័ន្ធអ៊ីនធឺណិត និងមូលហេតុដែលសាលាច្បាប់ត្រូវរៀបចំមេធាវីថ្ងៃអនាគតសម្រាប់វេទិការនៅលើប្រព័ន្ធអ៊ីនធឺណិត" សារព័ត៌មានច្បាប់ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ Pepperdine ឆ្នាំ ២០១៤។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖

http៖//digitalcommons.pepperdine.edu/cgi/viewcontent.cgi?article=1261&context=drlj

Hor Peng, Kong Phallack, Menzel Jorg (២០១២)៖ "សេចក្តីណែនាំអំពីច្បាប់នៃប្រទេសកម្ពុជា" Konrad Adenauer Stiftung Cambodia រាជធានីភ្នំពេញ (ប្រទេសកម្ពុជា) ឆ្នាំ ២០១២។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖
http://www.kas.de/wf/doc/kas_31083-1522-2-30.pdf?120720080516

IFC (២០១៣), "ធ្វើការជាមួយកសិករខ្នាតតូច៖ សៀវភៅណែនាំសម្រាប់ក្រុមហ៊ុនធ្វើការបង្កើតខ្សែសង្វាក់ផ្គត់ផ្គង់ប្រកបដោយមាននិរន្តរភាព" សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ទីក្រុងវ៉ាស៊ិនតោន (សហរដ្ឋអាមេរិក) ខែកក្កដា ឆ្នាំ ២០១៣។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖
http://www.ifc.org/wps/wcm/connect/8dc5628042112fdbba2fff494779b2ad/ Handbook+-+Working+with+Smallholders.pdf?MOD=AJPERES

Minot, Nicholas and Ronchi Loraine (២០១៤)៖ "ផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ ហានិភ័យ និង អត្ថប្រយោជន៍សម្រាប់ភាពជាដៃគូរវាងកសិករ និងក្រុមហ៊ុន" ធនាគារពិភពលោក ទស្សនៈ កំណត់សម្គាល់ លេខ ៣៤៤ ទីក្រុងវ៉ាស៊ីនតោន (USA) ខែតុលា ឆ្នាំ ២០១៤។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖
https://www.wbginvestmentclimate.org/advisory-services/investment-generation/agribusiness/upload/VP_344-Contract-Farming.pdf

NAFES (២០១២)៖ "គោលការណ៍ណែនាំសម្រាប់ការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយស្មើភាព" សេវាផ្សព្វផ្សាយវិស័យកសិកម្ម និងព្រៃឈើថ្នាក់ជាតិ (NAFES) គម្រោងផ្សព្វផ្សាយវិស័យកសិកម្មប្រទេសឡាវ (LEAP) ទីក្រុងវៀងច័ន្ទ (ប្រទេសឡាវ) ខែមិថុនា ឆ្នាំ ២០១២។

Prowse, Martin (២០១២)៖ "ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងប្រទេសកំពុងអភិវឌ្ឍ៖ ការពិនិត្យឡើងវិញ" វិទ្យាស្ថានអភិវឌ្ឍគោលនយោបាយ និងការគ្រប់គ្រង សាកលវិទ្យាល័យ Antwerp, Agence Française de Développement (AFD), A Savoir No ១២, ទីក្រុងប៉ារីស (ប្រទេសបារាំង) ខែកុម្ភៈ ឆ្នាំ ២០១២។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖
៖//www.afd.fr/webdav/site/afd/shared/PUBLICATIONS/RECHERCHE/Scientifiques/A-http savoir/12-VA-A-Savoir.pdf

Rehber, E. (២០០៧), ផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ ទ្រឹស្តី និងការអនុវត្ត, ICFAI University Press, ទីក្រុង Hyderabad (ប្រទេសឥណ្ឌា)។

Sexton, Danièle (២០១៤)៖ "A quelles conditions l'agriculture contractuelle peut-elle favoriser les agricultures paysannes du Sud ? ", Coordination Sud, Paris (France), Décembre ២០១៤.
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ www.coordinationsud.org/wp-content/uploads/Rapport-agriculture-contractuelle.pdf

Sou, Sorphea and Tith Sideth (២០១៥)៖ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងក្រោមជាតិ" ស្ថាប័នសភានៃប្រទេសកម្ពុជា រាជធានីភ្នំពេញ (ប្រទេសកម្ពុជា) ឆ្នាំ ២០១៥។

TechnoServe and IFAD (២០១១)៖ "គម្រោង Outgrower៖ ការពង្រឹងគុណប្រយោជន៍" ការសង្ខេបបែបបច្ចេកទេស, IFAD, ទីក្រុងរ៉ូម (ប្រទេសអ៊ីតាលី) ខែកញ្ញា ឆ្នាំ ២០១១។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http៖//www.ifad.org/ruralfinance/pub/technoserve.pdf

Ton G. and van der Mheen-Sluijer J. (២០០៩)៖ "បញ្ជីតាមដានផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ ឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងបញ្ហាធ្ងន់ធ្ងរនៅក្នុងកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុង

ប្រទេសកំពុងអភិវឌ្ឍ”, EVD, ICCO, សាកលវិទ្យាល័យ Wageningen, ទីក្រុង Wageningen (ប្រទេសហូឡង់)។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http://library.wur.nl/WebQuery/wurpubs/378589

UNIDROIT, FAO និង IFAD (២០១៥)៖ “មគ្គុទ្ទេសច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា”, UNIDROIT/FAO/IFAD, ទីក្រុងរ៉ូម (ប្រទេសអ៊ីតាលី) ឆ្នាំ ២០១៥។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http://www.fao.org/3/a-i4756e.pdf

Will, Margret (២០១៣)៖ “សៀវភៅណែនាំស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា៖ មគ្គុទ្ទេសណែនាំសម្រាប់ការភ្ជាប់បណ្តាញអ្នកផលិត និងអ្នកទិញតាមរយៈការកែប្រែម៉ូឌែលអាជីវកម្ម”, Deutsche Gesellsschaft für Internationale Zusammenarbeit (GIZ) GmbH (ប្រទេសអាល្លឺម៉ង់) ខែមិថុនា ឆ្នាំ ២០១៣។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖ http://www.giz.de/fachexpertise/downloads/giz2013-en-handbook-contract-farming-manual-low-resolution.pdf

Yi Prasnar (Association Henri Capitant Cambodia) (២០១៤)៖ “ទិដ្ឋភាពច្បាប់នៃផលិតកម្មកសិកម្មតាមកិច្ចសន្យា” សិក្ខាសាលាស្តីពីការពិគ្រោះយោបល់ UNIDROIT / មគ្គុទ្ទេសច្បាប់របស់អង្គការ FAO ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ទីក្រុងបាំងកក (ប្រទេសថៃ) ឆ្នាំ ២០១៤។
មាននៅលើប្រព័ន្ធអ៊ិនធឺណិត៖
http://www.henricapitant-cambodia.org/wp-content/uploads/2014/09/AHCC-Prasnar-Yi-Overview-of-the-Legal-framework-of-contract-farming-in-Cambodia-2014-09-26-FINAL.pdf

Yrigoyen Fajardo Raquel Z., Kong Rady, Phan Sin (២០០៥)៖ “Sin ច្រកផ្លូវទៅកាន់យុត្តិធម៌៖ ការទទួលបានយុត្តិធម៌ដោយផ្តោតលើជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច” ក្រសួងយុត្តិធម៌ រាជធានីភ្នំពេញ (ប្រទេសកម្ពុជា) ឆ្នាំ ២០០៥។

# សន្ទស្សន៍



| ចំណងជើងសំខាន់ៗ | ផ្នែក/ទំព័រពាក់ព័ន្ធ |
|---|---|
| ការប្រមូលផលិតផល | ផ្នែក ៤.៨. / ផ្នែក ៥.២. |
| ការដោះស្រាយវិវាទ | ផ្នែក ៤.១៣ / ជំពូកទី ៦ ទាំងអស់ |
| ទំនាក់ទំនងជាមួយ នាយកដ្ឋានកសិ-ឧស្សាហកម្ម | |
| ការបង្កើតកិច្ចសន្យា | ជំពូកទី ៤ / ឧបសម្ព័ន្ធ ៤ |
| អង្គការកសិករ | ជំពូកទី ៧ ទាំងអស់ |
| ការគាំទ្រពីរដ្ឋាភិបាល | ផ្នែក ២.៣.២. / ផ្នែក ៣.១.១. |
| សាវតាច្បាប់ | ផ្នែក ២.២. / ផ្នែក ៤.១៤.១. |
| ការតាមដានការអនុវត្ត | ជំពូកទី ៥ ទាំងអស់ |
| ហានិភ័យធម្មជាតិ | ផ្នែក ៤.១០. |
| មិនបានអនុវត្ត | ផ្នែក ៤.១០ / ផ្នែក ៤.១២. |
| ការទូទាត់ និងលំហូរសាច់ប្រាក់ | ផ្នែក ៤.៩. / ផ្នែក ៥.២.៥. / ផ្នែក ៧.៤. |
| តម្លៃ | ផ្នែក ៤.៧. |
| គុណភាព | ផ្នែក ៤.៤. / ផ្នែក ៥.២.៣. / ផ្នែក ៧.៣. |
| ការចុះឈ្មោះកិច្ចសន្យា | ផ្នែក ៣.៣. |
| ការជ្រើសរើសដៃគូ | ផ្នែក ៣.២. |
| ប្រភេទនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា | ផ្នែក ១.១.២. |

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១៖ អនុក្រឹត្យលេខ ៣៦ អនក្រស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា..................
ឧបសម្ព័ន្ធ ២៖ សារាចរណែនាំលេខ១៩៦ សរណន.កសក ស្តីអំពី នីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា..........................................................................
ឧបសម្ព័ន្ធ ៣៖ សេចក្តីសម្រេចលេខ៧៨ សសរ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការស្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា.........................................
ឧបសម្ព័ន្ធ ៤៖ សេចក្តីសម្រេចលេខ៥៦០ សសរ.កសក ស្តីអំពី ការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការស្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា..................................
ឧបសម្ព័ន្ធ៥៖ ទម្រង់ពាក្យស្នើសុំសម្រាប់អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មសម្រាប់ នាយកដ្ឋានកសិ-ឧស្សាហកម្ម.........................................................................................
ឧបសម្ព័ន្ធ ៦៖ ទម្រង់ពាក្យស្នើសុំសម្រាប់អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មសម្រាប់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត......................................................
ឧបសម្ព័ន្ធ៧៖ ទម្រង់កិច្ចសន្យាគំរូនៃកិច្ចសន្យាផលិតកម្មកសិកម្ម.................................
ឧបសម្ព័ន្ធ៨៖ ឧទាហរណ៍នៃកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់ស្រូវសរីរាង្គ
..............................................................................................................

## ឧបសម្ព័ន្ធ ១៖ អនុក្រឹត្យលេខ ៣៦ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៦. អនក្រ. បក

**អនុក្រឹត្យ**

**ស្តីពី**

**ផលិតកម្មកសិកម្មតាមកិច្ចសន្យា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជីវសុវត្ថិភាព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង បង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គ-នាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឲ្យទៅជាអគ្គ-នាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១

១/៥

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ អំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ ៖

-ពង្រឹងការទទួលខុសត្រូវ និងភាពជឿទុកចិត្តគ្នា រវាងភាគីអ្នកផលិត និងភាគីអ្នកទិញ ដោយឈរលើគោលការណ៍ស្មើភាព និងយុត្តិធម៌

-ធានាឲ្យមានភាពច្បាស់លាស់អំពីតម្លៃ ការប្រមូលទិញ និងការផ្គត់ផ្គង់ផលិតផលកសិកម្ម តាមបរិមាណនិងគុណភាព

-បង្កើនការប្រមូលទិញ ការកែច្នៃ និងការនាំចេញផលិតផលកសិកម្ម

-រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត លើអាជីវកម្មផលិតកម្មកសិកម្មតាមកិច្ចសន្យាគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ៖

**ផលិតកម្មកសិកម្មតាមកិច្ចសន្យា** សំដៅដល់ផលិតកម្មកសិកម្ម ដោយមានការធានាអំពីតម្លៃ បរិមាណ និងគុណភាពផលិតផល ព្រមទាំងលក្ខខណ្ឌផ្សេងៗទៀត ដែលមានការព្រមព្រៀងគ្នាមុនការផលិត។

**កិច្ចសន្យាផលិតកម្មកសិកម្ម** សំដៅដល់ការព្រមព្រៀង លើអាជីវកម្មផលិតកម្មកសិកម្ម ដែលបានធ្វើឡើងរវាងភាគីពីរ ឬច្រើន ដើម្បីដាក់ឲ្យប្រតិបត្តិតាមផ្លូវច្បាប់ ហើយត្រូវមានចែងពីលក្ខខណ្ឌតម្រូវនានាជាមុន។

**អាជីវកម្មផលិតកម្មកសិកម្ម** សំដៅដល់មុខរបរផលិត លក់ ទិញ ផលិតផលកសិកម្ម ៖

-ការដាំដុះដំណាំគ្រប់ប្រភេទ

-កោសេយ្យវប្បកម្ម រុក្ខវប្បកម្ម វារីវប្បកម្ម បសុវប្បកម្ម

-ការផលិតពូជដំណាំ ពូជសត្វ ពូជវារិជាតិ និងពូជរុក្ខជាតិ

-ការកែច្នៃផលិតផលកសិកម្ម

-ការប្រមូលទិញ ផលិតផលកសិកម្មតាមកិច្ចសន្យា សម្រាប់ផ្គត់ផ្គង់ទីផ្សារ រោងចក្រកែច្នៃ ឬការនាំចេញ។

**ភាគីអ្នកផលិត** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានមុខរបរក្នុងផលិតកម្មកសិកម្ម។

**ភាគីអ្នកទិញ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើអាជីវកម្មទិញផលិតផលកសិកម្ម ស្របតាមនីតិវិធីនៃច្បាប់ជាធរមាន។

**សហគមន៍កសិកម្ម** សំដៅដល់សហគមន៍អភិវឌ្ឍកសិកម្ម សហភាពសហគមន៍អភិវឌ្ឍកសិកម្ម និងបុរេសហគមន៍អភិវឌ្ឍកសិកម្ម។

៧៩

## ជំពូកទី២
## ស្ថាប័ន និងយន្តការសម្របសម្រួល

**មាត្រា ៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័ននាំមុខក្នុងការទាក់ទង សម្របសម្រួល និងផ្ដល់សេវាជំនាញតាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីបង្កភាពងាយស្រួល ដល់ការអភិវឌ្ឍផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការតាមដាន វាយតម្លៃការងារទាំងនេះ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

**មាត្រា ៦.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តតួនាទីដូចខាងក្រោម ៖

-តភ្ជាប់ទំនាក់ទំនងរវាងអ្នកវិនិយោគទុន និងកសិករ ផលិតករ អ្នកកែច្នៃ ក្នុងក្របខណ្ឌនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

-ពង្រឹង ជំរុញ និងលើកទឹកចិត្តដល់ការបង្កើតសមាគម សហគមន៍កសិកម្ម ឬអង្គការកសិករនានាដែលជាមូលដ្ឋាន សម្រាប់ការអភិវឌ្ឍផលិតកម្មកសិកម្មតាមកិច្ចសន្យា

-លើកកម្ពស់ស្តង់ដារ ចំណាត់ថ្នាក់ និងគុណភាពផលិតផលកសិកម្ម ឲ្យស្របតាមតម្រូវការទីផ្សារ និងនិយាមអន្តរជាតិ

-ចូលរួមសម្រុះសម្រួលក្នុងការដោះស្រាយទំនាស់ និងបញ្ហាផ្សេងៗក្នុងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ដោយឈរលើមូលដ្ឋានច្បាប់ជាធរមាន

-បង្កភាពងាយស្រួលក្នុងការទទួលបានសិទ្ធិស្របច្បាប់ លើដីធ្លីតាមច្បាប់ជាធរមាន សម្រាប់ភាគីអ្នកផលិត កសិករ ក្នុងការធ្វើកសិធុរកិច្ច និងកសិឧស្សាហកម្ម

-បង្កភាពងាយស្រួល ក្នុងការទទួលបានសេវាគាំទ្របច្ចេកទេស ពូជដំណាំ ពូជវារីជាតិ ពូជរុក្ខជាតិ ពូជសត្វល្អៗ មធ្យោបាយផលិតកម្មផ្សេងៗ ជី ថ្នាំកសិកម្មប្រកបដោយគុណភាពខ្ពស់

-លើកកម្ពស់ការធ្វើប្រពលវប្បកម្ម ពិពិធកម្មកសិកម្ម និងការប្រកួតប្រជែងដើម្បីឆ្លើយតបនូវតម្រូវការទីផ្សារក្នុងស្រុក និងការនាំចេញ

-បង្កភាពងាយស្រួលដល់ការធ្វើកសិធុរកិច្ច កសិឧស្សាហកម្ម និងការនាំចេញ

-ពង្រឹង ពង្រីកសមត្ថភាព ក្នុងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ។

**មាត្រា ៧.-**

ត្រូវបានបង្កើតយន្តការមួយដែលមានឈ្មោះហៅថា គណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាសភាពនៃគណៈកម្មាធិការនេះមានដូចខាងក្រោម ៖

១. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន

២. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប អនុប្រធាន

៣. រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ០១ រូប សមាជិក

៧៥

| | | |
|---|---|---|
| ៤. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ០១ រូប | សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | ០១ រូប | សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១ រូប | សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១ រូប | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១ រូប | សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១ រូប | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១ រូប | សមាជិក |
| ១៣. អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា | | សមាជិក |
| ១៤. អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| ១៥. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ១៦. អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ | | សមាជិក |
| ១៧. ប្រធានសភាពាណិជ្ជកម្មកម្ពុជា | | សមាជិក |
| ១៨. តំណាងសភាមុខរបរ និងមីក្រូសហគ្រាស | | សមាជិក។ |

គណៈកម្មាធិការនេះមានភារកិច្ច ៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ដើម្បីលើកស្ទួយផលិតកម្មកសិកម្មតាមកិច្ចសន្យា
- សម្របសម្រួល និងពង្រឹងនូវសុខដុមនីយកម្មរវាងភាគីនៃកិច្ចសន្យាផលិតកម្មកសិកម្ម
- ធ្វើអន្តរាគមន៍ ឬ សម្រុះសម្រួលការខ្វែងគំនិត ឬ ទំនាស់ដែលអាចលេចចេញពីកិច្ចសន្យាផលិតកម្មកសិកម្ម ដែលស្ថាប័នជំនាញពុំអាចដោះស្រាយបាន ឬ ទំនាស់ដែលមានលក្ខណៈ តម្រូវឲ្យមានការដោះស្រាយអន្តរស្ថាប័ន។

គណៈកម្មាធិការនេះមាន នាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាជំនួយការ ។

## ជំពូកទី៣
## សិទ្ធិនិងការពព្វកិច្ចរបស់ភាគីអ្នកផលិត និងភាគីអ្នកទិញ

**មាត្រា ៨.-**

ភាគីអ្នកផលិត មានសិទ្ធិនិងកាតព្វកិច្ច ៖

-គោរពតាមលក្ខខណ្ឌផលិតកម្មកសិកម្ម ស្របតាមការព្រមព្រៀង

-ដំណើរការផលិតកម្មកសិកម្ម ស្របតាមរដូវកាល និងពេលវេលាកំណត់

-អនុវត្តបច្ចេកវិទ្យា និងវិធីសាស្ត្រផលិត ស្របតាមតម្រូវការរបស់ភាគីអ្នកទិញ

-ផ្គត់ផ្គង់ផលិតផលស្របតាម ចំណាត់ថ្នាក់ គុណភាព បរិមាណ និងពេលវេលាកំណត់

-ទទួលយកការទូទាត់តម្លៃផលិតផល ស្របតាមតម្លៃដែលបានព្រមព្រៀង។

**មាត្រា ៩.-**

ភាគីអ្នកទិញ មានសិទ្ធិនិងកាតព្វកិច្ច ៖

-គោរពតាមលក្ខខណ្ឌផលិតកម្មកសិកម្ម ស្របតាមការព្រមព្រៀង

៤៩

-កំណត់យថាប្រភេទទំនិញ បរិមាណ គុណភាព ទីកន្លែង និងកាលបរិច្ឆេទនៃការប្រគល់ទទួល
-ផ្តល់សម្ភារកសិកម្ម ពូជរុក្ខជាតិ ពូជដំណាំ ពូជវារីជាតិ ពូជសត្វ ឥណទានជាមុន សេវាបច្ចេកទេស និងមធ្យោបាយ ឬជំនួយផ្សេងៗទៀត ដល់ភាគីអ្នកផលិតតាមការព្រមព្រៀង ដើម្បីធានាដល់ដំណើរការ និងទទួលបានលទ្ធផលល្អ
-ទូទាត់តម្លៃផលិតផលកសិកម្ម តាមឯកតាច្បាស់លាស់ និងគុណភាពតាមតម្លៃដែលបានព្រមព្រៀង
-ទូទាត់តម្លៃទំនិញជូនភាគីអ្នកផលិតតាមលក្ខខណ្ឌ និងតាមដំណាក់កាលពេលវេលាកំណត់តាមការព្រមព្រៀង។

## ជំពូកទី៤
## ទម្រង់និងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម

**មាត្រា ១០.-**

កិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ក្រោមការសម្របសម្រួលតាមរយៈយន្តការដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ។

កិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ១១.-**

នៅពេលមានវិវាទទាក់ទងនឹងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ភាគីអ្នកផលិត និងភាគីអ្នកទិញ ត្រូវដោះស្រាយតាមការសម្រុះសម្រួលគ្នាជាមុន ផ្អែកតាមលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យា។

ក្នុងករណីមិនអាចដោះស្រាយបាន ភាគីវិវាទអាចអនុវត្តតាមរយៈយន្តការ ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ជ/ថ

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ២៖ ទម្រង់ពាក្យសុំសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់នាយកដ្ឋានកសិឧស្សាហកម្ម

ការបកប្រែក្រៅផ្លូវការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................. ភេទ.............. អាយុ............ឆ្នាំ សញ្ជាតិ........... ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ................ ក្រុមទី............ ភូមិ............ ឃុំ/សង្កាត់.................................... ស្រុក/ក្រុង/ខណ្ឌ....................................... ខេត្ត/រាជធានី។ ទូរស័ព្ទលេខ..........................ទូរសារ.......................អ៊ីម៉ែល..........................កាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ.......................................................................................... បច្ចុប្បន្នមានតួនាទីជា.............................................................................(ជាតំណាងអ្នកទិញ) ហៅកាត់ថាភាគីអ្នកទិញ។

**និង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................................. ភេទ.............. អាយុ............ឆ្នាំ សញ្ជាតិ........... ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ................ ក្រុមទី............ ភូមិ............ ឃុំ/សង្កាត់.................................... ស្រុក/ក្រុង/ខណ្ឌ....................................... ខេត្ត/រាជធានី។ ទូរស័ព្ទលេខ..........................ទូរសារ.......................អ៊ីម៉ែល..........................កាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ.......................................................................................... បច្ចុប្បន្នមានតួនាទីជា..........................................................................(ជាដំណាងអ្នកផលិត) ហៅកាត់ថាភាគីអ្នកផលិត។

**សូមគោរពជូន**
**លោកប្រធាននាយកដ្ឋានកសិឧស្សាហកម្ម**

**តាមរយៈ:** ៖ មន្ទីរកសិកម្មរាជធានីខេត្ត ....................................................................

**កម្មវត្ថុ** ៖ សំណើសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងការទិញលក់ផលិតផលកសិកម្ម ..............................................រវាង...................................................................................

និង.........................................................................................។

**ជូនភ្ជាប់** ៖ - ពង្រាងកិច្ចសន្យាចំនួន ........................................................................ ០១ច្បាប់

- តារាងបញ្ជីឈ្មោះសមាជិកក្រុមភាគីអ្នកផលិតដោយមានបញ្ជាក់ ទីតាំង ទំហំផ្ទៃដី ប្រភេទផលិតផល និងស្នាមមេដៃ (សម្រាប់ភាគីអ្នកផលិត) ចំនួន.................................................................... ០១ច្បាប់

- ថតចម្លង: អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនចំនួន ..................................០១ច្បាប់
- ប្រវត្តិរូបសង្ខេប អ្នកដំណាងភាគីទាំងពីរចំនួន...........................................០១ច្បាប់

សេចក្តីដូចមានចែងកម្មវត្ថុយោង និងជូនភ្ជាប់ខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោកប្រធានមេត្តាជ្រាបថា៖ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានេះគឺធ្វើឡើងរវាង.......................................................និង ....................................ដោយកំនត់យកទីតាំងអនុវត្តស្ថិតក្នុងភូមិ.......................ឃុំ.................. ស្រុក........................ខេត្ត.......................ក្នុងការទិញលក់ផលិតផលប្រភេទ................................ ទៅតាមបរិមាណ គុណភាព និងពេលវេលាកំណត់ដូចមានចែងក្នុងកិច្ចសន្យាដែលបានព្រមព្រៀងដោយភាគីទាំងពីរ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាអនុញ្ញាត និងគាំទ្រដល់ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានេះដោយក្តីអនុគ្រោះ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីរូបខ្ញុំ។

ធ្វើនៅ............ថ្ងៃទី...........ខែ...............ឆ្នាំ២០....

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ

តំណាងភាគីអ្នកទិញ តំណាងភាគីអ្នកផលិត

## ឧបសម្ព័ន្ធ៦៖ ទម្រង់ពាក្យសុំសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យាសម្រាប់មន្ទីរកសិកម្ម

ការបកប្រែក្រៅផ្លូវការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................................ ភេទ.............. អាយុ............ឆ្នាំ សញ្ជាតិ........... ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ................ ក្រុមទី............ ភូមិ............ ឃុំ/សង្កាត់.................................... ស្រុក/ក្រុង/ខណ្ឌ.................................... ខេត្ត/រាជធានី។ ទូរស័ព្ទលេខ..........................ទូរសារ......................អ៊ីម៉ែល..........................កាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ.................................................................................... បច្ចុប្បន្នមានតួនាទីជា..........................................................................(ជាតំណាងអ្នកទិញ) ហៅកាត់ថាភាគីអ្នកទិញ។

និង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................................ ភេទ.............. អាយុ............ឆ្នាំ សញ្ជាតិ........... ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ................ ក្រុមទី............ ភូមិ............ ឃុំ/សង្កាត់.................................... ស្រុក/ក្រុង/ខណ្ឌ.................................... ខេត្ត/រាជធានី។ ទូរស័ព្ទលេខ..........................ទូរសារ......................អ៊ីម៉ែល..........................កាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ.................................................................................... បច្ចុប្បន្នមានតួនាទីជា........................................................................(ជាដំណាងអ្នកផលិត) ហៅកាត់ថាភាគីអ្នកផលិត។

## សូមគោរពជូន
## លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**តាមរយៈ:** ៖ ការិយាល័យកសិ-ឧស្សាហកម្មរាជធានីខេត្ត..................................................

**កម្មវត្ថុ** ៖ សំណើសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាក្នុងការទិញលក់ផលិតផលកសិកម្ម ............................................រវាង.................................................................................... និង...........................................................................។

**ជូនភ្ជាប់** ៖ - ពង្រាងកិច្ចសន្យាចំនួន ............................................................. ០១ច្បាប់

- តារាងបញ្ជីឈ្មោះសមាជិកក្រុមភាគីអ្នកផលិតដោយមានបញ្ជាក់ ទីតាំង ទំហំផ្ទៃដី ប្រភេទផលិតផល និងស្នាមមេដៃ (សម្រាប់ភាគីអ្នកផលិត) ចំនួន.......................................................... ០១ច្បាប់

- ថតចម្លង: អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនចំនួន ..................................០១ច្បាប់
- ប្រវត្តិរូបសង្ខេប អ្នកដំណាងភាគីទាំងពីរចំនួន............................................០១ច្បាប់

សេចក្តីដូចមានចែងកម្មវត្ថុយោង និងជូនភ្ជាប់ខាងលើ ខ្ញុំសូមគោរពជម្រាបជូនលោកប្រធានមេត្តាជ្រាបថា៖ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានេះគឺធ្វើឡើងរវាង.......................................................និង ...................................ដោយកំនត់យកទីតាំងអនុវត្តស្ថិតក្នុងភូមិ.......................ឃុំ.................. ស្រុក.......................ខេត្ត......................ក្នុងការទិញលក់ផលិតផលប្រភេទ............................... ទៅតាមបរិមាណ គុណភាព និងពេលវេលាកំណត់ដូចមានចែងក្នុងកិច្ចសន្យាដែលបានព្រមព្រៀងដោយភាគីទាំងពីរ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាអនុញ្ញាត និងគាំទ្រដល់ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានេះដោយក្តីអនុគ្រោះ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីរូបខ្ញុំ។

ធ្វើនៅ...........ថ្ងៃទី..........ខែ..............ឆ្នាំ២០....

ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ

តំណាងភាគីអ្នកទិញ    តំណាងភាគីអ្នកផលិត

## ឧបសម្ព័ន្ធ៧៖ ទម្រង់កិច្ចសន្យាគំរូនៃកិច្ចសន្យាផលិតកម្មកសិកម្ម

ការបកប្រែក្រៅផ្លូវការ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាផលិតកម្មកសិកម្ម

## ស្តីពី

..............................................................

## រវាង

ភាគីអ្នកផលិត:..................................................

## និង

ភាគីអ្នកទិញ:.....................................................

ធ្វើនៅ.............ថ្ងៃទី.............ខែ..............ឆ្នាំ..............

# កិច្ចសន្យាផលិតកម្មកសិកម្ម

## ស្តីពី............................................

### រវាង

លោក/លោកស្រីឈ្មោះ...............................ភេទ........អាយុ..........មានតួនាទីជា.....................................

អាស័យដ្ឋានបច្ចុប្បន្ន...................................................................................................................

កាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ.....................................ចុះថ្ងៃទី........ខែ.........ឆ្នាំ............

លេខទូរស័ព្ទ................................... អ៊ីម៉ែល:....................................ប្រអប់សំបុត្រ..............................

តំណាងឲ្យ...................................ដែលបានចុះបញ្ជីលេខ.........................ចុះថ្ងៃទី........ខែ..........ឆ្នាំ.........

មានការិយាល័យកណ្តាលស្ថិតនៅ....................................................................ហៅថា ភាគីអ្នកផលិត ។

### និង

លោក/លោកស្រីឈ្មោះ...............................ភេទ........អាយុ..........មានតួនាទីជា.....................................

អាស័យដ្ឋានបច្ចុប្បន្ន...................................................................................................................

កាន់អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនលេខ........................................ចុះថ្ងៃទី........ខែ...........ឆ្នាំ.........

លេខទូរស័ព្ទ................................... អ៊ីម៉ែល:.................................. ប្រអប់សំបុត្រ..............................

តំណាងឲ្យ.........................................................................................ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

នៃព្រះរាជាណាចក្រកម្ពុជាលេខ.........................................................ចុះថ្ងៃទី........ខែ............ឆ្នាំ............

មានការិយាល័យកណ្តាលស្ថិតនៅ.............................................................ហៅថា ភាគីអ្នកទិញ ។

### យោង

- អនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា
- សារាចរណែនាំលេខ១៩៦ ស្តីពីនីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

## ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖

### ប្រការ ១ : កម្មវត្ថុនៃកិច្ចសន្យា

ភាគីអ្នកទិញយល់ព្រមទទួលទិញផលិតផលពីភាគីអ្នកផលិតនូវប្រភេទផលិតផល................................
បរិមាណ..........................ដែលមានទីតាំង...............................................................
.........................................................................................................................

### ប្រការ ២ : ថិរៈវេលានៃការអនុវត្តន៍កិច្ចសន្យា

កិច្ចសន្យានេះចាប់ផ្តើមថ្ងៃទី...........ខែ..............ឆ្នាំ.................
និងពេលវេលាបញ្ចប់ថ្ងៃទី...........ខែ..........ឆ្នាំ................. (កិច្ចសន្យាមានរយៈពេលខ្លីមធ្យម ឬ វែង អាស្រ័យលើអាយុកាលនៃប្រភេទដំណាំ រុក្ខជាតិ ឬ សត្វ ឬ តាមតម្រូវការរបស់ភាគី អ្នកទិញ)

### ប្រការ ៣ : សិទ្ធិនិងភារកិច្ចរបស់ភាគីអ្នកផលិត

- យល់ព្រមអនុវត្តតាមលក្ខខណ្ឌ ដែលបានស្នើឡើងដោយភាគីអ្នកទិញដូចមានចែងក្នុងកិច្ចសន្យា
- អនុញ្ញាតឲ្យបុគ្គលិកភាគីអ្នកទិញចូលពិនិត្យក្នុងទីតាំងរបស់ខ្លួនទៅតាមកម្មវិធីដែលបានព្រមព្រៀង
- ទទួលខុសត្រូវផ្គត់ផ្គង់ផលិតផលតាមប្រភេទ បរិមាណ គុណភាព និងពេលវេលាកំណត់ដូចមានចែងក្នុងប្រការ១ ប្រការ៥ ប្រការ៦ប្រការ៧ ប្រការ៨នៃកិច្ចសន្យានេះ
- ផ្តល់ព័ត៌មានអំពីដំណើរការផលិតកម្ម (ពេលវេលាប្រមូលផល និងការផ្លាស់ប្តូរទីកន្លែង...)
- រៀបចំបញ្ជីឈ្មោះក្រុមកសិករដែលចូលរួមអនុវត្តកិច្ចសន្យា (ករណីសមាជិកច្រើនចូលរួម)
- ទទួលខុសត្រូវសងការខូចខាតដល់ភាគីអ្នកទិញក្នុងករណីមិនបានអនុវត្តតាមលក្ខខណ្ឌ ដែលបានចែងក្នុង កិច្ចសន្យានេះ។

### ប្រការ៤ : សិទ្ធិនិងភារកិច្ចរបស់ភាគីអ្នកទិញ

- ផ្តល់ការគាំទ្រនូវផ្នែកខ្លះឬទាំងស្រុងនៅក្នុងសង្វាក់ផលិតកម្ម (ឧទាហរណ៍ : ឥណទាន ពូជ ជី ចំណីសត្វ...) ដាំដុះ ឬ ចិញ្ចឹម ប្រសិនបើមានតម្រូវការពីភាគីអ្នកផលិត ដោយធានានូវគុណភាព បរិមាណ ប្រភេទ និងរយៈពេល ដែលត្រូវអនុវត្ត (ដូចមានចែងលំអិតអំពីធាតុចូល ដែលផ្តល់ដោយភាគីអ្នកទិញ ដែលសន្យាគាំទ្រដល់ភាគីអ្នកផលិត ដូចមានក្នុងឧបសម្ព័ន្ធទី២)
- ភាគីអ្នកទិញមានសិទ្ធិចូលពិនិត្យក្នុងទីតាំងរបស់ភាគីអ្នកផលិតដោយផ្តល់ដំណឹងជាមុនដល់ភាគីអ្នកផលិត និង ផ្តល់ការណែនាំបច្ចេកទេសការបណ្តុះបណ្តាល ស្របតាមលក្ខខណ្ឌបច្ចេកទេស (ដោយមានភ្ជាប់ជាមួយឯកសារ បច្ចេកទេស) តាមការព្រមព្រៀង
- ទទួលខុសត្រូវទិញផលិតផលតាមប្រភេទ បរិមាណ គុណភាព និងពេលវេលាកំណត់ដូចមានចែងក្នុងប្រការ១ ប្រការ៥ ប្រការ៦ប្រការ៧ ប្រការ៨
- ទទួលខុសត្រូវសងការខូចខាតដល់ភាគីអ្នកផលិតក្នុងករណីមិនបានអនុវត្តតាមលក្ខខណ្ឌដែលបានចែងក្នុង កិច្ចសន្យានេះ។

**ប្រការ ៥ : ពេលវេលាប្រមូលផល ទីកន្លែងដឹកជញ្ជូន និងការផ្ទុកទំនិញ** -
ការកំណត់ពេលវេលាប្រមូលផល និងទីកន្លែងដឹកជញ្ជូនផលិតផល
- ការរៀបចំវិក័យប័ត្រប្រគល់និងទទួលផលិតផល
- កំណត់ការចំណាយលើការលើកដាក់ ការដឹកជញ្ជូន
- ភាគីអ្នកទិញត្រូវផ្តល់ភាពងាយស្រួលដល់ភាគីអ្នកផលិតក្នុងការដឹកជញ្ជូនផលិតផលចូលទីតាំងរបស់ខ្លួនឲ្យបានទាន់ពេលវេលា
- រាល់ការដឹកជញ្ជូនផលិតផលទៅកាន់រោងចក្រមានរូបភាពជាក្រុម ឬ ក៏សមាជិកម្នាក់ៗអាចដឹកទៅរៀងៗខ្លួនបាន (ត្រូវមានការចរចារគ្នារវាងភាគីទាំងពីរ)
- ក្នុងករណីមានបញ្ហាលើការដឹកជញ្ជូនភាគីទាំងពីរត្រូវផ្តល់ដំណឹងអំពីបញ្ហាយឺតយ៉ាវនោះដល់ភាគីម្ខាងទៀត (ក្នុងរយៈពេល..............)
- ភាគីអ្នកទិញត្រូវរៀបចំប័ណ្ណសំគាល់សមាជិករបស់ភាគីអ្នកផលិតក្នុងការដឹកជញ្ជូនទំនិញទៅកាន់ទីតាំងរបស់ខ្លួន។ ពេលដឹកមកដល់ទីតាំងរបស់ភាគីអ្នកទិញម្តងៗ ភាគីអ្នកទិញនិងភាគីអ្នកផលិត ត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់ការដឹកជញ្ជូនចំនួនបីច្បាប់ ហើយត្រូវរក្សាទុកជាឯកសាររៀងៗខ្លួន។ ការកំណត់ និងទីកន្លែង ប្រគល់-ទទួលផលិតផលក្នុងប្រការ ៥ នៃកិច្ចសន្យាមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ៥។

**ប្រការ ៦ : ការកំណត់គុណភាពផលិតផល**
- ការអនុវត្តជាក់ស្តែងក្នុងការកំណត់គុណភាពផលិតផល ផ្អែកលើការពិនិត្យជាក់ស្តែងដោយនៅទីតាំងផលិតកម្ម ឬ ការកំណត់គុណភាពផលិតផលនៅរោងចក្រតាមការព្រមព្រៀងរវាងភាគីទាំងពីរ។
- ការកំណត់កម្រិតគុណភាពផលិតផល ត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរ (ដូចមានចែងលំអិតក្នុងឧបសម្ព័ន្ធទី៣)។

**ប្រការ ៧ : ការកំណត់តម្លៃ**
- ការកំណត់តម្លៃអាស្រ័យនឹងកម្រិតគុណភាពផលិតផល ដែលត្រូវកំណត់ដោយមានការព្រមព្រៀងគ្នា (ដូចមានចែងលំអិតក្នុងឧបសម្ព័ន្ធទី៤)
- ត្រូវមានការព្រមព្រៀងគ្នាក្នុងការកំណត់តម្លៃជាមុន ឬ អាស្រ័យលើតម្លៃទីផ្សារជាក់ស្តែងនៅពេលប្រមូលផល។ ជាទូទៅការកំណត់តម្លៃតាមទីផ្សារជាក់ស្តែងនៅពេលប្រមូលផលត្រូវផ្អែកទៅតាមតម្លៃក្នុងតំបន់របស់ខ្លួន។ ត្រូវមានការកំណត់រូបមន្តតម្លៃទៅតាមពេលវេលាឲ្យបានច្បាស់លាស់ ។

**ប្រការ ៨ : ការទូទាត់**
- នៅពេលទំនិញដែលភាគីអ្នកផលិតដឹកទៅដល់ទីតាំងរបស់ភាគីអ្នកទិញ ត្រូវមានការទូទាត់ភ្លាម ឬរង់ចាំរយៈពេល ...................អាស្រ័យលើការព្រមព្រៀង។ ការទូទាត់អាចធ្វើតាមរយៈធនាគារ ឬ តាមការទូទាត់ជាសាច់ប្រាក់ អាស្រ័យលើការព្រមព្រៀងរបស់ភាគីទាំពីរ
- បើតាមរយៈធនាគារ ភាគីអ្នកទិញត្រូវចេញសក្ខីប័ត្រចំណាយ និងមូលប្បទានប័ត្រទៅឲ្យភាគីអ្នកផលិតជាតំណាង ឬ ចេញឲ្យសមាជិកម្នាក់ៗតាមការព្រមព្រៀង។ ភាគីអ្នកផលិតត្រូវបង្កើតលេខគណនេយ្យធនាគាររបស់ខ្លួន

- រាល់ការចំណាយលើសេវាផ្ទេរប្រាក់ជាបន្ទុករបស់ភាគីអ្នកទិញ
- ប្រភេទប្រាក់ចរាចរ ត្រូវមានការកំណត់ឯកភាពគ្នា ឲ្យបានច្បាស់លាស់ក្នុងកិច្ចន្យានេះ។

**ប្រការ ៩ : ករណីប្រធានសក្តិ**

- ក្នុងករណីមានហេតុការណ៍កើតឡើង ដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ខ្លួន ដូចជា អគ្គីភ័យ សត្វល្អិតបំផ្លាញ ឬ ជំងឺរាតត្បាតធ្ងន់ធ្ងរ ខ្យល់ព្យុះ រញ្ជួយដី ទឹកជំនន់ គ្រោះរាំងស្ងួតសង្គ្រាម ការធ្វេកប្តូរឬអំពើវិទ្ធង្សនានា។ល។ ភាគីរងគ្រោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរពាក់ព័ន្ធដែលស្ថិតនៅជិតកន្លែងកើតហេតុ និងភាគីម្ខាងទៀតក្នុងរយៈពេលមិនលើស ០៣ ថ្ងៃ ។
- ប្រសិនបើរយៈពេលនៃប្រធានសក្តិនេះបន្តលើសពី (ចំនួន......ថ្ងៃ) កិច្ចសន្យានេះត្រូវបញ្ចប់ដោយពុំមានកាតព្វកិច្ចទទួលខុសត្រូវដោយភាគីណាមួយឡើយ។
- នៅពេលដែលករណីប្រធានសក្តិបានកន្លងផុតទៅ ភាគីទាំងពីរគួរ ធ្វើការព្រមព្រាងគ្នាឡើងវិញ (ដូចដែលបានរៀបរាប់មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦)។

**ប្រការ ១០ : ការបញ្ចប់កិច្ចសន្យា**

- កិច្ចសន្យានឹងត្រូវបានបញ្ចប់បន្ទាប់ពីបានអនុវត្តពេញលេញតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង
- ចំពោះភាគីណាមួយដែលមិនបានអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាភាគីនោះត្រូវមានសំណងការខូចខាតដល់ភាគីម្ខាងទៀតទៅតាមការបង់ខាតជាក់ស្តែង។

**ប្រការ ១១ : ការដោះស្រាយវិវាទ**

- ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយគ្នាជាមុន។
- ក្នុងករណីមិនអាចដោះស្រាយបាននោះវិវាទនឹងបញ្ជូនទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីធ្វើការដោះស្រាយបន្ត។
- ករណីនៅតែមិនអាចដោះស្រាយបានទៀតនោះវិវាទនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការសម្របសម្រួលនៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីដោះស្រាយ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការសម្របសម្រួលស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យាគឺជាការសម្រេចចុងក្រោយ។

**ប្រការ ១២ : ការបង្កើតកិច្ចសន្យា និងភាសា**

កិច្ចសន្យានេះធ្វើឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរពិតប្រាកដ ដោយសេរីនិងគ្មានការគំរាមកំហែង។ កិច្ចសន្យានេះត្រូវបានយកភាសាខ្មែរជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។ កិច្ចសន្យានេះត្រូវបានធ្វើឡើងចំនួន ០៥ (ប្រាំ) ច្បាប់ មានតម្លៃស្មើគ្នា ដោយដំកល់ទុកនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិឧស្សាហកម្ម) ចំនួន ០១ ច្បាប់, មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ចំនួន ០១ ច្បាប់, សាលាឃុំ/សង្កាត់ ចំនួន ០១ ច្បាប់, ភាគីអ្នកផលិត ចំនួន ០១ ច្បាប់, ភាគីអ្នកទិញ ចំនួន ០១ ច្បាប់។

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទាំងអស់ត្រូវចាត់ទុកជាផ្នែកមួយនៃកិច្ចព្រមព្រៀង ៖

១២.១. ឧបសម្ព័ន្ធទី១: បញ្ជីឈ្មោះសមាជិកនិងលទ្ធភាពរបស់ភាគីអ្នកផលិតចូលរួមអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម

១២.២. ឧបសម្ព័ន្ធទី២: លក្ខខណ្ឌបច្ចេកទេសគាំទ្រដោយភាគីអ្នកទិញ

១២.៣. ឧបសម្ព័ន្ធទី៣: ការកំណត់ចំណាត់ថ្នាក់គុណភាព

១២.៤. ឧបសម្ព័ន្ធទី៤: បែបបទនៃការទូទាត់ថ្លៃសម្រាប់ផលិតផល

១២.៥. ឧបសម្ព័ន្ធទី៥: ការកំណត់និងទីកន្លែង ប្រគល់-ទទួលផលិតផលក្នុងប្រការ ៥ នៃកិច្ចសន្យា

១២.៦. ឧបសម្ព័ន្ធទី៦: ការអនុវត្តនៅពេលមានករណីប្រធានសក្តិកើតឡើង

ធ្វើនៅ........................ថ្ងៃទី..........ខែ...........ឆ្នាំ........

| តំណាងភាគី អ្នកផលិត | សាក្សី | សាក្សី | តំណាងភាគី អ្នកទិញ |
|---|---|---|---|
| ................................ | ................................ | ................................ | ................................ |
| (ស្នាមមេស្តាំសាមីខ្លួន) | (ស្នាមមេស្តាំសាមីខ្លួន) | (ស្នាមមេស្តាំសាមីខ្លួន) | (ស្នាមមេស្តាំសាមីខ្លួន) |

បានឃើញ

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កន្លែងតំកល់ឯកសារ** :

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  (នាយកដ្ឋានកសិ-ឧស្សាហកម្ម)
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត .........
- សាលាឃុំ/សង្កាត់ ...............
- ភាគីអ្នកផលិត
- ភាគីអ្នកទិញ

## ឧបសម្ព័ន្ធ ១

បញ្ជីឈ្មោះសមាជិកនិងលទ្ធភាពរបស់ភាគីអ្នកផលិតចូលរួមអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម

| ល.រ<br>No | នាម និង គោត្តនាម<br>Name | ទីតាំង<br>Location | ផលិតផល<br>Products | ទំហំផ្ទៃដី<br>Land Size | បរិមាណ លក់<br>Quantity sale ( Kg ) | ស្នាមមេដៃ/<br>Trumping |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ធ្វើនៅ.......ថ្ងៃទី.............ខែ................ឆ្នាំ...............

**តំណាងអ្នកផលិត**

( ស្នាមមេដៃស្ដាំសាមីខ្លួន )

លេខ :.......................

បានឃើញ និង បញ្ជាក់ថា:

ឈ្មោះ.................................................... នេះពិតជា

.....................នៃ................................................

និងពិតជាកំពុងស្នាក់នៅបច្ចុប្បន្ននៅផ្ទះលេខ.....................

ផ្លូវ...................ភូមិ/មណ្ឌល...................................

ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ...........................

..........................ខេត្ត/ក្រុង....................................

នេះប្រាកដមែន។

## ឧបសម្ព័ន្ធ ២

លក្ខខណ្ឌបច្ចេកទេសគាំទ្រដោយភាគីអ្នកទិញ

| ល.រ | បរិយាយ (ធាតុចូល) | បរិមាណ | តម្លៃ (ឯកតា) | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ធ្វើនៅ.......ឆ្នាំ..............ថ្ងៃទី.............ខែ...............

**តំណាងអ្នកផលិត**

(ស្នាមមេដៃស្ដាំសាមីខ្លួន)

## ឧបសម្ព័ន្ធ ៣

ការកំណត់ចំណាត់ថ្នាក់គុណភាព

សំគាល់ ១ : គុណភាព និង ស្តង់ដារនៃផលិតផល

..........................................................................................................................................

.....................................................

..........................................................................................................................................

.....................................................

សំគាល់ ២ : ភាគីទាំង ២ ព្រមព្រៀងទិញផលិតផលតាមកិច្ចព្រមព្រៀងតាមប្រការ ៦ នៃកិច្ចសន្យាដូចខាងក្រោម៖

| ល.រ | ចំណាត់ថ្នាក់គុណភាព | បរិមា (គ.ក្រ) | តម្លៃ (រៀល/គ.ក្រ) | សរុប (រៀល) | សំគាល់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ភាគីទាំងពីរ ព្រមព្រៀងគ្នាកែតម្រូវតម្លៃផលិតផល ដោយបន្ថែមថ្លៃលើតម្លៃទីផ្សារក្នុង អត្រាមិនលើសពី (%) (            ) នៃតម្លៃកិច្ចព្រមព្រៀម សំគាល់ ១ នៃការព្រមព្រៀម

## ឧបសម្ព័ន្ធ ៤

បែបបទនៃការទូទាត់ថ្លៃសម្រាប់ផលិតផល

១ .ទូទាត់ថ្លៃភ្លាមៗ ក្រោយប្រគល់និងទទួលផលិតផល

២. ទូទាត់ថ្លៃបន្ទាប់ពីប្រគល់ទទួលផលិតផលតាមរយៈ

.២.១  ការកំណត់ពេលនៃការទូទាត់ថ្លៃ

| ដំណាក់កាលប្រគល់ | កាលវិភាគទូទាត់ថ្លៃ |
|---|---|
| ១រយៈពេល............ថ្ងៃនៃ<br>ប្រគល់ ទទួលផលិតផលថ្ងៃ,<br>បន្ទាប់ពីថ្ងៃទី..................<br>ដល់ថ្ងៃទី......................<br>................................ | ១............ទូទាត់ថ្លៃលើកទីមួយ ចំនួន (១...............................................(រៀល)............<br>គុណភាព ១លេខ, លេខ២, លេខ៣, )........................................................................<br>ក្នុងបរិមាណផលិតផល.........................គ.ក្រ)..., ក្បាល.....នៅថ្ងៃទី(................................<br>១ ទូទាត់ថ្លៃលើក (២ ពីរ ចំនួន...........................................................(រៀល)............<br>គុណភាព ១លេខ, លេខ២, លេខ៣, )........................................................................<br>ក្នុងបរិមាណផលិតផល.........................គ.ក្រ)..., ក្បាល.....នៅថ្ងៃទី(................................<br>១ ទូទាត់ថ្លៃលើក (៣ បី ចំនួន...........................................................(រៀល)............<br>គុណភាព ១លេខ, លេខ២, លេខ៣, )........................................................................<br>ក្នុងបរិមាណផលិតផល.........................គ.ក្រ)..., ក្បាល.....នៅថ្ងៃទី(................................<br>..............................................................................................។................................ |
| ដំណាក់កាលប្រគល់ | កាលវិភាគទូទាត់ថ្លៃ |
| ២រយៈពេល............ថ្ងៃនៃ<br>ប្រគល់ ទទួលផលិតផលថ្ងៃ,<br>បន្ទាប់ពីថ្ងៃទី..................<br>ដល់ថ្ងៃទី......................<br>................................ | ២............ទូទាត់ថ្លៃលើកទីមួយ ចំនួន (១...............................................(រៀល)............<br>គុណភាព ១លេខ, លេខ២, លេខ៣, )........................................................................<br>ក្នុងបរិមាណផលិតផល.........................គ.ក្រ)..., ក្បាល.....នៅថ្ងៃទី(................................<br>២ ទូទាត់ថ្លៃលើក (២ ពីរ ចំនួន...........................................................(រៀល)............<br>គុណភាព ១លេខ, លេខ២, លេខ៣, )........................................................................<br>ក្នុងបរិមាណផលិតផល.........................គ.ក្រ)..., ក្បាល.....នៅថ្ងៃទី(................................<br>២ ទូទាត់ថ្លៃលើក (៣ បី ចំនួន...........................................................(រៀល)............<br>គុណភាព ១លេខ, លេខ២, លេខ៣, )........................................................................<br>ក្នុងបរិមាណផលិតផល.........................គ.ក្រ)..., ក្បាល.....នៅថ្ងៃទី(................................<br>..............................................................................................។................................ |

២.២ វិធីសាស្ត្រទូទាត់ថ្លៃ

២.២.១) ការទូទាត់ថ្លៃផលិតផលធ្វើឡើងតាមការព្រមព្រៀង (តាមរយៈសាច់ប្រាក់ឬធនាគា)

២.២.២) អ្នកទិញអាចទូទាត់ថ្លៃផលិតផលទៅសមាជិតម្នាក់ៗដោយផ្ទាល់ ឬ ទៅតំណាង

២.២.៣) ក្នុងករណីដែលភាគីអ្នកទិញទូទាត់ថ្លៃផលិតផលទៅក្នុងគណនេយ្យធនាគា ឬ សាប់ប្រាក់នៃស្ថាប័នអង្គការកសិកររួចរាល់នោះតំណាងស្ថាប័នអង្គការកសិករត្រូវទទួលខុសត្រូវក្នុងការទូទាត់ថ្លៃផលិតផលទៅដល់រាល់គ្រប់សមាជិកកសិករទាំងអស់វិញ។

២.២.៤) បើសិនជាភាគីអ្នកទិញ មិនព្រមទូទាត់ថ្លៃផលិតផលទៅក្នុងគណនេយ្យធនាគា ឬ សាច់ប្រាក់សម្រាប់ចំនួនប្រាក់ដែលជំពាក់ ឬ សងមិនគ្រប់ទៅតាមថ្ងៃដែលកំណត់ ដោយយោងទៅតាមការរៀបរាប់ក្នុង ចំនុចលេខ ២.១ កន្លងទៅ នោះភាគីអ្នកទិញសុខចិត្តសងជម្ងឺចិត្តដល់ទៅឲ្យភាគីអ្នកផលិតក្នុងអត្រា...............ភាគរយ (%) (....................) លើបរិមាណដែលទូទាត់ខ្វះហូតដល់ភាគីអ្នកទិញអាចទូទាត់គ្រប់ចំនួនទៅឲ្យភាគីអ្នកផលិត។

## ឧបសម្ព័ន្ធ ៥

### ការកំណត់ និងទីកន្លែង ប្រគល់-ទទួលផលិតផលក្នុងប្រការ ៥ នៃកិច្ចសន្យា

| កាលកំណត់<br>ការប្រគល់-ទទួល | ចំណាត់ថ្នាក់/គុណភាព<br>/ទំហំ | បរិមាណ ( គ.ក្រ ) | ទីកន្លែង<br>នៃការប្រគល់ | សំគាល់ |
|---|---|---|---|---|
| | | | | |

ធ្វើនៅ............ថ្ងៃទី...........ខែ...........ឆ្នាំ.........

តំណាងអ្នកទទួល

( ស្នាមមេដៃស្តាំសាមីខ្លួន )

តំណាងអ្នកប្រគល់

( ស្នាមមេដៃស្តាំសាមីខ្លួន )

ឧបសម្ព័ន្ធ ៦

ការអនុវត្តនៅពេលមានករណីប្រធានសក្តិកើតឡើង

បើសិនជាមានករណីប្រធានសក្តិកើតឡើងមុនពេលកំឡុងពេល ឬក្រោយពេលប្រគល់ទទួលផលិតផល នោះភាគីទាំងពីរគួរអនុវត្តន៍ដូចខាងក្រោមៈ

ករណីទី ១ ៖ ករណីប្រធានសក្តិកើតឡើងលើភាគីអ្នកផលិត

ភាគីអ្នកផលិតតែគួរប្រគល់ផលិតផល ឲ្យបានចំនួនច្រើនបំផុតដែលភាគីអ្នកផលិតអាចផលិតបាន ហើយភាគីអ្នកទិញត្រូវតែយល់ព្រមទទួលយកនូវផលិតផល ដែល បានប្រគល់ដោយភាគីអ្នកផលិត ដោយអនុលោមទៅតាមការព្រមព្រៀងថ្លៃ ដូចដែលបានព្រមព្រៀងគ្នាក្នុងប្រការ ៦ នៃកិច្ចព្រមព្រៀង និងបានរៀបរាប់ពីការព្រមព្រៀងគ្នារវាងភាគីអ្នកផលិតនិងភាគីអ្នកទិញ។

ករណីទី២ ៖ ករណីប្រធានសក្តិកើតឡើងលើភាគីអ្នកទិញ

ភាគីអ្នកទិញគួរទទួលផលិតផលឲ្យបានចំនួនច្រើនបំផុតដែលខ្លួនអាចទទួលយកបាន ហើយភាគីអ្នកផលិត ត្រូវតែគួរប្រគល់ឲ្យនូវបរិមាណនៃផលិតផលដែលយល់ព្រមទទួលដោយភាគីអ្នកទិញ ដែលតម្លៃនៃផលិតបានអនុលោមទៅតាមប្រការ ៦ នៃកិច្ចព្រមព្រៀង ហើយរៀបរាប់លំអិតដែលព្រមព្រៀងគ្នារវាងភាគីអ្នកផលិត និងភាគីអ្នកទិញ។

ការរៀបរាប់ដែលបានព្រមព្រៀងគ្នាដោយភាគីអ្នកផលិត និងភាគីអ្នកទិញមានដូចតទៅៈ

ដំណើរការនៃការទូទាត់ថ្លៃគួរអនុវត្តតាមតម្រូវការ និងវិធីសាស្ត្រដែលបានបង្ហាញក្នុងប្រការ៣ នៃកិច្ចព្រមព្រៀង។

| ដំណាក់កាលប្រគល់/ដំណាក់កាលទទួល | ចំណាត់ថ្នាក់គុណភាព | គុណភាពប្រហាក់ប្រហែលនៃ ការប្រគល់-ទទួលផលិតផល | តម្លៃ/គក្រ. (រៀល) | តម្លៃផលិតផលប្រហាក់ប្រហែល (រៀល) | ទីតាំងប្រគល់/ទទួល | ការទូទាត់ថ្លៃ |
|---|---|---|---|---|---|---|
| រយៈពេលថ្ងៃ............<br>នៃថ្ងៃប្រគល់-ទទួល<br>ផលិតផល,<br>បន្ទាប់ពីថ្ងៃទី............<br>ដល់ថ្ងៃទី................ | | | | | | ទូទាត់ថ្លៃលើកទីមួយ ចំនួន (រៀល).............<br>គុណភាព ១លេខ, លេខ២, លេខ៣, ).........<br>ក្នុងបរិមាណផលិតផលគ.ក្រ)......, ក្បាល(....<br>នៅថ្ងៃទី.............................................<br><br>ទូទាត់ថ្លៃលើកទីពីរ ចំនួន (រៀល)...............<br>គុណភាព ១លេខ, លេខ២, លេខ៣, ).........<br>ក្នុងបរិមាណផលិតផលគ.ក្រ)......, ក្បាល(....<br>នៅថ្ងៃទី.............................................<br><br>ទូទាត់ថ្លៃលើកទីបី ចំនួន (រៀល)................<br>គុណភាព ១លេខ, លេខ២, លេខ៣, ).........<br>ក្នុងបរិមាណផលិតផលគ.ក្រ)......, ក្បាល(....<br>នៅថ្ងៃទី............................................. |

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាផលិតកម្មកសិកម្មស្តីអំពី
# ការផលិតនិងការផ្គត់ផ្គង់ស្រូវសរីរាង្គ
# រវាង
# ក្រុមហ៊ុនអេមរ៉ូយស៍(ខេមបូឌា)
# និង
# សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ

## កាលបរិច្ឆេទចុះកិច្ចសន្យា៖ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១

កិច្ចសន្យាផលិតកម្មកសិកម្មស្តីអំពីការផលិត និងការផ្គត់ផ្គង់ស្រូវសរីរាង្គធ្វើឡើងនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៦ ។

**រវាង**

ក្រុមហ៊ុនអេមរុវាយស៍ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជាលេខ Co.0337 KH / 2011 ដែលមានទីតាំងបច្ចុប្បន្នការិយាល័យកណ្តាលស្ថិតនៅក្នុង **បុរី រិទ្ធ** ផ្ទះលេខ A13, A15 សង្កាត់ ឬស្សីកែវ ខណ្ឌ ឬស្សីកែវ រាជធានីភ្នំពេញដែលតំណាងដោយ **លោកឧកញ៉ា សុខសារ៉េន** មានតួនាទីជាអគ្គនាយកនៃក្រុមហ៊ុនអេមរ៉ុាយស៍មានទូរស័ព្ទលេខ: 012 303 016
អ៊ីម៉ែល: chairman@amrurice.com ហៅថា: ភាគីអ្នកទិញ។

**និង**

សហគមន៍កសិកម្មរហ័សសាមគ្គីមានជ័យដែលបានចុះបញ្ជីនៅមន្ទីរកសិកម្ម ខេត្តព្រះវិហារលេខ ០០៣ មានការិយាល័យកណ្តាលស្ថិតនៅភូមិថ្លៃង ឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារ ដែលតំណាងដោយ **លោក ប៉ាវ សាវ៉ាត** មានតួនាទីជាប្រធានត្រួតពិនិត្យសហគមន៍មានទូរស័ព្ទលេខ
០៨៨ ៣៣ ៦៦ ៤២២ អ៊ីមែល: (គ្មាន) ហៅថា៖ ភាគីអ្នកផលិត។

បានឃើញ និងយោងតាម:

- អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា
- អនុស្សរណៈសម្រាប់ការអភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវសរីរាង្គប្រកបដោយនិរន្តភាពក្នុងខេត្តព្រះវិហារ រវាងក្រុមហ៊ុនអេមរ៉ុាយស៍ សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ សហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ និងសហគមន៍កសិកម្ម។

បានព្រមព្រៀងគ្នាដូចខាងក្រោម:

## *ប្រការ ១: កម្មវត្ថុកិច្ចសន្យា*

- ការផលិត និងការផ្គត់ផ្គង់ស្រូវសរីរាង្គប្រភេទស្រូវក្រអូបទាំងស្រូវសើម និងស្រូវស្ងួត (ពូជផ្ការំដួល ផ្កាម្លិះ ផ្ការំដេង) ចំនួន ២៥០.៧៥ តោន និងពូជស្រូវសរចំនួន ៩.៥ តោន របស់ភាគីអ្នកផលិតដែលមានកសិករជាអ្នកផលិតចំនួន ១០៤ នាក់ (បញ្ជីឈ្មោះកសិករមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី១) ទៅឲ្យភាគីអ្នកទិញ។
- ការផលិត និងការផ្គត់ផ្គង់ស្រូវសរីរាង្គនេះធ្វើឡើងតាមការស្ម័គ្រចិត្តទាំងសងខាងដោយគ្មានការបង្ខិតបង្ខំ និងបានយល់ច្បាស់រវាងភាគីអ្នកទិញ និងអ្នកផលិតក្នុងការធ្វើកិច្ចសន្យាផលិត និងទិញស្រូវសរីរាង្គដែលមានការទទួលស្គាល់ដោយស្ថាប័នចេញវិញ្ញាបនប័ត្រពីខាងក្រៅដែលមានការទទួលស្គាល់កម្រិតអន្តរជាតិ។ បរិមាណស្រូវដែលគ្រោងនឹងទិញនេះនឹងអាចមានការប្រែប្រួលប្រសិនបើកសិករជាប់កិច្ចសន្យាផលិតស្រូវគុណភាពល្អស្របតាមស្តង់ដាបានក្នុងបរិមាណច្រើនឬគុណភាពស្រូវមិនបានឆ្លើយតបទៅតាមតម្រូវការស្តង់ដាស្រូវសរីរាង្គអន្តរជាតិសម្រាប់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។

## ប្រការ ២: ថេរវេលាក្នុងការអនុវត្ត

កិច្ចសន្យានេះមានសុពលភាពរយៈពេល ០៧ ខែ ដោយគិតចាប់ពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៦ រហូតដល់ថ្ងៃ ៣១ ខែមករា ឆ្នាំ២០១៧។

## ប្រការ ៣: សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីអ្នកផលិត

- ដាំដុះស្រូវក្រអូប (ពូជផ្ការំដួល ផ្កាម្លិះ និងផ្ការំដេង) និងស្រូវសរ (ពូជនាងអំពូជក្រចកដា, ពូជក្រចកជៀស, ពូជត្នោត, ពូជទូល្ញីស, ពូជក្រចេះ, ពូជនាង ចិន, ពូជចិនសីយ និងពូជស្រូវផ្សេងទៀតដែលមានប្រភេទគ្រាប់ធំហើយវែងដូចដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យានេះ) លើផ្ទៃដី ២០៤.១៥ ហិចតា សម្រាប់ផ្គត់ផ្គង់ឲ្យក្រុមហ៊ុនអេមរ៉ាយស៍ (ភាគីអ្នកទិញ)តាមកិច្ចសន្យា និងទទួលបន្ទុកចំណាយទាំងអស់ក្នុងការធ្វើផលិតកម្មស្រូវ។
- លក់ស្រូវដែលផលិតបានទៅឲ្យភាគីអ្នកទិញក្នុងបរិមាណគុណភាព និងតម្លៃដូចដែលបានបញ្ជាក់នៅក្នុងប្រការ ៦ និង ប្រការ ៧។
- ប្រមូលសមាជិកជាប់កិច្ចសន្យាមកចូលរួមវគ្គបណ្តុះបណ្តាល ដែលផ្តល់ដោយសហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ និងភាគីអ្នកទិញក្នុងកំឡុងពេលអនុវត្តកិច្ចសន្យានេះ។
- ផ្តល់បញ្ជីរសមាជិកតារាងបញ្ជីឈ្មោះរបស់សៀវភៅប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលចូលរួមកិច្ចសន្យាដែលមានកំណត់ទីតាំង និងទំហំផ្ទៃដីដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យានេះដល់ភាគីអ្នកទិញ។
- រាល់ពេលលក់ស្រូវសមាជិកម្នាក់ៗត្រូវរក្សាទុកវិក័យបត្រ័រៀងៗខ្លួន (បរិមាណស្រូវលក់ តម្លៃ និងថវិកាទទួលបាន)សម្រាប់ទុកជាឯកសារសម្រាប់ប្រព័ន្ធស្វែងរកតឹកតាង។
- គ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយសហការជាមួយសហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ។
- រ៉ាប់រងការចំណាយក្នុងការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យតាមរយៈការបង់ប្រាក់របស់សមាជិក ដែលចុះកិច្ចសន្យាចំនួន ៥០ រៀល/គ.ក្រ នៃបរិមាណស្រូវសរីរាង្គដែលនឹងត្រូវផ្គត់ផ្គង់មក ភាគីអ្នកទិញ។
- ទទួលខុសត្រូវក្នុងការចូលរួមចំណែកចំណាយសម្រាប់ការចេញវិញ្ញាបនប័ត្រតាមស្តង់ដាសរីរាង្គរបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកចំនួន ៥០% នៃថ្លៃសវនកម្មក្នុងការត្រួតពិនិត្យទៅលើកសិករអ្នកផលិត សម្រាប់ឆ្នាំ ២០១៦។
- មានសិទ្ធិប្តឹងតវ៉ាក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាប្រសិនបើមើលឃើញថា ភាគីអ្នកទិញមិនបានអនុវត្តតាមកិច្ចសន្យាត្រង់ប្រការណាមួយ។

## *ប្រការ ៤: សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីអ្នកទិញ*

- ទិញស្រូវក្រអូប (ពូជផ្ការំដួល ផ្កាម្លិះ ផ្ការំដេង) និងស្រូវសរ (ពូជនាងអំ ក្រចកជាក្រចេះ នាងចិន និងពូជស្រូវផ្សេងទៀត ដែលមានប្រភេទគ្រាប់ធំហើយវែងដូចដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យានេះ) ទៅតាមបរិមាណគុណភាព និងតម្លៃដូចដែលបានព្រមព្រៀងក្នុងប្រការ ៦ និង ប្រការ ៧ កិច្ចសន្យានេះ។
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ពិនិត្យគុណភាពស្រូវបឋមដល់គណៈកម្មការសហគមន៍កសិកម្ម មុនពេលប្រមូលផល។
- ផ្តល់សំបកបាវដល់ភាគីអ្នកផលិតដោយពុំគិតថ្លៃ មុនពេលប្រមូលផល។
- ទទួលខុសត្រូវ ក្នុងការចំណាយបង្គ្រប់សម្រាប់ការចេញវិញ្ញាបនប័ត្រតាមស្តង់ដាសរីរាង្គរបស់សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។
- ជាអ្នកដាក់ពាក្យស្នើសុំទៅស្ថាប័នត្រួតពិនិត្យ និងចេញវិញ្ញាបនប័ត្រពីខាក្រៅដែលស្របតាមស្តង់ដារសេរីរាង្គសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកដោយសហការជាមួយសហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ និងសហគមន៍កសិកម្មទាំងអស់ដែលជាដៃគូក្នុងកិច្ចសន្យា។
- មានសិទ្ធិប្តឹងតវ៉ាក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាប្រសិនបើមើលឃើញថាភាគីអ្នកផលិតមិនបានអនុវត្តតាមកិច្ចសន្យាត្រង់ប្រការណាមួយ។

## *ប្រការ ៥: ការប្រមូលផល និងការដឹកជញ្ជូន*

- ភាគីអ្នកផលិតត្រូវជូនដំណឹងទៅភាគីអ្នកទិញឲ្យបានរយៈពេល ១០ ថ្ងៃ មុនការប្រមូលផលស្រូវ។ ក្រោយទទួលបានការជូនដំណឹងពីភាគីអ្នកផលិតក្នុងរយៈពេល ០៣ ថ្ងៃ (ថ្ងៃបម្រើការងារ) នោះភាគីអ្នកទិញត្រូវផ្តល់ព័ត៌មានត្រលប់ដល់ ភាគីអ្នកផលិត។
- ភាគីអ្នកផលិតត្រូវផ្តល់ព័ត៌មានជាក់លាក់អំពីទីតាំងប្រមូលផ្តុំស្រូវ ដែលមានផ្លូវសម្រាប់ឡានដឹក (ចំណុះ ២០ តោន ឡើង) អាចចេញចូលបានដោយសុវត្ថិភាព។
- ក្នុងករណីស្រូវសើម (សំណើមលើសពី ១៩.៥%) ក្រោយពីបានច្រូតកាត់រួច ភាគីអ្នកផលិតត្រូវដឹកជញ្ជូនស្រូវទៅដាក់ទីតាំងប្រមូលផ្តុំដែលបានកំណត់ដាក់ស្តែងយ៉ាងយូរ ០១ ថ្ងៃ ក្រោយការច្រូតកាត់ ដើម្បីសម្រួលដល់ភាគីអ្នកទិញចូលទៅដឹកជញ្ជូនភ្លាម។
- រាល់ការចំណាយសម្រាប់ការលើកដាក់ និងដឹកជញ្ជូនពីកន្លែងប្រមូលផ្តុំស្រូវទៅរោងម៉ាស៊ីនជាបន្ទុករបស់ភាគីអ្នកទិញ។ ភាគីអ្នកផលិតត្រូវសហការជួយស្វែងរកកំលាំងពលកម្មក្នុងការលើកដាក់ស្រូវលើរថយន្ត។
- រាល់ការយល់ព្រមនិងទទួលស្រូវក្នុងការលើកដាក់លើឡានម្តងៗ ភាគីអ្នទិញ និងភាគីអ្នកផលិតត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់ការដឹកជញ្ជូនចំនួនពីរច្បាប់ហើយត្រូវរក្សាទុកជាឯកសាររៀងៗខ្លួន។ លិខិតបញ្ជាក់ការដឹកជញ្ជូនមានបញ្ជាក់ពីបរិមាណស្រូវដែលបានប្រគល់ និងទទួលបញ្ជាក់ជាក់លាក់ពីគុណភាពស្រូវ និងតម្លៃស្រូវទៅតាមគុណភាពដែលភាគីអ្នកទិញផ្តល់ឲ្យទៅភាគីអ្នកផលិត។

## ប្រការ ៦: គុណភាពស្រូវ

គុណភាពស្រូវត្រូវកំណត់តាមការពិនិត្យជាក់ស្តែងដោយមានការយល់ព្រមដោយភាគីទាំងពីរ។ ការពិនិត្យគុណភាពគឺសំដៅទៅលើភាពសុទ្ធនៃគ្រាប់ពូជ និងពណ៌សម្បុរ កម្រិតសំណើម និងអត្រាបាក់។

➢ គុណភាពស្រូវក្រអូប៖

| លក្ខណៈវិនិច្ឆ័យ ចំណាត់ថ្នាក់ | ភាពសុទ្ធ (%) | កម្រិតសំណើម (%) | អត្រាបាក់(%) |
|---|---|---|---|
| A1( អេ១) | 90%-100% | 13%-14.9% | 1%-24% |
| A2 (អេ២) | 90%-100% | 13%-14.9% | 25%-32% |
| A3 (អេ៣) | 90%-100% | 13%-14.9% | 33%-36% |
| A4(អេ៤) | 90%-100% | 13%-14.9% | 40%-52% |
| B1(ប៊ី១) | 90%-100% | 15%-19.4% | 1%-24% |
| B2(ប៊ី២) | 90%-100% | 15%-19.4% | 25%-36% |
| B3(ប៊ី៣) | 90%-100% | 15%-19.4% | 37%-40% |
| C1(ស៊ី១) | 90%-100% | 19.5%-30% | គ្មាន |

➢ គុណភាពស្រូវសរ៖

| លក្ខណៈវិនិច្ឆ័យ ចំណាត់ថ្នាក់ | ភាពសុទ្ធ (%) | កម្រិតសំណើម (%) | អត្រាបាក់(%) |
|---|---|---|---|
| D1 (ឌី ១) | 90%-100% | 13%-16% | 1%-16% |
| D2 (ឌី២) | 90%-100% | 13%-16% | 17%-24% |
| D3 (ឌី៣) | 82%-89% | 13%-16% | 1%-24% |

## *ប្រការ ៧: ការកំណត់តម្លៃស្រូវ*

➢ តម្លៃស្រូវក្រអូបៈ

- តម្លៃស្រូវត្រូវបានកំណត់ទៅតាមប្រភេទគុណភាពដូចមានចែងក្នុងប្រការ ៦។

- តម្លៃស្រូវក្រអូបត្រូវកំណត់តាមតម្លៃទីផ្សារជាក់ស្តែងដោយយោងតាមតម្លៃទីផ្សារខ្ពស់បំផុតក្នុងរយៈពេល ០៧ ថ្ងៃកន្លងមកដែលបានទិញដោយរោងម៉ាស៊ីនកិនស្រូវធំៗចំនួន ០៣ កន្លែងនៅក្នុងខេត្តកំពង់ធំ ឬ និងខេត្តសៀមរាប ( ឈ្មោះរោងម៉ាស៊ីនកិនស្រូវអាស្រ័យលើការព្រមព្រៀងដោយភាគីទាំងពីរក្នុងកំឡុងពេលប្រមូលផល )។

- តម្លៃស្រូវសរីរាង្គ ដែលទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រ័ពីខាងក្រៅត្រូវមានតម្លៃថ្លៃជាងស្រូវក្រអូបធម្មតានៅលើទីផ្សារ។ ថ្លៃបុព្វលាភដែលលើសពីតម្លៃស្រូវនៅលើទីផ្សារដែលបានកំណត់ទៅតាមប្រការទី ៦ មានបញ្ជាក់ក្នុងតារាងខាងក្រោមៈ

| លក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់ | ថ្លៃបុព្វលាភសម្រាប់ស្រូវសរីរាង្គ |
|---|---|
| A1( អេ១) | 270៛/គ.ក្រ |
| A2 (អេ២) | 180៛/គ.ក្រ |
| A3 (អេ៣) | 130៛/គ.ក្រ |
| A4(អេ៤) | 50៛/គ.ក្រ |
| B1(ប៊ី១) | 210៛/គ.ក្រ |
| B2(ប៊ី២) | 180៛/គ.ក្រ |
| B3(ប៊ី៣) | 130៛/គ.ក្រ |
| C1(ស៊ី១) | 50៛/គ.ក្រ |

➢ តម្លៃស្រូវសរៈ

- តម្លៃស្រូវសរសេរីវាង្គដែលទទួលស្គាល់ដោយអង្គភាពចេញវិញ្ញាបនបត្រ័ពីខាងក្រៅត្រូវមានតម្លៃថ្លៃជាងស្រូវសរធម្មតានៅលើទីផ្សារ។ ថ្លៃបុព្វលាភដែល លើសពីតម្លៃស្រូវនៅលើទីផ្សារដែលបានកំណត់ទៅតាមប្រការទី ៦ មានបញ្ជាក់ក្នុងតារាងខាងក្រោមៈ

| លក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់ | ថ្លៃបុព្វលាភសម្រាប់ស្រូវសរីរាង្គ |
|---|---|
| D1( ឌី១) | 230៛/គ.ក្រ |
| D2(ឌី២) | 190៛/គ.ក្រ |
| D3(ឌី៣) | 130៛/គ.ក្រ |

- ភាគរយស្រូវរនុកមិនលើសពី ៣%។

## *ប្រការ ៨: ការទូវទាត់ប្រាក់*

- ភាគីអ្នកទិញត្រូវទូទាត់ថ្លៃស្រូវឲ្យភាគីអ្នកផលិត តាមគណនីរបស់សហគមន៍យ៉ាងយូរបំផុត ០៧ ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្លឹងស្រូវដាក់រថយន្តរួចនៃថ្ងៃនីមួយៗ
- ភាគីអ្នកទិញត្រូវចេញវិក្ក័យប័ត្រនៃការទូទាត់ប្រាក់រួម និងលិខិតបញ្ជាក់ពីការដឹកស្រូវម្តងៗ។ ការទូទាត់ប្រាក់សម្រាប់ការទិញស្រូវត្រូវគិតជាប្រាក់រៀល។
- ភាគីអ្នកទិញត្រូវទូទាត់ថ្លៃស្រូវតាមរយៈគណនីធនាគាររបស់ភាគីអ្នកផលិត៖
    - ឈ្មោះធនាគារអេស៊ីលីដា ភីអិលស៊ី
    - សាខាធនាគារអេស៊ីលីដា ភីអិលស៊ីក្រុងព្រះវិហារខេត្តព្រះវិហារ
    - អាស័យដ្ឋានសាខាសង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
    - ម្ចាស់គណនី
        ១. អ្នកស្រី ហេង សុភាព
        ២. លោក ប៉ារ សារ៉ាត
        ៣. លោក ថោង ប៊ុនឡាញ់
        ៤. អ្នកស្រី សាំង សុផល
        ៥. លោក រៀម សំអុន
    - លេខគណនី: 34940148540212

រាល់ការចំណាយលើសេវាផ្ទេរប្រាក់ជាបន្ទុករបស់ភាគីអ្នកទិញ។

## ប្រការ ៩: ករណីប្រធានសក្តិ

- ពាក្យ "ករណីប្រធានសក្តិ" រួមមានភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាម រញ្ជួយដី ការរំជើបរំជួលនៃផ្នែកសង្គម សកម្មភាពបះបោរកុប្បកម្ម ការផ្ទុះផ្សេងៗ ការឆ្លងរាលដាលនៃជំងឺផ្សេងៗ ព្រមទាំងព្រឹត្តិការណ៍ ឬ កាលៈទេសៈផ្សេងៗទៀតដែលហួសពីការគ្រប់គ្រងសមស្របរបស់ភាគីទាំងពីរ ។

- ក្នុងករណីបរិមាណ និងគុណភាពស្រូវដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាមិនបានឈានដល់គោលដៅដោយសារករណីប្រធានសក្តិ ដូច្នេះកិច្ចសន្យានឹងត្រូវលុបចោលជាស្វ័យប្រវត្តិ ហើយមិនមានភាគីណាមួយទាមទារសំណងឡើយ។ ប៉ុន្តែភាគីអ្នកផលិតត្រូវជូនដំណឹងករណីខូចខាតដោយប្រការណាមួយខាងលើទៅភាគីអ្នកទិញមន្ទីរកសិកម្ម និងអាជ្ញាធរមូលដ្ឋានយ៉ាងយូរបំផុតរយៈពេល ៧ ថ្ងៃ ក្រោយការទទួលរងហានិភ័យ។

## ប្រការ ១០: ការបញ្ចប់កិច្ចសន្យា

- កិច្ចសន្យានឹងត្រូវបានបញ្ចប់បន្ទាប់ពីរាល់ការសន្យាត្រូវបានអនុវត្តពេញលេញ ដោយភាគីទាំងពីរពោលគឺបន្ទាប់ពីការផ្គត់ផ្គង់ស្រូវ និងការទូទាត់ប្រាក់ត្រូវបានធ្វើឡើងរួចរាល់ដោយភាគីទាំងពីរ។

- ក្នុងករណីភាគីណាមួយពុំបានបំពេញតាមកិច្ចព្រមព្រៀងភាគី ដែលមិនគោរពកិច្ចសន្យានោះត្រូវបង់ថ្លៃខូចខាតដូចបានកំណត់ក្នុងប្រការ ៣ និង ៤ ខាងលើ។

## ប្រការ ១១: ការដោះស្រាយវិវាទ

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយគ្នាជាមុនសិន។ ក្នុងករណីមិនអាចដោះស្រាយបាន នោះវិវាទនឹងបញ្ជូនទៅមន្ទីរកសិកម្ម ខេត្តសាម៉ីដើម្បីធ្វើការដោះស្រាយបន្ត។ ប្រសិនបើវិវាទនៅតែមិនអាចដោះស្រាយបានទៀតនោះវិវាទនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការសម្របសម្រួល នៃផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីដោះស្រាយជាចុងក្រោយ។ ដូច្នេះភាគីទាំងពីរត្រូវតែទទួលយកការសម្រេចរបស់គណៈកម្មាធិការសម្របសម្រួលស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា។

## *ប្រការ ១២: ការបង្កើតកិច្ចសន្យា និងភាសា*

- កិច្ចសន្យានេះធ្វើឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរពិតប្រាកដដោយសេរី និងគ្មានការគំរាមកំហែង។ កិច្ចសន្យានេះត្រូវបានយកភាសាខ្មែរជាមូលដ្ឋានក្នុងការធ្វើកិច្ចសន្យា និងជាមូលដ្ឋានក្នុងការដដែកដោះស្រាយវិវាទ។
- កិច្ចសន្យានេះអាចត្រូវបានកែប្រែក្នុងករណីមានការស្នើសុំពីភាគីណាមួយនិងត្រូវបានព្រមព្រៀងដោយភាគីទាំងពីរ។
- កិច្ចសន្យានេះត្រូវបានធ្វើឡើងចំនួន ០៥ (ប្រាំ)ច្បាប់ និងត្រូវបានចុះហត្ថលេខានៅលើច្បាប់ដើមទាំងប្រាំដែលច្បាប់នីមួយៗមានតម្លៃស្មើគ្នា។កិច្ចសន្យានេះត្រូវបានរក្សាទុកនៅ៖

| | |
|---|---|
| ១. ភាគីអ្នកផលិត | ០១(មួយ) ច្បាប់ |
| ២. ភាគីអ្នកទិញ | ០១(មួយ) ច្បាប់ |
| ៣. សាលាឃុំ | ០១(មួយ) ច្បាប់ |
| ៤. មន្ទីរកសិកម្មខេត្តព្រះវិហារ | ០១(មួយ) ច្បាប់ |
| ៥. នាយកដ្ឋានកសិឧស្សាហកម្ម | ០១(មួយ) ច្បាប់ |

- កិច្ចសន្យានេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាដោយភាគីទាំងពីរ និងភាគីដែលពាក់ព័ន្ធ។

| ភាគីអ្នកផលិត | ភាគីអ្នកទិញ |
|---|---|
| **លោក ប៉ាវ សាវ៉ាត** | **លោកឧកញ៉ា សុខ សារ៉េន** |
| ប្រធានគ្រួតពិនិត្យសហគមន៍កសិកម្ម សាមគ្គីរបស់មានជ័យ | នាយកក្រុមហ៊ុនអេមរុរាយស៍ |
| សាក្សី | សាក្សី |
| ........................................................ | ........................................................ |

**បានឃើញ**

.............................................................................

## ឧបសម្ព័ន្ធទី១

## បញ្ជីឈ្មោះផលិតករ

មានលេខកូដ, សមាជិកសហគមន៍កសិកម្ម, ផ្ទៃដី, បរិមាណរំពឹងទុក, ស្នាមមេដៃ ឬ ហត្ថលេខា (មិនបានភ្ជាប់ជូនទេ)។

## ឧបសម្ព័ន្ធទី២

## បញ្ជីឈ្មោះស្រូវសរដែលក្រុមហ៊ុនឯកភាពទិញ

ប្រភេទពូជស្រូវសរដែលមានគ្រាប់ធំហើយវែង ដែលក្រុមហ៊ុនឯកភាពទិញមានដូចខាងក្រោម៖

| ល.រ | ឈ្មោះពូជស្រូវសរ | ផ្សេងៗ |
|---|---|---|
| ១ | ពូជនាងអំ | |
| ២ | ពូជនាង អ៊ុក | |
| ៣ | ពូជបង្គួយ | |
| ៤ | ពូជត្នោត | |
| ៥ | ពូជចិនសីយ | |
| ៦ | ពូជ នាងខុន | |
| ៧ | ពូជ ទូល្សីស | |
| ៨ | ពូជ ក្រចេះ | |
| ៩ | ពូជ ច្រេស | |
| ១០ | ពូជឬស្សី | |
| ១១ | ពូជផ្ការំដួល | |
| ១២ | ពូជផ្ការំដេង | |
| ១៣ | ពូជផ្កាម្លិះ | |

## ឧបសម្ព័ន្ធ ៦ ៖ សារាចរណែនាំស្តីពីនីតិវិធីនៃការអនុវត្តផលិតផលកម្មកសិកម្មតាមកិច្ចសន្យា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៩៦ សរណន. កសក

### សារាចរណែនាំ
### ស្តីពី
### នីតិវិធីនៃការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា

កន្លងមក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសង្កេតឃើញថា ការអនុវត្តអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី "ផលិតកម្មកសិកម្មតាមកិច្ចសន្យា" បានជួបប្រទះបញ្ហាមួយចំនួនដូចជា ការមិនជឿទុកចិត្ត ការធានានូវតម្លៃ បរិមាណនិងគុណភាព ការបំពេញបែបបទឲ្យបានត្រឹមត្រូវតាមនីតិវិធី ភាពអសកម្មនៃការចូលរួមពីស្ថាប័នពាក់ព័ន្ធ កង្វះព័ត៌មានស្តីពីការស្នើសុំអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា និងកង្វះព័ត៌មានទំនាក់ទំនងរវាងភាគីអ្នកទិញ និងភាគីអ្នកផលិត។ល។

ដើម្បីអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដូចតទៅ៖

១- ភាគីអ្នកទិញឬភាគីអ្នកផលិត ដែលមានបំណងស្វែងរកដៃគូ មានដៃគូ ឬបានចុះកិច្ចសន្យារួចហើយ ត្រូវមកផ្តល់ និងទទួលព័ត៌មាន ដើម្បីបំពេញបែបបទស្តីពីនីតិវិធីក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅនាយកដ្ឋានកសិ-ឧស្សាហកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្តសាមី។

២- ត្រូវធ្វើការស្នើសុំការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅការិយាល័យកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តសាមី ចំពោះភាគីដែលមានដៃគូឬបានចុះកិច្ចសន្យាលើកម្មវត្ថុនៃទឹកប្រាក់ចំនួនក្រោម ២០០,០០០,០០០៖០០(ពីររយលានរៀលគត់)។

៣- ត្រូវធ្វើការស្នើសុំការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅនាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះភាគីដែលមានដៃគូឬបានចុះកិច្ចសន្យាលើកម្មវត្ថុនៃទឹកប្រាក់ចាប់ពី ២០០,០០០,០០០៖០០(ពីររយលានរៀលគត់) ឡើងទៅ។

៤- នាយកដ្ឋានកសិ-ឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដឹកនាំក្រុមការងារចុះពិនិត្យការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារបស់ភាគីទាំងពីរ ដោយសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធតាមការចាំបាច់។

៥- នាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយអង្គភាពជំនាញនិងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តតួនាទីដូចខាងក្រោម៖

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

– តភ្ជាប់ទំនាក់ទំនងរវាងអ្នកវិនិយោគទុន និងកសិករ ផលិតករ អ្នកកែច្នៃ ក្នុងក្របខណ្ឌនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា

– ពង្រឹង ជំរុញ និងលើកទឹកចិត្តដល់ការបង្កើតសមាគម សហគមន៍កសិកម្ម ឬអង្គការកសិករនានាដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា

– លើកកម្ពស់ស្តង់ដារ ចំណាត់ថ្នាក់ និងគុណភាពផលិតផលកសិកម្ម ឲ្យស្របតាមតម្រូវការទីផ្សារ និងនិយាមអន្តរជាតិ

– ចូលរួមសម្រុះសម្រួលក្នុងការដោះស្រាយទំនាស់ និងបញ្ហាផ្សេងៗក្នុងការអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្ម ដោយឈរលើមូលដ្ឋានច្បាប់ជាធរមាន

– បង្កភាពងាយស្រួលដល់ការធ្វើកសិធុរកិច្ច កសិ-ឧស្សាហកម្ម និងការនាំចេញ

– បង្កភាពងាយស្រួលក្នុងការទទួលបានសេវាកម្មគាំទ្របច្ចេកទេស ពូជដំណាំ ពូជវារីជាតិ ពូជរុក្ខជាតិ ពូជសត្វ មធ្យោបាយផលិតកម្មផ្សេងៗ ជីកសិកម្ម និងថ្នាំកសិកម្មប្រកបដោយគុណភាពខ្ពស់

– លើកកម្ពស់ការធ្វើប្រពលវប្បកម្ម ពិពិធកម្មកសិកម្ម និងការប្រកួតប្រជែងដើម្បីឆ្លើយតបនូវសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ។

៦- ការិយាល័យកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវធ្វើការតាមដាន វាយតម្លៃការអនុវត្តកិច្ចសន្យា និងធ្វើរបាយការណ៍មកនាយកដ្ឋានកសិ-ឧស្សាហកម្ម ក្នុងរយៈពេលបីខែម្តង ដើម្បីធ្វើការបូកសរុបរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧- អនុញ្ញាតឲ្យនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តប្រើប្រាស់គំរូពាក្យស្នើសុំអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា គំរូកិច្ចសន្យាផលិតកម្មកសិកម្ម និងលិខិតអនុញ្ញាតឲ្យអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យាដូចមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តន៍ឲ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនក្រសួងវិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិនា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- នាយកដ្ឋានកសិ-ឧស្សាហកម្ម
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**«សៀវភៅណែនាំសម្រាប់ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅកម្ពុជា»** នេះត្រូវបានផលិតឡើងក្រោមជំនួយឧបត្ថម្ភហិរញ្ញវត្ថុដោយ *Agence Française de Développement* (AFD) ជាផ្នែកមួយនៃគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ/អង្ករកម្ពុជាដែលបានសម្របសម្រួលដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

AFD

ខាងក្រោមនេះជាស្ថាប័នដែលបានចូលរួមចំណែកសរសេរសៀវភៅមួយនេះ

iram
NIRAS

សមាគម
ហង់រី កាពីតង់
មិត្តភាពវប្បធម៌ប្រព័ន្ធ
គតិយុត្តស៊ីវិលឡនៅកម្ពុជា
Association Henri Capitant
Des amis du droit cambodgien

AVSF
AGRONOMES & VÉTÉRINAIRES
SANS FRONTIÈRES

CIRD
Cambodian Institute for Research and Rural Development

adg